| អនុប្រធានការិយាល័យស្រុក ខណ្ឌ | ៩៦៣ | ២៥៥ | ៩៥១ | ២៥៣ | -១២ | -២ |

## ២.២- ការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងមន្ត្រីរាជការ

គិតត្រឹមខែតុលា ឆ្នាំ២០១៩ ចំនួនមន្ត្រីរាជការនៅក្នុងតារាងប្រាក់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាមានសរុបចំនួន២១៥ ៩៨១នាក់ (ស្ត្រី ៨៧ ២៩០នាក់)។ មន្ត្រីរាជការសរុបនេះរាប់បញ្ចូលទាំងមន្ត្រីផ្សេងៗ (មន្ត្រីនយោបាយ ទីប្រឹក្សា ជំនួយការជាដើម) ដែលមិនមែនជាមន្ត្រីមុខងារសាធារណៈ ប៉ុន្តែមានឈ្មោះនៅក្នុងតារាងទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការ។

| ចំនួនមន្ត្រីរាជការស៊ីវិលក្នុងតារាងបៀវត្សតាមព័ត៌មានវិទ្យា | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | ប្រុស | | ស្រី | | សរុប | |
| | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ថ្នាក់កណ្តាល | ៣២ ៤៨៥ | ១៥,០៤ | ១២ ៩៤៨ | ៦ | ៤៥ ៤៣៣ | ២១,០៤ |
| ថ្នាក់រាជធានី ខេត្ត | ៩៦ ២០៦ | ៤៤,៥៤ | ៧៤ ៣៤២ | ៣៤,៤២ | ១៧០ ៥៤៨ | ៧៨,៩៦ |
| សរុប | ១២៨ ៦៩១ | ៥៩,៥៨ | ៨៧ ២៩០ | ៤០,៤២ | ២១៥ ៩៨១ | ១០០% |

## ៣- ការងារកែទម្រង់បៀវត្សនិងប្រាក់ឧបត្ថម្ភ

កំណែទម្រង់បៀវត្ស ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗរួមមាន (១)ការដំឡើងបៀវត្សត្រូវអនុវត្តស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច (២)ការធានាបាននូវសមធម៌ ការបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង(៣)ការធានាសង្គតិភាពរវាងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនិងក្របខ័ណ្ឌកងកម្លាំងប្រដាប់អាវុធ។

ឯកតាជារៀល

| បរិយាយ | ២០១៨ | ២០១៩ | កើន |
|---|---|---|---|
| បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ | | | |
| វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស | ១ ០១៤ ៤៥០ | ១ ១០០ ១០០ | ៨៥ ៦៥០ |
| វិស័យអប់រំ | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ៨៥ ៦៥០ |
| វិស័យសុខាភិបាល | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ៨៥ ៦៥០ |
| នគរបាលជាតិ | ១ ០៩៨ ៩២៧ | ១ ១៨៤ ៥៧៧ | ៨៥ ៦៥០ |
| យោធិន | ១ ០៣៥ ០២៧ | ១ ១១៤ ៣៧៧ | ៧៩ ៣៥០ |

| | | | |
|---|---|---|---|
| ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ | | | |
| មន្ត្រីជាប់កិច្ចសន្យា | ៦០០ ០០០ | ៦៥០ ០០០ | ៥០ ០០០ |
| ជំនួយការរដ្ឋបាល | ៦០០ ០០០ | ៦៥០ ០០០ | ៥០ ០០០ |
| ជំនួយការបច្ចេកទេស | ៦០០ ០០០ | ៦៥០ ០០០ | ៥០ ០០០ |
| ជំនួយការថ្នាក់ដឹកនាំ | ៦០០ ០០០ | ៦៥០ ០០០ | ៥០ ០០០ |
| អ្នកបច្ចេកទេសជំនាញ | ៦០០ ០០០ | ៦៥០ ០០០ | ៥០ ០០០ |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ៣៦០ ០០០ | ១ ៤៤០ ០០០ | ៨០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ១ ០៨៥ ០០០ | ១ ១៣៥ ០០០ | ៥០ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ១ ០៧៥ ០០០ | ១ ១៥៥ ០០០ | ៨០ ០០០ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៨៦០ ០០០ | ៩១០ ០០០ | ៥០ ០០០ |
| ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ | ១ ០៣០ ០០០ | ១ ១១០ ០០០ | ៨០ ០០០ |
| ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១ និងទី២ | ៨០០ ០០០ | ៨៥០ ០០០ | ៥០ ០០០ |
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៧០០ ០០០ | ៧៤០ ០០០ | ៤០ ០០០ |
| មេភូមិ | ២៥០ ០០០ | ៤០០ ០០០ | ១៥០ ០០០ |
| អនុប្រធានភូមិ | ២០០ ០០០ | ២៨០ ០០០ | ៨០ ០០០ |
| សមាជិកភូមិ | ១៨០ ០០០ | ២៥០ ០០០ | ៧០ ០០០ |
| ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងសុខាភិបាល | | | |
| តំបន់ការជួបការលំបាក | ៨០ ០០០ | ៨០ ០០០ | 0 |
| តំបន់ដាច់ស្រយាលទី១ | ១០០ ០០០ | ១០០ ០០០ | 0 |
| តំបន់ដាច់ស្រយាលទី២ | ១២០ ០០០ | ១២០ ០០០ | 0 |
| **របបសន្តិសុខសង្គមអប្បបរមាប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន** | | | |
| អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន | ៤៨០ ០០០ | ៥៦០ ០០០ | ៨០ ០០០ |
| **ការដំឡើងសន្ទស្សន៍បៀវត្សមូលដ្ឋាន** | | | |
| សន្ទស្សន៍ | ២ ១៣០ | ២ ៣៤០ | ២១០ |

## ៤- ការគ្រប់គ្រងមុខងារសាធារណៈ

### ៤.១- ការរៀបចំនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត

ក្រសួងមុខងារសាធារណៈបានរៀបចំ ដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ រួមមាន (១)ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (២)អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ (៣)សេចក្តីណែនាំស្តីពីគោលការណ៍និងនីតិវិធីនៃការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួង ដែលបានបំពេញការងារនៅថ្នាក់ក្រោមជាតិ និង(៤)សេចក្តីណែនាំស្តីពីគោលការណ៍និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ក្រសួងមុខងារសាធារណៈបានបង្កិតសេវាគ្រប់គ្រងមន្ត្រីរាជការស៊ីវិល តាមរយៈការផ្ទេរអំណាចដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពលើការងារវិវឌ្ឍន៍អាជីពរបស់បុគ្គលិកដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ក្រសួងមុខងារសាធារណៈក៏បានកសាងនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដើម្បីបម្រើដល់ការងារគ្រប់គ្រងមន្ត្រីរាជការ ការអភិវឌ្ឍវិស័យមុខងារសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ការកែលម្អនិងពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ ក្នុងនោះរួមមាន អនុក្រឹត្យចំនួន១៤ សេចក្តីសម្រេច១ ប្រកាសអន្តរក្រសួង២ និងសារាចរចំនួន១ នៅក្នុងឆ្នាំ២០១៨ និងព្រះរាជក្រឹត្យចំនួន១ អនុក្រឹត្យចំនួន១៣ សារាចរចំនួន១ នៅក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០១៩។

ទន្ទឹមនេះ ក្រសួងបានដោះស្រាយករណីសំណើស្នើសុំធ្វើវិចារណកម្មមុខងារ ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័ន ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួង ស្ថាប័ន បានចំនួន៣៧ករណី នៅក្នុងឆ្នាំ២០១៨ និងចំនួន៣៣ករណី នៅក្នុងឆ្នាំ២០១៩។

## ៤.២- ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ

បានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ ក្នុងគោលបំណងលុបបំបាត់វិសមភាពយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ជាពិសេសគឺបង្កើនចំនួនមន្ត្រីរាជការជាស្ត្រីចំនួន៤០% ក្នុងចំណោមមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស និងបង្កើនឱកាសឱ្យកាន់តំណែងក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តចំនួន២៥% នៃមន្ត្រីរាជការស៊ីវិលដែលមានមុខតំណែង។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៩នេះ ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីនៅទូទាំងប្រទេសបានកើនឡើងពី០,១៤% និងចំនួនស្ត្រីដែលមានតួនាទីជាអ្នកសម្រេចចិត្តបានកើនឡើងចំនួន០,៨៨%។

| បរិយាយ | ២០១៨ | | ២០១៩ | |
|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី |
| **ភាគរយនៃចំនួនមន្ត្រីរាជការសរុប** | | | | |
| អត្រាភាគរយ | ៥៨,៨៨% | ៤១,១២% | ៥៨,៧៤% | ៤១,២៦% |
| **ភាគរយនៃចំនួនមន្ត្រីរាជការដែលកាន់មុខតំណែង** | | | | |
| អត្រាភាគរយ | ៧៤,៨៦% | ២៥,១៤% | ៧៣,៩៨% | ២៦,០២% |

## ៤.៣- ការកែលម្អគុណភាពសេវាសាធារណៈ

ការកែលម្អគុណភាពសេវាសាធារណៈ តាមរយៈការកាត់បន្ថយនីតិវិធីនិងរយៈពេលនៃការផ្តល់សេវា យ៉ាងតិច៣០% និងការផ្តល់សេវាក្នុងទម្រង់ឌីជីថល។ ក្នុងន័យនេះ ក្រសួងមុខងារសាធារណៈ បានធ្វើបច្ចុប្បន្នភាពព័ត៌មានសេវាសាធារណៈ របស់ក្រសួងព័ត៌មាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងទេសចរណ៍ អគ្គិសនីកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីដាក់បញ្ចូលទៅក្នុងគេហទំព័រច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ នៅក្នុងការវិវត្តដ៏ឆាប់រហ័សនៃបរិការណ៍ជាតិនិងអន្តរជាតិ ក្រសួងមុខងារសាធារណៈបាននិងកំពុងអនុវត្តគម្រោងកម្រិតអាស៊ាន ស្តីពីការរៀបចំឯកសារណែនាំអាស៊ានស្តីពីការផ្តល់សេវាសាធារណៈ (ASEAN Guideline on Public Service Delivery) ហើយបានជ្រើសរើសទីប្រឹក្សាតំបន់របស់គម្រោង និងបានរៀបចំជួបសម្ភាសនិងប្រមូលទិន្នន័យស្តីពីការអនុវត្តការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ដោយឡែក នៅក្នុងឆ្នាំ២០១៩នេះ រាជរដ្ឋាភិបាលបានផ្តល់រង្វាន់លើកទឹកចិត្តចំពោះអង្គភាពផ្តល់សេវាសាធារណៈគំរូទទួលបានថវិកាទៅតាមលំដាប់ថ្នាក់ គឺ (ទី១)ចំនួនពីររយលានរៀល (ទី២)ចំនួនមួយរយហាសិបលានរៀល (ទី៣)ចំនួនមួយរយលានរៀល (ទី៤)ចំនួនប៉ែតសិបលានរៀល (ទី៥)ចំនួនហុកសិបលានរៀល និង(ទី៦ដល់ទី១០)ចំនួនសែសិបលានរៀល។ បន្ទាប់ពីបានធ្វើការត្រួតពិនិត្យ វាយតម្លៃ និងចុះពិនិត្យទីតាំងរបស់អង្គភាពដែលជាបេក្ខភាពជ័យលាភីរួចមក គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិបានវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈក្នុងការជ្រើសរើសជ័យលាភី អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងសុខាភិបាល រួមមាន៖

- វិស័យអប់រំៈ (១)វិទ្យាល័យពេជ្រចិន្តា (២)វិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ (៣)វិទ្យាល័យហ៊ុនសែនប្រសូតិ (៤)វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក (៥)វិទ្យាល័យសម្តេចជាស៊ីមអង្គរជ័យ (៦)វិទ្យាល័យកោះស្តេច (៧)វិទ្យាល័យហ៊ុនសែនប្រាសាទបាគង (៨)វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសអនុវត្តកំពង់ឈើទាល (៩)វិទ្យាល័យប៊ុនរ៉ានីវត្តភ្នំ និង(១០)វិទ្យាល័យអង្គរកា។

- វិស័យសុខាភិបាលកម្រិត១(CPA1) : (១)មន្ទីរពេទ្យបង្អែកបាកាន (២)មន្ទីរពេទ្យបង្អែកព្រះស្តេច (៣)មន្ទីរពេទ្យបង្អែកព្រៃឈរ (៤)មន្ទីរពេទ្យបង្អែកពួក (៥)មន្ទីរពេទ្យបង្អែកខេត្តកែប (៦)មន្ទីរពេទ្យបង្អែកស្រែអំបិល (៧)មន្ទីរពេទ្យបង្អែកបាភ្នំ (៨)មន្ទីរពេទ្យបង្អែកល្វាឯម (៩)មន្ទីរពេទ្យបង្អែកប៊ុនរ៉ានី ហ៊ុនសែនកោះស្លា និង (១០)មន្ទីរពេទ្យបង្អែកជីភូ។ វិស័យសុខាភិបាលកម្រិត២(CPA2) : (១)មន្ទីរពេទ្យបង្អែកខេត្តកោះកុង (២)មន្ទីរពេទ្យបង្អែកបាធាយ (៣)មន្ទីរពេទ្យបង្អែកពារាំង (៤)មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ (៥)មន្ទីរពេទ្យបង្អែកគិរីវង់ (៦)មន្ទីរពេទ្យបង្អែកកំពង់ត្របែក (៧)មន្ទីរពេទ្យបង្អែកអង្គរជ័យ (៨)មន្ទីរពេទ្យបង្អែកចំការលើ (៩)មន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុត្បូងឃ្មុំ និង(១០)មន្ទីរពេទ្យបង្អែកពញាឮ។

- វិស័យសុខាភិបាលកម្រិត៣(CPA3) : (១)មន្ទីរពេទ្យខេត្តកំពង់ចាម (២)មន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា ជប៉ុនមង្គលបូរី (៣)មន្ទីរពេទ្យបង្អែកខេត្ត១៦មករា (៤)មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង (៥)មន្ទីរពេទ្យបង្អែកខេត្តកំពត (៦)មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង (៧)មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ (៨)មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង (៩)មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និង(១០)មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

## ទី២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

### ១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយ ក្រោមការដឹកនាំពីសំណាក់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ទាំងតាមរូបភាពពិគ្រោះយោបល់ ផ្តល់អនុសាសន៍ និងឃ្លាំមើលដំណើរការការងារ បានបន្តដឹកនាំការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ប្រកបដោយការច្នៃប្រឌិត ឈ្លាសវៃ និងស្របតាមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិត គោលនយោបាយចង្អុលបង្ហាញទិសច្បាស់ៗរបស់រាជរដ្ឋាភិបាល ដែលមានទាំងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨-២០២៣) និងក្នុងសារនយោបាយដែលបានប្រកាស និងដាក់ចេញជាបន្តបន្ទាប់ ដោយផ្តល់ពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី។

ឆន្ទៈនយោបាយដែលកាន់តែមុតស្រួច អមដោយអភិក្រមទាំង៥នៃការដឹកនាំ (ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់) ការផ្តល់អាទិភាពលើការពង្រឹងភាពស្អាតស្អំ ក្នុងរដ្ឋបាលសាធារណៈ ការបន្តកែទម្រង់មិនចេះនឿយហត់ទាំងក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាកម្លាំងរុញសន្ទុះប្រយុទ្ធប្រឆាំងអំពើពុករលួយ ឱ្យកាន់តែរលូននិងកាន់តែមានប្រសិទ្ធភាព សំដៅនាំមកបន្ថែមទៀតនូវសមិទ្ធផលថ្មីៗគួរជាទីមោទនៈ ជូនរាជរដ្ឋាភិបាលនិងសង្គមជាតិទាំងមូល។

ជាមួយគ្នានេះ ក្នុងក្របខ័ណ្ឌនៃការបំពេញការងារអាទិភាពស្នូលរបស់ខ្លួនរួមមាន (១)អប់រំ (២)បង្ការទប់ស្កាត់ និង(៣) អនុវត្តច្បាប់បង្ក្រាប អង្គភាពប្រឆាំងអំពើពុករលួយបានបន្តនាំមកនូវសមិទ្ធផលសំខាន់ៗដូចជា៖

**១- ការអប់រំ**

ជាមួយនឹងជំនឿជឿជាក់ថា ការសម្រេចបាននូវការប្រែប្រួលប្រកបដោយចីរភាពនូវឥរិយាបថ ការគិត ការប្រព្រឹត្ត និងការចូលរួមរបស់មហាជន ចំពោះការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺត្រូវចេញពីគ្រួសារ ក្រុម ទើបឈានទៅសង្គមទាំងមូលបាន អង្គភាពប្រឆាំងអំពើពុករលួយ បានបន្តជំរុញបេសកកម្មអប់រំ បំផុស និងផ្សព្វផ្សាយរបស់ខ្លួនជាប្រចាំអំពីច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រឆាំងផលវិបាកនៃអំពើពុករលួយចំពោះការអភិវឌ្ឍ និងចំពោះសង្គម ក៏ដូចជាសារៈសំខាន់នៃការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យឈានទៅកាត់បន្ថយនិងលុបបំបាត់បាននូវអំពើពុករលួយ។ ការអប់រំ ត្រូវបានធ្វើឡើងទាំងក្នុងសាលានិងក្រៅសាលា តាមរយៈការដាក់ចេញនូវមេរៀនអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ទៅគ្រប់កម្រិតសិក្សានៃថ្នាក់ចំណេះដឹងទូទៅ ជូនសម្រាប់ទំពាំងស្នងឫស្សីដែលជាធនធានជំនាន់ក្រោយ ការចុះផ្សព្វផ្សាយដល់មូលដ្ឋាន ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ មន្ទីរ និងអង្គភាពជំនាញចំណុះសាលារាជធានីខេត្ត គ្រឹះស្ថានឧត្តមសិក្សា និងសាលាវិជ្ជាជីវៈ និងទីកន្លែងងាយរងគ្រោះដោយអំពើពុករលួយនិងវិស័យឯកជន។ ការប្រារព្ធទិវាជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ និងការផលិត និងដាក់ចេញនូវឧបករណ៍អប់រំផ្សព្វផ្សាយ ក៏ត្រូវបានធ្វើឡើងជាប្រចាំផងដែរ។ អ.ប.ព.ជឿថា នៅពេលការអប់រំកាន់តែជ្រួតជ្រាប និងកាន់តែទូលំទូលាយ នោះការងារប្រឆាំង អំពើពុករលួយនឹងទទួលបានផលកាន់តែមានប្រសិទ្ធភាពនិងយូរអង្វែង។

**២- ការបង្ការទប់ស្កាត់**

ការបង្ការ ទប់ស្កាត់ ក៏ត្រូវបានអនុវត្តស្របគ្នានឹងការអប់រំ សំដៅលុបបំបាត់ឱកាសចន្លោះប្រហោងនៃការប្រព្រឹត្តអំពើពុករលួយ។ ការងារសង្កេតការណ៍លទ្ធកម្មសាធារណៈនៅតាមក្រសួង ស្ថាប័នរដ្ឋ ត្រូវបានធ្វើជាប្រចាំសំដៅចូលរួមកាត់បន្ថយចំណាយ និងធ្វើឱ្យចំណាយរដ្ឋកាន់តែមានប្រសិទ្ធភាព។ ការសង្កេតការណ៍ក៏ត្រូវបានអនុវត្តលើការប្រឡងជ្រើសរើសមន្ត្រីចូលបម្រើរដ្ឋជាបន្តបន្ទាប់ សំដៅធានានូវយុត្តិធម៌និងភាពស្មើភាពក្នុងការប្រកួតប្រជែង ក៏ដូចជាប្រសិទ្ធភាពក្នុងការជ្រើសរើសមន្ត្រីរាជការ។ ការចូលរួមបង្កើនចំណូលរដ្ឋក៏ត្រូវបានអនុវត្តបន្តតាមរយៈយន្តការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ រួមមាន៖ ការដាក់ចេញនិងកែសម្រួលប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ និងការចុះពិនិត្យការផ្តល់សេវាសាធារណៈជាក់ស្តែង នៅតាមក្រសួង ស្ថាប័ន និងការទទួលជាតុចូលពីវិស័យឯកជន សំដៅដាក់ចេញចំណាត់ការឆ្លើយតបដោះស្រាយបាតុភាពនិងបញ្ហាប្រឈមដែលមាន។

ក្រៅពីការចូលរួមពង្រឹងសុចរិតភាព អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ធុរកិច្ចស្អាតស្អំពីសំណាក់វិស័យឯកជនក៏ត្រូវបានជំរុញ និងគាំទ្រជាប្រចាំ។ ការចុះអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហការប្រឆាំងអំពើពុករលួយរវាងអ.ប.ព. និងវិស័យឯកជន ត្រូវបានធ្វើជាបន្តបន្ទាប់គ្របដណ្តប់ដល់រាប់រយក្រុមហ៊ុន ហើយការរៀបចំវេទិកាពិគ្រោះយោបល់ និងការដោះស្រាយបញ្ហាប្រឈមនានាដែលវិស័យឯកជនជួបប្រទះក្នុងធុរកិច្ចរបស់ខ្លួន ក៏ត្រូវបានធ្វើឡើងនិងដោះស្រាយបញ្ហាបានជាបន្តបន្ទាប់។

ការបង្ការ ទប់ស្កាត់ក្នុងទម្រង់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិនិងបំណុល ដែលត្រូវបានកំណត់ដោយច្បាប់ប្រឆាំងអំពើពុករលួយ ក៏បានចូលរួមចំណែកដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់បង្ក្រាបលើបទល្មើសជាច្រើនផងដែរ។ អ.ប.ព. ជឿជាក់ថាខណៈចំណាត់ការបង្ការទប់ ស្កាត់កន្លងមកបានចូលរួមកាត់បន្ថយ ឬបិទឱកាសនិងលទ្ធភាពប្រព្រឹត្តអំពើពុករលួយ ក៏ដូចជាកសាងបរិយាកាសអំណោយផលដល់ការពង្រឹងសុចរិតភាពនៅតាមស្ថាប័ន។ អ.ប.ព. ត្រូវប្រឹងប្រែងបន្តអនុវត្តនិងកែលម្អចំណាត់ការដែលបានធ្វើ ក៏ដូចជាដាក់ចេញបន្ថែមទៀតនូវចំណាត់ការបង្ការទប់ស្កាត់ សំដៅពង្រឹងសមិទ្ធផលថ្មីៗទៀត។

**៣- ការអនុវត្តច្បាប់បង្ក្រាប**

ការងារអនុវត្តច្បាប់បង្ក្រាបក៏បានដើរទន្ទឹមគ្នាជាមួយនឹងការអប់រំ បង្ការ និងទប់ស្កាត់។ យន្តការទទួលនិងដោះស្រាយពាក្យប្តឹងត្រូវបានទទួលការវាយតម្លៃជាវិជ្ជមានជាទូទៅពីសំណាក់អ្នកប្តឹង។ រាល់ការមកប្តឹងផ្ទាល់ ប្តឹងតាមប្រអប់សំបុត្រស តាមប្រៃសណីយ៍ ទូរសព្ទ អ៊ីម៉ែល និងតាមបណ្តាញទំនាក់ទំនងសង្គម(Facebook) ត្រូវបានយកមកពិនិត្យនិងដោះស្រាយក្នុងកិច្ចប្រជុំអាហារពេលព្រឹក (ចាប់ផ្តើមម៉ោង៧: ៣០នាទី) នៅរៀងរាល់ព្រឹកនៃថ្ងៃធ្វើការ ដើម្បីពិនិត្យពាក្យប្តឹងដែលបានដាក់មកនៅមួយថ្ងៃមុនត្រូវបានបន្តរៀបចំឡើង ដោយមានការបើកទ្វារជូនដល់ម្ចាស់បណ្តឹង ដើម្បីស្តាប់ការជជែកវែកញែក ក៏ដូចជាការផ្តល់នូវធាតុចូលបន្ថែមពីករណីដែលត្រូវបានប្តឹង។

ឱកាសក្នុងការចូលរួមនិងការមើលឃើញផ្ទាល់នូវសក្ខីភាពនៃកិច្ចប្រឹងប្រែងប្រកបដោយសមត្ថភាព ដោយស្មារតីទទួលខុសត្រូវ វិជ្ជាជីវៈច្បាស់លាស់របស់អ.ប.ព. ក្នុងការដោះស្រាយបណ្តឹង តែងតែទទួលបាននូវការសាទរពីសំណាក់អ្នកប្តឹង។ យន្តការដោះស្រាយបណ្តឹងនិងស៊ើបអង្កេត ក៏ត្រូវបានប្រើប្រាស់សម្រាប់ព័ត៌មានដែល ទទួលបានទាំងប្រភពចំហ និងចារកម្ម ក្រោមគោលការណ៍តឹងរ៉ឹង និងមិនអាចដោះដូរបាននូវការរក្សាការសម្ងាត់នៃប្រភពក៏ដូចជាសាក្សីទាំងនៅក្នុងអ.ប.ព. និងនៅក្រៅ ជាពិសេសនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅតុលាការ។

ក្នុងចំណោមពាក្យប្តឹងដែលអ.ប.ព. ទទួលបានជារៀងរាល់ឆ្នាំ មន្ត្រីរាជការដែលតែងតាំងដោយប្រកាសទទួលរងនូវបណ្តឹងច្រើនជាងគេ បើប្រៀបធៀបទៅនឹងមន្ត្រីរាជការដែលតែងតាំងដោយព្រះរាជក្រឹត្យនិងអនុក្រឹត្យ។

បទពិសោធបានចង្អុលបង្ហាញពីកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ តាមក្រសួងស្ថាប័នប្រកបដោយភាពវិជ្ជមានក្នុងការដោះស្រាយពាក្យប្តឹងដែលមិនទាន់មាន ឬមិនអាចមាន ឬក៏មានភស្តុតាងតែភស្តុតាងត្រូវបានរលត់ និងមិនអាចយកមកប្រើប្រាស់ដើម្បីបញ្ជូនសំណុំរឿងទៅតុលាការបានថា ប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតាមបែបរដ្ឋបាលនិងវិន័យ ក៏អាចនាំមកនូវឥទ្ធិពលដុំព្រិល(Snowball Effect) ពោលគឺនាំមកនូវលទ្ធផលដែលចង់បាន នោះគឺកំហុសដដែលៗមិនអាចកើតឡើងជាថ្មី ហើយការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលស្អាតស្អំនៅតាមស្ថាប័នសាធារណៈ ក៏មានសន្ទុះវិជ្ជមានគួរឱ្យកត់សម្គាល់។

**៤-ការបំពេញកាតព្វកិច្ចជាតិនិងអន្តរជាតិ**

អ.ប.ព. បានបំពេញភារកិច្ចក្នុងនាមជាស្ថាប័នតំណាងឱ្យរដ្ឋភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(UNCAC) ដោយអ.ប.ព. គឺជាស្ថាប័នបង្គោលក្នុងការសម្របសម្រួលលើដំណើរការទទួលការត្រួតពិនិត្យការអនុវត្តUNCAC ជុំទី២នៅកម្ពុជា ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមានស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងផ្នែកសិក្សាធិការ។

អ.ប.ព. ក៏បានចូលរួមយ៉ាងសស្រាក់សស្រាំ យន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម កំណត់ដោយអង្គការFATF។ ការងារគាំទ្រ និងការបំពេញភារកិច្ចពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយ សំដៅរុញច្រានកម្ពុជាចេញពីបញ្ជីប្រផេះ កំណត់ដោយអង្គការ FATF គឺជាអាទិភាពមួយចាំបាច់នាពេលខាងមុខ។

អ.ប.ព. ស្វាគមន៍ចំពោះកាតព្វកិច្ចអន្តរជាតិទាំងអស់ដែលកម្ពុជាមានពាក់ព័ន្ធនឹងការងារប្រឆាំងអំពើពុករលួយ និងការសម្អាតប្រាក់ ហើយជឿថា កាតព្វកិច្ចទាំងនេះបាននាំមកដល់កម្ពុជានូវឱកាសនៃការអភិវឌ្ឍន៍ផ្ទៃក្នុង ទាំងក្នុងក្របខ័ណ្ឌច្បាប់និងការអនុវត្តតួនាទីរបស់តួអង្គពាក់ព័ន្ធទាំងអស់។

## ២- ការអប់រំ ផ្សព្វផ្សាយ និងអធិការកិច្ច

### ២.១- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ដើម្បីដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ទប់ស្កាត់ ការរំលោភដោយអំណាច និងបាតុភាព អសកម្មនានា និងជំរុញប្រសិទ្ធភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូល ដែលរួមមាន ការផ្សព្វផ្សាយច្បាប់ ការចុះធ្វើអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការទទួលនិងដោះស្រាយពាក្យបណ្តឹង។ តាមរយៈការងារអធិការកិច្ច ក្រសួងបានបានរកឃើញកំហុសឆ្គងមួយចំនួននៅតាមក្រសួង ស្ថាប័ន និងបានស្នើឱ្យកែលម្អជាហូរហែ។

**សមិទ្ធផលសំខាន់ៗរបស់ក្រសួង មានដូចខាងក្រោម៖**

- បានចុះផ្សព្វផ្សាយច្បាប់ចំនួន១៤២លើកគឺៈ (១)ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៧០លើក ក្នុងនោះ ក្នុងខេត្តកំពង់ធំ១៣លើក ព្រះសីហនុ១០លើក ស្ទឹងត្រែង៩លើក កណ្តាល៨លើក ស្វាយរៀង៨លើក កំពង់ស្ពឺ៧លើក ព្រៃវែង៤លើក កំពង់ចាម៤លើក បាត់ដំបង៣លើក បន្ទាយមានជ័យ២លើក កំពត១លើក និងកែប១លើក (២)ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៦១លើក ក្នុងនោះ ខេត្តក្រចេះ២២លើក តាកែវ៩លើក កណ្តាល៥លើក ព្រះសីហនុ៥លើក ឧត្តរមានជ័យ៤លើក កំពង់ចាម៣លើក ស្វាយរៀង៣លើក ត្បូងឃ្មុំ២លើក កំពត២លើក កែប២លើក កំពង់ធំ២លើក ព្រៃវែង១លើក និងសៀមរាប១លើក (៣)ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៦លើកក្នុងខេត្តព្រៃវែង (៤)ច្បាប់ស្តីពីជលផលចំនួន៣លើក ក្នុងខេត្តក្រចេះ (៥)ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន១លើកក្នុងខេត្តកំពត និង (៦)ច្បាប់ភូមិបាលចំនួន១លើក ក្នុងខេត្តសៀមរាប ដោយមានអ្នកចូលរួមចំនួន ៤៧ ៧២៤នាក់ (ស្ត្រីចំនួន១៩ ១៥៧នាក់)។
- បានចុះធ្វើអធិការកិច្ចការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធតាមក្រសួង ស្ថាប័នចំនួន១៧ រាជធានីខេត្តទាំង២៥ និងមន្ទីរ-អង្គភាពចំនួន៧៧០ ដែលក្នុងនោះ រួមមានៈ (១)លើវិស័យសេដ្ឋកិច្ច នៅក្រសួងចំនួន៩ អង្គភាពថ្នាក់ជាតិចំនួន២ និងមន្ទីរ អង្គភាពក្នុង ២៥រាជធានី ខេត្ត ស្មើនឹង៣០៣មន្ទីរ អង្គភាព (២)លើវិស័យរដ្ឋបាលទូទៅ នៅក្រសួងចំនួន១ និងមន្ទីរ អង្គភាពក្នុង២៣រាជធានី ខេត្ត ស្មើនឹង២៣៧មន្ទីរ អង្គភាព និង(៣)លើវិស័យសង្គមកិច្ច នៅក្រសួងចំនួន៧ និងមន្ទីរ អង្គភាពក្នុង២៥រាជធានី ខេត្ត ស្មើនឹង២៣០មន្ទីរ អង្គភាព។
- បានចុះតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាចំនួន៣៨លើក រួមមានៈ (១)នៅបណ្តាក្រសួង-ស្ថាប័នចំនួន៥(ក្នុងនោះ ច្បាប់ចំនួន៣ និងអនុក្រឹត្យចំនួន៧) និង(២) នៅរាជធានី ខេត្ត និងអង្គភាពផ្សេងៗបានចំនួន៣២លើក(ក្នុងនោះ ច្បាប់ចំនួន៦ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាចំនួន៤)។

### ២.២- ការងារអធិការកិច្ចក្នុងវិស័យមុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈ បានធ្វើអធិការកិច្ចលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈក្នុងន័យពង្រឹងប្រសិទ្ធភាពរៀបចំនិងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍នៅក្នុងពេលបំពេញការងាររបស់មន្ត្រីសាធារណៈ ដើម្បីពង្រឹងប្រសិទ្ធភាពនិងផលិតភាពលើការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ។

ជាលទ្ធផល មន្ត្រីអធិការកិច្ចនៃក្រសួងមុខងារសាធារណៈបាន (១)ចុះតាមដានត្រួតពិនិត្យនិងវាយតម្លៃពីការបំពេញការងាររបស់មន្ត្រីរាជការចំនួន៨នាក់ (២)ចុះធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យានៅតាមមន្ទីរនិងអង្គភាពនៅក្នុងរដ្ឋបាលខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ ស្ទឹងត្រែង កោះកុង កំពង់ស្ពឺ និងមណ្ឌលគិរី (៣)បានចុះត្រួតពិនិត្យមន្ត្រីរាជការដែលមានមុខតំណែងអចិន្ត្រៃយ៍លើសពី១ ចំនួន៥២ករណី (៤)ចុះត្រួតពិនិត្យគ្រូពុទ្ធិកជាប់កិច្ចសន្យាចំនួន១៦០អង្គ/នាក់ និងមន្ត្រីរាជការចំនួន២៩អង្គ/នាក់ មានភេទជាព្រះសង្ឃ ព្រមទាំងបានស្នើចាត់វិធានការលុបឈ្មោះចេញពីក្របខ័ណ្ឌចំនួន៣អង្គ/នាក់ និង(៥)ចាត់វិធានការចំពោះករណីបើកបៀវត្សលើសឱ្យបង្វែរថវិកាចូលរតនាគារខេត្តវិញ។ ជាក់ស្តែង ក្រសួងមុខងារសាធារណៈបានរកឃើញប្រាក់បៀវត្សបើកលើស និងចាត់វិធានការឱ្យបង្វែរថវិកាចូលរតនាគារខេត្តវិញចំនួន ៤ ៣៤៩ ០៩៧ ៦៨៩រៀល នៅក្នុងឆ្នាំ២០១៨ និងចំនួន៤ ៣៤៩ ០៩៧ ៦៨៩រៀល នៅក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៩។

## ទី៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

### ១- ការងារវិមជ្ឈការនិងវិសហមជ្ឈការ

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន១ខេត្តចំនួន២៤ ក្រុងចំនួន២៧ ស្រុកចំនួន១៦២ ខណ្ឌចំនួន១៤ ឃុំចំនួន១ ៤០៥ សង្កាត់ចំនួន២៤១ និងភូមិចំនួន១៤ ៣៩៤។ នៅក្នុងនោះ នៅដើមនីតិកាលទី៦នេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតថ្មីនូវក្រុងចំនួន១ ស្រុកចំនួន៣ និងខណ្ឌចំនួន២ រួមមាន ក្រុងកោះរ៉ុងនៃខេត្តព្រះសីហនុ ស្រុកតាំងគោកនៃខេត្តកំពង់ធំ ស្រុកតាលោសែនជ័យនៃខេត្តពោធិ៍សាត់ ស្រុកបុរីអូរស្វាយសែនជ័យនៃខេត្តស្ទឹងត្រែង ខណ្ឌបឹងកេងកងនិងខណ្ឌកំបូលនៃរាជធានីភ្នំពេញ។

ក្នុងការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលទី៣ ឬហៅកាត់ថា ផអ៣ ទី៣(២០១៨-២០២០) ដែលជាផែនការចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃបានផ្តោតទៅលើកិច្ចការគន្លឹះដូចជា ១- ការពង្រឹងយន្តការដឹកនាំ គ្រប់គ្រងការងារកំណែទម្រង់នានាក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ២- ការបន្តពង្រឹងអភិបាលកិច្ចមូលដ្ឋានក្នុងការផ្តល់សេវានិងការអភិវឌ្ឍ ៣- ការគាំទ្រនិងការសម្របសម្រួលការអនុវត្តមុខងារនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៤- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និង៥- ការតាមដានត្រួតពិនិត្យការអនុវត្តថវិកានិងមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

#### ១.១- ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

##### ក- ការពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់

ផ្អែកតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងគណៈកម្មាធិកាជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្រសួងមហាផ្ទៃបានរៀបចំយន្តការសម្របសម្រួលការដឹកនាំកំណែទម្រង់ទាំង៤នៅក្នុងក្របខ័ណ្ឌរបស់ខ្លួន ដើម្បីធានាដល់ការអនុវត្តដំណើរការកំណែទម្រង់នេះ ឱ្យមានភាពស៊ីចង្វាក់គ្នានិងមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ ក្នុងការកែទម្រង់រចនាសម្ព័ន្ធអង្គភាពនានានៃក្រសួងមហាផ្ទៃ ដើម្បីធានាដល់ការគាំទ្រនិងការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ក្រសួងមហាផ្ទៃបាននិងកំពុងសហការជាមួយលេខាធិការដ្ឋានគ.ជ.អ.ប រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីរចនាសម្ព័ន្ធនិងមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងសេចក្តីព្រាងក្របខ័ណ្ឌការងារសម្រាប់អនុវត្តអនុក្រឹត្យនេះ។

ដើម្បីធានានិរន្តរភាព ប្រសិទ្ធភាពនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមការសម្របសម្រួល និងការគាំទ្រពីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ននានា និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបង្កើតគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់របស់ខ្លួន។ បច្ចុប្បន្ន ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងនេះបាននិងកំពុងប្រើប្រាស់ថវិការបស់ខ្លួនគាំទ្រដល់កិច្ចប្រតិបត្តិការនៃដំណើការកំណែទម្រង់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ខ- ការពង្រឹងការងារគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកតាមអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានដាក់ចេញនាពេលកន្លងមក ក្រសួងមហាផ្ទៃបានរៀបចំលិខិតបទដ្ឋានជាច្រើនសម្រាប់គាំទ្រការអនុវត្តអនុក្រឹត្យទាំងនេះ ព្រមទាំងផ្តល់ការគាំទ្រដល់ការជ្រើសរើសនិងការអភិវឌ្ឍសមត្ថភាពប្រធាន អនុប្រធាន និងមន្ត្រីនៃការិយាល័យប្រជាពលរដ្ឋដែលបានបង្កើតឡើងទាំងនៅថ្នាក់រាជធានី ខេត្ត និងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីសម្របសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការបំពេញការងារនិងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក នៅក្នុងឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានផ្តល់វគ្គបណ្តុះបណ្តាលចាំបាច់នានាពាក់ព័ន្ធនឹងតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារដល់មន្ត្រីការិយាល័យប្រជាពលរដ្ឋ ព្រមទាំងបានសហការសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដាក់ឱ្យដំណើរការការិយាល័យប្រជាពលរដ្ឋចំនួន៣១ស្រុកគោលដៅ។

ជារួម នៅក្នុងរយៈពេល១ឆ្នាំកន្លងទៅនេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដែលបានដាក់ឱ្យដំណើរការ ទទួលបានពាក្យបណ្តឹងនិងព័ត៌មានផ្សេងៗសរុបចំនួន៦ ៩២៥ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន៨៨ករណី (ដោះស្រាយរួចរាល់) បណ្តឹងក្រៅសមត្ថកិច្ចចំនួន ២៣៧ករណី សំណូមពរចំនួន ៣១៧ករណី ការសរសើរចំនួន៣៨១ករណី និងការសាកសួរព័ត៌មានផ្សេងៗចំនួន២ ៩០២ករណី។ ទន្ទឹមគ្នានេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលបានដាក់ឱ្យដំណើការ ទទួលបានពាក្យបណ្តឹងនិងព័ត៌មានផ្សេងៗ ចំនួន៣០៦ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន៦៥ករណី (ដោះស្រាយចប់រួចរាល់ចំនួន៤៧ករណី និង ១៨ករណីទៀត កំពុងបន្តដោះស្រាយ) បណ្តឹងក្រៅសមត្ថកិច្ចចំនួន៩៥ករណី សំណូមពរចំនួន៥៤ករណី ការសរសើរចំនួន៨ករណី និងការសាកសួរព័ត៌មានផ្សេងៗចំនួន៨៤ករណី។

### គ- ការគាំទ្រនិងការសម្របសម្រួលការអនុវត្តមុខងារនានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

គិតត្រឹមដំណាច់ខែសីហា ឆ្នាំ២០១៩ មានមុខងារចំនួន១៦ក្នុងវិស័យអាទិភាពមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបផែននៃការប្រគល់និងមានមុខងារជាច្រើនទៀត ត្រូវបានផ្ទេរតាមបែបផែននៃការធ្វើប្រតិភូកម្ម ជាពិសេសតាមរយៈយន្តការច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទាំងនេះប្រកបដោយប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានផ្តល់កិច្ចសហការ គាំទ្រ សម្របសម្រួលទាំងក្នុងការរៀបចំដាក់ឱ្យអនុវត្ត ការតាមដាន ត្រួតពិនិត្យ ការបណ្តុះបណ្តាលអំពីគោលការណ៍និងនីតិវិធីនៃការអនុវត្តមុខងារដែលបានផ្ទេរ និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការផ្ទេរ ការគ្រប់គ្រង និងការចាត់ចែងធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្ស សម្រាប់អនុវត្តមុខងារទាំងនោះ។ ក្រៅពីនេះ ការរៀបចំនិងអនុវត្តមុខងារជាអាណត្តិទូទៅ ក្រសួងមហាផ្ទៃបានផ្តល់ការគាំទ្រផងដែរ ទាំងផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យការរៀបចំនិងអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំនិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមិនមែនហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានក្រោមក្របខ័ណ្ឌថវិកាឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ សម្រាប់ដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបតម្រូវការចាំបាច់និងជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ឃ- ការគាំទ្រនិងការតាមដាន ត្រួតពិនិត្យការអនុវត្តថវិកា ឬមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានគ.ជ.អ.ប. ធ្វើការគាំទ្រផ្នែកបច្ចេកទេស និងតាមដានត្រួតពិនិត្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការរៀបចំនិងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ក្នុងនោះរួមមានដូចខាងក្រោម៖

- **គម្រោងអភិវឌ្ឍន៍របស់រាជធានី ខេត្ត** : នៅក្នុងរយៈពេល១ឆ្នាំកន្លងទៅនេះ ក្រសួងមហាផ្ទៃបានធ្វើអនុលោមភាពលើគម្រោងអភិវឌ្ឍន៍សម្រាប់ជាគុណប្រយោជន៍របស់រាជធានី ខេត្តសរុបចំនួន៤៤៦គម្រោង ទឹកប្រាក់ចំនួន៧៦០ ៤០៤ ២០១ ១១២រៀល សមមូល ១៩០ ១០១ ០៥០ដុល្លារអាម៉េរិក។ គម្រោងទាំងនេះរួមមាន ការសាងសង់អគាររដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ពាន ផ្លូវថ្នល់ សួនច្បារសាធារណៈ បណ្តាញអគ្គិសនីបំភ្លឺសាធារណៈ និងសំណង់សិល្បការនានា...។

- **គម្រោងមូលនិធិក្រុង ស្រុក** : គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ គម្រោងមូលនិធិក្រុង ស្រុក ដែលបានគ្រោងឡើងក្នុងឆ្នាំ២០១៨ ចំនួន៤៨៨គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន៣៧៣គម្រោង(ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន៣៥៦គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន៨គម្រោង កំពុងត្រៀមរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន៨៣គម្រោង និងមិនទាន់សិក្សាចំនួន២៤គម្រោង។ ដោយឡែក គម្រោងមូលនិធិក្រុង ស្រុក ដែលគ្រោងឡើងក្នុងឆ្នាំ២០១៩ ចំនួន៤៥៩គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន៥៧គម្រោង(ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន២១គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន២៨គម្រោង កំពុងត្រៀមរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន១៧១គម្រោង កំពុងដំណើការសិក្សាចំនួន១៥៥គម្រោងនិងមិនទាន់សិក្សាចំនួន៤៨គម្រោង។

- **គម្រោងមូលនិធិឃុំ សង្កាត់** : គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានគ្រោងឡើងក្នុងឆ្នាំ២០១៨ ចំនួន១ ៧៥៣គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន១ ៧៣២គម្រោង (ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន១ ៥៧៨គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន៥គម្រោង កំពុងត្រៀមរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន១០គម្រោង និងកំពុងដំណើរការសិក្សា ចំនួន៦គម្រោង។ ដោយឡែក គម្រោងមូលនិធិឃុំ សង្កាត់ ដែលគ្រោងឡើងក្នុងឆ្នាំ២០១៩ ចំនួន១ ៧៩៨គម្រោង បានចុះកិច្ចសន្យាសាងសង់រួចចំនួន៨៥៩គម្រោង(ក្នុងនោះបានបញ្ចប់ការសាងសង់ជាស្ថាពរចំនួន១៥១គម្រោង) កំពុងត្រៀមចុះកិច្ចសន្យាសាងសង់ចំនួន១៩៣គម្រោង កំពុងត្រៀមរៀបចំធ្វើកិច្ចលទ្ធកម្មចំនួន៣៤៧គម្រោង កំពុងដំណើការសិក្សាចំនួន៣៤១គម្រោង និងមិនទាន់សិក្សាចំនួន៥៨គម្រោង។

### ង- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងការពង្រឹងកិច្ចដំណើការនៃការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ បានសហការជាមួយក្រសួងមុខងារសាធារណៈ រៀបចំនិងប្រកាសផ្ទេរបុគ្គលិកក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលកំពុងបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនជាង ៦ ២០០រូប ឱ្យស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៩តទៅ។ ទន្ទឹមនេះ ក្រសួងក៏បានរៀបចំលិខិតបទដ្ឋាននានាទាក់ទងនឹងកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ និងសម្របសម្រួលដល់កិច្ចដំណើរការនៃការប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សាទាំងនោះសរុបចំនួន៤ ១១៤រូប(ស្រី៧១៦រូប) ក្នុងនោះ ក្រុមប្រឹក្សារាជធានីខេត្តចំនួន៥៥៩រូប(ស្រី៩៤រូប) និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន៣ ៥៥៥រូប(ស្រី៦២២រូប)។

ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃបានដាក់ចេញនូវឯកសារគតិយុត្តសំខាន់ៗចំនួន២ គឺប្រកាសនិងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្នុងក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកតាមស្មារតីនៃឯកសារទាំងពីរនេះ ក្រសួងមហាផ្ទៃកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិលមួយដែលធានាបាននូវប្រសិទ្ធភាព គុណភាព និងភាពឆ្លើយតបកាន់តែប្រសើរក្នុងការលើកកម្ពស់សមត្ថភាពបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលទាំងនៅទីស្តីការក្រសួងមហាផ្ទៃនិងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ ក្រសួងក៏កំពុងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូនិងអ្នកពាក់ព័ន្ធនានា ជាពិសេសជាមួយធនាគារអភិវឌ្ឍអាស៊ី(ABD) ដើម្បីអាចចាប់ផ្តើមអនុវត្តបានឆាប់រហ័សនូវគម្រោងសាលាជាតិរដ្ឋបាលមូលដ្ឋាន។

រដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ សរុបចំនួន១៧៥សកម្មភាព ដែលមានសិក្ខាកាមចូលរួមចំនួនជាង៥ ០០០រូប។

### ច- ការរៀបចំនិងគាំទ្រច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងការគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយនៅស្រុកគោលដៅទាំង៣១ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៨ ក្រសួងបានផ្តល់វគ្គបណ្តុះបណ្តាលចាំបាច់មួយចំនួនដល់ថ្នាក់ដឹកនាំនិងមន្ត្រីនៃការិយាល័យទាំងនេះ ក្នុងនោះរួមមានវគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ការិយាល័យច្រកចេញចូលតែមួយ បច្ចេកទេសនៃការផ្តល់សេវាតាមវិស័យជំនាញនីមួយៗដែលបានធ្វើប្រតិភូកម្មដល់ការិយាល័យច្រកចេញចូលតែមួយ និងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ(MIS)ជាដើម។

ដើម្បីឆ្លើយតបនឹងតម្រូវការនៃការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ក្រោមការសម្របសម្រួល និងគាំទ្របច្ចេកទេសពីក្រសួងមហាផ្ទៃ នាដើមឆ្នាំ២០១៩នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំបង្កើតបន្ថែមនូវការិយាល័យច្រកចេញចូលតែមួយនៅស្រុកគោលដៅថ្មីចំនួន៣២។

ការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥ គឺបានដំណើរការចាប់ពីដើមត្រីមាសទី៤ ឆ្នាំ២០១៨ ដោយបានផ្តល់សេវារដ្ឋបាលសរុប៤៩២ ១៦៨សេវា លើ១៤វិស័យជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងទទួលបានចំណូលសរុប ៣៥ ១២៥ ៨០៣ ៧៥៦រៀល សមមូល ៨ ៧៨១ ៤៥១ដុល្លារអាម៉េរិក។ ដោយឡែក ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌគោលដៅទាំង៥២ ដែលបានដាក់ឱ្យដំណើរការនាពេលកន្លងមកនៅក្នុងរយៈពេល១ឆ្នាំនេះ បានផ្តល់សេវារដ្ឋបាលសរុប១ ២២៦ ៨៦៩ សេវា លើ១៤វិស័យ និងទទួលបានចំណូលសរុប១៩ ៥៤៣ ៧៩២ ៥៦៦រៀល សមមូល៤ ៨៨៥ ៩៤៩ដុល្លារអាម៉េរិក។

## ១.២- ការសម្របសម្រួលនិងសហការអនុវត្តគម្រោងដោយឡែកនានា

ក្នុងរយៈពេល១ឆ្នាំកន្លងទៅនេះ ក្រសួងមហាផ្ទៃបានបន្តសហការជាមួយដៃគូអភិវឌ្ឍចំនួន៤ សម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍នានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរួមមាន៖

**ទី១- គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ(LEAP)** : បានគាំទ្រដល់ការលើកស្ទួយកម្រិតជីវភាពប្រជាជនតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ និងឱកាសបង្កើនប្រាក់ចំណូល ការជួសជុលហេដ្ឋារចនាសម្ព័ន្ធខូចខាតខ្នាតតូច ឆ្លើយតបទាន់ពេលវេលានិងមានប្រសិទ្ធភាពក្នុងពេលមានគ្រោះអាសន្ន ឬកិច្ចការបន្ទាន់ណាមួយរបស់គ្រួសារក្រីក្រនិងសហគមន៍គោលដៅងាយរងគ្រោះក្នុងខេត្តគោលដៅសៀមរាបនិងរាជធានីភ្នំពេញ(២០១៧-២០២២) ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោកចំនួន២០,១៧លានដុល្លារអាម៉េរិក និងការចូលរួមទុនបដិភាគរបស់រាជរដ្ឋាភិបាលចំនួន២លានដុល្លារអាម៉េរិក។

**ទី២- កម្មវិធីមូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ(UNICEF)** : បានគាំទ្រដល់ការលើកកម្ពស់វិស័យសេវាសង្គមនៅឃុំ សង្កាត់ លើការពង្រឹងសមត្ថភាពសហគមន៍ ដើម្បីឱ្យមានលទ្ធភាពលើកកម្ពស់ការរស់រានរបស់កុមារ និងការការពារនិងអភិវឌ្ឍន៍កុមារ ដោយចំណាយថវិកាសរុបប្រមាណ៩៤ ៥៨៤,៦៩ដុល្លារអាម៉េរិក។

**ទី៣- វិទ្យាស្ថានបៃតងសកល(GGGI)** : បានផ្តល់ការគាំទ្រលើគម្រោងអភិវឌ្ឍន៍ទីប្រជុំជនបៃតង ដោយចំណាយថវិកាប្រមាណ៥៣៨ ៦១៨ដុល្លារអាម៉េរិក។

**ទី៤- គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ (DCOCP)** : ទទួលថវិកាចំនួន១០លានដុល្លារអាម៉េរិក ក្រោមក្របខ័ណ្ឌមូលនិធិទ្រទ្រង់ថវិកាឆ្នាំ២០១៦-២០១៩ សម្រាប់គាំទ្រការសាងសង់អគាររដ្ឋបាលនិងអគារសាលប្រជុំសាលាស្រុកចំនួន៧ និងអគាររដ្ឋបាលឃុំ សង្កាត់ចំនួន១៥០។ បច្ចុប្បន្ន គម្រោងនេះបាននិងកំពុងដំណើរការសាងសង់នៅស្រុកចំនួន៧ និងឃុំ សង្កាត់ចំនួន៩៧ ស្មើនឹង៦៥%។

## ២- ការពង្រឹងវិស័យយុត្តិធម៌និងនីតិរដ្ឋ

### ២.១- ការពង្រឹងវិស័យយុត្តិធម៌

#### ២.១.១- សមិទ្ធផលការងារសំខាន់ៗរបស់ក្រសួងយុត្តិធម៌ ៖

| បរិយាយ | ចេញព្រឹត្តិបត្រថ្កោលទោស | | | | | ទឹកប្រាក់(រៀល) |
|---|---|---|---|---|---|---|
| | សល់ពីមុន | ចូលថ្មី | សរុប | ចាត់ការរួច | កំពុងចាត់ការ | |
| ៩/២០១៨-៩/២០១៩ | ៣៧ ២២៩ | ៤៩៦៤៥ | ៨៦ ៨៧៤ | ៤៨ ៥៨៩ | ៣៨ ២៨៥ | ២៦០៦៣០០០០០ |

| ការគ្រប់គ្រងសាលដីកា សាលក្រមស្ថាពររបស់សាលាជម្រះក្តី | | | |
|---|---|---|---|
| **បរិយាយ** | សាលក្រម សាលដីកា | | សរុប |
| | សល់ពីមុន | ចូលថ្មី | |
| ៩/២០១៨-៩/២០១៩ | ១៧ ៦១៣ | ៨ ៩៤៦ | ២៦ ៥៥៩ |

| | | | |
|---|---|---|---|
| **ចៅក្រម** | ៩/២០១៨-៩/២០១៩ | ចៅក្រមអាសនៈ៣០៥នាក់ (ស្រី៤៦នាក់) | ចៅក្រមអយ្យការ១៧៩នាក់ (ស្រី២៥នាក់) |
| ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ សិស្សចៅក្រមកំពុងទទួលការ បណ្តុះបណ្តាលពីរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការជំនាន់ទី៧ ទី៨ និងជំនាន់ទី៩ សរុប ១៩៧នាក់ (ស្រី ៤១នាក់)។ | | | |
| **ក្រឡាបញ្ជី** | ៩/២០១៨-៩/២០១៩ | ក្រឡាបញ្ជី ៨២៤នាក់(ស្រី១៨៧នាក់) | |
| ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ ក្រឡាបញ្ជី ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការជំនាន់ទី៥ និងជំនាន់ទី៦ សរុប ២១១នាក់(ស្រី៦៣នាក់)។ | | | |
| **មេធាវី** | ៩/២០១៨-៩/២០១៩ | មេធាវីទទួលការបណ្តុះបណ្តាល១៧២នាក់ (ស្រី៥៨នាក់) | |

<table>
<tr><td colspan="3">ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីសរុបនៅទូទាំងប្រទេស សរុប ១ ៩៨៧ នាក់ (ស្រី៤៣៤នាក់)។</td></tr>
<tr><td>អាជ្ញាសាលា</td><td rowspan="2">២០១៨</td><td>ទទួលការបណ្តុះបណ្តាល ២៧នាក់(ស្រី២នាក់)</td></tr>
<tr><td>សារការី</td><td>ទទួលការបណ្តុះបណ្តាល ២០នាក់(ស្រី៤នាក់)</td></tr>
<tr><td colspan="3">ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ សារការីដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការជំនាន់ទី១ សរុប១៥នាក់(ស្រី៣នាក់)។</td></tr>
</table>

- **ការងារអធិការកិច្ច៖**

ការធ្វើអធិការកិច្ចតាមបណ្តឹងតវ៉ាពីរូបវន្តបុគ្គលឬនីតិបុគ្គលនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តក្រចេះ កំពង់ស្ពឺ ស្វាយរៀង សៀមរាប និងខេត្តបាត់ដំបង សរុប៧លើក។

- **សេវាកម្មយុត្តិធម៌៖**

ការបង្កើតសេវាយុត្តិធម៌ឱ្យទៅជិតប្រជាពលរដ្ឋបានកាន់តែច្រើន ដោយបង្កើតនូវចំនួនមណ្ឌលសេវាកម្ម-យុត្តិធម៌នៅតាមក្រុង ស្រុក ខណ្ឌ ៦៦មណ្ឌល (គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩) ដើម្បីជួយដោះស្រាយវិវាទតូចតាចជូនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន បានឆាប់រហ័ស ទាន់ពេលវេលា និងចំណេញថវិកា។

### ២.១.២- រដ្ឋបាលតុលាការ៖

ការរៀបចំនិងដាក់ដំណើរការអង្គការរដ្ឋបាលតុលាការ សម្រាប់គ្រាំទ្រដល់កិច្ចដំណើរការរបស់អង្គតុលាការ និងអង្គការអយ្យការ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ អង្គភាពរដ្ឋបាលនេះ ហៅថា លេខាធិការដ្ឋានរដ្ឋបាល ដែលមានតួនាទីសម្របសម្រួល គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការសាធារណៈ រដ្ឋបាលនីតិវិធី កិច្ចការហិរញ្ញវត្ថុ កិច្ចការបុគ្គលិក ការងារស្រាវជ្រាវ ផ្សព្វផ្សាយ បណ្តុះបណ្តាលច្បាប់លើវិស័យរដ្ឋបាលតុលាការនិងបម្រុងការប្រើប្រាស់បច្ចេកវិទ្យាជាឧបករណ៍ជំនួយការងាររដ្ឋបាល ការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង ក្នុងគោលបំណងលើកកម្ពស់និងធានានូវដំណើរការល្អនៃយុត្តិធម៌នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

| **បៀវត្សសម្រាប់មន្ត្រីតុលាការ** | | |
|---|---|---|
| ល.រ | បរិយាយ | ប្រាក់បំណាច់(រៀល) |
| ១ | - ប្រធានតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | ១០ ០០០ ០០០ |
| ២ | - អនុប្រធានតុលាការកំពូល<br>- ប្រធានសភានៃតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល<br>- ប្រធានសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ៤ ៨០០ ០០០ |
| ៣ | - ចៅក្រមតុលាការកំពូល<br>- ព្រះរាជអាជ្ញាអមតុលាការកំពូល<br>- អនុប្រធានសាលាឧទ្ធរណ៍<br>- ប្រធានសភានៃសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ | ៤ ៣០០ ០០០ |

| | | |
|---|---|---|
| ៤ | - ចៅក្រមសាលឧទ្ធរណ៍<br>- ប្រធានសាលដំបូង<br>- ព្រះរាជអគ្គាអមសាលាឧទ្ធរណ៍<br>- ព្រះរាជអាជ្ញាអមសាលាដំបូង<br>- ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ | ៣ ៨០០ ០០០ |
| ៥ | - អនុប្រធានសាលាដំបូង<br>- ប្រធានតុលាការជំនាញនៃសាលាដំបូង<br>- ព្រះរាជអាជ្ញារងអមសាលាដំបូង | ៣ ៥០០ ០០០ |
| ៦ | - ចៅក្រមសាលាដំបូង | ៣ ៣០០ ០០០ |
| ៧ | - ចៅក្រមកម្មសិក្សា<br>- ព្រះរាជអាជ្ញារងកម្មសិក្សា | ២ ០០០ ០០០ |

## ២.២- **ការពង្រឹងនីតិរដ្ឋ**

### **ទីស្ដីការគណៈរដ្ឋមន្ត្រី**

#### **១- ក្រុមប្រឹក្សាអ្នកច្បាប់**

✡ ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់

| បរិយាយ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|
| ព្រះរាជក្រម(ច្បាប់) | ១៩ | ២៦ | ៤៥ |

✡ ច្បាប់ដែលរាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយស្នើសូមព្រះករុណា ព្រះមហាក្សត្រទ្រង់ ព្រះរាជទានព្រះរាជក្រមប្រកាសឱ្យប្រើបន្ទាប់ពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចចាប់ពីឆ្នាំ**១៩៩៣** ដល់ដំណាច់ឆ្នាំ២០១៩ សរុបមាន**៥៣៧ច្បាប់**។

✡ ទទួលសំណួរនិងសំណើពីសមាជិករដ្ឋសភានិងស្ថាប័នពាក់ព័ន្ធ

| បរិយាយ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|
| សំណួរ ចម្លើយ (ករណី) | ១៤ | ១៨ | ៣២ |

#### **២- ការងាររៀបចំកិច្ចប្រជុំ**

| បរិយាយ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|
| កិច្ចប្រជុំជំនាញបច្ចេកទេស(លើក) | ២៤ | ៥៦ | ៨០ |
| កិច្ចប្រជុំអន្តរក្រសួង(លើក) | ១៦ | ២៣ | ៣៩ |
| កិច្ចប្រជុំអន្តរក្រសួងចង្អៀត(លើក) | ០ | ១៧ | ១៧ |
| កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ(លើក) | ០ | ២ | ២ |
| កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី(លើក) | ៦ | ៦ | ១២ |

#### **៣- ការងាររាជកិច្ច**

| **នាយកដ្ឋានរាជកិច្ច** |
|---|
| **ក- ការងារផ្នែកប្រមូលនិងចងក្រង** |

| ល.រ | លិខិតបទដ្ឋាន | ឯកសារគតិយុត្ត បោះពុម្ពឆ្នាំ២០១៨ | ឯកសារគតិយុត្ត បោះពុម្ពឆ្នាំ ២០១៩ | សរុប |
|---|---|---|---|---|
| ១ | ព្រះរាជក្រម | ៥ | ៤ | ៩ |
| ២ | ព្រះរាជក្រឹត្យ | ៦០៧ | ៨៥៤ | ១ ៤៦១ |
| ៤ | រដ្ឋសភា | ១ | ២ | ៣ |
| ៥ | អនុក្រឹត្យបង្កើត | ៨៧ | ៨៦ | ១៧៣ |
| ៦ | អនុក្រឹត្យតែងតាំង | ៤៣៤ | ៧២៥ | ១ ១៥៩ |
| ៧ | សេចក្តីសម្រេច | ៥៤ | ១១៧ | ១៧១ |
| ៨ | សារាចរ | ២ | ៤ | ៦ |
| ៩ | សារាចរណែនាំ | ២ | ៥ | ៧ |
| ១០ | សេចក្តីណែនាំ | ០ | ១ | ១ |
| ១១ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៣៥ | ១២៤ | ១៥៩ |
| ១២ | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៧៦ | ៩៤ | ១៧០ |
| ១៣ | ក្រសួងការពារជាតិ | ១ | ០ | ១ |
| ១៤ | ក្រសួងយុត្តិធម៌ | ០ | ២ | ២ |
| ១៥ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | ០ | ១ | ១ |
| ១៦ | ក្រសួងរ៉ែនិងថាមពល | ០ | ២០ | ២០ |
| ១៧ | ក្រសួងកិច្ចការនារី | ០ | ២០ | ២០ |
| ១៨ | ធនាគារជាតិនៃកម្ពុជា | ១ | ១ | ២ |
| សរុបរួម | | ១ ៣០៥ | ២ ០៦០ | ៣ ៣៦៥ |

**ខ- ការងារផ្នែកបោះពុម្ព**

| បរិយាយ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|
| ចំនួនសៀវភៅក្នុងមួយលេខ(ក្បាល) | ១ ៧០០ | ១ ៧០០ | ៣ ៤០០ |
| ចំនួនសៀវភៅប្រចាំខែ(ក្បាល) | ១៣ ៦០០ | ៨ ៦៨៩ | ២២ ២៨៩ |
| ចំនួនសៀវភៅប្រចាំឆ្នាំ(ក្បាល) | ៥៤ ៤០០ | ៧៨ ២០០ | ១៣២ ៦០០ |

**៤- ការងារតម្កល់ឯកសារជាតិ**

| បរិយាយ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|
| ចំនួនឯកសារដែលបានស្កែន | ១ ០០០ | ២៦ ៣៤៦ | ២៧ ៣៤៦ទំព័រ |
| ចំនួនផែនទី ប្លង់ដែលបានជួសជុល | ៣០ | ៤៩ | ៧៩ផ្ទាំង |
| ចំនួនភ្ញៀវមកសិក្សាស្រាវជ្រាវ | ១០៥ | ១ ១០២ | ១ ២០៧នាក់ |
| ចំនួនភ្ញៀវមកធ្វើទស្សនកិច្ច | ៤២ | ៩៤ | ១៣៦នាក់ |
| ចំនួនសៀវភៅដែលទទួលបាន | ៥២៦ | ១ ៣៧៨ | ១ ៩០៤ក្បាល |

| ៥- ការងាររដ្ឋបាល | | | |
|---|---|---|---|
| បរិយាយ | ២០១៨ | ២០១៩ | សរុប |
| សេចក្ដីសម្រេច | ១០១ | ១៦៥ | ២៦៦ |
| ប្រកាស | ១០៩ | ១០០ | ២០៩ |
| អនុក្រឹត្យតែងតាំង | ១ ២៧៩ | ១ ២៥១ | ២ ៥៣០ |
| អនុក្រឹត្យបង្កើត | ១៩៦ | ១៥៤ | ៣៥០ |
| សារាចរ | ៧ | ៧ | ១៤ |
| សារាចរណែនាំ | ៨ | ៩ | ១៧ |
| សេចក្ដីណែនាំ | ៣ | ០ | ៣ |

**៦- មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

មជ្ឈមណ្ឌលបាន (១)ធ្វើការកែសម្រួលប្រតិចារឹក១៤ប្រតិចារឹក ស្មើនឹង១ ២៦៩ទំព័រ និងធ្វើការបន្ស៊ីវីដេអូជាមួយប្រតិចារឹកដែលបានកែសម្រួលរួចចំនួន៦៨វីដេអូ (២)ថតចម្លងឯកសារសំឡេងពីកាស្សែតទៅជាទម្រង់ឌីជីថល២១កាស្សែត (៣)បោះត្រាឌីជីថលលើសំណុំរឿងអេឡិចត្រូនិកករណី០០១ ចំនួន៧ ០២៦សំណុំ សរុប៧៤ ៣២៤ទំព័រ ដែលមាន៣ភាសាគឺ ភាសាខ្មែរ អង់គ្លេស និងភាសាបារាំង (៤)ធ្វើតារាងបញ្ចូលទិន្នន័យចំណងជើងសារព័ត៌មាន ដែលបានស្កេនរួចជាភាសាខ្មែរ៤ ២៥៤ចំណងជើង ភាសាអង់គ្លេស១៤ ៥៥៥ចំណងជើង ភាសាបារាំង១៩៥ចំណងជើង និងភាសាជប៉ុន១៤ចំណងជើង សរុប១ ៩៩៤ទំព័រ (៥)បញ្ចូលសៀវភៅទាំងអស់នៅក្នុងប្រភេទ «ប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម សាលក្រម សាលដីកា សៀវភៅទូទៅ» ផ្នែកភាសាអង់គ្លេស១២០ក្បាល ស្មើនឹង៦៤ចំណងជើង និងក្នុងប្រភេទ «សាលក្រម សាលដីកា» ផ្នែកភាសាខ្មែរ២៩ក្បាល ស្មើនឹង៩ចំណងជើង ទៅក្នុងប្រព័ន្ធកម្មវិធីគ្រប់គ្រងសៀវភៅនិងបណ្ណាល័យ(ញូវជេនលីប) និងបិទកូដសៀវភៅនៅបន្ទប់ដើមបណ្ដឹងរដ្ឋប្បវេណី៤០៦ក្បាល (៦)ទទួលឯកសារសាធារណៈសំណុំរឿង០០២ដំណាក់កាលទី១ ជាឯកសារទន់(Soft Copy) មាន៨ឌីវីឌីសរុប១៧ ២៦៧សំណុំ មាន១៧៥ ២៤៦ទំព័រ ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.) និងទទួលសៀវភៅពីស្ថាប័ននានាចំនួន១០ក្បាល (៧)ទទួលការអនុម័តជាផ្លូវការពីរដ្ឋាភិបាលជប៉ុនក្នុងការប្រើប្រាស់ថវិកា**២៥១ ៩៧០ដុល្លារអាម៉េរិក** ពីមូលនិធិបដិភាគជប៉ុន (Japan V) សម្រាប់ការអនុវត្តគម្រោង «អនុវត្តអាណត្តិកេរដំណែលរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» រយៈពេល៣ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ និង (៨) ចុះឧទ្ទេសនាមអំពីតួនាទីនិងភារកិច្ចរបស់មជ្ឈមណ្ឌលនៅរាជធានី ខេត្ត តាមគ្រឹះស្ថានសិក្សានិងស្ថាប័នពាក់ព័ន្ធ៤១កន្លែង ដែលមានសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងមហាជនចូលរួម១២ ១៥២នាក់។

## ៣- យន្តការដោះស្រាយបណ្ដឹង

### ៣.១- ក្រសួងមហាផ្ទៃ

គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានទទួលពាក្យបណ្ដឹងចំនួន៣៥១សំណុំរឿង និងរបាយការណ៍បំភ្លឺពីបណ្ដារាជធានី ខេត្តចំនួន២៦របាយការណ៍។ បណ្ដឹងទាំងនេះ ភាគច្រើនពាក់ព័ន្ធនឹងវិវាទរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ វិវាទរវាងប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលនិងមន្ត្រីនគរបាល និងវិវាទរវាងមន្ត្រីរាជការនិងមន្ត្រីរាជការ។

បើគិតទាំងបណ្ដឹងដែលនៅសល់ពីឆ្នាំមុនចំនួន២៩សំណុំរឿង បណ្ដឹងសរុបមានចំនួន៣៨០សំណុំរឿង ដែលក្នុងនោះរួមមាន៖

- ផ្នែករដ្ឋបាល : បណ្ដឹងសរុបចំនួន២៥៤សំណុំរឿង ក្នុងនោះបណ្ដឹងចូលថ្មីចំនួន២៤១សំណុំរឿង បណ្ដឹងនៅសល់ពីឆ្នាំមុនចំនួន១៣សំណុំរឿង និងរបាយការណ៍បំភ្លឺពីបណ្ដារាជធានី ខេត្តចំនួន២៣របាយការណ៍។

- ផ្នែកនគរបាល : បណ្ដឹងសរុបចំនួន១២៦សំណុំរឿង ក្នុងនោះបណ្ដឹងចូលថ្មីចំនួន១១០សំណុំរឿង បណ្ដឹងនៅសល់ពីឆ្នាំមុនចំនួន១៦សំណុំរឿង និងរបាយការណ៍បំភ្លឺពីបណ្ដារាជធានី ខេត្តចំនួន៣របាយការណ៍។

ជាលទ្ធផល ក្រសួងបានដោះស្រាយបញ្ចប់និងបង្វែរជូនស្ថាប័នពាក់ព័ន្ធនិងសាមីបណ្ដឹងវិញ សរុបចំនួន ២២២សំណុំរឿង (ក្នុងនោះដោះស្រាយបញ្ចប់ចំនួន ៣១សំណុំរឿង)។ រីឯបណ្ដឹងចំនួន ១៥៨សំណុំរឿងទៀតកំពុងធ្វើការអង្កេតស្រាវជ្រាវ និងបន្តដោះស្រាយតាមនីតិវិធី។

### ៣.២-ក្រសួងយុត្តិធម៌៖

| ការដោះស្រាយពាក្យបណ្ដឹង | | | | | |
|---|---|---|---|---|---|
| ការដោះស្រាយពាក្យបណ្ដឹងផ្សេងៗដែលបានប្ដឹងចូលមកក្រសួងយុត្តិធម៌ | | | | | |
| ក- អគ្គាធិការដ្ឋានកិច្ចការតុលាការ | | | | | |
| បរិយាយ | សល់ពីមុន | ចូលថ្មី | សរុប | ចាត់ការរួច | កំពុងចាត់ការ |
| ៩/២០១៨-៩/២០១៩ | ១២៥ | ៧៦ | ២០១ | ៣៩ | ១៦២ |
| ខ- អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី | | | | | |
| ៩/២០១៨-៩/២០១៩ | ៣៣៧ | ៤៩ | ៣៨៦ | ៣៣៧ | ៤៩ |
| គ- អគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ | | | | | |
| ៩/២០១៨-៩/២០១៩ | ១ ៣៦៥ | ២០៩ | ១ ៥៧៤ | ២២៦ | ១ ៣៤៨ |

| មណ្ឌលសេវាកម្មយុត្តិធម៌(សន្ទានកម្ម) | | | | | |
|---|---|---|---|---|---|
| ក- មណ្ឌលសេវាកម្មយុត្តិធម៌ | | | | | |
| បរិយាយ | សល់ពីមុន | ចូលថ្មី | សរុប | ចាត់ការរួច | កំពុងចាត់ការ |
| ២០១៨ | ១៩៨ | ៨៥២ | ១ ០៥០ | ៧៨៦ | ២៦៤ |
| ២០១៩ | ២៤០ | ១ ៤២៧ | ១ ៦៤៧ | ១ ៣៣៧ | ៣៣០ |
| ខ- ការផ្ដល់ប្រឹក្សានិងការដោះស្រាយវិវាទ | | | | | |
| ២០១៨ | ២២៥ | ៣ ៩៧២ | ៤ ១៩៧ | ២ ៤៥៤ | ១ ៧៤៣ |
| ២០១៩ | ២៩៩ | ៤ ៤៧៧ | ៤ ៧៧៦ | ២ ៥៨២ | ២ ១៩៤ |
| ការដោះស្រាយបណ្ដឹងរបស់សាលាដំបូងរាជធានី-ខេត្ត | | | | | |
| ក- ស្ថិតិសំណុំរឿងព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីខេត្ត | | | | | |
| ៩/២០១៨-៩/២០១៩ | ៣០៥ | ៦៦ | ៣៧១ | ៩៧ | ២៧៤ |
| ខ- ស្ថិតិសំណុំរឿងរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានីខេត្ត | | | | | |
| ៩/២០១៨-៩/២០១៩ | ១២ ៣២២ | ២ ២៣២ | ១៤ ៥៥៤ | ១ ៣៨៨ | ១៣ ១៦៦ |

### ៣.៣- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- បានទទួលពាក្យបណ្ដឹងចំនួន១៣៥បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៤៦បណ្ដឹង និង មន្ទីររាជធានី ខេត្តចំនួន៨៩បណ្ដឹង) ដោយបានដោះស្រាយចប់ចំនួន២៨បណ្ដឹង។

## ៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

### ៤.១- លទ្ធផលការងារសំខាន់ៗរបស់កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ

#### ក- កំណែទម្រង់កងយោធពលខេមរភូមិន្ទ

ក្រសួងការពារជាតិ បានបន្តការយកចិត្តទុកដាក់អនុវត្តការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ ស្របតាមផែនការនិងលិខិតបទដ្ឋានគតិយុត្ត ដើម្បីឆ្លើយតបទៅនឹងវិធានការយុទ្ធសាស្ត្រនានាដែលបានដាក់ចេញ រួមមាន បានកែសម្រួលពង្រឹងការងារគ្រប់គ្រង ដឹកនាំ បញ្ជានៅគ្រប់លំដាប់ថ្នាក់ កែសម្រួលផ្ទេរក្របខ័ណ្ឌកងពលធំអន្តរាគមន៍ចំនួន២និងកងពលតូចចំនួន៣ ពីអគ្គបញ្ជាការដ្ឋានមកចំណុះផ្ទាល់បញ្ជាការដ្ឋានកងទ័ពជើងគោក ផ្ទេរក្របខ័ណ្ឌកងពលតូចចំនួន១ ពីបញ្ជាការដ្ឋានកងទ័ពជើងគោកមកចំណុះផ្ទាល់យោធភូមិភាគទី៣ និងបានកែសម្រួលតួនាទីភារកិច្ច រចនាសម្ព័ន្ធចាត់តាំងក្របខ័ណ្ឌចំនួនទ័ព។ ជាមួយគ្នានេះ បានបង្កើតផ្នែកសឹករងចំនួន៤និងមូលដ្ឋានកងរាជអាវុធហត្ថចំនួន៥ ចំណុះតំបន់ប្រតិបត្តិការសឹករងនិងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីខេត្តមួយចំនួន និងបានកែសម្រួលទីតាំងនិងចំណុចឈរជើងរបស់បណ្ដាកងឯកភាពមួយចំនួនផងដែរ។

ចំពោះការគ្រប់គ្រងស្ថិតិចំនួនកងទ័ព ដោយមានការអនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល ក្រសួងការពារជាតិបានជ្រើសរើសកងទ័ពថ្មីបំពេញក្របខ័ណ្ឌជូនបណ្ដាកងឯកភាពមួយចំនួន និងជ្រើសរើសនិស្សិតសិស្ស តាមរយៈការប្រឡងប្រជែងដើម្បីទទួលការបណ្ដុះបណ្ដាលនិងហ្វឹកហ្វឺនតាមផែនការឆ្នាំ ជំនួសឱ្យយោធិនចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ និងយោធិនប្រភេទ២(ពលី មរណៈ និងពិការ) និងយោធិនដែលអវត្តមានគ្មានមូលហេតុ។

ក្នុងគោលដៅលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាព និងសេចក្ដីត្រូវការធនធានមនុស្សនៅក្នុងកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិបានបន្តធ្វើការកែសម្រួល ពង្រឹងគុណភាពហ្វឹកហ្វឺន បណ្ដុះបណ្ដាលបំប៉នជំនាញផ្សេងៗនៅតាមបណ្ដាសាលាហ្វឹកហ្វឺនក្នុងប្រទេស ដែលមានសិក្ខាកាមទាំងវគ្គចាស់និងវគ្គថ្មីសរុបចំនួន៥ ៧០៤នាក់ ព្រមទាំងចាត់បញ្ជូនទៅសិក្សានៅក្រៅប្រទេសចំនួន១ ៣០៧នាក់។ ក្រៅពីនេះ បានហ្វឹកហ្វឺននៅនឹងកន្លែងតាមបណ្ដាកងអង្គភាពនិងបានចាត់តាំងធ្វើលំហាត់ហ្វឹកហ្វឺន៣លើក ជាអាទិ៍(១)នាគមាសឆ្នាំ២០១៩ (២)មហារំអិល២០១៩ និង(៣)ហានុមានមាស២០១៩ ផងដែរ។

កងយោធពលខេមរភូមិន្ទត្រូវបានទទួលការបំពាក់បំប៉នអប់រំចិត្តសាស្ត្រ ស្មារតីសតិអារម្មណ៍ច្បាប់ផ្សេងៗនិងសភាពការណ៍ថ្មីៗ ពិសេសច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យស្ដីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ដើម្បីលើកកម្ពស់ការយល់ដឹង ការគោរពនិងអនុវត្តច្បាប់ បទបញ្ជា និងទឹកចិត្តស្នេហាជាតិមាតុភូមិ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងការពារនិងស្មោះត្រង់ដាច់ខាតចំពោះរាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ កងយោធពលខេមរភូមិន្ទក៏ទទួលបានការដំឡើងប្រាក់បៀវត្ស តាមរយៈការកែប្រែសន្ទស្សន៍បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារ។ បើពិនិត្យចំពោះបៀវត្សរបស់ពលទាហានម្នាក់ៗគិតជាមធ្យមក្នុងឆ្នាំ២០១៩ បានកើនឡើងដល់ចំនួន១ ០៩០ ៩០០រៀល (ប្រៀបធៀបនឹងឆ្នាំ២០១៨ អត្រាកំណើន

៧,៨៤%)។ ជាមួយគ្នានេះ ក៏មានការយកចិត្តទុកដាក់ក្នុងការបន្តផ្តល់ប្រាក់ហូបបន្ថែមសមរភូមិមុខ បង្កើនឥណទានថវិកាហ្វឹកហ្វឺន លំហាត់សមយុទ្ធ ថែទាំបច្ចេកទេស គ្រឿងបំពាក់ ប្រេងឥន្ធនៈ ថវិកាជំនាញមួយចំនួន និងប្រាក់ឧបត្ថម្ភមាតុភាពជូនយោធិននារីទៅតាមលទ្ធភាពជាក់ស្តែង គួបផ្សំនឹងការឧបត្ថម្ភពីសប្បុរសជននានាប្រទេសដៃគូ អង្គភាពសម្ព័ន្ធមេត្រីភាពនិងការងារបង្កបង្កើនផល បានធ្វើឱ្យកងទ័ពកាន់តែមានលទ្ធភាពមួយកម្រិតថែមទៀតក្នុងការបំពេញភារកិច្ចជូនជាតិ មាតុភូមិ និងមានជីវភាពរស់នៅប្រចាំថ្ងៃប្រសើរឡើងជាលំដាប់។

**ខ- ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត**

ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួងការពារជាតិសម្រេចបាននិងកំពុងបន្ត រួមមាន ១- សេចក្តីព្រាងច្បាប់ ស្តីពីបទល្មើសយោធានិងនីតិវិធីបទល្មើសយោធា ២- សេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំអង្គការតុលាការយោធា ៣- សេចក្តីព្រាងច្បាប់ ស្តីពីការការពារជាតិ ៤- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៩នៃអនុក្រឹត្យលេខ៤៩អនក្រ.បក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ (ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨) និង៥- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១០និងមាត្រា១១ នៃអនុក្រឹត្យលេខ២២២អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំយន្តការគ្រប់គ្រងកម្រិតថ្នាក់និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ (ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩)។

**គ- កិច្ចការអតីតយុទ្ធជន**

សម្រាប់ផែនការអនុវត្តឆ្នាំ២០១៩ ក្រសួងបានបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូង ជូនយោធិនចូលនិវត្តន៍ ចេញពីជួរ និងយោធិនប្រភេទ២ សរុបចំនួន ៣ ៩១៤នាក់ (សោធននិវត្តន៍ចំនួន ៣ ៥០៤នាក់ ចេញពីជួរចំនួន៧នាក់ ពលីចំនួន២៧៨នាក់ និងពិការចំនួន១២៥នាក់) កើនឡើង៣៥,៧៩% បើប្រៀបធៀបនឹងផែនការអនុវត្តឆ្នាំ២០១៨។ ដោយឡែក អតីតមន្ត្រី បុគ្គលិកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជាដែលបានបញ្ចូលក្របខ័ណ្ឌចំនួន៤៧២នាក់ (សោធននិវត្តន៍២៩១នាក់ ពលី៥៣នាក់ និងពិការ១២៨នាក់) ផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រីឯមុខសញ្ញាពិការដែលជាអតីតយុទ្ធជននៃកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅយោធភូមិភាគទី៣ និងយោធភូមិភាគទី៥ ចំនួន ២ ២៨១នាក់ នឹងបន្តចុះពិនិត្យវាយតម្លៃជាបន្តបន្ទាប់ក្នុងរយៈពេលបីឆ្នាំ(២០១៩-២០២០-២០២១)។

សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នូវការសាងសង់ផ្ទះនៅលើដីសម្បទានជូនសមាជិកអតីតយុទ្ធជនកម្ពុជាដែលមានជីវភាពក្រីក្រលំបាក ជម្រកស្នាក់នៅមិនសមរម្យ និងគ្មានដី គ្មានផ្ទះ សរុបចំនួន១ ៩៩៣ខ្នង។ សមាជិកអតីតយុទ្ធជនកម្ពុជាដែលកំពុងទទួលរបបឧបត្ថម្ភគោលនយោបាយរៀងរាល់ខែពីរដ្ឋមានចំនួន១០៨ ៨៧១នាក់ ក្នុងនោះ សមាជិកសមាគមអតីតយុទ្ធជនដែលគ្មានដី គ្មានផ្ទះ មានដីគ្មានផ្ទះនិងរស់នៅលើដីសាធារណៈចំនួន ៦ ១១៤នាក់។ ទន្ទឹមនេះ បានបើកប្រាក់បេឡាមរណៈសង្គ្រោះជូនគ្រួសារសពសមាជិកសមាគមអតីតយុទ្ធជនចំនួន១ ២៤៧សព។

ក្រសួងការពារជាតិមានមជ្ឈមណ្ឌលអភិវឌ្ឍយោធិនពិការចំនួន៣កន្លែង និងមានយោធិនពិការគ្រួសារនគរបាលពលី និងគ្រួសារបញ្ជូនមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រស់នៅសរុប ១ ០៥៨គ្រួសារ (១)មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧កោះស្លា ស្រុកឈូក ខេត្តកំពតចំនួន២៥៥គ្រួសារ (២)មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការសម្តេចតេជោ **ហ៊ុន សែន** គូលែន៣១៧ ខេត្តសៀមរាបចំនួន២៦៦គ្រួសារ និង(៣)មជ្ឈមណ្ឌលអភិវឌ្ឍយោធិនពិការ៣១៧ តេជោភ្នំឆត្រ ខេត្តបន្ទាយមានជ័យ ចំនួន៥៣៧គ្រួសារ)។

### ឃ- ការកសាងបណ្តាញផ្លូវគមនាគមន៍ សំណង់អគារ និងកិច្ចការសង្គម

ក្រៅពីការបំពេញភារកិច្ចស្នូលខាងលើ កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ចចូលរួមចំណែកកសាងបណ្តាញផ្លូវគមនាគមន៍ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ សំណង់អគារ ជំរំ បន្ទាយ ផ្ទះសម្បែងកងទ័ព និងចូលរួមកិច្ចការសង្គមជួយប្រជាពលរដ្ឋដូចជា ជួយសង្គ្រោះគ្រោះមហន្តរាយនានា(គ្រោះរាំងស្ងួត ព្យុះ ទឹកជំនន់ អគ្គិភ័យ គ្រោះថ្នាក់ចរាចរណ៍ ...) សាងសង់និងជួសជុលផ្ទះ ផ្លូវ ស្ពាន បង្គន់អនាម័យ ជីកស្រះទឹក អណ្តូងទឹក ដឹកទឹកចែកជូនតំបន់ខ្វះទឹក ពិនិត្យព្យាបាលជំងឺ ជួយការងារបង្កបង្កើនផល និងជួយឧបត្ថម្ភផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលជួបការលំបាកខ្វះខាត។

លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានៈ

- កសាងនិងជួសជុលបណ្តាញផ្លូវគមនាគមន៍ៈ ផ្លូវបេតុង៨០ខ្សែ ប្រវែង១៦ ៤៩១ ម៉ែត្រ/១០៥ខ្សែ ប្រវែង៣១ ៦១៥ម៉ែត្រ ផ្លូវកៅស៊ូ១៩ខ្សែ ប្រវែង៨៤ ៨០៧ម៉ែត្រ/៦៤ខ្សែ ប្រវែង២៦៣ ៦៧១ម៉ែត្រ ផ្លូវក្រួសក្រហម៦៦ខ្សែ ប្រវែង២៩២ ៣៦៥ម៉ែត្រ/១២០ខ្សែ ប្រវែង៥២៨ ៨៤៧ម៉ែត្រ ស្ពានបេតុង១២កន្លែង ប្រវែង៦៣៣ម៉ែត្រ/២៦កន្លែង ប្រវែង១ ២១៥ម៉ែត្រ លូ(ប)៣កន្លែង ប្រវែង៤ ១៧០ម៉ែត្រ/៣កន្លែង ប្រវែង៤ ១៧០ម៉ែត្រ ជាឡូ៥៧កន្លែង/៩២កន្លែង និងលូ(០) គ្រប់ប្រភេទ៣៥៧កន្លែង/៦១២កន្លែង។

- កសាងផ្លូវក្រវាត់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-វៀតណាម កម្ពុជា-ថៃ និងផ្លូវតភ្ជាប់ផ្ទៃក្នុងប្រទេសៈ ផ្លូវកៅស៊ូប្រវែង២២ ៥៧០ម៉ែត្រ ផ្លូវក្រួសក្រហមនិងផ្លូវល្បាយថ្មភ្នំប្រវែង១៨៦ ៦៣០ម៉ែត្រ ផ្លូវយោធាប្រវែង១៥ ៦៧០ម៉ែត្រ។

- ធ្វើការបោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះសម្រេចបានផ្ទៃដី៣៣ ៥៤៣ ៧៥៣ម$^{២}$ រកឃើញគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះចំនួន២ ១១៦គ្រាប់ ព្រមទាំងអំបែងសំបកគ្រាប់ កន្ទុយគ្រាប់ និងកម្ទេចដែកចំនួន៨ ៤៩៨គីឡូក្រាមនិង៥១ ៨១៧ដុំ។

## ៤.២- លទ្ធផលការងាររបស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ

### ក- ការពង្រឹងយន្តការ

ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការដឹកនាំ គ្រប់គ្រងស្ថាប័ន ក៏ដូចជាឆ្លើយតបទៅនឹងសំណូមពរចាំបាច់នៃកិច្ចប្រតិបត្តិការការងារ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួននិងដោយផ្អែកទៅលើមូលដ្ឋាននៃការវិភាគមុខងារផងដែរនោះ ក្រសួងមហាផ្ទៃបានរៀបចំកែសម្រួលឡើងវិញនូវអនុក្រឹត្យលេខ១០៩ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យនេះផងដែរ។ លើសពីនេះ ក្រសួងបានរៀបចំនិងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវឯកសារជាច្រើនដែលមានលក្ខណៈជាកម្មវិធីការងារ ផែនការយុទ្ធសាស្ត្រតាមវិស័យ ការតម្រង់ទិស ការពង្រឹងវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រី បទបញ្ជាផ្សេងៗ ព្រមជាមួយនឹងការជំរុញចុះធ្វើអធិការកិច្ច និងធ្វើសវនកម្មផ្ទៃក្នុងជាប្រចាំដើម្បីពង្រឹងរបៀបរបបការងារប្រកបដោយគណនេយ្យភាព តម្លាភាព លុបបំបាត់អំពើពុករលួយ ប្រឆាំងវប្បធម៌និទណ្ឌភាព ការធានាភាពអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ នីតិវិធីកំណត់។

នាដើមឆ្នាំ២០១៩ ក្រសួងមហាផ្ទៃបានរៀបចំកែសម្រួលរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទមួយចំនួនដូចជា ការបំពេញបន្ថែមការិយាល័យ និងផ្នែកជំនាញចំណុះឱ្យនាយកដ្ឋានបុគ្គលិក និងនាយកដ្ឋានតម្រួតបទបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ បន្ថែមផ្នែកជំនាញឱ្យអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងបង្កើតបន្ថែមនូវវរសេនាតូចនគរបាលអន្តរាគមន៍ចំនួន១វរសេនាតូចចំណុះឱ្យនាយកដ្ឋាននគរបាលការពារព្រំដែនគោក។

### ខ- ការលើកកម្ពស់សមត្ថភាព

ចំពោះការគ្រប់គ្រង អភិវឌ្ឍធនធានមនុស្ស និងលើកកម្ពស់សមត្ថភាព ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ទាំងលើបរិមាណនិងគុណភាព តាមរយៈការជ្រើសរើសមន្ត្រីថ្មីដើម្បីបំពេញជំនួសមន្ត្រីចាស់ដែលបានកាត់ចេញនិងបំពេញតម្រូវការចាំបាច់របស់អង្គភាព ការលើកកម្ពស់ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងចាត់បញ្ជូនចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល កម្មវិធីសិក្សានានាទាំងក្នុងនិងក្រៅប្រទេស និងធ្វើបច្ចុប្បន្នភាពមន្ត្រីជាប្រចាំ។

ដើម្បីធានាបាននូវភាពម្ចាស់ការលើការអប់រំ បណ្តុះបណ្តាលកងកម្លាំង ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំ គ្រប់គ្រង និងការអនុវត្តតួនាទី ភារកិច្ចរបស់មន្ត្រី ក្រសួងមហាផ្ទៃបានបន្តយកចិត្តទុកដាក់ជំរុញកិច្ចការសំខាន់ៗដែលជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាលដូចជា ធ្វើការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងជាប្រចាំ ដើរទន្ទឹមនឹងការខិតខំបង្កើនកម្រិតគុណវុឌ្ឍិ សមត្ថភាពគ្រូបង្រៀន និងការអភិវឌ្ឍកម្មវិធីសិក្សា ពង្រឹងការអនុវត្តវិន័យ និងលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានសម្ភារៈរូបវន្តគ្រប់ប្រភេទសម្រាប់ទ្រទ្រង់ដល់ដំណើរការអប់រំបណ្តុះបណ្តាល ។ល។

ជាក់ស្តែង នៅក្នុងរយៈពេល១ឆ្នាំកន្លងទៅ ក្រសួងបានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារចំនួន១៤ថ្នាក់ និង៥៣វគ្គ មាននិស្សិត សិក្ខាកាម និងសិស្សសរុបចំនួន៥ ៣២៤រូប ស្រី៥៥០រូប ក្នុងនោះ ថ្នាក់វគ្គសិក្សាបានបញ្ចប់ជាស្ថាពរចំនួន៣ថ្នាក់និង៣៦វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សចំនួន៣ ២៣០រូប ស្រី២៦៥រូប និងថ្នាក់វគ្គសិក្សាកំពុងបន្តចំនួន១១ថ្នាក់និង១៧វគ្គសិក្សា មាននិស្សិត សិក្ខាកាម និងសិស្សចំនួន២ ០៩៤រូប ស្រី២៨៥រូប។ ទន្ទឹមនេះ ក៏បានធ្វើការលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំ និងគ្រូនគរបាលជាតិ តាមរយៈការបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងចាត់បញ្ជូនទៅសិក្សានៅក្នុង និងក្រៅប្រទេសចំនួន៤៦៦រូប ក្នុងនោះគ្រូនគរបាលជាតិចំនួន១៨៤រូប(ទៅសិក្សានៅក្រៅប្រទេសចំនួន៥៧រូប)។

### គ- ការអនុវត្តគោលនយោបាយលើកទឹកចិត្តនិងវិន័យ

ដោយផ្អែកលើសមត្ថភាព ស្នាដៃ និងបទពិសោធការងាររបស់មន្ត្រី ក្រសួងបានសម្រេចធ្វើការតែងតាំងមុខតំណែង ដំឡើងឋានន្តរសក្តិ ថ្នាក់ និងលើកទឹកចិត្តជាបន្តបន្ទាប់។ ដោយឡែក ចំពោះមន្ត្រីដែលបានប្រព្រឹត្តផ្ទុយពីបទដ្ឋានកំណត់ ក្រសួងក៏បានធ្វើការដាក់វិន័យទៅតាមនីតិវិធីផងដែរ។

ក្នុងរយៈពេល១ឆ្នាំកន្លងទៅ មន្ត្រីនគរបាលជាតិត្រូវបានបញ្ចូលក្របខ័ណ្ឌថ្មីមានចំនួន ១ ១៣៤រូប កាត់ចេញពីក្របខ័ណ្ឌចំនួន១ ៦៧៨រូប ដំឡើងឋានន្តរសក្តិតាមមុខតំណែងចំនួន២ ១៤៨រូប និងតែងតាំងមុខតំណែងគ្រប់លំដាប់ថ្នាក់ចំនួន១ ៦៥៣រូប ព្រមទាំងទទួលការបណ្តុះបណ្តាលរយៈពេលវែង-ខ្លី ទាំងក្នុងនិងក្រៅប្រទេសសរុបចំនួន៤ ៩៧៩រូប។

## ទី៤- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

### ១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

| ក- ការងារចុះធ្វើអធិការកិច្ចការងារនិងវិធានការដែលប្រព្រឹត្តល្មើសច្បាប់ | | | | |
|---|---|---|---|---|
| បរិយាយ | ឯកតា | កញ្ញា ២០១៨-កក្កដា ២០១៩ | | |
| | | សរុប | ថ្នាក់កណ្តាល | រាជធានី-ខេត្ត |
| ការចុះអធិការកិច្ចការងារ | លើក | ៤ ០៩៦ | ៩៦៧ | ៣ ១២៩ |
| *ចុះធ្វើអធិការកិច្ចការងារសាមញ្ញ* | លើក | ៣ ៦១២ | ៨៧២ | ២ ៧៤០ |

| | | | | |
|---|---|---|---|---|
| *ចុះធ្វើអធិការកិច្ចការងារពិសេស* | លើក | ៣៨៨ | ៧៩ | ៣០៩ |
| *ចុះធ្វើអធិការកិច្ចការងារពិសេសក្រៅកម្មវិធី* | លើក | ៩៦ | ១៦ | ៨០ |
| ដាក់កំហិត | លើក | ៧៥៥ | ១៣៧ | ៦១៨ |
| ត្រូវផាកពិន័យ | លើក | ៧២ | ២២ | ៥០ |
| បានចេញលិខិតផាកពិន័យ | លើក | ១៨ | - | ១៨ |
| ប្ដឹងទៅតុលាការ | សហគ្រាស | ២ | - | ២ |
| ដោះស្រាយសំណុំរឿងជាមួយតុលាការ | លើក | ៤ | - | ៤ |

**ខ- ស្ថានភាពសហគ្រាស គ្រឹះស្ថានបើកថ្មី បិទលែងដំណើរការ និងព្យួរការងារ**

| ស្ថានភាពហគ្រាស គ្រឹះស្ថាន | | | កញ្ញា ២០១៨-កក្កដា ២០១៩ | | |
|---|---|---|---|---|---|
| | | | សរុប | ថ្នាក់កណ្ដាល | រាជធានី-ខេត្ត |
| សហគ្រាស គ្រឹះស្ថាន បើកថ្មី | កាត់ដេរ | | ១៦០ | ១២២ | ៣៨ |
| | កម្មករ និយោជិត | សរុប | ៣៣ ៩៤០ | ២៦ ៥០៦ | ៧ ៤៣៤ |
| | | ស្រី | ២៨ ៥៩៥ | ២២ ៥៧២ | ៦ ០២៣ |
| | ក្រៅពីកាត់ដេរ | | ១ ៩៩១ | ៨៩២ | ១ ០៩៩ |
| | កម្មករ និយោជិត | សរុប | ៦៦ ៧៩០ | ៤១ ១៥៤ | ២៥ ៦៣៦ |
| | | ស្រី | ២៧ ៨៤២ | ១៧ ៧៣៩ | ១០ ១០៣ |
| | **សរុបរួម** | | ២ ១៥១ | ១ ០១៤ | ១ ១៣៧ |
| | **កម្មករ និយោជិត** | **សរុប** | **១០១ ៧៣០** | **៦៨ ៦៦០** | **៣៣ ០៧០** |
| | | **ស្រី** | **៥៦ ៤៣៧** | **៤០ ៣១១** | **១៦ ១២៦** |
| សហគ្រាស គ្រឹះស្ថានបិទ | កាត់ដេរ | | ១៤៧ | ១១២ | ៣៥ |
| | កម្មករ និយោជិត | សរុប | ៥៨ ៨២៤ | ៤១ ៥៨៤ | ១៧ ២៤០ |
| | | ស្រី | ៤៦ ៨១៤ | ៣៣ ០៨៤ | ១៣ ៧៣០ |
| | ក្រៅពីកាត់ដេរ | | ៥៨៤ | ៣៤ | ៥៥០ |
| | កម្មករ និយោជិត | សរុប | ១៣ ៤៨៥ | ៣ ៥២៣ | ៩ ៩៦២ |
| | | ស្រី | ៥ ១៥៩ | ៨៦៨ | ៤ ២៩១ |
| | **សរុបរួម** | | ៧៣១ | ១៤៦ | ៥៨៥ |
| | **កម្មករ និយោជិត** | **សរុប** | **៧២ ៣០៩** | **៤៥ ១០៧** | **២៧ ២០២** |
| | | **ស្រី** | **៥១ ៩៧៣** | **៣៣ ៩៥២** | **១៨ ០២១** |
| សហគ្រាស គ្រឹះស្ថានព្យួរការងារ | កាត់ដេរ | | ៣៥ | ១៨ | ១៧ |
| | កម្មករ និយោជិត | សរុប | ២៨ ៩៦០ | ១៧ ៣៩០ | ១១ ៥៧០ |
| | | ស្រី | ២៤ ៧៨៥ | ១៤ ៥២៤ | ១០ ២៦១ |
| | ក្រៅពីកាត់ដេរ | | ៥ | ២ | ៣ |
| | កម្មករ និយោជិត | សរុប | ៥៥០ | ២៣៥ | ៣១៥ |
| | | ស្រី | ២៨១ | ១៩១ | ៩០ |
| | **សរុបរួម** | | ៣៩ | ១៩ | ២០ |
| | **កម្មករ និយោជិត** | **សរុប** | **២៩ ៤៦៥** | **១៧ ៥៨០** | **១១ ៨៨៥** |
| | | **ស្រី** | **២៥ ០៤២** | **១៤ ៦៩១** | **១០ ៣៥១** |

**២- ក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តការងារចុះធ្វើអធិការកិច្ចហត្ថពលករបរទេសនៅតាមបណ្តារោងចក្រ សហគ្រាស និងគ្រឹះស្ថាននានា រកឃើញពលករបរទេសគ្មានបណ្ណការងារចំនួន៤ ៨៣១នាក់ និងធ្វើការផាកពិន័យជាទឹកប្រាក់សរុបចំនួន **២ ៤១៥ ៥០០ ០០០**រៀល។

## បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

បរិស្ថានគ្រប់ដណ្តប់ល្អប្រសើរ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តប្រកបដោយជោគជ័យនូវអាទិភាពគោលនយោបាយតាមផ្នែកនៃចតុកោណយុទ្ធសាស្ត្រទាំង៤ ដើម្បីធានាសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍ។ ជារួមកម្ពុជាត្រូវបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព និងពង្រឹងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលទ្ធភាពនិងការផ្តល់កាលានុវត្តក្នុងការបន្តដំណើរអភិវឌ្ឍន៍ទៅមុខ។

### ទី១- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ

**១- ការការពារឯករាជ្យនិងអធិបតេយ្យជាតិ មិនឱ្យបរទេសលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា**

ដើម្បីក្តាប់យកមកវិញនូវមោទនភាពជាតិនិងការកសាងសង្គមជាតិមួយទំនើប ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ បានតស៊ូឥតងាករេនៅលើសមរភូមិការទូតនិងសាធារណៈមតិ តបទៅនឹងការគំរាមកំហែងលើឯករាជ្យនិងអធិបតេយ្យភាពរបស់កម្ពុជា ដែលផុសចេញក្រោមរូបភាពពហុសណ្ឋានដូចជា ការចិញ្ចឹមបំណងប្រាថ្នានិងចលនាធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ការញុះញង់បំបែកបំបាក់ស្មារតីសាមគ្គីភាពសង្គមជាតិ និងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជាក្រោមស្លាកលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ព្រមទាំងការដាក់សម្ពាធឱ្យកម្ពុជាជ្រើសរើសនិងកាន់ជើងតែមហាអំណាចណាមួយ ដោយបាន៖

- ធ្វើការពន្យល់បកស្រាយជាច្រើនលើក តាមរយៈជំនួបរវាងថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា ជាមួយឥស្សរជនបរទេស ស្ថាប័នអន្តរជាតិ ក៏ដូចជាសហគមន៍ខ្មែរនៅបរទេស អំពីសច្ចភាពនិងលម្អនយោបាយនៅកម្ពុជា និងការចាត់វិធានការច្បាប់នានាក្នុងការការពារឯករាជ្យ អធិបតេយ្យភាព និងនិរន្តរភាពនៃការអភិវឌ្ឍរបស់ខ្លួន។

- បានវាយបកទាន់ពេលវេលានិងបកស្រាយយ៉ាងច្បាស់លាស់ តាមរយៈការចេញសេចក្តីថ្លែងការណ៍បំភ្លឺតបទៅនឹងការលើកឡើងរបស់មជ្ឈដ្ឋាននានាចំនួន១១លើក ដែលមានចេតនាបំភាន់សាធារណៈមតិអំពីធម្មានុរូបរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណើរការប្រជាធិបតេយ្យូបនីយកម្មនៅកម្ពុជា និងបានច្រានចោលយ៉ាងដាច់អហង្ការអំពីព័ត៌មានចចាមអារ៉ាមស្ដីពីការអនុញ្ញាតឱ្យមានវត្តមានយោធាបរទេសនៅកម្ពុជា។

- បានបញ្ជាក់ជំហរខ្លួនយ៉ាងដាច់ណាត់ ក្នុងការការពារឯករាជ្យនិងអធិបតេយ្យភាពរបស់ខ្លួន ដោយមិនដោះដូរជាមួយនឹងជំនួយណាមួយឡើយ។

- បានបន្តនូវអាណត្តិ២ឆ្នាំរបស់ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងបានបញ្ជាក់ច្បាស់លាស់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រកាន់ភ្ជាប់នូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាខ្លួនទទួលរងនូវភាពអយុត្តិធម៌ ក្រោមការអនុវត្តលទ្ធិប្រជាធិបតេយ្យ«ស្តង់ដាពីរ» ពីបណ្តាប្រទេសលោកខាងលិចក៏ដោយ។

**២- កិច្ចការពារជាតិនិងថែរក្សាសន្តិសុខជាតិ**

នៅក្នុងការអនុវត្តកិច្ចការការពារជាតិមាតុភូមិ កងយោធពលខេមរភូមិន្ទបានពុះពារជម្នះគ្រប់ឧបសគ្គរក្សាបាននូវអធិបតេយ្យ បូរណភាពទឹកដីនៅតាមខ្សែបន្ទាត់ព្រំដែននៅគ្រប់កាលៈទេសៈដែលមានការរំលោភបំពានពីប្រទេសជិតខាង និងបានបន្តកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជិតខាង ដោះស្រាយបញ្ហាផ្សេងៗដែលកើតឡើងដោយសន្តិវិធី។ កងយោធពលខេមរភូមិន្ទនៅតែបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាពនិងត្រៀមខ្លួនជាប់ជានិច្ច ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ណាមួយដែលអាចកើតឡើងជាយថាហេតុ ព្រមទាំងបានធ្វើការកែសម្រួលពង្រឹងប្រព័ន្ធការពារជាតិ ដែលជាគ្រឹះដ៏រឹងមាំនៅតាមតំបន់ព្រំដែនគោកនិងបណ្តាកោះមួយចំនួន ដូចជាកសាងនិងជួសជុលប្រព័ន្ធលេណដ្ឋានគ្រប់ប្រភេទ ជំរំជម្រក បន្ទាយកងទ័ព ភូមិឋាន ផ្ទះសម្បែង អណ្តូងទឹក ស្រះទឹក អាងស្តុកទឹក បោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ កសាងផ្លូវយុទ្ធសាស្ត្រយោធាតាមតំបន់ព្រំដែនជាដើម។

ដោយឡែក នៅក្នុងផ្ទៃប្រទេស កងយោធពលខេមរភូមិន្ទបានម្ចាស់ការនិងសហការចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ការពារសន្តិសុខ ស្ថិរភាពនយោបាយ ទប់ស្កាត់និងបង្ក្រាបសកម្មភាពល្មើសគ្រប់ប្រភេទ ព្រមទាំងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលក្នុងការបង្ក្រាបសកម្មភាពបំផ្លិចបំផ្លាញធនធានធម្មជាតិ និងសកម្មភាពគេចពន្ធផងដែរ។ ជាក់ស្តែងបានម្ចាស់ការស្រាវជ្រាវនិងបង្ក្រាបបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម សរុបចំនួន២ ១៥៥លើក ឃាត់ខ្លួនជនសង្ស័យចំនួន៣ ៣៤៦នាក់ ក្នុងនោះរកឃើញជនពាក់ព័ន្ធចំនួន២ ៩៥៩នាក់ និងវត្ថុតាងមួយចំនួន បញ្ជូនទៅតុលាការ (ពិសេសការបង្ក្រាបបទល្មើសធនធានធម្មជាតិ ដោយបានដុតបំផ្លាញចោលរថយន្តបាកុង១១៦គ្រឿង រថយន្តផ្សេងៗ១២គ្រឿង ម៉ូតូកែច្នៃ២៦គ្រឿង ក្បាលត្រាក់ទ័រ២គ្រឿង គោយន្ត៤គ្រឿង ម៉ាស៊ីនរ៉ែ៥គ្រឿង រ៉ឺម៉កម៉ូតូ២គ្រឿង ខ្សែរណារ១៥ខ្សែ បានរឹបអូសឈើគ្រប់ប្រភេទ មធ្យោបាយ សម្ភារៈផ្សេងៗយកមករក្សាទុកនៅអង្គភាពកងរាជអាវុធហត្ថបរិស្ថាន និងនៅតាមក្រុមហ៊ុនក្រោមការគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ព្រមទាំងបានត្រួតពិនិត្យនិងបញ្ឈប់អាជីវកម្មរ៉ែខុសច្បាប់ចំនួន៩៩ទីតាំងផងដែរ)។ ជាមួយគ្នានេះ ក៏បានសហការនិងត្រៀមលក្ខណៈចាត់វិធានការតាមផ្លូវច្បាប់ចំពោះទណ្ឌិត សម រង្ស៊ី ជនក្បត់ជាតិនិងបក្ខពួក ដែលប៉ុនប៉ងធ្វើរដ្ឋប្រហារបំផ្លិចបំផ្លាញសន្តិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនេះ ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងអង្គការចាត់តាំងភេរវកម្មគ្រប់ប្រភេទនិងមុខសញ្ញាដែលប៉ុនប៉ងធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម តាមរយៈការពង្រឹងបណ្តាញព័ត៌មានផ្ទៃក្នុងនិងសហប្រតិបត្តិការអន្តរជាតិ ដោយបានរកឃើញនិងដាក់ចេញវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាប បំបាត់ប្រសិទ្ធភាពជាមុន ធ្វើឱ្យកម្ពុជានៅតែរក្សាបានយ៉ាងរឹងមាំនូវខឿនសន្តិសុខជាតិនិងធានាបាននូវនិរន្តរភាពនៃដំណើរការរបស់ស្ថាប័នជាតិទាំងបី និងប្រក្រតីភាពនៃជីវភាពសង្គមលើគ្រប់វិស័យ។

ជាក់ស្តែងការបង្ក្រាប បំបាត់ប្រសិទ្ធភាព និងទប់ស្កាត់ទាន់ពេលវេលានូវក្រុមចលនា **«កងកម្លាំងខ្មែររំដោះខ្មែរ»** ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់និងករណីបង្កៃគ្រឿងផ្ទុះក្លែងក្លាយក្នុងចេតនាបង្កឱ្យមានវិទ្ធង្សនា។ ការបង្ក្រាបបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា(ពាក់ព័ន្ធការបង្ហោះសារប្រមាថព្រះមហាក្សត្រ និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល គំរាមសម្លាប់ ញុះញង់ឱ្យមានឧក្រិដ្ឋកម្មផ្សេងៗ) សរុបចំនួន៣៩ករណី ឃាត់ខ្លួន៩២នាក់(ជនបរទេស១៩នាក់) ក្នុងនោះ កសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន៣៥នាក់។

ការការពារព្រះរាជសុវត្ថិភាពថ្វាយព្រះមហាក្សត្រនិងសុវត្ថិភាពជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនានា កម្មវិធីបុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍នយោបាយ ជាពិសេសការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ រួមទាំងគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ វិនិយោគ និងទេសចរណ៍ចំនួន ៨ ០០០លើក ត្រូវបានការពារប្រកបដោយសុវត្ថិភាព។

សកម្មភាពបាតុកម្មនិងកូដកម្មគ្រប់រូបភាពប្រមាណ៨៧៧លើក ត្រូវបានគ្រប់គ្រងសភាពការណ៍ ចាត់វិធានការតាមគោលការណ៍នីតិរដ្ឋ និងសម្របសម្រួលដោះស្រាយប្រកបដោយជោគជ័យ។

### ៣- ការងារប្រជាធិបតេយ្យនីយកម្ម

គិតត្រឹមខែសីហា ឆ្នាំ២០១៩ គណបក្សនយោបាយមានចំនួនសរុប៤២គណបក្ស រួមមាន (១)គណបក្សប្រជាជនកម្ពុជា (២)គណបក្សហ្វ៊ុនស៊ិនប៉ិច (៣)គណបក្សកម្ពុជាសេរីឯករាជ្យប្រជាធិបតេយ្យ (៤)គណបក្សកសិករ (៥)គណបក្សវង្គតខេមរៈមហានគរ (៦)គណបក្សចំរើននិយមខ្មែរ (៧)គណបក្សមូលីណាកា (៨)គណបក្សអភិវឌ្ឍន៍កម្ពុជា (៩)គណបក្សភ្លើងទៀន (១០)គណបក្សខ្មែរជួយខ្មែរ (១១)គណបក្សខ្មែរអង្គរ (១២)គណបក្សធម្មាធិបតេយ្យ (១៣)គណបក្សប្រជាធិបតេយ្យខ្មែរ (១៤)គណបក្សស្ត្រីដើម្បីស្ត្រី (១៥)គណបក្សចលនាប្រជាធិបតេយ្យ (១៦)គណបក្សជាតិនិយម (១៧)គណបក្សមហានគរ (១៨)គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (១៩)គណបក្សសង្គមប្រជាធិបតេយ្យ (២០)គណបក្សអំណាចប្រជាពលរដ្ឋ (២១)គណបក្សសិទ្ធិមនុស្ស (២២)គណបក្សខ្មែរឈប់ក្រ (២៣)គណបក្សខ្មែរសាធារណរដ្ឋ (២៤)គណបក្សសង្គមយុត្តិធម៌

(២៥)គណបក្សសញ្ជាតិកម្ពុជា (២៦)គណបក្សនគរប្រជាធិបតេយ្យ (២៧)គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច (២៨)គណបក្សខ្មែរឈ្នះ (២៩)គណបក្សយុវជនកម្ពុជា (៣០)គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (៣១) គណបក្សខ្មែររួបរួមជាតិ (៣២)គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (៣៣)គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (៣៤)គណបក្សសាមគ្គីជាតិខ្មែរ (៣៥)គណបក្សពន្លឺថ្មី (៣៦)គណបក្សមាតុភូមិយើង (៣៧)គណបក្សខ្មែរតែមួយ (៣៨)គណបក្សរស្មីខេមរា (៣៩)គណបក្សធន្ធះខ្មែរ (៤០)គណបក្សប្រជាធិបតេយ្យថ្មី (៤១) គណបក្សខ្មែរក្រោក និង(៤២)គណបក្សបំណងពលរដ្ឋ។

ទន្ទឹមនេះ ក្រសួងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងគោលបំណង (១)ផ្សព្វផ្សាយនិងស្វែងយល់ពីខ្លឹមសារច្បាប់ស្តីពីគណបក្សនយោបាយ (២)ពិនិត្យឡើងវិញនូវស្ថានភាពនៃការអនុវត្តច្បាប់ស្តីគណបក្សនយោបាយ ដើម្បីកំណត់នូវបញ្ហាប្រឈមដែលបានជួបប្រទះ និងស្វែងរកដំណោះស្រាយប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព និង(៣)ពង្រឹងនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែរឹងមាំ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

### ៣.១- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បានធ្វើការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាស្រុក អាណត្តិទី៣ ឆ្នាំ២០១៩ ដែលមានគណបក្សចូលរួម៧ រួមមានគណបក្សប្រជាជនកម្ពុជា គណបក្សយុវជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សខ្មែររួបរួមជាតិ គណបក្សធន្ធះខ្មែរ គណបក្សសញ្ជាតិកម្ពុជា និងគណបក្សខ្មែរសាធារណរដ្ឋ។ គណបក្សនយោបាយទាំង៧ បានធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោតចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩។ ការបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសស្ងប់ស្ងាត់ គ្មានអំពើហិង្សា កាលពីថ្ងៃអាទិត្យទី២៦ ខែឧសភា ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:០០ព្រឹក ដល់ម៉ោង ៣:០០រសៀល នៅតាមរាជធានីខេត្តទាំង២៥ ដែលមានការិយាល័យបោះឆ្នោត**២០៣** និងមានអង្គបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងចំនួន១១ ៥៧២នាក់។

យោងតាមការប្រកាសលទ្ធផលផ្លូវការ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត សរុប៥៥៩នាក់(ស្រី៩៤នាក់) និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សរុប**៣ ៥៥៥នាក់**(ស្រី៦២២នាក់) ហើយមានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន៣ ទទួលបានសំឡេងឆ្នោតនិងអាសនៈក្នុងក្រុមប្រឹក្សា៖

**១- គណបក្សប្រជាជនកម្ពុជា**

- ក្រុមប្រឹក្សារាជធានី ខេត្ត ទទួលបានសំឡេងឆ្នោតសរុប១១ **១២៣សំឡេង** ទទួលបានអាសនៈសរុប**៥៥០អាសនៈ**។

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទទួលបានសំឡេងឆ្នោតសរុប**១១ ១១៣សំឡេង** ទទួលបាន អាសនៈសរុប**៣ ៤៨៤អាសនៈ**។

**២- គណបក្សហ៊្វុនស៊ិនប៉ិច**

- ក្រុមប្រឹក្សារាជធានី ខេត្ត ទទួលបានសំឡេងឆ្នោតសរុប**២២៦សំឡេង** ទទួលបានអាសនៈសរុប**៣អាសនៈ**។

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទទួលបានសំឡេងឆ្នោតសរុប**២១៣សំឡេង** ទទួលបានអាសនៈសរុប**៣៣អាសនៈ**។

**៣- គណបក្សខ្មែររួបរួមជាតិ**

- ក្រុមប្រឹក្សារាជធានី ខេត្ត ទទួលបានសំឡេងឆ្នោតសរុប**១៧៥សំឡេង** ទទួលបានអាសនៈសរុប**៦អាសនៈ**។

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទទួលបានសំឡេងឆ្នោតសរុប១៩៩សំឡេង ទទួលបានអាសនៈសរុប**៣៨អាសនៈ**។

### ៣.២- ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

**ក្នុងឆ្នាំ២០១៩ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ បានបើកកិច្ចប្រជុំចំនួន១៧លើកដើម្បីពិភាក្សាលើ៖**

១- ការចុះសិក្សាដោយផ្ទាល់នៃទស្សនវិស័យស្វ័យសម្រេចរបស់ប្រតិភូគណបក្សសាមីនីមួយៗ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ម៉ម សូណង់ដូ** ប្រធានគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ជាមួយរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រធានលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩។

២- សមិទ្ធផលរបស់ក្រសួងយុត្តិធម៌ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ហួង ជៀមទៀង** ប្រធានគណបក្សខ្មែរសាធារណរដ្ឋ ជាមួយប្រតិភូក្រសួងយុត្តិធម៌ ដឹកនាំដោយឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

៣- សមិទ្ធផលរបស់ក្រសួងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការទប់ស្កាត់នូវរាល់ការផ្សាយពាណិជ្ជកម្មនៃផលិតផលទំនិញនិងសេវាដែលមានលក្ខណៈភូតកុហក ឆបោក ក៏ដូចជាមានលក្ខណៈលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេសយុវជនសេពគ្រឿងស្រវឹង ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ពេជ្រ សូជេដ្ឋា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩។

៤- ទិដ្ឋភាពជាក់ស្តែងចំពោះប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយព័ត៌មានមិនពិត រួមទាំងប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋសេពគ្រឿងស្រវឹង និងបង្កប៉ះពាល់ដល់សន្តិសុខជាតិ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ពេជ្រ សូជេដ្ឋា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងព័ត៌មាន ដឹកនាំដោយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៥- ទិដ្ឋភាពជាក់ស្តែងពាក់ព័ន្ធនឹងការស្វែងរកការងារជូនប្រជាពលរដ្ឋ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩។

៦- សមិទ្ធផលការងារ ព្រមទាំងបញ្ហាប្រឈមមួយចំនួននៃប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើសនានា និងបរិបទផ្សេងៗក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩។

៧- សមិទ្ធផលការងាររបស់ក្រសួងសុខាភិបាល ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ពេជ្រ ស្រស់** ប្រធានគណបក្សយុវជនកម្ពុជា ជាមួយប្រតិភូក្រសួងសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

៨- សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម(ប.ស.ស.) ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ ជាមួយប្រតិភូរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩។

៩- សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សធន្ទះខ្មែរ ជាមួយប្រតិភូក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយ ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។

១០- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០២០-២០២៣ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សធន្ទះខ្មែរ ជាមួយប្រតិភូក្រសួងផែនការ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

១១- សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញនៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សធន្ទះខ្មែរ ជាមួយប្រតិភូអង្គភាពប្រឆាំងអំពើពុករលួយ ដឹកនាំដោយឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

១២- ការធានារបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម ២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩។

១៣- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីសហជីព ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩។

១៤- បរិបទនៃការកំណត់ខណ្ឌសីមា និងដំណើរការនៃការបោះបង្គោលព្រំដែនគោករវាងកម្ពុជានិងវៀតណាម ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **កែម រឹទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដឹកនាំដោយឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

១៥- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **កែម រឹទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២២ខែតុលា ឆ្នាំ២០១៩។

១៦- កិច្ចប្រជុំពិភាក្សាទូទៅដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងធនធានទឹក និងឧតុនិយម ដឹកនាំដោយឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩។

១៧- កិច្ចប្រជុំពិភាក្សាទូទៅដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

ក្រៅពីនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំប្រជុំចំនួន៣លើកៈ

១- កិច្ចប្រជុំប្រចាំឆមាសលើកទី១នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដើម្បីស្តាប់របាយការណ៍សង្ខេបនិងសំណូមពរ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ដឹកនាំកិច្ចប្រជុំប្រចាំឆមាសលើកទី២នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដើម្បីស្តាប់របាយការណ៍សង្ខេបនិងសំណូមពរ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

៣- បិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩។

**៤- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន**

**៤.១- ការងារច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារសរុបចំនួន៨២ ក្នុងនោះច្រកទ្វារកំពង់ផែអន្តរជាតិចំនួន៣ ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន៣ ច្រកទ្វារព្រំដែនអន្តរជាតិចំនួន២៦ ច្រកទ្វារព្រំដែនទ្វេភាគីចំនួន១៤ ច្រកទ្វារតំបន់ព្រំដែនចំនួន២៦ និងច្រកទ្វារកំពង់ផែសមុទ្រចំនួន១០។ នៅក្នុងនោះ រាជរដ្ឋាភិបាលបានសម្រេចដំឡើងកម្រិតច្រកទ្វារតំបន់ព្រំដែនចំនួន៣ ទៅជាច្រកទ្វារអន្តរជាតិ សាងសង់ស្ពានឆ្លងកាត់អូរធម្មជាតិនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ និងសាងសង់ស្ពានដែក១កន្លែងនៅចន្លោះស្ពានថ្មនិងស្ពានផ្លូវរថភ្លើងនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត។

ចំពោះកិច្ចការផ្តល់បណ្ណព្រំដែន ដោយគិតចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានផ្តល់បណ្ណព្រំដែនជូនប្រជាពលរដ្ឋចំនួន១២៥ ៩៥៥ក្បាល និងរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ បានផ្តល់បណ្ណព្រំដែនចំនួន១៦ក្បាល។

**៤.២- ការងារព្រំដែន(ការងារចរចា រុករក និងបោះបង្គោលព្រំដែន)**

កម្ពុជាបាននិងកំពុងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងជំរុញការចរចាជាមួយប្រទេសជិតខាង ដើម្បីរក្សាសន្តិភាពនិងស្ថិរភាពនៅតាមតំបន់ព្រំដែន ក៏ដូចជាការស្វែងរកដំណោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ដោយសន្តិវិធី ឈរលើមូលដ្ឋានច្បាប់អន្តរជាតិនិងគោលការណ៍មិនកែប្រែខ្សែព្រំដែនក្រោយពេលទទួលឯករាជ្យពីអាណានិគមបារាំង សំដៅប្រែក្លាយតំបន់ព្រំដែន ជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍដើម្បីផលប្រយោជន៍រវាងប្រទេសនិងប្រជាជន៖

**១- ជាមួយប្រទេសវៀតណាម**

- បានចុះហត្ថលេខាលើឯកសារច្បាប់ចំនួន២ គឺសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនរវាងកម្ពុជា និងវៀតណាម ដែលទទួលស្គាល់សមិទ្ធផល៨៤% ដែលប្រទេសទាំងពីរសម្រេចបានលើការងារខណ្ឌសីមា និងបោះបង្គោលព្រំដែននៅតំបន់ដែលឯកភាពលើខ្សែព្រំដែន។

- បានបោះបង្គោលព្រំដែនបំពេញបន្ថែមចំនួន១ ៥១១បង្គោល នៅលើតំបន់ដែលបានឯកភាពលើខ្សែព្រំដែន។

- បានធ្វើកំណត់ទូតតវ៉ាប្រឆាំងនឹងសកម្មភាពសាងសង់នានារបស់ប្រទេសវៀតណាម នៅតាមតំបន់ព្រំដែន ដែលប្រទេសទាំងពីរមិនទាន់បានបោះខណ្ឌសីមានិងបោះបង្គោលព្រំដែន។

**២- ជាមួយប្រទេសថៃ**

- បានធ្វើការវាស់វែងនិងរុករកបង្គោលព្រំដែនបារាំង-សៀម បាន២បង្គោលបន្ថែមទៀត ដែលរហូតមកដល់ពេលនេះបានរកឃើញបង្គោលសរុបទាំងអស់ចំនួន៧៣បង្គោល ដែលបោះដោយបារាំង-សៀម ក្នុងនោះភាគីទាំងពីរបានឯកភាពទទួលស្គាល់ចំនួ៤៥បង្គោល។

- បានសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានឆ្លងព្រំដែនស្ទឹងបត់(ខេត្តបន្ទាយមានជ័យ) និងបានណងអៀន(ខេត្តស្រះកែវ) និងបានភ្ជាប់ផ្លូវរថភ្លើងរវាងប្រទេសទាំងពីរកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

- កំពុងពន្លឿនដំណើរការបើកច្រកទ្វារព្រំដែនអន្តរជាតិចំនួន៤ផ្សេងទៀត ដើម្បីជំរុញការតភ្ជាប់រវាងប្រជាជននិងប្រជាជន ការដឹកជញ្ជូនទំនិញ និងពាណិជ្ជកម្មជាដើម។

**៣- ជាមួយប្រទេសឡាវ**

- បាននិងកំពុងជំរុញការចរចាលើសេចក្ដីព្រាងបែបបទបច្ចេកទេស(TOR)ស្ដីពីការស្នើអ្នកឯកទេសបារាំងខាងផែនទី មកជួយផ្នែកបច្ចេកទេសលើការគូសចម្លងខ្សែព្រំដែនពីផែនទីបោន(GSI) ខ្នាត១/១០០ ០០០ មកលើផែនទីUTM ខ្នាត១/៥០ ០០០ សម្រាប់កំណត់ខ្សែព្រំដែនដែលនៅសេសសល់ទាំង១៤%។

- បានធ្វើកំណត់ទូតទៅភាគីឡាវ គូសបញ្ជាក់អំពីជំហររបស់កម្ពុជាចំពោះតំបន់អូរតាង៉ាវ ដែលស្ថិតនៅក្នុងទឹកដីក្រោមអធិបតេយ្យភាពរបស់កម្ពុជា ដោយផ្អែកលើផែនទីដែលគណៈកម្មការទទួលបន្ទុកកិច្ចការព្រំដែនប្រទេសទាំងពីរបានទទួលយកកាលពីឆ្នាំ១៩៩៨។

## ៥- ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំមានសុវត្ថិភាព»

ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព បាននិងកំពុងជំរុញឱ្យក្លាយទៅជាចលនាជាតិតែមួយ ដើម្បីធ្វើឱ្យសហគមន៍ ភូមិ ឃុំ ទទួលបាននូវសុខសន្តិភាព សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយល្អ ប្រជាពលរដ្ឋរស់នៅនិងប្រកបរបរចញ្ចឹមជីវិតមានភាពកក់ក្តៅទាំងផ្លូវកាយនិងផ្លូវចិត្ត។

រយៈពេល១ឆ្នាំកន្លងទៅនេះ ទាំងការធ្វើវេទិកាសាធារណៈ ទាំងការផ្សព្វផ្សាយគោលនយោបាយនានាត្រូវបានជំរុញកាន់តែសស្រាក់សស្រាំរហូតដល់មូលដ្ឋាននិងខ្នងផ្ទះប្រជាពលរដ្ឋ ដែលធ្វើឱ្យពួកគាត់ទទួលបានព័ត៌មានកាន់តែជាក់លាក់អំពីការផ្តល់សេវាសាធារណៈ សេវាសន្តិសុខ ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងឆ្លើយតបនិងដោះស្រាយបានទាន់ពេលវេលានូវសំណើ សំណូមពរ និងបញ្ហាប្រឈមនានា។ ជាមួយគ្នានេះ ការកសាងចលនាប្រជាការពារក្រោមការដឹកនាំរបស់អាជ្ញាធរមូលដ្ឋាន ដោយមាននគរបាលជាតិជាកម្លាំងស្នូល បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម តាមរយៈការធ្វើសកម្មភាពល្បាតយាមកាម ការចូលរួមសម្រួលចរាចរណ៍ និងសណ្តាប់ធ្នាប់នៅតាមទីសាធារណៈ ការជួយសង្គ្រោះប្រជាពលរដ្ឋក្នុងពេលជួបគ្រោះអាសន្ន គ្រោះអគ្គិភ័យ គ្រោះធម្មជាតិ។ល។

ផ្អែកតាមលទ្ធផលនៃការធ្វើប្រជាមតិនាឆ្នាំ២០១៩ឃើញថា ប្រជាពលរដ្ឋមានការជឿជាក់មកលើកម្លាំងមានសមត្ថកិច្ចក្នុងអត្រា៨៤,៣% និងមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងភូមិ ឃុំ សង្កាត់របស់ខ្លួនក្នុងអត្រា៨១,១%។

## ៦- លទ្ធផលនៃការបង្ក្រាបបទល្មើស រក្សាសុវត្ថិភាពសង្គម

បទល្មើសព្រហ្មទណ្ឌកើតឡើង៣ ០៧៧/២ ៩៥៧លើក កើន១២០លើក(ឧក្រិដ្ឋ៦៧៤/៦៦៨លើក កើន៦លើក និងមជ្ឈិម២ ៤០៣/២ ២៨៩លើក កើន១១៤លើក)។ បើកកិច្ចប្រតិបត្តិការបង្ក្រាប២ ៦៨៧ករណីស្មើនឹង៨៧%នៃបទល្មើសដែលកើតឡើង ឃាត់ខ្លួនជនល្មើស៣ ៩២៩នាក់(ឧក្រិដ្ឋ៥៦៧ករណី/៩៦០នាក់ និងមជ្ឈិម២ ១២០ករណី/២ ៩៦៩នាក់) ក្នុងចំណោមជនល្មើសទាំងនេះ មាន១ ៤៤៦នាក់ជាប់ពាក់ព័ន្ធប្រើប្រាស់សារធាតុញៀន។ ដោយឡែក អនុវត្តដីកាឃាត់ខ្លួនជនសង្ស័យ២៨៨នាក់/២៩០ដីកា។ វត្ថុតាងនិងជនល្មើសត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្តអនុវត្តតាមនីតិវិធីច្បាប់។

បង្ក្រាបបទល្មើសជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ១៥០ករណី ឃាត់ខ្លួនជនល្មើស១៩៦នាក់ (ស្រី៦៦នាក់)(បញ្ជូនទៅតុលាការ) រំដោះជនរងគ្រោះ៤០២នាក់(បញ្ជូនទៅសង្គមកិច្ច១៨២នាក់ អង្គការ១នាក់ និងបញ្ជូនទៅអាណាព្យាបាលវិញ ២១៩នាក់)។

បង្ក្រាបក្មេងទំនើង១ ០០៣ករណី ឃាត់ខ្លួន២ ១០៩នាក់ ក្នុងនោះអនុវត្តវិធានការរដ្ឋបាល៤៧៩ករណី/១ ២២៤នាក់(ធ្វើកិច្ចសន្យាអប់រំ៤៥៨ករណី/១ ២០២នាក់ និងបញ្ជូនទៅមណ្ឌលអប់រំ២១ករណី/២២នាក់) និងអនុវត្តវិធានការច្បាប់ ៥២៤ករណី/៨៨៥នាក់ កសាងសំណុំរឿងបញ្ជូនទៅតុលាការ (ពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ១៦៦ករណី/២៧០នាក់ និងពាក់ព័ន្ធបទល្មើសគ្រឿងញៀន ៣៥៨ករណី/៦១៥នាក់)។

បង្ក្រាបល្បែងស៊ីសង៨០៧ករណី ឃាត់ខ្លួន២ ៤៨៥នាក់(ស្រី៩៤៨នាក់) ក្នុងនោះបញ្ជូនទៅតុលាការ ៥៣៥នាក់។

បង្ក្រាបបទល្មើសសេដ្ឋកិច្ច៣៨១លើក (ម្ចាស់ការបង្ក្រាប៥៤លើក) ឃាត់ខ្លួន៧៤នាក់ ក្នុងនោះបញ្ជូនទៅតុលាការ១៧នាក់។

បង្ក្រាបបទល្មើសគ្រឿងញៀន៧ ០៧៧ករណី ឃាត់ខ្លួន១៤ ៥៧៨នាក់ រឹបអូសបានសារធាតុញៀនសរុប៣៧០,០៤គីឡូក្រាម កញ្ឆាក្រៀម៣៥,៤១គីឡូក្រាម និងដុតបំផ្លាញដើមកញ្ឆាចំនួន៣៨ ៧៨០ដើម។

សម្រាប់ឆ្នាំ២០១៩ បង្ក្រាបបទល្មើសគ្រឿងញៀន៩ ៨០៦ករណី ចាប់ខ្លួនជនសង្ស័យបាន២០ ៤៩០នាក់ រឹបអូសសារធាតុញៀនបាន១៥០គីឡូក្រាម កាប់បំផ្លាញកញ្ឆាស្រស់បាន៩៨ ៥៩៩ដើម។

### ៧- សភាពការណ៍និងកិច្ចប្រតិបត្តិការរក្សាសណ្តាប់ធ្នាប់សាធារណៈ

គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩ គ្រោះថ្នាក់សង្គមកើតឡើងចំនួន៧ ៩៨៥លើក ក្នុងនោះ គ្រោះថ្នាក់ចរាចរណ៍៣ ៩២៥/៣ ៣៩០លើក (ស្លាប់ ១ ៨៩៦/១ ៩៣៦នាក់ របួស៥ ៧៨៤/៥ ១៩២នាក់) អាវុធជាតិផ្ទុះ៤១លើក(ស្លាប់១៩នាក់ របួស៤២នាក់) អគ្គិភ័យ ៦៦៩លើក(ស្លាប់១៨នាក់ របួស៩០នាក់ ឆេះផ្ទះ ៥៩៨ខ្នង តូប៣១៦)។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើនេះ ក្រសួងមហាផ្ទៃបានប្រមូលផ្តុំចាត់វិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះដូចតទៅៈ

- ការងារចរាចរណ៍ : ជំរុញ រឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅទូទាំងប្រទេស ដោយយកចិត្តទុកដាក់ពង្រឹងទាំងវិធានការត្រួតពិនិត្យតាមដងផ្លូវ ការអប់រំផ្សព្វផ្សាយច្បាប់ និងការលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអនុវត្តច្បាប់។ កត់សម្គាល់ : បានត្រួតពិនិត្យយានយន្តសរុបចំនួន១ ៦១១ ៦៨៨គ្រឿង ក្នុងនោះរកឃើញយានយន្តល្មើសចំនួន៣៩៨ ៥៤៥គ្រឿង(ផាកពិន័យ ២៩៨ ២២៩គ្រឿង និងអប់រំ១០០ ៣១៦គ្រឿង)។

- ការងារអគ្គិភ័យ : ទន្ទឹមនឹងការខិតខំពង្រឹងកិច្ចប្រតិបត្តិការក្នុងការជួយសង្គ្រោះហេតុការណ៍អគ្គិភ័យ ការផ្សព្វផ្សាយអប់រំ លើកកម្ពស់ការប្រុងប្រយ័ត្ន និងការណែនាំវិធានការបង្ការ ទប់ស្កាត់អគ្គិភ័យ ក៏ត្រូវបានអនុវត្តដូចភ្លៀងរលឹម កាន់តែទូលំទូលាយក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋ។ ជាមួយនេះ ក៏បានបង្កើតឱ្យមានក្រុមពន្លត់អគ្គិភ័យស្ម័គ្រចិត្តនៅតាមមូលដ្ឋានដើម្បីរួមចំណែកក្នុងការបង្ការ ទប់ស្កាត់ និងជួយអន្តរាគមន៍ពន្លត់ សង្គ្រោះបឋមផងដែរ។

- ការងារគ្រប់គ្រងអាវុធជាតិផ្ទុះ : បានយកចិត្តទុកដាក់ពង្រឹងជាប្រចាំ ទាំងលើការត្រួតពិនិត្យ ការចុះបញ្ជីគ្រប់គ្រង និងការផ្សព្វផ្សាយអប់រំ។ ជាក់ស្តែង បានផ្តល់បណ្ណប្រើប្រាស់អាវុធថ្មីចំនួន**២ ០២៤បណ្ណ**(ខ្លី១ ៥៤៨បណ្ណ វែង៤៧៦បណ្ណ) ប្តូរបណ្ណអាវុធចំនួន**៤ ៨៨០បណ្ណ**(ខ្លី៤ ០៤៩បណ្ណ វែង៨៣១បណ្ណ) សហការដុតបំផ្លាញចោលសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៤៤ ៧៤០គ្រាប់** ប្រគល់អាវុធខូចគុណភាពចំនួន**១១ ៩១៥ដើម** ឱ្យទៅមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា និងធ្វើការផ្សព្វផ្សាយអប់រំអំពីសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន**៣ ២៦២លើក** (មានអ្នកចូលរួមសរុប**២៦៣ ១១០នាក់**)។

### ៨- ការងារគ្រប់គ្រងពន្ធនាគារ

- គ្រប់មណ្ឌលកែប្រែនិងពន្ធនាគាររាជធានី ខេត្ត ត្រូវបានពង្រឹងការការពារសន្តិសុខជាប្រចាំ តាមរយៈការត្រួតពិនិត្យឆែកឆេររាង្គកាយ សម្ភារៈនិងបន្ទប់ឃុំឃាំងរបស់ជនជាប់ឃុំ ក្នុងនោះ រកឃើញសារធាតុញៀន**១កញ្ចប់ធំ**និង**២០កញ្ចប់តូច** រួមទាំងសម្ភារៈហាមឃាត់មួយចំនួនទៀត។ ជាមួយនឹងការត្រួតពិនិត្យលើផ្នែកទាំងនេះ ក៏មានការរៀបចំកែលម្អរបៀបរបបការងារជនជាប់ឃុំ ការវាយតម្លៃធ្វើចំណាត់ថ្នាក់សន្តិសុខ ការអនុវត្តច្បាប់ស្តីពីពន្ធនាគារ និងនីតិវិធីពន្ធនាគារផងដែរ សំដៅធានាការពារឱ្យបានរាល់សកម្មភាពផ្ទុយពីបែបបទកំណត់ផ្ទៃក្នុងពន្ធនាគារ។

- ជនជាប់ឃុំចំនួន**៣ ៧៥០នាក់**(**ស្រី៣៦៣នាក់**) ទទួលបានការបណ្តុះបណ្តាលលើជំនាញវិជ្ជាជីវៈដូចជា កាត់ដេរ កាត់សក់ សម្អាងការ ប្រើប្រាស់និងជួសជុលកុំព្យូទ័រ ម៉ូតូ យានយន្តនិងបរិក្ខារត្រជាក់ បច្ចេកទេសកសិកម្ម សិប្បកម្ម សំណង់ស៊ីវិល អេឡិចត្រូនិក ជំនាញផលិតកម្ម ... ក្នុងនោះមាន**៤៧៣នាក់**(**ស្រី៥៦នាក់**) ទទួលបាន វិញ្ញាបនបត្របញ្ជាក់ការសិក្សា។ ក្រៅពីការបណ្តុះបណ្តាលមុខជំនាញ ជនជាប់ឃុំក៏ត្រូវបានបង្រៀនពីបទបញ្ជាផ្ទៃក្នុង អក្ខរកម្ម ថ្នាក់បឋមសិក្សា ភាសាបរទេស បំណិនជីវិត សីលធម៌ អប់រំផ្សេងៗ បញ្ចេញឱ្យលេងកីឡា ហាត់ប្រាណ និងចូលរៀនអានសៀវភៅក្នុងបណ្ណាល័យផងដែរ។

- ពិនិត្យនិងព្យាបាលជូនជនជាប់ឃុំសរុបចំនួន**១៧៥ ៥៦៥ករណី** ក្នុងនោះ នៅប៉ុស្តិ៍សុខភាពពន្ធនាគារ **១៧៣ ១៨០ករណី** និងបញ្ជូនទៅព្យាបាលនិងសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ**២ ៣៨៣ករណី**។

- ដោយការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃនិងតាមរយៈកិច្ចសហប្រតិបត្តិការនិងការជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មពីដៃគូអភិវឌ្ឍនានា អគារ ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈបច្ចេកទេសនៅតាមមណ្ឌលអប់រំកែប្រែនិងពន្ធនាគាររាជធានី ខេត្ត ត្រូវបានសាងសង់ ជួសជុលកែលម្អ និងបំពាក់បន្ថែមជាបន្តបន្ទាប់ ក្រោមគម្រោងប្រើប្រាស់ថវិការដ្ឋចំនួន៤គម្រោង គម្រោងផ្ទាល់របស់ក្រសួង៤គម្រោង គម្រោងវិនិយោគជាមួយវិស័យឯកជន**១គម្រោង** និងគម្រោងសហការជាមួយដៃគូនានា**១២គម្រោង** ដែលក្នុងនោះ មាន**១០គម្រោង**ត្រូវបានបញ្ចប់ជាស្ថាពរនិង១២គម្រោងទៀតកំពុងដំណើរការ។

- ជាការកត់សម្គាល់ក្នុងរយៈពេល១ឆ្នាំនេះ ស្ថានភាពចំនួនជនជាប់ឃុំមានការប្រែប្រួល ជាអាទិ៍ចាប់ចូលថ្មី **២០ ០២៥នាក់**(ស្រី១ ៥៧៥នាក់) ដោះលែងចំនួន**១៥ ៤១០នាក់**(ស្រី១ ៦៧៤នាក់) ស្លាប់**១២០នាក់** (ស្រី៨នាក់) និងរត់រួច**៥នាក់**។

## ៩- ការងារអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម

ដើម្បីអនុវត្តសម្រេចបានជោគជ័យនូវផែនការយុទ្ធសាស្ត្រជាតិរយៈពេល១០ឆ្នាំ(២០១៧-២០២៦) ស្តីពីអត្តសញ្ញាណកម្ម ដែលជាក្របខ័ណ្ឌគោលនយោបាយរយៈពេលវែងសម្រាប់ធានានិរន្តរភាពប្រព័ន្ធការងារអត្តសញ្ញាណកម្ម និងឆ្លើយតបនូវកាតព្វកិច្ចក្នុងក្របខ័ណ្ឌអន្តរជាតិ ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ជំរុញការកសាងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ការបណ្តុះបណ្តាលធនធានមនុស្ស ការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ ការពង្រីកវិសាលភាពទីកន្លែងផ្តល់សេវា ការផ្គត់ផ្គង់ឧបករណ៍សម្ភារៈ ប្រព័ន្ធបច្ចេកវិទ្យាទំនើប ការកែសម្រួលយន្តការនានា ដើម្បីដោះស្រាយសំណើ សំណូមពរ ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ។

ក្រសួងមហាផ្ទៃកំពុងខិតខំជំរុញបញ្ចប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីៗ ពិសេសសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងពិនិត្យឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធការងារអត្តសញ្ញាណកម្ម។ ជាមួយនេះ ក្រសួងក៏បានដាក់ចេញប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការលះបង់សញ្ជាតិខ្មែរ។

| **៩.១- ការងារអត្រានុកូលដ្ឋាន** | |
|---|---|
| ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ | **២២ ៧៩២បញ្ជី ស្មើនឹង២៥៦ ៩២៦នាក់** (ស្រី១២៧ ៩៦២នាក់) |

| | |
|---|---|
| ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ | **៣ ៤៧៩ច្បាប់ ស្មើនឹង១៧ ០០៤សន្លឹក** |
| សេចក្តីសម្រេចស្តីពីការកែតម្រូវនិងធ្វើមោឃភាពទិន្នន័យនៃចុះបញ្ជីអត្រានុកូលដ្ឋាន | **១៨ ៧២៦ច្បាប់** |
| ចេញសេចក្តីសម្រេចស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរនិងជនបរទេស | **២ ០៤៦ច្បាប់និង៣២សញ្ញាតិ** |

ផ្តល់សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន៨ ៦២៩ក្បាលនិងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន **៩៤៣ ៥០០សន្លឹក** ជូន២៥រាជធានី ខេត្ត

**៩.២- ការងារគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ**

- គិតពីខែសីហា ឆ្នាំ២០០២ដល់ដំណាច់ខែសីហា ឆ្នាំ២០១៩ ប្រជាពលរដ្ឋដែលបានចុះបញ្ជីស្ថិតិមានចំនួន **៣ ៥៩៣ ៤៧៨គ្រួសារ** ស្មើនឹង**១៥ ៥៨០ ៤១០នាក់**(ស្រី៧ ៩៨២ ៥២៤នាក់)
- បញ្ចូលទិន្នន័យចុះបញ្ជីក្នុងប្រព័ន្ធកុំព្យូទ័រ(ខេត្តកែបនិងខេត្តកំពត) រួមមាន សៀវភៅស្នាក់នៅចំនួន**៩៩៧ក្បាល ស្មើនឹង៣ ៩៥៦នាក់**(ស្រី១ ៩៣៤នាក់)និងសៀវភៅគ្រួសារចំនួន**៨៦៦ក្បាល ស្មើនឹង៣ ៥៨៦នាក់**(ស្រី ១ ៧៣២នាក់)
- ផ្តល់សៀវភៅស្នាក់នៅថ្មីជូនដល់ប្រជាពលរដ្ឋចំនួន**៨៥ ៧៨៣ក្បាល** ទុតិយតា**៥១ ៨៥៩ក្បាល** និងសៀវភៅគ្រួសារថ្មីចំនួន**៥៤ ២៩៤ក្បាល** ទុតិយតា**៣៣ ៩៩១ក្បាល**
- ផ្តល់សៀវភៅស្នាក់នៅថ្មីជូនដល់ប្រជាពលរដ្ឋចំនួន**៨៥ ៧៨៣ក្បាល** ទុតិយតា**៥១ ៨៥៩ក្បាល**និងសៀវភៅគ្រួសារថ្មីចំនួន**៥៤ ២៩៤ក្បាល** ទុតិយតា**៣៣ ៩៩១ក្បាល**
- បើកផ្តល់ឯកសារស្ថិតិប្រជាពលរដ្ឋជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រួមមានបញ្ជីស្នាក់នៅចំនួន**៥៦០ក្បាល** បញ្ជីគ្រួសារ**៧៩ក្បាល** សៀវភៅស្នាក់នៅ**២៤៤ ២៩៥ក្បាល** សៀវភៅគ្រួសារ**៥១ ៦៣១ក្បាល** ពាក្យសុំផ្លាស់ប្តូរទីលំនៅ**៥០០ក្បាល** លិខិតផ្លាស់ប្តូរទីលំនៅ**៣០០ក្បាល** បញ្ជីចុះឈ្មោះស្នាក់នៅបណ្តោះអាសន្ន**១៩០ក្បាល** និងលិខិតអនុញ្ញាតស្នាក់នៅបណ្តោះអាសន្ន**១៧០ក្បាល**
- ទទួលពលរដ្ឋខ្មែរធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាម៉េរិក២លើក ចំនួន**៧៣នាក់**(ស្រី១នាក់)

**៩.៣- ការងារផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែន**

- គិតចាប់ពីថ្ងៃទី១ខែកញ្ញា ឆ្នាំ២០០២ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ប្រមូលទិន្នន័យស្នើសុំ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរចំនួន**៤៥៧ ០៨៦នាក់** រួមមានទិន្នន័យបានការ**៤៣០ ១៧២នាក់** ទិន្នន័យខូច២ ០៤០នាក់ និងទិន្នន័យស្នួនក្រយៅដៃ**២៨ ៩៥៤នាក់** ក្នុងនោះបោះពុម្ពជូនប្រជាពលរដ្ឋចំនួន**៤១៧ ៦៣១សន្លឹក។**
- គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ផ្តល់លិខិតឆ្លងដែនធម្មតាជូនប្រជាពលរដ្ឋចំនួន**៣៨៨ ៥៥៨ក្បាល** និងផ្តល់លិខិតធ្វើដំណើរជូនពលករកម្ពុជាធ្វើការនៅបរទេសចំនួន **៦០ ៨១៦ក្បាល។**

**៩.៤- ការងារសញ្ជាតិ**

| **ករណីស្នើសុំចូលសញ្ជាតិខ្មែរតាមលក្ខខណ្ឌនានា និងករណីលះបង់សញ្ជាតិ** | | | |
|---|---|---|---|
| ក្របខ័ណ្ឌវិនិយោគ **៩០ករណី ស្មើនឹង៩៣នាក់**(ស្រី១៣នាក់) | ស្នាក់នៅចាប់ពី៧ឆ្នាំឡើងទៅ **២៧ករណី ស្មើនឹង២៨នាក់**(ស្រី ៨នាក់) | ទាមទារសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍**១៥ករណី ស្មើនឹង១៥នាក់** | ករណីលះបង់សញ្ជាតិ **២០ករណី ស្មើនឹង** |

| | | | |
|---|---|---|---|
| | | (ស្រី៧នាក់) | **២០នាក់**(ស្រី១៤ នាក់) |

| | |
|---|---|
| **ព្រះរាជក្រឹត្យ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរសរុបចំនួន៥៣៣ករណី ស្មើនឹង៥៣៩នាក់** | |
| ឆ្លងនីតិវិធីតាមរយៈក្រសួងមហាផ្ទៃ<br>**៥៥ករណី ស្មើនឹង៦១នាក់** | ធន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល<br>**៤៧៨ករណី ស្មើនឹង៤៧៨នាក់** |

**១០- ការងារអន្តោប្រវេសន៍**

**១០.១- ការគ្រប់គ្រងអ្នកដំណើរចេញ ចូលព្រះរាជាណាចក្រកម្ពុជា**

| | | | | |
|---|---|---|---|---|
| **ជនបរទេសធ្វើដំណើរចូល-ចេញ** | | | | |
| ជនបរទេសចូល | | ជនបរទេសចេញ | | ជនបរទេសចូល លេងល្បែងកាស៊ីណូ |
| អន្តរជាតិ<br>**៥ ៤៦២ ៤០៣នាក់ ២០០សញ្ជាតិ** | ក្របខ័ណ្ឌតំបន់<br>**៤០ ៣៤១នាក់ ៣សញ្ជាតិ** | អន្តរជាតិ<br>**៥ ៦៧៦ ០៧៣នាក់ ២០០សញ្ជាតិ** | ក្របខ័ណ្ឌតំបន់<br>**១០៣ ៣០៩នាក់ ៣សញ្ជាតិ** | តំបន់ព្រំដែន<br>**១ ២៥៥ ៣៧៣នាក់ ៥០សញ្ជាតិ** |
| **ពលរដ្ឋខ្មែរធ្វើដំណើរចេញ-ចូលមកវិញ** | | | | |
| ពលរដ្ឋខ្មែរចេញ | | ពលរដ្ឋខ្មែរចូល | | ពលរដ្ឋខ្មែរខុសច្បាប់ បញ្ជូនមកវិញ |
| អន្តរជាតិ<br>**២ ១៩៣ ៤០៥នាក់** | ក្របខ័ណ្ឌតំបន់<br>**៦ ១៣៧ ៧១៧នាក់** | អន្តរជាតិ<br>**១ ៧០៨ ៤៤២នាក់** | ក្របខ័ណ្ឌតំបន់<br>**៧ ១២៥ ១៤៥នាក់** | **១៨៧ ៣៧៥នាក់ (ស្រី៥ ៨២៧នាក់ កុមារ១ ៨៥៤នាក់) និងពលករ៩៦ ១៩០ នាក់** |

**១០.២- ការងារគ្រប់គ្រងជនបរទេស**

| | | |
|---|---|---|
| **អំពីជនបរទេសអន្តោប្រវេសន៍** | | |
| ជំរឿនរកឃើញ**៤៩ ៦០៣គ្រួសារ ស្មើនឹង១៨២ ៦៧៣នាក់**(ស្រី៨២ ៤៨៨នាក់) | | |
| ប្រើប្រាស់ឯកសាររដ្ឋបាលមិនប្រក្រតី<br>**២០ ២១៨គ្រួសារ ស្មើនឹង៧៣ ៣៩៧នាក់**<br>(ស្រី៣៥ ៨៨៨នាក់) | អ្នកស្នាក់នៅយូរគ្មានឯកសារ<br>**២៩ ៣៨៥គ្រួសារ ស្មើនឹង១០៩ ២៧៦នាក់**<br>(ស្រី៤៦ ៦០០នាក់) | |
| **អនុលោមតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល**<br>**អនុក្រឹត្យលេខ១២៩អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ២០១៧** | | |
| ដកហូតឯកសាររដ្ឋបាល មិនប្រក្រតី**៣៧ ៤៣៦ច្បាប់ ស្មើនឹង២០ ១០៧គ្រួសារ មនុស្ស៦៩ ៩៥៧នាក់** | ទទួលពាក្យសុំប្រកាសទទួល ស្គាល់ជាជនបរទេសអន្តោប្រវេសន៍ **៣២ ៦២៧គ្រួសារ** | ទទួលពាក្យសុំច្បាប់ស្នាក់នៅ អចិន្ត្រៃយ៍**២៨ ៩៤៥គ្រួសារ មនុស្ស៦៣ ៥៨៧នាក់** (ស្រី ៣០ ៥៧៥នាក់) ក្នុងនោះ |

| | | |
|---|---|---|
| (ស្រី៣៣ ៨៧៦នាក់) | **មនុស្ស៧២ ១៣៤នាក់** (ស្រី៣៥ ១២៧នាក់) ក្នុងនោះក្រសួងប្រកាសទទួលស្គាល់**១៨ ២៧២ គ្រួសារ មនុស្ស៥៥ ៥១២នាក់** (ស្រី២៦ ១៦៩០នាក់) | ក្រសួងបានចេញបណ្ណអចិន្ត្រៃយ៍ **១៣ ៥១៤គ្រួសារ មនុស្ស២៥ ២៣៦នាក់** (ស្រី១១ ១៩០៧នាក់) |
| **អំពីជនបរទេសមិនមែនអន្តោប្រវេសន៍** | | |
| ផ្តល់ទិដ្ឋាការចូល **៣ ០៩១ ០៦០នាក់** | ផ្តល់ទិដ្ឋាការចេញ **១១ ៤៨៤នាក់** | ពន្យារទិដ្ឋាការស្នាក់នៅ **៧០៦ ៨២៩នាក់** |
| ✡✡- គិតមកដល់បច្ចុប្បន្ននេះ ជនបរទេសដែលទទួលបានឋានៈជាជនភៀសខ្លួនចំនួន**៦៤នាក់**(ស្រី១៥នាក់) **៨សញ្ជាតិ** អ្នកសុំសិទ្ធិជ្រកកោនចំនួន**២១នាក់**(ស្រី១១នាក់) **៦សញ្ជាតិ** និងជនជាតិម៉ុងតាញ៉ានៅសល់ចំនួន ២៧នាក់(ស្រី២នាក់)។ ក្នុងរយៈពេលមួយឆ្នាំនេះ ក្រសួងបានអនុវត្តនីតិវិធីលើករណីស្នើសុំឋានៈជាជនភៀសខ្លួនចំនួន**៣នាក់**(ស្រី២នាក់) និងករណីស្នើសុំសិទ្ធិជ្រកកោននៅកម្ពុជាចំនួន**១៣នាក់**(ស្រី៩នាក់)។ | | |

## ទី២- បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

ក្នុងឆ្នាំ២០១៩ ក្រសួងពាណិជ្ជកម្មបានធ្វើការចុះបញ្ជីពាណិជ្ជសញ្ញា**៣ ៨៤១ម៉ាក** បើធៀបនឹងឆ្នាំមុនមាន **៣ ៧៦១ម៉ាក** កើនឡើង**២,១៣%**។ ក្នុងរយៈពេល១១ខែ ឆ្នាំ២០១៩ ក្រសួងបានចុះបញ្ជីក្រុមហ៊ុនថ្មី ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសបាន**១៦ ២០៨ក្រុមហ៊ុន**(ចុះបញ្ជីដោយដៃ៧៩៥ក្រុមហ៊ុន) បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុនមាន**១៣ ១១៩ក្រុមហ៊ុន** កើនឡើង**២៣,៥៤%** និងបានលុបឈ្មោះក្រុមហ៊ុន(តាមការស្នើសុំ)**១២៥ក្រុមហ៊ុន** បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុនមាន**១២៧ក្រុមហ៊ុន** ថយចុះ **១,២៧%**។

ចាប់ពីឆ្នាំ១៩៨៨ មកដល់ឆ្នាំ២០១៩ ក្រសួងពាណិជ្ជកម្មបានចុះបញ្ជីក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសបាន**៧៤ ៩៥៧ក្រុមហ៊ុន** ហើយបានលុបឈ្មោះក្រុមហ៊ុន**២ ៣០៩ ក្រុមហ៊ុន**។

## ទី៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

### ១- ការងារការទូត

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ កម្ពុជាបានផ្សារភ្ជាប់ទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសចំនួន១៧៣ ប្រទេស និងមាន(១)ស្ថានតំណាងកម្ពុជាប្រចាំនៅបរទេសចំនួន៦៣(ស្ថានឯកអគ្គរាជទូតចំនួន២៧ ស្ថានអគ្គកុងស៊ុលចំនួន១១ ស្ថានកុងស៊ុលកិត្តិយសចំនួន២១ និងស្ថានបេសកកម្មអចិន្ត្រៃយ៍ចំនួន៤ (២)ស្ថានបេសកកម្មបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅកម្ពុជាមានចំនួន៤៩(ស្ថានឯកអគ្គរាជទូត/រដ្ឋទូតចំនួន៣២ ស្ថានអគ្គកុងស៊ុលចំនួន៣ ស្ថានកុងស៊ុលកិត្តិយសចំនួន១០ និងការិយាល័យកុងស៊ុលចំនួន៤) និង(៣)ស្ថានបេសកកម្មបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជាដែលមាននិវេសនដ្ឋាននៅបរទេសមានចំនួន៩១។

រាជរដ្ឋាភិបាលបានបន្តពង្រឹងយន្តការទ្វេភាគីដែលមានស្រាប់ និងរិះរកយន្តការថ្មីៗ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្តលើគ្រប់វិស័យ ជាអាទិ៍ មានគណៈកម្មការចម្រុះទ្វេភាគីសរុបចំនួន ១៣ គណៈកម្មការអន្តររដ្ឋាភិបាលចំនួន២ និងបានបង្កើតកិច្ចពិគ្រោះយោបល់នយោបាយបន្ថែមជាមួយប្រទេសចំនួន១១ (សរុបចំនួន ២៩)។ ក្រសួងការបរទេសក៏កំពុងចរចាបង្កើតយន្តការពិគ្រោះយោបល់នយោបាយនេះជាមួយប្រទេសជាង២០បន្ថែមទៀតផងដែរ។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលរក្សាបាននូវទំនាក់ទំនងល្អជាមួយប្រទេសនានា តាមរយៈការពង្រឹងការផ្លាស់ប្តូរទស្សនកិច្ចផ្លូវការនិងទស្សនកិច្ចការងាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា នៅបរទេសជាង៤០លើក ដើម្បីពង្រឹងទំនុកចិត្តទៅវិញទៅមកផ្នែកនយោបាយ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជ-កម្ម វិនិយោគ ទេសចរណ៍ អប់រំ និងវប្បធម៌ជាដើម។

## ២- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ

សប្បុរសជនក្នុងនិងក្រៅប្រទេស ដែលបានចូលរួមថវិកានិងសម្ភារៈក្នុងការកសាង អភិវឌ្ឍមូលដ្ឋានលើគ្រប់វិស័យ ទាំងផ្នែកពុទ្ធចក្រនិងអាណាចក្រ ក្នុងការកសាងរចនាសម្ព័ន្ធនានា ដូចជាផ្លូវ ស្ពាន ប្រព័ន្ធលូទឹក ប្រព័ន្ធទឹកស្អាត ធារាសាស្ត្រ ទំនប់ប្រឡាយ មន្ទីរពេទ្យ មណ្ឌលសុខភាព កសាងអន្តេវាសិកដ្ឋាន អគារសិក្សា សាលារៀនគ្រប់កម្រិត មណ្ឌលកុមារកំព្រា វត្តអារាម ព្រះវិហារ កុដិ សាលាបាលី សាលាឆាន់ វិហារអ៊ិស្លាម សាររ៉ាវជាដើម។ ដែលគិតជាទឹកប្រាក់៖

| បរិយាយ | ប្រាក់ដុល្លារអាម៉េរិក | ប្រាក់រៀល |
|---|---|---|
| ឆ្នាំ២០១៨ | ១៣ ៩២៩ ១០១ | ២៧១ ១១១ ១០០ |
| ដំណាច់ខែកញ្ញា ឆ្នាំ២០១៩ | ១៣ ៨៦៧ ៤៧៧ | ១៩១ ៥០០ ០០០ |

**ដើម្បីសម្តែងការដឹងគុណចំពោះសប្បុរសជនក្នុងនិងក្រៅប្រទេសបាន ផ្តល់មេដាយនិងគោរម្យងារ**

| បរិយាយ | ឆ្នាំ២០១៨ | ដំណាច់ខែកញ្ញា ឆ្នាំ២០១៩ |
|---|---|---|
| **ព្រះរាជក្រឹត្យ** | | |
| ព្រះរាជាណាចក្រកម្ពុជា (គ្រឿង) | ១១ ៩៤៤ | ៣ ៨២៣ |
| ព្រះមហាក្សត្រីយានី (គ្រឿង) | ៤២៣ | ៧៣ |
| ការពារជាតិ (គ្រឿង) | ២២០ | ៥ ៣៧១ |
| សហមេត្រី (គ្រឿង) | ៨៥ | ៧៩ |
| សុវត្ថារា (គ្រឿង) | ៨១៨ | ២១៦ |
| មុនីសារាភណ្ឌ (គ្រឿង) | ១ ១៩៧ | ៨០១ |
| ជាតូបការ (គ្រឿង) | ៣៧៣ | ១២២ |
| សេនាជ័យសិទ្ធិ (គ្រឿង) | ៣២៤ | ៦៧ |
| ឯករាជជាតិ (គ្រឿង) | ០ | ២ |
| ឧកញ៉ា (រូប) | ៥៧ | ៤៦ |
| **អនុក្រឹត្យ** | | |
| សហមេត្រី (គ្រឿង) | ២០៦ | ៣៦២ |
| សុវត្ថារា (គ្រឿង) | ១ ២៨៥ | ៩១៦ |
| មុនីសារាភណ្ឌ (គ្រឿង) | ៣ ៨៨៥ | ៤ ២៣៧ |
| ស្ថាបនាជាតិ (គ្រឿង) | ២ ០៣៥ | ៣ ៨២៣ |
| ការងារ (គ្រឿង) | ១៦ ៧៩៩ | ២០ ៦៩៥ |
| ស្ត្រីវឌ្ឍនា (គ្រឿង) | ០ | ៦៥ |

### ៣- ការងារសង្គមស៊ីវិល

សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃសរុបចំនួន **៥ ៦២០**(សមាគមចំនួន២ ២០៣ អង្គការមិនមែនរដ្ឋាភិបាលចំនួន៣ ២៨០ និងសហគមន៍ចំនួន ១៣៧)។ ក្នុងនោះ រយៈពេលមួយឆ្នាំនៃដើមនីតិកាលទី៦នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគមចំនួន**១៥៣** អង្គការមិនមែនរដ្ឋាភិបាលចំនួន**៩០** និងសហគមន៍ចំនួន**១៣** សរុបចំនួន**២៥៦** និងបានសម្រេចលុបចេញពីបញ្ជីនូវសមាគមចំនួន៨ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន២៤។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃបានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសង្គមស៊ីវិលចំនួន**២លើក** ក្នុងគោលបំណងពិនិត្យឡើងវិញ កំណត់នូវបញ្ហាប្រឈម ស្តាប់សំណូមពរនិងអនុសាសន៍ដែលបានលើកឡើង ដើម្បីស្វែងរកដំណោះស្រាយនិងអាចរួមចំណែកដល់ការសម្រេចបាននូវគោលដៅនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំពិគ្រោះយោបល់ដំបូងជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ក្នុងគោលបំណងបង្កើតបរិយាកាសភាពជាដៃគូប្រកបដោយសុខដុមនីយកម្ម។ គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៩ អង្គការមិនមែនរដ្ឋាភិបាលបរទេសមានចំនួន៤០៣ បានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយក្នុងនោះ បានចុះបញ្ជីថ្មីចំនួន**៧៦អង្គការ** អនុលោមតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**អង្គការសហប្រជាជាតិ(UN)** : ដើម្បីលើកកម្ពស់ផលប្រយោជន៍និងកិត្យានុភាពជាតិកម្ពុជាបានចូលរួមយ៉ាងសកម្មនិងទទួលបានការគាំទ្រឱ្យដើរតួនាទីយ៉ាងសំខាន់នៅក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិដូចជា៖

- បានជាប់ឆ្នោតនិងបំពេញតួនាទីយ៉ាងសកម្មក្នុងនាមជាអនុប្រធានមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧៣ ដោយបានចូលរួមនិងដឹកនាំកិច្ចប្រជុំពេញអង្គនៃមហាសន្និបាតអង្គការសហប្រជាជាតិជាច្រើនលើកក្នុងការពិនិត្យនិងអនុម័តលើសេចក្តីសម្រេចចិត្តនានាពាក់ព័ន្ធនឹងបញ្ហាប្រឈមជាសកល។
- បានជាប់ឆ្នោតនិងបំពេញតួនាទីជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមអង្គការសហប្រជាជាតិសម្រាប់អាណត្តិឆ្នាំ២០១៩។
- ក្រៅពីបេសកកម្មដ៏ឧត្តុង្គឧត្តមនិងថ្លៃថ្នូរខាងលើនេះ កម្ពុជាក៏បានចូលរួមវិភាគទានដល់បុព្វហេតុសន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក តួយ៉ាងប្រឆាំងនឹងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលអាកាសធាតុ ការជួញដូរគ្រឿងញៀន ។ល។ និងបានដាក់ចេញនូវជំហរច្បាស់លាស់លើបញ្ហាផ្សេងៗ ដូចជា បញ្ហាឧបទ្វីបកូរ៉េ សមុទ្រចិនខាងត្បូង គំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ ទស្សនទានឥណ្ឌូ-ប៉ាស៊ីហ្វិក និងសភាពការណ៍នៅមជ្ឈិមបូព៌ា ។ល។

**អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី(OIF)** : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបាន : ១- រៀបចំមហាសន្និបាតលើកទី២នៃក្រុមប្រឹក្សាលើកកម្ពស់ការប្រើប្រាស់ភាសាបារាំងនៅកម្ពុជា ដើម្បីពិភាក្សាអំពីរបាយការណ៍សកម្មភាពឆ្នាំ២០១៨ និងគម្រោងសកម្មភាពហ្វ្រង់កូហ្វូនីឆ្នាំ២០១៩ របស់បណ្តាស្ថាប័ននិងសាកលវិទ្យាល័យប្រើប្រាស់ភាសាបារាំងនៅភ្នំពេញ ២- រៀបចំពិធីអបអរទិវាអន្តរជាតិហ្វ្រង់កូហ្វូនី និង៣- ដាក់បេក្ខភាពជាសមាជិកក្រុមប្រឹក្សាតម្រង់ទិសនៃគណៈកម្មាធិការអន្តរជាតិកីឡាហ្វ្រង់កូហ្វូនី។

### ៤- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា(គជនា) បានទទួលដោះស្រាយសំណើសុំនាំចូលសម្ភារៈបរិក្ខារដោយការបង់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ សម្រាប់ការអនុវត្តគម្រោងជាជំនួយទ្វេភាគី ពហុភាគី និងជំនួយអង្គការមិនមែនរដ្ឋាភិបាល១ ៤៦១**សំណើ** ដែលមានទឹកប្រាក់សរុប**៧២ ៨៨៤ ៨៧២,៤៨ដុល្លារអាម៉េរិក** ក្នុងនោះ ជំនួយទ្វេភាគី**៥៩៩សំណើ** មានទឹកប្រាក់**២៧ ៧១៦ ៩៦៩,៨៣ដុល្លារអាម៉េរិក** ជំនួយពហុភាគី**២៧៦សំណើ** មានទឹកប្រាក់**១៥ ១៥១ ៣១៩,៣៣ដុល្លារអាម៉េរិក** និងជំនួយអង្គការមិនមែនរដ្ឋាភិបាល**៥៨៦សំណើ** មានទឹកប្រាក់**៣០ ០១៦ ៥៨៣,៣២ដុល្លារអាម៉េរិក**។

## ទី៤- ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

### ១- កិច្ចសហប្រតិបត្តិការស្តីពីសមាហរណកម្មរបស់កម្ពុជាក្រោមក្របខ័ណ្ឌអាស៊ាន

កម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយប្រទេសសមាជិកទាំងអស់ ដើម្បីសម្រេចឱ្យបាននូវគោលដៅអាស៊ានជាសហគមន៍តែមួយ ដែលផ្អែកលើវិធានច្បាប់ និងការរក្សាមជ្ឈភាពអាស៊ាន។ ជាក់ស្តែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួម៖

- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣ នៅសាធារណរដ្ឋសិង្ហបុរី កាលពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយបានអនុម័តឯកសារចំនួន៧ រួមមាន (១)ក្របខ័ណ្ឌទីក្រុងឆ្លាតអាស៊ាន (២)សេចក្តីថ្លែងការណ៍ ស្តីពីគោលការណ៍ណែនាំអំពីជំនួយផ្នែកកុងស៊ុលដោយស្ថានបេសកកម្មការទូតនានា នៃបណ្តាប្រទេសសមាជិកអាស៊ាននៅក្នុងបណ្តាប្រទេសទីបី ដល់ជនជាតិនៃប្រទេសសមាជិកអាស៊ានដទៃទៀត (៣)ផែនការមេសម្រាប់ការជំរុញអាស៊ានឆ្នាំ២០២៥ ការបញ្ជ្រាបចំណេះដឹងសិទ្ធិជនពិការ (៤)សេចក្តីថ្លែងការណ៍អាស៊ានស្តីពីការអនុម័តទិវាយុវជនអាស៊ាន ក្នុងសកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ (៥)សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការលើកកម្ពស់ការងារបៃតងសម្រាប់កំណើនប្រកបដោយបរិយាបន្ននិងសមធម៌ក្នុងសហគមន៍អាស៊ាន (៦) សេចក្តីប្រកាសរួមអាស៊ាន ស្តីពីការប្រែប្រួលអាកាសធាតុជូនសន្និសីទលើកទី២៤ នៃភាគីពាក់ព័ន្ធ (COP 24)ចំពោះអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និង (៧) សេចក្តីប្រកាសរួមអាស៊ានជូនកិច្ចប្រជុំលើកទី១៤ នៃសន្និសីទរបស់ភាគីអនុសញ្ញាស្តីពីពិពិធភាពជីវៈចម្រុះ(CBD COP 14)។
- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៤ កាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ក្រោមមូលបទ "ជំរុញភាពជាដៃគូសម្រាប់ចីរភាព" ដោយបានអនុម័ត (១)សេចក្តីប្រកាសចក្ខុវិស័យរបស់ថ្នាក់ដឹកនាំអាស៊ាន ស្តីពីភាពជាដៃគូសម្រាប់ចីរភាព (២)សេចក្តីថ្លែងការណ៍ទីក្រុងបាងកក ស្តីពីការទប់ស្កាត់សំណល់សមុទ្រក្នុងតំបន់អាស៊ាន (៣)សេចក្តីប្រកាសថ្នាក់ដឹកនាំអាស៊ាន ស្តីពីឆ្នាំវប្បធម៌អាស៊ាន២០១៩ និង (៤)ឯកសារទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក ព្រមទាំងបានប្រកាសដាក់ឱ្យដំណើរការនូវឃ្លាំងផ្គាយរណបអាស៊ាន នៅក្នុងខេត្តឆៃណាតព្រះរាជាណាចក្រថៃ ដែលស្ថិតក្រោមប្រព័ន្ធភស្តុភារសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ។
- កិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី២១ កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី២០ កិច្ចប្រជុំកំពូលអាស៊ាន-រុស្ស៊ីលើកទី៣ កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី២១ កិច្ចប្រជុំកំពូលក្រៅផ្លូវការអាស៊ាន-ឥណ្ឌា កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២១ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១៣ និងកិច្ចប្រជុំកំពូលភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់លើកទី២ ផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក៏បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំនានានៅក្នុងក្របខ័ណ្ឌអាស៊ានដូចជា៖

- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥២ និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ កាលពីថ្ងៃទី២៧ ខែកក្កដា ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ ដោយបានពិភាក្សាលើ (១)ការ

កសាងសហគមន៍អាស៊ាន ដែលផ្តោតជាសំខាន់ទៅលើការអនុវត្តយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃផែនការមេទាំង៣នៃសហគមន៍អាស៊ាន និង(២)ទំនាក់ទំនងខាងក្រៅរបស់អាស៊ាន ជាពិសេសនិម្មាបនកម្មតំបន់ជាមួយដៃគូសន្ទនាអាស៊ាន ភាពជាដៃគូសន្ទនាអាស៊ានតាមវិស័យ ដៃគូអភិវឌ្ឍអាស៊ាន និងអង្គការតំបន់និងអន្តរជាតិ។ ទន្ទឹមនឹងនេះ ក៏បានចូលរួមក្នុងសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយដៃគូសន្ទនារបស់អាស៊ាន កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបីលើកទី២០ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំកំពូលអាស៊ី-បូព៌ាលើកទី៩ និងវេទិកាតំបន់អាស៊ានលើកទី២៦។

- កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅខេត្តឈៀងម៉ៃ ព្រះរាជាណាចក្រថៃ កាលពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ដើម្បីពិភាក្សាលើបញ្ហាសំខាន់ៗទាក់ទងនឹងការបន្តតាមដានលទ្ធផលកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៣និងកិច្ចប្រជុំពាក់ព័ន្ធនានា ជាពិសេសដំណើរការកសាងសហគមន៍អាស៊ាន ទំនាក់ទំនងអាស៊ានជាមួយដៃគូខាងក្រៅ និងបញ្ហាតំបន់និងអន្តរជាតិ។
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុបលើកទី២២ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្សិក កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ដោយលទ្ធផលសំខាន់រួមមាន (១)ពិនិត្យលើកិច្ចសហប្រតិបត្តិការអាស៊ាន-សហភាពអឺរ៉ុប និងទិសដៅអនាគត ព្រមទាំងបានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់និងអន្តរជាតិនានាដែលជាកង្វល់រួមរបស់ពិភពលោក (២) អនុម័ត "សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុបលើកទី២២" ដែលតាមរយៈសេចក្តីប្រកាសនេះ អាស៊ាននិងសហភាពអឺរ៉ុបបានឯកភាពគ្នាជាគោលការណ៍ដំឡើងភាពជាដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុប ឱ្យដល់កម្រិតយុទ្ធសាស្ត្រ ដោយបន្តចរចាលើចំណុចលម្អិត និងកាលបរិច្ឆេទច្បាស់លាស់ និង (៣)សហភាពអឺរ៉ុបបានអះអាងជាថ្មីនូវការគាំទ្រចំពោះតួនាទីស្នូលរបស់អាស៊ាននៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងវិវឌ្ឍ និងតួនាទីនាំមុខរបស់អាស៊ានក្នុងការជំរុញកិច្ចសន្ទនា ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដើម្បីសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព ដោយឈរលើមូលដ្ឋានច្បាប់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងក្រៅតំបន់។

ក្រៅពីនេះ មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាផ្សេងទៀត ក៏បានចូលរួមកិច្ចប្រជុំនៅក្រោមសសរស្តម្ភផ្សេងៗរបស់អាស៊ាន ដូចជាៈ

- កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី២៥ កាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងភូកេត ព្រះរាជាណាចក្រថៃ ដោយបានចុះហត្ថលេខាលើឯកសារចំនួន២ រួមមាន (១)កិច្ចព្រមព្រៀងអាស៊ានស្តីពីសេវាកម្ម និង(២)ពិធីសារទី៤ ស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ហើយបានអនុម័តឯកសារវិស័យសេដ្ឋកិច្ចជាអាទិភាពសម្រាប់ឆ្នាំ២០១៩។
- កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន លើកទី២០ កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី ដោយបានអនុម័ត (១)សេចក្តីប្រកាសអាស៊ានស្តីពីការលើកកម្ពស់ការងារបៃតងសម្រាប់សមធម៌ និងកំណើនដែលប្រកបដោយបរិយាបន្នសម្រាប់សហគមន៍អាស៊ាន (២)ផែនការមេអាស៊ានឆ្នាំ២០២៥ៈ ការបញ្ជ្រាបសិទ្ធិជនពិការ (៣)សេចក្តីថ្លែងការណ៍រួមអាស៊ាន ស្តីពីការប្រែប្រួលអាកាសធាតុនៃសន្និសីទភាគីលើកទី២៤ ចំពោះអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការ

ប្រែប្រួលអាកាសធាតុ (៤)សេចក្តីថ្លែងការណ៍រួមអាស៊ាន ស្តីពីកិច្ចប្រជុំសន្និសីទរបស់ភាគីនៃអនុសញ្ញាស្តីពីជីវៈចម្រុះលើកទី១៤ (៥)សេចក្តីថ្លែងការណ៍រួមអាស៊ានបូកបី ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងមេរោគដែលស៊ាំថ្នាំអង់ទីប៊្យូទិក និង(៦)សេចក្តីប្រកាសអាស៊ាន ស្តីពីការអនុម័តទិវាយុវជនអាស៊ានក្នុងសកម្មភាពទប់ទល់នឹងអាកាសធាតុនិងភាពធន់នៃគ្រោះធម្មជាតិ។

- កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ានលើកទី២១ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ នៅខេត្តឈៀងម៉ៃ ព្រះរាជាណាចក្រថៃ ក្រោមប្រធានបទអាស៊ានឆ្នាំ២០១៩ ស្តីពីការជំរុញភាពជាដៃគូដើម្បីនិរន្តរភាព ដោយបានអនុម័តសេចក្តីប្រកាសទីក្រុងបាងកកស្តីពីការប្រយុទ្ធប្រឆាំងសំរាមក្នុងសមុទ្រក្នុងតំបន់អាស៊ាន និងសេចក្តីថ្លែងការណ៍មេដឹកនាំអាស៊ានស្តីពីឆ្នាំ២០១៩ ជាឆ្នាំវប្បធម៌អាស៊ាន។
- កិច្ចប្រជុំក្រុមការងារចម្រុះអាស៊ាន-ចិន លើកទី២៩ និងការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់ភាគីក្នុងសមុទ្រចិនខាងត្បូង នៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី២១ ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩។

ក្រៅពីការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំអាស៊ានគ្រប់កម្រិតជាន់ថ្នាក់ កម្ពុជាបានរួមចំណែកជាមួយប្រទេសអាស៊ាន និងដៃគូសន្ទនាអាស៊ាន ដូចជាអាស៊ានបូកបី ក្នុងការកែប្រែនិន្នាការនៃរបបគាំពារនិយមក្នុងតំបន់ និងបន្តធ្វើការលើពាណិជ្ជកម្មសេរី ដោយបានចូលរួមក្នុងកិច្ចប្រជុំភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)លើកទី៦ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី កិច្ចប្រជុំភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)លើកទី៧ កាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩ នៅខេត្តសៀមរាប ប្រទេសកម្ពុជា និងកិច្ចប្រជុំភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)លើកទី៨ នៅថ្ងៃទី២ ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុងប៉េកាំង ប្រទេសចិន ដោយសម្រេចបានការចរចាលើការបើកច្រកទីផ្សារលើកលែងពន្ធប្រមាណ២ភាគ៣ និងការចរចារលើអត្ថបទកិច្ចព្រមព្រៀងប្រមាណ៧៩,១%។ កម្ពុជាក៏បានចូលរួមពិធីសម្ពោធលេខាធិការដ្ឋានអាស៊ានថ្មី និងកម្មវិធីខួបលើកទី៥២នៃការបង្កើតអាស៊ាននៅប្រទេសឥណ្ឌូនេស៊ីផងដែរ។

## ២- ការអនុវត្តការទូតសេដ្ឋកិច្ច និងវប្បធម៌

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បាននិងកំពុងជំរុញយុទ្ធសាស្ត្រអាទិភាពថ្មីមួយទៀត ដើម្បីចូលរួមជាវិភាគទានពង្រឹងជន្ទល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងលើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់និងអន្តរជាតិ ពោលគឺការប្រែក្លាយពីការទូតប្រពៃណីទៅជាការអនុវត្តការទូតទំនើប ដោយបន្ថែមការទូតសេដ្ឋកិច្ចជាចំណែកដ៏សំខាន់មួយ៖

- បានបង្កើតក្រុមការងារការទូតសេដ្ឋកិច្ច ដើម្បីធ្វើការស្រាវជ្រាវអំពីសេដ្ឋកិច្ចការទូត ឈានទៅរកការកំណត់គោលដៅច្បាស់លាស់ ក្នុងការរៀបចំនូវឯកសារយុទ្ធសាស្ត្រស្តីពីសេដ្ឋកិច្ចការទូតនិងផែនការសកម្មភាពផ្សេង ដែលបម្រើជាត្រីវិស័យសម្រាប់អ្នកការទូតក្នុងការទាក់ទាញវិនិយោគ ក៏ដូចជាទេសចរណ៍ពីបរទេស

- ស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស បានខិតខំសម្របសម្រួលនិងសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ក្នុងការរៀបចំការតាំងពិព័រណ៍ផ្សព្វផ្សាយពាណិជ្ជកម្ម សក្តានុពលភាពទេសចរណ៍ និងផលិតផលនានារបស់កម្ពុជា

- បានរៀបចំចងក្រងផ្ទាំងព័ត៌មាន( Dashboard) ទូទៅស្តីពីសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ដើម្បីផ្តល់ជូនអ្នកការទូតប្រើប្រាស់ក្នុងការទំនាក់ទំនងទាក់ទាញវិនិយោគនិងភ្ញៀវទេសចរពីបរទេស

- បានចូលរួមយ៉ាងសកម្មនៅក្នុង «គំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ» ដែលបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដូចជាការសម្រេចបាននូវគម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ក៏ដូចជាការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តព្រះសីហនុ។

**៣- ជំនួយពីដៃគូអភិវឌ្ឍ**

ឯកឧត្តម **ហូរីណូអ៊ូជិ ហ៊ីដេហ៊ីស** (Horinouchi Hidehisa) ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា និងឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ បានចុះហត្ថលេខាបន្តគាំទ្រសម្រាប់អនុវត្តគម្រោងចំនួន២គឺ (១)ឥណទានសម្បទានដែលមានទឹកប្រាក់ប្រមាណ**៣១,៥៦លានដុល្លារអាម៉េរិក** អនុវត្តលើគម្រោងកែលម្អនិងស្តារប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធរំដោះទឹក ភាគខាងលិចបឹងទន្លេសាប និង(២)ហិរញ្ញប្បទានឥតសំណងដែលមានទឹកប្រាក់ប្រមាណ**១១,៨លានដុល្លារអាម៉េរិក** អនុវត្តលើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអគ្គិសនីនៅកំពង់ផែ ដើម្បីធ្វើទំនើបកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើគម្រោងនៃមូលនិធីពិសេសមេគង្គ-ឡានឆាង ដែលមានទឹកប្រាក់ចំនួន**៧,៦៦លានដុល្លារអាម៉េរិក** ដោយគ្របដណ្តប់លើការពង្រឹងសមត្ថភាព ការអប់រំសិក្សាស្រាវជ្រាវ និងកម្មវិធីផ្លាស់ប្តូរ។ នៅក្នុងគម្រោងនៃមូលនិធិនេះ កម្ពុជាបានទទួលចំនួន១៩គម្រោង ដែលមានថវិកាសរុបជាង**៧លានដុល្លារអាម៉េរិក**។

**៤- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ**

គិតមកដល់ឆ្នាំ២០១៩នេះ គឺជាឆ្នាំទី១៣ ដែលកម្ពុជាបានបញ្ជូនកងកម្លាំងទៅចូលរួមក្នុងបេសកកម្មរក្សាសន្តិភាព ក្រោមឆត្រអង្គការសហប្រជាជាតិនៅតាមប្រទេសលើជំនាញបោសសម្អាតមីន កម្ទេចគ្រាប់មីនមិនទាន់ផ្ទុះ អាវុធហត្ថ មន្ទីរពេទ្យកម្រិត២ វិស្វកម្មសំណង់ វិស្វកម្មព្រលានយន្តហោះ នាយទាហានសេនាធិការ នាយទាហានសង្កេតការណ៍ សរុបចំនួន **៦ ៥៥៦នាក់**(នារី៣៣៨នាក់)។ បច្ចុប្បន្ន កម្លាំងកំពុងបំពេញបេសកកម្មនៅតាមបណ្តាប្រទេសមានចំនួន៧៨៨នាក់(នារី៦៦នាក់)ក្នុងនោះនៅសាធារណរដ្ឋស៊ូដង់ សាធារណរដ្ឋម៉ាលី សាធារណរដ្ឋអាហ្វ្រិកកណ្តាល និងសាធារណរដ្ឋលីបង់។ ចំណុចដែលគួរឱ្យកត់សម្គាល់ ត្រូវបានអង្គការសហប្រជាជាតិវាយតម្លៃបរិច្ចាគកម្លាំងច្រើនជាងគេក្នុងលំដាប់ប្រទេសនាំមុខ៣០/១២២ប្រទេស និងទទួលបានចំណាត់ថ្នាក់ទី២៦ រីឯការបញ្ជូនកម្លាំងយោធិននារី១៧,២% គឺលើសពីផែនការរបស់អង្គការសហប្រជាជាតិដែលបានកំណត់ត្រឹមតែ ១៥% ជាកងកម្លាំងដែលបានបន្តរក្សាភាពស្អាតស្អំនិងកេរ្តិ៍ឈ្មោះល្អជាប្រទេសមួយក្នុងចំណោម១៤/១២២ ប្រទេសដែលមិនមានជាប់ពាក់ព័ន្ធនឹងអំពើហិង្សា ការកេងប្រវញ្ចជួញដូរផ្លូវភេទ ព្រមទាំងទទួលបានការកោតសរសើរលើជំនាញកម្ទេចនិងដោះបំផ្លាញគ្រឿងផ្ទុះក្នុងបេសកកម្ម MUNUSMA នៅសាធារណរដ្ឋម៉ាលី ដោយប្រទេសមួយចំនួនមិនចូលរួមដោយសារប្រឈមហានិភ័យ ការគំរាមកំហែងដោយគ្រោះធម្មជាតិ ព្យុះខ្សាច់សាហារ៉ា គ្រាប់មីន គ្រឿងផ្ទុះកែច្នៃ ការវាយប្រហារអត្តឃាតពីក្រុមភេរវកម្ម ជំងឺឆ្លង Ebola ជំងឺគ្រុនចាញ់។ល។ នៅក្នុងតំបន់អាស៊ាន កម្ពុជាស្ថិតក្នុងលេខរៀងទី៣នៃប្រទេសដែលបញ្ជូនកងទ័ពមួកខៀវចូលរួមបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងស្ថិតក្នុងលេខរៀងទី២នៃប្រទេសដែលបានបញ្ជូនកងកម្លាំងជានារី។

# ចតុកោណយុទ្ធសាស្ត្រទី១
## ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណនៅគ្រប់ដំណាក់កាល ពិសេសបានក្លាយជាអាទិភាពទី១ នៅក្នុងដំណាក់កាលទី៣និងទី៤នេះ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពនិងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។

**មុំទី១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

ក្រសួងអប់រំ យុវជន និងកីឡាសម្រេចការងារបានដូចខាងក្រោម៖

**១-ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស (ឆ្នាំ២០១៨-២០១៩)**

ក្រសួងនិងដៃគូអភិវឌ្ឍបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ ជាពិសេសសិស្ស និស្សិតបានខិតខំរៀនសូត្រជាងមុន និងគ្រូបង្រៀនខិតខំបំពេញការងារល្អប្រសើរជាងមុន។ តាមរយៈអន្តរាគមន៍មួយចំនួនដូចជាការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន ការផ្តល់ថវិកាដំណើរការសាលារៀន ការផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ បានបង្កលក្ខណៈឱ្យសិស្សានុសិស្ស និងនិស្សិតមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត។ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ កុមារបានទទួលសេវាអប់រំ កុមារតូចមាន៤២៥ ៤០៣នាក់ ស្រី២១២ ៤៥៧នាក់ ស្មើនឹង៤៩,៩៤ ភាគរយ។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាពមាន១៩១ ៨៣២នាក់(ស្រី៩៤ ២៨៨នាក់)។ សិស្សបឋមសិក្សាសរុប២ ១៦៣ ១៤៣នាក់(ស្រី១ ០៣៩៩៣៦នាក់)។ សិស្សមធ្យមសិក្សាបឋមភូមិសរុប៦៣៨ ៧១២នាក់(ស្រី៣៣៣ ០៣៦នាក់)និងសិស្សមធ្យមសិក្សាទុតិយភូមិសរុប៣៣៩ ៨៤៧នាក់(ស្រី១៨០ ៩៥០នាក់) សិស្សបច្ចេកទេស២ ១០៣នាក់(ស្រី៧៨៤នាក់)។

ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកអប់រំទូទាំងប្រទេស កើនឡើងដល់១២០ ២៩៩នាក់(ស្រី ៥៤ ៩៥៨នាក់) ក្នុងនោះថ្នាក់ជាតិ៣ ៤១៦នាក់ (ស្រី ៩៣៩នាក់) និងថ្នាក់ក្រោមជាតិ១១៦ ៨៨៣នាក់ (ស្រី៥៤ ០១៩នាក់)។ ក្របខ័ណ្ឌគ្រូមត្តេយ្យសិក្សា៣ ៨៣៤នាក់(ស្រី៣ ៧៣១នាក់) គ្រូបឋមសិក្សា៥៦ ១០៥នាក់ (ស្រី ២៨ ៥៨៩នាក់) គ្រូបង្រៀនកម្រិតមូលដ្ឋាន៤១ ៥៥៦នាក់(ស្រី១៧ ៣៩៦នាក់) គ្រូបង្រៀនកម្រិតឧត្តម ១៦ ៥៥៧នាក់(ស្រី ៤ ៩២៦នាក់) អធិការបឋមសិក្សា៥៩ នាក់(ស្រី ១១នាក់) និងអធិការមធ្យមសិក្សា៩២ នាក់(ស្រី ១៧នាក់)។

ដើម្បីលើកកម្ពស់គុណភាពអប់រំនិងភាពឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តនូវកិច្ចការដ៏សំខាន់ៗមួយចំនួនដូចជា: អនុម័តកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាគ្រប់ភូមិសិក្សា កែលម្អការបណ្តុះបណ្តាលគ្រូនិងវិក្រឹតការគ្រូបង្រៀន អភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងរៀបចំផែនការសកម្មភាព ដើម្បីអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ពង្រីកការអនុវត្តសាលារៀនជំនាន់ថ្មីបាន១១កន្លែង (សាលាបឋមសិក្សា៤ និងសាលាមធ្យមសិក្សា៧) ជំរុញការកែលម្អវិធីសាស្ត្របង្រៀន ជំរុញការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ក្រសួងកំពុងសាកល្បងនិងពង្រីកការអនុវត្តការគ្រប់គ្រងសាលារៀន ឆ្ពោះទៅបង្កើនគណនេយ្យភាពនិងស្វ័យភាព និងការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសាលារៀន អនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្ស និងកែលម្អវិធីសាស្ត្របង្រៀន។

## ១.១- ការអប់រំចំណេះទូទៅ

| | | |
|---|---|---|
| មត្តេយ្យសិក្សា(រដ្ឋ) | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | ២០១៨-២០១៩ |
| សាលារៀន/កន្លែង | ៤ ១៧៦ | ៤ ៣០១ |
| សិស្ស (នាក់) | ២០៥ ៤៩២ | ២១៧ ៥០៩ |
| គ្រូបង្រៀន (នាក់) | ៥ ៣៩៨ | ៥ ៥៥៩ |
| មត្តេយ្យសិក្សា(ឯកជន) | | |
| សាលារៀន/កន្លែង | ៤៥៦ | ៥០៩ |
| សិស្ស (នាក់) | ៤៧ ២៥១ | ៤៨ ៣១៨ |
| បឋមសិក្សា(រដ្ឋ) | | |
| សាលារៀន | ៧ ១៨៩ | ៧ ២២៨ |
| សិស្ស (នាក់) | ២ ០២៨ ៦៩៤ | ២ ០៤០ ២៥៧ |
| គ្រូបង្រៀន (នាក់) | ៥៧ ៩១៥ | ៥៧ ៨១១ |
| បឋមសិក្សា(ឯកជន) | | |
| សាលារៀន | ៤៣២ | ៤៨៨ |
| សិស្ស (នាក់) | ១១១ ៧៩៨ | ១២២ ៨៨៦ |
| មធ្យមសិក្សាបឋមភូមិ(រដ្ឋ) | | |
| អនុវិទ្យាល័យ | ១ ២៣៧ | ១ ២៤៦ |
| សិស្ស (នាក់) | ៦០៥ ១៧៣ | ៦១០ ២៦១ |
| គ្រូបង្រៀន (នាក់) | ៣៣ ១៨១ | ៣៣ ៦៣៨ |
| មធ្យមសិក្សាបឋមភូមិ(ឯកជន) | | |
| សាលា | ៦៦ | ៧៨ |
| សិស្ស (នាក់) | ២៥ ៩២៨ | ២៨ ៤៥១ |
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | |
| បេក្ខជនមកប្រឡង (នាក់) | ១៥០ ០៩៩ | ១៥៤ ៦៧៩ |
| បេក្ខជនប្រឡងជាប់ (នាក់) | ១៤១ ៤១០ | ១៤៤ ៣៦៥ |
| មធ្យមសិក្សាទុតិយភូមិ(រដ្ឋ) | | |
| វិទ្យាល័យ | ៥១១ | ៥២៥ |
| សិស្ស (នាក់) | ៣០៣ ៨៩៣ | ៣២១ ១៤៥ |
| គ្រូបង្រៀន (នាក់) | ១៥ ១៧៦ | ១៥ ៧៦១ |
| មធ្យមសិក្សាទុតិយភូមិ(ឯកជន) | | |
| សាលា | ១២២ | ១៤៧ |
| សិស្ស (នាក់) | ១៨ ១០៧ | ១៨ ៣០២ |

| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | |
|---|---|---|
| បេក្ខជនមកប្រឡង (នាក់) | ១១៣ ៣៦៥ | ១១៥ ២០៦ |
| បេក្ខជនប្រឡងជាប់ (នាក់) | ៧៦ ០៣៤ | ៧៩ ០៥២ |
| ឧត្តមសិក្សា (រដ្ឋ និងឯកជន) | | |
| គ្រឹះស្ថានរដ្ឋ (១) | ៤៨ | ៤៨ |
| គ្រឹះស្ថានឯកជន (២) | ៧៣ | ៧៧ |
| សរុប ១+២ | ១២១ | ១២៥ |
| និស្សិតបរិញ្ញាបត្ររង (នាក់) | ២០ ៥៧០ | ១៩ ៨៧១ |
| និស្សិតបរិញ្ញាបត្រ (នាក់) | ១៦៥ ៣៥៩ | ១៦៨ ២៤២ |
| និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ (នាក់) | ២០ ២៧២ | ២២ ០២២ |
| និស្សិតថ្នាក់បណ្ឌិត (នាក់) | ១២២ | ១ ៣៤៩ |

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងសរុប១៩ ៨៧១នាក់(ស្រី៩ ៨០៧នាក់) ក្នុងនោះ និស្សិតអាហារូបករណ៍២ ៨៨៥នាក់(ស្រី១ ២៥៥នាក់)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រសរុប១៦៨ ២៤២នាក់(ស្រី៨៣ ៥៨៥នាក់)។ និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រសរុប២៣ ៣៧១ នាក់(ស្រី៥ ២៣៨នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់២២ ០២២នាក់(ស្រី៥ ១៦០ នាក់) និងថ្នាក់បណ្ឌិត១ ៣៤៩ នាក់(ស្រី៧៨ នាក់)។

### ១.២- គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស

| ប្រភេទសាលា/ភាសា | ខ្មែរ | ចិន | ម៉ូស្លីម | អង់គ្លេស | សរុប |
|---|---|---|---|---|---|
| សាលាមត្តេយ្យ | ៣៧៣ | ១៩ | ៥ | ១១០ | ៥០៨ |
| សាលាបឋមសិក្សា | ៤០៦ | ២៦ | ១៧ | ៣៧ | ៤៨៧ |
| អនុវិទ្យាល័យ | ៦២ | ១០ | ១ | ៥ | ៧៨ |
| វិទ្យាល័យ | ១៣៤ | ០ | ៥ | ៨ | ១៤៧ |

### ១.៣- ការសិក្សាតាមបែបឌីជីថល

ក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាជំនាន់ថ្មីកម្រិតមធ្យមសិក្សាមាន៧ គឺវិទ្យាល័យព្រះស៊ីសុវត្ថិ ព្រះយុគន្ធរ ហ៊ុនសែនកំពង់ចាម ហ៊ុនសែនព្រែកលៀប ជាស៊ីមព្រែកអញ្ចាញ ហ៊ុនសែនពាមជីកង និងអនុវិទ្យាល័យគោកព្រីង មានសិស្សសរុប៣ ១៦៣ នាក់(ស្រី១ ៥៩៨នាក់)។ សាលារៀនជំនាន់ថ្មីត្រូវបានក្លាយជាសាលារៀនគំរូសម្រាប់ការបណ្តុះបណ្តាលគ្រូ ការកែលម្អវិធីសាស្ត្របង្រៀន ការពង្រឹងស្វ័យភាពនិងគណនេយ្យភាព ការគ្រប់គ្រងសាលារៀន និងការចូលរួមរបស់សហគមន៍។

### ១.៤- ការងារយុវជន អប់រំកាយ និងកីឡា

#### ក- សមិទ្ធផលសំខាន់ៗនៃការងារយុវជន

១- ក្រសួងបានធ្វើបច្ចុប្បន្នកម្មក្រុមប្រឹក្សាកុមារកម្ពុជានិងក្រុមប្រឹក្សាយុវជនកម្ពុជា ដើម្បីជំរុញចលនា"**បីល្អ**"របស់កុមារដែលបានជះឥទ្ធិពលជាវិជ្ជមានដល់សិស្សានុសិស្ស គណៈគ្រប់គ្រងសាលា និងគណៈកម្មការទ្រទ្រង់សាលា។ ជាមួយគ្នានេះ ក្រសួងបានជំរុញសកម្មភាពរបស់ក្រុមប្រឹក្សាយុវជនឱ្យបានចូលរួមជួយការងារស្វ័យគ្រប់គ្រងសាលា គាំទ្រក្លឹបក្រុមប្រឹក្សាយុវជន បង្កើតក្លឹបសិក្សា និងជួយបំប៉នបន្ថែមដល់សិស្សត្រៀមប្រឡងថ្នាក់ទី១២។

២- បើកសិក្ខាសាលាស្តីពី ការគ្រប់គ្រងផ្លូវចិត្តយុវជន តម្រង់ទិសកាយរឹទ្ធិកម្មនិងគោលនយោបាយកាយរឹទ្ធិកម្ពុជា កម្មវិធីកាយរឹទ្ធិកម្មនិងទិវាសន្តិភាពពិភពលោកក្រោមប្រធានបទ«**កាយរឹទ្ធិម្នាក់ដើមឈើមួយដើម**» ការគ្រប់គ្រងមជ្ឈមណ្ឌលនិងយុវជន និងស្តីពីសហគ្រិនជោគជ័យ ដែលមានអ្នកចូលរួម៤ ៤៥១នាក់(ស្រី២ ៥៩៤នាក់) នៅខេត្តតាកែវ កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ បន្ទាយមានជ័យ ព្រះសីហនុ សៀមរាប កែប កោះកុង បាត់ដំបង និងខេត្តព្រៃវែង។

៣- រៀបចំមហោស្រពវិទ្យាសាស្ត្រនិងវិស្វកម្មកម្ពុជាលើកទី៥ស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅពហុកីឡដ្ឋានជាតិ កាលពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- រៀបចំវេទិកាយុវជនតំបន់ត្រីកោណអភិវឌ្ឍកម្ពុជា វៀតណាម ឡាវលើកទី៨ នៅខេត្តក្រចេះ កាលពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ និងកម្មវិធីប្រារព្ធខួបលើកទី២០ ទិវាអន្តរជាតិសម្រាប់យុវជន១២ សីហា ២០១៩ ដែលមានអ្នកចូលរួម**១ ៥០០នាក់** នៅរាជធានីភ្នំពេញ។

៥- ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត និងបានទទួលការសម្រេចជាផ្លូវការពីគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ ២០១៩។

៦- ប្រកួតស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ«**ការប្រកួតប្រជែងគម្រោងផែនការអភិវឌ្ឍវិស័យកសិកម្មតាមបែបវិទ្យាសាស្ត្រ**» ដែលមានអ្នកចូលរួម**៣១៥នាក់** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា កាលពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩។

៧- បោះជំរំកាយរឹទ្ធិរៀមច្បងលើកទី១ដែលមានអ្នកចូលរួម**៤៥០នាក់**(ស្រី២១៥នាក់)នៅរមណីយដ្ឋានបឹងសំរឹទ្ធ ខេត្តកំពង់ធំ កាលពីថ្ងៃទី២២ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- បញ្ជូនប្រតិភូយុវជន**៣៥នាក់**(ស្រី១១នាក់)ចូលរួមកម្មវិធីនានានៅក្នុងតំបន់និងអន្តរជាតិ។

៩- បញ្ជូនប្រតិភូកាយរឹទ្ធិ**៣៣នាក់**(ស្រី៨នាក់)ចូលរួមកម្មវិធីនានានៅក្នុងតំបន់និងអន្តរជាតិ។

១០- បើកវគ្គបណ្តុះបណ្តាលមេដឹកនាំកាយរឹទ្ធិជាន់ខ្ពស់ជំនាន់ទី២ចំនួន**៦៤នាក់**(ស្រី៩នាក់) កាលពីថ្ងៃទី១៧ដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៩ និងមូលដ្ឋានគ្រឹះមេដឹកនាំកាយរឹទ្ធិជំនាន់ទី៦ចំនួន**៧៨នាក់**(ស្រី១៦នាក់) កាលពីថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ នៅខេត្តសៀមរាប។

១១- ពិធីបំពាក់កន្សែងជូនកាយរឹទ្ធិកម្ពុជា**៤៧០នាក់**(ស្រី២៦០នាក់) នៅខេត្តកោះកុង។

១២- បើកវគ្គបំប៉នស្តីពីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ដែលមានអ្នកចូលរួម**៥៧៨នាក់**(ស្រី២៨៤នាក់) នៅរាជធានីភ្នំពេញ ខេត្តសៀមរាប រតនគិរី ពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ។

១៣- ប្រារព្ធទិវាសហគ្រិនភាពកម្ពុជាដែលមានអ្នកចូលរួម៤ **៦៨៥នាក់**(ស្រី២ ៧៣៥នាក់) នៅទូទាំង២៥ រាជធានី ខេត្ត និងប្រារព្ធទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត៥ ធ្នូ ២០១៩ដែលមានអ្នកចូលរួម**១ ២៥០នាក់** (ស្រី៧២៥នាក់)នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

១៤- រៀបចំទិវាជាតិអំណានក្រោមប្រធានបទ«**ការអានបណ្ដុះវប្បធម៌ពេញមួយជីវិត**» ដែលមានអ្នកចូលរួមប្រកួតប្រជែងប្រឡងការអានអត្ថបទ ស្មូតកំណាព្យនិងតែងនិពន្ធ**១៩១នាក់**(ស្រី១០២នាក់)មកពី២៥រាជធានី ខេត្ត។

១៥- ក្រសួងបានពង្រីកកម្មវិធីសាកល្បងការអប់រំសហគ្រិនភាព នៅ២៥រាជធានី ខេត្ត ដាក់អនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត ដំណើរការមជ្ឈមណ្ឌលណែនាំអំពីអាជីពនិងការងារបំប៉នសមត្ថភាពស្ដីពីការអភិវឌ្ឍសហគ្រាសតាមសហគមន៍ដល់យុវជន បណ្ដុះបណ្ដាលវគ្គមូលដ្ឋានគ្រឹះមេដឹកនាំកាយរឹទ្ធិនិងបំប៉នជំនាញខ្លីៗដល់យុវជន។

## ខ- សមិទ្ធផលសំខាន់ៗនៃការងារអប់រំកាយ និងកីឡា

### ខ.១- ការងារសិក្ខាសាលានិងបណ្ដុះបណ្ដាល

១- បើកសិក្ខាសាលាស្ដីពីការតាក់តែងសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា ការអនុវត្តសៀវភៅអប់រំកាយនិងកីឡាសម្រាប់គ្រូនៅគ្រឹះស្ថានបឋមសិក្សា ការរៀបចំតេស្ដកាយសម្បទាកុមារពីអាយុ៦ឆ្នាំដល់១២ឆ្នាំ ការរៀបចំផែនការនិងទ្រឹស្ដីហាត់ហ្វឹកហ្វឺន ការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡានៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ប៉ៃលិន សៀមរាប កំពង់ធំ កំពង់ចាម ឧត្ដរមានជ័យ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ដែលមានអ្នកចូលរួមសរុប**១ ០៩៣នាក់**(ស្រី១០៦នាក់)

២- បើកវគ្គបំប៉នស្ដីពីវិធីសាស្ត្រថ្មីៗក្នុងការបង្ហាត់បង្រៀនជូនគ្រូបង្រៀនអប់រំកាយ និងកីឡានៅខេត្តកំពង់ចាម កំពង់ឆ្នាំង និងខេត្តក្រចេះ ដែលមានអ្នកចូលរួម**២១០នាក់**(ស្រី៣០នាក់)។

### ខ.២- ការងារបណ្ដុះបណ្ដាលគ្រូកីឡា

១- បើកវគ្គបណ្ដុះបណ្ដាលគ្រូបង្វឹកកីឡាពលកម្មអន្តរជាតិកម្រិត១ចំនួន**២៥នាក់**(ស្រី៥នាក់) នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែឧសភា ដល់ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩។

២- រៀបចំប្រឡងជ្រើសរើសគរុសិស្សឱ្យចូលរៀនថ្នាក់គ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡាជំនាន់ទី២៩ សម័យប្រឡងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានបេក្ខជនដាក់ពាក្យប្រឡង**១ ៤៧៦នាក់**(ស្រី៣០១នាក់) ជាលទ្ធផលជាប់**១៥០នាក់**(ស្រី១៤នាក់)។

### ខ.៣- ការប្រកួតកីឡា

១- រៀបចំប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំសិក្សា២០១៨-២០១៩ ដែលមានប្រតិភូកីឡាករ កីឡាការិនីចូលរួមសរុប**១ ៦២៦នាក់**(ស្រី៩២៩នាក់) កាលពីថ្ងៃទី២៩ ខែមីនា ដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩ និងការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិលើកទី១ ឆ្នាំ២០១៩ ដែលមានប្រតិភូកីឡាករ កីឡាការិនីចូលរួមសរុប**៣ ៤៥៩នាក់**(ស្រី១ ៣៣១នាក់)មកពី២៥រាជធានី ខេត្ត នៅរាជធានីភ្នំពេញកាលពីថ្ងៃទី១០ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩។

២- រៀបចំប្រកួតកីឡាប៉េតង់ជើងឯកពិភពលោកយុវជន និងនារីលើកទី១៧ កាលពីថ្ងៃទី១៨ដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមាន៤៩ប្រទេស កីឡាករ**៣១៨នាក់**(ស្រី១១៥នាក់) ជាលទ្ធផលព្រះរាជាណាចក្រកម្ពុជាទទួលបានមេដាយមាស**១គ្រឿង**និងមេដាយសំរឹទ្ធ**១គ្រឿង** និងប្រកួតកីឡាទាញព្រ័ត្រជ្រើសរើសជើងឯកថ្នាក់ជាតិឆ្នាំ២០១៩ ដែលមានសមាគមចូលរួម**៧ប្រតិភូ** កីឡាករ**១១២នាក់**(ស្រី៤៤នាក់)នៅពហុកីឡដ្ឋានជាតិ។

៣- រៀបចំប្រកួតកីឡានៅពហុកីឡដ្ឋានជាតិលើប្រភេទកីឡាបាល់ទាត់អាស៊ានអាយុក្រោម២២ឆ្នាំ AFF U22 LG 2019 កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ កីឡាបាល់ទាត់អាស៊ីអាយុក្រោម២៣ឆ្នាំ កាលពីថ្ងៃទី២២ដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ កីឡាបាល់ទាត់មិត្តភាពអន្តរជាតិកម្ពុជានិងម៉ុងហ្គោលី កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ កីឡាបាល់ទាត់ពានរង្វាន់សម្ដេចហ៊ុន សែន កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ កីឡាបាល់ទាត់ពានរង្វាន់ Asian Cup 2023 Qualifiers កាលពីថ្ងៃទី10 ខែកញ្ញា ឆ្នាំ២០១៩ កីឡាតេក្វាន់ដូ ITF ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍ លើកទី២ឆ្នាំ២០១៩ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ និងកីឡាប្រដាល់សកលជ្រើសរើសជើងឯកថ្នាក់ជាតិឆ្នាំ២០១៩ កាលពីថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។

៤- រៀបចំប្រកួតកីឡាវ៉ូវីណាមជ្រើសរើសជើងឯកពិភពលោកលើកទី៦ឆ្នាំ២០១៩ នៅពហុកីឡដ្ឋានជាតិ កាលពីថ្ងៃទី១៦ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ ជាលទ្ធផលព្រះរាជាណាចក្រកម្ពុជាទទួលបានមេដាយមាស**៩គ្រឿង** មេដាយប្រាក់**១០គ្រឿង** និងមេដាយសំរឹទ្ធ**១២គ្រឿង**។

៥- បញ្ជូនប្រតិភូ គ្រូបង្វឹក ជំនួយការគ្រូបង្វឹក កីឡាករ កីឡាការិនី**៩០៣នាក់**(ស្រី១៧៥នាក់) លើប្រភេទកីឡាស៊ីហ្គេមលើកទី៣០ កីឡាទ្រីយ៉ាត្លុង បាល់ទាត់ កាយសម្ព័ន្ធ វាយសីថ្ពាល វូស៊ូ ប្រដាល់សកល សូហ្វតេនីស អត្តពលកម្ម កាយវប្បកម្ម តេក្វាន់ដូWT ប៉ាក់ាឡាំពិក វាយសី ការ៉ាតេដូ បាល់ទះ បាល់បោះ វាយកូនបាល់ ទូកប្រពៃណី ស៊ីដក់និងឈិនឡូន ទូកកានូនិងរ៉ូអ៊ីង ស៊ីដក់ កូនឃ្លីលើតុ ហែលទឹក ល្បុក្កតោ ប៉េតង់ ម៉ូតូទឹក តេក្វាន់ដូ ITF និងកីឡារាំ ទៅចូលរួមប្រកួតប្រជែងនៅក្នុងតំបន់និងអន្តរជាតិ។ ជាលទ្ធផលព្រះរាជាណាចក្រកម្ពុជាទទួលបានមេដាយមាស**៣២គ្រឿង** មេដាយប្រាក់**២៦គ្រឿង** និងមេដាយសំរឹទ្ធ**៦១គ្រឿង** រួមមានកីឡាស៊ីហ្គេមលើកទី៣០ទទួលបានមេដាយមាស**៤គ្រឿង** មេដាយប្រាក់**៦គ្រឿង** និងមេដាយសំរឹទ្ធ**៣៦គ្រឿង** ប៉េតង់ជើងឯកអាស៊ីអាគ្នេយ៍ទទួលបានមេដាយមាស**៤គ្រឿង** មេដាយប្រាក់**១គ្រឿង** និងមេដាយសំរឹទ្ធ**១គ្រឿង** កីឡារាំទទួលបានមេដាយមាស**៨គ្រឿង** មេដាយប្រាក់**៧គ្រឿង** និងមេដាយសំរឹទ្ធ**៦គ្រឿង** ល្បុក្កតោទទួលបានមេដាយមាស**៦គ្រឿង** និងមេដាយសំរឹទ្ធ**១គ្រឿង** និងតេក្វាន់ដូITFទទួលបានមេដាយមាស**១គ្រឿង** មេដាយប្រាក់**២គ្រឿង** និងមេដាយសំរឹទ្ធ**២គ្រឿង**។

៦- ប្រារព្ធទិវាកីឡាដើម្បីទាំងអស់គ្នា «**កីឡាដើម្បីសុខភាព មិត្តភាព និងសាមគ្គីភាព**» ដែលមានមហាជនចូលរួម**៦៣៧នាក់** កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៩ នៅពហុកីឡដ្ឋានជាតិ និងទិវាអាស៊ានហាត់ប្រាណដើម្បីសុខភាពដែលមានមហាជនចូលរួម**១ ៥០០នាក់** កាលពីថ្ងៃទី២ដល់ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ នៅខេត្តពោធិ៍សាត់។

✡ **ក្រសួងការពារជាតិ** បានបញ្ជូនកីឡាករ កីឡាការិនីកងយោធពលខេមរភូមិន្ទទៅចូលរួមប្រកួតកីឡាដណ្តើមពានរង្វាន់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រកួតជ្រើសរើសជើងឯកជាតិទូទាំងប្រទេស ប្រកួតដណ្តើមពានរង្វាន់ផ្សេងៗនៅក្នុងប្រទេស ទទួលបានមេដាយមាស **៨២គ្រឿង**(មេដាយមាសប៉េតង់ពិភពលោក១គ្រឿង) ប្រាក់**៣៤គ្រឿង** សំរឹទ្ធ**២៤គ្រឿង**(មេដាយសំរឹទ្ធប៉េតង់ពិភពលោក**១គ្រឿង**) ពាន១(ពានប៉េតង់ពិភពលោក១) ខ្សែក្រវាត់២និងថវិកា២០ ០០០ដុល្លារអាម៉េរិកនិង២០ ០០០ ០០០រៀល ព្រមទាំងទទួលបានចំណាត់ថ្នាក់លេខ១ គ្រងជើងឯកប្រចាំឆ្នាំ២០១៩និងនាំមុខក្នុងសហព័ន្ធកីឡាចំនួន៥ បើធៀបនឹងបណ្តាឆ្នាំកន្លងមក មានសន្ទុះឈានឡើងគួរឱ្យកត់សម្គាល់។ ដោយឡែកនៅក្នុងព្រឹត្តិការណ៍ព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះប្រកួតកីឡាប៉េតង់ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រីលើកទី១៧ ឆ្នាំ២០១៩ ដែលមាន៤៩ប្រទេសចូលរួមសម្រាប់វិញ្ញាសាវាយស៊ុត (ឯកត្តជននារី) កីឡាការិនីកងយោធពលខេមរភូមិន្ទបានបំបែក

ឯកត្តកម្មជាម្ចាស់មេដាយមាសពិភពលោកជាប់គ្នា៤លើក(ឆ្នាំ២០១៣នៅប្រទេសបារាំង ឆ្នាំ២០១៥នៅប្រទេស ថៃ ឆ្នាំ២០១៧នៅប្រទេសចិន និងឆ្នាំ២០១៩នៅព្រះរាជាណាចក្រកម្ពុជា)។ រីឯការទៅចូលរួមប្រកួតនៅក្រៅប្រទេសលើវិញ្ញាសា ការ៉ាតេដូជើងឯកអាស៊ីលើកទី១៨ វិញ្ញាសាឈិនឡូនជើងឯកពិភពលោកលើកទី៣៤ និងវិញ្ញាសាការ៉ាតេដូជើងឯកនគរបាល ពិភពលោកនៅប្រទេសម៉ាឡេស៊ី ថៃ និងសាធារណរដ្ឋប្រជាមានិតចិនបានទទួលមេដាយមាស៥គ្រឿង ប្រាក់២គ្រឿង សំរឹទ្ធ២គ្រឿង។

**ម៉ុំទី២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស**

**១- ការបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន**

| ក្រសួង ស្ថាប័ន | ឆ្នាំ២០១៨ | | | ឆ្នាំ២០១៩ | | |
|---|---|---|---|---|---|---|
| | សរុប | ក្នុងប្រទេស | ក្រៅប្រទេស | សរុប | ក្នុងប្រទេស | ក្រៅប្រទេស |
| ១- ទីស្តីការគណៈរដ្ឋមន្ត្រី | **៥៩៥** | ៥៧២ | ២៣ | **២៤៤** | ១៨១ | ៦៣ |
| ២- ក្រសួងមហាផ្ទៃ | **៤ ៣៩១** | ៣ ៧៤៦ | ៦៤៥ | **៣ ១២៦** | | |
| ៣- ក្រសួងការពារជាតិ | **១ ៤៦៤ ០៣៨** | ១ ៤៦០ ៩០១ | ៣ ១៣៧ | **៧ ០១១** | ៥ ៧០៤ | ១ ៣០៧ |
| ៤- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | **៣៦៨** | ២៥៨ | ១១០ | **៤៣០** | ៣៥២ | ៧៨ |
| ៥- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | **៤៧៧** | ៨៥ | ៣៩២ | **៤៧៨** | ២១៥ | ២៦៣ |
| ៦- ក្រសួងអភិវឌ្ឍន៍ជនបទ | **៤ ៣៤៩** | ៤ ៣៣១ | ១៨ | **១ ១១១** | ១ ០៧០ | ៤១ |
| ៧- ក្រសួងមុខងារសាធារណៈ | **៧៧២** | ៧២៥ | ៤៧ | **១ ៨២៨** | ១ ៧៣១ | ៩៧ |
| ៨- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | **១ ៣១០** | ៩៨០ | ៣៣០ | **១ ១៤៧** | ៧៩៣ | ៣៥៤ |
| ៩-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | **៧ ០៨០** | ៦ ៧៨០ | ៣០០ | **១ ៣១០** | ១ ០២៩ | ២៨១ |
| ១០- ក្រសួងទេសចរណ៍ | **៦៦៨** | ៦១១ | ៥៧ | **៥៣០** | ៤០៨ | ១២២ |
| ១១- ក្រសួងធនធានទឹកនិងឧតុនិយម | **៥១៥** | ៤៦៥ | ៥០ | **៥៨៤** | ៥៣៣ | ៥១ |
| ១២.ក្រសួងរ៉ែ និងថាមពល | **១ ០០៩** | ៨៨១ | ១២៨ | **២ ១១៩** | ១ ៩៥៧ | ១៦២ |
| ១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | **៧៦៩** | ៦៤៦ | ១២៣ | **៧៤៥** | ៥៥៤ | ១៩១ |
| ១៤- ក្រសួងបរិស្ថាន | **៩១៣** | ៨២១ | ៩២ | **១ ០៥០** | ៩៦៦ | ៨៤ |
| ១៥- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | **២ ៩១៦** | ២ ២៨០ | ៦៣៦ | **២ ២៦៨** | ១ ៣៥២ | ៩១៦ |
| ១៦- ក្រសួងកិច្ចការនារី | **៤៥** | ២៤ | ២១ | **៩៥** | ៤៣ | ៥២ |
| ១៧- ក្រសួងពាណិជ្ជកម្ម | **២៤០** | ២៣២ | ៨ | **១៧៧** | ១០៧ | ៧០ |
| ១៨- ក្រសួងអប់រំ យុវជន និងកីឡា | **១៦១** | ៦០ | ១០១ | **១១២** | ២១ | ៩១ |
| ១៩- ក្រសួងផែនការ | **៦០** | ៥០ | ១០ | **១០២** | ៨១ | ២១ |
| ២០- ក្រសួងយុត្តិធម៌ | **៥** | ២ | ៣ | **៥៣** | ២៩ | ២៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ២១- ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | | | **៣៥៤** | ៣៤៩ | ៥ |
| ២២- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | | | | **១៩** | ៨ | ១១ |
| ២៤- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | | | | **១ ៨៤៩** | ១ ៨៤៩ | |
| ២៥- ក្រសួងធម្មការនិងសាសនា | | | | **២១** | ២១ | |
| ២៦- រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល | **៣៣៣** | ២៨៩ | ៤៤ | **៦០៣** | ៥០៦ | ៩៧ |
| ២៧- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | **៣០** | ២៨ | ២ | | | |
| **សរុប** | **១៤៩១ ១៤៥** | ១ ៤៨៤ ៧៧១ | ៦ ៣៧៤ | **១៧ ៤៩៣** | ១៤ ៣៤៦ | ៣ ១៤៧ |

## ២- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

**២.១- ក្រសួងមហាផ្ទៃតាមរយៈសាលាបណ្ឌិត្យសភានគរបាលកម្ពុជា** : បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារចំនួន១៤ថ្នាក់និង៥៣វគ្គសិក្សា មាននិស្សិត សិក្ខាកាមសរុបចំនួន៥ ៣២៤រូប(ស្រី៥៥០រូប) ក្នុងនោះថ្នាក់វគ្គសិក្សាបានបញ្ចប់ជាស្ថាពរ៣ថ្នាក់និង៣៦វគ្គសិក្សា មាននិស្សិត សិក្ខាកាមនិងសិស្ស៣ ២៣០រូប(ស្រី២៦៥រូប) និងថ្នាក់វគ្គសិក្សាកំពុងបន្តចំនួន១១ថ្នាក់និង១៧វគ្គសិក្សា មាននិស្សិត សិក្ខាកាមនិងសិស្ស២ ០៩៤រូប(ស្រី២៨៥រូប)។ ទន្ទឹមគ្នានេះ ក៏បានធ្វើការលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំនិងគ្រូនគរបាលជាតិតាមរយៈការបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងចាត់បញ្ជូនទៅសិក្សាក្នុងនិងក្រៅប្រទេស៤៦៦រូប ក្នុងនោះគ្រូនគរបាលជាតិ១៤៨រូប(ទៅសិក្សានៅក្រៅប្រទេស៥៧រូប)។

**២.២- ក្រសួងមុខងារសាធារណៈតាមរយៈសាលាភូមិន្ទរដ្ឋបាល** : បានខិតខំពង្រឹង និងពង្រីកសមត្ថភាពនៃការបណ្តុះបណ្តាលតាមរយៈការកែសម្រួល អភិវឌ្ឍជាបន្តបន្ទាប់ និងបញ្ចូលកម្មវិធីសិក្សាថ្មីៗមួយចំនួនដូចជាការចុះអនុវត្តការងារសង្គម កម្មវិធីមនុស្សធម៌ និងកម្មវិធីកីឡា ព្រមទាំងបង្កើនសូចនាករបណ្តុះបណ្តាលមន្ត្រីពីចំនួន៣ ៥០០នាក់ នៅក្នុងឆ្នាំ២០១៨ ទៅ៤ ៥០០នាក់ នៅក្នុងឆ្នាំ២០១៩។ ដោយឡែកនៅក្នុងរយៈពេល៩ខែ ក្នុងឆ្នាំ២០១៩ សាលាភូមិន្ទរដ្ឋបាលបានសម្រេចគោលដៅប្រមាណ១០០%នៃផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ។ ជារួម ការកសាងសមត្ថភាពមន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាលនៅក្នុងរយៈពេលចុងក្រោយនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ ដូចខាងក្រោមៈ

**ស្ថិតិបណ្តុះបណ្តាលដំបូង**

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១០ (២០១៨-២០១៩) | | | ៦០ | ១៥ | ៦០ | ១៥ |
| សិស្សក្រមការជំនាន់ទី៨ | | | ១១៩ | ៣២ | ១១៩ | ៣២ |
| សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី ឆ្នាំ២០១៧ | ៨៧៥ | ៣២៧ | | | ៨៧៥ | ៣២៧ |

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី ឆ្នាំ២០១៨ | | | ៤០៩ | ១៧៨ | ៤០៩ | ១៧៨ |
| សរុប | ៨៧៥ | ៣២៧ | ៥៨៨ | ២២៥ | ១ ៤៦៣ | ៥៥២ |

**ស្ថិតិបណ្តុះបណ្តាលបន្ត**

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | ២៨៧ | ៣៤ | | | ២៨៧ | ៣៤ |
| វគ្គវិក្រឹត្យការមន្ត្រីមធ្យម | ១១៥ | ២៤ | | | ១១៥ | ២៤ |
| វគ្គបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថាន | ៦០ | ១៧ | ៤៧ | ៦ | ១០៧ | ២៣ |
| វគ្គគ្រប់គ្រងគ្រឹះស្ថានសិក្សាជានាយកសាលាខេត្តព្រៃវែងនិងខេត្តកណ្តាល នៃក្រអយក. | ១៥៩ | ១៥ | | | ១៥៩ | ១៥ |
| វគ្គពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ៣៧ | ១១ | ៣៧ | ១៨ | ៧៤ | ២៩ |
| វគ្គខ្លីជំនាញរដ្ឋបាលសាធារណៈ | ៥៧៦ | ៧៨ | ២៤០ | ៥៦ | ៨១៦ | ១៣៤ |
| វគ្គខ្លីជំនាញគ្រប់គ្រងអង្គភាពសាធារណៈ | ២៥៨ | ៤៤ | ៧៧ | ១៦ | ៣៣៥ | ៦០ |
| វគ្គខ្លីនវានុវត្តន៍ | ១២៧ | ២៨ | ៣៩៦ | ១០៨ | ៥២៣ | ១៣៦ |
| វគ្គថ្នាក់ដឹកនាំនិងគណៈគ្រប់គ្រងជាស្ត្រី | | | ១៦៤ | ១៦៤ | ១៦៤ | ១៦៤ |
| វគ្គបណ្តុះបណ្តាលស្តីពីតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុកពាមរក៍ខេត្តព្រៃវែង | | | ២៦ | ៥ | ២៦ | ៥ |
| វគ្គបណ្តុះបណ្តាលបណ្ណាញខុទ្ទកាល័យ | | | ៤០ | ៩ | ៤០ | ៩ |
| សរុប | ១ ៦១៩ | ២៥១ | ១ ០២៧ | ៣៨២ | ២ ៦៤៦ | ៦៣៣ |

## ២.៣- វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ ស្ថិតក្រោមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖

ក្នុងឆ្នាំ២០១៩ វិទ្យាស្ថានបានបង្កើតវគ្គបណ្តុះបណ្តាល ដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាលរយៈពេលខ្លី(លើសពី៣ខែ)ចំនួន១៥វគ្គ អ្នកចូលរួមសរុប៤៨៧រូប(ស្រី១៧៦រូប)
- វគ្គបណ្តុះបណ្តាលរយៈពេលខ្លី(ពី១ខែដល់៣ខែ)ចំនួន៨វគ្គ អ្នកចូលរួមសរុប២១៤រូប(ស្រី៥៣រូប)
- វគ្គបណ្តុះបណ្តាលរយៈពេលខ្លី(តិចជាង១ខែ)ចំនួន៣១វគ្គ អ្នកចូលរួមសរុប១ ៤២១រូប(ស្រី៥៦៣រូប)។

## ២.៤- ក្រសួងសុខាភិបាល តាមរយៈគ្រឹះស្ថានបណ្តុះបណ្តាលរដ្ឋនិងឯកជន

**១- ការបណ្តុះបណ្តាលមុនពេលបម្រើការងារកម្រិតឧត្តម (បរិញ្ញាបត្រឡើង)**

- ប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់មូលដ្ឋានកម្រិតបរិញ្ញាបត្រ១ ៩០៥នាក់

| |
|---|
| - និស្សិតកំពុងសិក្សាកម្រិតបរិញ្ញាបត្រឡើងទៅនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលរដ្ឋ និងឯកជនទាំង៨មានចំនួន៧ ៣៣០នាក់(ស្រី៣ ៦៧០នាក់)<br>- និស្សិតប្រឡងចេញថ្នាក់ជាតិកម្រិតបរិញ្ញាបត្រលើកទី១ជាប់ជាស្ថាពរ១ ១៤៤នាក់និងធ្លាក់១០១នាក់ ក្នុងចំណោមបេក្ខជនដាក់ពាក្យប្រឡងសរុប១ ២៤៥នាក់ និងប្រឡងលើកទី២ជាប់ជាស្ថាពរ១៣៨នាក់និងធ្លាក់៩នាក់ ក្នុងចំណោមបេក្ខជនដាក់ពាក្យប្រឡងសរុប១៤៧នាក់។ |
| **២- ការបណ្តុះបណ្តាលមុនពេលបម្រើការងារកម្រិតមធ្យម (បរិញ្ញាបត្ររង)**<br>- ប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់ឆ្នាំទី១កម្រិតបរិញ្ញាបត្ររង១ ៤៨០នាក់<br>- និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលរដ្ឋនិងឯកជនទាំង១៨ មានចំនួន៤ ៧៤១នាក់(ស្រី៣ ០១១នាក់)<br>- និស្សិតប្រឡងចេញថ្នាក់ជាតិកម្រិតបរិញ្ញាបត្ររងលើកទី១ជាប់ជាស្ថាពរ២ ៦៥៥នាក់និងធ្លាក់៤២១នាក់ ក្នុងចំណោមបេក្ខជនដាក់ពាក្យប្រឡងសរុប៣ ០៧៦នាក់ និងប្រឡងលើកទី២ជាប់ជាស្ថាពរ២១៧នាក់ និងធ្លាក់២៩៤នាក់ ក្នុងចំណោមបេក្ខជនដាក់ពាក្យប្រឡងសរុប៥១១នាក់។ |
| **៣- ការបណ្តុះបណ្តាលក្រោយមូលដ្ឋាន** : ក្នុងប្រទេសសម្រាប់ថ្នាក់វេជ្ជបណ្ឌិតឯកទេសឆ្នាំសិក្សា២០១៨-២០១៩ មានចំនួន១៥៦នាក់ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំសិក្សា២០១៨-២០២០ មានចំនួន៧៩នាក់។ |
| **៤- ការបណ្តុះបណ្តាលពេលកំពុងបម្រើការងារ** : បញ្ជូនមន្ត្រីសុខាភិបាលទៅក្រៅប្រទេសចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលរយៈពេលតិចជាង៦ខែចំនួន៦៤៣នាក់(ស្រី១៣២នាក់) និងបណ្តុះបណ្តាលរយៈពេលលើសពី៦ខែចំនួន២២នាក់(ស្រី៧នាក់)។ |

## ២.៥- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគ្រឹះស្ថានសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ៖

ចាប់ពីខែកញ្ញា ២០១៨ ដល់ខែកក្កដា២០១៩ ការបណ្តុះបណ្តាលសិស្សនិស្សិតដែលស្ថិតនៅក្រោមគ្រឹះស្ថានសាធារណៈមានចំនួនសរុប៤៣ ១៧១នាក់(ស្រី១៣ ៩៨៨នាក់) ដែលក្នុងនោះកម្រិតក្រោយឧត្តមចំនួន១៧៨នាក់ កម្រិតឧត្តម១៨ ០៤៥នាក់ កម្រិតជាន់ខ្ពស់បច្ចេកទេស/បរិញ្ញាបត្ររង៨ ៨៥៩នាក់ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត១ ២ ៣ ចំនួន៣ ៦៣០នាក់ និងកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ១២ ៤៥៩នាក់។

| **សិស្ស និស្សិតកំពុងបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សាអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(អ.ប.វ)** | | | |
|---|---|---|---|
| ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | | កញ្ញា ២០១៨ - កក្កដា ២០១៩ | |
| | | សរុប | ស្រី |
| ១- សាធារណៈ | | | |
| ១ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ១៧៨ | ២៥ |
| ២ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ១៨ ០៤៥ | ៤ ៤៣៥ |
| ៣ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៨ ៨៥៩ | ២ ១២៨ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ៤៧២ | ៧៧ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ៨២៤ | ១៤៩ |
| ៦ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ២ ៣៣៤ | ៦០៧ |
| ៧ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ១២ ៤៥៩ | ៦ ៥៦៧ |

| | | | |
|---|---|---|---|
| សរុប(១) | | ៤៣ ១៧១ | ១៣ ៩៨៨ |
| ២- ឯកជន | | | |
| ១ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ៣៣៣ | ១០៧ |
| ២ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ៤ ០៨៣ | ២ ១៩៨ |
| ៣ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៤៧៤ | ១៧៤ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ០ | ០ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ៥៥ | ២៧ |
| ៦ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ៨០ | ២៨ |
| ៧ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ១ ១១៦ | ៣៨០ |
| សរុប(២) | | ៦ ១៤១ | ២ ៩២៤ |
| ៣ - អង្គការ-សមាគម | | | |
| ១ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ១៥ | ១១ |
| ២ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ១ ១៧១ | ៥៨៥ |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ១៦៦ | ១៩ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ៣១៩ | ១៦១ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ៤៩៧ | ២០៤ |
| ៦ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ០ | ០ |
| សរុប(៣) | | ២ ១៦៨ | ៩៨០ |
| **សរុបរួម(១+២+៣)** | | **៥១ ៤៨០** | **១៧ ៨៩២** |

| | | | |
|---|---|---|---|
| **សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថាន( អ.ប.វ.) ឆ្នាំ២០១៧-២០១៨** | | | |
| ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | | កញ្ញា ២០១៨ - កក្កដា ២០១៩ | |
| | | សរុប | ស្រី |
| ១- សាធារណៈ | | | |
| ១ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ២៧ | ២ |
| ២ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ៤ ៦៩៦ | ១ ៨៣០ |
| ៣ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៤ ១៣៣ | ១ ០២០ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ២៣៨ | ៥២ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ២៧០ | ៥៨ |
| ៦ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ១ ៦៦០ | ៤៤០ |
| ៧ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ២៧ ១៣៥ | ១៥ ៩៣២ |
| សរុប(១) | | ៣៨ ១៥៩ | ១៩ ៣៣៤ |

| | | | |
|---|---|---|---|
| ២- ឯកជន | | | |
| ១ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ២៤ | ៥ |
| ២ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ៧៦០ | ៣៥៧ |
| ៣ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ២១៧ | ៦៨ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ០ | ០ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ២២ | ៩ |
| ៦ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ០ | ០ |
| ៧ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ១ ៧១៥ | ៤៦៨ |
| សរុប (២) | | ២ ៧៣៨ | ៩០៧ |
| ៣- អង្គការ-សមាគម | | | |
| ១ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ៦៦ | ៤៤ |
| ២ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៥៥៨ | ២៤៧ |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | ១៦០ | ១០២ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | ២២១ | ៨៩ |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | ៣១៣ | ១៤៦ |
| ៦ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ៦ ០០០ | ១ ៧២០ |
| សរុប (៣) | | ៧ ៣១៨ | ២ ៣៤៨ |
| **សរុបរួម (១+២+៣)** | | **៤៨ ២១៥** | **២២ ៥៨៩** |

**២.៦- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ក- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ**( គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ )

- និស្សិតឆ្នាំសិក្សា២០១៨-២០១៩ បានប្រឡងបញ្ចប់ការសិក្សាជាស្ថាពរនៅមហាវិទ្យាល័យទាំង៥ ចំនួន២៤៤នាក់(ស្រី៩០នាក់)
- ឆ្នាំសិក្សា២០១៨-២០១៩ មាននិស្សិតកំពុងសិក្សាសរុបចំនួន២ ៤៣៥នាក់(ស្រី៩៧១នាក់)។

**ខ- សាលាមធ្យមសិក្សាវិចិត្រសិល្បៈ**

- ឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សកំពុងសិក្សាសរុបចំនួន៩៧១នាក់(ស្រី៥១០នាក់)
- ឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សប្រឡងយកសញ្ញាបត្រសិល្បៈនិងស្នាតកបត្រសិល្បៈជាប់ជាស្ថាពរសរុបចំនួន១៦២នាក់(ស្រី៨៧នាក់)
- ឆ្នាំសិក្សា២០១៩-២០២០(គិតពីខែមករា-ធ្នូ ឆ្នាំ២០១៩) សិស្សប្រឡងចូលរៀនសរុបចំនួន២៦៤នាក់(ស្រី១១៧នាក់)។

**២.៧- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

| បរិយាយ | ២០១៨ (១ឆ្នាំ) | ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) |
|---|---|---|
| បណ្តុះបណ្តាលវិជ្ជាជីវៈ (រយៈពេលវែង) | | |
| ថ្នាក់ពិសេសមធ្យមសុរិយោដី | ១វគ្គ មានសិក្ខាកាម២៧នាក់ | ១វគ្គ មានសិក្ខាកាម១៩នាក់ |

| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្ររងរៀបចំដែនដី | ១វគ្គ មានសិក្ខាកាម១៧នាក់ | គ្មាន |
| បញ្ជូនមន្ត្រីចូលវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | | |
| ក្នុងប្រទេស | ២៥៨នាក់ | ២៧៣នាក់ |
| ក្រៅប្រទេស | ១១០នាក់ | ៦៩នាក់ |

## ២.៨- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| ១- សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង | | | | |
|---|---|---|---|---|
| ស្ថិតិនិស្សិត(អាហារូបករណ៍) | | | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ១១១ | ៤២ | ១០៣ | ៤៩ |
| វិទ្យាសាស្ត្រសត្វ | ៨១ | ២២ | ៧៤ | ២៥ |
| វេជ្ជសាស្ត្រសត្វ | ៧៣ | ៣២ | ៧៨ | ៤០ |
| វិទ្យាសាស្ត្រព្រៃឈើ | ៥៩ | ២៦ | ៦៩ | ២៩ |
| វិទ្យាសាស្ត្រជលផល | ៧៣ | ៣១ | ៨៣ | ៣៨ |
| វិស្វកម្មកសិកម្ម | ៨៧ | ២២ | ៧៦ | ២៣ |
| សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ | ៨៤ | ៤៥ | ៨៣ | ៤៤ |
| កសិឧស្សាហកម្ម | ១២៩ | ៧៧ | ១២៦ | ៧៣ |
| រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៨៣ | ៤១ | ១១០ | ៥៥ |
| វិទ្យាសាស្ត្រកៅស៊ូ | ៣២ | ១៩ | ២៣ | ១៦ |
| **សរុបរួម** | **៨១២** | **៣៥៧** | **៨២៥** | **៣៩២** |
| **ស្ថិតិនិស្សិតបង់ថ្លៃសិក្សា** | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ៦៨៧ | ២០៧ | ៧០៩ | ២៤៩ |
| វិទ្យាសាស្ត្រសត្វ | ៨៣ | ១០ | ៨៨ | ១៥ |
| វេជ្ជសាស្ត្រសត្វ | ៥៥៥ | ១១០ | ៤៨១ | ១០៥ |
| វិទ្យាសាស្ត្រព្រៃឈើ | ៦ | ២ | ១៧ | ៦ |
| វិទ្យាសាស្ត្រជលផល | ២៧ | ៥ | ២៦ | ១០ |
| វិស្វកម្មកសិកម្ម | ១៦ | ១ | ២៣ | ១ |
| សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ | ១៥១ | ៦៦ | ១២៧ | ៥៦ |
| កសិឧស្សាហកម្ម | ៣២៧ | ២០៨ | ៤២២ | ២៦៧ |
| រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ១៣៩ | ៣៩ | ២២៥ | ៦៦ |
| វិទ្យាសាស្ត្រកៅស៊ូ | ៦ | ១ | ៦ | ៣ |
| **សរុបរួម** | **១ ៩៩៧** | **៦៤៩** | **២ ១២៤** | **៧៧៨** |

| ២- សាលាជាតិកសិកម្មព្រែកលៀប | | | | |
|---|---|---|---|---|
| **ស្ថិតិនិស្សិត** | | | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ១៨៩ | ៦៦ | ១៧១ | ៧៤ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ២២៥ | ៥០ | ២០៣ | ៥៤ |
| វិទ្យាសាស្ត្រព្រៃឈើ | ៤៥ | ២០ | ៤៤ | ១៩ |
| វិទ្យាសាស្ត្រជលផល | ៥៤ | ២២ | ៥៧ | ២៨ |
| វិស្វកម្មកសិកម្ម | ១៣ | ១ | ១២ | ១ |
| សេដ្ឋកិច្ចកសិកម្ម | ៤៧ | ២៣ | ៥៤ | ២៤ |
| ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៥៨ | ៣០ | ៦៥ | ៣៧ |
| កសិឧស្សាហកម្ម | ៤៨ | ២៧ | ៤៩ | ៣០ |
| សុរិយោដីនិងការគ្រប់គ្រងដី | ១០១ | ៣២ | ១៣៦ | ៣៩ |
| វិទ្យាសាស្ត្រកៅស៊ូ | ០ | ០ | ០ | ០ |
| **សរុបរួម** | **៧៨០** | **២៧១** | **៧៩១** | **៣០៦** |
| **ស្ថិតិនិស្សិតបង់ថ្លៃសិក្សា** | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ១១៦ | ៣៨ | ៨៣ | ៣០ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ១៥៩ | ៣៣ | ១៣៨ | ២៨ |
| វិទ្យាសាស្ត្រព្រៃឈើ | ៩ | ១ | ១១ | ៥ |
| វិទ្យាសាស្ត្រជលផល | ៦ | ២ | ១៣ | ៦ |
| វិស្វកម្មកសិកម្ម | ០ | ០ | ២ | ០ |
| សេដ្ឋកិច្ចកសិកម្ម | ៧ | ៣ | ៧ | ៤ |
| ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ១៣ | ៤ | ១០ | ៤ |
| កសិឧស្សាហកម្ម | ៩ | ២ | ៧ | ៣ |
| សុរិយោដីនិងការគ្រប់គ្រងដី | ៥៤ | ១៧ | ៥៩ | ១៦ |
| **សរុបរួម** | **៣៧៣** | **១០០** | **៣៣០** | **៩៦** |
| **ស្ថិតិនិស្សិតអាហារូបករណ៍** | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ៧៣ | ២៨ | ៨៨ | ៤៤ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៦៦ | ១៧ | ៦៥ | ២៦ |
| វិទ្យាសាស្ត្រព្រៃឈើ | ៣៦ | ១៩ | ៣៣ | ១៤ |
| វិទ្យាសាស្ត្រជលផល | ៤៨ | ២០ | ៤៤ | ២២ |
| វិស្វកម្មកសិកម្ម | ១៣ | ១ | ១០ | ១ |
| សេដ្ឋកិច្ចកសិកម្ម | ៤០ | ២០ | ៤៧ | ២០ |
| ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៤៥ | ២៦ | ៥៥ | ៣៣ |

| | | | | |
|---|---|---|---|---|
| កសិឧស្សាហកម្ម | ៣៩ | ២៥ | ៤២ | ២៧ |
| សុរិយោដីនិងការគ្រប់គ្រងដី | ៤៧ | ១៥ | ៧៧ | ២៣ |
| **សរុបរួម** | **៤០៧** | **១៧១** | **៤៦១** | **២១០** |
| **ស្ថិតិនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បានបញ្ចប់ការសិក្សាពីឆ្នាំ២០១៧-២០១៩** | | | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ២២ | ៨ | ៣៦ | ១៥ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៤៦ | ៦ | ២៣ | ៧ |
| វិទ្យាសាស្ត្រជលផល | ៦ | ២ | ១១ | ៤ |
| សេដ្ឋកិច្ចកសិកម្ម | ៨ | ៥ | ៨ | ៤ |
| **សរុបរួម** | **៨២** | **២១** | **៧៨** | **៣០** |
| **ស្ថិតិនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររង បានបញ្ចប់ការសិក្សាពីឆ្នាំ២០១៧-២០១៩** | | | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ២២ | ៩ | ២១ | ៦ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៣៦ | ៦ | ២៥ | ៨ |
| វិទ្យាសាស្ត្រជលផល | ១០ | ៦ | ៣ | ១ |
| សេដ្ឋកិច្ចកសិកម្ម | ៣ | ៣ | ៣ | ០ |
| **សរុបរួម** | **៧១** | **២៤** | **៥២** | **១៥** |
| **ស្ថិតិនិស្សិតបង់ថ្លៃថ្នាក់បរិញ្ញាបត្រ បានបញ្ចប់ការសិក្សាពីឆ្នាំ២០១៧-២០១៩** | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ១៤ | ៦ | ២៦ | ៨ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ២៩ | ៥ | ២៦ | ៧ |
| **សរុបរួម** | **៤៣** | **១១** | **៥២** | **១៥** |
| **៣- សាលាជាតិកសិកម្មកំពង់ចាម** | | | | |
| **ស្ថិតិនិស្សិតកំពុងសិក្សា ថ្នាក់បរិញ្ញាបត្ររង(អាហារូបករណ៍)** | | | | |
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ០ | ០ | ៣៧ | ១២ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ០ | ០ | ២៦ | ៧ |
| វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ១៦ | ៤ |
| វិទ្យាសាស្ត្រជលផល | ០ | ០ | ១៥ | ៥ |
| វិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | ០ | ០ | ១៤ | ៦ |
| **សរុបរួម** | **០** | **០** | **៩៣** | **៣៤** |

| ស្ថិតិនិស្សិតកំពុងសិក្សា ថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩(បង់ថ្លៃ) | | | | |
|---|---|---|---|---|
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | | | ៤១ | ២០ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | | | ៥៦ | ៩ |
| វិទ្យាសាស្ត្រជលផល | | | ១៩ | ៨ |
| **សរុបរួម** | **០** | **០** | **១១៦** | **៣៧** |

| ស្ថិតិនិស្សិតកំពុងសិក្សា ថ្នាក់បរិញ្ញាបត្រ (អាហារូបករណ៍) | | | | |
|---|---|---|---|---|
| ឆ្នាំសិក្សា | ២០១៧-២០១៨ | | ២០១៨-២០១៩ | |
| | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | | | ៧៩ | ៤៩ |
| វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | | | ៧៣ | ២៧ |
| វិទ្យាសាស្ត្រដំណាំកៅស៊ូ | | | ៣០ | ៥ |
| វិទ្យាសាស្ត្រជលផល | | | ២៧ | ១៣ |
| វិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | | | ៦១ | ៤៤ |
| **សរុបរួម** | ០ | ០ | **២៧០** | **១៣៨** |

**២.៩- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមរយៈវិទ្យាស្ថានជាតិ សង្គមកិច្ច មានសិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រចំនួន១៨៦នាក់ ក្នុងនោះ ជំនាញភាពជាអ្នកដឹកនាំ ៧៦នាក់ ជំនាញរៀបចំផែនការយុទ្ធសាស្ត្រ៣០នាក់ និងជំនាញមូលដ្ឋានគ្រឹះនៃការផ្តល់សេវាសង្គមកិច្ច៨០នាក់ និងនិស្សិតកំពុងបន្តការសិក្សាចំនួន៤៩០នាក់(ស្រី២៦១នាក់)

| និស្សិតកំពុងសិក្សាតាមឆ្នាំនិងជំនាញ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | បរិញ្ញាបត្រ | ចំនួននិស្សិត(ឯកតាៈនាក់) | | | | |
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | **សរុប** |
| ១ | សង្គមកិច្ច | ១៩ | ៤០ | ២១ | ២១ | **១០១** |
| ២ | សង្គមវិទ្យា | ៣៥ | ៩ | ៥ | ១០ | **៥៩** |
| ៣ | កិច្ចគាំពារសង្គម | ២៣ | ១៤ | ៧ | ១១ | **៥៥** |
| ៤ | គ្រប់គ្រងសាធារណៈ | ៤៤ | ១៧ | ១៧ | ១២ | **៩០** |
| ៥ | រដ្ឋបាលសាធារណៈ | ១៥ | ៣៩ | ១៩ | ២៦ | **៩៩** |
| ៦ | គោលនយោបាយសង្គម | ៩ | ៥ | | | **១៤** |
| ៧ | គោលនយោបាយសាធារណៈ | ៦ | ១០ | | | **១៦** |
| ៨ | អក្សរសាស្ត្រអង់គ្លេស | ៨ | ១៥ | ៦ | ៨ | **៣៧** |
| ៩ | វិស្វកម្មឧស្សាហកម្មសិប្បនិម្មិតនិងរណប | ៨ | ៥ | | ៦ | **១៩** |
| **សរុប** | | **១៦៧** | **១៥៤** | **៧៥** | **៩៤** | **៤៩០** |

**២.១០- ក្រសួងផែនការ** ក្រសួងផែនការក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានសម្របសម្រួលនិងដឹកនាំរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣ ដែលជាឧបករណ៍យ៉ាងសំខាន់សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦នៃរដ្ឋសភា។ ផ.យ.អ.ជ. ២០១៩-២០២៣នេះ ក៏ជាឯកសារគោលសម្រាប់ក្រសួង ស្ថាប័ននានា រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងវិស័យរបស់ខ្លួន រួមទាំងក្រសួងផែនការផ្ទាល់ក៏បានរៀបចំផែនការយុទ្ធសាស្ត្រក្រសួងផែនការ ដើម្បីចូលរួមអនុវត្តបណ្តាគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់ក្នុងផ.យ.អ.ជ.២០១៩-២០២៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះ។ ជាមួយគ្នានេះ ក្រសួងផែនការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរៀបចំធ្វើមូលដ្ឋាននីយកម្ម គោលដៅអភិវឌ្ឍប្រកបដោយចីរភាព(គ.អ.ច.)២០១៦-២០៣០មកក្នុងបរិការណ៍កម្ពុជា ដើម្បីរួមបញ្ចូលជាមួយគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍកម្ពុជា និងចូលរួមធ្វើឱ្យសម្រេចបានគោលដៅនានារបស់គ.អ.ច.សាកល។ មកដល់ពេលនេះ ក្រសួងផែនការបានសហការនឹងដឹកនាំរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) ២០១៦-២០៣០។

ក្រសួងផែនការក៏បានរៀបចំគោលនយោបាយជាតិប្រជាជន គោលនយោបាយជាតិស្តីពីមនុស្សចាស់ដែលជាផ្នែកយ៉ាងសំខាន់សម្រាប់គាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស។ ក្រសួងផែនការក៏បានដំណើរការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងកម្មវិធីកំណត់គ្រួសារក្រីក្រតាមការស្នើសុំ ដើម្បីកំណត់និងរកឱ្យឃើញគ្រួសារក្រីក្រពិតប្រាកដនៅតំបន់ជនបទនិងតំបន់ទីប្រជុំជន។ ព័ត៌មាននិងទិន្នន័យដែលជាលទ្ធផលនៃកម្មវិធីនេះត្រូវបានប្រើប្រាស់សម្រាប់រៀបចំគោលនយោបាយនានាសម្រាប់គាំទ្រដល់គ្រួសារក្រីក្រ ជាពិសេសកម្មវិធីផ្ទេរសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះនិងកុមារ និងកម្មវិធីបេឡាជាតិសន្តិសុខសង្គម សម្រាប់ឱ្យសម្រេចបានមុំទី៤នៃចតុកោណទី១របស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

ក្រសួងផែនការក៏ជាស្ថាប័នស្នូលដែលទទួលបន្ទុកប្រមូលនិងវិភាគទិន្នន័យ សម្រាប់បម្រើដល់ការរៀបចំគោលនយោបាយផែនការនិងការធ្វើសេចក្តីសម្រេចចិត្តនានា តាមរយៈការរៀបចំជំរឿនទូទៅនូវប្រជាជនកម្ពុជាឆ្នាំ២០១៩ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ និងអង្កេតផ្សេងៗទៀត។

ជាមួយគ្នានេះ ក្រសួងក៏បានចូលរួមអនុវត្តការងារដែលមានលក្ខណៈអន្តរវិស័យ ដូចជាការផ្សព្វផ្សាយពីការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ការបណ្តុះបណ្តាលពីយេនឌ័រនិងបញ្ជ្រាបយេនឌ័រទៅក្នុងផែនការគោលនយោបាយនិងស្ថិតិ និងបានបន្តបណ្តុះបណ្តាលដល់និស្សិតជំនាន់ទី៣០និងទី៣១ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការនិងស្ថិតិ។

**២.១១- ក្រសួងអភិវឌ្ឍន៍ជនបទ** តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍជនបទកម្ពុជា-កូរ៉េ មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពង់ស្ពឺ តាកែវ ពោធិ៍សាត់ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពត កំពង់ធំ បន្ទាយមានជ័យ សៀមរាប និងខេត្ត បាត់ដំបងបាននិងបន្តបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជាៈ ការអភិវឌ្ឍសហគមន៍ បច្ចេកទេសចិញ្ចឹមមាន់ បច្ចេកទេសចិញ្ចឹមត្រី បច្ចេកទេសដាំត្រសក់ បច្ចេកទេសចិញ្ចឹមកង្កែប-អន្ទង់ បច្ចេកទេសកែច្នៃម្ហូបអាហារ បច្ចេកទេសចិញ្ចឹមទា បច្ចេកទេសផលិតសាប៊ូលាងចាន បច្ចេកទេសបណ្តុះផ្សិត បច្ចេកទេសដាំបន្លែតាមបែបទំនើបកម្ម បច្ចេកទេសចិញ្ចឹមនិងភ្ញាស់កូនមាន់ កាត់ដេរសម្លៀកបំពាក់ អ៊ុតសក់និងកែសម្ផស្ស កុំព្យូទ័ររដ្ឋបាលភាសាអង់គ្លេស បច្ចេកទេសចិញ្ចឹមនិងព្យាបាលជ្រូក បច្ចេកទេសធ្វើជីកំប៉ុស្ត បច្ចេកទេសចិញ្ចឹមនិងព្យាបាលមាន់ ជួសជុលម៉ូតូគ្រប់ប្រភេទ ជួសជុលគ្រឿងម៉ាស៊ីនខ្នាតតូច ជួសជុលវិទ្យុម៉ាញ៉េ និងទូរទស្សន៍ ផលិតគ្រឿងសង្ហារឹមពីឫស្សី បច្ចេកទេសដាំដំណាំស្រូវ បច្ចេកទេសជួសជុលនិងថែទាំអណ្តូងស្នប់ បច្ចេកទេសដាំដំណាំគ្រួសារ កាត់សក់បុរស បច្ចេកទេសបណ្តុះកូនឈើនិងផ្សាំមែក និងបច្ចេកទេសចិញ្ចឹមក្តាមថ្ម ដែលមានសិក្ខាកាមចូលរួមសរុប **៤ ៨៥៣នាក់**(ស្រី២ ២៥៦នាក់)។

## ២.១២- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

| | | | |
|---|---|---|---|
| **១- បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ(រយៈពេល១ឆ្នាំ)** | | | |
| ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ប្រុស៤៧នាក់ | ស្រី៣៨នាក់ | សរុប៨៥នាក់ |
| ពាណិជ្ជកម្មអេឡិចត្រូនិក | ប្រុស៤០នាក់ | ស្រី៤០នាក់ | សរុប៨០នាក់ |
| ទូរគមនាគមន៍និងបណ្តាញ | ប្រុស៥៤នាក់ | ស្រី២៣នាក់ | សរុប៧៧នាក់ |
| វិទ្យាសាស្ត្រកុំព្យូទ័រ | ប្រុស៧៦នាក់ | ស្រី៥០នាក់ | សរុប១២៦នាក់ |
| **សរុប** | **ប្រុស២១៧នាក់** | **ស្រី១៥១នាក់** | **សរុប៣៦៨នាក់** |
| **២- បណ្តុះបណ្តាលរយៈពេលខ្លី(រយៈពេល១ឆ្នាំ)** | | | |
| បណ្តុះបណ្តាលពីចម្ងាយ ស្តីពីការប្រើប្រាស់ NerveNet System នៅខេត្តកំពង់ឆ្នាំង | ប្រុស២០នាក់ | ស្រី១០នាក់ | សរុប៣០នាក់ |
| បណ្តុះបណ្តាលមន្ត្រីរាជការលើវិស័យ ICT និងលើវិស័យប្រៃសណីយ៍ (រាជធានី ខេត្ត ក្រុង) | ប្រុស១៧២នាក់ | ស្រី៦៨នាក់ | សរុប២៤០នាក់ |
| បណ្តុះបណ្តាលICT សម្រាប់ការងាររដ្ឋបាលនិងកម្មវិធីទូរស័ព្ទឆ្លាតវៃជូនមន្ត្រីរាជការនិងសិស្សានុសិស្សតាមរយៈកម្មវិធីអ្នកស្ម័គ្រចិត្ត ICT កម្ពុជា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាមនិងខេត្តកំពង់ឆ្នាំង | ប្រុស៧០៤នាក់ | ស្រី១ ៤១៥ នាក់ | សរុប២ ១១៩ នាក់ |
| បណ្តុះបណ្តាលជំនាញវិស្វករ IT ដើម្បីត្រៀមប្រឡងសញ្ញាបត្រ IT Passport របស់ IPA , Japan បណ្តាក្រសួងនានា | ប្រុស២០៥នាក់ | ស្រី៣៥នាក់ | សរុប២៤០នាក់ |
| **សរុប** | ប្រុស១ ១០១ នាក់ | ស្រី១ ៥២៨នាក់ | **២ ៦២៩នាក់** |
| **៣- បណ្តុះបណ្តាលក្រៅប្រទេស(រយៈពេល១ឆ្នាំ)** | | | |
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(មន្ត្រី) | ប្រុស៣នាក់ | ស្រី០នាក់ | សរុប៣នាក់ |
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(និស្សិត) | ប្រុស១២នាក់ | ស្រី៣នាក់ | សរុប១៥នាក់ |
| អាហារូបករណ៍ទៅប្រទេសជប៉ុន(គ្រូបង្គោល) | ប្រុស១នាក់ | ស្រី០នាក់ | សរុប១នាក់ |
| អាហារូបករណ៍ទៅប្រទេសបារាំង(គ្រូបង្គោល) | ប្រុស៣នាក់ | ស្រី០នាក់ | សរុប៣នាក់ |
| **សរុប** | **ប្រុស១៩នាក់** | **ស្រី៣នាក់** | **សរុប២២នាក់** |
| **៤- បណ្តុះបណ្តាលមន្ត្រីក្នុងវិទ្យាស្ថាន(រយៈពេល១ឆ្នាំ)** | | | |
| វគ្គបណ្តុះបណ្តាលស្តីពីDeveloping Government Policies to Promote MSME Development and Attract FDIs | ប្រុស២នាក់ | ស្រី១នាក់ | សរុប៣នាក់ |
| បណ្តុះបណ្តាលស្តីពី Privatisation and Financial Reforms for MSME Development | ប្រុស០នាក់ | ស្រី៣នាក់ | សរុប៣នាក់ |
| បណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៩ | ប្រុស១នាក់ | ស្រី៥នាក់ | សរុប៦នាក់ |
| **សរុប** | **ប្រុស៣នាក់** | **ស្រី០៩នាក់** | **សរុប១២នាក់** |

**២.១៣- ក្រសួងកិច្ចការនារី** តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅ១៤ខេត្ត(ខេត្តកំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ កែប កំពត ព្រះសីហនុ កំពង់ស្ពឺ ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ) បាននិងកំពុងធ្វើការបណ្តុះបណ្តាលជំនាញអ៊ុតសក់ សម្អាងការ កាត់ដេរ ច្នៃម៉ូដ តម្បាញ កែច្នៃចំណីអាហារ និងជំនាញក្នុងការធ្វើអាជីវកម្ម ការផ្តល់សេវានិងតួនាទីភារកិច្ចដល់ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ស្ត្រីជនជាតិដើមភាគតិច និងក្មេងស្រីបោះបង់ចោលការសិក្សា សរុប១៥ ៨៥៣នាក់។

**២.១៤- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច:** តាមរយៈវិទ្យាស្ថានជាតិអធិការកិច្ច ក្រសួងបានផ្តល់ការបណ្តុះបណ្តាលជំនាញអធិការកិច្ចបឋម ជូនមន្ត្រីរាជការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៨វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣២៧រូប(ស្ត្រី ១២២រូប)និងបានសហការជាមួយអង្គការមូលនិធិអាស៊ី និងក្រុមហ៊ុនប្រឹក្សាយោបល់ CPS ផ្តល់ការបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពស្រាវជ្រាវជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០រូប(ស្ត្រីចំនួន៤រូប)។

## មុំទី៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

### ១- ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល

គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៩ មូលដ្ឋានសុខាភិបាលសាធារណៈដែលមានមុខងារផ្តល់សេវាថែទាំសុខភាពទូទាំងប្រទេស មានមណ្ឌលសុខភាព១ ២១៦ ប៉ុស្តិ៍សុខភាព១៣១ និងមន្ទីរពេទ្យបង្អែក១២៥។

ជាមួយគ្នានេះ សំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ និងមន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ កំពុងសាងសង់ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន។ មណ្ឌលសុខភាពចំនួន៤៥កន្លែង អគារសម្ភពថែទាំទារក១៥កន្លែង មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ មន្ទីរពេទ្យខេត្តប៉ៃលិននិងមន្ទីរពេទ្យខេត្តឧត្តរមានជ័យ កំពុងដំណើរការសាងសង់ដែលហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក្រោមគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល។ ដោយឡែក មន្ទីរពេទ្យខេត្តបាត់ដំបងក៏កំពុងសាងសង់ក្រោមជំនួយរបស់ប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។

### ២- ស្ថិតិបុគ្គលិកមន្ត្រីសុខាភិបាល

| បរិយាយ | ខែកញ្ញា ឆ្នាំ២០១៨ | ខែកញ្ញា ឆ្នាំ២០១៩ |
|---|---|---|
| ស្ថិតិមន្ត្រីរាជការសុខាភិបាល | | |
| មន្ត្រីបម្រើការងារក្នុងវិស័យសុខាភិបាលសាធារណៈ (នាក់) | ២៤ ៩៤៣ | ២៥ ០៣២ |
| ផ្តល់ក្របខ័ណ្ឌថ្មីចូលបម្រើការក្នុងអង្គភាព (កន្លែង) | ៧០០ | ១ ៣០០ |
| ការពង្រាយបុគ្គលិកសុខាភិបាលនៃបុគ្គលិកសរុប | | |
| បុគ្គលិកសុខាភិបាលបម្រើការងារនៅថ្នាក់រាជធានី ខេត្ត | ១៩ ២៦៧នាក់ ស្មើនឹង៧៧,២៤% | ១៩ ៤៤០នាក់ ស្មើនឹង៧៧,៦៦% |
| ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីសុខាភិបាលបានកើនឡើងពី១ ១១៤ ៤៥០រៀល/ខែក្នុងឆ្នាំ២០១៨ ដល់១ ២០០ ១០០ រៀល/ខែក្នុងឆ្នាំ២០១៩ | | |

### ៣- ការធានានិយ័តកម្មផ្នែកឱសថ

១- ស្ថិតិគ្រឹះស្ថានផ្នែកឱសថនិងគ្រឿងសំអាងៈ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ គ្រឹះស្ថានឱសថនិងឧបករណ៍បរិក្ខារពេទ្យមាន២០កន្លែង គ្រឹះស្ថានផលិតផលជំនួយសុខភាព១កន្លែង គ្រឹះស្ថានអាហារ័ណនីហារ័ណឱសថ៤២៧កន្លែង សាខាគ្រឹះស្ថានអាហារ័ណនីហារ័ណឱសថ៣១កន្លែង គ្រឹះស្ថានអាហារ័ណនីហារ័ណគ្រឿងសម្អាង ៤១៤កន្លែង មជ្ឈមណ្ឌលថែរក្សាសម្ផស្សមាន៥៧កន្លែង សាខាមជ្ឈមណ្ឌលថែរក្សាសម្ផស្សមាន ២កន្លែង និង ឱសថស្ថាន-ឱសថស្ថានរងមាន២ ៨៥១កន្លែង។

២- ការងារចុះបញ្ជិកា-ទិដ្ឋាការឱសថ : ផលិតផលឱសថដែលបានចុះបញ្ជិកា-ទិដ្ឋាការមកដល់ខែកញ្ញា ឆ្នាំ២០១៩ មានចំនួន២៣ ៦៩៧មុខ ក្នុងនោះ មានឱសថសម័យនាំចូល២ ៦១៥មុខ ឱសថផលិតក្នុងស្រុក ២៥១មុខ ផលិតផលបំប៉នសុខភាព២៩៩មុខ ឱសថបុរាណ១១២មុខ ប្រតិករ២៤៨មុខ និងផលិតផលជំនួយសុខភាព៨៣មុខ។ ក្រសួងសុខាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធចុះបញ្ជិកា-ទិដ្ឋាការឱសថតាមអនឡាញកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩។ ជាមួយគ្នានេះ ក្រសួងសុខាភិបាលបានចូលរួមរៀបចំ និងអនុវត្តកម្មវិធីច្រកចេញចូលតែមួយលើប្រព័ន្ធអនឡាញសម្រាប់ការនាំចូលនិងនាំចេញផលិតផល ឱសថ បរិក្ខារពេទ្យនិងគ្រឿងសម្អាងជាមួយអគ្គនាយកដ្ឋានគយនិងពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគ្រោងចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០១៩ខាងមុខ។

### ៤- ការគាំពារសុខភាពសង្គម

គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ ក្រសួងសុខាភិបាលបានអនុវត្តទៅលើការចំណាយការងារគាំពារសង្គមសំខាន់ៗមានដូចជា៖

១- ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន : បានផ្តល់ថវិកាដល់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ឧបត្ថម្ភស្ត្រីជាកម្មករនិយោជិតនៅពេលសម្រាលកូនបានចំនួន៨៣ ៧៦០ នាក់ សរុបជាទឹកប្រាក់ចំនួន៣៣ ៥០៤ ០៣៣ ០០០រៀល។

២- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព : បានផ្តល់ថវិកាដល់បេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ដែលបានទទួលសេវាពិនិត្យនិងព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ សរុបជាទឹកប្រាក់ចំនួន២៤ ៦៨៨ ៦៥៩ ៩៥៧រៀល។

៣- មូលនិធិសមធម៌សម្រាប់កម្មករក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ ប្រតិបត្តិករបោសសម្អាតមីន កម្មករស៊ីក្លូ : បានទូទាត់ចំណាយថវិកាមូលនិធិសមធម៌សម្រាប់ក្រុមគោលដៅខាងលើ ដែលបានមកទទួលសេវាពិនិត្យនិងព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ៧០ ០០២ករណី សរុបជាទឹកប្រាក់ចំនួន២ ១១៤ ៥១១ ០០០រៀល។

៤- មូលនិធិសមធម៌សម្រាប់ប្រជាជនក្រីក្រ : ក្រោមគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សេវាសុខាភិបាល បានទូទាត់ថវិកាមូលនិធិសមធម៌សម្រាប់ប្រជាជនក្រីក្រដែលបានមកទទួលសេវាពិនិត្យនិងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ៣ ០៧១ ៦៣៨ករណី សរុបជាទឹកប្រាក់៨៤ ៦៤៦ ៥២៦ ៥០០រៀល។

៥- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកូនអាយុក្រោម២ឆ្នាំនៃគ្រួសារមានបណ្ណសមធម៌ ឬបណ្ណអាទិភាព : បានឧបត្ថម្ភសាច់ប្រាក់ជូនអ្នកទទួលផលពីកម្មវិធីនេះតាមរយៈធនាគារឯកទេសវីង ដោយមានស្ត្រីចុះឈ្មោះក្នុងប្រព័ន្ធ CTP App ចំនួន៤៣ ៥៤១ករណី និងបានប្រើប្រាស់សេវាសរុប៩៤ ៤៥៧ករណី គិតជាទឹកប្រាក់ចំនួន៦ ១៩១ ០៨០ ០០០រៀល។

| វឌ្ឍនភាពនៃសូចនាករស្នូលក្នុងការគាំពារសុខភាពសង្គម | | | |
|---|---|---|---|
| ល.រ | សូចនាករស្នូល | លទ្ធផលសម្រេចបាន | |
| | | ២០១៨ | កញ្ញា២០១៨-កញ្ញា២០១៩ |
| ១ | ករណីដែលបានមកទទួលសេវាពិនិត្យនិងព្យាបាលជំងឺ គ្របដណ្តប់ដោយមូលនិធិសមធម៌ | ២ ៨៥៤ ៦២៩ករណី | ៣ ១៤១ ៦៤០ករណី |
| ២ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសាក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | គ្មាន | ៤៤ ១១៣ករណី |
| ៣ | កុមារអាយុក្រោមពីរឆ្នាំនៅក្នុងគ្រួសាក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | គ្មាន | ៥០ ៣៤៤ករណី |

## ៥- ការផ្តល់សេវាថែទាំសុខភាព

| ល.រ | សូចនាករស្នូល | លទ្ធផលសម្រេចបាន | |
|---|---|---|---|
| | | កញ្ញា២០១៧-កញ្ញា២០១៨ | កញ្ញា២០១៨-កញ្ញា២០១៩ |
| ១ | ការពិនិត្យជំងឺក្រៅករណីថ្មី | ១០ ៩០១ ៩១៣ករណី | ១០ ៦៨០ ០៦០ករណី |
| ២ | អត្រាប្រើប្រាស់គ្រែ | ១០១,៧៣% | ១០៩,១៨% |
| ៣ | ស្ត្រីពិនិត្យថៃទាំគក៌លើកទី៤ | ២៨០ ២៩០ករណី | ២៨២ ៨៣៧ករណី |
| ៤ | ស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាល | ៣១០ ៣៨៧នាក់ | ៣១២ ៧២៦នាក់ |
| ៥ | ស្ត្រីសម្រាលកូននៅមូលដ្ឋានសុខាភិបាល | ២៨៩ ៤៤៤នាក់ | ៣០២ ៦៥៤នាក់ |
| ៦ | ស្ត្រីក្រោយសម្រាលកូនបានទទួលការពិនិត្យថៃទាំលើកទី១ | ២៤៦ ៨១៥នាក់ | ២៤៥ ៨៦៨នាក់ |
| ៧ | កុមារអាយុក្រោម១ឆ្នាំទទួលវ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ៣ដូស | ២៤៦ ៨១៩នាក់ | ៣៨០ ៦៨៣នាក់ |
| ៨ | កុមារអាយុក្រោម១ឆ្នាំទទួលវ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល-ស្អូច | ៣៣២ ៦៥៥នាក់ | ៣៨០ ៥៩៦នាក់ |
| ៩ | ទារកកើតរស់បានទទួលការបំបៅដោយទឹកដោះម្តាយនៅក្នុងម៉ោងដំបូងក្រោយកំណើត | ១៩៨ ៤៣៧នាក់ | ២០១ ៣១៧នាក់ |
| ១០ | កុមារអាយុ៦-៥៩ខែបានទទួលគ្រាប់ថ្នាំជីវជាតិអា | ២ ៤៧៥ ២៦៤នាក់ | ២ ៥៨៣ ៣២៩នាក់ |
| ១១ | កុមារអាយុពី១២-៥៩ខែបានទទួលថ្នាំមេបង់ដាហ្សុល | ២ ១១៥ ២៧៩នាក់ | ២ ៣១២ ៣០៨នាក់ |
| ១២ | ស្ត្រីមានគក៌បានទទួលគ្រាប់ថ្នាំជាតិដែក/ អាស៊ីតហ្វូលិក៦០គ្រាប់ | ៣៦៥ ៦៦៨នាក់ | ៣៨០ ៥៤៦នាក់ |
| ១៣ | ប្រជាជនបានទទួលការពិនិត្យព្យាបាលជំងឺគ្រុនចាញ់(ករណីថ្មី) | ៤៣ ៤០១ករណី | ១៩ ៤៨២នាក់ |

| | | | |
|---|---|---|---|
| ១៤ | អ្នកជំងឺទឹកនោមផ្អែមបានមកពិគ្រោះពិនិត្យជំងឺក្រៅករណីថ្មី | ៥៩ ៨៨៣នាក់ | ៦៩ ១៩៥នាក់ |
| ១៥ | ការពិគ្រោះជំងឺឡើងសម្ពាធឈាមដំបូង | ២២០ ៣២៩នាក់ | ២២៧ ៨៧៤នាក់ |
| ១៦ | ស្ត្រីអាយុតិចជាង៣០ឆ្នាំបានទទួលការស្រាវជ្រាវរកមហារីកមាត់ស្បូន | ៣ ០៤១នាក់ | ១ ៨៥២នាក់ |
| ១៧ | អ្នកជំងឺភ្នែកឡើងបាយបានទទួលការវះកាត់ភ្នែកឡើងបាយ | ១១ ២២៨នាក់ | ១៩ ៧២១នាក់ |

**៦- ការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទបាន៖**

- សម្របសម្រួលការអនុវត្តគម្រោងពហុវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា(MUSEFO) និងបានបើកកិច្ចប្រជុំគណៈកម្មាធិការដឹកនាំគម្រោងខាងលើ២លើក គឺថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅភ្នំពេញ និងនៅខេត្តកំពត ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួម**៥០នាក់**

- រៀបចំវេទិកាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធលើការអនុវត្តគម្រោងកម្មវិធីនានា លើការលើកកម្ពស់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា៤លើកគឺលើកទី៦៧ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ លើកទី៦៨ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ លើកទី៦៩ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៩ លើកទី៧០ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួម**២៦៥នាក់**

- បើកសិក្ខាសាលាពិគ្រោះយោបល់គោលនយោបាយជាតិស្តីពីគម្រោងការបង្កើតបរិយាកាសងាយស្រួលសម្រាប់ស្បៀងនិងកសិកម្មដើម្បី ដោះស្រាយបញ្ហាអាហារូបត្ថម្ភ ស្ថានភាព វឌ្ឍនភាព និងទិសដៅ ២លើក គឺថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារភ្នំពេញ និងនៅសណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៩ ដែលមានអ្នកចូលរួមសរុប**៨៧នាក់**

- បើកសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយផែនទីបង្ហាញផ្លូវ ដើម្បីរៀបចំប្រព័ន្ធគាំពារសង្គម ដែលឆ្លើយតបនឹងហានិភ័យនិងវិបត្តិសម្រាប់ប្រទេសកម្ពុជា នៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមសរុប**៥៧នាក់**

- បានរៀបចំប្រជុំក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ចំនួន ២លើក គឺ លើកទី៨ និង លើកទី៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩។ ដើម្បីពិនិត្យសម្រេចលើសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ២០១៩-២០២៣ ដើម្បីធ្វើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បូកសរុបជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពចូលរួមប្រមាណជា**៧០នាក់**

- កិច្ចប្រជុំការងារបច្ចេកទេស (TWG) លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៩ ស្តីពីយុទ្ធសាស្ត្រជាតិ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៩-២០២៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងបណ្តាញសង្គមស៊ីវិល ដើម្បីពិភាក្សាគ្នាលើប្រធានបទចំនួន២ គឺ ទី១-ខ្លឹមសារសង្ខេបយុទ្ធសាស្ត្រជាតិលើកទី២ស្តីពីយុទ្ធសាស្ត្រជាតិសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ២០១៩-២០២៣ និងទី២-សូចនាករតាមដានរួមគ្នាឆ្នាំ២០១៩-២០២៣របស់ក្រុមការងារបច្ចេកទេស(TWG) លើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលក្នុងនោះមានបញ្ចូលសូចនាករតាមដានរួមគ្នាលើវិស័យទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ នាថ្ងៃទីថ្ងៃទី១៣ មិថុនា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួមប្រមាណ**៥០នាក់**

- ដឹកនាំនិងសម្របសម្រួលរៀបចំយុទ្ធសាស្ត្រជាតិស្តីពីវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ៥ឆ្នាំ (២០១៩ ដល់២០២៣)លើកទី២ និងបានបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិបាន៤លើក ដើម្បីប្រមូលធាតុចូល លើកទី១ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ លើកទី២ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ លើកទី៣ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩ និងលើកទី៤ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមសរុប**៤៣១នាក់**

- បើកកិច្ចប្រជុំប្រចាំឆ្នាំ២០១៩ស្តីពីចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា ដើម្បីបង្ហាញនិងអនុម័តនូវរបាយការណ៍វាយតម្លៃរួមនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជានិងស្វែងរកការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការជួយជំរុញបង្កើនចលនាអាហារូបត្ថម្ភនៅកម្ពុជា និងបង្ហាញពីវឌ្ឍនភាពនៃការរៀបចំឯកសារយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ឆ្នាំ២០១៩ដល់ឆ្នាំ២០២០ នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួម**២០០នាក់**

- រៀបចំវេទិកាពិភាក្សាស្តីពីការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមរយៈវិស័យកសិកម្ម នៅសាលាជាតិកសិកម្មកំពង់ចាម ដើម្បីអប់រំនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈឱ្យបានទូលំទូលាយអំពីសារៈសំខាន់របស់វិស័យកសិកម្មថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួម**៣០០នាក់**

-សហការជាមួយដៃគូក្នុងការរៀបចំវេទិកាយុវជនដើម្បីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ៣លើក លើកទី១នៅសាកលវិទ្យាល័យវេស្ទើន ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ លើកទី២ នៅសាលាជាតិកសិកម្មព្រែកលាភថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ និងលើកទី៣ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួម**៣០០នាក់**

- រៀបចំទិវាជាតិអាហារូបត្ថម្ភលើកទី៦ ក្រោមប្រធានបទ ការបំបៅកូនដោយទឹកដោះម្តាយគឺជាជម្រើសដ៏ប្រសើរសម្រាប់អភិវឌ្ឍមូលធនមនុស្សនិងសេដ្ឋកិច្ចជាតិនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានសមាសភាពពីក្រសួង ស្ថាប័នថ្នាក់ជាតិ ដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល កម្មករ ស្ត្រីមានផ្ទៃពោះ និងនិស្សិតសាកលវិទ្យាល័យសរុប**៨៥០នាក់**

- រៀបចំទិវាអាហារូបត្ថម្ភនៅថ្នាក់ក្រោមជាតិ២លើក ក្រោមប្រធានបទ ការបំបៅកូនដោយទឹកដោះម្តាយគឺជាជម្រើសដ៏ប្រសើរសម្រាប់អភិវឌ្ឍមូលធនមនុស្សនិងសេដ្ឋកិច្ចជាតិលើកទី១ នៅខេត្តសៀមរាប ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ និងលើកទី២ នៅខេត្តកំពង់ធំ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួម**៣០០នាក់**

- រៀបចំទិវាអាហារូបត្ថម្ភនៅថ្នាក់ក្រោមជាតិ ក្រោមប្រធានបទ ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នកគឺជាការវិនិយោគដ៏ប្រសើរបំផុតនៅខេត្តចំនួន៦ គឺខេត្តកំពង់ចាម សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង និងខេត្តព្រៃវែង ដែលមានអ្នកចូលរួម**៥០០នាក់**

- បានដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំ អនុក្រុមការងារស្តីពីទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភជាច្រើនលើក ដើម្បីរៀបចំសូចនាករតាមដានរួមគ្នា ស្តីពីសមាហរណកម្មវិស័យទឹកស្អាត អនាម័យ និង អាហារូបត្ថម្ភដាក់បញ្ចូលក្នុងសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០១៩-២០២៣ ដែលមាន សមាសភាពចូលរួមប្រមាណជា២០០នាក់

- បានរៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយពីវឌ្ឍនភាពការងារនៃចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា បានចំនួន២ ខេត្ត គឺៈខេត្តកំពង់ធំ និងបន្ទាយមានជ័យ ដែលមានសមាសភាពចូលរួមប្រមាណ១៥០នាក់ក្នុងមួយខេត្ត។

## ចំណុចទី៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

### ១- ការពង្រឹងសមភាពយេនឌ័រ

ក្រសួងកិច្ចការនារីសម្រេចការងារដូចខាងក្រោម៖

#### ក- ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

-សិក្ខាសាលានិងវេទិកាស្តីពីសហគ្រិនស្ត្រីក្នុងសហគ្រាសខ្នាតមីក្រូតូចនិងមធ្យម បានរៀបចំជាមួយនឹងមន្ទីរកិច្ចការនារី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី រួមជាមួយស្ថាប័នពាក់ព័ន្ធ និងសហគ្រិនស្ត្រីសរុប១២០នាក់ (ស្រី៨៧នាក់)ដើម្បីពង្រឹងបណ្តាញសហគ្រិនស្ត្រី និងស្វែងយល់អំពីតម្រូវការដើម្បីអភិវឌ្ឍសហគ្រិនភាពស្ត្រីនិងអាជីវកម្មប្រកបដោយប្រសិទ្ធភាព

- សេចក្តីព្រាងលក្ខន្តិកៈនៃបណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា (CamWEN) បានរៀបចំនិងជូនដំណឹងពីការដាក់ពាក្យចូលជាសមាជិកនៃបណ្តាញសហគ្រិនស្ត្រីកម្ពុជានិងផ្សព្វផ្សាយដើម្បីត្រៀមបង្កើតបណ្តាញជាផ្លូវការ

- សហគ្រិនស្ត្រីកម្ពុជាចំនួន៩នាក់ទទួលបានពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ានឆ្នាំ២០១៩ ក្នុងចំណោម៨៧នាក់ នៅបណ្តាប្រទេសអាស៊ានទាំង១០

- បានអភិវឌ្ឍសមត្ថភាពលើជំនាញទំនាក់ទំនងជាមួយវិស័យឯកជន ដំណើរការខ្សែចង្វាក់ផលិតកម្ម និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានិងព័ត៌មានដល់មន្ត្រីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនិងមន្ទីរកិច្ចការនារីទាំង២៥រាជធានី ខេត្ត ចំនួន១៩៧នាក់(ស្រី ១៧១នាក់)

- បាននិងកំពុងរៀបចំសេចក្តីព្រាងកម្មវិធីស្តីពីអភិវឌ្ឍន៍សហគ្រិនស្ត្រី ផ្តោតលើការពង្រីកបរិយាកាសឆ្លើយតបយេនឌ័រក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី និងការធ្វើអាជីវកម្មតាមអេឡិចត្រូនិក (E-Commerce)

- បានរៀបចំរបាយការណ៍សមិទ្ធផលកម្ពុជា និងការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីស្ត្រីនិងការអភិវឌ្ឍ (Cambodia Report to the General Assembly resolution A/Res/72/234 on "Women in Development") និងរបាយការណ៍កម្ពុជា ស្តីពីការលើកកម្ពស់ស្ត្រីនិងកុមារីនៅជនបទ (Cambodia Report to the General Assembly resolution A/Res/72/148 on "Women and Girls in Rural Areas")

- មន្ទីរកិច្ចការនារីនិងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីរាជធានី ខេត្ត បានអភិវឌ្ឍសមត្ថភាពដល់ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ក្មេងស្រីបោះបង់ចោលការសិក្សា និងស្ត្រីជនជាតិដើមភាគតិចសរុប១៥,៨៥៣នាក់លើជំនាញអ៊ុតសក់ សំអាងកាយ កាត់ដេរ ច្នៃម៉ូដ តម្បាញ និងកែច្នៃចំណីអាហារ និងជំនាញក្នុងការធ្វើអាជីវកម្ម ។

#### ខ- ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ

- គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានរៀបចំសន្និបាតបូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៧-២០១៨ និងលើកទិសដៅឆ្នាំ២០១៩ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តការងារ ចំណុចខ្លាំង បញ្ហាប្រឈម និងលើកទិសដៅបន្ត ក្រោមអធិបតីភាពរបស់លោកជំទាវ **វេជ្ជ.អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលមានការចូលរួមពីសមាជិក សមាជិកាក្រសួងស្ថាប័នពាក់ពន្ធ័ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុប៤៥០នាក់ (ស្រី ៣៩២នាក់)

- ឧបករណ៍ផ្សព្វផ្សាយសកល(កម្រិតទី១) និងឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ (កម្រិតទី២)ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ត្រូវបានបណ្តុះបណ្តាល ដល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ បានចំនួន២២៦នាក់(ស្រី១៧៦នាក់) និងបន្តផ្សព្វផ្សាយដល់តាមសហគមន៍(ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ) សរុបចំនួន៤ ៩៨២នាក់(ស្រី៣ ៨៤៦នាក់)

- វេទិកាពិគ្រោះយោបល់ស្តីពីការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ ក្រោមប្រធានបទ ខ្ញុំមិនភ័យខ្លាចដល់សិស្សចំនួន១.៨៦៥នាក់(ស្រី១.០៥៧នាក់) នៅវិទ្យាល័យចំនួន១២ក្នុងខេត្តតាកែវ កំពង់ចាម បន្ទាយមានជ័យ និងខេត្តប៉ៃលិន បានយល់ដឹងនិងស្វែងរកមុខវិជ្ជាសម្រាប់អនាគតរបស់ខ្លួនស្របតាមទីផ្សារការងារ

- មន្ត្រីក្រសួង និងមន្ទីរមន្ទីរកិច្ចការនារីរាជធានី ខេត្តទាំង២៥ សរុបចំនួន១៩៦នាក់ (ស្ត្រី១៥១នាក់) ត្រូវបានបណ្តុះបណ្តាលលើកម្មវិធីអប់រំនិងសុខុមាលភាពសង្គមនៅខេត្តព្រៃវែង ស្វាយរៀង និងខេត្តស្ទឹងត្រែង ដើម្បីជួយស្ត្រីនិងក្មេងស្រីឱ្យយល់ដឹងពីសិទ្ធិទទួលបានការគ្រប់គ្រងលើអចលនទ្រព្យ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសិល្បៈក្នុងការរស់នៅប្រកបដោយសមធម៌យេនឌ័រ ។

### គ- ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារីនិងការទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជំងឺអេដស៍

- វេទិកានិងយុទ្ធនាការអប់រំសហគមន៍ស្តីពីយេនឌ័រ សុខភាពបន្តពូជ មេរោគអេដស៍ ជំងឺអេដស៍ និងអាហារូបត្ថម្ភក្នុងខេត្តត្បូងឃ្មុំ សៀមរាប កំពត ព្រះវិហារ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីប្រជាពលរដ្ឋចំនួន១ ៦៣៧នាក់(ស្រី៩៣៣នាក់)

- មន្ត្រីក្រសួង មន្ទីរការិយាល័យកិច្ចការនារីស្រុក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ សរុបចំនួន៦៦៩នាក់(ស្រី៤៥៧នាក់) ក្នុងខេត្តកំពង់ឆ្នាំង កណ្តាល ព្រះសីហនុ បាត់ដំបង និងខេត្តព្រះវិហារត្រូវបានទទួលការបណ្តុះបណ្តាល ស្តីពីការកសាងទំនាក់ទំនងរវាងមាតានិងយុវតីទាក់ទងនឹងសុខភាពបន្តពូជ សុខភាពផ្លូវភេទ ការបង្ការនិងទប់ស្កាត់ការឆ្លងមេរោគអេដស៍និងជំងឺអេដស៍និងអាហារូបត្ថម្ភ យេនឌ័រនិងសុខភាពភ្នែក

- បានធ្វើនិងធ្វើរបាយការណ៍ប្រចាំព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងការអនុវត្តសេចក្តីសម្រេចចិត្តលេខ៦០២/២របស់គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី នៃអង្គការសហប្រជាជាតិ (Commission on the Status of Women ស្តីពី "Women, the girl child and HIV and AIDS")។

### ឃ- កិច្ចការពារផ្លូវច្បាប់ សម្រាប់ស្ត្រីនិងកុមារី

- គ្រូបង្គោលប្រចាំតំបន់ ជាមន្ត្រីមន្ទីរកិច្ចការនារី មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន១ ២៨៨នាក់(ស្រី១ ១២៩នាក់) ត្រូវបានបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ អំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចនានា ព្រមទាំងច្បាប់និងឯកសារក្បួននីតិវិធីប្រតិបត្តិការ

- បានគាំទ្រមន្ទីរកិច្ចការនារីក្នុងរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា ព្រមទាំងការទប់ស្កាត់ការប្រើប្រាស់និងជួញដូរគ្រឿងញៀននៅថ្នាក់ឃុំនិងភូមិចំនួន៣៧លើក ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៦ ៥៩៧នាក់ (ស្រី៤០៤២នាក់)

- សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ចំនួន៧លើក និងបានបញ្ជូនទៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងបានឆ្លងកិច្ចប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២លើក និងកំពុងរងចាំការសម្រេចពីរាជរដ្ឋាភិបាលតាមរយៈកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីដាក់ឱ្យអនុវត្តជាផ្លូវការ

- ក្រុមការងារពហុវិស័យឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តចំនួន៨ និងស្រុកចំនួន២៣ ត្រូវបានបង្កើតនិងអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការផ្តល់សេវាឆ្លើយតបចំពោះស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានជាអាទិ៍ជំនាញស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី បទដ្ឋានអប្បបរមាស្តីពីការប្រឹក្សាយោបល់ជាមូលដ្ឋានសម្រាប់ជួយស្ត្រីនិងក្មេងស្រីជាជនរងគ្រោះ ព្រមទាំងគោលការណ៍នៃការបញ្ជូនជនរងគ្រោះទៅរកសេវា និងការគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

-កន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានបង្កើតនិងអនុវត្តសាកល្បងក្នុងខេត្តគោលដៅចំនួន២ គឺ ខេត្តកំពង់ចាមនិងខេត្តស្ទឹងត្រែង

-បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត និងសម្របសម្រួលរកមេធាវីជូនជនរងគ្រោះដោយអំពើហិង្សាបានចំនួន៤៣ករណី(៣៣ករណីប្រឹក្សាផ្នែកច្បាប់ ៦ករណីប្រឹក្សាផ្លូវចិត្ត ២ករណីបានសម្របសម្រួលរកមេធាវី និង២ករណីសម្របសម្រួលបញ្ជូនទៅមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ ដើម្បីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- បានចុះប្រមូលទិន្នន័យអំពីស្ថានភាពរបស់ស្ត្រីដែលកំពុងជាប់ក្នុងពន្ធនាគារទាំង២៥ រាជធានីខេត្ត។ ជាលទ្ធផលស្ត្រីដែលកំពុងជាប់ក្នុងពន្ធនាគារសរុបចំនួន១ ៧៩៨នាក់(ក្នុងនោះមានទណ្ឌិត៧៨៩នាក់ ពិរុទ្ធជន១ ០០៩នាក់ ស្ត្រីកំពុងមានផ្ទៃពោះ៣០នាក់ និងស្ត្រីមានកូនតូចតាម១១៨នាក់)

- បានផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ក្នុងការធ្វើការប៉ាន់ប្រមាណថវិកាសម្រាប់អនុវត្តផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់នៅខេត្តរតនគិរី

- រៀបចំកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្រុមខមមីតកម្ពុជា(COMMIT) បានចំនួន៥លើក ដើម្បីពិនិត្យពិភាក្សាលើលទ្ធផលការងារដែលសម្រេចបាននិងលើកទិសដៅការងារបន្តសម្រាប់ដាក់បញ្ចូលក្នុងផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣

- យុទ្ធនាការ១៦ថ្ងៃ បំពាក់បូពណ៌ស បញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិចំនួន៤១លើក ត្រូវបានរៀបចំក្រោមប្រធានបទ ***បញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី គឺចាប់ផ្តើមពីខ្លួនអ្នក*** សម្រាប់ឆ្នាំ២០១៨និង**រួមគិត រួមធ្វើ រួមដោះស្រាយ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី** សម្រាប់ឆ្នាំ២០១៩ ដើម្បីបង្កើនការចូលរួមទប់ស្កាត់និងការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ លើកកម្ពស់ការប្រព្រឹត្តបែបវិជ្ជមានចំពោះជនរងគ្រោះ ជនងាយរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារទាក់ទងនឹងយេនឌ័រ និងលើកទឹកចិត្តយុវជនឱ្យចូលរួមបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដែលមានអ្នកចូលរួមសរុបចំនួន១០ ៩៧១នាក់(ស្រី ៧ ៥២៨ នាក់)

- វេទិកាផ្សព្វផ្សាយនារីរតនៈស្តីពីយុវជនរួមគ្នាកាត់បន្ថយអំពើហិង្សា នៅវិទ្យាល័យចំនួន១២ ក្នុងខេត្តកំពង់ចាម ព្រៃវែង ពោធិ៍សាត់ និងខេត្តសៀមរាប សមាសភាពចូលរួមមានលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន១ ៦៨០នាក់ (ស្រី ៩៥៤នាក់)។

## ខ- ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រ

- រៀបចំរបាយការណ៍ជាតិស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង ក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនៅកម្ពុជា ( Beijing Declaration and Platform for Action ) លើកទី២៥ និងបានផ្ញើជូនអង្គការសហប្រជាជាតិដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍រួមក្នុងតំបន់

- ក្រុមការងារបញ្ជ្រាបយេនឌ័រចំនួន៣០បានបង្កើតនិងកំពុងដំណើរការ ក្នុងនោះក្រសួងស្ថាប័នចំនួន២៩ មានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យនិងទទួលបានថវិកាជាតិសម្រាប់ការអនុវត្ត។ នៅឆ្នាំ២០១៩ ក្រសួង ស្ថាប័នចំនួន៧ បាននិងកំពុងធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ

- គោលនយោយបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរៀបចំនិងអនុម័តដោយគ.ជ.អ.ប។ ការសិក្សានិងរបាយការណ៍ការសិក្សាស្តីពីព័ត៌មានស្ត្រីមានសក្តានុពល ដើម្បីឈានទៅរៀបចំផែនការបន្តវេនសម្រាប់ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ

- បានរៀបចំនិងសម្រេចផ្ទេរប្រភេទមុខងារចំនួន៣ ដល់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌៈ (១)ការសម្របសម្រួល ទប់ស្កាត់និងដោះស្រាយអំពើហិង្សាលើស្ត្រីនិងកុមារនិងការជួញដូរស្ត្រីនិងកុមារ (២)ការគ្រប់គ្រងនិងប្រមូលទិន្នន័យស្ត្រីនិងកុមារនៅតាមមូលដ្ឋាន (៣)ការអប់រំផ្សព្វផ្សាយអំពីសិទ្ធិស្ត្រីនិងកុមារ ដើម្បីលើកកម្ពស់សីលធម៌សង្គម និងសមធម៌យេនឌ័រ

- រៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីកិច្ចការនារី និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្តការងារ និងជំនាញការស្វែងរកការគាំទ្រមតិ ការបញ្ជ្រាបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងសមាហរណកម្មផែនការឃុំ សង្កាត់ថ្នាក់ស្រុក និងភាពជាអ្នកដឹកនាំនិងគ្រប់គ្រងដែលមានអ្នកចូលរួមសរុបចំនួន៤៦៧នាក់(ស្រី៤០៧នាក់)

- គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលឆ្លើយតបយេនឌ័រនិងយន្តការគាំទ្រកំពុងដំណើរការយ៉ាងសកម្ម ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

*តារាងស្ថិតិស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ*

| ល.រ | បរិយាយ | ឆ្នាំ ២០១៨ | | ឆ្នាំ ២០១៩ | | ប្រៀបធៀប |
|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | |
| ១ | ស្ត្រីជាសមាជិកព្រឹទ្ធសភា | | | ១០ | ១៦.១៣ | កើន១.៣៨% ធៀបឆ្នាំ២០១៤ |
| ២ | ស្ត្រីជាសមាជិករដ្ឋសភា | ២៦ | ២០.៨០ | | | កើន០.៤៨% ធៀបឆ្នាំ២០១៣ |
| ៣ | ស្ត្រីជារដ្ឋមន្ត្រី | ៣ | ១០.៣៤ | ៣ | ១០.៣៤ | % មិនមានកើន |
| ៤ | ស្ត្រីជារដ្ឋលេខាធិការ | ៤៤ | ១៥.៨៣ | ៥៣ | ១៦.៣៦ | កើន ០.៥៣% ធៀបឆ្នាំ២០១៨ |
| ៥ | ស្ត្រីជាអនុរដ្ឋលេខាធិការ | ៦៧ | ១៥.៣៣ | ៧០ | ១៦.៨៧ | កើន ១.៥៤% ធៀបឆ្នាំ២០១៨ |
| ៦ | ស្ត្រីជាអភិបាលរាជធានី ខេត្ត | ១ | ៤ | ១ | ៤ | % មិនមានកើន |
| ៧ | ស្ត្រីជាអភិបាលរងរាជធានី ខេត្ត | ២៦ | ១៧.៤៤ | ២៦ | ១៧.៤៤ | % មិនមានកើន |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ស្ត្រីជាអភិបាលក្រុងស្រុកខណ្ឌ | ៦ | ៣.០៦ | ៦ | ៣.០៦ | % មិនមានកើន |
| ៩ | ស្ត្រីជាអភិបាលរងក្រុងស្រុកខណ្ឌ | ១៩៤ | ២៥.៥២ | ១៩៤ | ២៥.៥២ | % មិនមានកើន |
| ១០ | ស្ត្រីជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ (២០១៤) | ០.២៥ | ០ | ០ | ថយចុះ០.២៥ ធៀបឆ្នាំ២០១៤ |
| ១១ | ស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ៦៤ (២០១៤) | ១៦.២៨ | ៩៤ | ១៧.៦០ | កើន១.៣២ធៀបឆ្នាំ២០១៤ |
| ១២ | ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ | ២ (២០១៤) | ១.០១ | ៥ | ២.៤៦ | កើន១.៤៥ ធៀបឆ្នាំ២០១៤ |
| ១៣ | ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុងស្រុកខណ្ឌ | ៤០៤ (២០១៤) | ១៣.៧៨ | ៦១៧ (២០១៩ | ១៨.៤១ | កើន៤.៦៣ ធៀបឆ្នាំ២០១៤ |
| ១៤ | ស្ត្រីជាមេឃុំ ចៅសង្កាត់ | ១៣០ | ៧.៨៩ | ១៣០ | ៧.៨៩ | % មិនមានកើនឡើង |
| ១៥ | ស្ត្រីជាជំទប់ទី ១ | ២៧២ | ១៦.៥២ | ២៧២ | ១៦.៥២ | % មិនមានកើនឡើង |
| ១៦ | ស្ត្រីជាជំទប់ទី ២ | ២៨៥ | ១៧.៣១ | ២៨៥ | ១៧.៣១ | % មិនមានកើនឡើង |
| ១៧ | ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ១.៦១១ | ១៣.៩៣ | ១.៦១១ | ១៣.៩៣ | % មិនមានកើនឡើង |
| ១៨ | ស្ត្រីជាចៅក្រម | ៣៧ | ១៤.១៧ | X | X | |
| ១៩ | ស្ត្រីជាព្រះរាជអាជ្ញា | ២៣ | ១២.៩៩ | X | X | |
| ២០ | ស្ត្រីជាក្រឡាបញ្ជី | ១៦៥ | ២១.៩៤ | X | X | |
| ២១ | ស្ត្រីជាមន្ត្រីរាជការ | ៨៨៥៨០ | ៤១ | ៨៨៥៨០ | ៤១ | %មិនមានកើនឡើង |
| ២២ | ស្ត្រីជាមន្ត្រីរាជការ មានមុខតំណែងចាប់ពីថ្នាក់ការិយាល័យដល់អគ្គនាយក | ៧៦៦៩ | ២៤.៣៣ | X | X | |
| ២៣ | ស្ត្រីក្នុងកងយោធពលខេមរភូមិន្ទ | X | X | X | X | |
| ២៤ | ស្ត្រីក្នុងកងរាជអាវុធហត្ថ | X | X | X | X | |
| ២៥ | ស្ត្រីក្នុងនគរបាលជាតិ | ១ ៣១៣ | គ្មានទិន្នន័យ | X | X | |
| ២៦ | ស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន | X | X | X | X | |
| ២៧ | ស្ត្រីបម្រើការងារនៅតាមមណ្ឌលសុខភាពរដ្ឋ និងឯកជន | X | X | X | X | |
| ២៨ | ស្ត្រីបម្រើការងារនៅតាមគ្រឹះស្ថានក្រុមហ៊ុនឯកជន | X | X | X | X | |
| ២៩ | ស្ត្រីបម្រើការងារក្នុងវិស័យឧស្សាហកម្ម | | | | | |
| ៣០ | ស្ត្រីបម្រើការងារក្នុងវិស័យកសិកម្ម | X | X | X | X | |

## ច- យេនឌ័រ និងការប្រែប្រួលអាកាសធាតុនិងពិការភាព

- មន្ត្រីក្រសួង មន្ទីរកិច្ចការនារី មន្ទីរពាក់ព័ន្ធសាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២៤៩នាក់(ស្រី១២៤នាក់) បានយល់ដឹងពីការគណនាតម្លៃបន្ថែមក្នុងការបញ្ជ្រាបយេនឌ័រក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- អណ្តូងទឹកស្អាត ចំនួន ៨ ក្នុងស្រុកអង្គរជ័យ ខេត្តកំពត ទំនប់បង្ហៀរនិងទ្វាររក្សាទឹកទុក១ ក្នុងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងបង្គន់អនាម័យសាធារណៈចំនួន២កន្លែង ក្នុងស្រុករុក្ខគិរី ខេត្តបាត់ដំបងត្រូវបានសាងសង់ឡើងដោយបានគិតគូរពីការឆ្លើយតបចំពោះសមភាពយេនឌ័រនិងអាកាសធាតុ ជាពិសេសសម្រាប់ស្ត្រីតាមរយៈការលើកកម្ពស់អនាម័យជនបទ ការចិញ្ចឹមសត្វ និងដាំបន្លែ

- សិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រនិងពិការភាព បានរៀបចំដើម្បីកំណត់ពីបញ្ហាប្រឈមដែលស្ត្រី និងកុមារីមានពិការភាពជួបប្រទះ និងដំណោះស្រាយសមស្របនានាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អង្គការសង្គមស៊ីវិល សមាគមជនពិការ មន្ទីរកិច្ចការនារី និងរដ្ឋបាលថ្នាក់ក្រោមជាតិ សរុបចំនួន៨៧១នាក់(ស្រី៥៩៤នាក់) ដើម្បីជំរុញលុបបំបាត់ការរើសអើងស្ត្រីពិការ កុមារគ្រប់រូបភាព និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រ ការស្វែងរកការគាំទ្រមតិ ការលើកកម្ពស់សិទ្ធិស្ត្រីពិការយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ។

- មន្ត្រីក្រសួងកិច្ចការនារី មន្ទីរពាក់ព័ន្ធ សាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២៤៩នាក់(ស្រី១២៤នាក់) បានយល់ដឹងពីការគណនាតម្លៃបន្ថែមក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

## ឆ- ការអភិវឌ្ឍស្ថាប័ន

- សមត្ថភាពមន្ត្រីក្រសួង មន្ទីរ និងមន្ត្រីការិយាល័យកិច្ចការនារីក្រុង ស្រុក ចំនួន៦៦៨នាក់ (ស្រី៥២៩នាក់) មានការកើនឡើងពាក់ពន្ធ័អំពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងរដ្ឋបាល កិច្ចការស្ត្រីនិងអាស៊ាន និងនីតិវិធីគាំទ្រការចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំ នីតិវិធីសវនកម្ម និងការងារគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការ ស្ថិតិ ការត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ

- រៀបចំមិទ្ទីញអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៨ ក្រោមប្រធានបទ "លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីអភិវឌ្ឍន៍ធនជានមនុស្ស "ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលមានអ្នកចូលរួម ៣ ២០០នាក់ នៅសាលមហោស្រព និងពិព័រណ៌កោះពេជ្រ។

## ជ- ការងារចុះអនុស្សរណៈ និងផ្សព្វផ្សាយព័ត៌មាន

- អនុស្សរណៈនៃការយោគយល់ចំនួន៥ត្រូវបានចុះហត្ថលេខាៈ ១-គម្រោងស្តីពីការផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់ស្ត្រីនិងស្ត្រីជាសហគ្រិន ក្នុងការសម្របសម្រួលស្វែងរកមធ្យោបាយទទួលបានឥណទានសមស្របនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបង្កើនចំណេះដឹងសហគ្រិនភាពសម្រាប់យុវតីនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា រយៈពេល១ឆ្នាំ(២០២០)គាំទ្រដោយធនាគារជាតិនៃកម្ពុជា ២-គម្រោងស្តីពីការបើកគន្លឹះភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីរយៈពេល៥ឆ្នាំ(២០១៩-២០២៤) គាំទ្រដោយអង្គការវីឌូកម្ពុជា ៣-គម្រោងស្តីពីយេនឌ័រនិង

សុខភាពផ្នែករយៈពេល៣ឆ្នាំ(២០១៩ - ២០២១) គាំទ្រដោយមូលនិធិហ្វ្រេតហូឡូ ៤-គម្រោងស្ដីពីការគ្រប់គ្រងមណ្ឌលព័ត៌មានទំនាក់ទំនងនិងបច្ចេកវិទ្យា(WEE through ICT) គាំទ្រដោយស្ថានទូតឥណ្ឌា ៥-គម្រោងជំនួយផ្នែកសុខភាពស្ត្រី គាំទ្រដោយអង្គការTABITHA CAMBODIA

- ផ្សព្វផ្សាយសកម្មភាពនិងសមិទ្ធផលរបស់ក្រសួងតាមរយៈបណ្ដាញសង្គមហ្វេសប៊ុករបស់ក្រសួងកិច្ចការនារីតាមអាសយដ្ឋាន www.facebook.com/mowa.gov.kh ចំនួន២៥៨ដង មានអ្នកចូលចិត្ត Like ចំនួន ៤៣ ៦២៣ ចំនួនអ្នកចូលរួមយោបល់ចំនួន៥៩៥ អ្នកចែករំលែកការផ្សាយចំនួន១៦ ៩៩៦ និងអ្នកបានចូលមើលចំនួន ៦០១ ៣៦០ សមាជិកទំព័រហ្វេកប៊ុកមានចំនួនសរុប៩១ ៣៣០នាក់

- សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដល់បណ្ដាញសារព័ត៌មាន សិល្បករ ពិធីករ ពិធីការិនី អ្នកនិពន្ធ និស្សិតសារព័ត៌មាន សមាសភាពចូលរួម ៥៧៥នាក់(ស្រី ៣៤៥នាក់)។

**២- ការលើកកម្ពស់ការគាំពារសង្គម**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចការងារដូចខាងក្រោម៖

**២.១- ការងារសង្គមកិច្ច**

- ទទួលជនអនាថា**១ ៦០៧នាក់** ពីរាជធានីភ្នំពេញ**៩៦៣នាក់** និងបណ្ដាខេត្តចំនួន**១១ សរុប ៦៣៧នាក់** ក្នុងនោះ បានធ្វើសមាហរណកម្មទៅសហគមន៍វិញ**២ ១០៨នាក់** ពីរាជធានីភ្នំពេញ**១ ៣០៧នាក់** និងតាមបណ្ដាខេត្តចំនួន១០ សរុប **៨០១នាក់**

- ទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសចិន**៧២នាក់** ថៃ**៤៣នាក់** ម៉ាឡេស៊ី**៣២នាក់** វៀតណាម**៩នាក់** និងប្រទេសអារ៉ាប៊ីសាអូឌីត**២នាក់**

- បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅ**៤៨នាក់ ស្រី២៨នាក់**

- ប្រារព្ធទិវាអន្តរជាតិស្ដីពីគ្រួសារ ១៥ឧសភា ឆ្នាំ២០១៩ ខួបលើកទី២៥ ក្រោមប្រធានបទ "**សុខុមាលភាពគ្រួសារ ជាកាតាលីករក្នុងការអនុវត្តប្រព័ន្ធការពារសង្គមនៅកម្ពុជា**" នៅសាលាខេត្តកំពង់ចាម ដែលមានអ្នកចូលរួម ជាតំណាងគ្រួសារ អាជីវករ ពាណិជ្ជករ និវត្តជន កសិករ កម្មករ សរុប**៤៥០នាក់**

- បើកវគ្គបណ្ដុះបណ្ដាលស្ដីពីការងារសង្គមកិច្ច កិច្ចការពារកុមារ ការពង្រឹងគុណភាពប៉ាន់ស្មានប្រមាណការតាមដានករណីកុមារនិងគ្រួសារដែលធ្វើសមាហរណកម្មនៅខេត្តកំពង់ចាមនិងខេត្តសៀមរាប មានអ្នកចូលរួម**៧៥នាក់**។

**២.២- ការងារស្តារលទ្ធភាពពលកម្ម**

- **ផ្តល់សេវាស្តារលទ្ធភាពគ្រប់ប្រភេទជូនជនពិការ** : បាន**២៧ ៤២៦នាក់**(ស្រី៦ ៨៧០នាក់) និងជនពិការដោយសារមីន**១១ ០០៥នាក់**នៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនិងរោងជាងទាំង**១៥កន្លែង**។ ក្រៅពីការទទួលសេវាដោយឥតគិតថ្លៃពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ជនពិការក៏បានទទួលការឧបត្ថម្ភជាប្រាក់ថ្លៃអាហារនិងប្រាក់ធ្វើដំណើរទៅមកផងដែរ។ ផលិតឧបករណ៍សិប្បនិម្មិតនិងរណបសរុប១០ ០៣៣គ្រឿង ព្រមទាំងជួសជុលឧបករណ៍សិប្បនិម្មិតនិងរណបនិងឧបករណ៍ជំនួយរាងកាយសរុបចំនួន១៤ ៨១៧គ្រឿង

- **ស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រពិនិត្យ ព្យាបាល វះកាត់ដាក់កែវភ្នែកសិប្បនិម្មិត** : ដាក់កញ្ចក់ក្នុងកែវភ្នែក ផ្តល់វ៉ែនតា វះកាត់ដៃជើងនិងមុខមាត់ ព្យាបាលជំងឺហង់សិន និងព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នង **៦០ ១១៦នាក់**(ស្រី៣២ ៣០៩នាក់) និងជនពិការដោយសារមីន**៦៧នាក់**។ ផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យនិងថែទាំសុខភាពជូនជនពិការក្រីក្រនៅតាមសហគមន៍ចំនួន៥ ៦៤៣នាក់ ក្នុងម្នាក់ទទួលបានថវិកា ៣០ ០០០រៀល។

**២.៣- ការងារអតីតយុទ្ធជន**

- ចេញប្រកាសដាក់មន្ត្រីរាជការចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម ចំនួន ៤ ០៥៦នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន៣ ៦០៩នាក់ និងបានផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

- លុបឈ្មោះសពនិវត្តជននិងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ **១ ៣៩៧នាក់** និងបន្តឧបត្ថម្ភប្រាក់គោលជូនអ្នកនៅក្នុងបន្ទុក**៦ ៩៦៤នាក់**

- កែសម្រួលកាំប្រាក់សោធនជូននិវត្តជន១០២នាក់ លុបនិវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ១ ៥៣១នាក់ និងលុបសពមន្ត្រីរាជការស៊ីវិល២៧នាក់

- លុបរបបសន្តិសុខសង្គមអ្នកនៅក្នុងបន្ទុករបស់សពនិវត្តជននិងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ៧១៦នាក់

- ផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិចំនួន២២៥នាក់

- បើកផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តនៃប.ជ.ស. សរុបចំនួន៩១ ០៥៥នាក់។ និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ **៥៥ ៦៩៥នាក់** (និវត្តជន ៥៣ ៦៦០នាក់) កំពុងទទួលតាមប្រព័ន្ធធនាគារ

- ដំឡើងប្រាក់របបសន្តិសុខសង្គមប្រចាំខែជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈពីកម្រិតទាបដល់ ៥៦០ ០០០រៀលក្នុងមួយខែ

- សហការជាមួយប.ស.ស. ផ្តល់បណ្ណថែទាំសុខភាពសម្រាប់និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទាំងស្រុង ព្រមទាំងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ប.ជ.ស ដែលមានឈ្មោះថា www.nssfc.gov.kh។

**ទិន្នន័យសិទ្ធិវន្តនៃប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារក្នុងខែសីហា ឆ្នាំ២០១៩**

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | ទឹកប្រាក់សរុប(រៀល) |
|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | |
| ១ | និវត្តជន | ៥៣ ៦៦០ | ២៩ ៨១០ | ៤ ៦៥៥ | ៣២ ៣១២ ៨៧៥ ៥០៨ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ២ ០៣៥ | ៨៨៥ | ១០ | ១ ១៤០ ៩៧២ ៨៩០ |
| **សរុប** | | **៥៥ ៦៩៥** | **៣០ ៦៩៥** | **៤ ៦៦៥** | **៣៣ ៤៥៣ ៨៤៨ ៣៩៨** |

**អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គម គិតត្រឹមខែសីហា ឆ្នាំ២០១៩**

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ២៦ ២១៦ | ៥ ៦៨០ | ១១ ០៩២ | ១៦៩ | ១៩ ៤០៣ | ៩ ១៤៧ | | ៤៥ ៤៩១ | **៥៣១,១០** |
| ២ | ជនមរណៈ | ៧ ៥៣២ | ១ ០០១ | ១ ៩០២ | ៣០ | ៦ ៨៩១ | ៤ ៤៥៣ | | ១៤ ២៧៧ | **១៧៥,៨៤** |
| ៣ | ជនពិការ | ២៧ ១៩៧ | | | | ២៣ ១២០ | ១៤ ៤២០ | ១ ២៨០ | ៣៨ ៨២០ | **១៨ ៧៥៤,៥៥** |
| ៤ | និវត្តជន | ២៨ ០០៨ | | | | ២៣ ៤៤៧ | ៩ ៧៨៤ | | ៣៣ ២៣១ | **១៩ ៥៨៨,៩១** |
| ៥ | ជនបាត់បង់ | ១ ៥៣៨ | | | | ១ ១៤៩ | ៥១៨ | ៣៧ | ១ ៧០៤ | **៨៦៧,៤៤** |
| សរុប | | ៩០ ៤៩១ | ៦ ៦៨១ | ១២ ៩៩៤ | ១៩៩ | ៧៤ ០១០ | ៣៨ ៣២២ | ១ ៣១៧ | ១៣៣ ៥២៣ | ៣៩ ៩១៧,៨៤ |

## ២.៤- ការខារយុវនីតិសម្បទា បានៈ

- ចុះធ្វើអធិការកិច្ចនៅតាមមណ្ឌលថែទាំកុមារ**ដែលបានចុះកិច្ចព្រមព្រៀង៥០មណ្ឌល** មានកុមារស្នាក់នៅ**១ ៨៧៤នាក់** មណ្ឌលដែលកំពុងបន្តចុះកិច្ចព្រមព្រៀង មណ្ឌលដែលកំពុងបន្តកិច្ចព្រមព្រៀងនិងគ្មានកិច្ចព្រមព្រៀង**១៥៣មណ្ឌល** មានកុមារស្នាក់នៅ**៣ ៥៧៤នាក់**។ មណ្ឌលកុមារកំព្រារបស់រដ្ឋ២០មណ្ឌល មានកុមារនិងយុវជន**១ ១៣៥នាក់**(ស្រី៥០០នាក់)។ កន្លែងថែទាំបែបសហគមន៍សរុប**១២៨កន្លែង** មានកុមារស្នាក់នៅ **២ ៨០០នាក់**(ស្រី១ ២៩៤នាក់)

- ទទួលរបាយការណ៍ស្ដីពីការវិវឌ្ឍរបស់កូនសុំ**៦៦៤ករណី**(ប្រទេសអ៊ីតាលី៦២៩ អូទ្រីស១៦ បារាំង១ អេស្ប៉ាញ១ សហរដ្ឋអាម៉េរិក៥ ហូឡង់១ និងប្រទេសម៉ាល់តា១១) បានបញ្ជាក់ថាកូនសុំទាំងនោះមានការរស់នៅលូតលាស់និងការវិវឌ្ឍល្អប្រសើរ។

| សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ឧបត្ថម្ភជូនមណ្ឌលកុមារកំព្រា | | | | |
|---|---|---|---|---|
| ល.រ | ឈ្មោះមណ្ឌល/អង្គការ | ការឧបត្ថម្ភ | | |
| | | អង្ករ | ថវិកា | សម្ភារៈ |
| ១ | បុរីទារកនិងកុមារជាតិស្ថិតនៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | | ១០លានរៀល/ឆ្នាំ | គ្រឿងបរិភោគ |
| ២ | មណ្ឌលសាលាគថ្លង់ភ្នំពេញថ្មី ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ១តោន | ៣លានរៀល/ឆ្នាំ | |
| ៣ | មណ្ឌលសាលាគថ្លង់ច្បារអំពៅ ស្ថិតនៅសង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ | ១តោន | ៣លានរៀល/ឆ្នាំ | |
| ៤ | មណ្ឌលកុមារកំព្រាភ្នំពេញថ្មី ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ៥០០គ.ក្រ | ១លានរៀល/ឆ្នាំ | |
| ៥ | មណ្ឌលកុលាបទី៤ ស្ថិតនៅសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ | | ៣លានរៀល/ឆ្នាំ | |
| ៦ | មណ្ឌលផ្កាម្លិះ ស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ១តោន | ៣លានរៀល/ឆ្នាំ | |
| ៧ | សមាគមជនអត់ទីពឹង ស្ថិតនៅសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ | ១តោន | ៣លានរៀល/ឆ្នាំ | |
| ៨ | បុរីកុមារកម្ពុជាបារាំងហុងគ្រី ស្ថិតនៅខេត្តកណ្ដាល | | ១,៩លានរៀល/ឆ្នាំ | |

## ៣- ការបើកប្រាក់ឧបត្ថម្ភសម្រាប់កម្មការិនីសម្រាលកូន

ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

| ប្រាក់ឧបត្ថមបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន | | | |
|---|---|---|---|
| បរិយាយ | ស្ត្រីសម្រាលកូន | ចំនួនកូន | ទឹកប្រាក់សរុប(រៀល) |
| កញ្ញា ២០១៨-កក្កដា ២០១៩ | ៦៩ ២៩៥ | ៦៩ ៧៧៤ | ២៧ ៩០៩ ៦០០ ០០០ |
| (កម្មការិនីសម្រាលកូន១ទទួលបាន**៤០០ ០០០រៀល** សម្រាលកូនភ្លោះ២ទទួលបាន**៨០០ ០០០រៀល**) | | | |

## ៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន

ក្រសួងផែនការ ក្នុងឆ្នាំ២០១៩សម្រេចការងារដូចខាងក្រោម៖

- ចុះត្រួតពិនិត្យ តាមដានសកម្មភាពត្រៀមរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២០-២០២២ នៅខេត្តកំពង់ធំ កាលពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩

- អនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី១២ ឆ្នាំ២០១៨-២០១៩នេះ នៅតាមបណ្តារាជធានីខេត្តទាំង៩គោលដៅ(រាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងខេត្តស្ទឹងត្រែង) សរុប**១ ២៨៦ ៥៦៣គ្រួសារ** ក្នុងនោះគ្រួសារក្រ១ មាន**៦៩ ០០៣គ្រួសារ** ស្មើនឹង **៥,៨០%** និងគ្រួសារក្រ២ មាន**១២០ ៨៩៨គ្រួសារ ស្មើនឹង១០%**។ បច្ចុប្បន្នកំពុងដំណើរការផលិត បណ្ណសមធម៌គ្រួសារក្រីក្រ និងចែកបណ្ណសមធម៌បាន**១៨៩ ៩០០បណ្ណ**

- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣ ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៩

- សេចក្តីព្រាងរបាយការណ៍ស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ ត្រូវបានទូលព្រះបង្គំជាខ្ញុំពិនិត្យនិងសម្រេចឯកភាពកាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ និងបានផ្ញើទៅអង្គការសហប្រជាជាតិរួចរាល់ហើយ

- ធ្វើការផ្សព្វផ្សាយតួលេខបណ្តោះអាសន្នជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ក្រោមអធិបតីភាពរបស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩។ ការធ្វើជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ បានធ្វើឡើងក្នុងរយៈពេល១១ថ្ងៃ ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩កន្លងទៅ។ ជាលទ្ធផលបណ្តោះអាសន្នមាន**៣ ៣៤១ ៧៧០គ្រួសារ** ស្មើនឹង **១៥ ២៨៨ ៤៨៩នាក់**(ស្រី៧ ៨៦៩ ៩១២នាក់)

- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២០-២០២២ ត្រូវបានទទួលការសម្រេចក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

# ចតុកោណយុទ្ធសាស្ត្រទី២
# ការធ្វើពិពិធកម្មសេដ្ឋកិច្ច

ការធ្វើពិពិធកម្មសេដ្ឋកិច្ច គឺជាដំណើរការចាំបាច់នៃការបង្កើតជន្ទល់ឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រឹងការនាំចេញ ឬបង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីអាចរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ ក្នុងរយៈពេលមធ្យមនិងវែងនាពេលខាងមុខ។

## មុំទី១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

### ១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន

#### ១.១- ការងារដឹកជញ្ជូនផ្លូវគោក

ផ្លូវជាតិនិងផ្លូវខេត្តមកទល់បច្ចុប្បន្នមានប្រវែងសរុប**១៦ ២៩២គ.ម..** ក្នុងនោះចាក់កៅស៊ូនិងបេតុងបានប្រវែង៨ **៦២០គ.ម..** ស្មើនឹង**៥២,៩១%**នៃប្រវែងសរុប ក្នុងនោះ៖

- ផ្លូវជាតិកម្រិត១ចំនួន**៩ខ្សែ** ប្រវែង**២ ២៥៤គ.ម.**(ចាក់កៅស៊ូនិងបេតុងបាន២ ២៥៤គ.ម.) ស្មើនឹង**១០០%**
- ផ្លូវជាតិកម្រិត២ចំនួន**៦៦ខ្សែ** ប្រវែង**៥ ០០៧គ.ម.**(ចាក់កៅស៊ូនិងបេតុងបាន៣ ៦២១គ.ម.) ស្មើនឹង**៧២,៣០%**
- ផ្លូវខេត្តមានចំនួន**៥២៨ខ្សែ** ប្រវែង**៩ ០៣១គ.ម.**(ចាក់កៅស៊ូនិងបេតុងបាន២ ៧៤៥គ.ម.) ស្មើនឹង**៣០,៤០%**
- ស្ពានអាកាសមិត្តភាពកម្ពុជា-ចិន សែនសុខ (ស្ពានអាកាសផ្សារដើមហុយជាស្ពានទី៥ នៅរាជធានីភ្នំពេញ) មានប្រវែង៩០៥ម ទទឹង១៦,៥០ម. ដែលមានទីតាំងខាងកើត ស្ថិតនៅក្នុងសង្កាត់ទឹកថ្លា និងខាងលិចស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
- ស្ពានកោះប៉ែនមានប្រវែង៧៧៩ម. ទទឹង៩,២០ម. ចាប់ពីកំពង់ចម្លងថៃវ៉ាត សង្កាត់សំបួរមាស ក្រុងកំពង់ចាម ឆ្លងទន្លេមេគង្គទៅឃុំកោះមិត្ត(កោះប៉ែន) ស្រុកកំពង់សៀម ខេត្តកំពង់ចាម
- ស្ពានមិត្តភាពកម្ពុជា-ជប៉ុន(ស្ពានជ្រោយចង្វាទី១) មានប្រវែង៩៧១ម. ទទឹង១៣ម.
- ស្ពានឆ្លងកាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ពីភូមិស្ទឹងបត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ទៅភូមិណងអៀន ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ មានប្រវែង១៣០ម.។

**លទ្ធផលការងារជួសជុលនិងសាងសង់ផ្លូវថ្នល់ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩**

| បរិយាយ | ផ្លូវ (ឯកតា : គ.ម.) | | | |
|---|---|---|---|---|
| | បេតុង | AC | DBST | ក្រួសក្រហម |
| ផ្លូវជាតិកម្រិត១ | ០,២៨ | ៣,២៤ | ៣,៤៦ | ០ |
| ផ្លូវជាតិកម្រិត២ | ១,៧៥ | ១,២៥ | ១០៤,៨៧ | ០ |
| ផ្លូវខេត្ត | ២៨,៧៦ | ៤,៤៧ | ២៩៦,២២ | ៣៦៥,៥៩ |
| **សរុបរួម** | **៣០,៧៩** | **៨,៩៦** | **៤០៤,៥៥** | **៣៦៥,៥៩** |

| បរិយាយ | ស្ពាន-លូ (ឯកតា : ម) | | | | | |
|---|---|---|---|---|---|---|
| | ស្ពានបេតុង | ស្ពានបេឡេត៍ | ស្ពានខ្សែកាប | ប្រឡាយ | លូមូល | លូជ្រុង |
| ផ្លូវជាតិកម្រិត១ | ០ | ០ | ០ | ៣ ០៦០ | ៣ ២៣២ | ០ |
| ផ្លូវជាតិកម្រិត២ | ១៦៦ | ០ | ០ | ៤ ៧៧៧ | ៣២ | ២៧,៣៥ |
| ផ្លូវខេត្ត | ១ ១៩៤ | ០ | ០ | ៦ ៦៣៧ | ១២ ៤៤៦ | ៦២៨,៤៤ |
| **សរុបរួម** | **១ ៣៦០** | **០** | **០** | **១៤ ៤៧៤** | **១៥ ៧១០** | **៦៥៥,៧៩** |

**លទ្ធផលការងារជួសជុលខួប(ផ្លូវនិងស្ពាន)ប្រចាំឆ្នាំ២០១៨ សម្រេចបាន៩៨,៤៥% និងការងារជួសជុលខួប (ផ្លូវនិងស្ពាន)ប្រចាំឆ្នាំ២០១៩ សម្រេចបាន៣៤,០២%**

| បរិយាយ | ផ្លូវ (ឯកតា : គ.ម.) | | | |
|---|---|---|---|---|
| | ផ្លូវបេតុង | ផ្លូវ AC | ផ្លូវ DBST | ផ្លូវក្រួសក្រហម |
| ការងារជួសជុលខួប(ជំពូក៦១) | ៤,៤៨ | ៣,៩៩ | ១១៧,៤៦ | ២១,៦០ |
| ការងារសាងសង់ថ្មីឬលើកកម្រិត(ជំពូក២១) | ២៦,៣១ | ៥,១៧ | ២៨៧,០៨ | ៣៤៣,៩៩ |
| **សរុបរួម** | **៣០,៧៩** | **៩,១៦** | **៤០៤,៥៤** | **៣៦៥,៥៩** |
| ការងារជួសជុលបន្ទាន់ | ៣,១៥ | ០,៩០ | ១៩,៨៨ | ១៥៥,២៨ |
| ការងារថែទាំជាប្រចាំ (ជំពូក៦១) | ៨ | ៩២៤ | ៥ ១១៦ | ៣ ១២១ |

| បរិយាយ | ស្ពាន ប្រឡាយ លូ (ឯកតា : ម) | | | | | |
|---|---|---|---|---|---|---|
| | ស្ពានបេតុង | ស្ពានបេឡេត៍ | ស្ពានខ្សែកាប | ប្រឡាយ | លូមូល | លូជ្រុង |
| ការងារជួសជុលខួប (ជំពូក៦១) | ២៤ | ០ | ០ | ៧ ៣៣២ | ៥ ៤៧២ | ៣៧ |
| ការងារសាងសង់ថ្មីឬ លើកកម្រិត(ជំពូក២១) | ១ ៣៣៦ | | | ៧ ១៤២ | ១០ ២៣៨ | ៦១៨,៧៩ |
| **សរុបរួម** | **១ ៣៦០** | | | **១៤ ៤៧៤** | **១៥ ៧១០** | **៦៥៥,៧៩** |
| ការងារជួសជុលបន្ទាន់ | ១០ | ០ | ០ | ៤០ | ១០ ៦៨៧ | ៧៧៨ |
| ការងារថែទាំជាប្រចាំ (ជំពូក៦១) | ៣១ ១៩៥ | ៣ ០៦៨ | ០ | ០ | ៤ ៩១៣ | ៨ ៣៦០ |

**ការងារគម្រោងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ**

| តារាងសង្ខេបអំពីវឌ្ឍនភាពនៃគម្រោងផ្លូវ ស្ពាន ប្រើប្រាស់ថវិការអន្តរជាតិ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ឈ្មោះគម្រោង | ប្រវែង (គ.ម.) | តម្លៃគម្រោង ដុល្លារអាម៉េរិក ($) | ស្ថានភាពគម្រោង | | |
| | | | | ក្រុមហ៊ុន សាងសង់ | ភាគរយ (%) | ឆ្នាំបញ្ចប់ គម្រោង |

I. **ការងារសម្រេចបាន**

**ក- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយប្រទេសចិន**

| | | | | | | |
|---|---|---|---|---|---|---|
| **គម្រោងបញ្ចប់៖** | | | | | | |
| ១ | គម្រោងស្ថារ និងលើកកម្រិតផ្លូវជាតិលេខ៧ | ៩៣,៧០ | ១៣ ១២០ ០០០ | ក្រុមហ៊ុន សៀងហៃ | ១០០ | ២០១៨ |
| ២ | ផ្លូវជាតិលេខ៥៨ (ក្រុងប៉ោយប៉ែត-ត្រង់ផ្អុង/ខេត្តឧត្តរមានជ័យ) | ១៧៤ | ១២២ ៩៨០ ០០០ | SCGC | ១០០ | ២០១៨ |
| ៣ | គម្រោងពង្រីកកំណាត់ផ្លូវជាតិលេខ៦ បួនគន្លង (មុខក្រសួងសុខាភិបាលថ្មី-ថ្នល់កែង) | ៩៦,៤៨ | ៧០ ២៥០ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| ៤ | កំណាត់ផ្លូវជាតិលេខ៧៦បន្ត (សែនមនោរម្យ-កោះញែក ខេត្តមណ្ឌលគិរី ដល់លំផាត់-តាអង់ ខេត្តរតនគិរី) | ១៧១,៧៨ | ៩១ ៦៨០ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| ៥ | ផ្លូវភ្ជាប់ស្ពានតាខ្មៅ | ១២,០៧ | ៧ ៤៩០ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| ៦ | គម្រោងសាងសង់ផ្លូវជាតិលេខ៤៤ (ច្បារមន-ឪរ៉ាល-ឧត្តុង) | ១៣៩,១៤៤ | ៨០ ៣០០ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| ៧ | គម្រោងសាងសង់ស្ពានកោះធំ | ០,៤១៥ | ១៩ ៣៨៨ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| ៨ | គម្រោងជួសជុលឡើងវិញកំណាត់ផ្លូវជាតិលេខ៧ (ស្រុកចិត្របូរី-ស្រុកសំបូរ ខេត្តក្រចេះ) | ៣៨,៨០ | ១០ ៦៨០ ០០០ | ក្រុមហ៊ុនចិន | ១០០ | ២០១៨ |
| **សរុប** | | **៧២៦,៣៨៩** | **៤១៥ ៨៨៨ ០០០** | | | |
| **គម្រោងកំពុងដំណើរការ៖** | | | | | | |
| ១ | គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣ និងផ្លូវខ្វែងប្រវែង ៥,៣៦គ.ម.. | ៤៥,៦១ | ២១៥៣៨៨០០០ | SCGC | ១៦,១៨ | ២០២២ |
| ២ | គម្រោងពង្រីកផ្លូវជាតិលេខ៣ (ចោមចៅ-ក្រុងកំពត) | ១៣៤,៨០ | ២១៥៣៨៨០០០ | CRBC | ៥៦,៩២ | ២០២២ |
| ៣ | គម្រោងសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី២ (មហាវិថីសហព័ន្ធរុស្សី-ព្រែកហូរ/ផ្លូវជាតិលេខ២) ភាគខាងលិច រាជធានីភ្នំពេញ និងស្ពានអាកាសប្រវែង៦១០ ម. | ១៦,៦៨ | ៦១ ៩០៣ ០០០ | SCGC | ៩៥,៣៩ | ២០១៩ |
| ៤ | ការស្តារឡើងវិញនូវផ្លូវជាតិលេខ៥១ (ឧត្តុង្គ ផ្លូវជាតិលេខ៥ ដល់ថ្នល់ទទឹង ផ្លូវជាតិលេខ៤) | ៣៨ | ៤០ ៨៨០ ០០០ | CRBC | ៩៥ | ២០២០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | គម្រោងសាងសង់ស្ពានឆ្លងទន្លេមេគង្គ ក្រូចឆ្មារ-ស្ទឹងត្រង់ និងផ្លូវតភ្ជាប់ក្បាលស្ពានទាំងសងខាង និងផ្លូវខ្នែង (ដំណាក់កាលទី១) | ៩,៤៣១ | ៥៦ ៩៩៨ 000 | SCGC | ៦៧,៤៥ | ២០២១ |
| ៦ | គម្រោងសាងសង់ផ្លូវជាតិលេខ១១ និងផ្លូវវាង(អ្នកលឿង-ថ្នល់ទទឹង ផ្លូវជាតិលេខ៧) | ៩៦,៤៨ | ៩៨ ៣៨៨ 000 | CRBC | ៦៣,៩៤ | ២០២១ |
| ៧ | គម្រោងអភិវឌ្ឍន៍ផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ | ១៩0,0១៦ | ២0១៩000000 | CPPE | ៤ | ២០២៣ |
| សរុប | | ៥៣១,0១៧ | ២៧0៧៩៤៥000 | | | |
| **ខ- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយប្រទេសជប៉ុន** | | | | | | |
| **គម្រោងបញ្ចប់៖** | | | | | | |
| ១ | គម្រោងធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ១ ប្រវែង៤គ.ម.. (ច្បារអំពៅ-ក្តីតាកុយ) | | | | ១០០ | ២០១៨ |
| ២ | គម្រោងអភិវឌ្ឍន៍ចំណតពហុបំណង កំពង់ផែស្វយ័តក្រុងព្រះសីហនុ | | | | ១០០ | ២០១៨ |
| ៣ | គម្រោងជួសជុលស្ពានជ្រោយចង្វាកម្ពុជា-ជប៉ុន | ៩៧១ម. | ៣0 000 000 | Obayashi Corporation | ១០០ | ២០១៩ |
| សរុប | | 0,៩៧១ | ៣0 000 000 | | | |
| **គម្រោងកំពុងដំណើរការ៖** | | | | | | |
| ១ | គម្រោងសាងសង់ស្ពានចំនួន៧កន្លែង (តាមបណ្តោយផ្លូវជាតិលេខ៧៣-ខេត្តក្រចេះចំនួន៥ និងផ្លូវជាតិលេខ១១-ខេត្តព្រៃវែងចំនួន២) | ៤ 0៩៤ ម. | ១៥ 000 000 | HAC | ៤៣,៦០ | ២០២១ |
| ២ | គម្រោងសាងសង់ពង្រីកជា៤គន្លង លើកំណាត់ផ្លូវជាតិលេខ៥ ពីបាត់ដំបងទៅសិរីសោភ័ណ | ៨៤,៧៤ | ២១៥ 000 000 | Tekken-TaiyoJV Daiho-Asanuma JV | ៥៣,៣ | ២០២១ |
| ៣ | គម្រោងសាងសង់ពង្រីកជា៤គន្លង លើកំណាត់ផ្លូវជាតិលេខ៥ពីព្រែកក្តាមទៅថ្នាម្អម | ១៣៥,២៥ | ២៦៥ ១៥៧ 000 | សម្ព័ន្ធ SMC សម្ព័ន្ធHEC | ៨,១៨ | ២០២៣ |
| ៤ | គម្រោងធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ៥ភាគកណ្តាល (ថ្លាម្អម-បាត់ដំបង និងសិរីសោភ័ណ-ប៉ោយប៉ែត) | ១៤៦,0៤ | | ICJV, OBAYASHI TEKKEN-IKEE JV | 0,៦៥ | ២០២៣ |
| សរុប | | ៣៧0,១២៤ | ៤៩៥ ១៥៧ 000 | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **គ- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយសាធារណរដ្ឋកូរ៉េ** | | | | | | |
| **គម្រោងបញ្ចប់៖** | | | | | | |
| ១ | គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២១ ក្រាលកៅស៊ូAC ដំហាន១ ប្រវែង៥៥គ.ម.. (តាខ្មៅ-ជ្រៃធំ) | ៥៥ | | | ១០០ | ២០១៨ |
| ២ | គម្រោងសាងសង់ប្រព័ន្ធលូនិងស្ថានីយចម្រោះទឹកកខ្វក់ ខេត្តសៀមរាប | ៦ 000M$^3$ | | | ១០០ | ២០១៨ |
| **សរុប** | | **៥៥** | | | | |
| **គម្រោងកំពុងដំណើរការ៖** | | | | | | |
| ១ | គម្រោងស្តារឡើងវិញប្រភេទ ក្រាលកៅស៊ូ AC លើផ្លូវជាតិលេខ២១ ដំហាន២ (គ.ម.. លេខ៥៥-ផ្លូវបំបែកស្ពានជ្រៃធំ) | ៨,៦០ | ១១ ៥៨៦ 000 | HEC | ៩៨,៩៥ | ២០១៩ |
| **សរុប** | | **៨,៦០** | **១១ ៥៨៦ 000** | | | |
| **ឃ- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី** (ADB) | | | | | | |
| **គម្រោងបញ្ចប់៖** | | | | | | |
| ១ | ផ្លូវជាតិលេខ១៣(កំចាយមារ/ខេត្តព្រៃវែង-ប្រសូត/ខេត្តស្វាយរៀង) | ៦២,៤០ | ២២ ៧៦៨ ៥៥៨ | Sinohydro Co., Ltd. | ១០០ | ២០១៩ |
| ២ | ផ្លូវខេត្តលេខ៣១៤D (ប្រសូត-ព្រៃវល្លិ៍/ព្រំដែនកម្ពុជា-វៀតណាម) | ២៥,៥០ | ១០៧២៨៩០៥ | Sinohydro Co., Ltd. | ១០០ | ២០១៩ |
| ៣ | ផ្លូវជាតិលេខ៥៣ និងផ្លូវខេត្តលេខ១៥១ B (តាដេស/កំពង់ឆ្នាំង-អមលាំង/កំពង់ស្ពឺ) | ៧០,៦០ | ១៨៦៧១២៥៩ | GVJ | ១០០ | ២០១៩ |
| **សរុប** | | **១៥៨,៥០** | **៥២១៦៨៧២២** | | | |
| **គម្រោងកំពុងដំណើរការ៖** | | | | | | |
| ១ | គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង(កែលម្អហេដ្ឋារចនាសម្ព័ន្ធ ក្រុងរួមមានក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងទីប្រជុំជនអ្នកលឿង) | | ៩២ ៨00 000 | | ៦៧ | ២០២០ |
| **សរុប** | | | **៩២ ៨00 000** | | | |
| **ខ- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយធនាគារពិភពលោក** (WB) | | | | | | |
| ១ | គម្រោងលើកកម្រិត ក្រាលកៅស៊ូ AC និងថែទាំផ្លូវជាតិលេខ៧ | ១៦៤ | ២០ ០៩០ ០២៥ | Guanadong provincial | ៨៤,៦៦ | ២០២០ |
| ២ | គម្រោងលើកកម្រិត ក្រាលកៅស៊ូ AC និងថែទាំផ្លូវជាតិលេខ៣ | ៥៤,៣០ | ៨ ១៧០ ៥៥៩ | SRB | ៧៥,២០ | ២០២០ |
| **សរុប** | | **២១៨,៣០** | **២៨ ២៦០ ៥៨៤** | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **ច- គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយប្រទេសថៃ** | | | | | | |
| **គម្រោងបញ្ចប់៖** | | | | | | |
| ១ | គម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ(ស្ទឹងបត់-បានណាងអៀន) ប្រវែងសរុប៦២០ម៉ែត្រ ទទឹង១៧ម៉ែត្រ (AC) ក្នុងនោះ តួស្ពានប្រវែង១៣០ម៉ែត្រ (ផ្នែកកម្ពុជាប្រវែង៦៥ម៉ែត្រ)ផ្លូវភ្ជាប់ក្បាលស្ពានប្រវែង៤៩០ម៉ែត្រ (ផ្នែកកម្ពុជាប្រវែង១៥០ម៉ែត្រ) | ៦២០ ម. | | | ១០០ | ២០១៩ |
| សរុប | | - | ២៦ ៤២០ ០០០ | | | |

## ឆ- ស្ពានធំៗឆ្លងកាត់ទន្លេនិងដៃសមុទ្រដែលបានស្ថាបនារួច និងដាក់ឱ្យប្រើប្រាស់

ឯកតាជាម៉ែត្រ

| ល.រ | ឈ្មោះស្ពាន | ឆ្នាំ | ប្រវែង | ប្រភេទ | ផ្លូវជាតិ | ទីតាំង | ឆ្លងកាត់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ១ | ស្ពានព្រះមុនីវង្ស | ១៩៦០ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ២ | ស្ពានជ្រោយចង្វាទី១ | ១៩៦៦ | ៧១០ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ជប៉ុន |
| ៣ | ស្ពានគីហ្សូណា | ២០០១ | ១ ៥០០ | បេតុង | ៧ | កំពង់ចាម | ទន្លេមេគង្គ | ជប៉ុន |
| ៤ | ស្ពានកោះកុង | ២០០២ | ១ ៩០០ | បេតុង | ៤៨ | កោះកុង | ដៃសមុទ្រ | ជាតិ |
| ៥ | ស្ពានសេកុង | ២០០៨ | ១ ០៥៧ | បេតុង | ៧ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ៦ | ស្ពានព្រះមុនីវង្សថ្មី | ២០០៩ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ៧ | ស្ពានព្រែកព្នៅ | ២០១០ | ៩៩៦ | បេតុង | ៥ | ភ្នំពេញ | ទន្លេសាប | ជាតិ |
| ៨ | ស្ពានព្រែកក្ដាម | ២០១០ | ៩៨១ | បេតុង | ៥ | កណ្ដាល | ទន្លេសាប | ចិន |
| ៩ | ស្ពានព្រែកតាមាក់ | ២០១១ | ១ ០៦៦ | បេតុង | ៨ | កណ្ដាល | ទន្លេមេគង្គ | ចិន |
| ១០ | ស្ពានកោះពស់ | ២០១១ | ៩០០ | បេតុង | | ព្រះសីហនុ | សមុទ្រ | ឯកជន |
| ១១ | ស្ពានតាខ្មៅ | ២០១៥ | ៨៥៥ | បេតុង | ២១A | កណ្ដាល | ទន្លេបាសាក់ | ចិន |
| ១២ | ស្ពានមេកុង | ២០១៥ | ១ ៧៣១ | បេតុង | ៩ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ១៣ | ស្ពានអ្នកលឿង | ២០១៥ | ២ ២១៥ | ខ្សែកាប | ១ | ព្រៃវែង | ទន្លេមេគង្គ | ជប៉ុន |
| ១៤ | ស្ពានជ្រោយចង្វាទី២ | ២០១៥ | ៧១៩ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ចិន |
| ១៥ | ស្ពានកោះធំ | ២០១៦ | ៤២០ | បេតុង | ២១ | កណ្ដាល | ទន្លេបាសាក់ | ចិន |
| ១៦ | ស្ពានជ្រៃធំ | ២០១៧ | ២១៩ | បេតុង | ២១ | កណ្ដាល | ទន្លេបាសាក់ | វៀតណាម |

## លទ្ធផលការងារចុះបញ្ជីយានយន្តនិងការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចាប់ពីខែសីហា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩

| បរិយាយ | ការងារចុះបញ្ជីយានយន្ត (គ្រឿង) | ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត (គ្រឿង) |
|---|---|---|
| រថយន្តទេសចរណ៍ | ៥៤ ៥៧៤ | ១៧៤ ០០៥ |
| រថយន្តដឹកអ្នកដំណើរធុនតូច | ៧ ៤១៣ | ២៨ ៥០៨ |
| រថយន្តដឹកអ្នកដំណើរធុនធំ | ១ ០៣៨ | ៤ ១៧៣ |

| | | |
|---|---|---|
| រថយន្តដឹកទំនិញធុនតូច | ២០ ៣០៧ | ៥៥ ២៧២ |
| រថយន្តដឹកទំនិញធុនធំ | ១១ ៣០១ | ៥៦ ៤៣៤ |
| ទោចក្រយានយន្ត | ៥០០ ៦៨១ | |
| ត្រីចក្រយានយន្ត | ៣០ ៣៥៥ | |
| **សរុប** | **៦២៥ ៦៦៩** | **៣១៨ ៣៩២** |

<table>
<tr><th colspan="4">ការងារផ្តល់អាជ្ញាបណ្ណយានយន្តធ្វើអាជីវកម្មដឹកអ្នកដំណើរនិងដឹកជញ្ជូនទំនិញ (គ្រឿង)</th></tr>
<tr><td colspan="2">រថយន្តតាក់ស៊ី</td><td colspan="2">២១២</td></tr>
<tr><td colspan="2">រថយន្តដឹកអ្នកដំណើរធុនតូច</td><td colspan="2">១៣ ៣២៤</td></tr>
<tr><td colspan="2">រថយន្តដឹកអ្នកដំណើរធុនធំ</td><td colspan="2">២ ៤៧៩</td></tr>
<tr><td colspan="2">រថយន្តដឹកទំនិញធុនតូច</td><td colspan="2">៣៧ ៦២៩</td></tr>
<tr><td colspan="2">រថយន្តដឹកទំនិញធុនធំ</td><td colspan="2">១៥ ៣១៣</td></tr>
<tr><th colspan="4">ការងារផ្តល់បណ្ណបើកបរ (សន្លឹក)</th></tr>
<tr><td colspan="2">បណ្ណប្រភេទ ក</td><td colspan="2">១២ ០៩២</td></tr>
<tr><td colspan="2">បណ្ណប្រភេទ ខ</td><td colspan="2">១២៣ ៦០៣</td></tr>
<tr><td colspan="2">បណ្ណប្រភេទ គ និង ឃ</td><td colspan="2">១៥ ៦១២</td></tr>
<tr><td colspan="2">បណ្ណប្រភេទ ង</td><td colspan="2">៦៤១</td></tr>
<tr><th colspan="4">ការងារត្រួតពិនិត្យយានយន្តកែច្នៃខុសបច្ចេកទេស (គ្រឿង)</th></tr>
<tr><td colspan="2">ត្រូវតាមបច្ចេកទេស</td><td colspan="2">២០៣ ៧១២</td></tr>
<tr><td colspan="2">មិនត្រូវតាមបច្ចេកទេស</td><td colspan="2">១៧ ៥៦៥</td></tr>
<tr><td colspan="2">កាត់ទ្រុង</td><td colspan="2">៥៨១</td></tr>
<tr><th colspan="4">ការងារចុះបញ្ជីយានយន្ត ជួសជុលនិងយានដ្ឋានកែច្នៃដំឡើងយានយន្ត (កន្លែង)</th></tr>
<tr><td colspan="2">យានដ្ឋានជួលជុល៣ ២៨១</td><td colspan="2">យានដ្ឋានកែច្នៃ២៧៥</td></tr>
<tr><td>ច្បាប់២ ៥៤១</td><td>អត់ច្បាប់៧៤០</td><td>ច្បាប់២៥៤</td><td>អត់ច្បាប់២១</td></tr>
<tr><th colspan="4">ការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់</th></tr>
<tr><td colspan="2">យានយន្តបានត្រួតពិនិត្យ</td><td colspan="2">១ ៣៨៧ ០៣១គ្រឿង</td></tr>
<tr><td colspan="2">យានយន្តមិនលើសទម្ងន់</td><td colspan="2">៨៨៤ ១៨៦គ្រឿង</td></tr>
<tr><td colspan="2">លើសក្រោម៥%</td><td colspan="2">៥០០ ០៨៧គ្រឿង</td></tr>
<tr><td colspan="4">យានយន្តលើសទម្ងន់ពី៥%-១០% ចំនួន៤គ្រឿង ពី១០%-២០%ចំនួន១ ២៧៦គ្រឿង និងច្រើនជាង២០% ចំនួន១ ៤២៧គ្រឿង សរុបយានយន្តពិន័យចំនួន២ ៧០៧គ្រឿង</td></tr>
<tr><td colspan="2">ទឹកប្រាក់ពិន័យ</td><td colspan="2">៦ ៣៨៤ ៧៥០ ០០០រៀល</td></tr>
<tr><td colspan="4">ការងារត្រួតពិនិត្យរថយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសទូទាំងរាជធានី ខេត្ត សរុបចំនួន២២ ៨៣១គ្រឿង ក្នុងនោះ កាត់ទ្រុង៥៨១គ្រឿង ដោះរានតខាងក្រោយ៤៤៣គ្រឿង គ្មានផ្លាកលេខ៤១៤គ្រឿង រថយន្តដឹកទំនិញលក្ខណៈខុសបច្ចេកទេស១ ៨៤២គ្រឿង រថយន្តដាក់ភ្លើងបំភ្លឺខុសបច្ចេកទេស៨០៩គ្រឿង ខ្វះឯកសារ៩ ២៩៣គ្រឿង គ្មានបណ្ណបើកបរ១ ៥៨៥នាក់ ប្រើបណ្ណបើកបរខុសប្រភេទយានយន្ត២ ៥៩៣នាក់ ប្រើឯកសារក្លែងក្លាយ៦៥គ្រឿង ប្រើបណ្ណបើកបរក្លែងក្លាយ១១៧នាក់ បកស្កុតខ្មៅ២៤១គ្រឿង បញ្ជូនទៅស្នងការដ្ឋាន១៥០គ្រឿង ប្រើផ្លាកលេខក្លែងក្លាយ១គ្រឿង និងអ្នកបើកបរផ្ទុកសារធាតុញៀន១២នាក់ និងរថយន្តបានពិនិត្យឃើញថាត្រឹមត្រូវ២០៣ ៧១២គ្រឿង។</td></tr>
</table>

**ការងារត្រួតពិនិត្យរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅគោលដៅដើមទីក្នុងកំពង់ផែស្វយ័តក្រុងព្រះសីហនុនិងកំពង់ផែស្វយ័តភ្នំពេញ ជាលទ្ធផល(ចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩)**
(១)ត្រួតពិនិត្យរថយន្ត៧ ១៦១គ្រឿង (២)រថយន្តល្មើស៤៧១គ្រឿង (៣)រថយន្តត្រឹមត្រូវ៦ ៦៨៩គ្រឿង (៤)មានជាតិអាកុលលើសពីច្បាប់កំណត់១ករណី (៥)ថវិកាផាកពិន័យ១៤៦ ៧៧៥ ០០០រៀល (៦)ល្មើសលិខិតស្នាម២៥៩ករណី(បណ្ណបើកបរ ឆៀក លិខិតអនុញ្ញាតអាជីវកម្ម) (៧)ល្មើសលក្ខណៈបច្ចេកទេស៥១៩ករណី(កង់សឹក រនាំងខ្វះប៊ូឡុងតាកេកង់ គន្លឹះកុងតឺន័រ ភ្លើងបំភ្លឺ) និង(៨)ឃាត់យានយន្តទុក១គ្រឿង។

**ការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

| កិច្ចសហប្រតិបត្តិការ | កូតាយានយន្តក្នុងកិច្ចព្រមព្រៀង | កូតាយានយន្តចុះបញ្ជី(គ្រឿង) | | ច្រកព្រំដែន |
|---|---|---|---|---|
| | | ទំនិញ | ដឹកអ្នកដំណើរ | |
| | គ្រឿង | គ្រឿង | គ្រឿង | |
| កម្ពុជា-វៀតណាម(ទ្វេភាគី) | ៥០០ | ១០៧ | ៣៩៣ | ៧ |
| កម្ពុជា-ឡាវ(ទ្វេភាគី) | ៤០ | - | ២ | ១ |
| កម្ពុជា-វៀតណាម-ឡាវ(ត្រីភាគី) | ១៥០ | ៣៨ | ១០១ | ៨ |
| កម្ពុជា-ថៃ(ទ្វេភាគី) | ១៥០ | - | ៥០ | ១ |
| មហាអនុតំបន់ទន្លេមេគង្គ(GMS) | ៥០០ | ៦ | - | ៥ |

## ១.២- ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ

| ល.រ | បរិយាយ | ឯកតា | ចំនួន | ឯកតា(រៀល) |
|---|---|---|---|---|
| **ក- ស្ថិតិផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវទឹក** | | | | |
| ១ | ផ្តល់បណ្ណសម្គាល់ជលយានគ្រប់ប្រភេទ | គ្រឿង | ១៥ | ៣ ៧៥០ ០០០ |
| ២ | ផ្ទេរម្ចាស់កម្មសិទ្ធិ | ច្បាប់ | ៥ | ៥០០ ០០០ |
| ៣ | ប្តូរបណ្ណនិងទុតិយតា | ច្បាប់ | ១៩ | ២ ២២០ ០០០ |
| ៤ | ផ្តល់បណ្ណបើកបរថ្មី | បណ្ណ | ១៥ | ១ ៤៥០ ០០០ |
| ៥ | ផ្តល់បណ្ណបើកបរបន្ត | បណ្ណ | ១៤ | ៨៤០ ០០០ |
| ៦ | ផ្តល់បណ្ណយន្តការីថ្មី | បណ្ណ | 0 | - |
| ៧ | ផ្តល់បណ្ណយន្តការីថ្មីបន្ត | បណ្ណ | 0 | - |
| ៨ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេសប្រភេទទេសចរណ៍មានបន្ទប់ | គ្រឿង | ៩ | ៤ ៥០០ ០០០ |
| ៩ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេសក្នុងស្រុក | គ្រឿង | ១៧៤ | ២៦ ១០០ ០០០ |
| ១០ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេសដចម្លង | គ្រឿង | ១៨ | ១ ៨០០ ០០០ |
| ១១ | ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនទេសចរណ៍/ស្នាក់នៅ | ច្បាប់ | ២៤ | ២០ ៣១០ ០០០ |
| ១២ | ផ្តល់លិខិតអនុញ្ញាតនាវាដឹកទំនិញឆ្លងដែន | ច្បាប់ | ១២ | ៤ ៨០០ ០០០ |
| ១៣ | ផ្តល់លិខិតអនុញ្ញាតនាវាដឹកទំនិញ | ច្បាប់ | ១៣១ | ៧២ ០៤៣ ៥០០ |
| ១៤ | ផ្តល់លិខិតអាជីវកម្មសាឡាងដឹកទំនិញ(គ្មានម៉ាស៊ីន) | ច្បាប់ | ៧ | ២ ០៣៤ ៥០០ |
| ១៥ | ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ | ច្បាប់ | ៤២ | ២ ២៧៧ ០០០ |
| ១៦ | ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនដចម្លង | ច្បាប់ | ១៩ | ១ ៣៦១ ០០០ |
| ១៧ | ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូន នាវាសណ្តោង | ច្បាប់ | ៨ | ១ ៨២៥ ៥០០ |
| **សរុប** | | | **៥១២** | **១៤៥ ៨១១ ៥០០** |

| ខ- ស្ថិតិផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវសមុទ្រ | | | | |
|---|---|---|---|---|
| ១ | ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកថ្នាក់ជំនួយការ(អន្តរជាតិ) | បណ្ណ | ៤ | ៤៨០ ០០០ |
| ២ | ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកថ្នាក់ទី៣(តំបន់ឆ្នេរ) | បណ្ណ | ៤៦ | ២ ៣០០ ០០០ |
| ៣ | បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកថ្នាក់ទី១ | បណ្ណ | ១៤ | ៨៤០ ០០០ |
| ៤ | បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកថ្នាក់ទី៣ | បណ្ណ | ១ | ៣០ ០០០ |
| ៥ | ការផ្តល់សៀវភៅនាវិក(ថ្មី/ប្តូរ) | ក្បាល | ១៣ | ៣ ៩០០ ០០០ |
| ៦ | ពន្យារសុពលភាពសៀវភៅនាវិក | ក្បាល | ១៩ | ១ ៩០០ ០០០ |
| ៧ | ការផ្តល់បណ្ណសម្គាល់នាវា(ពី២០តោន-១៥០តោន) | បណ្ណ | ១ | ២០០ ០០០ |
| ៨ | ការផ្តល់បណ្ណសម្គាល់នាវា(លើសពី១៥០តោន) | បណ្ណ | ៣៧ | ១៨ ៥០០ ០០០ |
| ៩ | ប្តូរទុតិយតា តតិយតាបណ្ណសម្គាល់នាវា | បណ្ណ | ១ | ៣០០ ០០០ |
| ១០ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេស(២០តោន-១៥០តោន) | ក្បាល | ១ | ១០០ ០០០ |
| ១១ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេស(ពី១៥០តោន-៣០០តោន) | ក្បាល | ២៤ | ៤ ៨០០ ០០០ |
| ១២ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេស(ពី៣០០តោន-៥០០តោន) | ក្បាល | ១៣ | ៣ ២៥០ ០០០ |
| ១៣ | ត្រួតពិនិត្យលក្ខណៈបច្ចេកទេស(លើសពី៥០០តោន) | ក្បាល | ១០ | ៣ ០០០ ០០០ |
| ១៤ | អូប័រ នាវាជនបរទេស នាវាពិសេស | ក្បាល | ១៣ | ២ ៦០០ ០០០ |
| ១៥ | លិខិតអនុញ្ញាតនាវាធ្វើអាជីវកម្ម | គ្រឿង | ៤៨ | ១២ ៣៧៨ ៥០០ |
| ១៦ | ច្បាប់ស្ថាបនានាវា(២០តោន-១៥០តោន) | គ្រឿង | ២ | ៥២០ ០០០ |
| **សរុប** | | | **២៤៧** | **៥៥ ០៩៨ ៥០០** |

| គ- ស្ថិតិផ្តល់សេវារដ្ឋបាលកំពង់ផែ | |
|---|---|
| ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ | ផ្តល់លិខិតបន្តសុពលភាព លិខិតអនុញ្ញាតប្រតិបត្តិការកំពង់ផែ |
| ១០ច្បាប់ | ១ច្បាប់ |

| ឃ- កំពង់ផែស្វយ័តក្រុងព្រះសីហនុ | | | |
|---|---|---|---|
| ទំនិញឆ្លងកាត់ (តោន) | បរិមាណកុងតឺន័រឆ្លងកាត់(TEUs) | បរិមាណនាវាឆ្លងកាត់ (គ្រឿង) | ចំណូលអាជីវកម្ម(ពាន់រៀល) |
| **៥ ៥៧៥ ៨០២** | **៥៤១ ៩៦៨** | **១ ៤៩៤** | **២៨១ ៣៥២ ១១៣** |

| ង- កំពង់ផែស្វយ័តភ្នំពេញ | | | | |
|---|---|---|---|---|
| ទំនិញឆ្លងកាត់ (តោន) | បរិមាណកុងតឺន័រឆ្លងកាត់(TEUs) | បរិមាណនាវាផ្ទុកទំនិញឆ្លងកាត់ (គ្រឿង) | បរិមាណនាវាដឹកអ្នកដំណើរ(ចំនួនជើង) | ចំណូលអាជីវកម្ម (ពាន់រៀល) |
| **៣ ៣៤៦ ០៥៧** | **២២៦ ៧២៦** | **២ ០២៣** | **៣៦២** | **១៤ ៣១៦ ២៦៦** |

## ១.៣- ការដឹកជញ្ជូនតាមផ្លូវដែក

| ល.រ | បរិយាយ | ឯកតា | ប្រវែង ទម្ងន់ និងចំនួន |
|---|---|---|---|
| ១ | ប្រវែងផ្លូវដែកភាគខាងត្បូងភ្នំពេញ-ក្រុងព្រះសីហនុ | គ.ម. | ២៦៦ |
| ២ | ប្រវែងផ្លូវដែកភាគខាងជើងភ្នំពេញ-ប៉ោយប៉ែត | គ.ម. | ៣៨៦ |
| ៣ | បរិមាណដឹកជញ្ជូនទំនិញសរុប | តោន | ៧៤៧ ១០៧ |
| ៤ | បរិមាណដឹកជញ្ជូនទំនិញនាំចូល | តោន | ៧៧ ០៣០ |
| ៥ | បរិមាណដឹកជញ្ជូនទំនិញនាំចេញ | តោន | ៦៧០ ០៧៧ |
| ៦ | ចំនួនអ្នកដំណើរសរុប | នាក់ | ២១ ០៥៥ |
| ៧ | ចំនួនអ្នកដំណើរភ្នំពេញ-ក្រុងព្រះសីហនុ | នាក់ | ១៦ ០៦៦ |
| ៨ | ចំនួនអ្នកដំណើរភ្នំពេញ-ប៉ោយប៉ែត | នាក់ | ១៨៩ |
| ៩ | ចំនួនអ្នកដំណើរភ្នំពេញ-អាកាសយានដ្ឋានអន្តរជាតិ | នាក់ | ៤ ៨០០ |
| ១០ | ចំនួនប្រតិបត្តិការដឹកជញ្ជូនទំនិញនាំចេញ-ចូល | ជើង | ២ ០៨៣ |
| ១១ | ចំនួនប្រតិបត្តិការដឹកអ្នកដំណើរ | ជើង | ៩៣០ |

**- បាននាំចូលក្បាលរថភ្លើងពីប្រទេសម៉ាឡេស៊ីចំនួន១០គ្រឿង បច្ចុប្បន្នកំពុងដំណើរការ ខ្សែរត់ទៅផ្លូវដែកទិសខាងជើងថែមទៀត។**

## ១.៤- ការដឹកជញ្ជូននិងអាជីវកម្មតាមផ្លូវអាកាស

| ស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាសពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ | | | | |
|---|---|---|---|---|
| បរិយាយ | ហោះហើរ (ជើង) | អ្នកធ្វើដំណើរ(នាក់) | ដឹកអីវ៉ាន់(គ.ក្រ.) | កញ្ចប់ប្រៃសណីយ៍(គ.ក្រ.) |
| អន្តរជាតិ | ៨៨ ៧២៤ | ១០ ១៩៤ ០២៧ | ៧៤ ៦៨៧ ៣៩៨ | ១ ២១៧ ៣០៩ |
| ក្នុងប្រទេស | ១៤ ៤៨៨ | ៦២១ ៧១៧ | ២៨៩ ២៨៤ | NIL |
| **សរុប** | **១០៣ ២១២** | **១០ ៨១៥ ៧៤៤** | **៧៤ ៩៧៦ ៦៨២** | **១ ២១៧ ៣០៩** |

- ក្រុមហ៊ុនអាកាសចរណ៍អនុញ្ញាតហោះហើរជាប្រក្រតីក្នុងរដូវកាលថ្មី(IATASummer Season)២០១៨ ជូនក្រុមហ៊ុនអាកាសចរណ៍ក្នុងនិងក្រៅប្រទេសចំនួន៤៧ក្រុមហ៊ុន (ក្នុងស្រុកចំនួន៩)។

- ក្រុមហ៊ុនអាកាសចរណ៍អនុញ្ញាតហោះហើរជាលក្ខណៈ Charter/Extra Flights

| ល.រ | ឈ្មោះក្រុមហ៊ុន | | | |
|---|---|---|---|---|
| ១ | Cambodia Angkor Air | K6 | មានចំនួន | ៣៦លើក |
| ២ | Vietnam Airlines | VN | មានចំនួន | ៥លើក |
| ៣ | China Eastern Airlines | MU | មានចំនួន | ៣លើក |
| ៤ | China Southern Airlines | CZ | មានចំនួន | ១លើក |
| ៥ | Silk Air | MI | មានចំនួន | ២លើក |
| ៦ | Sky Angkor Airlines | ZA | មានចំនួន | ២លើក |
| ៧ | Jetstar Pacific Airlines | BL | មានចំនួន | ១លើក |
| ៨ | Turkish Airlines | TK | មានចំនួន | ១លើក |
| ៩ | JC Cambodia Intl. Airlines | QD | មានចំនួន | ១៥លើក |

| | | | | |
|---|---|---|---|---|
| ១០ | Lanmei Airlines | LQ | មានចំនួន | ៧លើក |
| ១១ | Xiamen Airlines | MF | មានចំនួន | ២លើក |
| ១២ | Juneyao Airlines | HO | មានចំនួន | ១លើក |
| ១៣ | Cambodia Airways | KR | មានចំនួន | ៣លើក |
| ១៤ | Qata Airways | QR | មានចំនួន | ៥លើក |
| ១៥ | Bangkok Airways | PQ | មានចំនួន | ១លើក |
| ១៦ | Thaiai Air As | FD | មានចំនួន | ២លើក |
| ១៧ | Lao Airlines | QV | មានចំនួន | ២លើក |
| ១៨ | Lucky Air | 8L | មានចំនួន | ១លើក |
| ១៩ | Nine Air | AQ | មានចំនួន | ១លើក |
| ២០ | Qingdao Airlines | QV | មានចំនួន | ១លើក |
| ២១ | Zhejian Loong Airlines | GJ | មានចំនួន | ១លើក |

## ២- ថាមពល

### ២.១- ការអភិវឌ្ឍថាមពលអគ្គិសនី

ថាមពលអគ្គិសនី គឺជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍវិស័យផ្សេងៗ ការអភិវឌ្ឍតំបន់ជនបទនិងការបង្កើនសុខុដុមនីយភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាកាន់តែមានស្ថិរភាពនយោបាយ និងក្នុងខណៈពេលដែលសេដ្ឋកិច្ចជាតិនិងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ សេចក្តីត្រូវការនិងភាពចាំបាច់នៃថាមពលអគ្គិសនីក៏កាន់តែកើនឡើងជាលំដាប់ផងដែរ។ ដូច្នេះត្រូវតែរៀបចំធ្វើការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ដើម្បីធ្វើឱ្យកម្ពុជាមានការផ្គត់ផ្គង់អគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាពអាចទុកចិត្តបាន មានគុណភាពនិងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា។

ការអភិវឌ្ឍប្រភពអគ្គិសនីបានកើនឡើងពី២ ៦៣៥មេហ្គាវ៉ាត់ មក៣ ៣៨២មេហ្គាវ៉ាត់ ឆ្លើយតបនឹងសេចក្តីត្រូវការ ក្នុងនោះការផលិតក្នុងស្រុកកើនពី២ ១៨៦មេហ្គាវ៉ាត់ មក២ ៧៥៥មេហ្គាវ៉ាត់ ការនាំចូលប្រភពអគ្គិសនីមានការកើនឡើងពី១៦,០៩%ទៅ២៥,២% ការអភិវឌ្ឍខ្សែបញ្ជូននិងអនុស្ថានីយបន្ថែមធ្វើឱ្យនៅឆ្នាំ២០១៩ កម្ពុជាមានខ្សែបញ្ជូនតង់ស្យុងខ្ពស់ប្រវែង២ ២៦៧គ.ម. និងមានអនុស្ថានីយ៍ចំនួន៣៦ គ្របដណ្តប់ផ្ទាល់លើរាជធានី/ខេត្តចំនួន២១ ខ្សែតង់ស្យុងមធ្យមមានប្រវែង៣៤ ០៥៦គ.ម. ត្រង់ស្វូចែកចាយ១៨ ៤៦២គ្រឿង និងតង់ស្យុងទាបមានប្រវែង៣៦ ៨៥៣គ.ម.. ដែលគ្របដណ្តប់លើភូមិ៩២,៦៨% ការភ្ជាប់អគ្គិសនីឱ្យអ្នកប្រើប្រាស់គ្រប់ប្រភេទ បានកើនដល់២,៨៣លានទីតាំង ក្នុងចំណោមនោះមានលំនៅឋានចំនួន២,៦៨លានខ្នងផ្ទះត្រូវជា៧៤,៧៨% បានភ្ជាប់អគ្គិសនីប្រើប្រាស់រួចហើយ។

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ ប្រភពថាមពលធំៗក្នុងស្រុកបានអភិវឌ្ឍតាមផែនការ ក្នុងនោះមានវារីអគ្គិសនីចំនួន៧គម្រោងបានដាក់ឱ្យដំណើរការអានុភាពសរុប១ ៣២៩មេហ្គាវ៉ាត់ កើនឡើងចំនួន៨,១៤% ធៀបនឹងខែកញ្ញា ឆ្នាំ២០១៨ និងស្ថានីយ៍អគ្គិសនីដុតធ្យូងថ្មចំនួន២គម្រោងមានអានុភាពសរុប៥០៥មេហ្គាវ៉ាត់នៅខេត្តព្រះសីហនុ។

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ កម្ពុជាបានផលិតថាមពលអគ្គិសនីពីប្រភពថាមពលកកើតឡើងវិញជីវម៉ាសប្រមាណ១២៣,៥៧មេហ្គាវ៉ាត់ (ថាមពលដើរដោយពន្លឺព្រះអាទិត្យមានអានុភាព៩៥មេហ្គាវ៉ាត់និងថាមពលជីវម៉ាស់អានុភាព២៨,៥៧មេហ្គាវ៉ាត់) ដែលត្រូវជា១,៣១% ធៀបនឹងតម្រូវការថាមពលសរុបទូទាំងប្រទេស។

| ការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាង | | | | |
|---|---|---|---|---|
| ល.រ | ប្រភពនាំចូល | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | កើនឡើង |
| ១ | សាធារណរដ្ឋសង្គមនិយមវៀតណាម | ២៧៧មេហ្គាវ៉ាត់ | ៣២៣មេហ្គាវ៉ាត់ | ១៦,៦០% |
| ២ | ព្រះរាជាណាចក្រថៃ | ១៣៥មេហ្គាវ៉ាត់ | ២២៧មេហ្គាវ៉ាត់ | ៦៨,១៤% |
| ៣ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ៣៦មេហ្គាវ៉ាត់ | ៧៦មេហ្គាវ៉ាត់ | ១១១% |
| សរុប | | ៤៤៨មេហ្គាវ៉ាត់ | ៦២៦មេហ្គាវ៉ាត់ | ៣៩,៧៣% |

| ការផ្គត់ផ្គង់ថាមពលអគ្គិសនី | | |
|---|---|---|
| ១ | ការផ្គត់ផ្គង់ថាមពលអគ្គិសនី(មាននៅក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) របស់EDC | ១២ ០១៤លានKWh |
| ២ | ភាគរយនៃប្រភពថាមពលអគ្គិសនីកកើតឡើងវិញ(អានុភាពដំឡើង ធៀបនឹងអានុភាពសរុប) | ១,៣១% |
| ៣ | ចំនួននាឡិកាស្ទង់ដែលបានភ្ជាប់ចរន្ត | ២,៨៣លាន |
| ៤ | ភូមិដែលមានការផ្គត់ផ្គង់ថាមពលអគ្គិសនី | ៩២,៦៨% |
| ៥ | ចំនួនខ្នងផ្ទះដែលមានថាមពលអគ្គិសនីប្រើប្រាស់ | ៧៤,៧៨% |

| តារាងតម្លៃសម្រាប់ការផ្គត់ផ្គង់ប្រភពអគ្គិសនីឱ្យអ្នកផ្គត់ផ្គង់បន្ត(បញ្ជូនរងនិងចែកចាយ) | | |
|---|---|---|
| ប្រភេទនៃការទិញរបស់អ្នកផ្គត់ផ្គង់បន្ត | ឯកតា | អត្រាថ្លៃលក់ដែលត្រូវអនុវត្ត |
| | | ២០១៩ |
| ១- អ្នកផ្គត់ផ្គង់បន្តដែលទិញពីទ្វារចរន្តMV នៃអនុស្ថានីយ | $/kWh | 0,១១៨0 |
| ២- អ្នកផ្គត់ផ្គង់បន្តដែលទិញពីទ្វារចរន្តMV តាមនាឡិកា MV | $/kWh | 0,១៣៥0 |
| ៣- អ្នកផ្គត់ផ្គង់បន្តដែលទិញក្រោមត្រង់ស្វូ តាមនាឡិកា LV | | |
| - ករណីត្រង់ស្វូវិនិយោគដោយអ្នកទិញ | $/kWh | 0,១៤0៤ |
| - ករណីត្រង់ស្វូវិនិយោគដោយអ្នកលក់ | $/kWh | 0,១៤៨៤ |

| ថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជាសម្រាប់អ្នកប្រើប្រាស់ | | |
|---|---|---|
| ប្រភេទនៃអ្នកប្រើប្រាស់និងលក្ខខណ្ឌទិញ | ឯកតា | អត្រាថ្លៃលក់ដែលត្រូវអនុវត្ត |
| | | ២០១៩ |
| ១- អ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីពីអនុស្ថានីយ៖ | | |
| - ទិញពីទ្វារចរន្តតង់ស្យុងខ្ពស់ | $/kWh | 0,១១៧0 |
| - ទិញពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយក្នុងភ្នំពេញ | $/kWh | 0,១៣៥0 |
| - ទិញពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយនៅខេត្ត | $/kWh | 0,១២២0 |

| | | |
|---|---|---|
| ២- អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម | | |
| - ទិញពីអនុស្ថានីយបណ្តាញជាតិផ្ទាល់ | $/kWh | តាមចំណុច១ខាងលើ |
| - ទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមតាមនាឡិកា MV | $/kWh | ០,១៤៧០ |
| - ទិញពីក្រោមត្រង់ស្វូផ្ទាល់តាមនាឡិកា LV ៖ | | |
| ក- ករណីត្រង់ស្វូវិនិយោគដោយអ្នកទិញ | $/kWh | ០,១៥២៩ |
| ខ- ករណីត្រង់ស្វូវិនិយោគដោយអ្នកលក់ | $/kWh | ០,១៦០៩ |
| - ទិញពីខ្សែបណ្តាញចែកចាយសាធារណៈតង់ស្យុងទាប | ៛/kWh | ៧៤០ |
| ៣- អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្មនិងរដ្ឋបាល ៖ | | |
| - ទិញពីអនុស្ថានីយបណ្តាញជាតិផ្ទាល់ | $/kWh | តាមចំណុ១ខាងលើ |
| - ទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមតាមនាឡិកា MV | $/kWh | ០,១៥៩០ |
| - ទិញពីក្រោមត្រង់ស្វូផ្ទាល់តាមនាឡិកា LV ៖ | | |
| ក- ករណីត្រង់ស្វូវិនិយោគដោយអ្នកទិញ | $/kWh | ០,១៦៥៤ |
| ខ- ករណីត្រង់ស្វូវិនិយោគដោយអ្នកលក់ | $/kWh | ០,១៧៣៤ |
| - ទិញពីខ្សែបណ្តាញចែកចាយសាធារណៈតង់ស្យុងទាប | ៛/kWh | ៧៤០ |
| ៤- អ្នកប្រើប្រាស់ប្រភេទលំនៅឋាន | | |
| ៤.១- ទិញពីខ្សែបណ្តាញចែកចាយសាធារណៈ | | |
| - អ្នកប្រើពី១ដល់១០គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៛/kWh | ៣៨០ |
| - អ្នកប្រើពី១១ដល់៥០គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៛/kWh | ៤៨០ |
| - អ្នកប្រើពី៥១ដល់២០០គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៛/kWh | ៦១០ |
| - អ្នកប្រើចាប់ពី២០១គីឡូវ៉ាត់ម៉ោងក្នុង១ខែឡើងទៅ | ៛/kWh | ៧៤០ |
| ៤.២- ទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម | | តាមអត្រាចំណុច៣ |
| ៥- អ្នកប្រើប្រាស់ប្រភេទអនុគ្រោះពិសេស៖ | | |
| - ការបូមទឹកធ្វើកសិកម្មពេលយប់ពីម៉ោង៩យប់ដល់ម៉ោង៧ព្រឹក | ៛/kWh | ៤៨០ |
| - សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ | ៛/kWh | ៦១០ |

## ២.២- ការងារបរមាណូស៊ីវិល

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ ការអភិវឌ្ឍផ្នែកបរមាណូស៊ីវិល សម្រេចបានដូចខាងក្រោម៖

- បានចុះត្រួតពិនិត្យមើលកម្រិតវិទ្យុសកម្មនៅតាមការដ្ឋានរ៉ែចំនួន៣២ទីតាំង ក្នុងបណ្តារាជធានីខេត្តចំនួន១៣ ដើម្បីធានាថាមិនមានជាតិវិទ្យុសកម្មកើតឡើងដោយធម្មជាតិដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថានជុំវិញនិងបានចុះស្រង់ទិន្នន័យការប្រើប្រាស់ឧបករណ៍មានការប្រើប្រាស់ប្រភពវិទ្យុសកម្ម ឬបញ្ចេញជាតិវិទ្យុសកម្មតាមមន្ទីរពេទ្យចំនួន៥ទីតាំង នៅខេត្តចំនួន២។

- បានសម្របសម្រួលគម្រោងសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនិងភ្នាក់ងារថាមពលបរមាណូអន្តរជាតិ(IAEA) ចំនួន៣២គម្រោង ក្នុងនោះគម្រោងមានស្រាប់២០គម្រោងនិងគម្រោងថ្មី(សម្រាប់អនុវត្តពីឆ្នាំ២០២០ដល់ឆ្នាំ២០២៤)ចំនួន១២គម្រោង និងបានសហការជាមួយជំនាញការអន្តរជាតិក្រោមជំនួយរបស់ទីភ្នាក់ងារ IAEA ក្នុងការដំឡើងឧបករណ៍ចាប់កម្រិតវិទ្យុសកម្មក្នុងបរិយាកាសចំនួន២គ្រឿង និងប្រព័ន្ធសម្រាប់ធ្វើការទាក់ទងដោយសុវត្ថិភាពជាមួយនឹង IAEA ចំនួន១ឈុត។

- បានផ្តល់សេវាកម្មអានកម្រិតវិទ្យុសកម្មលើបរិធានចាប់ពីកម្រិតវិទ្យុសកម្ម TLD សរុបចំនួន ៣៩៥បរិធាននៃអ្នកប្រើប្រាស់សរុបចំនួន៧៩នាក់។

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើផ្នែកកម្មវិធីបរិមាណូស៊ីវិល ព្រមទាំងវិទ្យុសកម្មចំនួន៤ លើក មានសិក្ខាកាមចូលរួម៣០០នាក់មកពីស្ថាប័នពាក់ព័ន្ធនិងមន្ត្រីមន្ទីររ៉ែនិងថាមពលទូទាំង២៥រាជធានី ខេត្ត និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើផ្នែកបច្ចេកទេសថាមពល(ស្តង់ដាអគ្គិសនី)ចំនួន១លើក មានសិក្ខាកាម ចូលរួម១៥០នាក់ ដែលជាតំណាងពីស្ថាប័នពាក់ព័ន្ធនិងតំណាងក្រុមហ៊ុនឯកជន។

## ៣- វិស័យរ៉ែ

### ៣.១- ការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យរ៉ែ

#### ក- ការសិក្សាភូគព្ភសាស្ត្រនិងសក្តានុពលធនធានរ៉ែ

ក្រសួងរ៉ែនិងថាមពលបាននិងកំពុងជំរុញឱ្យធ្វើការសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ទិន្នន័យអំពី សក្តានុពលធនធានរ៉ែ ដើម្បីកសាងផែនទីភូគព្ភសាស្ត្ររ៉ែចំនួន៣ប្រភេទសំខាន់ៗ (១)ផែនទីភូគព្ភសាស្ត្រកម្រិត ទាបនៅកម្ពុជាលើមាត្រាដ្ឋាន១/១ ០០០ ០០០ ដោយបានប្រមូលសំណាក រ៉ែធម្មតាចំនួន១ ៧៩៥សំណាកនៅទូទាំង ប្រទេសធៀបនឹងឆ្នាំ២០១៨ ដែលប្រមូលសំណាករ៉ែធម្មតាបានត្រឹមតែ៧៦៦សំណាក នៅក្នុងខេត្តចំនួន១៤ កើនឡើង ២៣៤% និងសំណាកគោលបានចំនួន២៧សំណាក នៅទូទាំងប្រទេសកើនឡើង១០០% ព្រោះក្នុងឆ្នាំ២០១៨ ពុំបានអនុវត្ត (២)កសាងផែនទីវារីភូគព្ភសាស្ត្រនិងបរិស្ថានភូគព្ភសាស្ត្រលើមាត្រាដ្ឋាន១ : ៥០០០ ០០០ ដោយ បានប្រមូលសំណាកគំរូចំនួន២៧២សំណាក ធៀបនឹងឆ្នាំ២០១៨ ដែលប្រមូលបានត្រឹមតែ៧២ កើនឡើង ៣៧៧%។ សំណាកគំរូខាងលើត្រូវបានបែងចែកជា២ប្រភេទគឺទី១- សំណាកទឹកក្រោមដីបានចំនួន១៧៧សំណាក ធៀបនឹងឆ្នាំ២០១៨ បានចំនួន២៣សំណាក និងទី២- សំណាកទឹកលើដីបានចំនួន៩៥ ធៀបនឹងឆ្នាំ២០១៨បាន ចំនួន៤៩សំណាកនិងតាមបណ្តាខេត្តចំនួន១៩ ធៀបនឹងឆ្នាំ២០១៨ បានចំនួន៥ខេត្ត និង(៣) កសាងផែនទី ភូគព្ភសាស្ត្រសមុទ្រនិងគ្រោះអន្តរាយតំបន់ឆ្នេរ ដោយបានចុះសិក្សានៅខេត្តព្រះសីហនុ និងខេត្តកោះកុង ដែល ប្រមូលសំណាកខ្សាច់ចំនួន១៦ សំណាកទឹកសមុទ្រចំនួន៤០ សំណាកពំនុះកាត់ឆ្នេរចំនួន២២និងដាំបង្គោល តម្រុយចំនួន៣ទីតាំង និងយកសំណាកទឹកសមុទ្រ សំណាកដីល្បាប់ខ្សាច់សម្រេចប្រហែល៩០%។ គម្រោងនេះ ក្រុមការងារបានរៀបចំនិងចងក្រងបោះពុម្ពលទ្ធផលស្រាវជ្រាវជាសៀវភៅបានចំនួន៤០ក្បាល។

គម្រោងទាំង៣ខាងលើ ត្រូវបានប្រើជាប្រយោជន៍ដល់ការអភិវឌ្ឍធនធានរ៉ែនិងប្រភេទថ្ម (សិលាសាស្ត្រ) ការអភិវឌ្ឍវិស័យកសិកម្ម ការអភិវឌ្ឍវិស័យបរិស្ថាននិងសុខភាព ការអភិវឌ្ឍភូគព្ភសាស្ត្រនិង ធនធានរ៉ែបាតសមុទ្រ ដើម្បីយល់ដឹងអំពីការប្រែប្រួលនិងធ្វើម៉ូដែលភូគព្ភសាស្ត្រតំបន់ឆ្នេរនិងដឹងពីគ្រោះអន្តរាយ ធនធានធម្មជាតិនៅបាតសមុទ្រ។ បន្ថែមពីលើការកសាងផែនទីភូគព្ភសាស្ត្រទាំងបីខាងលើ ក្រសួងក៏បានចុះ សិក្សាទីតាំងភូគព្ភសាស្ត្ររ៉ែសម្រាប់អភិរក្សចំនួន៣៨កន្លែងក្នុងខេត្ត ចំនួន២ គឺខេត្តបាត់ដំបងនិងខេត្តប៉ៃលិននិង បានចុះស្រង់ទិន្នន័យភូគព្ភសាស្ត្រនិងសន្ទស្សន៍រ៉ែនៅកម្ពុជាបាន១៨កន្លែងទូទាំងប្រទេស។

#### ខ- ស្ថានភាពវិនិយោគក្នុងវិស័យរ៉ែ

ក្រសួង បាននិងកំពុងជំរុញឱ្យមានការវិនិយោគលើការធ្វើអាជីវកម្មរ៉ែប្រកបដោយចីរភាព ដោយធ្វើការត្រួតពិនិត្យភាពអនុលោមជាប្រចាំ វាយតម្លៃអំពីតម្រូវការនិងលទ្ធផលនៃការធ្វើប្រតិបត្តិការធនធានរ៉ែ ដែលនាំឱ្យការវិនិយោគរ៉ែមានស្ថានភាព ដូចតទៅៈ (១)**ប្រតិបត្តិការស្វែងរករ៉ែបានថយចុះពី៥៦មកត្រឹម៣៧ អាជ្ញាបណ្ណ** ដោយធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវរ៉ែលោហៈ២៨អាជ្ញាបណ្ណ រ៉ែបុកស៊ីត១អាជ្ញាបណ្ណ រ៉ែត្បូងថ្ម៥ អាជ្ញាបណ្ណរ៉ែខ្សាច់ស១អាជ្ញាបណ្ណ និងសិក្សាស្រាវជ្រាវរ៉ែថ្មកំបោ២អាជ្ញាបណ្ណ (២)ប្រតិបត្តិការឧស្សាហកម្ម

អាជីវកម្មរ៉ែមានចំនួន១៧អាជ្ញាបណ្ណ ដោយធ្វើអាជីវកម្មរ៉ែមាស៦អាជ្ញាបណ្ណ រ៉ែដែក១អាជ្ញាបណ្ណ រ៉ែខ្សាច់ស១អាជ្ញាបណ្ណ រ៉ែប៉ុកស៊ីត១អាជ្ញាបណ្ណ រ៉ែត្បូងថ្ម១អាជ្ញាបណ្ណ និងអាជីវកម្មរ៉ែថ្មកំបោរ៧អាជ្ញាបណ្ណ និង(៣)ប្រតិបត្តិការលើការធ្វើអាជីវកម្មរ៉ែក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម បានថយចុះពីចំនួន៣១២មកត្រឹម២៩៥អាជ្ញាបណ្ណ ក្នុងនោះធ្វើអាជីវកម្មខ្សាច់៨៥អាជ្ញាបណ្ណ អាជីវកម្មសំណង់១១៩អាជ្ញាបណ្ណ អាជីវកម្មថ្មអារ(ថ្មកែវ ថ្មក្រានីត ថ្មកក់ ថ្មម៉ាប ឡាតេរីតអារ)៣៤អាជ្ញាបណ្ណ និងអាជីវកម្មអាចម៍ដីនិងខ្សាច់បក៥៧អាជ្ញាបណ្ណ។

តាមទិន្នន័យខាងលើយើងសង្កេតឃើញថា ប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទត្រូវបានថយចុះដោយសារការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានរ៉ែ តាមរយៈការវាយតម្លៃអំពីភាពអនុលោមផលសេដ្ឋកិច្ចនិងសក្តានុពលនៃការប្រតិបត្តិការធនធានរ៉ែ ដើម្បីធ្វើជាមូលដ្ឋានក្នុងការបញ្ចប់សកម្មភាពប្រតិបត្តិការធនធានរ៉ែមួយចំនួនធំនិងកំណត់លក្ខខណ្ឌតឹងរ៉ឹងក្នុងការអនុញ្ញាតឱ្យមានសកម្មភាពប្រតិបត្តិការធនធានរ៉ែថ្មី។ ថ្វីត្បិតតែប្រតិបត្តិកាធនធានរ៉ែមានការថយចុះ ប៉ុន្តែផលសេដ្ឋកិច្ចដែលកើតចេញពីការធ្វើប្រតិបត្តិការធនធានរ៉ែមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាក់ស្តែងការផលិតស៊ីម៉ងត៍ ថ្ម ខ្សាច់នៅក្នុងប្រទេសអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារសំណង់ ដែលកើតចេញយ៉ាងគំហុកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនិងសំណង់តូចធំនានា។

**គ- ការងារអធិការកិច្ចធនធានរ៉ែ**

ប្រតិបត្តិការធនធានរ៉ែក្នុងរយៈពេល១ឆ្នាំនៃការបង្កើតរាជរដ្ឋាភិបាល នីតិកាលទី៦ ក្រសួងបានពិនិត្យនិងអធិការកិច្ច ដូចតទៅៈ **១**-ក្រុមការងារអធិការកិច្ចឧស្សាហកម្មអាជីវកម្មធនធានរ៉ែចុះពិនិត្យចំនួន៤លើក **២**- ក្រុមការងារអធិការកិច្ចអាជីវកម្មរ៉ែថ្មសំណង់ ចុះពិនិត្យចំនួន៤លើក **៣**- ក្រុមការងារអធិការកិច្ចអាជីវកម្មរ៉ែខ្សាច់ចុះពិនិត្យចំនួន៤លើក **៤**- ក្រុមការងារអធិការកិច្ចអាជីវកម្មរ៉ែក្រួស ឡាតារីត ខ្សាច់បកនិងអាចម៍ដីចុះពិនិត្យចំនួន៦លើក និង**៥**- ការត្រួតពិនិត្យដោយមន្ត្រីជំនាញអគ្គនាយកដ្ឋានរដ្ឋបាលបានចំនួន៣៦លើក ដែលបានត្រួតពិនិត្យចំនួន៣០១ក្រុមហ៊ុន/សហគ្រាស។

**ឃ- ការអភិវឌ្ឍសហគមន៍មូលដ្ឋាន**

ក្រសួង បានរៀបចំឱ្យមានមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមមូលដ្ឋាន ដែលជំរុញការអភិវឌ្ឍសហគមន៍ដែលមានប្រតិបត្តិករធនធានរ៉ែ ក្នុងគោលបំណងជួសជុលផលប៉ះពាល់និងលើកកម្ពស់ជីវភាពប្រជាជននៅក្នុងតំបន់ដែលមានប្រតិបត្តិការធនធានរ៉ែ។ ក្នុងរយៈពេល១ឆ្នាំនៃការបង្កើតរាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ក្រសួងបានអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋានបានចំនួន៥គម្រោង គឺទី**១**- ជួសជុលផ្លូវដីសដោយក្រាលក្រួសក្រហមចំនួន២ខ្សែ ប្រវែង ១ ៤០៧ម៉ែត្រនិងដាក់លូមុខកាត់៨០ស.ម. ចំនួន៣កន្លែង ស្ថិតក្នុងឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប បម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រមាណ៨២០គ្រួសារ ចំណាយថវិកា ១៧ ៤០០ដុល្លារអាម៉េរិក។ ទី**២**- ជួសជុលផ្លូវក្រាលក្រួសក្រហម១ខ្សែ ប្រវែង១ ៥០០ម៉ែត្រ ទទឹង៣ម៉ែត្រ នៅឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង បម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រមាណ១៦០គ្រួសារ ចំណាយថវិកា ៧ ១០០ដុល្លារអាម៉េរិក។ **ទី៣**- ជួសជុលផ្លូវចំនួន២ខ្សែ ប្រវែង៦៨០ម៉ែត្រ បាតក្រោម១០ម៉ែត្រ ខ្នងលើ៦ម៉ែត្រនិងកម្រាស់២ម៉ែត្រ ដែលជាផ្លូវតភ្ជាប់ផ្លូវជាតិលេខ៦Aចូលទៅភូមិព្រែកតាសោម ក្នុងឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល បម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រមាណ៣០០គ្រួសារ ចំណាយថវិកា២៨ ០០០ ដុល្លារអាម៉េរិក។ **ទី៤**- ជួសជុលផ្លូវដីសដោយក្រាលក្រួសក្រហមចំនួន៣ខ្សែ ប្រវែង១ ០៥០ម៉ែត្រ ទទឹង៤ម៉ែត្រ ស្ថិតក្នុងឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប បម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រមាណ២ ៩៩១គ្រួសារ ចំណាយថវិកា២០ ៥៣៥ដុល្លារអាម៉េរិក និង**ទី៥**- ជួសជុលផ្លូវក្រាលក្រួសក្រហមចំនួន១ខ្សែ ប្រវែង៣ ១៥០ម៉ែត្រ ទទឹង៥ម៉ែត្រ សាងសង់ស្ពានឈើបេតុងប្រវែង២៤ម៉ែត្រ ទទឹង៤ម៉ែត្រ ដាក់លូមុខកាត់០,៨០ម៉ែត្រ ស្ថិតក្នុងឃុំយ៉ាទុង ស្រុកអូរយ៉ាដាវ ខេត្តរតនគីរី បម្រើផលប្រយោជន៍ប្រជាពលរដ្ឋប្រមាណ៤៦៧គ្រួសារ ចំណាយថវិកា ៤៤ ៧១៩ដុល្លារអាម៉េរិក។

គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០១៩ មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋានមានសមតុល្យចំនួន៣ ៧១៨ ៥២៥ដុល្លារអាមេរិក នឹងត្រូវយកមកប្រើប្រាស់សម្រាប់អភិវឌ្ឍន៍សហគមន៍ដែលមានប្រតិបត្តិការធនធានរ៉ែទូទាំងប្រទេស។

**មុំទី២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ**

**១- ការកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ**

| តារាងសង្ខេបសមិទ្ធផល | | |
|---|---|---|
| ល.រ | បរិយាយ | ចំនួន |
| ១ | ចំណូលថវិកាជាតិ | ២០,៦លានដុល្លារ |
| ២ | បរិមាណស៊ីម៉ងត៍ដែលត្រូវបានផលិត | ៨,១លានតោន |
| ៣ | បរិមាណត្បូងថ្ម | ៧,២ពាន់តោន |
| ៤ | បរិមាណខ្សាច់ស | ១៥៥ពាន់តោន |
| ៥ | នាំចេញថ្មម៉ាបប្លុក | ៥១ ៩១៦,៥៤ម$^២$ |
| ៦ | នាំចេញថ្មម៉ាបសន្លឹក | ៤ ១៦៣,២២ម$^២$ |
| ៧ | ការអភិវឌ្ឍសហគមន៍ដោយប្រើមូលនិធិទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន | ៥គម្រោង |
| **ប្រភេទអាជ្ញាបណ្ណដែលបានចេញ** | | |
| ១ | អណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម | ២៩អាជ្ញាបណ្ណ |
| ២ | អណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់គោលបំណងឧស្សាហកម្ម | ៤អាជ្ញាបណ្ណ |
| ៣ | លិខិតអនុញ្ញាតបុរេសនា | ៥លិខិត |
| ៤ | លិខិតបញ្ជាក់សំណាកធនធានរ៉ែ | ៤លិខិត |

**២- វិស័យប្រេងកាត**

**២.១- ការអភិវឌ្ឍធនធានប្រេងកាត**

កន្លងមកក្រសួងបានខិតខំអភិវឌ្ឍន៍វិស័យប្រេងកាត ដោយទទួលបានលទ្ធផលការងារមួយចំនួនដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាតត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩
- សម្របសម្រួលការងារគម្រោងប្លុកA ដែលនឹងឈានទៅផលិតប្រេងនៅឆ្នាំ២០២០ខាងមុខ
- បញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពផែនការមេប្រេងបម្រុងយុទ្ធសាស្ត្រឆ្នាំ២០៣០ បញ្ចប់ការរៀបចំគោលការណ៍ណែនាំអំពីសុវត្ថិភាពក្នុងការប្រើប្រាស់និងលក់ឧស្ម័នអ៊ិលភីជី(LPG) និងបញ្ចប់ការចរចានិងចុះកិច្ចព្រមព្រៀងប្រេងកាតប្លុកD ជាមួយក្រុមហ៊ុន Cambodian Resource Energy Development Co.,Ltd
- ចុះពិនិត្យ វាយតម្លៃកម្រិតហានិភ័យស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈបានចំនួន១៧៤ស្ថានីយ ចុះស្រង់ព័ត៌មានទីតាំងស្ថានីយ៍ប្រេងនិងឧស្ម័នឥន្ធនៈក្នុងរាជធានីភ្នំពេញដើម្បីបញ្ចូលក្នុងកម្មវិធី ផែនទីGoogle Map បានចំនួន៥១២ស្ថានីយ៍
- បានចុះសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រប្រេងកាត និងធ្វើរបាយការណ៍បឋមស្តីពីលក្ខណៈភូគព្ភសាស្ត្រទូទៅនិងសក្តានុពលនៃសិលាសែលឬសិលាប្រភពក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប ឆ្នាំ២០១៩

- បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសសិក្សាស្រាវជ្រាវនិងផលិតកម្មប្រេងកាត (Exploration and Production Task Force)របស់ក្រុមប្រឹក្សាប្រេងកាតអាស៊ាន ហៅកាត់ថា ASCOPE កាលពីថ្ងៃទី៣០-៣១ ខែកក្កដា ឆ្នាំ២០១៩ នៅទីក្រុងសៀមរាប

- សិក្ខាសាលាផ្សព្វផ្សាយស្ដីពីបច្ចុប្បន្នភាពនៃវិស័យប្រេងកាតនៅកម្ពុជាចំនួន៤លើក គឺខេត្តបាត់ដំបង សៀមរាប កំពង់ចាម និងខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួម៨៧៥នាក់ សិក្ខាសាលាផ្សព្វផ្សាយជាមួយអង្គការYRDP ចំនួន៧លើក គឺរាជធានីភ្នំពេញ បាត់ដំបង កំពង់ចាម ដែលមានអ្នកចូលរួម១ ២៤៥នាក់ និងរៀបចំសន្និសីទប្រេងនិងឧស្ម័នសម្រាប់ឆ្នាំ២០១៩នៅកម្ពុជារបស់ក្រុមហ៊ុន Gas Academy នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម៥០០នាក់។

## ២.២- ការងារប្រមូលចំណូលមិនមែនសារពើពន្ធ

| ល.រ. | បរិយាយ | សរុប |
|---|---|---|
| ១ | ចំណូលថវិកាជាតិ(លានរៀល) | ៧ ៧៩០,៣៧ |
| ២ | ចំនួនស្ថានីយ៍ប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ | ៣ ៩៩៨ |
| ៣ | ចំនួនវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ | ៨៣ |
| ៤ | ចំនួនលិខិតអនុញ្ញាតដំណើរការស្ថានីយ | ១១៦ |
| ៥ | ចំនួនអាជ្ញាបណ្ណមណ្ឌលសន្និធិប្រេងនិងឧស្ម័នឥន្ធនៈ | ៤ |
| ៦ | ចំនួនអាជ្ញាបណ្ណនាំប្រេងឥន្ធនៈ | ១ |
| ៧ | អាជ្ញាបណ្ណរោងចក្រចម្រាញ់ប្រេងកាត | ១ |

## ៣- ការងារចុះបញ្ជីរោងចក្រ

ក្នុងរយៈពេល១ឆ្នាំនៃការបង្កើតរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា ដោយគិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ មានរោងចក្របង្កើតថ្មីចំនួន**២៧៥**រោងចក្រ។ រោងចក្រដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម(បច្ចុប្បន្នជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ មានចំនួន**១ ៦៨៦**រោងចក្រ ក្នុងនោះរួមមានៈ ផ្នែកផលិតកម្មផលិតអាហារ ភេសជ្ជៈ និងបារី មានចំនួន**១៥៥**រោងចក្រ ផ្នែកវាយនភណ្ឌសម្លៀកបំពាក់ កាបូប និងស្បែកជើងមានចំនួន**១ ០៥០**រោងចក្រ ផ្នែកផលិតកម្មផលិតក្រដាស ផលិតផលពីក្រដាស និងបោះពុម្ពផ្សេងៗ (លើកលែងបោះពុម្ពលើសម្លៀកបំពាក់) មានចំនួន**៥៨**រោងចក្រ ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិកមានចំនួន**១២៩**រោងចក្រ ផ្នែកឧស្សាហកម្មពីរ៉ែអលោហៈមានចំនួន**៤៧**រោងចក្រ ផ្នែកឧស្សាហកម្មកែច្នៃលោហៈមានចំនួន**១៤១**រោងចក្រ ផ្នែកផលិតកម្មផលិតគ្រឿងសង្ហារឹម និងផលិតផលផលិតពីឈើមានចំនួន**៥៣**រោងចក្រ និងផ្នែកផលិតកម្មដទៃទៀតមានចំនួន**៥៣**រោងចក្រ ដែលមានកម្លាំងពលកម្មសរុបចំនួន**១ ០២៧ ៩៤៨**នាក់។ រោងចក្របិទទ្វារឈប់ដំណើរការផលិតកម្មមានចំនួន**៦៧**រោងចក្រ (ផ្នែកវាយនភណ្ឌ សម្លៀកបំពាក់ កាបូប និងស្បែកជើង មានចំនួន៥៣រោងចក្រ) និងប៉ះពាល់ដល់កម្លាំងពលកម្មចំនួន**៦៣,៥០៦**នាក់។

| **ល.រ** | **ប្រភេទរោងចក្រ** | **ចំនួនរោងចក្រ** |
|---|---|---|
| ១ | ផ្នែកផលិតកម្មផលិតអាហារ ភេសជ្ជៈ និងបារី | ១៥៥ |
| ២ | ផ្នែកវាយនភណ្ឌ សម្លៀកបំពាក់ កាបូប និងស្បែកជើង | ១,០៥០ |

| | | |
|---|---|---|
| ៣ | ផ្នែកផលិតកម្មផលិតក្រដាស ផលិតផលពីក្រដាស និងបោះពុម្ពផ្សេងៗ (លើកលែងបោះពុម្ពលើសម្លៀកបំពាក់) | ៥៨ |
| ៤ | ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិក | ១២៩ |
| ៥ | ផ្នែកឧស្សាហកម្មពីរ៉ែអលោហៈ<br>- រោងចក្រផលិតសម្ភារៈសំណង់ និងផលិតផលផលិតពីរ៉ែអលោហៈដទៃទៀត<br>- រោងចក្រផលិតស៊ីម៉ងត៍ | ៤៧<br>៤០<br>០៧ |
| ៦ | ផ្នែកឧស្សាហកម្មកែច្នៃលោហៈ | ១៤១ |
| ៧ | ផ្នែកផលិតកម្មផលិតគ្រឿងសង្ហារឹម និងផលិតផលផលិតពីឈើ | ៥៣ |
| ៨ | ផ្នែកផលិតកម្មដទៃទៀត | ៥៣ |
| **សរុប** | | **១ ៦៨៦** |

- តម្លៃសរុបបរិមាណផលិតផល ក្នុងរយៈពេលមួយឆ្នាំនេះ មានចំនួនប្រមាណ១៦ពាន់លានដុល្លារអាមេរិក (កើនឡើង ១៧% បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន) ក្នុងនោះរួមមានៈ ឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក មានចំនួនប្រមាណ៣.៩៤ពាន់លានដុល្លារអាមេរិក(កើនឡើង១៣%) ឧស្សាហកម្មនាំចេញ(ផលិតផលសម្លៀកបំពាក់ កាបូប និងស្បែកជើង) មានចំនួនប្រមាណ១០.១៤ពាន់លានដុល្លារអាមេរិក(កើនឡើង១៦%) និងឧស្សាហកម្មនាំចេញផ្សេងៗទៀត មានចំនួនប្រមាណ១.៩២ពាន់លានដុល្លារអាមេរិក(កើនឡើង៣៦%)។

- បានត្រួតពិនិត្យសុវត្ថិភាពឡចំហាយ និងគ្រឿងចក្រ-គ្រឿងម៉ាស៊ីនបានចំនួន៦៨៤រោងចក្រនិងបណ្តុះបណ្តាលសុវត្ថិភាពឧស្សាហកម្មបានចំនួន២ ២៥៩នាក់ មកពី៥៦១រោងចក្រ និងបានរៀបចំចងក្រងស្ថិតិនៃការប្រើប្រាស់ឡចំហាយក្នុងឆ្នាំ២០១៨

- បានត្រួតពិនិត្យឯកសារគម្រោងប្លង់បង្ហាញទីតាំង ប្លង់រួម ប្លង់ទីតាំងគ្រឿងម៉ាស៊ីន ក្នុងការស្នើសុំប្រកាសបង្កើតរោងចក្រថ្មី និងកំពុងដំណើរការបានចំនួន១៤៦រោងចក្រ-សិប្បកម្ម

- បានចូលរួមកិច្ចប្រជុំចំនួន៣០លើក រៀបចំដោយគណៈកម្មការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរោងចក្រកាត់ដេរសម្លៀកបំពាក់(OPA)ស្តីពីការស្នើសុំនាំចូលផ្ទាំងអាវចាក់ឡើងវិញរបស់រោងចក្រ

- បានចុះអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពកម្មសិទ្ធិបញ្ញាប្រទេសកូរ៉េ

- បានទទួលសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មសរុបចំនួន១៩១ និងបានផ្តល់ប្រកាសនីយបត្រតក្កកម្មចំនួន៧៩

- បានទទួលសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលដែលមានអត្ថប្រយោជន៍សរុបចំនួន១១ និងបានផ្តល់ជូនចំនួន៣

- បានទទួលសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មសរុបចំនួន ១១០ (ក្នុងស្រុក១២ និងក្រៅស្រុក៩៨) និងបានចុះបញ្ជីគំនូរឧស្សាហកម្មចំនួន៧១ (ក្នុងស្រុក២៩ និងក្រៅស្រុក៤២)

- បានចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោមចំនួន១០ ដែលក្នុងនោះ មន្ទីរពិសោធន៍ចំនួន៤ អង្គភាពអធិការកិច្ចចំនួន៤ និងអង្គភាពចេញវិញ្ញាបនបត្រចំនួន២

- ទទួលពាក្យស្នើសុំវាយតម្លៃទទួលស្គាល់(CABs)ចំនួន៦ រួមមានៈ មន្ទីរពិសោធន៍ធ្វើតេស្តចំនួន៣ មន្ទីរពិសោធន៍ព្យាសកម្មចំនួន១ និងអង្គភាពចេញវិញ្ញាបនបត្រចំនួន២) និងពាក្យស្នើសុំចុះបញ្ជីអង្គភាពវាយតម្លៃអនុលោមចំនួន៣

- រួមសហការជាមួយស្ថាប័នPTB នៃប្រទេសអាល្លឺម៉ង់ រៀបចំទិវាវាយតម្លៃទទួលស្គាល់ពិភពលោក(World Accredita-tion Day) ឆ្នាំ២០១៨

- ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអាស៊ានACCSQ-WG2លើកទី៣៦ របស់ក្រុមការងារផ្នែកវាយតម្លៃទទួលស្គាល់ និងវាយតម្លៃអនុលោមភាព

- រួមសហការជាមួយ BLA-DSS នៃប្រទេសថៃ បានចុះធ្វើConcurrence Assessment ដល់មន្ទីរពិសោធន៍ធ្វើតេស្តនៃក្រុមហ៊ុន SGS (Cambodia) Limited និងមន្ទីរពិសោធន៍ធ្វើតេស្តនៃក្រុមហ៊ុន Modern Testing Services (Cambodia)Ltd.

- សហការជាមួយស្ថាប័ន PTB នៃប្រទេសអាល្លឺម៉ង់ បន្តបើកវគ្គបណ្តុះបណ្តាលពីការពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងគុណភាព (QMS-DA) ដោយផ្ទៀងផ្ទាត់ជាមួយស្តង់ដា ISO/IEC 17011:2017 ជូនដល់មន្ត្រីក្រសួងនិងអ្នកជំនាញនៅក្នុង Assessor & Experts Pool ចំនួន៤លើក

- សហការជាមួយអង្គភាពវាយតម្លៃទទួលស្គាល់ SAC, NATA, JAS-ANZ, BOA, TAF ចុះអង្កេតតាមដាន និងវាយតម្លៃទទួលស្គាល់ជូនមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា(ILCC) នាយកដ្ឋានវិញ្ញាបនបត្រកម្មនៃវិទ្យាស្ថានស្តង់ដាកម្ពុជា, ក្រុមហ៊ុន Bureau Veritas Co.,Ltd, ក្រុមហ៊ុន Intertek Testing Services Co.,Ltd និង Modern Testing Services

- ក្រុមហ៊ុន/សហគ្រាសចំនួន១០ បានចូលរួមអនុវត្តកម្មវិធីពានរង្វាន់ **ស៥** «សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដានិងស្ថិតស្ថេរ» ឆ្នាំ២០១៨ ដែលក្នុងនោះក្រុមហ៊ុន/សហគ្រាសចំនួន០៤ ទទួលបានពានរង្វាន់និងក្រុមហ៊ុន/សហគ្រាសចំនួន០៦ ទទួលបានវិញ្ញាបនបត្រ

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពានរង្វាន់ **ស៥** «សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដានិងស្ថិតស្ថេរ» ដែលមានសិក្ខាកាមចូលរួមសរុប៩៨នាក់ ក្នុងនោះមន្ត្រីក្រសួង១៤នាក់ និងវិស័យឯកជន៨៤នាក់

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រអភិវឌ្ឍន៍ផលិតភាពនៅទីស្តីការក្រសួង(បច្ចុប្បន្នជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) ចំនួន៨វគ្គ មានសិក្ខាកាមចូលរួម ៤៨នាក់ (មន្ត្រីក្រសួង២នាក់ និងវិស័យឯកជន ៤៦នាក់) និងបានរៀបចំតាមបណ្តាខេត្តចំនួន៤ រួមមានខេត្តពោធិ៍សាត់ កំពង់ចាម កំពង់ឆ្នាំង និងខេត្តព្រៃវែង មានសិក្ខាកាម ចូលរួមចំនួន១៣០នាក់ (មន្ត្រីក្រសួង ៤៩នាក់ និងវិស័យឯកជន ៨១នាក់)

- បានសម្របសម្រួលនិងរៀបចំកម្មវិធីនានាក្រោមគម្រោងរបស់អង្គការផលិតភាពអាស៊ី នៅក្នុងប្រទេសបានចំនួន៥គម្រោង មានសិក្ខាកាមចូលរួម២២២នាក់ (មន្ត្រីក្រសួង ១០នាក់ ស្ថាប័នពាក់ព័ន្ធ ២៥នាក់ វិស័យឯកជន ១៦៥នាក់ និងស្ថាប័នផលិតភាពជាតិហ្វីលីពីន ២២នាក់) និងកម្មវិធីក្រៅប្រទេសបានចំនួន ៣៧គម្រោង មានសិក្ខាកាម ចូលរួមចំនួន៥៣នាក់ (មន្ត្រីក្រសួង ១៩នាក់ ស្ថាប័នពាក់ព័ន្ធ ១៥នាក់ និងវិស័យឯកជន ១៩នាក់)។

### ៤- ការខារផលិតទឹកស្អាត

ការផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈនិងឯកជនសរុបចំនួន**៣៤៦ ៩២១ ០១៦ម៣** មានការកើនឡើង**៣៧ ៩៩៨ ២៨២ម៣** ស្មើនឹង**១២,៣០%** បើប្រៀបធៀបជាមួយបរិមាណផលិតឆ្នាំ២០១៨ មានចំនួន**៣០៨ ៩២២ ៧៣៤ម៣** ។ គិតត្រឹមឆ្នាំ២០១៩ ប្រជាជននៅទីប្រជុំជនបានទទួលទឹកស្អាតប្រើប្រាស់ មានចំនួន**៨៩៤ ៧១៨** គ្រួសារ ស្មើនឹង**៤ ៩៨៩ ២៨៨** នាក់(គិតជាមធ្យមមានសមាជិក ៥នាក់ក្នុងមួយគ្រួសារ) គឺស្មើ ៥៦,៣៧% បើធៀបនឹងឆ្នាំ២០១៨ ដែលមានត្រឹមតែ**៨០៥ ១៩០** គ្រួសារ ស្មើនឹង**៤ ៥១៦ ៦៥៣**នាក់ គឺស្មើ **៥១,០៤%**។

ការផលិតនិងចែកចាយទឹកស្អាតពីបណ្តាអង្គភាពរដ្ឋាករទឹកសាធារណៈ រដ្ឋាករទឹកស្វយ័ត ក្រុមហ៊ុន និងអាជីវករទឹកស្អាតឯកជននៅទូទាំងប្រទេស ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

| តារាងទិន្នន័យផលិតកម្មទឹកស្អាត (ឆ្នាំ២០១៨-ឆ្នាំ២០១៩) | |
|---|---|
| បរិយាយ | បរិមាណផលិតទឹកស្អាត (ម៣) |
| -រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ២២១ ៥០៩ ២១៤ ម៣ |
| -រដ្ឋាករទឹកស្វយ័តសៀមរាប | ៦ ៩៧២ ០១០ ម៣ |
| -រដ្ឋាករទឹកសាធារណៈ ១១ | ៣៧ ៣៥១ ៣៥៨ ម៣ |
| -ក្រុមហ៊ុននិងអាជីវករទឹកស្អាតឯកជន | ៨១ ០៨៨ ៤៣៤ ម៣ |
| សរុប | ៣៤៦ ៩២១ ០១៦ ម៣ |

ឆ្លើយតបទៅនឹងគោលនយោបាយរាជរដ្ឋាភិបាលលើការធ្វើវិមជ្ឈការ និងវិសហមជ្ឈការលើវិស័យផ្គត់ផ្គង់ទឹកទៅថ្នាក់ក្រោមជាតិ ស្របតាមគោលដៅសហសវត្សប្រកបដោយចីរភាព ដើម្បីពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង ទីប្រជុំជនឱ្យបាន៩០% ដល់ឆ្នាំ២០២៣ និង១០០% ត្រឹមឆ្នាំ២០២៥ សម្រាប់បម្រើតម្រូវការចាំបាច់របស់ប្រជាជនក៏ដូចជាសម្រាប់ផលិតកម្មនិងសេវាកម្មនានា តាមរយៈការអភិវឌ្ឍពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ទាំងផ្នែកសាធារណៈ និងផ្នែកឯកជនដោយឈរលើបុរេលក្ខខណ្ឌបួនយ៉ាងគឺ ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ ដែលសំដៅធានាទាំងផលប្រយោជន៍គ្រប់ភាគី រួមមានភាគីរដ្ឋាភិបាល ភាគីអ្នកផ្តល់សេវា និងជាពិសេសភាគីប្រជាជន ដោយជួយឧបត្ថមធនដល់ប្រជាជនក្រីក្រ។ ក្រសួង ក៏បានជំរុញការចូលរួមពីវិស័យឯកជនក្នុងការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅឃុំ សង្កាត់ ភូមិ ដែលពុំទាន់មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ទន្ទឹមនឹងនេះ ក៏បានយកចិត្តទុកដាក់បង្កើនការផ្គត់ផ្គង់ទឹកស្អាតតាមគ្រប់មធ្យោបាយផ្សេងៗ សំដៅធានាឲ្យប្រជាជនគ្រប់រូបនៅតាមទីប្រជុំជនបានទទួលទឹកស្អាតប្រើប្រាស់ដោយសុវត្ថិភាព ស្ថិរភាពនៅគ្រប់រដូវកាល។

អនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬគ្រួសារមានចំណូលទាប និងកំពុងរៀបចំកែសម្រួលការបញ្ចុះថ្លៃទឹកស្អាតនិងតភ្ជាប់បណ្តាញទឹកស្អាតជូនកម្មករ កម្មការិនី និងសិស្ស និស្សិត ស្នាក់នៅបន្ទប់ជួលនៅរាជធានីភ្នំពេញ ដោយបានចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួលសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតក្នុងតម្លៃ ៧០០រៀល/ម៣ ហើយម្ចាស់ផ្ទះជួលអាចលក់ជូនក្នុងតម្លៃ ៨០០រៀល/ម៣។

គិតត្រឹមខែសីហា ឆ្នាំ២០១៩ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានធ្វើការផ្គត់ផ្គង់ទឹកស្អាតជូនកម្មករនិយោជិត សិស្ស និស្សិត ស្នាក់នៅតាមផ្ទះជួលនិងបន្ទប់ជួលបានចំនួនសរុប ៩៣ ៤៥៦បន្ទប់។

## ៥- ការងារស្តង់ដា

- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម(បច្ចុប្បន្នជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បាននិងកំពុងពង្រឹងនិងលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចស្តង់ដា ក្នុងការធានាបាននូវគុណភាព បរិមាណ សុវត្ថិភាព សេវាកម្ម បរិស្ថាន និងការប្រើប្រាស់ស្តង់ដានីយកម្ម ដើម្បីប្រែក្លាយការងារស្តង់ដានេះ ឱ្យទៅជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែងទាំងទីផ្សារក្នុងស្រុកនិងបរទេស

- ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យនេះ ក្រសួង ក៏បានធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដាតាមរយៈសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនានា ដែលជាលទ្ធផលសម្រាប់រយៈពេលមួយឆ្នាំនៃការបង្កើតរាជ-រដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បានទទួលលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោមៈ

- រហូតមកដល់បច្ចុប្បន្ននេះ ក្រសួងបានបង្កើតស្តង់ដាសរុបចំនួន**៩២៦** ស្តង់ដា ដែលគិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩ ក្រសួងបានបង្កើតស្តង់ដារចំនួន**៧០** បន្ថែមទៀត ដែលក្នុងនោះមានស្តង់ដាយានយន្តអាម៉េរិក(FMVSS) ចំនួន**៣៩** ស្តង់ដាអន្តរជាតិផ្នែកប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ(ISO22000:2018 និងISO/TR 22002-1:2009)ចំនួន**២** ស្តង់ដារអន្តរជាតិ(ISO) ផ្នែកផលិតផលពីកៅស៊ូចំនួន**៥** ស្តង់ដាអន្តរជាតិ (ISO) ផ្នែកសារធាតុនិងផលិតផលគីមីចំនួន៤ ស្តង់ដាអន្តរជាតិ(IEC)សម្រាប់បរិក្ខារអគ្គិសនីប្រើប្រាស់ក្នុងលំនៅឋានចំនួន**១៩** ស្តង់ដាយានយន្ត (UNCB Regulation R28)ចំនួន**១**

- ការរៀបចំប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ទៅលើគុណភាពនិងសុវត្ថិភាពផលិតផល និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងរោងចក្រ សហគ្រាសធុនតូចនិងមធ្យម ឱ្យស្របទៅតាមស្តង់ដាជាតិ ស្តង់ដាតំបន់ និងអន្តរជាតិ ទទួលបានលទ្ធផល រួមមាន វិញ្ញាបនបត្របញ្ជាក់ផលិតផល**៤៨** អាជ្ញាបណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផលបានចំនួន**៥៤**អាជ្ញាបណ្ណ និងវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងគុណភាព និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចំនួន**៦**

- បានចេញទិដ្ឋាការចុះបញ្ជីបញ្ជាក់ការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធចំនួន**៧** បានផ្តល់អាជ្ញាបណ្ណប្រើសញ្ញាសុវត្ថិភាពសម្រាប់ផលិតផលអគ្គិសនីនិងអេឡិចត្រូនិកចំនួន**៥៥១** អាជ្ញាបណ្ណ

- ផ្តល់បណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល(ចបផ) ចំនួន**៨៣០** អាជ្ញាបណ្ណ បានចេញលិខិតបញ្ជាក់មុខសញ្ញានិងស្តង់ដាប្រើប្រាស់សារធាតុគីមីចំនួន**៥៧៩** លិខិតនិងចេញលិខិតបញ្ជាក់មុខសញ្ញាប្រើប្រាស់សារធាតុគីមីជាប់បញ្ញត្តិចំនួន**១៧៣** លិខិត

- មន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា បានទទួលធ្វើតេស្តវិភាគគំរូផលិតផលចំនួន**៨ ៤៤៦**គំរូផលិតផល (កើនឡើងចំនួន**១ ៤២១**គំរូផលិតផល ប្រៀបធៀបជាមួយឆ្នាំ២០១៨ ដែលមានចំនួន**៧ ០២៥**គំរូផលិតផល) ទាំងផ្នែកគីមីសាស្ត្រ និងមីក្រូជីវសាស្ត្រ។ មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា មានសមត្ថភាពធ្វើតេស្តរហូតដល់**១៤៥**ប៉ារ៉ាម៉ែត្រ ដោយក្នុងនោះ មានប៉ារ៉ាម៉ែត្រចំនួន**៥៤** ត្រូវបានទទួលការវាយតម្លៃទទួលស្គាល់ជាអន្តរជាតិ អនុលោមតាមស្តង់ដាISO/IEC 17025។

## ៦- ការងារមាត្រាសាស្ត្រ

- ការងារមាត្រាសាស្ត្រ ជាសេវាកម្មគាំទ្រនិងបំពេញឱ្យគ្នាទៅវិញទៅមកជាមួយវិស័យជំនាញដទៃទៀតរបស់ក្រសួង និងកំពុងដើរតួនាទីសំខាន់ក្នុងការរួមចំណែកធ្វើឱ្យមានសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្ម សុខភាព សុវត្ថិភាព និងបរិស្ថានធុរកិច្ច។ ក្នុងឆ្នាំកន្លងទៅ ការងារមាត្រាសាស្ត្របានពង្រីកវិសាលភាពនៃការពិនិត្យផ្ទៀងផ្ទាត់ ព្យាសកម្ម ធ្វើតេស្តវិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្មនិងសេវាកម្ម ដោយទទួលលទ្ធផលមានៈ

- ព្យាសកម្មឧបករណ៍មាត្រាសាស្ត្រដល់ចំនួន១ ០១០គ្រឿង ដែលឆ្នាំ២០១៨ សម្រេចបានត្រឹមចំនួន ៦៤៦ គ្រឿងប៉ុណ្ណោះ

- ត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងតោនបានចំនួន១៦១គ្រឿង ដែលបញ្ហានេះក៏មានការពាក់ព័ន្ធដល់ការធ្វើអាជីវកម្មទិញ-លក់ផលិតផលកសិកម្មរបស់ប្រជាជនយើង

- ចុះបញ្ជីមាត្រាសាស្ត្រថ្មីបានចំនួន២៥១ មូលដ្ឋាន និងបន្តវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្របានចំនួន ២៩៤មូលដ្ឋាន(សរុបចំនួន៥៤៥មូលដ្ឋាន)

- ផ្តល់អាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាបានចំនួន១ អាជ្ញាបណ្ណ និងបានចេញអាជ្ញាបណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រជូនក្រុមហ៊ុនបានចំនួន២(អាជ្ញាបណ្ណថ្មីចំនួន១ និងបន្តអាជ្ញាបណ្ណចំនួន១)

- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត(បច្ចុប្បន្នជាមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) បានបង្កើនការអនុវត្តភារកិច្ចពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្របានច្រើនជាងមុន ដោយកើនពី ១៨ ៤២៨ ក្នុងឆ្នាំ២០១៨ ដល់ចំនួន២៥ ៦៧០ លើឧបករណ៍វង្វាស់វង្វាល់នៅឆ្នាំ២០១៩ ជាពិសេសលើដៃបាញ់ប្រេងតាមស្ថានីយប្រេង ដែលមានចំនួនដល់ទៅ២៤ ៤៧៩។ ក្រៅពីនេះ នៅតាមផ្សារ ទីប្រជុំជនធំៗ មន្ទីរបានដាក់ឱ្យប្រើប្រាស់នូវជញ្ជីងយុត្តិធម៌ ដែលជួយដល់ការពង្រឹងភាពត្រឹមត្រូវសម្រាប់អាជីវកម្មទិញលក់ទំនិញ និងអតិថិជននៅលើទីផ្សារ

ក្រៅពីការងារខាងលើ ក្រសួង ក៏បានយកចិត្តទុកដាក់ផងដែរ លើការពង្រឹងនិងជំរុញការងារកិច្ចសហប្រតិបត្តិការទាំងទ្វេភាគី ក្នុងតំបន់និងសកល ក្នុងការជួយអភិវឌ្ឍវិស័យមាត្រាសាស្ត្រតាមរយៈជំនួយបច្ចេកទេស និងធនធានមនុស្ស ដែលជាលទ្ធផល វិទ្យាស្ថានមាត្រាសាស្ត្រជាតិចិន (NIM, China) បានប្រគល់ឧបករណ៍ស្តង់ដា មាត្រាសាស្ត្រចំនួន៥មុខ ជាជំនួយឥតសំណងក្នុងទំហំទឹកប្រាក់សរុបចំនួន៩០៩ ០០០យ័ន មានដូចជា AC Tester, Electricity Meters, Three-phase Portable Reference Standard Meter Class 0.02, Calibrator for Calibration of Digital Multi-meter (DMM), និង Calibrator (Three-phase Reference Standard Meter Class 0.01)

- ចុះហត្ថលេខាលើប្រកាសរួម ស្តីពីការបង្កើនកិច្ចសហប្រតិបត្តិការមាត្រាសាស្ត្ររវាងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នរដ្ឋសម្រាប់បទប្បញ្ញត្តិទីផ្សារនៃសាធារណៈរដ្ឋប្រជាមានិតចិន នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

- ចូលជាសមាជិកពេញសិទ្ធិរបស់អង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ(OIML)ជាសមាជិកពេញសិទ្ធិរបស់អង្គការកម្មវិធីមាត្រាសាស្ត្រតំបន់អាស៊ីប៉ាស៊ីហ្វិច(APMP) និងជាសមាជិកពេញសិទ្ធិរបស់អង្គការវេទិកានីត្យានុកូលមាត្រាសាស្ត្រតំបន់អាស៊ីប៉ាស៊ីហ្វិច (APLMF)

- បាននិងកំពុងអនុវត្តន៍គម្រោងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) ស្តីពីពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ (NQI) នៃព្រះរាជាណាចក្រកម្ពុជា ក្នុងទំហំទឹកប្រាក់០.៨ លានអឺរ៉ូ

## ៧- ស្ថានភាពគម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ

| ស្ថានភាពគម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍសម្រាប់ឆមាសទី១ ឆ្នាំ២០១៩<br>សរុបមានចំនួន៤៦គម្រោង(កំពុងអនុវត្ត៤៤គម្រោងនិងផ្អាកសកម្មភាព២គម្រោង | | | |
|---|---|---|---|
| អគ្គនាយកដ្ឋាន | គម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ | កំពុងអនុវត្ត | ផ្អាកសកម្មភាព |
| អគ្គនាយកដ្ឋានឧស្សាហកម្ម | សហប្រតិបត្តិការជាមួយ WIPO,EPOS, JPO/JRTRO, CNIPA,USA,LMEC&PRC,JICA, (ASAEAN,SCIC, | ១៩ | |

| | | | |
|---|---|---|---|
| | JCIA&ACC),រាជរដ្ឋាភិបាលកម្ពុជា-ASEAN,CATTC& PRC,ROK,MOP | | |
| អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម | ១- គម្រោងសហប្រតិបត្តិការជាមួយGIZ (២០១៨-២០២១)ចំនួន១គម្រោងមានថវិកាចំនួន៣លានអឺរ៉ូ ២-គម្រោងសហប្រតិបត្តិការជាមួយGIZ (២០១៩-២០២១) ចំនួន១គម្រោងមានថវិកាចំនួន៣លានអឺរ៉ូ ៣- គម្រោងសហប្រតិបត្តិការជាមួយGIZ (២០១៩-២០២៣)ចំនួន១គម្រោងមានថវិកាចំនួន៩,៣៥លានអឺរ៉ូ ៤- គម្រោងសហប្រតិបត្តិការជាមួយNOMI Network Cambodia (២០១៩-២០២១)ចំនួន១គម្រោងមានថវិកាចំនួន៤០៧ ៥៩០ដុល្លារអាម៉េរិក និងគម្រោងសហប្រតិបត្តិការ៥ផ្សេងទៀតជាមួយ UNICEF, GIZ, កូរ៉េខាងត្បូង, GGGI,iBan,IFC។ | ១០ | |
| | គម្រោងសហប្រតិបត្តិការជាមួយADB ចំនួន២គម្រោង | | ២ |
| អគ្គនាយកដ្ឋានទឹកស្អាត | ១- គម្រោងសហប្រតិបត្តិការជាមួយADB (២០១៤-២០១៩)ចំនួន១គម្រោង មានថវិកាចំនួន៣៧ ៤០០ ០០០ដុល្លារអាម៉េរិក ២- គម្រោងសហប្រតិបត្តិការជាមួយ ADB (២០១៨-២០២២)ចំនួន១គម្រោង មានថវិកាចំនួន ១១៩,១៧ដុល្លារអាម៉េរិក ៣- គម្រោងសហប្រតិបត្តិការជាមួយ JICA (២០១៨-២០២២)ចំនួន១គម្រោង មានថវិកាចំនួន៦៥០ ០០០ដុល្លារអាម៉េរិក ៤- គម្រោងសហប្រតិបត្តិការជាមួយJICA (ខេត្តពោធិ៍សាត់) ចំនួន១គម្រោង ចុងឆ្នាំ២០១៩ ទើបរាជរដ្ឋាភិបាលជប៉ុនផ្តល់ហិរញ្ញប្បទាន ៥-គម្រោងកម្មវិធីវិនិយោគហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត(3i) ចំនួន១គម្រោង ជំនួយឥតសំណង (២០១៥-២០២០) ៦-គម្រោងសហប្រតិបត្តិការជាមួយ JICS ចំនួន១គម្រោង មានថវិកាចំនួន៣ ២៧១ ០០០យ៉េន ៧-គម្រោងសហប្រតិបត្តិការជាមួយWorld Bank និង RGC (២០១៩-២០២៤)ចំនួន១គម្រោង មានថវិកាចំនួន ៣២ ០០០ ០០០ដុល្លារអាម៉េរិក | ៧ | |
| វិទ្យាស្ថានស្តង់ដាកម្ពុជា | គម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ CNRIFFI Phase II | ១ | |
| មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ១- គម្រោងសហប្រតិបត្តិការជាមួយPTB (២០១៨-២០២០)ចំនួន១គម្រោង ២- គម្រោងសហប្រតិបត្តិការជាមួយKATS ចំនួន១គម្រោង ៣- គម្រោងសហប្រតិបត្តិការ | ៧ | |

| | | | |
|---|---|---|---|
| | ជាមួយចិនNIM and NMC (២០១៦-២០២១)ចំនួន១គម្រោង ៤- គម្រោងសហប្រតិបត្តិការជាមួយNMC and PTB (២០១៨-២០២១)ចំនួន១គម្រោងមានថវិកាចំនួន ០,៨លានអឺរ៉ូ ៥- គម្រោងសហប្រតិបត្តិការជាមួយNIM and GXQTS (២០១៧-២០២២)ចំនួន១គម្រោងជាជំនួយឥតសំណង និងគម្រោងសហប្រតិបត្តិការក្នុងតំបន់ចំនួនពីរគម្រោង(វគ្គបណ្តុះបណ្តាល) គឺគម្រោងMEDEA (ឧបត្ថម្ភដោយ PTB)របស់អង្គការ APMP និង APLMF | | |

## ៨- ការជំរុញវិស័យទេសចរណ៍និងផ្នែកសេវាកម្សាន្ត

### ៨.១- ផ្នែកសេវាកម្សាន្ត

សម្រាប់ឆ្នាំ២០១៨ ក្រសួងទេសចរណ៍បានផ្តល់អាជ្ញាបណ្ណទេសចរណ៍ថ្មី និងបន្តសរុប ៣ ១៥១ អាជ្ញាបណ្ណ ក្នុងនោះសណ្ឋាគារថ្មីចំនួន៦០ សណ្ឋាគារបន្តមាន៤៣៣ សរុបដំណើរការចំនួន៤៧០ មានបន្ទប់ ៣៧ ១១៥ បិទចំនួន៧ និងពិន័យ១២។ ផ្ទះសំណាក់ថ្មីចំនួន ១១ និងផ្ទះសំណាក់បន្ត ៣៩៥ សរុបដំណើរការ ៣៧៩ មានបន្ទប់ចំនួន៩ ៨២៣ បិទចំនួន២ និងពិន័យ ២។ អាហារដ្ឋាន និងភោជនីយដ្ឋានថ្មីមានចំនួន៩០ ៩១ និងអាហារដ្ឋាន និងភោជនីយដ្ឋានបន្តមាន ៣៦៥ សរុបដំណើរការ៤៦១ បិទចំនួន២ ពិន័យ៧។ ម៉ាស្សាថ្មីមានចំនួន ១៩ និងម៉ាស្សាបន្តមាន៥៦ សរុបដំណើរការ ចំនួន៦៤ និងពិន័យ១។ សេវាកម្សាន្តទេសចរណ៍បន្តមាន ៥ សរុបដំណើការ៥។ ក្រុមហ៊ុនដឹកជញ្ជូនភ្ញៀវទេសចរណ៍ ថ្មីមាន៧ និងក្រុមហ៊ុនដឹកជញ្ជូនភ្ញៀវទេសចរណ៍បន្តមាន២៥ សរុបដំណើរការ៣២។ មគ្គុទ្ទេសក៍ទេសចរណ៍ថ្មីមាន ៤៥៦នាក់ និងមគ្គុទ្ទេសក៍ទេសចរណ៍បន្តមាន ១ ២៨៤នាក់ សរុបដំណើរការ១ ៧៤០នាក់។

សម្រាប់ឆ្នាំ២០១៩ ក្រសួងទេសចរណ៍បានផ្តល់អាជ្ញាបណ្ណថ្មី និងបន្តសរុបចំនួន១ ៥៦៨អាជ្ញាបណ្ណ ក្នុងនោះ សណ្ឋាគារថ្មីមាន១០៣ និងសណ្ឋាគារបន្តមាន៤៥៤ សរុបដំណើរការ៥៥៧ មានបន្ទប់ចំនួន៤១ ២៨៦ និងពិន័យ១៧។ ផ្ទះសំណាក់ថ្មីមាន២៧ និងផ្ទះសំណាក់បន្តមាន៣៤៤ សរុបដំណើរការ៣៧១ មានបន្ទប់៩ ៦២៨។ ភោជនីយដ្ឋាន និងអាហារដ្ឋានថ្មីមាន៧៨ និងអាហារដ្ឋាន និងភោជនីយដ្ឋានបន្តមាន ៤៣២ សរុបដំណើរការ ៥១០ និងពិន័យ៦។ ម៉ាស្សាថ្មីមាន៣៤ និងម៉ាស្សាបន្តមាន៩១ សរុបដំណើរការ១២៥។

| **ស្ថិតិអាជីវកម្មទេសចរណ៍ឆ្នាំ២០១៩** | | | | |
|---|---|---|---|---|
| ល.រ | ប្រភេទអាជីវកម្ម | ចំនួនអាជីវកម្មថ្មី | ចំនួនអាជីវកម្មបន្ត | សរុប |
| ១ | សណ្ឋាគារ | ១០៣ | ៤៥៤ | ៥៥៨ |
| ២ | ផ្ទះសំណាក់ | ២៧ | ៣៤៤ | ៣៧១ |
| ៣ | ភោជនីយដ្ឋាន និងអាហារដ្ឋាន | ៧៨ | ៤៣២ | ៥១០ |
| ៤ | ម៉ាស្សា | ៣៤ | ៩១ | ១២៥ |
| | សរុប | ២៤២ | ១ ៣២៦ | ១ ៥៦៨ |

**- ស្ថិតិសណ្ឋាគារមានចំណាត់ថ្នាក់**

ចាប់ពីផ្តើមអនុវត្តមកដល់ខែធ្នូ ឆ្នាំ២០១៩ សណ្ឋាគារមានចំណាត់ថ្នាក់ផ្កាយសរុប១៦០ ក្នុងនោះ ផ្កាយ៥ មាន ៣៧ ផ្កាយ៤មានចំនួន៣៩ ផ្កាយ៣ មាន៣៦ ផ្កាយ២ មាន១៧ និងផ្កាយ១ មាន៣១។ សណ្ឋាគារដែលស្នើសុំចំណាត់ថ្នាក់ ផ្កាយថ្មី និងបន្តសរុបមាន ៧២ ក្នុងនោះមានផ្កាយ៥ថ្មីចំនួន ៦ និងបន្តមាន ១៦ ផ្កាយ៤ថ្មី មាន៤ និងបន្តមាន១០ ផ្កាយ៣ថ្មីមាន៦ និងបន្តមាន ១៦ ផ្កាយ២ថ្មីមាន៤ និងបន្តមាន៣ និងផ្កាយ១ថ្មីមាន១៣ និងបន្តមាន២។

| **តារាងសណ្ឋាគារដែលស្នើសុំចំណាត់ថ្នាក់ផ្កាយថ្មី និងបន្ត** | | | | |
|---|---|---|---|---|
| ល.រ | ចំណាត់ថ្នាក់សណ្ឋាគារ | ថ្មី | បន្ត | សរុប |
| ១ | សណ្ឋាគារផ្កាយ៥ | ៦ | ១៦ | ២២ |
| ២ | សណ្ឋាគារផ្កាយ៤ | ៤ | ១០ | ១៤ |
| ៣ | សណ្ឋាគារផ្កាយ៣ | ៦ | ៨ | ១៤ |
| ៤ | សណ្ឋាគារផ្កាយ២ | ៤ | ៣ | ៧ |
| ៥ | សណ្ឋាគារផ្កាយ១ | ១៣ | ២ | ១៥ |
| | សរុប | ៣៣ | ៣៩ | ៧២ |

គិតត្រឹមខែធ្នូ ឆ្នាំ២០១៩នេះ មគ្គុទ្ទេសក៍ទេសចរណ៍សរុបមាន ៦ ៣៣៦ នាក់ ក្នុងនោះ៖

- មគ្គុទ្ទេសក៍ទេសចរណ៍តំបន់រាជធានីភ្នំពេញមាន ១ ០៩៩នាក់(ភាសាចិន២៥៤នាក់ អង់គ្លេស ៣៧៣នាក់ អង់គ្លេស-អេស្ប៉ាញ១នាក់ បារាំង១៤១នាក់ បារាំង-ថៃ១នាក់ អាល្លឺម៉ង់៥៤នាក់ អ៊ីតាលី១៣នាក់ ជប៉ុន៨៧នាក់ កូរ៉េ១២នាក់ ម៉ាឡេស៊ី១០នាក់ អេស្ប៉ាញ៣០នាក់ ថៃ១៥នាក់ វៀតណាម៨១នាក់)

- មគ្គុទ្ទេសក៍ទេសចរណ៍តំបន់សៀមរាបមាន៥ ១៨៦នាក់(ភាសាចិន១ ១៩១នាក់ អង់គ្លេស ១ ៦៥៩ នាក់ បារាំង៣១៤នាក់ បារាំង-អង់គ្លេស៤នាក់ អាល្លឺម៉ង់១១២នាក់ អ៊ីតាលី២៩នាក់ ជប៉ុន៨៣៣នាក់ កូរ៉េ២៥៧នាក់ ម៉ាឡេស៊ី៥នាក់ រុស្ស៊ី៨១នាក់ អេស្ប៉ាញ១៤៩នាក់ ថៃ-អង់គ្លេស១នាក់ វៀតណាម១២២នាក់)

- មគ្គុទ្ទេសក៍ទេសចរណ៍តំបន់ឆ្នេរសមុទ្រមាន៥១នាក់(ភាសាចិន៥នាក់ អង់គ្លេស៣៣នាក់ ថៃ ១នាក់ វៀតណាម១២នាក់)។

| ល.រ | មគ្គុទ្ទេសក៍ទេសចរណ៍ភាសា | តំបន់ភ្នំពេញ | តំបន់សៀមរាប | តំបន់ឆ្នេរសមុទ្រ | សរុប(នាក់) |
|---|---|---|---|---|---|
| ១ | ចិន | ២៥៤ | ១ ១៩១ | ៥ | ១ ៤៥០ |
| ២ | អង់គ្លេស | ៣៧៣ | ១ ៦៥៩ | ៣៣ | ២ ០៦៥ |
| ៣ | បារាំង | ១៤១ | ៣១៤ | ០ | ៤៥៥ |
| ៤ | អាល្លឺម៉ង់ | ៥៤ | ១១២ | ០ | ១៦៦ |
| ៥ | អ៊ីតាលី | ១៣ | ២៩ | ០ | ៤២ |
| ៦ | ជប៉ុន | ៨៧ | ៨៣៣ | ០ | ៩២០ |
| ៧ | កូរ៉េ | ១២ | ២៥៧ | ០ | ២៦៩ |
| ៨ | រុស្ស៊ី | ២៧ | ៨១ | ០ | ១០៨ |
| ៩ | អេស្ប៉ាញ | ៣០ | ១៤៩ | ០ | ១៧៩ |
| ១០ | ម៉ាឡេស៊ី | ១០ | ៥ | ០ | ១៥ |
| ១១ | ថៃ | ១៥ | ៤២៩ | ១ | ៤៤៥ |
| ១២ | វៀតណាម | ៨១ | ១២២ | ១២ | ២១៥ |
| ១៣ | បារាំង-អង់គ្លេស | ០ | ៤ | ០ | ៤ |
| ១៤ | បារាំង-ថៃ | ១ | ០ | ០ | ១ |

| | | | | | |
|---|---|---|---|---|---|
| ១៥ | អង់គ្លេស-អេស្ប៉ាញ | ១ | ០ | ០ | ១ |
| ១៦ | ថៃ-អង់គ្លេស | ០ | ១ | ០ | ១ |
| | សរុប | ១ ០៩៩ | ៥ ១៨៦ | ៥១ | ៦ ៣៣៦ |

- ក្នុងចំនួនមគ្គុទ្ទេសក៍ទេសចរណ៍សរុបខាងលើ គិតត្រឹមខែធ្នូឆ្នាំ២០១៩ កម្ពុជាមានមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិចំនួន១៦៩នាក់ (ភាសាចិន១៦នាក់ អង់គ្លេស៥៨នាក់ បារាំង៤០នាក់ អាល្លឺម៉ង់៦នាក់ អ៊ីតាលី៤នាក់ ជប៉ុន២៤នាក់ កូរ៉េ២នាក់ រុស្ស៊ី៣នាក់ អេស្ប៉ាញ៤នាក់ ថៃ៥នាក់ វៀតណាម៧នាក់)

- ក្រសួងទេសចរណ៍បានធ្វើបច្ចុប្បន្នភាពស្ថិតិមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ក្រោយធ្វើប្រតិភូកម្មដែលអាជីវកម្មទូទាំងប្រទេសមានចំនួន១១៧២។

**៨.២- ផ្នែកកិច្ចសហប្រតិបត្តិការ និងឃោសនាផ្សព្វផ្សាយទេសចរណ៍**

- ឆ្នាំ២០១៨ កម្ពុជាទទួលបានរង្វាន់ស្តង់ដាទេសចរណ៍អាស៊ានចំនួន១៥ រង្វាន់ទីក្រុងទេសចរណ៍ស្អាត អាស៊ានចំនួន៣ (១.ទីក្រុងបាត់ដំបង ២.កែប ៣.សៀមរាប) រង្វាន់សណ្ឋាគារបៃតងអាស៊ានចំនួន៥ (សណ្ឋាគាររីសតថ្ងៃបាំងឆត្រ ២.ភូមិបៃតងឋានសួគ៌ធម្មជាតិ ៣.សណ្ឋាគារ រីសត *Sokhalay Angkor* ៤-សណ្ឋាគារ រីសត និងភោជនីដ្ឋាន *Nataya Round House Coral Bay* ៥.សណ្ឋាគារ *Villa Lang Ka Boutique)* រង្វាន់បន្ទប់ប្រជុំអាស៊ាន(ប្រភេទក្នុងសណ្ឋាគារ)ចំនួន៥ (១-សណ្ឋាគារ រីសត *Sokha* សៀមរាប និង *Convention Centre* ២-សណ្ឋាគារ *Garden City* ៣-សណ្ឋាគារ រីសត *Sokhalay* និង *Spa* ៤-សណ្ឋាគារ *Sofitel ANGKOR Phukettra* និង៥-សណ្ឋាគារ រីសត *Apsara Palace)* និងរង្វាន់ទេសចរណ៍ប្រកបដោយ និរន្តរភាពអាស៊ានចំនួន២ (១.វត្តភ្នំ ភ្នំពេញ ២.កសិទេសចរណ៍ចំការម្រេច កែប)។

- ឆ្នាំ២០១៩ កម្ពុជាទទួលបានរង្វាន់ស្តង់ដាទេសចរណ៍អាស៊ានចំនួន១៨៖ រង្វាន់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ស្តង់ដាអាស៊ានចំនួន៣ (១-សហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង ខេត្តកោះកុង ២-សហគមន៍អេកូទេសចរណ៍បន្ទាយឆ្មារ ៣-សហគមន៍អេកូទេសចរណ៍កំពង់ភ្លុក) រង្វាន់ផ្ទះស្នាក់ស្តង់ដា អាស៊ានចំនួន៥ (១-ផ្ទះស្នាក់បាណាណាក្នុងសហគមន៍ទេសចរណ៍រុនតាឯក ខេត្តសៀមរាប ២-ផ្ទះស្នាក់តាំង ធិន ក្នុងសហគមន៍ ទេសចរណ៍ជីផាត ខេត្តកោះកុង ៣-ផ្ទះស្នាក់ខឿន ស្រីមុំ ក្នុងសហគមន៍ទេសចរណ៍បន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ៤-ផ្ទះស្នាក់ ទន់ សារិន ក្នុងសហគមន៍ទេសចរណ៍កំពង់ឃ្លាំង ខេត្តសៀមរាប ៥-ផ្ទះស្នាក់ឥសាន្តបុរីក្នុងសហគមន៍ ទេសចរណ៍សំបូរព្រៃគុក ខេត្តកំពង់ធំ) រង្វាន់សេវាស្ប៉ាស្តង់ដាអាស៊ានចំនួន៥ (១-សេវាស្ប៉ា *So SPA with L'OCCITANCE* ២-សេវាស្ប៉ា *Spa Temple* ៣-សេវាស្ប៉ា *Sunnaline* ៤-សេវាស្ប៉ា *Jasmin SPA* ៥-សេវាស្ប៉ា *SPA at NAGA World)* រង្វាន់បង្គន់អនាម័យសាធារណៈស្តង់ដាអាស៊ាន ចំនួន៥ (១-បង្គន់អនាម័យសាធារណៈ សួនច្បារ សម្តេចក្រឡាហោម ស ខេង ២-បង្គន់អនាម័យ សាធារណៈសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ៣-បង្គន់អនាម័យ សាធារណៈគ្រឹះស្ថានអង្គរ ៤-បង្គន់ អនាម័យសាធារណៈព្រះនាងប្រាជ្ញាបារមីតា ៥-បង្គន់អនាម័យសាធារណៈមណ្ឌល ព័ត៌មានទេសចរណ៍)។

- សម្រាប់ឆ្នាំ២០១៨ កម្ពុជាបានចូលរួមព្រឹត្តិការណ៍តាំងពិព័រណ៍ទេសចរណ៍អន្តរជាតិនៅតាមទីផ្សារទេសចរណ៍ អាទិភាពសំខាន់ៗចំនួន២៨លើក រួមមានទីផ្សារអាស៊ានចំនួន៨លើក ទីផ្សារចិនចំនួន៧លើក ទីផ្សារអឺរ៉ុបចំនួន៦លើក ទីផ្សារជប៉ុនចំនួន២លើក ទីផ្សារកូរ៉េចំនួន១លើក ទីផ្សាររុស្ស៊ីចំនួន១លើក ទីផ្សារអាមេរិកចំនួន១លើក និងទីផ្សារឥណ្ឌាចំនួន២លើក។

- បានតែងតាំងស្ថានតំណាងទេសចរណ៍កម្ពុជានៅក្រៅប្រទេសចំនួន១១ក្រុមហ៊ុន ស្ម័គ្រចិត្តនៅលើទីផ្សារអាទិភាពចំនួន១២ប្រទេស ទីផ្សារចិនចំនួន២ក្រុមហ៊ុន (នៅទីក្រុងប៉េកាំង ក្វាងចូវ និងទីក្រុងស៊ិនជិន) ទីផ្សារជប៉ុន ចំនួន១ក្រុមហ៊ុន ទីផ្សាររុស្ស៊ីចំនួន១ក្រុមហ៊ុន ទីផ្សារឥណ្ឌា និងស្រីលង្កាចំនួន១ក្រុមហ៊ុន ទីផ្សារមជ្ឈិមបូព៌ាចំនួន១ ក្រុមហ៊ុន ទីផ្សារកូរ៉េចំនួន១ក្រុមហ៊ុន ទីផ្សារអាម៉េរិកចំនួន១ក្រុមហ៊ុន ទីផ្សារអឺរ៉ុប ហុងគ្រី ប៉ូឡូញ អូទ្រីសចំនួន១ ក្រុមហ៊ុន ទីផ្សារអឺរ៉ុប អ៊ីតាលីចំនួន១ក្រុមហ៊ុន ។

- សហការជាមួយក្រុមហ៊ុន *Tourist Master* ដើម្បីដាក់ព័ត៌មានទេសចរណ៍រូបភាពនិងវីដេអូក្នុងគេហទំព័រ *www.tourismaster.asia* ដើម្បីផ្សព្វផ្សាយទៅកាន់ទូទាំងពិភពលោក។

- បានផលិត *App* ឈ្មោះ *Cambodia Kingdom of Wonder* ដែលមានព័ត៌មានទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន និងការដឹកជញ្ជូន។

## ៩- ផ្នែកជំរុញការលើកកម្ពស់ជំនាញវិជ្ជាជីវៈទេសចរណ៍

ក្នុងឆ្នាំ២០១៨ ក្រសួងទេសចរណ៍បានអភិវឌ្ឍធនធានមនុស្ស ជាពិសេសផ្នែកជំនាញក្នុងវិស័យរបស់ខ្លួនតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

-វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍និងបដិសណ្ឋារកិច្ចចំនួន១៩វគ្គ នៅខេត្តកោះកុង ស្ទឹងត្រែង រតនគិរី កោះកុង សៀមរាប កំពង់ឆ្នាំង កំពង់ចាម មណ្ឌលគិរី ក្រចេះ និងរាជធានីភ្នំពេញ ដែលមានសិក្ខាកាមចូលរួមចំនួន៨១០នាក់ ដែលក្នុងនោះមានគ្រូបង្គោល ចំនួន១៣០នាក់

- វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ចំនួន៩វគ្គ នៅតាមបណ្តាសហគមន៍ទេសចរណ៍ ខេត្តមណ្ឌលគិរី ពោធិ៍សាត់ បាត់ដំបង កំពង់ធំ ឧត្តរមានជ័យ កោះកុង និងខេត្តកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ២៣០នាក់

- បានរៀបចំបង្កើតបណ្តាញអ្នកជំនាញនិងសាស្ត្រាចារ្យក្នុងវិស័យទេសចរណ៍ ដែលមានសមាជិកបណ្តាញសរុបចំនួន៤០នាក់។

## ១០- ភ្ញៀវទេសចរជាតិនិងអន្តរជាតិ

- ពលរដ្ឋខ្មែរធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជាមាន**២ ១៩៣ ៥៥៨នាក់** បើធៀបនឹងឆ្នាំមុន**១ ៩៨៥ ៨៥៤នាក់** កើនឡើង**២០៧ ៧០៤នាក់** ស្មើនឹង**១០,៤៥%**

- ភ្ញៀវទេសចរអន្តរជាតិ ចូលមកព្រះរាជាណាចក្រកម្ពុជា មាន**៦ ២៩៥ ០៦២នាក់** បើធៀបនឹងឆ្នាំមុន **៥ ៩០០ ២៨៤នាក់** កើនឡើង**៣៩៤ ៧៧៨នាក់** ស្មើនឹង**៦,៦៩%** មាន**២៤៦សញ្ជាតិ** នាំមុខគេជនជាតិចិន វៀតណាម ថៃ ឡាវ កូរ៉េខាងត្បូង អាម៉េរិក ជប៉ុន ម៉ាឡេស៊ី បារាំង និងអង់គ្លេស។

## ១១- ចំណូលទិដ្ឋាការ

ចំណូលទិដ្ឋាការសរុបនៅតាមច្រកទ្វារអន្តរជាតិនិងច្រកទ្វារព្រំដែនអន្តរជាតិប្រចាំឆ្នាំ២០១៨ មាន **៧៧ ៥១៧ ៨៧៥ដុល្លារអាម៉េរិក** បើធៀបនឹងឆ្នាំមុន **៦៥ ៩៤១ ៩៩៥ដុល្លារអាមេរិក** កើនឡើង **១១ ៥៧៥ ៨៨០ ដុល្លារអាមេរិក** ស្មើនឹង **១៧,៥៥%**។

ចំណូលទិដ្ឋាការសរុបនៅតាមច្រកទ្វារអន្តរជាតិនិងច្រកទ្វារព្រំដែនអន្តរជាតិប្រចាំឆ្នាំ២០១៩ មាន **៧០ ៣៨៩ ៧៩៧ដុល្លារអាម៉េរិក** បើធៀបនឹងឆ្នាំមុនមាន**៧៧ ៥១៧ ៨៧៥ដុល្លារអាម៉េរិក** ថយចុះ**៧ ១២៨ ០៧៨ ដុល្លារអាម៉េរិក** ស្មើនឹង**៩,២០%**។

## ១២- ស្ថិតិភ្ញៀវទេសចរអន្តរជាតិទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប

គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ រយៈពេលមួយឆ្នាំនេះ គ្រឹះស្ថានអង្គរលក់សំបុត្រជូនភ្ញៀវទេសចរអន្តរជាតិចូលទស្សនារមណីយដ្ឋានអង្គរសៀមរាបបាន**២ ៥០៨ ៦២៤នាក់** ទទួលបានចំណូល**១១២ ២០៨ ៦៥៨ដុល្លារអាម៉េរិក** ។

នៅក្នុងចំណោមភ្ញៀវទេសចរបរទេសទាំង**២ ៥០៨ ៦២៤នាក់**មាន៖

- ភ្ញៀវទេសចរបរទេសដែលបានទិញបណ្ណប្រភេទ**៣៧ដុល្លារអាម៉េរិក**( ទស្សនា១ថ្ងៃ )មាន**១ ៧៤១ ៣០៦នាក់** ស្មើនឹង**៦៩,៤១%** នៃចំនួនភ្ញៀវទាំងអស់ និងទទួលបានចំណូល**៦៤ ៤២៨ ៣២២ដុល្លារអាម៉េរិក**

- ភ្ញៀវទេសចរបរទេសដែលបានទិញបណ្ណប្រភេទ**៦២ដុល្លារអាម៉េរិក**( ទស្សនា៣ថ្ងៃ ក្នុងសុពលភាព១សប្តាហ៍ ) មាន៧៤៦ ៦៥៦**នាក់ ស្មើនឹង២៩,៧៦%** នៃចំនួនភ្ញៀវទាំងអស់ និងទទួលបានចំណូល **៤៦ ២៩២ ៦៧២ ដុល្លារអាម៉េរិក**

- ភ្ញៀវទេសចរបរទេសដែលបានទិញបណ្ណប្រភេទ**៧២ដុល្លារអាម៉េរិក**( ទស្សនា៧ថ្ងៃ ក្នុងសុពលភាព១ខែ ) មាន**២០ ៦៦២នាក់** ស្មើនឹង**០,៨២%** នៃចំនួនភ្ញៀវទាំងអស់ និងទទួលបានចំណូល**១ ៤៨៧ ៦៦៤ ដុល្លារអាម៉េរិក**។

| លរ. | ប្រភេទបណ្ណ | ចំនួនភ្ញៀវទេសចរទិញបណ្ណ(នាក់) | ចំណូលដុល (ដុល្លារ) |
|---|---|---|---|
| ១ | ៣៧ដុល្លារ(១ថ្ងៃ) | ១ ៧៤១ ៣០៦ | ៦៤ ៤២៨ ៣២២ |
| ២ | ៦២ដុល្លារ(៣ថ្ងៃ) | ៧៤៦ ៦៥៦ | ៤៦ ២៩២ ៦៧២ |
| ៣ | ៧២ដុល្លារ(៧ថ្ងៃ) | ២០ ៦៦២ | ១ ៤៨៧ ៦៦៤ |
| **សរុប** | | **២ ៥០៨ ៦២៤** | **១១២ ២០៨ ៦៥៨** |

- អាជ្ញាធរអប្សរាបានចេញលិខិតអនុញ្ញាតឱ្យអ្នកស្រាវជ្រាវបុរាណវិទ្យា គណៈប្រតិភូជាតិនិងអន្តរជាតិចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប ដោយឥតគិតថ្លៃ១ ១៨៨នាក់។

## ១៣- ស្ថិតិភ្ញៀវចូលទស្សនាសារមន្ទីរនិងមណ្ឌលវប្បធម៌( គិតពីខែមករា-ធ្នូ ឆ្នាំ២០១៩ )

- សារមន្ទីរជាតិរាជធានីភ្នំពេញមានភ្ញៀវដែលបង់ប្រាក់ចូលទស្សនាសរុប **២២១ ៤១១នាក់**( ក្នុងនោះមានភ្ញៀវជាតិ៤៤ ៩៦៤នាក់ ទទួលបានថវិកា២២ ៤៨២ ០០០រៀល និងភ្ញៀវអន្តរជាតិ១៧៦ ៤៤៧នាក់ ទទួលបានថវិកា១ ៧៤៣ ៤៣០ដុល្លារអាម៉េរិក

- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមានភ្ញៀវចូលទស្សនាសរុប**៥២៣ ៧៤៩នាក់** (ក្នុងនោះមានភ្ញៀវអន្តរជាតិ៤០២ ៥៧៩នាក់) បើធៀបនឹងឆ្នាំមុន**៥១៨ ៦៣៥នាក់** កើនឡើង**៥ ១១៤នាក់** ស្មើនឹង **០,៩៨%**

- មណ្ឌលជើងឯកមានភ្ញៀវចូលទស្សនាសរុប**២៣៩ ៧១៧នាក់**( ក្នុងនោះមានភ្ញៀវអន្តរជាតិ១៥៩ ១១០នាក់)

- មណ្ឌលវប្បធម៌វត្តភ្នំមានភ្ញៀវចូលទស្សនា**២៨៨ ៦៧៤នាក់**( ក្នុងនោះមានភ្ញៀវអន្តរជាតិ២១២ ០៨៤នាក់) បើធៀបនឹងឆ្នាំមុន**២៧៨ ៧៣៣អង្គ/នាក់** កើនឡើង**៩ ៩១៤អង្គ/នាក់** ស្មើនឹង**៣,៥៦%**

- ព្រះបរមរាជវាំងមានភ្ញៀវទេសចរចូលទស្សនា**៤៩៩ ៦៥៨នាក់**( ភ្ញៀវអន្តរជាតិ៤៤៦ ៦១៥នាក់)។

ភ្ញៀវទេសចរជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរនិងមណ្ឌលវប្បធម៌(បង់ប្រាក់)

| បរិយាយ | សារមន្ទីរជាតិ | | សារមន្ទីរទួលស្លែង | | មណ្ឌលជើងឯក | | រមណីយដ្ឋានវត្តភ្នំ | | ព្រះបរមរាជវាំង | |
|---|---|---|---|---|---|---|---|---|---|---|
| ២០១៩ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ |
| | ៤៤ ៩៦៤ | ១៧៦ ៤៤៧ | ១២១ ១៧០ | ៤០២ ៥៧៩ | ៨០ ៦០៧ | ១៥៩ ១១០ | ៧៦ ៥៩០ | ២១២ ០៨៤ | ៥៣ ០៤៣ | ៤៥៦ ៦១៥ |

**១៤- ស្ថិតិភ្ញៀវចូលទស្សនារមណីយដ្ឋានប្រាសាទព្រះវិហារនិងកោះកែរ**(គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩)

បានទទួលភ្ញៀវចូលទស្សនារមណីយដ្ឋានប្រាសាទព្រះវិហារ**១៦០ ៤២៨នាក់** ក្នុងនោះភ្ញៀវអន្តរជាតិ **២៥ ៣២៧នាក់** និងចូលទស្សនារមណីយដ្ឋានប្រាសាទកោះកែរ**២៦៧ ៥១៣នាក់** ក្នុងនោះភ្ញៀវអន្តរជាតិ **៣១ ១៤៦នាក់**។

**១៥- ស្ថិតិភ្ញៀវចូលទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក**(គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩)

បានទទួលភ្ញៀវចូលទស្សនារមណីយដ្ឋានប្រាសាទសំបូរព្រៃគុក**២២៧ ៤៦១នាក់** ក្នុងនោះភ្ញៀវអន្តរជាតិ **២២ ៩៩៩នាក់**។

**១៦- ចំណូលពីវិស័យអាកាសចរស៊ីវិល**

| | | |
|---|---|---|
| ចំណូល | ៥០ ៥៣២ ៦៧៩ដុល្លារ (២០១៨) | ៥៣ ៣៧៥ ៩៩៦ដុល្លារ (២០១៩) |

**១៧- ចំណូលពីវិស័យដីធ្លីនិងសំណង់**

ឯកតា(រៀល)

| រយៈពេល | សេវាសុរិយោដី | សេវាសំណង់ | ការជួលទីតាំងរោងចក្រ | ពន្ធលើការផ្ទេរអចលនវត្ថុ |
|---|---|---|---|---|
| **២០១៨** | ៥៨ ៤៦៦ ១៩៦ ៧២៦ | ៣២ ១២២ ៦៩៩ ៧៧២ | ២៨១៦៤៨ ៨៨៨ | ៥៣៣ ៨៣៧ ៧៧៤ ៥១៤ |
| **២០១៩** | ៥៩ ០០០ ៥៨៥ ៦៧៧ | ៦៩ ៦២២ ៥៧៨ ៥៧១ | ២៨០ ៤៦៦ ៦១៦ | ៣៦២ ៧៥៨ ៦៨៦ ៤០៥ |

នៅឆ្នាំ២០១៩ ប្រមូលចំណូលថវិកាជាតិ គិតទាំងពន្ធប្រថាប់ត្រាលើការផ្ទេរអចលនទ្រព្យសរុប ៤៩១ ៦៦២ ៣១៧ ២៦៩រៀល កើនឡើង១៧%បើធៀបនឹងឆ្នាំ២០១៨។

**មុំទី៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤**

**១- វិស័យប្រៃសណីយ៍**

**១.១- ការងារគោលនយោបាយប្រៃសណីយ៍និងការអភិវឌ្ឍ**

ស្របនឹងការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា វិស័យប្រៃសណីយ៍ក៏ត្រូវតែកែទម្រង់ផងដែរ។ ក្នុងន័យនេះ ក្រសួងបានជំរុញការរៀបចំលិខិតបទដ្ឋាននិយ័តកម្មប្រៃសណីយ៍និងការចុះផ្សព្វផ្សាយអនុវត្ត ដូចជា ១-ប្រជុំពិភាក្សាស្ដីពីការងារជំរុញការអភិវឌ្ឍខាងផ្នែកពាណិជ្ជកម្មអេឡិចត្រូនិក(E-commerce) ២-ជំរុញការផ្សព្វផ្សាយរាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរួម និងការឱ្យប្រើប្រាស់នូវសៀវភៅលេខកូដប្រៃសណីយ៍ឆ្នាំ២០១៧ បន្ទាប់ពីការកែសម្រួលនិងបំពេញបន្ថែមលេខកូដប្រៃសណីយ៍ដែលមិនទាន់ពេញលេញ) តាមរយៈគេហទំព័រ(Website) របស់ក្រសួងប្រៃសណីយ និងទូរគមនាគមន៍និងតាមបណ្ដាខេត្តនានា ធ្វើឱ្យសាធារណជនដែលប្រើប្រាស់សេវាប្រៃសណីយ៍មានភាពងាយស្រួលសម្រាប់សម្គាល់អាសយដ្ឋាន និងងាយទទួលបញ្ញើ។ មិនតែប៉ុណ្ណោះ សៀវភៅលេខកូដប្រៃសណីយ៍ក៏ត្រូវបានផ្ញើជូនទៅសហភាពប្រៃសណីយ៍ពិភពលោក (UPU) ដើម្បីផ្សព្វផ្សាយទៅដល់ប្រទេសឬរដ្ឋជាសមាជិកផងដែរ ៣-ចុះផ្សព្វផ្សាយតាមដានពីការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យប្រៃសណីយ៍ដល់បណ្ដាប្រតិបត្តិករប្រៃសណីយ៍បានចំនួន២០ក្រុមហ៊ុននៅរាជធានីភ្នំពេញ និងសាខាតាមខេត្តនានា។

### ១.២- ការងារគ្រប់គ្រងនិងនិយ័តកម្មប្រៃសណីយ៍ឯកជន

ដើម្បីលើកកម្ពស់សេវាកម្មឱ្យមានភាពស្របច្បាប់និងកាន់តែល្អប្រសើរពីសំណាក់ប្រតិបត្តិករជំនាញ បានរៀបចំដំណើរការនៃការចុះត្រួតពិនិត្យអាជ្ញាបណ្ណប្រៃសណីយ៍( Controlling Process )និងបានចុះត្រួតពិនិត្យ ដោយបានរកឃើញក្រុមហ៊ុនចំនួន**៥០** ដែលគ្មានអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានទីតាំងនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្ត។ ជាមួយគ្នានេះ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនចំនួន**២៧** ដែលបានរៀបចំបែបបទសំណើសុំបន្តអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិចំនួន **២១ក្រុមហ៊ុន** សំណើសុំអាជ្ញាបណ្ណថ្មីលើសេវាបញ្ញើឆាប់រហ័សអន្តរជាតិចំនួន**៦ក្រុមហ៊ុន** បានរៀបចំបែបបទសំណើសុំឈប់ធ្វើអាជីវកម្មលើសេវា**៤ក្រុមហ៊ុន** និងបានរៀបចំបែបបទសំណើសុំបើកសាខាអាជីវកម្មបញ្ញើឆាប់រហ័សអន្តរជាតិបានចំនួន**៥សាខា** នេះគឺជាភារកិច្ចមន្ត្រីក្នុងការជំរុញឱ្យអាជីវករពាក់ព័ន្ធគោរពប្រតិបត្តិតាមលិខិតបទដ្ឋានដែលមានជាធរមាន។

### ១.៣- ការងារមុខជំនាញនិងពង្រឹងគុណភាពសេវាកម្ម

ដើម្បីលើកកម្ពស់គុណភាពដឹកនាំនិងគ្រប់គ្រងវិស័យនេះឱ្យកាន់តែប្រសើរ ត្រូវការចាំបាច់ប្រមូលព័ត៌មានពាក់ព័ន្ធនឹងថ្លៃសេវាប្រៃសណីយ៍ពីបណ្តាប្រតិបត្តិករ ដើម្បីសិក្សាថ្លៃដើមនិងកំណត់ថ្លៃសេវាប្រៃសណីយ៍ឱ្យបានត្រឹមត្រូវដោយផ្អែកលើច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ដូចនេះត្រូវមានគោលនយោបាយជាតិអភិវឌ្ឍវិស័យប្រៃសណីយ៍ ការត្រៀមរៀបចំអនុក្រឹត្យនិងការត្រួតពិនិត្យលេខកូដប្រៃសណីយ៍ឡើងវិញ ស្របនឹងបច្ចុប្បន្នភាពរចនាសម្ព័ន្ធរដ្ឋបាលថ្មី។ កន្លងមកក្នុងប្រទេសក៏មានការប្រជុំ**៤៧លើក**ដែលមានអ្នកចូលរួមចំនួន **២៣៨នាក់**និងសិក្ខាសាលាចំនួន**១០លើក** ដែលមានអ្នកចូលរួមចំនួន**១៤៣នាក់** ព្រមទាំងបានបញ្ជូនមន្ត្រីបាន៨នាក់ទៅប្រជុំនៅក្រៅប្រទេសចំនួន**៦លើក** ដើម្បីអាចស្វែងយល់អំពីការអភិវឌ្ឍវិស័យប្រៃសណីយ៍នៅតាមបណ្តាប្រទេសនានាមួយចំនួន។

### ១.៤- ការងារអាជីវកម្ម សហគ្រាសប្រៃសណីយ៍កម្ពុជា

ឯកតា : ដុល្លារ

| ល.រ. | សូចនាករ | កញ្ញា-ធ្នូ ២០១៨ | មករា-សីហា ២០១៩ | សរុប |
|---|---|---|---|---|
| ១ | បញ្ញើឆាប់រហ័ស | ២ ០៣៦ ៩៥៣ | ៣ ៥២៨ ៩៤៩ | ៥ ៥៦៥ ៩០២ |
| ២ | ប្រៃសណីយ៍កណ្ឌ | ៣៦៨ ៧៨៣ | ៦៩០ ៥៥១ | ១ ០៥៩ ៣៣៤ |
| ៣ | បញ្ញើកញ្ចប់និងលិខិត | ១៤៣ ៨៩៤ | ១៣១ ០៩៤ | ២៧៤ ៩៨៨ |
| ៤ | បែងចែកបញ្ញើអន្តរជាតិ | ១ ៩៦៦ ៦៦២ | ២ ៩៦៥ ២៩៦ | ៤ ៩៣១ ៩៥៨ |
| ៥ | ផលិតផលប្រៃសណីយ៍ | ៣៧ ៨៤០ | ៦៥ ០៣៥ | ១០២ ៨៧៥ |
| ៦ | សេវាអាណត្តិប្រៃសណីយ៍ | ១១ ៩០០ | ២៣ ៩៥៥ | ៣៥ ៨៥៥ |
| ៧ | រថយន្តដឹកអ្នកដំណើរ | ៤៣ ៦៦៧ | ៩៣ ៩៨៥ | ១៣៧ ៦២៥ |
| ៨ | ចំណូលផ្សេងៗ | ៣៩៥ ៩១៦ | ៣៦៨ ៩៨៩ | ៧៦៤ ៩០៥ |
| **សរុប** | | **៥ ០០៥ ៦១៥** | **៧ ៨៦៧ ៨៥៤** | **១២ ៨៧៣ ៤៤២** |

ផ្អែកតាមលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៨-២០១៩នេះ អាចវាយតម្លៃបានថាសកម្មភាពអាជីវកម្មប្រៃសណីយ៍កម្ពុជាមានការរីកចម្រើនមួយកម្រិតគួរឱ្យកត់សម្គាល់។ យើងសង្កេតឃើញថា ទោះបីមានផ្នែកខ្លះមានការរីកចម្រើនសមស្របតាមកម្រិតអភិវឌ្ឍន៍ក៏ដោយ ក៏នៅមានផ្នែកខ្លះទៀតពុំទាន់អាចបំពេញបានគ្រប់សំណូមពរ

និងចាំបាច់ត្រូវបន្តការខិតខំបន្ថែមទៀត រួមមាន១- បន្តបង្កើនចំណូលពីបញ្ញើក្នុងស្រុក ២- បន្តពង្រឹងការបែងចែកបញ្ញើ ៣- ត្រូវបង្កើនជើងបញ្ញើទៅកាន់បណ្តាគោលដៅសំខាន់ៗ ៤- បង្កើនការគ្រប់គ្រងចំណូលឱ្យបានល្អដោយកាត់បន្ថយចំណាយដែលពុំចាំបាច់ ៥- បន្តរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីជាយន្តការត្រួតពិនិត្យនិងពង្រឹងគុណភាពការងារ។ សូមជម្រាបជូនថា ប្រទេសកម្ពុជាយើងក្រៅពីប្រៃណីយ៍កម្ពុជា នៅមានប្រតិបត្តិករប្រៃសណីយ៍ឯកជនចំនួន**៤៣** ក្នុងនេះ ៥នៅរាជធានីភ្នំពេញ និង៨ក្រុមហ៊ុនមាន២០សាខា នៅតាមបណ្តាខេត្ត។

### ២- វិស័យទូរគមនាគមន៍

#### ២.១- ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញ

#### ក- ការកសាងហេដ្ឋារចនាសម្ព័ន្ធតាមរយៈគោលនយោបាយមូលនិធិ USO

ក្រោយពីបានដាក់ឱ្យដំណើរការនូវយន្តការកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍(USO)មានប្រតិបត្តិករទូរគមនាគមន៍ភាគច្រើនបានចូលរួមបំពេញកាតព្វកិច្ចបង់វិភាគទានចូលមូលនិធិ **USO** ដើម្បីរួមចំណែកពង្រីកការតភ្ជាប់ឌីជីថលឱ្យទៅដល់ទីជនបទ។ តំបន់អាទិភាពចំនួន០៧ ដែលមានលក្ខណៈភូមិសាស្ត្រខុសៗគ្នា ត្រូវបានជ្រើសរើសសម្រាប់អនុវត្តគម្រោងសាកល្បងក្នុងការពង្រីកវិសាលភាពគ្របដណ្តប់សេវាទូរគមនាគមន៍ឱ្យទៅដល់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល ដែលមិនទាន់មានសេវាទូរគមនាគមន៍ប្រើប្រាស់ មានដូចជា៖
១- ស្រុកទឹកផុស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ២- ស្រុកល្វាឯម ស្រុកស្អាង ខេត្តកណ្តាល ៣- ស្រុកកំពង់សិលា ខេត្តព្រះសីហនុ ៤- ស្រុកថ្មបាំង(តំបន់អារ៉ែង) ខេត្តកោះកុង។

គិតមកទល់ពេលនេះ ស្ថានីយ៍អង់តែនទូរសព្ទចល័តថ្មីចំនួន៤៤ ស្ថានីយ៍ទូរសព្ទចល័ត ត្រូវបានសាងសង់និងបំពាក់បរិក្ខារនៅក្នុងភូមិសាស្ត្រខាងលើនិងបានដាក់ឱ្យធ្វើសេវាកម្មសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ ដោយគ្មានរើសអើង។ ក្រៅពីនេះ ក៏មានស្ថានីយ៍ទូរសព្ទចល័តចំនួន **៩១**កន្លែងផ្សេងទៀតស្ថិតក្នុងភូមិសាស្ត្រនៃខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ សៀមរាប ព្រះវិហារ និងឧត្តរមានជ័យត្រូវបានបង្កើនសមត្ថភាព (Upgrading) ឬកែសម្រួលរចនាសម្ព័ន្ធឡើងវិញ(Reconfiguration)សំដៅជានាអ្នកប្រើប្រាស់អាចភ្ជាប់សេវាអ៊ីនធឺណិតបាន។

ដោយឡែកស្ថានីយ៍ទូរសព្ទចល័តចំនួន**៩៥**កន្លែងទៀត នៅទូទាំងប្រទេសកំពុងដំណើរការការដ្ឋានយ៉ាងសកម្មដោយរំពឹងថានឹងដាក់ឱ្យធ្វើសេវាកម្មនាពេលឆាប់ខាងមុខ រួមចំណែកពង្រីកសេវានិងលើកកម្ពស់គុណភាពការតភ្ជាប់ឌីជីថល។

#### ខ- កាត់បន្ថយគម្លាតឌីជីថលនិងការកសាងសមត្ថភាពធនធានមនុស្ស

ដោយមើលឃើញពីសារៈសំខាន់នៃការកាត់បន្ថយគម្លាតឌីជីថលនិងការកសាងសមត្ថភាពធនធានមនុស្សគឺជាស្នូលរួមចំណែកធ្វើឱ្យវិស័យបច្ចេកវិទ្យាមានការរីកចម្រើនប្រកបដោយចីរភាព ក្រសួងបានយកចិត្តទុកដាក់និងជំរុញយ៉ាងខ្លាំងក្លាតាមរយៈយន្តការផ្តល់ចំណេះដឹងមូលដ្ឋាននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដល់ប្រជាជននិងសិស្សានុសិស្ស និងមន្ត្រីរាជការមូលដ្ឋាននៅថ្នាក់ក្រោមជាតិ។ ក្រសួងបានចាត់តាំងកម្មវិធីអ្នកស្ម័គ្រចិត្តបច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាជារៀងរាល់ឆ្នាំ។ ជាក់ស្តែងក្នុងឆ្នាំ២០១៩នេះ បានផ្តល់ការបណ្តុះបណ្តាលចំណេះដឹងមូលដ្ឋាននៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដល់មន្ត្រីរាជការនិងសិស្សានុសិស្ស នៅស្រុកកំពង់លែង និងស្រុកទឹកផុសខេត្តកំពង់ឆ្នាំងតាមរយៈគម្រោងអ្នកស្ម័គ្រចិត្តបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាបានចំនួន**២០៥២នាក់**(ស្រី១ ៤១៥នាក់)។

**គ- ទូរគមនាគមន៍កម្ពុជា**

ដើម្បីបន្តចូលរួមប្រកួតប្រជែងជាមួយប្រតិបត្តិករឯកជនដទៃទៀត ក្នុងទីផ្សារទូរគមនាគមន៍ដែលកាន់តែទំនើបនោះក្នុងការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍កម្ពុជាបានជំរុញការអភិវឌ្ឍដោយបានសហការជាមួយដៃគូអភិវឌ្ឍបំពង់បណ្តាញផ្លូវកាបក្រោមដីក្នុងរាជធានីភ្នំពេញ ក្នុងគម្រោង១៧ផ្លូវ ក្នុងនោះ៖

១- អនុវត្តជាក់ស្តែងបានចំនួន៦ផ្លូវ។ ចំណែកភូមិសាស្ត្រនៅសេសសល់នឹងត្រូវដាក់ស្នើជាគម្រោងមកកាន់ក្រសួងអាណាព្យាបាលទាំងពីរដើម្បីសុំការអនុញ្ញាតអនុវត្តបន្តទៀត។

ទន្ទឹមនេះ ធ្វើការផ្ទេរការប្រើប្រាស់លេខទូរសព្ទអតិថិជន(Migration Switching) ពីបណ្តា Legacy Switching ចាស់ៗមកកាន់NGN Switching ថ្មីបានចំនួន២ Switching ក្នុងចំណោម Switching ទាំង៥របស់ទូរគមនាគមន៍កម្ពុជា។ ជាលទ្ធផលទទួលបានសម្រេចជាស្ថាពរនិងនៅសល់ Switching បីទៀតនឹងត្រូវដាក់ចេញជាទិសដៅសម្រាប់ធ្វើការផ្លាស់ប្តូរជាបន្តបន្ទាប់ទៀត។ សូមបញ្ជាក់ជូនដែរថា ការផ្ទេរបច្ចេកទេសនេះទូរគមនាគមន៍កម្ពុជាបានប្រើប្រាស់បច្ចេកវិទ្យា និងធនធានផ្ទាល់ខ្លួនដោយមិនបានប្រើប្រាស់បច្ចេកវិទ្យានិងធនធានពីខាងក្រៅឡើយ គឺបង្ហាញពីភាពរឹងមាំ និងម្ចាស់ការដែលកាន់តែធ្វើឱ្យទូរគមនាគមន៍កម្ពុជាសន្សំសំចៃបានមួយកម្រិតធំអំពីការប្រើប្រាស់ថាមពលអគ្គិសនីផងដែរ។

២- ស្តារហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ គឺបានកំណត់ផែនការជាយុទ្ធសាស្ត្រក្នុងការពង្រឹងគុណភាពផ្តល់សេវាជាក់ស្តែង ជូនតាមបណ្តាក្រសួង ស្ថាប័ននិងអង្គភាពរដ្ឋ តាមគោលការណ៍បានដាក់ស្នើជាមួយនេះ បណ្តាញឆ្អឹងខ្នង(Back Bone)ជាប្រភេទកាបកប់ក្រោមដី ដែលទូរគមនាគមន៍កម្ពុជា មានសរុបទូទាំងប្រទេសមានប្រវែង១ ៩៥៤គ.ម.ជាចំណែកមួយក្នុងប្រវែងសរុបរួម៤២ ៦៩៣គ.ម.។

និង៣- ចំណុះមាត់ច្រកអ៊ីនធឺណិតរបស់ទូរគមនាគមន៍កម្ពុជាទៅអន្តរជាតិមានពីរមាត់ច្រកគឺ ទី១-តាមរយៈមាត់ច្រកហុងកុងចំណុះល្បឿន 2 Gbps ភ្ជាប់ជា IP-Port (WCCW with 1Gbps) និងទី២-តាមរយៈមាត់ច្រកសិង្ហបុរី ចំណុះល្បឿន 2 Gbps ភ្ជាប់ជា IP-Port (Telstra=1Gbps and Equinix=1Gbps)។

**២.២- ការពង្រឹងគុណភាពសេវាកម្ម កំណើនសេដ្ឋកិច្ច/កាត់បន្ថយភាពក្រីក្រ**

| **២.២.១- ការងារអាជីកម្មរបស់ទូរគមនាគមន៍កម្ពុជា** | | | |
|---|---|---|---|
| **ក- សេវាទូរសព្ទអចល័តនិងសេវាអ៊ីនធឺណិតADSLដែលកំពុងផ្តល់ជូនអតិថិជនប្រើប្រាស់** | | | |
| **ប្រភេទសេវា** | **ខ្នាត** | **ខែកញ្ញា ២០១៨** | **ខែសីហា ២០១៩** |
| ទូរសព្ទភ្នំពេញនិងខេត្ត | | | |
| ទូរសព្ទ | អ្នកប្រើប្រាស់ | ៣០ ៦១០ | ២៩ ៧០១ |
| Internet ភ្នំពេញនិងខេត្ត | | | |
| Internet ក្នុងនោះ | អ្នកប្រើប្រាស់ | ៧ ៣១១ | ៧ ១៥៧ |
| -ADSL | | ៦ ៥២៦ | ៦ ០៨៤ |
| -IP Leased | | ២៥៦ | ៣៥៣ |
| -FTTH | | ៥២៩ | ៧២០ |

| **ខ-ចរន្តសេវាទូរសព្ទហៅឆ្លងកាត់ទៅវិញទៅមក** | (ឯកតា: នាទី) |
|---|---|
| **ប្រតិបត្តិករ** | **ខែកញ្ញា-ធ្នូ ឆ្នាំ ២០១៨**<br>**ខែមករា-សីហា ឆ្នាំ ២០១៩** |
| ចរន្តទូរសព្ទភ្ជាប់ចូល | |
| Fixed(CamGSM ,Camintel ,LATEL ,Viettel)-TC | ៨៦៨ ៤៥៣ |
| Mobile(CamGSM ,Sea Tel ,Viettel ,CadCom ,LATEL ,XINWEI)-TC | ៥ ២២៩ ៩៨០ |

| | |
|---|---|
| | |
| ចរន្តទូរសព្ទភ្ជាប់ចេញ(ឯកតា : នាទី) | |
| TC-Fixed(CamGSM ,Camintel ,LATEL ,Viettel)-TC | ១ ០៣៥ ៤៥៧ |
| TC-Mobile(CamGSM, Seatel, LATEL, Viettel,CadCom & XINWEI) | ១១ ៤៣៤ ៤៥៣ |
| **គ- ចរន្តទូរសព្ទអន្តរជាតិចេញ-ចូល** (Gate-Way) | ( ឯកតា : នាទី ) |
| ចរន្តទូរសព្ទតភ្ជាប់ចូល | |
| In (001-VoIP 154) | ៧១ ៨៤៤ ៣៨០ |
| Mobile(CamGSM , LATEL ,Viettel , CadCom ,Seatel ,XINWEI)-TC | ៥ ២២៩ ៩៨០ |
| ចរន្តទូរសព្ទតភ្ជាប់ចេញ | |
| Out (001-VoIP 154) | ៧៥៩ ៥៣៩ |

| **២.២.២- ការងារហិរញ្ញកិច្ច និងគណនេយ្យ** | **ឯកតា : ដុល្លារអាមេរិក** | |
|---|---|---|
| **ចំណូល** | គិតត្រឹមខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ | ៣ ៦១៤ ៥៧១ |
| | គិតត្រឹមខែមករា ដល់ខែសីហា ឆ្នាំ២០១៩ | ៦ ៨៥០ ៧១៤ |
| **សរុប** | | **១០ ៤៦៥ ២៨៥** |
| **ចំណាយ** | គិតត្រឹមខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ | ៥ ០៦០ ៣៧៦ |
| | គិតត្រឹមខែមករា ដល់ខែសីហា ឆ្នាំ២០១៩ | ៨ ៨៦២ ២៧៥ |
| **សរុប** | | **១៣ ៩២២ ៦៥១** |
| **ខាត(ខែកញ្ញា ២០១៨-កញ្ញា ២០១៩)** | | **-៣ ៤៥៧ ៣៦៥** |

**២.៣- អាជីវកម្មសហគ្រាស-ក្រុមហ៊ុនឯកជន**

| **ក-ទិន្នន័យអតិថិជនប្រើសេវាទូរគមនាគមន៍** | | | |
|---|---|---|---|
| ប្រតិបត្តិករទូរគមនាគមន៍ | ឯកតា | ២០១៨ | ២០១៩ (ខែមករា ដល់ខែសីហា) |
| ទូរសព្ទចល័ត | នាក់ | ១៩ ៤១៧ ១២៣ | ២១ ២៥៥ ៥៩១ |
| ទូរសព្ទអចល័ត | នាក់ | ៩៦ ២៦១ | ៦៣ ៧៣៥ |
| អ៊ីនធឺណិតចល័ត | នាក់ | ១៣ ៤៥៥ ៩៦៤ | ១៥ ៨៩៤ ០៧៦ |
| អ៊ីនធឺណិតអចល័ត | នាក់ | ១៥៣ ៣៤៨ | ២០០ ៤៦៧ |

បញ្ជាក់ : - ទូរសព្ទចល័តមានចំនួន ៦ ប្រតិបត្តិករទូរសព្ទអចល័តមានចំនួន៧ ប្រតិបត្តិករ

- អ៊ីនធឺណិតចល័តមានចំនួន៧ប្រតិបត្តិករ អ៊ីនធឺណិតអចល័តមានចំនួន៣៤ប្រតិបត្តិករ។

| **ខ- ទិន្នន័យជាប្រវែងបណ្តាញខ្សែកាបអុបទិក** | | |
|---|---|---|
| ល.រ | ប្រតិបត្តិករ | គិតត្រឹមខែធ្នូ ឆ្នាំ ២០១៨ |
| 1 | CFOCN | ១៨ ៣៧១គ.ម. |
| 2 | Telecom Cambodia | ២ ៣២២គ.ម. |
| 3 | Viettel(Cambodia) | ២២ ០០០គ.ម. |
| **សរុប** | | **៤២ ៦៩៣គ.ម.** |

### ៣- វិស័យសាធារណការនិងដឹកជញ្ជូន

ក្រសួងសាធារណការនិងដឹកជញ្ជូនបាននិងកំពុងត្រៀមគំនិតផ្តួចផ្តើមដូចខាងក្រោម៖

- បានដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មចំពោះការផ្តល់សេវាសាធារណៈលើការងារដឹកជញ្ជូនផ្លូវគោក រួមទាំងការបង់ប្រាក់ធ្វើតាមប្រព័ន្ធធនាគារ
- សហការបច្ចេកទេសរៀបចំកម្មវិធី Mobile App យល់ដឹងពីទ្រឹស្តីនៃការបើកបរនិងច្បាប់ចរាចរណ៍ផ្លូវគោក ត្រួតពិនិត្យព័ត៌មានយានយន្តនិងបណ្ណបើកបរសម្រាប់មន្ត្រីសមត្ថកិច្ចជំនាញជាអ្នកប្រើប្រាស់
- បានអនុញ្ញាតឱ្យមានការដឹកជញ្ជូនតាមវិធីការដឹកជញ្ជូនចែករំលែក (Ride Sharing) ដូចជាGrab ឬ PassApp
- បាននិងកំពុងរៀបចំនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ Port EDI System
- បានរៀបចំដាក់ឱ្យដំណើរការកម្មវិធី App សម្រាប់ការចូលរួមកម្មវិធីថែទាំផ្លូវថ្នល់ (Road Care App)
- កំពុងសិក្សារៀបចំដាក់ឱ្យដំណើរការកម្មវិធី App សម្រាប់ដីចំណីផ្លូវ (ជប៉ុន)។

### ៤- វិស័យធនាគារជាតិនៃកម្ពុជា

**ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់** ធនាគារជាតិនៃកម្ពុជា បានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់សំដៅរួមចំណែកជំរុញការប្រើប្រាស់ ការទូទាត់អេឡិចត្រូនិកនិងបរិយាបន្នហិរញ្ញវត្ថុ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយបានដាក់ឱ្យដំណើរការបឋមនៃប្រព័ន្ធខេមបូឌានស៊ែស្វិច និងបន្តធ្វើសន្ទានកម្មប្រព័ន្ធនេះរបស់គ្រឹះស្ថានសមាជិកដាក់ឱ្យដំណើរការបឋមនៃប្រព័ន្ធរីថែលផេ ក្រោមកិច្ចសហការជាមួយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការកូរ៉េ (KOICA) និងដាក់ឱ្យដំណើរការសាកល្បងគម្រោងបាគង ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆែន (blockchain)។

## មុំទី៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

### ១- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសាធារណៈ

#### ១.១- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា

នៅឆ្នាំ២០១៩ នេះ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅបន្តមានវឌ្ឍនភាពល្អប្រសើរ ជាមួយនឹងកំណើន **៧,១%** ដែលជំរុញដោយវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍ ខណៈវិស័យកសិកម្មមានកំណើនអវិជ្ជមាន។ ក្នុងនោះ វិស័យឧស្សាហកម្មបន្តកំណើនខ្ពស់ក្នុងអត្រា ១១,៣% មានចំណែកស្មើនឹង ៣៤,២% នៃ ផ.ស.ស. ស្របពេលដែលវិស័យសេវាកម្មបន្តកំណើនរឹងមាំក្នុងរង្វង់ ៦,២% ស្មើនឹង ៣៨,៨% នៃ ផ.ស.ស. ខណៈវិស័យកសិកម្មមានកំណើន -០,៥% ស្មើនឹង ២០,៧% នៃ ផ.ស.ស.។ ទន្ទឹមនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ស្ថិតក្នុងកម្រិតទាប ១,៨% ស្របពេលដែលអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់ ៤ ០៥៥ រៀល ក្នុងមួយដុល្លារអាម៉េរិក។

**ការរួមចំណែករបស់វិស័យនីមួយៗដល់ផ.ស.ស.**



### ១.២- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[9]

បន្ទាប់ពីការដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ការប្រមូលចំណូលថវិកាជាតិក្នុងឆ្នាំ២០១៨និង២០១៩ សម្រេចបានលទ្ធផលគួរជាទីមោទនៈ ដែលជាបច្ច័យនៃជវភាពកំណើនសេដ្ឋកិច្ចកម្ពុជា ដែលបានជំរុញឱ្យសកម្មភាពអាជីវកម្មលើគ្រប់វិស័យមានភាពរីកចម្រើនយ៉ាងឆាប់រហ័ស ព្រមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វប្បធម៌នៃការបង់ពន្ធនិងការកែសម្រួលគោលនយោបាយពន្ធ។ ក្នុងន័យនេះ ការប្រមូលចំណូលក្នុងស្រុកសម្រេចបានប្រមាណ ២១ ៩៧៧,៧ ប៊ីលានរៀល ស្មើនឹង ៥ ៤២៥,២ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០១៨ និងបន្តកើនឡើងរហូតដល់ប្រមាណ ២៧ ៧៤២,៦ ប៊ីលានរៀល ស្មើនឹង ៦ ៨៤១,៦ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០១៩ ។

**តារាងចំណូលថវិកាជាតិឆ្នាំ ២០១៨ និង ២០១៩**

| ចំណូល | ឆ្នាំ ២០១៨ | | ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ |
| **ចំណូលក្នុងស្រុក** | **២១ ៩៩៧,៧** | **៥ ៤២៥,២** | **២៧ ៧៤២,៦** | **៦ ៨៤១,៦** |
| ចំណូលចរន្ត | ២១ ៧៨២,៩ | ៥ ៣៧៧,២ | ២៧ ៥៦១,១ | ៦ ៧៩៦,៨ |
| ចំណូលសារពើពន្ធ | ១៨ ៨៨២,៦ | ៤ ៦៦១,២ | ២៤ ១៥៨,៦ | ៥ ៩៥៧,៧ |
| ចំណូលគយ និងរដ្ឋាករ | ១០ ១០២,២ | ២ ៤៩៣,៨ | ១២ ៨៩៧,៤ | ៣ ១៨០,៦ |
| ចំណូលពន្ធដារ | ៨ ៧៨០,៤ | ២ ១៦៧,៥ | ១១ ២៦១,២ | ២ ៧៧៧,១ |
| ចំណូលមិនមែនសារពើពន្ធ | ២ ៩០០,៣ | ៧១៦,០ | ៣ ៤០២,៥ | ៨៣៩,១ |
| ចំណូលមូលធន | ១៩៤,៧ | ៤៨,១ | ១៨១,៤ | ៤៤,៧ |







ចំពោះផ្នែកចំណាយថវិកាជាតិ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយវិត្ថារកម្មថវិកា (expansionary fiscal policy) ក្នុងឆ្នាំ២០១៨ ដោយប្រើប្រាស់ថវិកាសរុបប្រមាណ ២៤ ២៧៧,០ ប៊ីលានរៀល ស្មើនឹង ៥ ៩៩២,៩ លានដុល្លារអាម៉េរិក ដែលចំណាយថវិកានេះ គឺជាកាតាលីករដ៏សំខាន់ក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបាន រហូតដល់ ៧,៥% ក្នុងឆ្នាំ២០១៨។ ដោយឡែក ក្នុងឆ្នាំ២០១៩ រាជរដ្ឋា-ភិបាលកម្ពុជាបានអនុវត្តគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (fiscal consolidation) ដោយប្រើប្រាស់

---

*[9] ទិន្នន័យសម្រាប់ឆ្នាំ ២០១៩ ជាតួលេខបណ្តោះអាសន្ន គិតត្រឹមខែឧសភា ឆ្នាំ២០២០ ដែលប្រើប្រាស់សម្រាប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១*

ថវិកាសរុបប្រមាណ២៨ ៣២៨,៩ ប៊ីលានរៀល ស្មើនឹង៦ ៩៨៦,២ លានដុល្លារអាមេរិក ។ គោលនយោបាយថវិកានេះមានគោលដៅក្នុងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាជាតិ  តាមរយៈការវិភាជឱ្យកាន់តែចំគោលដៅនិងកាត់បន្ថយចំណាយមិនចាំបាច់នានា  ខណៈធានាបង្កើនចំណាយសម្រាប់គោលនយោបាយអាទិភាពសំខាន់ៗ។  ជារួមថវិកាឆ្នាំ២០១៩  បានដើរតួនាទីជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពក្នុងការរក្សាការពារនិងពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេង  ដែលកម្ពុជាសម្រេចបានកន្លងមកក៏ដូចជាក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត ។

**តារាងចំណាយថវិកាជាតិឆ្នាំ ២០១៨ និង ២០១៩**

| ចំណាយ | ឆ្នាំ ២០១៨ | | ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ |
| **ចំណាយសរុប** | **២៤ ២៧៣,០** | **៥ ៩៩២,៩** | **២៨ ៣២៨,៩** | **៦ ៩៨៦,២** |
| ចំណាយចរន្ត | ១៦ ២៧៣,៣ | ៤ ០១៨,១ | ១៨ ៥៤៣,៥ | ៤ ៥៧៣,០ |
| បន្ទុកបុគ្គលិក | ៨ ៣៩៩,៥ | ២ ០៧៣,៤ | ៨ ៥១៧,៤ | ២ ១០០,៥ |
| ក្រៅបន្ទុកបុគ្គលិក | ៧ ៨៧៣,៨ | ១ ៩៤៤,៧ | ១០ ០២៦,១ | ២ ៤៧២,៥ |
| ចំណាយមូលធន | ៧ ៩៩៩,៧ | ១ ៩៧៤,៨ | ៩ ៧៨៥,៤ | ២ ៤១៣,២ |







ជាមួយនឹងលទ្ធផលដ៏ល្អប្រសើរនៃការប្រមូលចំណូលនិងការអនុវត្តចំណាយថវិកាជាតិប្រកបដោយភាពប្រុងប្រយ័ត្ននិងសន្សំសំចៃខ្ពស់  តុល្យភាពថវិកាជាតិមានភាពប្រសើរឡើងជាលំដាប់  ពោលគឺឱនភាពថវិកាបានថយចុះពីប្រមាណ២ ២៩៩,៤ប៊ីលានរៀល ស្មើនឹង៥៦៧,៦ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០១៨ មកត្រឹមប្រមាណ៥៨៦,៣ ប៊ីលានរៀល ស្មើនឹង១៤៤,៦លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០១៩ ។

**តារាងតុល្យភាពថវិកាជាតិឆ្នាំ២០១៨ និង២០១៩**

| តុល្យភាពថវិកា | ឆ្នាំ ២០១៨ | | ឆ្នាំ ២០១៩ | |
|---|---|---|---|---|
| | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ | គិតជាប៊ីលានរៀល | គិតជាលានដុល្លារ |
| ចំណូលក្នុងស្រុក | **២១ ៩៩៧,៧** | **៥ ៤២៥,២** | **២៧ ៧៤២,៦** | **៦ ៨៤១,៦** |
| ចំណូលចរន្ត | ២១ ៧៨២,៩ | ៥ ៣៧៧,២ | ២៧ ៥៦១,១ | ៦ ៧៩៦,៨ |
| ចំណាយសរុប | **២៤ ២៧៣,០** | **៥ ៩៩២,៩** | **២៨ ៣២៨,៩** | **៦ ៩៨៦,២** |
| ចំណាយចរន្ត | ១៦ ២៧៣,៣ | ៤ ០១៨,១ | ១៨ ៥៤៣,៥ | ៤ ៥៧៣,០ |
| **អតិរេកចរន្ត** | **៥ ៥០៥,៦** | **១ ៣៥៩,១** | **៩ ០១៧,៦** | **២ ២២៣,៨** |
| **ឱនភាពថវិកា** | **២ ២៩៩,៤** | **៥៦៧,៦** | **៥៨៦,៣** | **១៤៤,៤** |

## ២- ការជំរុញការអភិវឌ្ឍវិស័យធនាគារ

### ២.១- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

#### ក- ស្ថានភាពទូទៅ

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមានធនាគារពាណិជ្ជ៤៦ ធនាគារឯកទេស១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ៧៥ គ្រឹះស្ថានឥណទានជនបទ២៤៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ១៥ និងគ្រឹះស្ថានផ្តល់សេវាទូទាត់២០។

ប្រព័ន្ធធនាគារនៅកម្ពុជាមានទំហំនិងវិសាលភាពសេវាកម្មកាន់តែធំក្នុងសេដ្ឋកិច្ច ដោយទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង២២,៩%ដល់១៩៨,៣ ទ្រីលានរៀលស្មើនឹង ៤៨,៤ ប៊ីលានដុល្លារអាម៉េរិក ដែលរួមចំណែកដោយឥណទាន១២៥,៨ទ្រីលានរៀល ស្មើនឹង៣០,៧ ប៊ីលានដុល្លារអាម៉េរិក ព្រមទាំងគាំទ្រដោយប្រាក់បញ្ញើអតិថិជន១១៤,៩ ទ្រីលានរៀល ស្មើនឹង២៨ ប៊ីលានដុល្លារអាម៉េរិក ដើមទុន២២,៨ទ្រីលានរៀល ស្មើនឹង៥,៦ប៊ីលានដុល្លារអាម៉េរិក និងមូលនិធិកម្ចី១៦ទ្រីលានរៀល ស្មើនឹង៣,៩ ប៊ីលានដុល្លារអាមេរិក។ ជាមួយគ្នានេះ បណ្តាញប្រតិបត្តិការ នៅតាមរាជធានី-ខេត្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តកើនឡើងនិងរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនដល់២ ៤៥០សាខា ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ(ATM) ដល់២ ៥២០ម៉ាស៊ីន និងបានផ្តល់សេវាប្រាក់បញ្ញើ៧ ២៩៨ ១៥៦គណនី និងសេវាឥណទាន២ ៩៧៣ ៧៨៦គណនី។

#### ខ- អត្រាការប្រាក់បញ្ញើនិងឥណទាន

អត្រាការប្រាក់បញ្ញើជារៀលនិងជាដុល្លារអាម៉េរិករបស់គ្រឹះស្ថានធនាគារមានកម្រិត៦,១៧% និង៤,៩៩% រៀងគ្នានៅខែកញ្ញា ឆ្នាំ២០១៩ បើធៀបនឹងគ្រាដូចគ្នាឆ្នាំមុន៦,៣៣% និង៤,៨៦%។ ដោយឡែកអត្រាការប្រាក់ឥណទានជារៀល និងជាដុល្លារអាម៉េរិកមាននិន្នាការថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយបានថយចុះពី១៤,៧៨% និង១១,០៦% រៀងគ្នានៅឆ្នាំមុន មក១២,៧៧% និង១០,១៤%រៀងគ្នា។

អត្រាការប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការប្រែប្រួលតិចតួច ដោយមានកម្រិត៥,០៩% និង៤,៦៥%រៀងគ្នា។ ដោយឡែក អត្រាការប្រាក់ឥណទានជារៀលនិងជាដុល្លារអាម៉េរិកបានថយចុះជាលំដាប់ពី៣៤,៥% និង២៩,៦%រៀងគ្នាក្នុងឆ្នាំ២០១៦ មកត្រឹម២២,៩% និង ២០% រៀងគ្នាក្នុងឆ្នាំ២០១៧ និងមកត្រឹម១៧,១៤% និង១៧,២២%រៀងគ្នានៅខែកញ្ញា ឆ្នាំ២០១៩ បន្ទាប់ពីការដាក់ចេញនូវប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន១៨% ដែលការណ៍នេះបានផ្តល់ផលវិជ្ជមានច្រើនដល់អតិថិជនមីក្រូហិរញ្ញវត្ថុ។

#### គ- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាម៉េរិកបន្តមានស្ថិរភាព ជាមធ្យមប្រមាណ ៤ ០៥៥ រៀល ក្នុងមួយដុល្លារអាម៉េរិក (តុលា ២០១៨-កញ្ញា ២០១៩) ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន៤ ០៤៩រៀល ដោយសារការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ក្នុងបរិបទដែលតម្លៃប្រាក់រៀលបានប្រែប្រួលបន្តិចបន្តួចទៅតាមកត្តារដូវកាល ជាពិសេសកំណើនតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយបញ្ចេញប្រាក់រៀលស្មើ១,៤ដងនៃទំហំ ក្នុងឆ្នាំមុន។

### ឃ- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

អតិរេកជញ្ជីងទូទាត់បានបន្តរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដុលដល់ប្រមាណ ១៧,១ ប៊ីលានដុល្លារអាម៉េរិក គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ ដែលអាចធានាលើការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៩ខែ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍ(៣ខែ)។

### ៣- ការងារអភិវឌ្ឍសេដ្ឋកិច្ចជនបទ

ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុប**៣ ៩៩៣ ៨០៤ ១៣៥រៀល** ស្មើនឹង**១ ០១៧ ៦៧៧ដុល្លារអាម៉េរិក** មានអ្នកខ្ចីសរុប **៤ ២៥២នាក់** នៅភូមិគោលដៅ**២៤៤ភូមិ ១២០ឃុំ ៣២ស្រុក** ក្នុងខេត្តគោលដៅ**១៥** គឺខេត្តកំពង់ចាម ត្បូងឃ្មុំ បាត់ដំបង ព្រះសីហនុ តាកែវ កំពង់ស្ពឺ កំពត កោះកុង ពោធិ៍សាត់ សៀមរាប បន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង។

# ចតុកោណយុទ្ធសាស្ត្រទី៣
# ការអភិវឌ្ឍវិស័យឯកជននិងការងារ

ការអភិវឌ្ឍវិស័យឯកជននៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារ និងមានតួនាទីគន្លឹះ ក្នុងការជំរុញកំណើននិងអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។ ក្នុងស្មារតីនេះ ការអភិវឌ្ឍវិស័យឯកជននឹងត្រូវអនុវត្តតាមវិធានការជាកញ្ចប់និងគ្រប់ជ្រុងជ្រោយ។

## មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

### ១- ការបង្កើតការងារ

ក្រសួងបន្តយកចិត្តទុកដាក់លើការបង្កើតបរិយាកាសមុខរបរនិងការងារកាន់តែទូលំទូលាយ ដោយការបង្កើនឱកាសការងារសមរម្យនិងផលិតភាពការងារខ្ពស់ ការពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរនិងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសនិងការពារពលករទេសន្តប្រវេសន៍ខ្មែរ ការបង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារនិងការពង្រីកការផ្តល់សេវារកការងារឱ្យធ្វើ និងការផ្សព្វផ្សាយ ព្រមទាំងការបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនឱកាសការងារប្រកបដោយសមធម៌និងការកាត់បន្ថយការធ្វើទេសន្តប្រវេសន៍ដោយប្រថុយប្រថាន និងការលើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនៅកម្ពុជា។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ និងបានអនុវត្តដោយជោគជ័យនូវកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៦-២០១៨ ព្រមទាំងបានបន្តការអនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣។ ជាក់ស្តែង តាមរយៈការខិតខំរបស់ក្រសួង គិតចាប់ពីខែកក្កដា ឆ្នាំ២០១៨ ដល់ ខែកក្កដា ឆ្នាំ២០១៩ ប្រជាពលរដ្ឋទទួលបានការងារធ្វើថ្មី១៨៨ ៧៥៣នាក់(ស្រី១០៨ ៩៨៤នាក់) ក្នុងនោះក្នុងប្រទេស១២៧ ២៨៣នាក់(ស្រី៨៣ ១១៦នាក់) និងបញ្ជូនទៅធ្វើការនៅក្រៅប្រទេស៦១ ៤៧០នាក់(ស្រី២៥ ៨៦៨នាក់)។

| ពលករ ពលការិនីខ្មែរធ្វើការងារនៅក្នុងប្រទេស | | | | | |
|---|---|---|---|---|---|
| បរិយាយ | | ឯកតា | កញ្ញា ២០១៨ - កក្កដា ២០១៩ | | |
| | | | សរុប | ថ្នាក់កណ្តាល | រាជធានី-ខេត្ត |
| ធ្វើការងារក្នុងប្រទេស | សរុប | នាក់ | **១២៧ ២៨៣** | **៩៤ ៣៨១** | **៣២ ៩០២** |
| | ស្រី | នាក់ | **៨៣ ១១៦** | **៦៦ ១៦៦** | **១៦ ៩៥០** |

| ពលករពលការិនីខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស | | |
|---|---|---|
| បរិយាយ | កញ្ញា ២០១៨-កក្កដា ២០១៩ | |
| | សរុប (នាក់) | ស្រី (នាក់) |
| ប្រទេសថៃ | ៥៣ ២៦៤ | ២៣ ១១០ |
| សាធារណរដ្ឋកូរ៉េ | ៤ ៤៤៤ | ៩០០ |
| ប្រទេសជប៉ុន | ៣ ៤១៩ | ១ ៥៤៥ |

| | | |
|---|---|---|
| ប្រទេសសិង្ហបុរី | ១៧៣ | ១៧៣ |
| ប្រទេសអារ៉ាប់ប៊ីសាអូឌីត | ៦៣ | ៦៣ |
| ប្រទេសម៉ាឡេស៊ី | ៥៦ | ២៦ |
| តំបន់រដ្ឋបាលពិសេសហុងកុង | ៥១ | ៥១ |
| **សរុប** | **៦១ ៤៧០** | **២៥ ៨៦៨** |

## ២- ការគ្រប់គ្រងកម្លាំងពលកម្មក្នុងប្រទេសនិងពលករទេសន្តរប្រវេសន៍ខ្មែរ ដែលកំពុងស្នាក់នៅនិងធ្វើការនៅបរទេស

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសនិងពលករទេសន្តរប្រវេសន៍ខ្មែរ ដែលកំពុងស្នាក់នៅនិងធ្វើការនៅបរទេស ដោយបាននិងកំពុងធ្វើទំនើបកម្ម ដើម្បីសម្រួលការផ្តល់ការប្រើប្រាស់និងការគ្រប់គ្រងសៀវភៅការងារកម្មករនិយោជិតខ្មែរ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលគ្រោងនឹងដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០២០នេះ។ ជាក់ស្តែងចាប់ខែកញ្ញា ២០១៨ ដល់ខែកក្កដា ២០១៩ នេះ ក្រសួងបានផ្តល់សៀវភៅការងារបានចំនួនសរុប**២៤១ ៨៦៦ ក្បាល** ចុះទិដ្ឋាការចូលចំនួន**២៨ ៩៧៦នាក់** ចុះទិដ្ឋាការចេញចំនួន**១៨ ០៤៦នាក់** និងបានប្រមូលអាករចូលរដ្ឋបានចំនួន**២ ៤១៨,៦៦លានរៀល**។ ចុះធ្វើអធិការកិច្ចហត្ថពលកម្មជនបរទេសបានចំនួន**៣ ៦២២**សហគ្រាសគ្រឹះស្ថាន និងពិនិត្យឃើញមានជនបរទេសសរុបចំនួន**៣១ ១៦៥នាក់** ក្នុងនោះ ៩៥,២% មានបណ្ណការងារនិងសៀវភៅការងារជនបរទេស។ ទន្ទឹមនឹងនេះ ក្រសួងបានចេញសៀវភៅការងារជនបរទេសថ្មីនិងចុះទិដ្ឋាការចូលដល់ជនបរទេសសរុបចំនួន**១០៥ ២២៩នាក់** និងបានពន្យារសុពលភាពលើបណ្ណនិងសៀវភៅការងារជនបរទេសសរុបចំនួន**៧០ ៥៩២នាក់** ដោយប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈការប្រមូលអាករជនបរទេសបានថវិកាសរុបចំនួនប្រមាណជា**៩៦ ១៣៦,៩៨លានរៀល** ។

| បរិយាយ | ឯកតា | កញ្ញា ២០១៨ -កក្កដា ២០១៩ | | |
|---|---|---|---|---|
| | | សរុប | ថ្នាក់កណ្តាល | រាជធានី -ខេត្ត |
| **ការងារត្រួតពិនិត្យកម្មករនិយោជិតខ្មែរ** | | | | |
| ផ្តល់សៀវភៅការងារ | នាក់ | ២៤១ ៨៦៦ | ១៤៣ ៦៧៦ | ៩៨ ១៩០ |
| ចុះទិដ្ឋាការចូល | នាក់ | ២៨ ៩៧៦ | ៩ ៣៣២ | ១៩ ៦៤៤ |
| ចុះទិដ្ឋាការចេញ | នាក់ | ១៨ ០៤៦ | ៥៤៣ | ១៧ ៥០៣ |
| ការងារត្រួតពិនិត្យកម្មករនិយោជិតខ្មែរ | លាន រៀល | ២ ៤១៨,៦៦ | ១ ៤៣៧ | ៩៨១,៩០ |
| **ការគ្រប់គ្រងជនបរទេស** | | | | |
| ផ្តល់បណ្ណសៀវភៅការងារថ្មី និងទិដ្ឋាការចូល | នាក់ | ១០៥ ២២៩ | ៧១ ០០៦ | ៣៤ ២២៣ |
| ពន្យារសុពលភាពលើបណ្ណ និងសៀវភៅការងារ | នាក់ | ៧០ ៥៩២ | ៣៨ ៤៧២ | ៣២ ១២០ |
| សរុប | នាក់ | ១៧៥ ៨២១ | ១០៩ ៤៧៨ | ៦៦ ៣៤៣ |
| អាករសរុបដែលប្រមូលបាន | លានរៀល | ៩៦ ១៣៦,៩៨ | ៥៧ ៤៥២,៥៥ | ៣៨ ៦៨៤,៤៣ |

| ការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស | | | | |
|---|---|---|---|---|
| ចំនួនសហគ្រាសដែលបានធ្វើអធិការកិច្ច | សហគ្រាស | ៣ ៦២២ | ២ ៩៤០ | ៦៨២ |
| ចំនួនជនបរទេសដែលពិនិត្យឃើញ | នាក់ | ៣១ ១៦៥ | ១៩ ៣៥៩ | ១១ ៨០៦ |
| ចំនួនអ្នកមានប័ណ្ណនិងសៀវភៅការងារ | នាក់ | ២៩ ៦៩៦ | ១៨ ៧០០ | ១០ ៩៩៦ |
| ចំនួនអ្នកគ្មានប័ណ្ណនិងសៀវភៅការងារ | នាក់ | ១ ៣៨២ | ៦៥៩ | ៧២៣ |

## ៣- ការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ដល់កម្មករនិយោជិត

ដោយផ្អែកតាមស្ថានភាពនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ហើយការប្រកួតប្រជែងនៅក្នុងតំបន់កាន់តែកើនឡើងខ្លាំង ការគ្រប់គ្រងលើតម្លៃពលកម្មនិងការជំរុញផលិតភាពគឺជាកត្តាចំបងក្នុងការរក្សាកំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លីនិងមធ្យម។ ប៉ុន្តែការគ្រប់គ្រងលើតម្លៃពលកម្មតាមរយៈការកំណត់ប្រាក់ឈ្នួលអប្បបរមា គឺជាកត្តាមួយយ៉ាងសំខាន់ក្នុងការទាក់ទាញវិនិយោគិនមកប្រទេសកម្ពុជា និងទាមទារឱ្យមានការសិក្សាស្រាវជ្រាវជាក់លាក់និងតាមបែបវិទ្យាសាស្ត្រ ដោយថ្លឹងថ្លែងពីផលវិជ្ជមាននិងអវិជ្ជមាននៃកម្រិតប្រាក់ឈ្នួលដែលអាចជះឥទ្ធិពលដល់កម្រិតជីវភាពរបស់កម្មករនិយោជិតនិងលទ្ធភាពបង្កើតការងារនៅក្នុងប្រទេស។ ក្នុងឆ្នាំ២០១៩នេះ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានប្រជុំចំនួន២០លើកសម្រាប់ការកំណត់ប្រាក់ឈ្នួលកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរនិងផលិតស្បែកជើង ដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះចំនួន១៩០ដុល្លាអាម៉េរិកសម្រាប់ឆ្នាំ២០២០ ហើយបើបូកនិងប្រាក់អត្ថប្រយោជន៍បន្ថែមកម្មករនិយោជិតម្នាក់អាចទទួលបានប្រាក់ឈ្នួលពី២០៧ទៅ២១៨ដុល្លារអាម៉េរិកក្នុងមួយខែ។

**តារាង ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជា (ជាដុល្លារអាម៉េរិក)**

| **សរុប** | **40** | **50** | **55** | **55** | **66** | **68** | **73** | **83** | **97** | **117** | **145** | **157** | **170** | **187** | **199** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ឈ្នួលអប្បបរមា** | **40** | **45** | **50** | **50** | **61** | **61** | **61** | **61** | **80** | **100** | **128** | **140** | **153** | **170** | **182** |
| ប្រាក់រង្វាន់ធ្វើការទៀងទាត់ | | 5 | 5 | 5 | 5 | 7 | 7 | 10 | 10 | 10 | 10 | 10 | 10 | 10 | 10 |
| ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅ | | | | | | | | 7 | 7 | 7 | 7 | 7 | 7 | 7 | 7 |
| ប្រាក់ថែទាំសុខភាព | | | | | | | 5 | 5 | | | | | | | |
| ប្រាក់ឧបត្ថម្ភជីវភាព | | | | | | | | | | | | | | | |
| **កាលបរិច្ឆេទនៃ ការអនុម័ត** | 1997 | 1 សីហា 2000 | 1 មករា 2007 | 1 មេសា 2008 | 1 តុលា 2010 | 1 មីនា 2011 | 1 មករា 2012 | 1 កញ្ញា 2012 | 1 ឧសភា 2013 | 1 កុម្ភៈ 2014 | 1 មករា 2015 | 1 មករា 2016 | 1 មករា 2017 | 1 មករា 2018 | 1 មករា 2019 |

## ៤- ការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តយកចិត្តទុកដាក់លើការអភិវឌ្ឍរបបសន្តិសុខសង្គមដល់កម្មករនិយោជិតនិងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយបន្តការពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ការបន្តពង្រឹងនិងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ការជំរុញការរៀបចំនិងដាក់ឱ្យដំណើរការរបបប្រាក់សោធន និងការពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យ

សេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងការអភិវឌ្ឍសមត្ថភាព ដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា សំដៅលើកកម្ពស់សុខុមាលភាពនិងសាមគ្គីភាពសង្គម ព្រមទាំងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រជាអតិបរមាជាពិសេសប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន។

ចាប់តាំងពីដំណើរការដំបូងនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ប.ស.ស. បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សរុបចំនួន១៣ ៨៥១ សហគ្រាស មានកម្មករនិយោជិតចំនួន១ ៥៣១ ៧០៧ នាក់ (ស្រី ៩២២ ៨២១នាក់)។ ដោយឡែកចាប់ខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ប.ស.ស. បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានចំនួន១ ៦០៨សហគ្រាស មានកម្មករនិយោជិតចំនួន៦១ ៥៧៩នាក់ (ស្រី៣៥ ៩២៦នាក់)និងបានផ្តល់តាវកាលិកហានិភ័យការងារមានចំនួន១៧ ៦១២ ឯកសារ និងចំណាយអស់ថវិកាចំនួន១៧ ៨៧៥,៦៨ លានរៀល។

ការចុះបញ្ជីការសហគ្រាស គ្រឹះស្ថានផ្នែកហានិភ័យការងារ

| បរិយាយ | សហគ្រាសចុះបញ្ជិកានិងសមាជិកសរុប | | |
|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី |
| ២០០៨-កក្កដា២០១៩ | ១៣ ៨៥១ | ១ ៥៣១ ៧០៧ | ៩២២ ៨២១ |
| | សហគ្រាសចុះបញ្ជិកានិងសមាជិកថ្មី | | |
| កញ្ញា២០១៨-កក្កដា២០១៩ | ១ ៦០៨ | ៦១ ៥៧៩ | ៣៥ ៩២៦ |

ក្នុងការពង្រឹងនិងការពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ប.ស.ស. បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញឆ្នាំ២០១៦ដល់ខែកក្កដា ឆ្នាំ២០១៩ នេះ បានចំនួន១០ ២០១ សហគ្រាស មានកម្មករនិយោជិតចំនួន២ ១៣៤ ៧៦០នាក់(ស្រី១ ៣៥០ ៨៨៦នាក់) និងមានកម្មករនិយោជិតដែលបានទៅប្រើប្រាស់សេវាផ្នែកថែទាំសុខភាពសរុបចំនួន១ ៩៦៨ ៤៣៧ដង/នាក់ និងចំណាយតាវកាលិកផ្នែកថែទាំសុខភាពអស់ចំនួន២២៨,៤៤ប៊ីលានរៀល។ ជាមួយគ្នានេះ ប.ស.ស.ចាប់ដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ប.ស.ស. បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជនចំនួន៣៥ ក្រសួង ស្ថាប័ន និងមានសមាជិកសរុបចំនួន៣១២ ៤២៣នាក់ (ស្រី៩៧ ៧៣៣នាក់) និងមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ដែលបានទៅប្រើសេវាថែទាំសុខភាពសរុបមានចំនួន៦២ ១៥៧ដង/នាក់ និងចំណាយតាវកាលិកអស់ចំនួន១០,១៨ប៊ីលានរៀល។ ជារួមការប្រើប្រាស់សេវាផ្នែកថែទាំសុខភាពសរុបមានចំនួន២ ០៣០ ៥៩៤ ដង/នាក់ និងចំណាយតាវលិកអស់ចំនួន២៣៨,៦២ប៊ីលានរៀល។

**៥- របបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

អនុលោមតាមប្រកាសអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករ និយោជិតក្រៅប្រព័ន្ធដែលអាចប្រើប្រាស់សេវាតាមមូលដ្ឋានសុខាភិបាលពីថ្នាក់បឋម នៅមូលដ្ឋាន សុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។ ជាក់ស្តែង ប.ស.ស.បានចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ចំនួន ៩៤៥ សហគ្រាស មានកម្មករនិយោជិតចំនួន

៨៨ ២០០នាក់(ស្រី ១៧ ៥៨៣នាក់)។ ក្នុងការបើកប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុងនិងក្រៅប្រព័ន្ធត្រូវដាក់ឱ្យអនុវត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨មក។ សម្រាប់ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកក្កដា ឆ្នាំ២០១៩ នេះ ប.ស.ស. បានផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រី សម្រាលកូនបានចំនួន ៦៩ ២៩៥នាក់ ស្មើនឹងចំនួនកូន ៦៩ ៧៧៤ នាក់ ដែលគិតជាទឹកប្រាក់អស់ចំនួន ២៧,៩ប៊ីលានរៀល។

| ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបានចុះបញ្ជិកាក្រៅប្រព័ន្ធ | | | |
|---|---|---|---|
| បរិយាយ | សរុប | | |
| | សហគ្រាស | សមាជិក | ស្រី |
| កញ្ញា ២០១៨ - កក្កដា ២០១៩ | ៩៤៥ | ៨៨ ២០០ | ១៧ ៥៨៣ |

**៦- ការពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តរក្សាស្ថិរភាពទីផ្សារពលកម្ម ទប់ស្កាត់ និងកាត់បន្ថយវិវាទការងារ ការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ការពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញានៅថ្នាក់កណ្តាលនិងថ្នាក់រាជធានី ខេត្ត ការដោះស្រាយទាន់ពេលវេលាករណីរោងចក្រក្ស័យធនឬបិទទ្វារដោយថៅកែរត់ចោល ការបន្តផ្សព្វផ្សាយនិងការបកស្រាយទាន់ពេលវេលាទៅនឹងចម្ងល់នានាអំពីលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធវិស័យការងារ។ ជាក់ស្តែងគិតចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកក្កដា ឆ្នាំ២០១៩ នេះ ក្នុងការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ ក្រសួងបានចុះបញ្ជិកាសហភាពសហជីពមានចំនួន៣ សហព័ន្ធសហជីពមានចំនួន២៥ សហជីពមូលដ្ឋានមានចំនួន៤០៩ និងសមាគមនិយោជកមានចំនួន២។ ក្រសួងបានចេញលិខិតទទួលស្គាល់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈសរុបចំនួន១៦៧ ដែលរួមមាន សហព័ន្ធសហជីពចំនួន២ សហជីពមូលដ្ឋានចំនួន១៦២ សមាគមនិយោជក៣ ហើយក្រសួងក៏បានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យដើម្បីចងក្រងនិងគ្រប់គ្រងទិន្នន័យអង្គការវិជ្ជាជីវៈ សំដៅធានាឱ្យតម្លាភាពនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈក៏ដូចជាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីសហជីព។

ក្នុងការទទួលដោះស្រាយវិវាទការងារ ចាប់ខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកក្កដា ឆ្នាំ២០១៩ នេះ ក្រសួងបានដោះស្រាយវិវាទការងារសរុបចំនួន៧៨៥ ករណី ក្នុងនោះ វិវាទបុគ្គលមានចំនួន៥៦១ ករណី និងវិវាទការងាររួមមានចំនួន២២៤ ករណី។ ក្រសួងបានបន្តជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលបានទទួលដោះស្រាយវិវាទការងាររួមសរុបចំនួន៩១ សំណុំរឿង ដែលក្នុងនោះ សំណុំរឿងចំនួន៦២ ត្រូវបានដោះស្រាយ ដោយចេញសេចក្តីបង្គាប់ សំណុំរឿងចំនួន២៦ ត្រូវបានដោះស្រាយសះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលខ្លួនឯង ហើយសំណុំរឿងចំនួន៣ ត្រូវបានសះជាដោយភាគីទាំងពីរ។ ជាមួយលទ្ធផលនៃការដោះស្រាយវិវាទការងារខាងលើនេះ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាបាតុកម្ម កូដកម្មនៅតាមគ្រប់មុខសញ្ញា បានធ្វើអន្តរាគមន៍ ដោះស្រាយ និងផ្សះផ្សាបញ្ហាកូដកម្មសរុបចំនួន៤៧ករណី ដែលមានកូដករចំនួន២០ ៦៩៨ នាក់ និងដោះស្រាយបាតុកម្មចំនួនសរុប១ករណី ដែលមានបាតុករ៣០០នាក់។

**មុំទី២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព**

**១- ការអភិវឌ្ឍឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យម**

**១.១- សហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម**

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម គឺជាផ្នែកមួយដ៏សំខាន់និងមានឧត្តមភាពខ្ពស់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ដោយបានកំណត់និងដាក់ចេញ

ជាក្របខ័ណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ សំដៅលើកកម្ពស់និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលវែង។ ក្នុងន័យនេះ វិស័យសហគ្រាសធុនតូចនិងមធ្យម មានលទ្ធភាពខ្ពស់និងកាលានុវត្តភាពជំធេងសម្រាប់អភិវឌ្ឍជំនាញ បង្កើតការងារ ជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ តាមរយៈធ្វើពិពិធកម្មមុខទំនិញ នវានុវត្តន៍ ធុរកិច្ចបង្កើតថ្មី សិក្សាបេកគំហើញថ្មីដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ដូចជា ភាពវៃឆ្លាតសិប្បនិមិត្ត ប្រព័ន្ធស្វ័យប្រវត្តិកម្មអេឡិចត្រូនិកជាដើម។ ការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និងការបង្កើនផលិតភាព ព្រមទាំងការធ្វើវិចារណកម្មនិងឯកទេសសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តាមរយៈការអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយនិងនិយ័តកម្ម ដែលមានលក្ខណៈបុរេសកម្ម ដោយឈរលើមូលដ្ឋាននៃឧត្តមានុវត្តន៍។

ចាប់ពីដើមខែកញ្ញា ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩ មានមូលដ្ឋានបង្កើតថ្មី ៦៦ មូលដ្ឋាន ចំនួនពលកម្មកើន៩១២នាក់ និងវិញ្ញាបនបត្របន្តដំណើរការមានចំនួន៧៣មូលដ្ឋាន។ សរុបមកដល់ចុងខែកញ្ញា ឆ្នាំ២០១៩ ចំនួនមូលដ្ឋានសរុប ៥២ ១៥៤និងចំនួនពលកម្មសរុប ៨២៤ ២៤៥ នាក់។

**តារាងទិន្នន័យស្ថិតិសហគ្រាស និងសិប្បកម្ម ត្រឹមខែកញ្ញា ឆ្នាំ២០១៩**

| លេខកូដ | ផ្នែក និងអនុផ្នែក | ដើមឆ្នាំ២០១៩ | | សរុបពីដើមឆ្នាំដល់ចុងខែកញ្ញា | | | | | សរុបពីដើមឆ្នាំដល់ខែរាយការណ៍ | |
|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនមូលដ្ឋាន | ពលកម្ម | ចំនួនមូលដ្ឋាន | | | ពលកម្ម | | ចំនួនមូលដ្ឋាន | ពលកម្ម |
| | | | | កើន | បន្ត | ថយ | កើន | ថយ | | |
| ១០-១២ | ស្បៀង ភេសជ្ជៈ និងថ្នាំជក់ | 41 775 | 324 493 | 42 | 59 | | 550 | | 41 817 | 325 043 |
| ១៣-១៥ | តម្បាញ កាត់ដេរ សម្លៀកបំពាក់ និង ផលិតផលពីស្បែក | 2 448 | 361 128 | 2 | - | | 32 | | 2 450 | 361 160 |
| ១៧-១៨ | ក្រដាស ផលិតផលពីក្រដាស និង បោះពុម្ព | 104 | 7 272 | 2 | - | | 40 | | 106 | 7 312 |
| ១៩-២២ | គីមី និងផលិតផលពីកៅស៊ូ | 469 | 14 023 | 9 | 7 | | 107 | | 478 | 14 130 |
| ២៣ | ឧស្សាហកម្មរ៉ែ ដែលមិនមែនជាលោហៈ | 1 511 | 56 164 | - | 2 | | - | | 1 511 | 56 164 |
| ២៤ | ឧស្សាហកម្មលោហៈមូលដ្ឋាន | 52 | 1 646 | 3 | 2 | | 129 | | 55 | 1 775 |
| ២៥-៣០ | ឧស្សាហកម្មកែច្នៃលោហៈ | 3 229 | 34 918 | 3 | 2 | | 28 | | 3 232 | 34 946 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣២ | ឧស្សាហកម្មផ្សេងៗ | 2 500 | 23 689 | 5 | 1 | | 26 | | 2 505 | 23 715 |
| សរុប | | 52 088 | 823 333 | 66 | 73 | | 912 | | 52 154 | 824 245 |

## ១.២- ការងារស្រែអំបិល

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម (បច្ចុប្បន្នជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រេចការងារដូចខាងក្រោម៖

- នៅឆ្នាំ២០១៨ ការផលិតអំបិលនៅខេត្តកំពតនិងខេត្តកែប ដែលមានផ្ទៃដីនៅសល់ប្រមាណ **៤,៧៤៩.៥៦** ហិកតា ដែលមានសហគមន៍អ្នកផលិតអំបិលជាអ្នកដឹកនាំ សម្របសម្រួលដល់ការងារផលិតកម្មអាជីវកម្ម សរុបចំនួន ២០១ ក្រុមសាមគ្គី ដោយប្រើប្រាស់កម្លាំងពលកម្មសរុបប្រមាណ ៥,០០០នាក់។

- បញ្ហាប្រឈមនៃផលិតកម្មអំបិលគឺមានកត្តាជាច្រើន ក្នុងនោះបញ្ហាកង្វះខាតកំលាំងពលកម្មដោយសារតម្លៃពលកម្មផលិតទាបធៀបនឹងផលិតកម្មដទៃ បញ្ហាដីធ្លី ដែលក្រុមផលិតមួយចំនួនតូចចង់កែប្រែដីផលិតអំបិលទៅជាដីប្រភេទលំនៅដ្ឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងការធ្លាក់ភ្លៀងមិនទៀងទាត់ ដែលជាកត្តាធ្វើឱ្យកង្វះខាតអំបិលសម្រាប់ផ្គត់ផ្គង់ទីផ្សារ។

-ចំពោះបញ្ហាខាងលើ ក្រសួងបានខិតខំរិះរកវិធានការដោះស្រាយ ដើម្បីកាត់បន្ថយការប្រឈមនៃការផលិតអំបិលដោយស្នើរាជរដ្ឋាភិបាលប្រគល់សិទ្ធិកាន់កាប់ដី ជូនដល់សហគមន៍ផលិតអំបិល អាចលក់ដូរ ឬផ្ទេរឱ្យកូនចៅបាន ប៉ុន្តែនៅតែរក្សាការផលិតអំបិលដដែល។ ម្យ៉ាងទៀត ក្រសួងបានពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីរិះរកដំណោះស្រាយសមស្របក្នុងគោលដៅយុទ្ធសាស្ត្រជាតិរបស់ប្រទេសកម្ពុជា ដែលត្រូវរក្សាផលិតកម្មអំបិល ប្រកបដោយស្ថិរភាពនិងចីរភាព។

- ចំពោះមុខ កង្វះខាតអំបិលកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឱ្យសហគមន៍អ្នកផលិតអំបិលនាំចូលអំបិលចំនួន៣០ ០០០តោន ពីប្រទេសចិននិងថៃ ដើម្បីបំពេញកង្វះខាតបណ្ដោះអាសន្ន។

**តារាងទិន្នន័យផ្ទៃដីស្រែអំបិលខេត្តកំពត-កែប**

| លរ. | ឈ្មោះមណ្ឌល | ទំហំស្រែហាល | ទំហំស្រែបណ្ដុះ | អ៊ូ | ទំហំដីសរុប | សមត្ថភាពផលិត តោនឆ្នាំ/ | ចំនួនក្រុម |
|---|---|---|---|---|---|---|---|
| ១ | មណ្ឌលបឹងរូង១ | 648,40 | 92,64 | 69,26 | 810,29 | 13 262,00 | 37 |
| ២ | មណ្ឌលបឹងរូង២ | 406,62 | 78,87 | 159,69 | 645,18 | 9 970,00 | 30 |
| ៣ | មណ្ឌលសេះស | 307,10 | 33,92 | 97,22 | 438,24 | 6 203,00 | 18 |
| ៤ | មណ្ឌលបឹងទូក | 254,27 | 14,64 | 8,97 | 277,87 | 4 953,00 | 08 |
| ៥ | មណ្ឌលកំពង់ត្រាច | 213,40 | 24,34 | 167,07 | 404,81 | 8 004,00 | 07 |
| ៦ | មណ្ឌលត្រើយកោះ | 633,34 | 103,94 | 388,70 | 1 125,98 | 12 377,00 | 78 |

| | | | | | | |
|---|---|---|---|---|---|---|
| សរុបខេត្តកំពត | | 2 463,12 | 348,35 | 890,90 | 3 702,38 | 54 769,00 | 178 |
| ៧ | មណ្ឌលកែប | 586,67 | 170,45 | 264,97 | 1 047,18 | 15 795,60 | 23 |
| សរុបកំពតនិងកែប | | 3 049,79 | 518,80 | 1 155,87 | 4 749,56 | 70 564,60 | 201 |

- នៅក្នុងឆ្នាំ២០១៨ ការផលិតអំបិលពុំបានទទួលលទ្ធផលល្អ ដោយកត្តាអាកាសធាតុដែលមិនអាចធានាការផ្គត់ផ្គង់ក្នុងស្រុកបានគ្រប់គ្រាន់។ ដើម្បីរក្សាតុល្យភាពនៃការផ្គត់ផ្គង់តាមតម្រូវការ ក្រសួងបានគាំទ្រឱ្យមានការនាំចូលអំបិលចំនួន៣០ ០០០តោន ពីប្រទេសចិននិងប្រទេសថៃ។ ដោយឡែក គិតត្រឹមចុងខែឧសភា ឆ្នាំ២០១៩នេះ ការផលិតអំបិលសរុបបានចំនួន១៨ ៤៣០តោន លើផ្ទៃដីទំហំ**៤ ៧៤៩,៥៦**ហិកតា ក្នុងខេត្តកំពតនិងខេត្តកែបនិងមានក្រុមសាមគ្គីចំនួន២០១ ក្រុមសាមគ្គីដែលបានបង្កើតការងារសរុបប្រមាណ៥ ០០០នាក់។

ដើម្បីធានាឱ្យការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មានប្រសិទ្ធភាពល្អប្រសើរ ក្រសួង បានខិតខំជំរុញការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាល និងការងារគ្រប់គ្រងទិន្នន័យពាក់ព័ន្ធវិស័យនេះ ដូចខាងក្រោម៖

- រៀបចំគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម
- បានបង្កើតគោលការណ៍កំណត់ផលិតផលកម្ពុជាមានគុណភាពខ្ពស់ ដើម្បីជំរុញការប្រកួតប្រជែងក្នុងផលិតកម្ម ការលើកកម្ពស់គុណភាពផលិតផល និងការធ្វើពាណិជ្ជកម្មលើទីផ្សារផលិតផលកម្ពុជា
- បាននិងកំពុងរៀបចំអនុក្រឹត្យ ស្តីពីការបង្កើតនិងគ្រប់គ្រងសួនសហគ្រាសធុនតូចនិងមធ្យម
- ចេញប្រកាសរួមរវាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ជាមួយក្រសួងផែនការ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលបានបញ្ចូលជាតិអ៊ីយ៉ូដ
- សេចក្តីសម្រេចបង្កើតក្រុមការងារជំរុញចលនាភូមិមួយ ផលិតផលមួយរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម (បច្ចុប្បន្នជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍)
- សេចក្តីណែនាំ ស្តីពីនីតិវិធីនិងបែបបទសម្រាប់ការផ្តល់អាជ្ញាបណ្ណប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិល ដែលបានបញ្ចូលជាតិអ៊ីយ៉ូដ
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយអង្គការ NOMI ស្តីពីការគាំទ្រនិងពង្រឹងសមត្ថភាពសហគ្រាសធុនតូចនិងមធ្យម លើវិស័យកាត់ដេរ តាមរយៈកិច្ចគាំទ្រកម្មវិធីបណ្តុះបណ្តាលដល់សិប្បករកាត់ដេរសម្លៀកបំពាក់ ចងក្រងសៀវភៅស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដែលបានចុះបញ្ជី
- បោះពុម្ពសៀវភៅឆ្នាំ សហគ្រាសធុនតូចនិងមធ្យមកម្ពុជា
- រៀបចំនិងគ្រប់គ្រងទិន្នន័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មតាមប្រព័ន្ធ Database
- បានរៀបចំចងក្រងសៀវភៅទិន្នន័យនៃសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តាមមូលដ្ឋានរាជធានី ខេត្ត និងតាមប្រភេទ ប្រចាំឆ្នា២០១៨
- ក្រៅពីនេះ ក្រសួងបានធ្វើប្រតិភូកម្មមុខងារដល់ថ្នាក់ក្រោមជាតិ(ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញ) សំដៅធ្វើឱ្យការផ្តល់សេវាដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មនិងសិប្បកម្ម ត្រូវបានពង្រាយ និងបង្អិតជិតទៅដល់អ្នកដែលត្រូវការសេវា ដោយអនុវត្តតាមគោលការណ៍តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស។ ការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលធ្លាប់តែអនុវត្តនៅថ្នាក់កណ្តាល ត្រូវបានផ្ទេរសមត្ថកិច្ចឱ្យទៅមន្ទីរឧស្សាហកម្មនិងសិប្បកម្មរាជធានី ខេត្ត។

## ២-គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១

- ចូលរួមសន្និសីទអន្តរជាតិចលនាភូមិ១ផលិតផល១ និងការតាំងពិព័រណ៍ផលិតផលភូមិ១ ផលិតផល១ មកពី១០ប្រទេស ដែលសន្និសីទនេះរៀបចំដោយក្រសួងកសិកម្មនិងក្រសួងអភិវឌ្ឍន៍ជនបទ នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី១៧ ដល់ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៩

- បើកសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយជាមួយនឹងអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ លើផែនការយុទ្ធសាស្ត្រស្តីពី ការជំរុញចលនាភូមិមួយ ផលិតផលមួយ ៥ឆ្នាំ (២០១៩-២០២៣) លើកទី១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអ្នកចូលរួម**១៤៣នាក់** កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

- សហការជាមួយនឹងក្រសួងពាណិជ្ជកម្ម អង្គការ APCICT-ESCAP អង្គការតម្លាភាពកម្ពុជា (TIC) អង្គការទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) អង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា (CIESF) អង្គការ RESOLVO ក្រុមហ៊ុនកូកាកូឡាកម្ពុជា (Coca-cola) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (LOLC) ដើម្បីបើកវគ្គបណ្តុះបណ្តាលរយៈពេល១ថ្ងៃ ស្តីពីសហគ្រិននិងការផ្តួចផ្តើមឱ្យស្ត្រីប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មាន ក្នុងបរិបទចលនាភូមិ១ផលិតផល១ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដល់ម្ចាស់អាជីវកម្ម សមាគម សហគមន៍ និស្សិត ជាពិសេសស្ត្រី នៅតាមបណ្តាខេត្តចំនួន១១ខេត្ត គឺខេត្តបាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង កំពង់ចាម ព្រៃវែង កំពង់ធំ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ តាកែវ និងខេត្តកំពត ដែលមានសិក្ខាកាមចូលរួមប្រមាណ**៨៤៩នាក់**(ស្រី៤២១នាក់)

- សហការជាមួយគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ ខេត្តកំពង់ចាម រៀបចំទស្សនៈកិច្ចលើកទី២ នៃក្រុមបេសកកម្មទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសថៃ ដើម្បីចុះពិនិត្យនិងសិក្សាស្វែងយល់ពីចង្វាក់ផលិតកម្មផលិតផលខ្មែរ បានចំនួន៤ស្រុក រួមមានស្រុកកោះសូទិន កងមាស ជើងព្រៃ និងស្រុកចំការលើពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩

- សហការជាមួយនឹងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ និងមន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្តព្រះវិហារ ដើម្បីបើកវគ្គបណ្តុះបណ្តាលជូនយោធិនក្នុងអង្គភាពអភិវឌ្ឍន៍ជើងគោកខេត្តព្រះវិហារ លើប្រធានបទ ការកែច្នៃផលិតផលកសិកម្ម ក្នុងក្របខ័ណ្ឌចលនាភូមិ១ ផលិតផល១ ដែលមានសិក្ខាកាមចូលរួម **១០០នាក់** ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩

- សហការជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ (TICA) ក្នុងការដឹកនាំប្រតិភូកម្ពុជា **២០នាក់** ទៅធ្វើទស្សនៈកិច្ចសិក្សាលើការគ្រប់គ្រងនិងសហប្រតិបត្តិការនៃគម្រោង **«ឃុំមួយ ផលិតផលមួយ»** (OTOP) នៅខេត្តសុរិន្ទ ចាប់ពីថ្ងៃទី២៥ ខែសីហា ដល់ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩

- សហការជាមួយវិស័យឯកជនរៀបចំពិព័រណ៍ផលិតផលខ្មែរនិងផលិតផលប្រើប្រាស់ទូទៅនៅខេត្តព្រះសីហនុ ដោយមានការរៀបចំស្តង់ចំនួន២០០ស្តង់ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩

- ចូលរួមពិព័រណ៍ផលិតផលខ្មែរនិងទំនិញនាំចេញ នាំចូលកម្ពុជាលើកទី១៤ ឆ្នាំ២០១៩ រៀបចំដោយក្រសួងពាណិជ្ជកម្ម នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

## ចំណុចទី៣- ការរៀបចំនិងការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន

រាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជនដើម្បីដោះស្រាយសំណើនានា រួមមាន១- ក្រុមការងារផ្នែកកសិកម្ម កសិឧស្សាហកម្ម ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២- ក្រុមការងារផ្នែកទេសចរណ៍ ដឹកនាំដោយឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ៣- ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា ដឹកនាំដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៤- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច ដឹកនាំដោយឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៥- ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ៦- ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ៧- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ៨- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ៩- ក្រុមការងារផ្នែកស្រូវ អង្ករ ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ១០- ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ១១- ក្រុមការងារផ្នែកអប់រំ ដឹកនាំដោយឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ១២- ក្រុមការងារផ្នែកសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង១៣- ក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ ដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

វេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជនលើកទី១៨ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានស្តាប់របាយការណ៍ស្តីពីសកម្មភាពអភិវឌ្ឍន៍ផ្នែកឯកជន ធុរកិច្ច និងការវិនិយោគនាពេលកន្លងមក និងពិនិត្យដោះស្រាយនូវបញ្ហាជាកង្វល់មួយចំនួនរបស់ធុរជននិងវិនិយោគិន ដែលបាននិងកំពុងធ្វើសកម្មភាពបណ្តាក់ទុននៅព្រះរាជាណាចក្រកម្ពុជា។

| **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការវិនិយោគ** | | | |
|---|---|---|---|
| បរិយាយ | គម្រោងថ្មី និង ពង្រីកផលិតកម្ម | ទុនវិនិយោគ | បង្កើតការងារធ្វើ |
| កញ្ញា ២០១៨-សីហា ២០១៩ | ៣៣៧គម្រោង | ៨ ៦៣៤ ៥១០ ៧១០ ដុល្លារអាម៉េរិក | ៣០៧ ៩០៦កន្លែង |
| **១.១- ការវិនិយោគនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស** | | | |
| កញ្ញា ២០១៨-សីហា ២០១៩ | ចំនួន (គម្រោង) | ទុនវិនិយោគ (ដុល្លារអាម៉េរិក) | បង្កើតការងារធ្វើ (កន្លែង) |
| គម្រោងវិនិយោគថ្មី | ២០៥ | ៧ ៦៤៤ ៤៤៥ ១៩២ | ២៣៨ ២៥៥ |

| | | | |
|---|---|---|---|
| ពង្រីកផលិតកម្ម | ៣៤ | ២៣៧ ៥១៨ ៨៦៤ | ៣៤ ៥៣១ |
| **១.២- ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស** | | | |
| គម្រោងវិនិយោគថ្មី | ៩៨ | ៧៥២ ៥៤៦ ៦៥៤ | ៣៥ ១២០ |

**មុំទី៤- ការពង្រឹងការប្រកួតប្រជែង**

**១- ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស**

**១.១- ការនាំចេញអង្ករ**

បរិមាណនាំចេញអង្ករតាមច្រកចេញចូលតែមួយក្នុងឆ្នាំ២០១៩មានចំនួន**៦២០ ១០៦តោន**ថយចុះ**៦ ១១៩តោន** ស្មើនឹង**០,៩៨%** តិចជាងបរិមាណនាំចេញអង្ករក្នុងឆ្នាំ២០១៨ ចំនួន**៦២៦ ២២៥តោន**។ ចំពោះការនាំចេញអង្ករទៅទីផ្សារក្នុងឆ្នាំ២០១៩ មានចំនួន៥៩ប្រទេស ថយចុះ២ប្រទេស ស្មើនឹង**៣,២៨%** តិចជាងការនាំចេញអង្ករទៅទីផ្សារក្នុងឆ្នាំ២០១៨ មានចំនួន៦១ប្រទេស។ ចំណែកឯការនាំចេញអង្ករទៅកាន់ទីផ្សារនាំមុខគេក្នុងឆ្នាំ២០១៩នេះ រួមមានប្រទេសចិនឈរលំដាប់ទី១ មានចំនួន**២៤៨ ១០៥តោន** ប្រទេសបារាំងឈរលំដាប់ទី២ មានចំនួន**៨១ ៩០៥តោន**ប្រទេសហ្គាបុងឈរលំដាប់ទី៣ មានចំនួន **៣៦ ៦៦៣តោន** ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ មានចំនួន**៣៦ ៣៩៧តោន** ប្រទេសអូស្ត្រាលីឈរលំដាប់ ទី៥ មានចំនួន**២៣ ៧៥០តោន** ប្រទេសហូឡង់ឈរលំដាប់ទី៦ មានចំនួន**២១ ៣៩០តោន** ប្រទេសព្រុយណេឈរលំដាប់ទី៧ មានចំនួន**១៩ ៣៩៩ តោន** ប្រទេសអង់គ្លេសឈរលំដាប់ទី៨ មានចំនួន **១៤ ៨៣៦តោន** ប្រទេសអេស្ប៉ាញឈរលំដាប់ទី៩ មានចំនួន**១៣ ៨៧១តោន** និងប្រទេសបែលហ្សិក ឈរលំដាប់ទី១០ មានចំនួន**១២ ៨៧៦តោន**។ បច្ចុប្បន្នក្រុមហ៊ុនដែលបាននាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិមានចំនួន **៨៩ក្រុមហ៊ុន**។

**១.២- ការនាំចេញ នាំចូល**(១ដុល្លារអាម៉េរិក= ៤ ០៥៥រៀល)

(តាមតួលេខគយនិងរដ្ឋាករកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩)

| |
|---|
| ១- **ការនាំចេញ**មានតម្លៃប្រមាណ **៥៨ ០៨៨,៧៤ ប៊ីលានរៀល** ស្មើនឹង ១៤ ៣២៥,២១ **លានដុល្លារអាម៉េរិក** កើនឡើង**១៦,៩៨%** បើធៀបនឹងឆ្នាំមុនក្នុងនោះការកើនឡើងនៃទំនិញក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ**១៦,៣៩%** ផលិតផលនេសាទ**១១,១៣%** កៅស៊ូ**៨,៩៦%**និងវាយនភណ្ឌនិងស្បែកជើង**១៦,១១%**។ រីឯការថយចុះនៃទំនិញមានផលិតផលឈើកែច្នៃ**៤២,៩២%** ។ |
| ២- **ការនាំចូល**មានតម្លៃប្រមាណ **៧៨ ៤៩១,១៧ ប៊ីលានរៀល** ស្មើនឹង១៩ ៣៥៦,៦៤ **លានដុល្លារអាម៉េរិក** កើនឡើង**២៨,២៩%** បើធៀបនឹងឆ្នាំមុន ក្នុងនោះការកើនឡើងនៃទំនិញជីកសិកម្ម**៨៣,២០%** ថ្នាំកសិកម្ម**១៤៨,១៥%**ដែកសំណង់**៤៤,០២%** ស៊ីម៉ងត៍**២,៧០%** ផ្លែឈើនិងបន្លែ**១៥,១៣%** និងការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ**៩,០៣%**។ **រីឯការថយចុះនៃទំនិញ** ស្រូវសាលី**២១,៣១%**គ្រាក់ទ័រនិងគោយន្ត**១៣,១៧%**និងអង្ករ**៥,២៤%**។ |
| ៣- ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាមានឱនភាព**២០ ៤០២,៤២ប៊ីលានរៀល** ស្មើនឹង ៥ ០៣១,៤២**លានដុល្លារអាម៉េរិក**។ |

**១.៣- ការងារពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្មរកចំណូលបាន**១០៧ ៩៨៥ ៦៩៣ ៣៧៦រៀល** ស្មើនឹង**៦២,៧០%**នៃផែនការឆ្នាំ២០១៩ ដែលមាន**១៧២ ១៦៧ ០០០ ០០០**រៀល។

| ការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញដូចជាទំនិញវាយនភណ្ឌ ស្បែកជើង កាបូប និងមួក ព្រមទាំងអាជ្ញាបណ្ណផ្សេងៗសម្រាប់នាំចេញទៅកាន់ទីផ្សារពិភពលោក<br>ឯកតា : គិតជាដុល្លារអាម៉េរិក | | | | |
|---|---|---|---|---|
| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ភាគរយ (%) |
| ១ | ទីផ្សារទ្វីបអាម៉េរិក | **៣ ២២០ ៩៧៣ ៨០៨** | **៣ ៩៣៤ ៥៧៥ ៧៧១** | កើន**២២,១៥** |
| ២ | ទីផ្សារសហគមអឺរ៉ុប | **៣ ៣៤០ ៦២៩ ៤៥៤** | **៣ ២៩៤ ០៥៤ ៩០២** | ថយចុះ**១,៣៩** |
| ៣ | ទីផ្សារចក្រភពអង់គ្លេស | **៩២២ ០៣៨ ៤១៤** | **៨៦៣ ២០១ ៣៨១** | ថយចុះ**៦,៣៨** |
| ៤ | ទីផ្សារទ្វីបអាស៊ី និងអូសេអានី | **៣ ៣៤១ ៥២៥ ៦០៥** | **៣ ៥៧០ ២៨៨ ៨៤៧** | កើនឡើង ៦,៨៤ |
| ៥ | ទីផ្សារទ្វីបអាហ្រ្វិក មជ្ឈិមបូព៌ា និងប្រទេសផ្សេងៗ | **១៨២ ០៣១ ៤២៩** | **២០៣ ០៧០ ៨៩៣** | កើនឡើង**១១,៥៦** |

ក្រសួងពាណិជ្ជកម្មបានចូលរួមពិព័រណ៍នៅក្រៅប្រទេសបាន**៣៣លើក** និងអនុញ្ញាតឱ្យរៀបចំពិព័រណ៍ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសបាន**៥៧លើក**។

| **២- ការត្រួតពិនិត្យស្តង់ដា គុណភាព សុវត្ថិភាព និងផលិតផលទំនិញ** |
|---|
| **២.១- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលមានវិទ្យាស្ថានស្តង់ដាកម្ពុជាជាសេនាធិការ**<br>- ចុះត្រួតពិនិត្យខ្សែចង្វាក់ផលិតកម្មរោងចក្រធុនតូចផលិតទឹកពិសាជបចំនួន**៣៧មូលដ្ឋានផលិតកម្ម**<br>- ចេញវិញ្ញាបនបត្រផលិតផលនិងអាជ្ញាបណ្ណប្រើសញ្ញាបញ្ជាក់ផលិតផលសម្រាប់សិប្បកម្មផលិត**៦៦មូលដ្ឋានផលិតកម្ម** និងចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមប្រើសញ្ញាស្តង់ដាកម្ពុជា សម្រាប់ទឹកពិសាជបចំនួន**៥០មូលដ្ឋានផលិតកម្ម**<br>- ចេញសេចក្តីជូនដំណឹងស្តីពីភាពមិនអនុលោមទឹកពិសាជបចំនួន**១០មូលដ្ឋានផលិតកម្ម**<br>- ចេញអាជ្ញាបណ្ណប្រើប្រាស់សញ្ញាសុវត្ថិភាពផលិតផល**៦៨៧ច្បាប់**។ |
| **២.២- ក្រសួងពាណិជ្ជកម្មដែលមានអគ្គនាយកដ្ឋានកាំកុងត្រូលជាសេនាធិការ (បច្ចុប្បន្នជាអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែងនិងបង្រ្កាបការក្លែងបន្លំ)**<br>- ចុះអង្កេតតាមទីផ្សារនៅទូទាំងប្រទេសបាន**៥៤៩ផ្សារ** ហើយរកឃើញនិងដកហូតទំនិញហួសកាលបរិច្ឆេទប្រើប្រាស់បានមួយចំនួន។<br>- រកចំណូលបាន**១៤ ៦១៨ ៦៥៨ ០០០រៀល** ថយចុះ**១១២ ៥០២ ៩៤៣ ៩៦៩រៀល** ស្មើនឹង៨៨,៥០% បើធៀបនឹងឆ្នាំមុន។ |
| **២.៣- ការងារឧស្សាហកម្ម**<br>- ក្រសួងបានចុះបញ្ជីរោងចក្រធុនធំបានចំនួន**១ ៦៨៦រោងចក្រ** និងប្រើប្រាស់កម្លាំងពលកម្មសរុប ចំនួន **១ ០២៧ ៩៤៨នាក់**<br>- ក្នុងរយៈពេលមួយឆ្នាំ(កញ្ញា ២១០៨-កក្កដា ២០១៩) មានរោងចក្រកើតថ្មីចំនួន**២៧៥រោងចក្រ** កើនឡើង៣៨% បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុនមានរោងចក្រកើតថ្មីចំនួន**១៥៦រោងចក្រ** |

- ផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ ចាក់សម្លៀកបំពាក់ ស្បែកជើង និងកាបូប នៅតែមានសក្តានុពលនិងកម្លាំងនៃការបង្កើតអនុបាតនិងកំណើនវិស័យឧស្សាហកម្ម។

## ៣- ការត្រួតពិនិត្យសុវត្ថិភាពនិងសន្តិសុខនៅតាមអាកាសយានដ្ឋានអន្តរជាតិ

**៣.១- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ៖**

- ពិនិត្យឃើញបទល្មើសច្បាប់អន្តោប្រវេសន៍មាន**៩៥៣លើក** ពាក់ព័ន្ធអ្នកដំណើរ១ ៨១០នាក់ (ស្រី២៩៣នាក់) មាន**៦៧សញ្ជាតិ** ផ្អាកដំណើរមិនឱ្យចូលប្រទេសកម្ពុជានិងបញ្ជូនត្រឡប់ទៅវិញមាន**៩៩លើក** ពាក់ព័ន្ធអ្នកដំណើរ **៩៣០នាក់**(ស្រី៦៥នាក់) មាន**៥៣សញ្ជាតិ** និងបញ្ជូនជនបរទេសចេញពីប្រទេសកម្ពុជា**៣៧១លើក** មានមនុស្ស១ **១៣៤នាក់** (ស្រី១៥៧នាក់) មាន**១១សញ្ជាតិ**
- ទទួលប្រជាពលរដ្ឋខ្មែរឱ្យត្រឡប់មកមាតុភូមិវិញ**២៩៧លើក** មានមនុស្ស**៧៧៧នាក់** (ស្រី៣១៥នាក់)
- ចាប់ឃាត់បណ្តោះអាសន្ននូវគ្រឿងបន្លាស់ម៉ាស៊ីនល្បែង**២ករណី**
- បង្ក្រាបរូបិយបណ្ណរត់ពន្ធ**៨៦ករណី** ស្មើនឹងប្រាក់ពិន័យ**៥ ៦៨៥ ៩០៩ដុល្លារអាមេរិក** បង្ក្រាបគ្រឿងញៀនចំនួន**១ករណី** ស្មើនឹង**១ ៦២៨ក្រាម** និងបង្ក្រាបអាហារបំប៉នក្នុងទម្រង់គ្រាប់ (Food Supplement Product)**១ករណី** ដែលមាន **១៤៣កេស** ស្មើនឹង**៨៥៥គីឡូក្រាម** ទាំងសំបកវេចខ្ចប់
- បង្ក្រាបសំណាកឆ្អឹងសត្វ**១ករណី** មាន**៥កេស**ស្មើនឹង**២៨២គីឡូក្រាម**។

**៣.២- អាកាសយានដ្ឋានអន្តរជាតិសៀមរាប**

- ពិនិត្យឃើញបទល្មើសចូលប្រទេសកម្ពុជា**៨៨លើក**ចំនួន**៨០នាក់** និងពិនិត្យឃើញបទល្មើសចេញពីប្រទេសកម្ពុជា**២៤**លើក ចំនួន**៦៦នាក់**
- ទទួលប្រជាពលរដ្ឋខ្មែរឱ្យត្រឡប់មកមាតុភូមិវិញ**៨ករណី** ចំនួន**២៦នាក់**
- បដិសេធផ្តល់ទិដ្ឋាការនិងបញ្ជូនចេញសរុប**៤០នាក់**
- បង្ក្រាបអំពើរត់ពន្ធសារធាតុញៀន**២ករណី** ប្រភេទមេតំហ្វេតាមីន ដែលករណីទី១ មានទម្ងន់**៤៦៥១ក្រាម** និងករណីទី២ មានទម្ងន់**២៣,៣០គីឡូក្រាម** និងបង្ក្រាបរូបិយបណ្ណរត់ពន្ធ**២ករណី** ដែលមានទឹកប្រាក់ **២ ២៣៦ ០០០ដុល្លារអាមេរិក**។

## ៤- ការត្រួតពិនិត្យភូតគាមអនាម័យនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

**៤.១- ការត្រួតពិនិត្យការនាំចូលបន្លែនិងផ្លែឈើ :** ត្រួតពិនិត្យផ្លែសាឡាក់**៦៣លើក**មានបរិមាណ**២៩២ ១៩៧គីឡូក្រាម**និងត្រួតពិនិត្យកូនចេក**១២លើក** មានបរិមាណ**១៤ ០៤១គីឡូក្រាម** (២ ៩៣៧ ៦០០ដើម)។

**៤.២- ការត្រួតពិនិត្យការនាំចេញបន្លែនិងផ្លែឈើ :** ត្រួតពិនិត្យបន្លែនាំចេញទៅកាន់ប្រទេសបារាំង អង់គ្លេស និងប្រទេសឆេក មានបរិមាណ**១៥៧ ១៩៤គីឡូក្រាម** និងត្រួតពិនិត្យផ្លែស្វាយនាំចេញទៅកាន់ប្រទេសបារាំង សាធារណរដ្ឋកូរ៉េ រុស្ស៊ី និងទីក្រុងហុងកុង មានបរិមាណ**១៣០ ៤៨៤គីឡូក្រាម**។

## ចតុកោណយុទ្ធសាស្ត្រទី៤
## ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

ទន្ទឹមនឹងការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

**មុំទី១- ការលើកស្ទួយវិស័យកសិកម្មនិងអភិវឌ្ឍជនបទ**

**១- ការលើកស្ទួយវិស័យកសិកម្ម**

ក- ផលិតកម្មស្រូវ ដំណាំរួមផ្សំ និងឧស្សាហកម្មរួមផ្សំ

| **ផលិតកម្មស្រូវ** | | |
|---|---|---|
| **១- ការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សា** | | |
| បរិយាយ | ២០១៨ | ២០១៩ |
| ផ្ទៃដីភ្ជួររាស់ | ៣ ០០៦ ៥៣៩ ហ.ត. | ២ ៨១៥ ៩៩១ ហ.ត. |
| ផ្ទៃដីសាប (ហ.ត.) | ៣៦ ៦៧៣ ហ.ត. | ២៣ ៧១៥ ហ.ត. |
| ផ្ទៃដីស្ទូងនិងព្រោះ | ២ ៧៣៩ ៤៤៦ហ.តស្មើនឹង ១០៨,៩៧% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត. | ២ ៧៣១ ៣៣៨ហ.ត. ស្មើនឹង១០៥,៦១% នៃផែនការ ២ ៥៨៦ ១៥២ហ.ត. |
| ភ្ជួររាស់ដោយគោក្របី | ១០៧ ១១៤ហ.ត. ស្មើនឹង៣,៥៦% | ៣២ ៧៧៩ហ.ត. ស្មើនឹង១,១៦% |
| ដោយគ្រឿងយន្ត | ២ ៨៩៩ ៤២៥ហ.ត. ស្មើនឹង៩៦,៤៣% | ២ ៧៨៣ ២១២ហ.ត. ស្មើនឹង៩៨,៨៤% |
| **២- ការងារប្រមូលផលស្រូវរដូវវស្សា** | | |
| ប្រមូលផលស្រូវរដូវវស្សា | ២ ៦៥៤ ៣១៤ហ.ត. បរិមាណផលសរុប ៨ ២១២ ៨៩៣តោន | ២ ៥១៧ ២៦៦ហ.ត. បរិមាណផលសរុប៧ ៩១២ ០៤១តោន |
| ទិន្នផលគិតជាមធ្យម | ៣,០៩៤តោន/ហ.ត. | ៣,០៩៥តោន/ហ.ត. |
| **៣- ផលិតកម្មស្រូវប្រាំង** | | |
| បរិយាយ | ២០១៨-២០១៩ | ២០១៩-២០២០ |
| ផ្ទៃដីភ្ជួររាស់ | ៦៣២ ០៥៦ហ.ត. | ៦០៣ ៣១២ហ.ត. |
| ផ្ទៃដីសាប | ១៧២ហ.ត. | ៧៤ហ.ត. |
| ផ្ទៃដីស្ទូងនិងព្រោះ(ហ.ត.) | ៥៩៦ ៤៨៣ហ.ត. ស្មើនឹង ១៣៣,២៩% នៃផែនការ ៤៤៧ ៥០០ហ.ត. | ៥៩៧ ៥០៨ហ.ត. ស្មើនឹង ១៣០,០១% នៃផែនការ ៤៥៩ ៥៩៤ហ.ត. |

| | | |
|---|---|---|
| ប្រមូលផលស្រូវរដូវប្រាំង | ៤២៥ ៨៥៣ហ.ត. បរិមាណផល សរុប ១ ៩០២ ៦៤២តោន | ៤៧៨ ៨២៣ហ.ត. បរិមាណផល សរុប២ ១៥០ ១០៨តោន |
| ទិន្នផលគិតជាមធ្យម | ៤ ៤៦៨តោន/ហ.ត. | ៤ ៤៩០តោន/ហ.ត. |
| **ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម** | | |
| ដំណាំរួមផ្សំមាន ពោតស ដំឡូងជ្វា បន្លែ ម្ទេស និងឪឡឹក(រដូវវស្សា) | ៥០ ៤៣៤ហ.ត. ស្មើនឹង ១១០,៥៣% នៃផែនការ ៤៨ ៧៣១ហ.ត. | ៥៦ ៩១៧ហ.ត. ស្មើនឹង ១១០,៥៣% នៃផែនការ ៥១ ៤៩២ហ.ត. |
| ដំណាំឧស្សាហកម្មមាន ពោតក្រហម ដំឡូងមី សណ្តែកដី សណ្តែកបាយ សណ្តែកសៀង ល្ង អំពៅ ថ្នាំជក់ ឈូកនិងក្រចៅ(រដូវវស្សា) | ៩១៧ ៧០៣ហ.ត. ស្មើនឹង ១១១,៧៥% នៃផែនការ ៨២១ ២១៧ហ.ត. | ៨៨៣ ១៧០ហ.ត. ស្មើនឹង ១០៥,៣៦% នៃផែនការ ៨៣៨ ២២០ហ.ត. |

គិតត្រឹមឆ្នាំ២០១៩នេះ ការងារបង្កបង្កើនផលរដូវប្រាំងទូទាំងប្រទេស សម្រេចបាន៥៩៧ ៥០៨ ហ.ត. ស្មើនឹង១៣០,០១% នៃផែនការ៤៥៩ ៥៩៤ហ.ត. និងការងារបង្កបង្កើនផលរដូវវស្សាទូទាំងប្រទេសសម្រេចបាន ២ ៧៣១ ៣៣៨ហ.ត. ស្មើនឹង១០៥,៦១% នៃផែនការ២ ៥៨៦ ១៥២ហ.ត។ ភ្ជួររាស់ដោយគោក្របី ៣២ ៧៧៩ ហ.ត ស្មើនឹង១,១៦% និងដោយគ្រឿងយន្ត២ ៧៨៥ ៥៤៤ហ.ត ស្មើនឹង៩៨,៨៤%។ ដំណាំរួមផ្សំរដូវប្រាំងមាន ពោតស ដំឡូងជ្វា បន្លែ ម្ទេស និងឪឡឹក អនុវត្តបាន៣៧ ៦២៦ហ.ត. ស្មើនឹង១១៦,១២%នៃផែនការ៣២ ៤០៣ ហ.ត. លើសឆ្នាំមុន២ ៧១៥ហ.ត. និងដំណាំឧស្សាហកម្មរដូវប្រាំងមានពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកដី សណ្តែកសៀង ល្ង អំពៅ ក្រចៅ ថ្នាំជក់ និងឈូកអនុវត្តបាន ៧៩ ២៧៤ហ.ត. ស្មើនឹង៧៤,៨៨%នៃផែនការ១០៥ ៨៧៣ហ.ត. តិចជាងឆ្នាំមុន១០ ៣៦៧ហ.ត.។

### ខ- ផលិតកម្មដំណាំកៅស៊ូ

| ផលិតកម្មដំណាំកៅស៊ូ | ២០១៨ | ២០១៩ |
|---|---|---|
| ផ្ទៃដីចម្ការកៅស៊ូ | ៤៣៦ ៦៨២ហ.ត. | ៤០៥ ៦១៧ហ.ត. |
| ផ្ទៃដីអាជីវកម្ម | ២០១ ៩៥០ហ.ត. | ២៥០ ៤៧៧ហ.ត. |
| ផលិតផលអនុវត្តបាន | ២២០ ១០០តោន | ២៨៧ ៦៣៨តោន |
| បរិមាណបញ្ចេញលក់ | ២១៧ ៥០០តោន | ២៨២ ០៧១តោន |
| ជ័រកៅស៊ូមានតម្លៃជាមធ្យម | | ១ ៣៣៦ដុល្លារអាម៉េរិក/តោន |

ក្នុងឆ្នាំ២០១៩នេះ សរុបផ្ទៃដីចម្ការកៅស៊ូរដ្ឋរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានិងឯកជនចំនួន ៩ក្រុមហ៊ុន គឺ ១-ក្រុមហ៊ុនសុកគ្គីនីកាអ៊ិនវេសមេនគ្រុប ២-ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ ៣-ក្រុមហ៊ុនចម្ការកៅស៊ូ មេមត់ខូអិលធីឌី ៤-ក្រុមហ៊ុនស៊ីហ្វរ៉ាប់បើលីមីធីត ខេត្តរតនគិរី ៥-ក្រុមហ៊ុនស៊ីហ្វវីសសស់ (ស្នួល) ៦-ក្រុមហ៊ុន ចម្ការកៅស៊ូឡុងស្រេង (បឹងកេត) ៧-ក្រុមហ៊ុនអានម៉ាឌីគ្រុប (ចម្ការអណ្តូង) ៨-ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) និង៩-ក្រុមហ៊ុនក្រេក(ខេមបូឌា ខូអិលធីឌី) ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច ព្រមទាំង ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ មានផ្ទៃដីចម្ការកៅស៊ូ៤០៥ ៦១៧ហ.ត. ក្នុងនោះ ផ្ទៃដីអាជីវកម្ម២៥០ ៤៧៧ហ.ត.ស្មើនឹង៦២% ផលិតផលអនុវត្តបាន២៨៧ ៦៣៨តោន កើនឡើង៦៧ ៥៣៨

តោន ស្មើនឹង៣១% បើធៀបនឹងឆ្នាំមុន។ បរិមាណបញ្ចូលក់២៨២ ០៧១តោន កើនឡើង៦៤ ៥៧១តោន ស្មើនឹង៣០%បើធៀបនឹងឆ្នាំមុន។ ជ័រកៅស៊ូមានតម្លៃជាមធ្យម១ ៣៣៦ដុល្លារអាម៉េរិក/តោន កើនឡើង១៩ដុល្លារអាម៉េរិក/តោន ស្មើនឹង១% បើធៀបនឹងឆ្នាំមុន។

**គ- លទ្ធផលនៃការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម**

សកម្មភាពបោសសំអាតមីនដោយប្រតិបត្តិករធំៗ៧ រួមមាន កងយោពលខេមរភូមិន្ទ អង្គភាពស៊ីម៉ាក់ (CMAC) អង្គការហាឡូត្រាស់ អង្គការអាប៉ូប៉ូ អង្គការម៉ែក អង្គការដោះមីនកម្ពុជា និងអង្គការអិនភីអេ។

| បរិយាយ | ២០១៨ | ២០១៩ | ប្រៀបធៀប |
|---|---|---|---|
| មីនប្រឆាំងមនុស្ស(គ្រាប់) | ១៤ ៧៨៨ | ១៥ ៨០៨ | កើន ១០២០ |
| មីនប្រឆាំងរថក្រោះ (គ្រាប់) | ១៩១ | ៣៤២ | កើន ១៥១ |
| សំណល់ជាតិផ្ទុះពីសង្គ្រាម (គ្រាប់) | ៥២ ១៦៥ | ៥៥ ៣០៦ | កើន ៣ ១៤១ |
| ផ្ទៃដីសម្រេចបាន (ម$^{២}$) | ១២៤ ៣២៣ ០២១ | ១៣០ ០៨៤ ៧៣៥ | កើន ៥ ៧៦១ ៧១៥ |
| ជនរងគ្រោះដោយសារមីន(នាក់) | ៥៨ | ៧៧ | កើន ១៩ |

គិតចាប់ពីឆ្នាំ១៩៩២ មកដល់ខែធ្នូ ឆ្នាំ២០១៩ ប្រតិបត្តិករទាំង៧ បានធ្វើការបោសសម្អាតមីនសម្រេចផ្ទៃដី១ ៩៧៩ ៤៧៦ ៦២៣ម$^{២}$ រកឃើញមីនប្រឆាំងមនុស្ស១ ០៨០ ៨១៤គ្រាប់ មីនប្រឆាំងរថក្រោះ២៥ ១៨៦ គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាម ២ ៨៣២ ៦២៦គ្រាប់។

**ឃ- អាជីវកម្មវិស័យជលផលនិងការងារវារីវប្បកម្ម**

| **១- ការងារអាជីវកម្មវិស័យជលផល** | | |
|---|---|---|
| បរិយាយ | ២០១៨ | ២០១៩ |
| **ក- អាជីវកម្មនេសាទទឹកសាប** | | |
| ដាយត្រី | ១៦ ៩៧៥តោន ស្មើនឹង១៤១,៤៦% នៃផែនការ ១២ ០០០តោន | ១៤ ៣២០តោន ស្មើនឹង១១៩,៣៣% នៃផែនការ១២ ០០០តោន |
| ការនេសាទគ្រួសារក្នុងដែននេសាទ | ៣៦០ ៧៣០តោន ស្មើនឹង១០៤,៥៦% នៃផែនការ ៣៤៥ ០០០តោន | ៣២៦ ៥០០តោនស្មើនឹង៩៤,៦៤% នៃផែនការ៣៤៥ ០០០តោន |
| ការនេសាទគ្រួសារតាមវាលស្រែ | ១៥៧ ៣០០តោន ស្មើនឹង១០៨,៤៨% នៃផែនការ ១៤៥ ០០០តោន | ១៣៨ ០៣០តោនស្មើនឹង៩៥,១៩% នៃផែនការ១៤៥ ០០០តោន |
| **ខ- អាជីវកម្មនេសាទសមុទ្រ** | | |
| ការនេសាទសមុទ្រ | ១២១ ១០០តោន ស្មើនឹង១០០,០៩% នៃផែនការ ១១០ ០០០តោន | ១២២ ២៥០តោន ស្មើនឹង១១១,១៤% នៃផែនការ១១០ ០០០តោន |
| **២- ការងារវារីវប្បកម្ម** | | |
| ការចិញ្ចឹមត្រីនិងបង្គា | ២៥៤ ០៤៨តោនស្មើនឹង ១០១,៦២% នៃផែនការ ២៥០ ០០០តោន | ៣០៧ ៤០៨តោន ស្មើនឹង១០២,៤៧% នៃផែនការ៣០០ ០០០តោន |
| ការចិញ្ចឹមក្រពើ | ៤១០ ០០០ក្បាល ស្មើនឹង ១៣៦,៦៧% នៃផែនការ ៣០០ ០០០ក្បាល | ៤១២ ៨១១ក្បាល ស្មើនឹង១៣៧,៦០% នៃផែនការ៣០០ ០០០ក្បាល |

| | | |
|---|---|---|
| ការភ្ញាស់កូនត្រីពូជ | ២១០ ០០០ ០០០កូន ស្មើនឹង៩៥,៤៥% នៃផែនការ ២២០ ០០០ ០០០កូន | ២២២ ០០០ ០០០កូន ស្មើនឹង១០០%នៃផែនការ២២២ ០០០ ០០០កូន |
| **៣- ការកែច្នៃ និងនាំចេញផលនេសាទ** | | |
| **ក- ការកែច្នៃផលនេសាទ** | | |
| ផលនេសាទទឹកសាបក្នុងរដូវនេសាទ | ៧៣ ០០០តោន ស្មើនឹង ៨៩,០២% នៃផែនការ ៨២ ០០០តោន | ៧២ ០៧៥តោន ស្មើនឹង៨៧,៩០%នៃផែនការ ៨២ ០០០តោន |
| ផលនេសាទសមុទ្រ | ១០ ៧៣៥តោនស្មើនឹង ១១៩,២៨% នៃផែនការ ៩ ០០០តោន | ៧ ១០៥តោន ស្មើនឹង៧៨,៩៤%នៃផែនការ៩ ០០០តោន |
| ការផលិតទឹកត្រី | ៥៨ ០០០ ០០០លីត្រ ស្មើនឹង៩៦,៦៧% នៃផែនការ ៦០ ០០០ ០០០ លីត្រ | ៤៥ ០០០ ០០០លីត្រ ស្មើនឹ៧៥,០០% នៃផែនការ៦០ ០០០ ០០០លីត្រ |
| **ខ- ការនាំចេញផលនេសាទ** | | |
| ផលនេសាទស្រស់នាំចេញ | ៩ ៥០០តោន ស្មើនឹង ៦៣,៣៣% នៃផែនការ ១៥ ០០០តោន | ៩ ១៩០តោន ស្មើនឹង៦១,២៧% នៃផែនការ១៥ ០០០តោន |
| ផលនេសាទកែច្នៃ | ៥ ០០០តោន ស្មើនឹង ១០០% នៃផែនការ ៥ ០០០តោន | ៤ ៩១០តោន ស្មើនឹង៩៨,២០% នៃផែនការ៥ ០០០តោន |
| **៤- ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសនេសាទ** | | |
| សំណុំរឿងបទល្មើសជលផល | ៣ ២០៤ករណី (បទល្មើសទឹកសាប ២ ៩៧០ករណី និងសមុទ្រ ២៣៤ករណី) | ៣ ១០១ករណី (បទល្មើសទឹកសាប ២ ៨៧៣ករណី និងសមុទ្រ២២៨ករណី) |

**ង- ការងារសុខភាពសត្វនិងផលិតកម្មសត្វ**

**ង.១- ការងារសុខភាពសត្វ :** ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ នៅរាជធានីនិងខេត្តចំនួន២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគ២៣៤ ៦២៥លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តទូទាំងប្រទេសបាន៤១០ករណី ក្នុងនោះចាប់ឃាត់ខ្លួន៦២ករណី ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ៣៤៨ករណី និងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឱ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។

**ង.២- ផលិតកម្មសត្វ**

ក្នុងឆ្នាំ២០១៩ ផលិតកម្មសត្វមានការកើនឡើងជាពិសេសការចិញ្ចឹមសត្វសម្រាប់ឧស្សាហកម្ម។ ជាក់ស្តែង សត្វចិញ្ចឹម(ជាលក្ខណៈគ្រួសារនិងលក្ខណៈពាណិជ្ជកម្ម)សរុបបានកើនឡើងដល់៤៥,៨៥លានក្បាល គឺកើនលើសឆ្នាំ២០១៨ ចំនួន៣,៣% ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណ២៣៩ពាន់តោនឬស្មើនឹង៨២% នៃតម្រូវការសាច់សរុបប្រមាណ២៩០ពាន់តោនក្នុងមួយឆ្នាំ។

| បរិយាយ | ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ | | | ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម | | |
|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ប្រៀបធៀប | ២០១៨ | ២០១៩ | ប្រៀប ធៀប |
| គោ | ២ ៩១៧ ៣០២ | ២ ៧៦៩ ៨៨៥ | -៥% | ១១ ២៣២ | ៩ ៨៧៧ | -១២,១% |
| ក្របី | ៥០០ ៧៧៨ | ៤៤៧ ១៦៧ | -១០,៧% | ២១៧ | ២១៨ | ០,៥% |
| កម្លាំង អូសទាញ | ៨៣៦ ៣០១ | ៧១៧ ៩០២ | -១៤,១% | - | - | - |
| ជ្រូក | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | -៤៦,៧% | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ៤២,១% |
| បក្សី | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | -៤,១% | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ៣៧,១% |
| សេះ | ៤ ២០៧ | ៣ ៧៧១ | -១០,៤% | ៨៩ | ៣០ | -៦៦,៣% |
| ចៀម | ៤៥៩ | ៦៤៨ | ៤១,២% | | | |
| ពពែ | ២៥ ៧៤៧ | ២៧ ៧៤០ | ៧,៧% | ៧០០ | | |
| ដំរី | ៥៨ | ១៨ | -៧១,៤% | | | |
| ស្វា | | | | | ១៤ ០៧៩ | ១០០% |
| **សរុប** | **៣៤ ៧២៦ ១១១** | **៣២ ៧៦១ ១០៤** | **-៦,៨៧%** | **១០ ០៣៥ ៥៨៥** | **១៣ ៨១១ ៦០៩** | **៣៧,៦%** |

ការជំរុញផលិតកម្មសត្វនិងបង្កើនផលិតភាពសត្វ ជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វមានលក្ខណៈពាណិជ្ជកម្មមានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងពី៨,២៦លានក្បាលនៅឆ្នាំ២០១៥ កើនដល់១៣,៨១លានក្បាលនៅក្នុងឆ្នាំ២០១៩។ ដោយឡែកនៅឆ្នាំ២០១៩នេះ ផលិតកម្មសត្វមានលក្ខណៈពាណិជ្ជកម្មមានកំណើន៣៧,៦%ក្នុងនោះផលិតកម្មជ្រូកមានលក្ខណៈពាណិជ្ជកម្មមានកំណើន៤២,១%និងផលិតកម្មបក្សីមានកំណើន៣៧,១%។ អត្រានៃកំណើនផលិតកម្មសត្វមានលក្ខណៈពាណិជ្ជកម្មនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមាន ដើម្បីឈានទៅកែលម្អផលិតភាពសត្វនិងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។ អត្រាចិញ្ចឹមសត្វមានលក្ខណៈពាណិជ្ជកម្មបានកើនពី២៣%នៅឆ្នាំ២០១៨ ដល់៣០%ក្នុងឆ្នាំ២០១៩។ ដោយឡែក អត្រាចិញ្ចឹមសត្វជាលក្ខណៈគ្រួសារបានថយចុះពី៧៧%នៅឆ្នាំ២០១៨មក៧០%ក្នុងឆ្នាំ២០១៩។

| បែបផែន ផលិតកម្មសត្វ | ស្ថិតិផលិតកម្មសត្វសរុប តាមបែបផលិតកម្មពីឆ្នាំ២០១៨-២០១៩ | | ប្រៀបធៀប២០១៩/ ២០១៨ |
|---|---|---|---|
| | ២០១៨ | ២០១៩ | |
| លក្ខណៈគ្រួសារ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | -៦,៧% |
| លក្ខណៈពាណិជ្ជកម្ម | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ៣៧,៦% |
| សរុប | **៤៤ ៣៧៥ ៣៩៥** | **៤៥ ៨៥៥ ១៤៣** | **៣,៣%** |

### ង.៣- តម្រូវការសត្វនិងសាច់

ផ្អែកតាមរបាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ការបរិភោគសាច់សត្វនៅកម្ពុជាក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៧,៦០គ.ក្រ. ក្នុងនោះសាច់គោ សាច់ក្របី៥ គ.ក្រ. សាច់ជ្រូក៩,២៩គ.ក្រ. សាច់បក្សី៣,៣គ.ក្រ. និងសាច់សត្វផ្សេងៗទៀត០,០១គ.ក្រ.។

| តម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែមឆ្នាំ២០១៩ | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | កង្វះខាត(ផែនការ) | |
| | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល |
| គោ ក្របី | ៨២ ៤៥០ | ៧៥០ | ៨៩ ៣៩៥ | ៨១២ | ៦ ៩២៥ | ៦៣ |
| ជ្រូក | ១៥៣ ១៩២ | ៣ ០៦៤ | ១០២ ៧៨៦ | ២ ០៥៦ | -៥០ ៤០៦ | -១ ០០៨ |
| បក្សី | ៥៤ ៤១៧ | ៤៥ ៣៤៨ | ៤៦ ៩៥៤ | ៣៩ ១២៩ | -៧ ៤៦៣ | -៦ ២១៩ |
| ផ្សេងៗ | ១៦៥ | ១៤ | - | - | -១៦៥ | -១៤ |
| **សរុប** | **២៩០ ២២៤** | | **២៣៩ ១៣៥** | | **-៥១ ១០៩** | |

### ង.៤- ការនាំចេញសត្វនិងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីអាហារ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។

| នាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វ | | | |
|---|---|---|---|
| ប្រភេទសត្វនិងផលិតកម្មសត្វ | ឯកតា | ២០១៨ | ២០១៩ |
| គោ ក្របី | ក្បាល | ៦ ៧៨៦ | ៥៦ ២១៨ |
| ជ្រូកពូជ(មេ បោ) | ក្បាល | ៥០៥ | ២០០ |
| ជ្រូកពូជ(កូន) | ក្បាល | ៥ ០០០ | |
| ស្វាក្តាម | ក្បាល | ១០ ៤៧២ | ១៦ ១៩៦ |
| សាច់គោ | តោន | ១២ | |
| ទឹកដោះគោ | តោន | ៧ ៥៥៨ | ៣ ៩៨៤ |
| ចំណីឆ្កែ | តោន | ១ ៤៩៤ | ១ ០១១ |
| រោមសត្វ | តោន | ២៤ | ៨ |
| ស្បែកគោ ក្របី ជ្រូក | តោន | ១ ២៧៥ | ១ ៤៤០ |

### ង.៥- អំពីចំណីសត្វ

ការងារចំបង គឺការរៀបចំកម្មវិធីកែលម្អចំណីសត្វ ផ្សព្វផ្សាយពូជស្មៅ ដែលសំបូរទៅដោយសារជាតុចិញ្ចឹមនិងផ្តល់ទិន្នផលខ្ពស់។ បច្ចុប្បន្នបានពង្រីកកម្មវិធីដំណាំចំណីសត្វនៅទូទាំង២៥រាជធានី ខេត្ត សរុបមានកន្លែងធ្វើបង្ហាញចំនួន១ ០៣២កន្លែង លើផ្ទៃដីចំនួន៣៨៤,៣៨ហិកតា។

បច្ចុប្បន្ន ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វនៅក្នុងប្រទេសកម្ពុជាមានចំនួន១៦ក្រុមហ៊ុន និងមានរោងចក្រផលិតចំណីសត្វសរុប១៨កន្លែង ដែលមានសមត្ថភាពផលិតចំណីសត្វបានប្រមាណជាង២លានតោនក្នុងមួយឆ្នាំ។

**ង.៦- សត្តឃាតដ្ឋាន** : គិតមកដល់ដំណាច់ឆ្នាំ២០១៩នេះ សត្តឃាតដ្ឋានទូទាំងប្រទេសមានចំនួន២២៥កន្លែង។

## ច- ការអភិវឌ្ឍសហគមន៍កសិកម្ម

### ច.១- ការបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម

គិតចាប់ពីឆ្នាំ២០០៣ ដល់ដំណាច់ខែកក្កដា ឆ្នាំ២០១៩នេះ ដោយអនុលោមតាមព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្មឆ្នាំ២០០០ និងអនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្មឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្របសម្រួលចងក្រងបង្កើតជាសហគមន៍កសិកម្ម១ ១៩០សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុប១៤០ ០៥១នាក់ ក្នុងនោះមានសមាជិកនារី ៨៧ ៨៩២នាក់ ស្មើនឹងប្រមាណ៦២%នៃសមាជិកសរុប ប្រាក់ភាគហ៊ុនសរុប៤០ ៧៧២ ៨៦៥ ៤០០រៀល(ប្រមាណ១០លានដុល្លារអាម៉េរិក) ដែលជាថវិកាផ្ទាល់របស់ប្រជាកសិករដាក់ភាគហ៊ុនវិនិយោគក្នុងសហគមន៍កសិកម្មរបស់ខ្លួន និងដើមទុនសរុប៩១ ០៨៣ ៦៥២ ៦០៩រៀល(ប្រមាណ២២,៧លានដុល្លារអាម៉េរិក)។

### ច.២- ការបង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្ម

សហភាពសហគមន៍កសិកម្ម គឺជាកម្រិតឬថ្នាក់ទី២នៃសហគមន៍កសិកម្មដែលត្រូវបានបង្កើតឡើងដោយស្ម័គ្រចិត្តចាប់ពីសហគមន៍កសិកម្មពីរឡើងទៅដើម្បីប្រមូលផ្តុំកម្លាំងផលិតកម្ម មធ្យោបាយផលិតកម្ម និងពង្រីកសមត្ថភាពនៅក្នុងផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្ម។

គិតត្រឹមឆ្នាំ២០១៩នេះ សហភាពសហគមន៍កសិកម្មមានចំនួន១០ នៅក្នុងខេត្តចំនួន៩ រួមមានខេត្តសៀមរាប២ កំពត១ ត្បូងឃ្មុំ១ តាកែវ១ ព្រះវិហារ១ ប៉ៃលិន១ បាត់ដំបង១ កំពង់ស្ពឺ១ និងខេត្តស្វាយរៀង១។ សហភាពសហគមន៍កសិកម្មមានសមាជិកសហគមន៍កសិកម្មសរុប១៦៨សហគមន៍ និងមានដើមទុនសរុប១ ៦៤០ ៦១៥ ០៨២រៀល(ប្រមាណ៤១ម៉ឺនដុល្លារអាម៉េរិក)។

### ច.៣- ការបង្កើតនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

សម្ព័ន្ធសហគមន៍កសិកម្ម គឺរចនាសម្ព័ន្ធចាត់តាំងកំពូលរបស់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មនៅកម្ពុជា ដែលរាល់សហគមន៍កសិកម្មនិងសហភាពសហគមន៍កសិកម្មទាំងអស់នៅព្រះរាជាណាចក្រកម្ពុជាជាមាជិករបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

សហគមន៍កសិកម្មចំនួន១ ១៩០ និងសហភាពសហគមន៍កសិកម្មចំនួន១០ បានក្លាយជាសមាជិកសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។ សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០។

### ច.៤- មុខរបរនិងការចុះកិច្ចសន្យាផលិតកម្មកសិកម្មរបស់សហគមន៍កសិកម្ម

មុខរបរសំខាន់ៗរបស់សហគមន៍កសិកម្ម រួមមាន **១**-មុខរបរទីផ្សារ(ទិញផលិតផលពីសមាជិកលក់ ដូចជាស្រូវ ពូជស្រូវ ម្រេច ពោត ដំឡូង សណ្តែក ស្វាយ មៀនប៉ៃលិន បន្លែគ្រប់ប្រភេទ ជ្រូក មាន់ ទា) **(២)**- មុខរបរផ្គត់ផ្គង់ធាតុចូលកសិកម្ម(ទិញធាតុចូលកសិកម្មពីខាងក្រៅមកលក់ឱ្យសមាជិក ដូចជាជីកសិកម្ម ថ្នាំកសិកម្ម ចំណីសត្វ ថ្នាំព្យាបាលសត្វ ពូជដំណាំ ទឹកបរិសុទ្ធ និងសម្ភារៈកសិកម្ម។ល។ **៣**- មុខរបរប្រើប្រាស់រួមគ្នាដែលបម្រើឱ្យសេវាកម្មរួមមាន ឡសម្ងួតស្រូវ កែច្នៃចំណីសត្វ កិនស្រូវ ភ្ជួររាស់ដោយគ្រឿងយន្តកសិកម្ម ច្រូតស្រូវដោយម៉ាស៊ីនច្រូត និង**៤**-មុខរបរឥណទានកសិកម្ម(ផ្តល់ប្រាក់កម្ចីនិងទទួលសេវាសន្សំប្រាក់របស់សមាជិកសហគមន៍កសិកម្ម)។

នៅក្នុងឆ្នាំ២០១៩ កន្លងមកនេះ សហគមន៍កសិកម្មចំនួន១៦៥ ។ សហគមន៍កសិកម្មបានចុះកិច្ចសន្យាផលិតកម្មកសិកម្មជាមួយក្រុមហ៊ុនឯកជនទៅតាមប្រភេទមុខដំណាំកសិកម្ម រួមមានស្រូវក្រអូប៩៣សហគមន៍ ស្រូវសរីរាង្គ៤៣សហគមន៍ បន្លែសុវត្ថិភាព១៦សហគមន៍ ដំឡូងមីសរីរាង្គ៩សហគមន៍ ម្រេច២សហគមន៍ ស្ករត្នោត១សហគមន៍ និងសណ្តែកខៀវសរីរាង្គ១សហគមន៍។

**ឆ- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍវិស័យកសិកម្មពូជដំណាំ**

នៅក្នុងឆ្នាំ២០១៩ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍវិស័យកសិកម្មពូជដំណាំបាន៖

- ចុះប្រមូលសំណាកផ្កាអ័រគីដេនិងដំណាំផ្សេងៗ១៩៧សំណាក និងបន្តអភិរក្សពូជដំណាំ៣៨ប្រភេទ រួមមានស្រូវ៦ ៧៣១បញ្ជិកា/សំណាក និងដំណាំផ្សេងៗ៣៧ប្រភេទចំនួន២ ២៧៨បញ្ជិកា/សំណាក ព្រមទាំងដាំ និងវាយតម្លៃកំណត់លក្ខណៈសំណាកត្រសក់ស្រូវ៥៣សំណាក ម្ទេស៥៨សំណាក ល្ពៅ២៤សំណាក និងសណ្តែកព្រៃ៤៣សំណាក

- ធ្វើការពិសោធពូជ៩៤ប្រភេទ នៅ៦៥៩កន្លែង ដែលក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញ៤៣៩កន្លែង ធ្វើការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស៥វគ្គ មានអ្នកចូលរួម១៥១នាក់ ធ្វើការបណ្តុះបណ្តាល៤០ដង ជូនដល់កសិករ១ ៦៣៥នាក់(ស្រី៥៥%)និងធ្វើទិវាស្រែ៨លើក មានកសិករចូលរួម៣៧៦នាក់(ស្រី៥១%)

- បញ្ចេញប្រភេទពូជស្រូវ១ពូជជាឯកត្តៈជម្រើសចេញពីក្រុមប្រភេទពូជសែនក្រអូប ហើយគណៈកម្មការបញ្ចេញប្រភេទពូជដំណាំដាក់ឈ្មោះសែនក្រអូប១។ សែនក្រអូប១ ជាប្រភេទពូជស្រូវស្រាលមិនប្រកាន់រដូវ មានអាយុកាលមធ្យម១០៥ថ្ងៃ(ព្រោះ)និង១១៥ថ្ងៃ(ស្ទូង) គ្រាប់អង្ករ សថ្លាមានប្រវែង៧,១៥ម.ម. បន្ទារ១,៩៥ម.ម. អាមីឡូស១៦% ផ្តល់ទិន្នន័យមធ្យម៣,៩តោន/ ហ.ត. និងអាចដល់៥,៨តោន/ហ.ត.ហើយមានក្លិនក្រអូបស្រាល។ ពូជស្រូវនេះមិនមានលក្ខណៈធន់ទ្រាំទៅនឹងជំងឺនិងសត្វល្អិតចង្រៃឡើយ។ ទន្ទឹមនឹងនេះបានជំរុញការទទួលយកប្រភេទពូជស្រូវថ្មីផ្កាមាលតីនិងដំណើបស្បែមង្គល តាមរយៈការធ្វើស្រែបង្ហាញជាមួយកសិករ១០០កន្លែង/មួយពូជ និងយកអង្ករដំណើបស្បែមង្គលដាក់លក់ផ្សព្វផ្សាយនៅតាមសាខាផ្សារទំនើបឡាក់គីមួយចំនួន

- បង្កើតផែនទីក្រុមដាំដុះស្រូវ២ស្រុក គឺស្រុកបារាយណ៍និងតាំងគោក ខេត្តកំពង់ធំ ហើយសិក្សារកឃើញបច្ចេកវិទ្យាគ្រប់គ្រងដំណាំ៨ និងលទ្ធផលអង្កេតសង្គមសេដ្ឋកិច្ចមួយចំនួន

- ចែកគ្រាប់ពូជស្រូវជូនកសិករ៣៤០គ្រួសារ នៅខេត្តត្បូងឃ្មុំ ឧត្តរមានជ័យ តាកែវ និងខេត្តព្រៃវែង ១ ៧០០គ.ក្រ. សម្រាប់ផលិតក្នុងរដូវវស្សានិងរដូវទឹកស្រកឆ្នាំនេះទុកជាគ្រាប់ពូជសម្រាប់ប្រើប្រាស់ឆ្នាំបន្ទាប់ ដោយក្នុងរដូវវស្សានេះកសិករ២១០គ្រួសារ នៅខេត្តត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យ ផលិតបានគ្រាប់ពូជសរុប៣៣តោន។ ផលិតគ្រាប់ពូជស្រូវគ្រឹះ ចុះបញ្ជីនិងវិញ្ញាបនបត្របានប្រមាណ៦៤តោន ព្រមទាំងបានលក់និងចែកចាយដល់អ្នកប្រើប្រាស់នូវគ្រាប់ពូជស្រូវជាង១៣តោន

- បោះពុម្ពឯកសារ៣០ ៣៤០ច្បាប់ និងបែងចែកឯកសារសរុប១៩ ៨៣៣ច្បាប់ និងអត្ថបទវិទ្យាសាស្ត្រ២អត្ថបទ។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានកាឌីតាមរយៈគេហទំព័រhttp://www.cardi.org.kh សរុប១ ០៥៧ ៣៨៣នាក់ គិតជាមធ្យម២ ៩០៥នាក់/ថ្ងៃ លើសឆ្នាំ២០១៨ ដែលមាន២៧៤នាក់/ថ្ងៃ។

## ២- ការងារធនធានទឹកនិងឧតុនិយម

លទ្ធផលសំខាន់ៗរបស់ក្រសួងធនធានទឹកនិងឧតុនិយម សម្រេចបាន៖

**ក- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹកនិងការអនុវត្តប្រព័ន្ធធារាសាស្ត្រ**

ទី១- ការស្តារនិងការសាងសង់ប្រព័ន្ធធារាសាស្ត្រ

| ក- ការជួសជុលស្តារឡើងវិញនិងការសាងសង់ប្រព័ន្ធធារាសាស្ត្របង្កើនលទ្ធភាពស្រោចស្រព | | | | | |
|---|---|---|---|---|---|
| បរិយាយ | គម្រោង | ស្រូវវស្សា(ហ.ត.) | ស្រូវប្រាំង(ហ.ត.) | សរុប(ហ.ត.) | ដំណាំ(ហ.ត.) |
| ២០១៩ | ៥២ | ២២ ៣១៥ | ១០ ៧៤៨ | ៣៣ ០៦៣ | ៤១២ |

| ខ- ការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួប រក្សានិរន្តរភាពស្រោចស្រព | | | | | |
|---|---|---|---|---|---|
| ២០១៩ | ១៩៩ | ៤០៩ ២៦៧ | ៩០ ៤៧៣ | ៤៩៩ ៧៤០ | ១ ៩២៤ |

ទី២- ការជួសជុល-ថែទាំសំណង់សិល្បៈការ

| បរិយាយ | ទ្វារទឹក(កន្លែង) | លូទឹក(កន្លែង) | ស្នាក់ទឹក(កន្លែង) | បង្ហៀរ(កន្លែង) |
|---|---|---|---|---|
| ២០១៩ | ៣៤ | ៤២ | ៣៧ | ៣ |

ទី៣- ការជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម

| ក- ការជួសជុលនិងថែទាំទំនប់ | | | | |
|---|---|---|---|---|
| បរិយាយ | ចំនួន(កន្លែង) | ប្រវែង | សាច់ដី | គ្រឿងចក្រ |
| ២០១៩ | ១៥ | ២៦ ៧២៤ម៣ | ១ ០៤៤ម៣ | គ្រឿងចក្រ |
| ខ- ការងារជីកនិងស្តារប្រឡាយ | | | | |
| ២០១៩ | ៥២ខ្សែ | ៩៨ ៦០៧ម៣ | ២៦ ៧២៤ម៣ | គ្រឿងចក្រ |

ទី៤- ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

| ក- ការរៀបចំសហគមគមន៍ប្រើប្រាស់ទឹក | | | | | |
|---|---|---|---|---|---|
| បរិយាយ | ចំនួន សហគមន៍ | ផ្ទៃដីដំណាំស្រូវ (ហ.ត.) | | | ឯកតា គ្រួសារ |
| | | ស្រូវវស្សា | ស្រូវប្រាំង | សរុប | |
| ២០១៩ | ១៣ | ២៨ ៩៥៤ | ៤ ៤០៣ | ៣៣ ៣៥៨ | ២១ ៣០៨ |

**ខ- ការគ្រប់គ្រងនិងការកាត់បន្ថយគ្រោះទឹកជំនន់និងទឹកប្រៃ**

ទី១- ការគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់-ទឹកប្រៃ

- ការទប់ស្កាត់ទឹកជំនន់

ក- ការសាងសង់ទំនប់ការពារទឹកជំនន់

| បរិយាយ | ចំនួនគម្រោង | ការពារលំនៅដ្ឋាន |
|---|---|---|
| ២០១៩ | ១ | ១០០ហ.ត. |

ខ- ជួសជុលថែទាំជាប្រចាំ

| បរិយាយ | ចំនួនគម្រោង | បង្កើនលទ្ធភាពការពារ(ហ.ត.) | | |
|---|---|---|---|---|
| | | លំនៅដ្ឋាន | ស្រូវវស្សា | សរុប |
| ២០១៩ | ២ | ៣ ៤២០ | ១ ៤៨១ | ៤ ៩០១ |

- ការទប់ស្កាត់ទឹកប្រៃ

| ក- ការសាងសង់ទំនប់ការពារទឹកប្រៃ | | | | |
|---|---|---|---|---|
| បរិយាយ | ចំនួនគម្រោង | បង្កើនលទ្ធភាពការពារ(ហ.ត.) | | |
| | | ស្រូវ | ដំណាំ | សរុប |
| ២០១៩ | ២ | ៦៥៥ | ២០ | ៦៧៥ |
| ខ- ការជួសជុល-ថែទាំជាប្រចាំ ដើម្បីរក្សានិរន្តរភាពការពារទប់ស្កាត់ទឹកប្រៃ | | | | |
| បរិយាយ | ចំនួនគម្រោង | រក្សានិរន្តរភាពនៃលទ្ធភាពការពារ(ហ.ត.) | | |

| | | លំនៅដ្ឋាន | ស្រូវវស្សា | ដំណាំ | សរុប |
|---|---|---|---|---|---|
| ២០១៩ | ១៦ | ៣៨៦ | ១៥ ៤០៣ | ១១០ | ១៥ ៨៩៩ |

ទី២- ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

| បរិយាយ | ការប្រើប្រាស់ប្រេង (លីត្រ) | | ផ្ទៃដីស្រូវសង្គ្រោះ (ហ.ត.) | | |
|---|---|---|---|---|---|
| | ប្រេងម៉ាស៊ូត | ប្រេងរំអិល | ស្រូវប្រាំង | ស្រូវវស្សា | សរុប |
| ២០១៩ | ១ ១៤០ ០០០ | ៥ ៦០០ | ៤៧ ៨៩២ | ៤២ ២៩៧ | ៩០ ១៨៩ |

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវដោយម៉ាស៊ីនបូមទឹក ក៏មានការសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ(បង្ហូរ) ។

| បរិយាយ | លទ្ធផលបង្ហូរសង្គ្រោះ (ហ.ត.) | | |
|---|---|---|---|
| | ស្រូវប្រាំង | ស្រូវវស្សា | សរុប |
| ២០១៩ | ៥៨២ | ៨៣៩ | ១ ៤២១ |

ទី៣- ការសាងសង់ដំឡើងស្ថានីយបូមទឹកនិងជួសជុលម៉ាស៊ីនបូមទឹក

| បរិយាយ | សាងសង់ស្ថានីយ(កន្លែង) | ជួសជុលស្ថានីយ(កន្លែង) | ជួសជុលម៉ាស៊ីន(កន្លែង) |
|---|---|---|---|
| ២០១៩ | | ៣ | ៤៩ |

ទី៤- ការងារជលសាស្ត្រ

| បរិយាយ | ស្ថានីយជលសាស្ត្រ(កន្លែង) | | ក្តារម៉ែត្រវាស់កម្ពស់ទឹក(កន្លែង) | |
|---|---|---|---|---|
| | ដំឡើង | ជួសជុល | ដំឡើង | ជួសជុល |
| ២០១៩ | | ១ | ១ | ១ |

ទី៥- ការងារឧតុនិយម

| បរិយាយ | ស្ថានីយឧតុនិយម(កន្លែង) | ប៉ុស្តិ៍តម្រងទឹកភ្លៀង(កន្លែង) | |
|---|---|---|---|
| | ជួសជុល | ដំឡើង | ជួសជុល |
| ២០១៩ | ៧ | ២០ | ៥ |

ជាក់ស្តែងនៅឆ្នាំ២០១៩នេះ ក្រសួងសម្រេចបាន៖

- បង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុបចំនួន៣៣ ០៦៣ហ.ត. ក្នុងនោះ រួមមាន (ស្រូវរដូវវស្សាចំនួន២២ ៣១៥ហ.ត. និងស្រូវរដូវប្រាំងចំនួន១០ ៧៤៨ហ.ត.)ស្រោចស្រពដំណាំរួមផ្សំបានចំនួន ៤១២ហ.ត.។ ក្រៅពីបង្កើនលទ្ធភាពស្រោចស្រពខាងលើ ក៏បានរក្សានិរន្តរភាពនៃការស្រោចស្រពដំណាំស្រូវសរុបចំនួន៤៩៩ ៧៤០ហ.ត. ក្នុងនោះ (ស្រូវវស្សាចំនួន៤០៩ ២៦៧ហ.ត. និងស្រូវរដូវប្រាំងចំនួន ៩០ ៤៧៣ហ.ត.) ស្រោចស្រពដំណាំរួមផ្សំចំនួន១ ៩២៤ហ.ត. តាមរយៈការជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួប
- ពង្រឹងច្រាំងទន្លេកុំឱ្យបាក់នៅខេត្តកណ្តាល កំពង់ចាម និងខេត្តក្រចេះបានប្រវែង១៣ ៥៩៥ម៉ែត្រ។ ការពារទប់ស្កាត់ទឹកជំនន់កុំឱ្យលិចលំនៅឋានចំនួន១០០ហ.ត. និងរក្សានិរន្តរភាពការពារទប់ស្កាត់កុំឱ្យទឹកជំនន់លិចលង់ចំនួន៤ ៩០១ហ.ត.
- បង្កើនលទ្ធភាពការពារទប់ស្កាត់ទឹកប្រៃកុំឱ្យហូរចូលលើផ្ទៃដីស្រូវនិងដំណាំរួមផ្សំចំនួន៦៧៥ហ.ត. និងរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន១៥ ៨៩៩ហ.ត. តាមរយៈការជួសជុល ថែទាំជាប្រចាំ
- បានព្យាករនិងជូនដំណឹងស្ថានភាពអាកាសធាតុនិងជលសាស្ត្រ ជូនប្រជាពលរដ្ឋផងដែរ។

## ៣- ការអភិវឌ្ឍជនបទ

## លទ្ធផលការងារសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ៖

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ |
|---|---|---|---|---|
| **ការងារផ្លូវលំជនបទ** | | | | |
| ១ | ជួសជុលបន្ទាន់ផ្លូវក្រាលក្រួសក្រហម បេតុង និង កៅស៊ូ | គ.ម. | ២៦៧,៩៥ | ២៨៥,១៤ |
| ២ | ការស្ដាបនានិងកែលម្អផ្លូវជនបទ(ជំពូក២១)<br>- ផ្លូវក្រាលកៅស៊ូ<br>- ផ្លូវក្រាលបេតុង<br>- ផ្លូវក្រាលក្រួសក្រហម | គ.ម. | <br>៥៥៣,៩៨<br>១៥,៨០<br>១០១៣,៦១ | <br>១០១,១៦<br>២៩,៩១<br>៣៨៧,១២ |
| ៣ | ការជួសជុលនិងថែទាំផ្លូវជាលក្ខណៈគ្រួសារ ប្រចាំ និង ខួប | គ.ម. | ២ ០២៥,២៨ | ៣ ២២០,៣៨ |
| ៤ | កែលម្អផ្លូវជនបទធន់នឹងការប្រែប្រួលអកាសធាតុ (DBST) | គ.ម. | ៨៣,២៦ | ៣,៦២ |
| ៥ | ទំបន់បង្ហៀរ | កន្លែង | ៣ | ២១ |
| ៦ | ការជួសជុលថែទាំស្ពាននិងសំណង់សិល្បការ | កន្លែង | ៧៣០ | ៥៨៥ |
| ៧ | ការសាងសង់ និងពង្រីកផ្លូវថ្មី | គ.ម. | ៣៩០,៤៦ | ១៦,៥០ |
| ៨ | ដាំកូនឈើតាមផ្លូវជនបទ | ដើម | ៣៣ ៨៥០ | ៨៨ ០០៤ |
| **ការងារផ្គត់ផ្គង់ទឹកជនបទ** | | | | |
| ១ | ការសាងសង់/ស្ដារប្រព័ន្ធស្រោចស្រពខ្នាតតូច | អណ្ដូង | ១ ៦២៥ | ១៨ |
| ២ | សាងសង់ជួសជុលអណ្ដូងគ្រប់ប្រភេទ | អណ្ដូង | ២ ៧៧៧ | ៤៧៦៣ |
| ៣ | ការស្រង់ទិន្នន័យនិងបញ្ជីសារពើភ័ណ្ឌអណ្ដូង | អណ្ដូង | | ៣០៨ ១០៥ |
| ៤ | ផ្ដល់ពាងចំណុះ ១ ០០០លីត្រ | ពាង | ២៨ ៧២២ | ៥៩៩៣១ |
| ៥ | ពាង | ពាង | ២៨ ៨៨៨ | ២៩៩ |
| ៦ | ធុងចម្រុះ | ធុង | ៥ ៣៩៨ | ២១៣០៦ |
| ៧ | អាងត្រងទឹកភ្លៀងចំណុះ ១០ ០០០ លីត្រ | អាង | ១ ០៥២ | ៩០៩ |
| ៨ | ស្ថានីយទឹកស្អាត | កន្លែង | ៤៣ | ២៩២ |
| ៩ | សាងសង់/ជួសជុលប្រព័ន្ធចែកចាយទឹក | ស្រះ | ៣៧៤ | ២១៣ |
| ១០ | សាងសង់/ស្ដារស្រះសហគមន៍ | ស្រះ | ១២៩ | ២២២ |
| ១១ | សាងសង់អាងចម្រោះសាធារណៈ | អាង | ២ | ៤ |
| ១២ | កម្មវិធីផ្សព្វផ្សាយការប្រើប្រាស់ទឹកស្អាតតាមសហគមន៍ | វគ្គ | ០ | ៤៥ |
| ១៣ | រៀបចំប្រារព្ធទិវាទឹកពិភពលោក | លើក | ០ | ២១ |
| **ការងារថែទាំ អនាម័យជនបទ** | | | | |
| ១ | សាងសង់បង្គន់អនាម័យ | បង្គន់ | ៤៣ ៦៧៤ | ៣ ៤៣០ |
| ២ | កន្លែងលាងដៃ និងសាងសង់រានហាលចាន | កន្លែង | ១២ ៩៧៥ | ៥ ១៦៧ |

| | | | | |
|---|---|---|---|---|
| ៣ | សាងសង់ឡសម្រាម/ធុង | ឡ | ៧៩ | ៣០៨ |
| ៤ | ធុងដាក់ទឹក | ធុង | ០ | ៧ ៥៤៧ |
| ៥ | ស្លាកប៉ាណូ | ស្លាក | ២០២ | ៣២០ |
| ៦ | ពង្រឹងសមត្ថភាពក្នុងការលើកកម្ពស់អនាម័យជនបទដល់ជនបង្គោល | វគ្គ | ០ | ៤៥ |
| ៧ | ការអប់រំផ្សព្វផ្សាយអនាម័យគ្រួសារនិងសហគមន៍ | វគ្គ | ០ | ២ ៩៤០ |
| **ការងារអភិវឌ្ឍន៍សហគមន៍** | | | | |
| ១ | ការអភិវឌ្ឍភូមិចម្រុះ | វគ្គ | ០ | ៥ |
| ២ | បញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ | វគ្គ | ០ | ១៩ |
| ៣ | ការលើកកម្ពស់សន្តិសុខស្បៀងលក្ខណៈគ្រួសារ | វគ្គ | ០ | ១០ |
| ៤ | ការងារទីផ្សារនិងការផ្តល់គំនិតអាជីវកម្មខ្នាតតូច | វគ្គ | ០ | ១២ |
| ៥ | ផ្តល់បេច្ចកទេសនិងបង្កើនមុខរបរអាជីវកម្ម | វគ្គ | ០ | ៣០ |
| ៦ | បណ្តុះបណ្តាល និងពង្រឹងសមត្ថភាព គ.អ.ភ | វគ្គ | ១១១វគ្គ ចំនួន៥៤៣៧ | ២៥៨ |
| ៧ | ការផ្សព្វផ្សាយនិងជំរុញឲ្យសហគមន៍ឥណទាន | វគ្គ | ៤ | ៦៥ |
| ៨ | ការអភិវឌ្ឍនិងការអភិរក្សជនជាតិដើមភាគតិចក្នុងសហគមន៍ | ភូមិ | ១៣ | ៧០ |
| ៩ | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងកំពង់ស្ពឺ | វគ្គ | ១៦ | ៥៩ |
| ១០ | ពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា កូរ៉េ | វគ្គ | ១៨ | ១០ |
| ១១ | រៀបចំទិវាជនជាតិដើមភាគតិច | លើក | ៤ | ១០ |
| **ការរៀបចំផែនការ និងហិរញ្ញវត្ថុ(បណ្តុះបណ្តាលធនធានមនុស្ស)** | | | | |
| ១ | បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ខេត្តស្រុក | វគ្គ | ៣ ០៨៦នាក់ | ៩១ |
| ២ | ការតាមដាននិងត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកាកម្មវិធី | លើក | ០ | ៧៧ |
| ៣ | សាងសង់ទីទួលសុវត្ថិភាព | កន្លែង | ០ | ៤ |
| ៤ | ពង្រឹងកិច្ចការរដ្ឋបាលនិងកិច្ចការទូទៅ | លើក | ០ | ៥៧ |
| ៥ | ការពង្រឹងសមត្ថភាពគ្រប់គ្រងបញ្ជីសារពើភណ្ឌ | លើក | ០ | ១៦ |
| ៦ | ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្ស | វគ្គ | ០ | ៤ |
| ៧ | ការអភិវឌ្ឍសមត្ថភាពមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | វគ្គ | ០ | ១២ |
| ៨ | ការស្រាវជ្រាវនិងផលិតព្រឹត្តបត្រព័ត៌មាន | លើក | ០ | ២ |
| ៩ | ចុះតាមដាននិងវាយតម្លៃការងារគ្រប់គ្រងរដ្ឋបាល ការចរាចរលិខិតស្នាមការរៀបចំទុកដាក់ឯកសារ | លើក | ២៥ | ២៥ |

| | | | | |
|---|---|---|---|---|
| ១០ | ក្នុងឆ្នាំ២០១៩ បានផ្តល់អាហារូបករណ៍១ ៩៩៦នាក់ សៀវភៅ៦ ២៦៧ក្បាល សង់ផ្ទះ/សាលា១០២ខ្នង បង្កើតផ្សារចល័ត១២ខ្នង បង្កើតសួនដាំបន្លែ៦៧កន្លែង សង់ទ្រុងដីកំប៉ុស្ត/ទ្រុង៥៦ទ្រុង ផ្តល់ជ្រូក១១៣ក្បាល មាន់/ទា១ ៣៩៦ល្បាល គោ១០២ក្បាល ផ្តល់ម៉ូតូចំនួន៤៣គ្រឿង ស្គរចំនួន៥២គ្រឿង តង់ចំនួន៩៨២តង់ ហ្វឺត ចំនួន៣៥ឈុត ទៃម៉ូមែត្រចំនួន៥៩ដើម ផ្តល់អាហារ៧ ១៤៦នាក់ ផ្តល់រ៉ូប៊ីនេ២៨គ្រាប់ ផ្តល់ពូជដំណាំ/គ្រួសារ ៣១១គ្រួសារ ។ | | | |
| ១១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន | វគ្គ | ១៩៣ | ២៣២ |
| ១២ | ពង្រឹងសវនកម្មនិងអធិការកិច្ច | វគ្គ | ៤ | ៣ |
| ១៣ | ប្រតិបត្តិការសវនកម្មផ្ទៃក្នុង | លើក | ២៥ | ២៥ |
| ១៤ | សឡា/បន្ទះ | បន្ទះ | ៥០ | ១៨៧ |
| ១៥ | ផ្តល់ម៉ាស៊ីនបូមទឹក/គ្រឿង | គ្រឿង | ១០ | ២៣ |
| ១៦ | ផ្តល់ម៉ូទ័របូមទឹក | គ្រឿង | ១០ | ០ |
| ១៧ | ចែកកង់ | គ្រឿង | ២០០ | ០ |

## មុំទី២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព

### ១- ធនធានធម្មជាតិ

### ១.១- ការគ្រប់គ្រងធនធានធម្មជាតិ

សមិទ្ធផលសំខាន់ៗរបស់ក្រសួងបរិស្ថានសម្រេចបាន៖

- រៀបចំបង្កើតតំបន់ការពារធម្មជាតិបន្ថែមពីចំនួន២៥ទៅ៦៥កន្លែងនិងរបៀងអភិរក្សជីវចម្រុះដែលមានផ្ទៃដីសរុបចំនួន៧,២លានហិកតា ស្មើនឹង៤១%នៃផ្ទៃដីសរុបទូទាំងប្រទេស

- បាននិងកំពុងរៀបចំកែសម្រួលការកំណត់និងបែងចែកតំបន់គ្រប់គ្រងដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងនៅតំបន់ការពារធម្មជាតិ មានជាអាទិ៍ដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច ដែនជម្រកសត្វព្រៃ ព្រៃឡង់ ដែនជម្រកសត្វព្រៃតាតៃ ឧទ្យានជាតិបុទុមសាគរ ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម ភ្នំគូលែន តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង។ល។

- រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិបាន១៦៨សហគមន៍ មានប្រជាពលរដ្ឋចូលរួមចំនួន ៤៥ ២៦៧គ្រួសារ និងមានផ្ទៃដីសរុប២៨៦ ០៥២ហិកតា ស្មើនឹង៤% នៃផ្ទៃដីសរុបនៃតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជានិងរៀបចំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ជាបណ្តាញ រួមមានបណ្តាញសហគមន៍មូលដ្ឋាន(សម្រាប់តំបន់ការពារធម្មជាតិ) បណ្តាញសហគមន៍ជាបណ្តាញសហគមន៍ថ្នាក់តំបន់(សម្រាប់តំបន់ខាងជើងនិងខាងត្បូងបឹងទន្លេសាបនិងខាងកើតទន្លេមេគង្គ) និងបណ្តាញសហគមន៍ថ្នាក់ជាតិ

- បាននិងកំពុងគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ កសិ-ទេសចរណ៍ តំបន់សេដ្ឋកិច្ច ពិសេស និងគម្រោងអភិរក្សព្រៃឈើនិងសត្វព្រៃចំនួន១៨គម្រោង មានផ្ទៃដីសរុប៩១ ៣០០ហិកតា ក្នុងនោះ ៥គម្រោងបានដំណើរការប្រសើរ ហើយ១៣គម្រោងទៀត កំពុងបន្តអនុវត្តនិតិវិធីតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងបរិស្ថាន

- បាននិងកំពុងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច(ក្រោម១០ហិកតា) ចំនួន១១៥គម្រោង មានផ្ទៃដីសរុបទំហំ១០៧ ៧៧៦ហិកតា ក្នុងនោះ ៧៦គម្រោង បានបោះបង្គោលព្រំប្រទល់រួចរាល់ ហើយ៨គម្រោងទៀតបានរៀបចំប្លង់មេរួចហើយ

- បានរៀបចំវេទិកាថ្នាក់តំបន់ស្តីពីការការពារនិងអភិរក្សធនធានធម្មជាតិ ចំនួន២លើក ក្រោមប្រធានបទផ្សេងៗគ្នា ដើម្បីបន្តប្រមូលព័ត៌មាន ពិភាក្សា និងរកដំណោះស្រាយពាក់ព័ន្ធនឹងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ

- បានចងក្រងឯកសារនិងទិន្នន័យស្តីពីបុរាណដ្ឋាននិងបេតិកភណ្ឌវប្បធម៌ចំនួន៧កន្លែង ស្ថិតក្នុងខេត្តបន្ទាយមានជ័យ និង១០៨កន្លែង ស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ខេត្តព្រះវិហារ ដើម្បីបង្កើតតំបន់បេតិកភណ្ឌ។

## ១.២- ការងារការពារនិងអភិរក្សធនធានធម្មជាតិ

- បានរៀបចំបង្កើតតំបន់ការពារធម្មជាតិបន្ថែមពីចំនួន២៣ទៅ៥៦កន្លែង និងរបៀងអភិរក្សជីវៈចម្រុះដែលមានផ្ទៃដីសរុបចំនួន៧,២លានហិកតា ស្មើនឹង៤១% នៃផ្ទៃដីសរុបទូទាំងប្រទេស
- បាននិងកំពុងរៀបចំកែសម្រួលការកំណត់និងបែងចែកតំបន់គ្រប់គ្រង ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងនៅតំបន់ការពារធម្មជាតិ ជាអាទិ៍ ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃសៀមប៉ាងនិងសៀងប៉ាងខាងលិច ដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃ«ព្រៃឡង់» ដែនជម្រកសត្វព្រៃតាតៃ ឧទ្យានជាតិបុទុមសាគរ ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម «ភ្នំគូលែន» តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ។ល។
- បានបង្កើតតំបន់ការពារទេសភាព«ភ្នំក្រាំងដីមាស»ខេត្តកំពង់ឆ្នាំង និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិចំនួន៦តំបន់ទៀត គឺតំបន់ការពារទេសភាព«ភ្នំឈ្មោក-ភ្នំនាងសេដាឱន» តំបន់ការពារទេសភាព«ភ្នំដំរី-ភ្នំផ្ការ» តំបន់ការពារទេសភាព«ភ្នំកំពង់ត្រាច» តំបន់ការពារទេសភាព«ភ្នំល្អាង» តំបន់ប្រើប្រាស់ច្រើនយ៉ាង «ព្រែកស្រែអំបិល» ខេត្តកំពត
- បានបញ្ចប់ការរៀបចំយុទ្ធសាស្ត្ររេដបូកជាតិនិងកម្រិតយោងព្រៃឈើជាតិ ដោយបានដាក់ជូនលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុនិងបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធតាមដានត្រួតពិនិត្យព្រៃឈើជាតិ និងបញ្ចប់ការរៀបចំប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពនិងសេចក្តីសង្ខេបព័ត៌មានស្តីពីប្រព័ន្ធធានាសុវត្ថិភាពរេដបូក
- បានបញ្ចប់ការបោះបង្គោលព្រំប្រទល់ដែនជម្រកសត្វព្រៃ«ពាមក្រសោប» ខេត្តកោះកុង និងដែនជម្រកសត្វព្រៃ«ភ្នំព្រេច» ខេត្តមណ្ឌលគិរី និងបានដាក់ស្នើសុំចុះបញ្ជីដីរដ្ឋទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងបានបន្តបោះបង្គោលព្រំប្រទល់ដែនជម្រកសត្វព្រៃ «កែវសីមា» ដែនជម្រកសត្វព្រៃ «ស្រែពក» និងដែនជម្រកសត្វព្រៃ«ព្រៃឡង់» ខេត្តស្ទឹងត្រែង
- បានដាក់តំបន់ការពារទេសភាព«អន្លង់ព្រីង» ជាតំបន់ផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើតអូស្ត្រាលី ព្រមទាំងធ្វើជំរឿនសត្វស្លាបនៅកម្ពុជា និងរៀបចំបោះពុម្ពសៀវភៅសត្វស្លាបកម្ពុជាដែលចងក្រងលទ្ធផលនៃការសិក្សា និងស្រាវជ្រាវអំពីលក្ខខណ្ឌជីវសាស្ត្រលម្អិតរបស់សត្វស្លាបចំនួន៦២៥ប្រភេទ
- បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងក្របខណ្ឌគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ក្នុងការទប់ស្កាត់ បង្ក្រាបបទល្មើស ការស៊ើបអង្កេតអ្នកប្រព្រឹត្តបទល្មើស និងអ្នកពាក់ព័ន្ធ និងការចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព

- បានសម្របសម្រួលនិងសហការជាមួយក្រសួងយុត្តិធម៌ ក្នុងការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ដល់ថ្នាក់ដឹកនាំ មន្ត្រីនៃអគ្គនាយកដ្ឋាន និងមន្ត្រីនៃមន្ទីរបរិស្ថានរាជធានី ខេត្តសរុប១ ៤៣៩រូប និងសហការជាមួយអគ្គនាយកដ្ឋានសម្ភារបច្ចេកទេស នៃក្រសួងការពារជាតិ ក្នុងការប្រគល់អាវុធប្រភេទ CKC ចំនួន ១ ២១០ដើម ដល់មន្ទីរបរិស្ថាន ខេត្ត ប្រើប្រាស់សម្រាប់ការល្បាត និងបានចាត់បញ្ជូនមន្ត្រីឧទ្យានុរក្សចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពការប្រើប្រាស់ថែទាំនិងគ្រប់គ្រងអាវុធជាតិផ្ទុះតាមបច្ចេកទេសពីគ្រូបង្វឹកជាយោធាចារ្យនៅតាមបណ្តាភូមិសាស្ត្ររៀងៗខ្លួនផងដែរ
- បានរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិបាន ១៦៨សហគមន៍ មានប្រជាជនចូលរួមចំនួន ៤៤ ៦៥៩គ្រួសារ និងមានផ្ទៃដីសរុបចំនួន ២៨៥ ៦០៩ហិកតា ដែលក្នុងនោះមានសហគមន៍ថ្មីចំនួន២១ទើបបានរៀបចំបង្កើតថ្មី និងប្រកាសទទួលស្គាល់ដោយក្រសួងបរិស្ថាន ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃ«ព្រៃឡង់» និងរបៀងអភិរក្សជីវៈចម្រុះ ក្នុងខេត្តក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង និងស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងយក្ខឡោមរតនគិរី និងស្ថិតនៅក្នុងតំបន់ការពារទេសភាពអន្លង់ព្រីង ខេត្តកំពត
- បានផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពី «តួនាទីនិងភារកិច្ចរបស់មន្ត្រីអភិវឌ្ឍន៍សហគមន៍» ដល់មន្ត្រីអភិវឌ្ឍន៍សហគមន៍ខេត្តគោលដៅចំនួន២៤ខេត្ត ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពី «ការត្រួតពិនិត្យនិងតាមដានការអនុវត្តផែនការគ្រប់គ្រងសហគមន៍» ដល់មន្ត្រីអភិវឌ្ឍន៍សហគមន៍ខេត្តគោលដៅចំនួន១៧ខេត្តនិងក្រុមប្រឹក្សាឃុំគោលដៅចំនួន៣៨ឃុំ
- បានផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពី «តួនាទីនិងភារកិច្ចរបស់បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ» ដល់គណៈកម្មការសហគមន៍និងគណៈកម្មការបណ្តាញសហគមន៍ក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តមភ្នំគូលែន
- តាមរយៈថវិការបស់រាជរដ្ឋាភិបាល បានផ្តល់ពូជគោ ជ្រូក មាន់ និងសម្ភារៈសម្រាប់បម្រើការងារទេសចរណ៍ធម្មជាតិដល់សមាជិកសហគមន៍ ចំនួន៣៧៦គ្រួសារ នៃសហគមន៍ចំនួន២០ ក្នុងឆ្នាំ ២០១៧ និងឆ្នាំ២០១៨ ដើម្បីផ្តល់ជម្រើសមុខរបរថ្មីដល់សមាជិកសហគមន៍ក្នុងការបង្កើនចំណូល
- តាមថវិការបស់រាជរដ្ឋាភិបាល បានបង្កើតស្ថានីយបង្កាត់ជ្រូកពូជញៀសាន ២កន្លែងនៅខេត្តពោធិ៍សាត់ និងខេត្តមណ្ឌលគិរី ដើម្បីត្រៀមលក្ខណៈរៀបចំជាស្ថានីយបន្សុទ្ធពូជ ដែលអាចឈានទៅជានាដល់ការផ្គត់ផ្គង់ពូជជ្រូកដែលមានផលិតភាពខ្ពស់
- បានតទឹកនិងកសាងប្រព័ន្ធទឹកពីធម្មជាតិ ចំនួន២កន្លែង គឺនៅសហគមន៍តំបន់ការពារធម្មជាតិទំព័រក្នុងខេត្តពោធិ៍សាត់និងនៅសហគមន៍តំបន់ការពារធម្មជាតិព្រៃឈើភ្លើងក្នុងខេត្តព្រះវិហារ សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ សម្រាប់ដាំបន្លែ និងសម្រាប់ចិញ្ចឹមសត្វ
- សហការជាមួយគម្រោងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(UNEP) បានដាំស្តារព្រៃឈើឡើងវិញក្នុងតំបន់សហគមន៍ សាលារៀន និងទីសាធារណៈ មានកូនឈើ សរុបប្រមាណជា៤៨ម៉ឺនដើម និងចែកកូនឈើហូបផ្លែប្រមាណជា៣៧ម៉ឺនដើម ដល់សហគមន៍តំបន់ការពារធម្មជាតិ ចំនួន១៤ សហគមន៍

- សហការជាមួយគម្រោងរបៀងអភិរក្សជីវៈចម្រុះ(BCCP) បានបំពាក់ផ្ទាំងកញ្ចក់ពន្លឺព្រះអាទិត្យចំនួន ៦៥៤ឈុត ដល់សហគមន៍តំបន់ការពារធម្មជាតិ ក្នុងខេត្តមណ្ឌលគិរីនិងខេត្តកោះកុង និងបានផ្តល់ធុងចម្រោះទឹកចំនួន១០០ ដល់សហគមន៍តំបន់ការពារធម្មជាតិនៅខេត្តកោះកុង
- សម្របសម្រួលការចុះកិច្ចសន្យានិងបង្កើតឱ្យមានកិច្ចសហការណ៍រវាងសហគមន៍តំបន់ការពារធម្មជាតិតាសាល ជាមួយក្រុមហ៊ុន TEAK FARM ដាំដើមម៉ៃសាក់លើផ្ទៃដីរេចរឹលរបស់សហគមន៍ ដែលផ្តល់ចំណូលប្រាក់ដល់សហគមន៍ចំនួន ១ ៣៦៥លានរៀល សម្រាប់រយៈពេល១៥ឆ្នាំ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានសហការជាមួយគម្រោងព្រៃឡង់បៃតងរបស់ USAID ក្នុងការជួយគាំទ្រដល់ដំណើរការរៀបចំសហគមន៍នៅដែនជម្រកសត្វព្រៃ «ព្រៃឡង់» នៃខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។ កិច្ចសហការក៏ផ្តោតផងដែរទៅលើការងារល្បាតនិងលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈកសិកម្ម និរន្តរភាពនៃអនុផលព្រៃឈើ និងការចិញ្ចឹមសត្វ
- អនុវត្តតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៩៦៨ សជណ.កស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ក្រសួងបរិស្ថាន បានរៀបចំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងជាបណ្តាញសហគមន៍ គឺបណ្តាញសហគមន៍មូលដ្ឋាន បណ្តាញសហគមន៍ថ្នាក់តំបន់(ខាងជើង និងខាងត្បូងបឹងទន្លេសាប និងខាងកើតទន្លេមេគង្គ) និងបណ្តាញសហគមន៍ថ្នាក់ជាតិ ដែលបណ្តាញសហគមន៍មូលដ្ឋានចំនួន៣៥បណ្តាញ មានសមាជិកចំនួន២២៨រូប ស្ត្រី៣១រូប ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ចំនួន២៤ ក្នុងខេត្តចំនួន១៧ មានសេចក្តីសម្រេចទទួលស្គាល់ពីរដ្ឋបាលខេត្តសាមី បណ្តាញសហគមន៍ថ្នាក់តំបន់(៣តំបន់) មានសមាជិកចំនួន២៣រូប ស្ត្រី៤រូប និងបណ្តាញថ្នាក់ជាតិ មានសមាជិកចំនួន១១រូប មានសេចក្តីសម្រេចទទួលស្គាល់ ដោយក្រសួងបរិស្ថាន
- តាមរយៈការលើកទឹកចិត្តដល់ស្ថាប័ននិងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីវាយតម្លៃជាអង្គភាពនិងសហគមន៍ឆ្នើម ដែលបានផ្តល់សេវាសាធារណៈគំរូក្នុងវិស័យបរិស្ថាន មានសហគមន៍តំបន់ការពារធម្មជាតិ ចំនួន៥ ដែលទទួលបានចំណាត់ថ្នាក់ជ័យលាភី រួមមានៈ លេខ១សហគមន៍តំបន់ការពារធម្មជាតិព្រៃក្តា ស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ខេត្តព្រះវិហារ លេខ២សហគមន៍បឹងការឆាង ស្ថិតក្នុងដែនជម្រកសត្វព្រៃពាមក្រសោមខេត្តកោះកុង លេខ៣សហគមន៍ទឹកធ្លាក់ចំបក់ ស្ថិតក្នុងឧទ្យានជាតិគិរីរម្យ ខេត្តកំពង់ស្ពឺ លេខ៤ សហគមន៍ជាំធ្លក ស្ថិតក្នុងដែនជម្រកសត្វព្រៃបឹងពែរ ខេត្តកំពង់ធំ និងលេខ៥ សហគមន៍តំបន់ការពារធម្មជាតិទឹកធ្លាក់ច្រកល្បៀង ស្ថិតក្នុងដែនជម្រកសត្វព្រៃឱរ៉ាល់ ខេត្តពោធិ៍សាត់
- បាននិងកំពុងគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ កសិ-ទេសចរណ៍ តំបន់សេដ្ឋកិច្ចពិសេស និងគម្រោងអភិរក្សព្រៃឈើ និងសត្វព្រៃសរុបចំនួន ១៨គម្រោង មានផ្ទៃដីសរុប ៩១ ៣០០ ហិកតា ក្នុងនោះ ៥គម្រោងបានដំណើរការល្អប្រសើរ ហើយ១៣គម្រោងទៀតកំពុងបន្តអនុវត្តនីតិវិធីតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលនិងក្រសួងបរិស្ថាន
- បាននិងកំពុងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច (ក្រោម១០ហិកតា) ចំនួន១១៥គម្រោង មានផ្ទៃដីសរុបទំហំ១០៧ ៧៧៦ហិកតា ក្នុងនោះ ៧៦គម្រោង បានបោះបង្គោលព្រំប្រទល់រួចរាល់ ហើយ៨គម្រោងទៀតបានរៀបចំប្លង់មេរួចហើយ

- បាននិងកំពុងគ្រប់គ្រងសម្របសម្រួលសហគមន៍តំបន់ការពារធម្មជាតិ ដែលមានបំរើសេវាកម្មទេសចរណ៍ធម្មជាតិចំនួន៣២ទូទាំងប្រទេស ដែលមានផ្ទៃដីទំហំ៣៩ ៩៥៣ហិកតា (សហគមន៍ចំនួន៨/៣២ មិនទាន់បានកំណត់ទំហំផ្ទៃដីនៅឡើយ)
- បានរៀបចំវេទិកាថ្នាក់តំបន់ស្តីពី **«ការការពារនិងអភិរក្សធនធានធម្មជាតិ»** ចំនួន៣លើក ក្រោមប្រធានបទផ្សេងៗគ្នា ដើម្បីបន្តប្រមូលព័ត៌មាន ពិភាក្សា និងរកដំណោះស្រាយពាក់ព័ន្ធនឹងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ
- បានរៀបចំសិក្ខាសាលាបច្ចេកទេសស្តីពី «ជំរុញការចូលរួមក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព»
- បានរៀបចំសន្និបាតថ្នាក់ជាតិប្រចាំឆ្នាំលើកទី១ស្តីពី«សហព័ន្ធសហភាព សហគមន៍អភិរក្សធនធានធម្មជាតិ»
- បានចងក្រងឯកសារនិងទិន្នន័យស្តីពីបុរាណស្ថាននិងបេតិកភណ្ឌវប្បធម៌ចំនួន៧កន្លែង ស្ថិតក្នុងខេត្តបន្ទាយមានជ័យនិង១០៨កន្លែងស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ខេត្តព្រះវិហារ ដើម្បីបង្កើតជាតំបន់បេតិកភណ្ឌធម្មជាតិ
- បានសិក្សាស្រាវជ្រាវផូស៊ីល ខ្យង ងាវ គ្រំ សត្វសមុទ្រ និងផូស៊ីលឈើ (Petrified Wood) នៅទីតាំងមួយចំនួននៅតាមបណ្តាខេត្តចំនួន៦ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។ បន្ថែមពីនេះ បានចុះធ្វើកំណាយផូស៊ីលឈើ ដោយបានរកឃើញផូស៊ីលឈើចំនួន២ដើម ១- ដើមទីមួយ មានអង្កត់ផ្ចិត៨០-១០០ស.ម. មានប្រវែង១៤ម៉ែត្រ និង២-ដើមទីពីរ ជីកបានប្រវែង៥ម៉ែត្រ ដែលកំណាយនេះធ្វើឡើងនៅក្នុងភូមិសាស្រ្តភូមិសាយ៉ស ឃុំកាឡែង ស្រុកលំផាត់ ខេត្តរតនគិរី នៅក្នុងដែនជម្រកសត្វព្រៃលំផាត់ ក្បែរទន្លេស្រែពក។

## ១.៣- កិច្ចគាំពារបរិស្ថាន

- បានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាលក្ខណៈប្រព័ន្ធ ស្ទើរគ្រប់គម្រោងវិនិយោគ ទាំងសាធារណៈនិងឯកជនចំនួន ១១៧គម្រោង ដែលបានជួយកាត់បន្ថយយ៉ាងច្រើននូវផលប៉ះពាល់មកលើបរិស្ថាននិងសង្គម
- បានរៀបចំចំណាត់ថ្នាក់គម្រោងអភិវឌ្ឍន៍ ដែលតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថានចំនួន២៧៦គម្រោងឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងចំនួន៦៨គម្រោងឬក៏របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញចំនួន៤៩គម្រោងដើម្បីសម្រួលនិងកាត់បន្ថយពេលវេលា ឱ្យស្របនឹងរយៈពេលតម្រូវចំនួន២៨ថ្ងៃ ឬ៣០ថ្ងៃ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានពង្រឹងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង ប្រព័ន្ធលូនិងប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងក្របខ័ណ្ឌនៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការដល់រដ្ឋបាលក្រុង ស្រុក និងបានជួយអន្តរាគមដល់ក្រុងស្រុកមួយចំនួន ដែលប្រឈមនឹងកំណើនសំរាមសំណល់រឹងច្រើន តាមរយៈការផ្តល់ការគាំទ្រថវិកា បច្ចេកទេស សម្ភារៈដឹកជញ្ជូនសំរាម និងការផ្តល់ឡដុតសំរាមនៅតាមទីតាំងគោលដៅសំខាន់ៗ
- បានពង្រឹងការអនុវត្តវិធានការច្បាប់ចំពោះទីតាំងបង្កការបំពុលនិងការគ្រប់គ្រងការសម្អាតសំណល់គ្រោះថ្នាក់ដែលបង្កដោយសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះ

- បានដំណើរការស្ថានីយតាមដានគុណភាពខ្យល់សាធារណៈចំនួន៤៩ទីតាំង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងបានដំណើរការស្ថានីយតាមដានគុណភាពទឹកទន្លេចតុមុខចំនួន១ទីតាំង ព្រមទាំងធ្វើការតាមដានគុណភាពប្រភពទឹកសាធារណៈ នៅរាជធានីភ្នំពេញ និងខេត្តគោលដៅចំនួន១១ជាប្រចាំ ហើយកំពុងជំរុញការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យ និងរាយការណ៍អំពីការបញ្ចេញ និងការបំភាយសារធាតុពុលទៅក្នុង បរិស្ថាន ទឹក ដី ខ្យល់ ចំពោះទីតាំងគម្រោង ដែលអាចបង្កហានិភ័យបរិស្ថានខ្ពស់។

## ១.៤- ការកសាងរដ្ឋបាលទំនើប

- បានបំពាក់សម្ភារៈនិងមធ្យោបាយបំពេញការងារសមស្រប ហើយកំពុងធ្វើផែនការពង្រីកអគារទីស្តីការក្រសួង ដើម្បីឆ្លើយតបនឹងតម្រូវការនិងវិសាលភាពការងារដែលកាន់តែកើនឡើងខ្លាំង ស្របនឹងដំណើរការវិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ
- បានអនុវត្តផែនការកសាងធនធានមនុស្ស តាមរយៈវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការមន្ត្រីឧទ្យានុរក្ស ជាពិសេសនៅបណ្តាការិយាល័យក្រុង ស្រុក មន្ទីរបរិស្ថានរាជធានី ខេត្ត លើការគ្រប់គ្រងធនធានធម្មជាតិ ការងារគ្រប់គ្រងរដ្ឋបាល វិធីសាស្ត្រល្បាតក្នុងតំបន់ការពារធម្មជាតិ និងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- បានសម្របសម្រួលនីតិវិធី ក្នុងការអនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញរបស់ក្រសួងបរិស្ថាន និងបង្កើតអង្គភាពថវិកាចំនួន៣១ (អគ្គលេខាធិការដ្ឋានចំនួន១ អគ្គនាយកដ្ឋានចំនួន៥ និងមន្ទីរបរិស្ថានរាជធានី ខេត្តចំនួន២៥) ជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ
- បានសហការជាមួយក្រសួងមុខងារសាធារណៈរៀបចំបង្កើត និងអនុវត្តយន្តការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យបរិស្ថាន ទៅតាមអង្គភាពផ្តល់សេវាសាធារណៈចំនួន៤ប្រភេទរួមមាន នាយកដ្ឋានចំណុះទីស្តីការក្រសួង មន្ទីរបរិស្ថានរាជធានី ខេត្ត តំបន់ការពារធម្មជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន ប្រសិទ្ធភាពការងារ និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈក្នុងវិស័យបរិស្ថានឱ្យកាន់តែប្រសើរឡើង
- បានផ្សព្វផ្សាយនិងបញ្ជ្រាបចំណេះដឹងបរិស្ថានឱ្យបានដល់សាធារណជនគ្រប់មជ្ឈដ្ឋាន ជាពិសេសដល់យុវជននិងសិស្សានុសិស្ស តាមរយៈការផលិតព័ត៌មានបរិស្ថានប្រចាំថ្ងៃ សិក្ខាសាលាស្តីពីចំណេះដឹងនៃកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ វេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថាន ទិវាបរិស្ថានជាតិនិងបរិស្ថានពិភពលោក
- បានសម្របសម្រួលប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ក្នុងការស្វែងរកការគាំទ្រដល់អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យបរិស្ថាន ដោយបានចុះកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់សរុបចំនួន១១ បន្ថែមទៀតក្នុងឆ្នាំ២០១៩ ហើយបច្ចុប្បន្នក្រសួងបរិស្ថានមានកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់សរុបចំនួន២៥កំពុងមានសុពលភាព
- បានសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងសហការជាមួយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ដែលបានបញ្ចប់គម្រោងដែលកំពុងដំណើរការ និងគម្រោងដែលកំពុងរៀបចំសរុប៧០ ដែលក្នុងនោះគម្រោងដែលបានបញ្ចប់មានចំនួន២៥ បានចំណាយថវិកាសរុបអស់ចំនួន២៥លានដុល្លារអាម៉េរិក គម្រោងកំពុងដំណើរការចំនួន៣២ មានថវិកាសរុប១២៧លានដុល្លារអាម៉េរិក និងគម្រោងដែលកំពុងរៀបចំចំនួន១៣ ដែលមានថវិកាជាង៩០លានដុល្លារអាម៉េរិក

- នៅក្នុងអាណត្តិទី៥និងបន្តដល់អាណត្តិទី៦នេះ ដោយទទួលបានការយល់ព្រមពីសម្តេចតេជោ នាយករដ្ឋមន្ត្រី ក្រសួងបរិស្ថានបានផ្តួចផ្តើមគំនិតរៀបចំសេចក្តីព្រាងក្រមបរិស្ថានដោយធនធានធម្មជាតិនិងគ្រោងបញ្ចប់នៅ ឆ្នាំ២០២១។

**១.៥- សមិទ្ធផលសំខាន់ៗក្នុងផ្នែកព្រៃឈើ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានក្នុងឆ្នាំ២០១៩៖

**ក- ការងារព្រៃឈើ**

- ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងព្រៃឈើ៣៨លើក នៅខេត្តកំពង់ស្ពឺ កោះកុង កែប បន្ទាយមានជ័យ ឧត្តរមានជ័យ ក្រចេះ មណ្ឌលគិរី កំពត តាកែវ ស្ទឹងត្រែង រតនគិរី កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំ មានអ្នកចូលរួម១ ៤៦៣នាក់(ស្រី៥៦៦នាក់)

- ចេញសេចក្តីប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍១១កន្លែង មានផ្ទៃដីទំហំ៧ ៣៤៩,៩៥ហ.ត. នៅខេត្តកំពង់ធំ១កន្លែង មានផ្ទៃដីទំហំ១ ២៧៥,៤៦ហ.ត. និងខេត្តបាត់ដំបង១០កន្លែង មានផ្ទៃដីទំហំ៦ ០៧៤,៤៩ហ.ត.

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍១២កន្លែង លើផ្ទៃដីទំហំ៧ ៥០១,៤៩ហ.ត. ក្នុងនោះខេត្តបាត់ដំបង១០កន្លែង មានផ្ទៃដីទំហំ៦ ០៧៤,៤៩ហ.ត. កោះកុង១កន្លែង មានផ្ទៃដីទំហំ៣២៣ហ.ត. និងខេត្តមណ្ឌលគិរី១កន្លែង មានផ្ទៃដីសរុបទំហំ១ ១០៤ហ.ត.

- ផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត៧១គ្រឿង និងយានយន្ត១០៧គ្រឿង ជូនក្រុមហ៊ុន៦

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុន១៣ក្រុមហ៊ុន និងអ្នកស្នើសុំ៥នាក់ មានឈើហុបមូល៣៣ ១០៣ម៣ ឈើអារ៤ ១៨៤ម៣ ឈើប្រណីត១០៨ម៣ និង៧៤៣គីឡូក្រាម ឈើជ្រុង២ ៧៩០ម៣ កូនឈើ២០០ ០១៨ដើម អុសចម្រុះ៥៣ ១៨១ស្ទែរ ជន្លង់ម្រេច២៣៩ដើម សសរ៥៦ដើម ធ្យូង១៨ ២១៧គីឡូក្រាម គ្រាប់ស្លែង៥៣៧គីឡូក្រាម គល់ផ្ចង់និងគល់បេង៥៩០គីឡូក្រាម ពកបេង៣៩៤គីឡូក្រាម និងជ័រទឹក៤៨២តោន និងផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើសាជាថ្មីជូនក្រុមហ៊ុន១ក្រុមហ៊ុន។

**ខ- ការដាំដើមឈើ**

- ថែទាំចម្ការឈើចាស់ ចម្ការពូជឈើ ឡូតិ៍បង្ហាញកសិរុក្ខកម្មនៅស្ថានីយផ្សព្វផ្សាយ និងស្ថារព្រៃឈើ៤កន្លែង ស្ថិតនៅខេត្តសៀមរាប កំពង់ធំ ព្រះសីហនុ និងខេត្តស្វាយរៀង ផ្ទៃដីទំហំ៩៨០ហ.ត.

- បង្កើតឡូតិ៍បង្ហាញកសិរុក្ខកម្មក្នុងសហគមន៍ចំបក់ហោះ ស្ថិតនៅស្រុករវៀង ខេត្តព្រះវិហារ និងដាំរួចលើផ្ទៃដីទំហំ១២ហ.ត. តាមផែនការប្រចាំឆ្នាំ២០១៩ មានកូនស្វាយចន្ទី២ ៥០០ដើម ចេក១ ៣៥០ដើម និងកូនឈើប្រភេទគ្រញូង បេងនិងផ្ចង់២ ៧០០ដើម

- ថែទាំចម្ការរុក្ខទិវា ស្ថិតនៅខេត្តកំពត កណ្តាល តាកែវ កំពង់ធំ និងខេត្តក្រចេះ សរុប៦០ហ.ត.

- ប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិ ៩កក្កដា ឆ្នាំ២០១៩ ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសម្បូរណ៍ ខេត្តក្រចេះ លើផ្ទៃដីទំហំ១០ហ.ត. ដោយបានដាំកូនឈើកកោះ គគីរ ផ្ចង់ អង្កាញ់ និងគ្រញូង១០ ៦៩៥ដើម ព្រមទាំងបានបោះបង្គោលថ្មនិងព័ទ្ធរបងលួសប្រវែង១ ៥០០ម៉ែត្រ។

**គ- ការនាំចេញ នាំចូលឈើ**

- ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុន៧ធ្វើការនាំចេញផលិតផលរានទេវតា គ្រឿងសង្ហារិម ជើងសាឡុង និងឈើអារកែច្នៃទៅក្រៅប្រទេសរួមមាន ប្រទេសជប៉ុន អាម៉េរិក ចិន វៀតណាម និងប្រទេសថៃ មានបរិមាណ២ ១៧៨ម៣ និងផលិតផលជ័រទឹក២៩១តោន

-អនុញ្ញាតឱ្យក្រុមហ៊ុន៤ធ្វើការនាំចូលផលិតផលឈើនិងឈើកែច្នៃពីប្រទេសចិន កុងហ្គោ កាមេរូន និងអ៊ូហ្គង់ដាមានបរិមាណ១ ៦៨១ម៣

-ផ្តល់ទិដ្ឋាការអាជ្ញាបណ្ណឱ្យក្រុមហ៊ុន១៣ នាំចេញផលិតផលឈើកែច្នៃ ក្តារកាប៉ូក្រាល គ្រឿងសង្ហារិម និងជើងសាឡុង២ ៨៣០ម៣ ឈើអាកាស្យា១ ៦៣២ស្ទែរ និងអនុផលព្រៃឈើដូចជាផលិតផលជ័រទឹក គ្រឿងសង្ហារិមកែច្នៃពីឫស្សី ឈើចន្ទន៍ក្រឹស្នាកែច្នៃសរុប២៦៨តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាបណ្ណនាំចូលផលអនុផលព្រៃឈើ៤ក្រុមហ៊ុន មានបរិមាណឈើកែច្នៃ១ ៧៥២ម៣។

**ឃ- លទ្ធផលនៃការបង្ក្រាបបទល្មើសព្រៃឈើ**

-ចាប់ឃាត់និងដកហូតឈើនិងសត្វព្រៃមានឈើហុបមូលជ្រុងសរុប៣៩៧ម៣ ឈើអារ២ ៩៦៧ម៣ ឈើគ្រាក់គ្រញូង២ម៣ សសរ១ ៥៩៧ដើម កូនឈើ៣ ២៧៣ដើម ជំនៀរទ្រៀក១ ៦២៤សន្លឹក ទ្វារ៦វង់ អុស ១ ១៧១ស្ទែរ ធ្យូង១៦១ ៦៧៦គីឡូក្រាមនិង១៧០ការុង ផ្ទះប្រក់ស័ង្កសី១ខ្នង សំបកឈើនាងនួន១ ៣០០ គីឡូក្រាម សត្វព្រៃរស់ងាប់៤ ៤៨១ក្បាលនិងសាច់សត្វព្រៃទម្ងន់៨៧៦គីឡូក្រាម ក្រពះស្វាក្រៀម២បន្ទះ ក្រចកខ្លាឃ្មុំតូចក្រៀម១៤គូ ចង្កូមខ្លាឃ្មុំ១០គូ ចែជ្រូកព្រៃ៦គូ សំណាកចែជ្រូកព្រៃ៥គីឡូក្រាម ភ្លុកដំរី៨គីឡូក្រាម សំណាកកម្ទេចភ្លុកដំរី៤គីឡូក្រាម ស្នែងឈ្លូស៣ស្នែង ឫស្សីឃ្លៃ១៣ ៨០០ដើម បង្គោលថ្ម១១៨ដើម ស្បែកសត្វពស់ត្រី ១ ០១៣បន្ទះ ព្រមទាំងបង្ក្រាបការកាប់រានដុត ឈូសឆាយដីព្រៃ១ ៧៧៣ហ.ត. ស្ថិតនៅខេត្តកំពង់ឆ្នាំង ក្រចេះ ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កំពង់ស្ពឺ ព្រះសីហនុ ពោធិ៍សាត់ និងខេត្តបាត់ដំបង

-សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ១ ២០១ករណី ក្នុងនោះ ៦០៣ករណីចាត់ថ្នាក់ជាករណីកំពុងតែធ្វើការដោះស្រាយនៅតុលាការ និង៥៩៨ករណីចាត់ថ្នាក់ជាករណីដែលបានបញ្ចប់សំណុំរឿងតាមនីតិវិធីនៃច្បាប់ស្តីពីព្រៃឈើ

-ចាប់ឃាត់រថយន្ត៥៣៦គ្រឿង គោយន្ត១៩០គ្រឿង ម៉ូតូ១០៣គ្រឿង ម៉ូទ័រ៥០គ្រឿង រ៉ឺម៉ក៣៨គ្រឿង ម៉ាស៊ីន២៨គ្រឿង តុឈូស២៦គ្រឿង ត្រាក់ទ័រ១១គ្រឿង រណារយន្ត៩គ្រឿង ប៊ុលដូស័រ៨គ្រឿង ឌីណាម៉ូ៦គ្រឿង អេស្កាវ៉ាទ័រ៤គ្រឿង ទូក១៥គ្រឿង រណារថាស១២គ្រឿង បង្គុំក្រឡឹង១១គ្រឿង និងវត្ថុតាងមួយចំនួនទៀត។

## ២- វប្បធម៌ សាសនា និងព័ត៌មាន

### ២.១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**ក- ការងារអភិរក្សបេតិកភណ្ឌវប្បធម៌**

ក្រសួងបានបន្តពង្រឹងកិច្ចការពារថែរក្សានិងអភិវឌ្ឍន៍បេតិកភណ្ឌជាតិទាំងរូបីនិងអរូបី ដោយបាន និងកំពុងត្រៀមឯកសារចុះបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ព្រមជាមួយគ្នានេះ ក្រសួងបានបន្តថែរក្សាជួសជុលទល់ទ្រប្រាសាទ វត្ថុសិល្បៈបុរាណ ស្ថានបុរាណ គ្រប់គ្រងស្ថានីយបុរាណនិងបន្តប្រមូលវត្ថុបុរាណដែលស្ថិតនៅរាយប៉ាយក្នុងមូលដ្ឋានទូទាំងប្រទេស។ ទន្ទឹមនេះក្រសួងបានពង្រឹងយន្តការ និងបទដ្ឋានគតិយុត្តនានារាំងស្កាត់រាល់ការរំលោភនិងបំផ្លាញបេតិកភណ្ឌវប្បធម៌។

**ក.១- សម្បត្តិវប្បធម៌ជាតិចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនិងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ**

- ក្រុមការងារក្រសួងបានរៀបចំចងក្រងឯកសារល្ខោនខោលដើម្បីស្នើសុំចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ។ តាមរយៈកិច្ចប្រជុំលើកទី១៣នៃគណៈកម្មការអន្តររដ្ឋាភិបាលសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់អង្គការយូណេស្កូ បានអនុម័តយល់ព្រមតាមសេចក្តីសម្រេច Decision13.COM.10.a.3 ចុះល្ខោនខោលចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីស

- បានកែសម្រួលឯកសារក្បាច់គុនល្បុក្កតោតាមការស្នើសុំរបស់អង្គការយូណេស្កូ និងបានដាក់ជូនទៅវិញនៅក្នុងខែកញ្ញា ឆ្នាំ២០១៩ ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ

- ក្រុមការងារក្រសួងក៏បាននិងកំពុងរៀបចំចងក្រងឯកសារស្នើសុំចុះបញ្ជីប្រាសាទកោះកែរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

- សិក្សានិងតាមដានការស្នើសុំចុះបញ្ជីបេតិកភណ្ឌវប្បធម៌និងធម្មជាតិក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងសម័យប្រជុំលើកទី៤៣ នៅទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់ ឆ្នាំ២០១៩

- សិក្សាលើអនុសាសន៍និងឯកសារសំណើដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌និងធម្មជាតិ របស់រដ្ឋភាគីនៃអនុសញ្ញាបេតិកភណ្ឌឆ្នាំ១៩៧២ សម្រាប់កិច្ចប្រជុំលើកទី៤៣នៅទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់ ឆ្នាំ២០១៩

- សិក្សានិងស្វែងយល់បន្ថែមពីមុខងារស្នូលនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបី។

**ក.២- ការងារគាំពារនិងអភិរក្សបេតិកភណ្ឌវប្បធម៌រូបី**

☼ **ការអភិរក្សនិងជួសជុល** : ក្រសួងបានធ្វើការជួសជុលទល់ទ្រប្រាសាទបន្ទាយឆ្មារចំនួន៦៦ចំណុច ជួសជុលប្រាសាទចំនួន៧ ដូចជាប្រាសាទឯកភ្នំ ប្រាសាទបាសែត ប្រាសាទបន្ទាយទ័ព ប្រាសាទបាកាន ប្រាសាទចតុមុខ ប្រាសាទព្រះថ្កោល និងប្រាសាទព្រះសម្ពី ជួសជុលព្រះវិហារចំនួន៤ គឺវត្តកោជនឹង វត្តកំពង់ព្រះ វត្តស្រីទួល និងវត្តអង្គរស្បូ(កំពុងជួសជុល) ជួសជុលស្ពានបុរាណចំនួន១ គឺស្ពានទ័ព ខេត្តឧត្តរមានជ័យ និងបានជួសជុលវត្ថុបុរាណនៅសារមន្ទីរជាតិបានចំនួន១០៤រូប។

☼ **កំណាយបុរាណវិទ្យា** : ក្រសួងបានធ្វើកំណាយសង្គ្រោះចំនួន៦ស្ថានីយ គឺ ទួលប្រាសាទភូមិមូលជើងឯក(រាជធានីភ្នំពេញ) ស្ថានីយល្អាងស្ពាន(ខេត្តបាត់ដំបង) ទួលកី(ខេត្តព្រៃវែង) លង្វែក(ខេត្តកំពង់ឆ្នាំង)និងវត្តអង្គរស្បូ(ខេត្តកណ្តាល)និងបានវិភាគសមុច្ច័យបុរាណវិទ្យានៅផ្លូវ៦០ម៉ែត្រ(ខេត្តកណ្តាល)។ ក្រសួងបានសហការជាមួយមន្ទីររាជធានីភ្នំពេញនិងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកបើកគម្រោងកំណាយបង្ការមុនពេលសាងសង់រូបសំណាកស្តីពីសោកនាដកម្មរបស់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅទីតាំងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក។

☼ **ក្រសួងបានរៀបចំបញ្ជីសារពើភណ្ឌនិងធ្វើផែនទីកំណត់ធនធានវប្បធម៌** ដោយបានសហការជាមួយអង្គការពាក់ព័ន្ធ អាជ្ញាធរដែនដី ដើម្បីចុះពិនិត្យនិងស្រង់ទិន្នន័យភ្នំបានចំនួន៧ទីតាំងនៅខេត្តកំពតនិងបានទទួលវត្ថុសិល្បៈសរុបចំនួន២៤៦រូប/ដុំ/ផ្ទាំង ក្នុងនោះមានសមុច្ច័យ១១៥ដុំ។

☼ **ក្រសួងបានសហការផ្សព្វផ្សាយស្តីពីបុរាណដ្ឋានដែលបានចុះបញ្ជីនិងធ្វើសាលាកបត្រមាន**ចំនួន១៦២ច្បាប់នៅស្រុកបាភ្នំខេត្តព្រៃវែង និងបានចូលរួមដោះស្រាយផលប៉ះពាល់វិវាទដីធ្លីនៅស្ថានីយបុរាណចំនួន៣ខេត្ត គឺខេត្តកណ្តាល ខេត្តព្រៃវែង និងនៅភ្នំគូលែន(ខេត្តសៀមរាប) ព្រមទាំងបានបន្តចុះសិក្សាស្រាវជ្រាវស្រង់ទិន្នន័យប្រាសាទ ស្ថានីយ ទួលនិងស្រះបុរាណនៅរាជធានីខេត្ត ដើម្បីរៀបចំកំណត់ដែនការពារទីតាំងបេតិកភណ្ឌវប្បធម៌។

### ក.៣- ការអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី

ដើម្បីធានាការរក្សាការពារបេតិកភណ្ឌវប្បធម៌អរូបីឱ្យបានគង់វង្ស ក្រសួងបានលើកកម្ពស់ធនធានមរតកមនុស្សរស់ជាយន្តការមួយជំរុញឱ្យមានការផ្ទេរចំណេះ ជំនាញ ទេពកោសល្យដល់យុវជនជំនាន់ក្រោយ។ ក្រសួងក៏បានគាំទ្រនិងលើកទឹកចិត្តដល់អ្នកនិពន្ធ អ្នកដឹកនាំរឿង សិល្បករ ផលិតករ វិចិត្រករនិងតន្ត្រីករដែលបានបង្កើតស្នាដៃថ្មីៗលើគ្រប់ផ្នែកបច្ចេកទេសវប្បធម៌ សំដៅអភិវឌ្ឍន៍ជាតិឱ្យកាន់តែសម្បូរបែបនិងអភិរក្សទម្រង់សិល្បៈមួយចំនួនដែលស្ទើរតែបាត់បង់ឱ្យរស់ឡើងវិញ ដោយបន្តរៀបចំបញ្ជីសារពើភណ្ឌវប្បធម៌អរូបីបច្ចុប្បន្នកម្មថ្នាក់ជាតិតាមប្រព័ន្ធកុំព្យូទ័រ ទុកជាឯកសារគោលសម្រាប់ជាវិធានការគ្រប់គ្រងនិងអភិរក្សបេតិកភណ្ឌអរូបីនិងដើម្បីជាប្រយោជន៍ដល់ការសិក្សា ស្រាវជ្រាវនិងអប់រំផ្សព្វផ្សាយ។ ចាត់មន្ត្រីជំនាញចុះទៅខេត្តមណ្ឌលគិរីនិងខេត្តរតនគិរី ដើម្បីអភិរក្សសិល្បៈរបស់ជនជាតិដើមភាគតិច។ ដំឡើងស្នាដៃល្ខោនបាសាក់ យីកេ របាំបុរាណប្រពៃណីនិងល្ខោនស្រមោលស្បែក(ធំ-តូច) និងបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងស្ថិតិធនធានវប្បធម៌ ដោយបាននិងកំពុងចុះស្រាវជ្រាវប្រមូលឯកសារស្ថិតិវប្បធម៌ជាតិនៅតាមរាជធានី ខេត្ត ដើម្បីចងក្រងទុកជាឯកសារគោលដល់ការអភិរក្សនិងអភិវឌ្ឍន៍វប្បធម៌។

### ខ- ការងារលើកស្ទួយតម្លៃវប្បធម៌ជាតិ

ក្រសួងបានពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវប្បធម៌ជាតិកាន់តែទូលំទូលាយតាមរយៈសារមន្ទីរ ការតាំងពិព័រណ៌ ការសិក្សាស្រាវជ្រាវ ការរៀបចំព្រឹត្តការណ៍ វប្បធម៌ ការជំរុញការច្នៃប្រឌិតបង្កើតស្នាដៃថ្មីនិងពង្រីកឧស្សាហកម្មវប្បធម៌។

### ខ.១- សារមន្ទីរនិងមណ្ឌលវប្បធម៌

ភ្ញៀវចូលសារមន្ទីរ(សារមន្ទីរជាតិនិងសារមន្ទីរទួលស្លែង) និងមណ្ឌលវប្បធម៌(មណ្ឌលជើងឯកនិងមណ្ឌលវត្តភ្នំ) ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩ មានចំនួន១ ២៧៣ ៥៥១នាក់ ។

| ភ្ញៀវទេសចរជាតិនិងអន្តរជាតិចូលទស្សនាសារមន្ទីរ និងមណ្ឌលវប្បធម៌ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | សារមន្ទីរជាតិ | | សារមន្ទីរទួលស្លែង | | មណ្ឌលជើងឯក | | រមណីយដ្ឋានវត្តភ្នំ | |
| | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ | ភ្ញៀវជាតិ | អន្តរជាតិ |
| ២០១៩ | ៤៤ ៩៦៤ | ១៧៦៤៤៧ | ១២១១៧០ | ៤០២៥៧៩ | ៨០៦០៧ | ១៥៩១១០ | ៧៦៥៩០ | ២១២០៨៤ |

### ខ.២- ការងារផ្សព្វផ្សាយវប្បធម៌

- តំបន់រមណីយដ្ឋានបេតិកភណ្ឌវប្បធម៌នៅឧទ្យានអង្គរ ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុក គឺអាជ្ញាធរទាំង៣(បី)តំបន់ ក៏ដូចជារមណីយដ្ឋានបេតិកភណ្ឌតាមបណ្តាខេត្តមួយចំនួនទៀតបានបង្កើនការគ្រប់គ្រងការផ្សព្វផ្សាយអំពីតម្លៃជាសកលនៃសម្បត្តិបេតិកភណ្ឌវប្បធម៌ តាមគ្រប់រូបភាពដើម្បីទាក់ទាញភ្ញៀវទេសចរចូលទស្សនានិងចូលរួមថែរក្សាការពារព្រមទាំងពង្រឹងគុណភាពសេវាកម្ម ក៏ដូចជាការជំរុញឱ្យមានផលិតផលទេសចរថ្មីដូចជាវត្ថុសិល្បៈដែលជានាគុណតម្លៃនិងវត្ថុនៃអនុស្សាវរីយ៍ដែលសម្គាល់អត្តសញ្ញាណជាតិ
- ការអភិវឌ្ឍកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតំបន់រមណីយដ្ឋានបេតិកភណ្ឌវប្បធម៌មានការវិវត្តឈានឡើងជាលំដាប់(បើធៀបនឹងឆ្នាំ២០១៨) សំដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការទស្សនារបស់ភ្ញៀវទេសចរនិងបានផ្តល់បទពិសោធល្អៗពីការទស្សនាសម្រាប់ភ្ញៀវ ក៏ដូចជាការជួយលើកកម្ពស់កម្រិតជីវភាពប្រជា-ពលរដ្ឋក្នុងតំបន់

- រៀបចំការតាំងពិព័រណ៍មិនអចិន្ត្រៃយ៍ចំនួន៥លើក និងរៀបចំតាំងពិព័រណ៍សមិទ្ធផលវប្បធម៌ក្នុងពិធីសម្ពោធវិមានឈ្នះឈ្នះ

- បើកសិក្ខាសាលាចំនួន២(ពីរ) គឺសិល្បៈចម្លាក់ស្បែកនិងរបាំក្បាច់បុរាណខ្មែរ ព្រមទាំងបើកមហោស្រពសិល្បៈល្ខោនស្រមោលស្បែកធំ

- ចូលរួមសម្តែងក្នុងឱកាសមហោស្រពសិល្បៈអាស៊ាន នៅតាមប្រទេសជាសមាជិកអាស៊ាន និងបានរៀបចំព្រឹត្តិការណ៍សិល្បៈវប្បធម៌សំខាន់ៗ ដូចជាមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ទិវាវប្បធម៌ជាតិ ៣មីនា មហោស្រពភាពយន្ត មហោស្រពបង្ហើរខ្លែងខ្មែរ ពិព័រណ៍សៀវភៅថ្នាក់ជាតិ ប្រឡងស្នាដៃតែងនិពន្ធប្រលោមលោកនិងកំណាព្យរឿង។

**ខ.៣- ការងារស្រាវជ្រាវនិងបោះពុម្ព**

- បានសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិក្នុងការសិក្សាស្រាវជ្រាវរុករកកំណត់ទីតាំង និងត្រៀមចុះបញ្ជីទីតាំងនៃស្ថានីយបុរេប្រវត្តិសាស្ត្រដែលកប់ក្នុងដី ដោយបានធ្វើកំណាយបុរាណវិទ្យានៅតាមស្ថានីយបុរាណនិងបុរាណដ្ឋានចំនួន៧ស្ថានីយ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង ព្រៃវែង និងខេត្តកំពង់ឆ្នាំង

- បានសិក្សាស្រាវជ្រាវ ចងក្រងល្បែងប្រជាប្រិយខ្មែរ ប្រពៃណីទំនៀមទម្លាប់ជនជាតិដើមភាគតិចតន្ត្រីបុរាណមហោរី ក្បាច់ចម្លាក់បុរាណខ្មែរ តម្បាញសូត្រ និងបានសរសេរអត្ថបទទស្សនាវដ្តីសម្រាប់បោះពុម្ពប្រចាំឆ្នាំ។ ទន្ទឹមនោះនាយកដ្ឋានជំនាញកំពុងស្រាវជ្រាវប្រមូលទិន្នន័យស្ថិតិវប្បធម៌ទូទាំងប្រទេស ដើម្បីចងក្រងជាឯកសារសម្រាប់បោះពុម្ពផ្សាយ

- បានរៀបចំបោះពុម្ពឯកសារជាសៀវភៅផ្នត់ស្តីពីដំណើរការបញ្ចូលបេតិកភណ្ឌវប្បធម៌ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនិងនីតិវិធី ព្រមទាំងបោះពុម្ពឯកសារស្តីពីការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌អរូបីទៅក្នុងបញ្ជីអភិរក្សបន្ទាន់និងបញ្ជីតំណាងបេតិកភណ្ឌអរូបីនៃមនុស្សជាតិ។

**ខ.៤- ការងារជំរុញការកែច្នៃប្រឌិតបង្កើតថ្មីនិងឧស្សាហកម្មវប្បធម៌**

- បាននិងកំពុងផលិតកម្មវិធីវប្បធម៌ វីដេអូឯកសារវប្បធម៌ និងភាពយន្តខ្មែរខ្នាតវែង សម្រាប់កម្មវិធីភាពយន្តក្នុងស្រុកបានចំនួន១១ចំណងជើង និងផលិតខារ៉ាអូខេចំនួន៨លេខ

- បានសិក្សានិងបង្កើតស្នាដៃទម្រង់របាំបុរាណ ប្រពៃណី ល្ខោននិងបង្កើតស្នាដៃគំនូរនិងចម្លាក់

- បានប្រគុំតន្ត្រីនិងសម្តែងសិល្បៈមហាជននិងអាជីពសរុបចំនួន៣ ១០៣លើក និងបានចេញសម្តែងនៅក្រៅប្រទេសចំនួន១៤លើក

- អង្គភាពជំនាញបានបញ្ជូនគ្រូជំនាញសិល្បៈចុះបង្ហាត់តាមសាលារៀន អង្គការ សង្គមស៊ីវិល និងនៅមន្ទីរតាមបណ្តាខេត្ត

- បានសិក្សាបង្កើតស្នាដៃថ្មីៗនូវទម្រង់របាំបុរាណប្រពៃណីជាទ្រង់ទ្រាយធំទស្សនីយភាពសម្រាប់សម្តែងក្នុងពិធីបុណ្យជាតិ អន្តរជាតិនិងទទួលគណៈប្រតិភូអន្តរជាតិ។

## គ- ការងារផ្តល់សេវាសាធារណៈ(គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០១៩)

| ១- ការងារផ្តល់សេវាសាធារណៈ | | |
|---|---|---|
| បរិយាយ | ឯកតា | ២០១៩ |
| ការផ្តល់លិខិតអនុញ្ញាតផ្នែកសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលលើស្នាដៃគ្មានមរតកសាសន៍ តូរ្យតន្ត្រី និងអក្សរសាស្ត្រ | ស្នាដៃ | ៣១៤ |
| ផ្តល់អាជ្ញាបណ្ណភាពយន្ត-វីដេអូ | ច្បាប់ | ១៣ |
| ផ្តល់ទិដ្ឋាការចម្រៀងខារ៉ាអូខេខ្មែរ | លេខ | ២២ |
| ផ្តល់ទិដ្ឋាការភាពយន្តបរទេសរឿងធំ | ចំណងជើង | ២០៨ |
| ផ្តល់ទិដ្ឋាការភាពយន្តខ្មែររឿងធំ | ចំណងជើង | ២៩ |
| ផ្តល់ទិដ្ឋាការភាពយន្តបរទេស(ភាគ) | ចំណងជើង | ៨០ |
| បានត្រួតពិនិត្យអនុញ្ញាតនាំចេញនាំចូលវត្ថុសិល្បៈអនុស្សាវរីយ៍ | រូប | ២ ៥០៩ |
| អ្នកស្រាវជ្រាវចូលអាននៅបណ្ណាល័យ | នាក់ | ២១ ៣០៩ |
| ផ្តល់លេខ ISBN ដល់អ្នកបោះពុម្ព | លេខ | ៣៧១ |

| ២- ចំណូលថវិកាបានពីការផ្តល់សេវានិងបម្រើសេវាសាធារណៈ | *ឯកតា* : *គិតជាប្រាក់រៀល* |
|---|---|
| បរិយាយ | ២០១៩ |
| លិខិតអនុញ្ញាតផ្នែកសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល | ១១ ៣៣៧ ០០០ |
| អនុញ្ញាតច្បាប់ផ្តល់អាជ្ញាបណ្ណទិដ្ឋាការអ្នកអាជីវកម្មភាពយន្ត-វីដេអូ | ៨៣៣ ០៨៩ ៦០០ |
| អនុញ្ញាតនាំចេញ នាំចូលវត្ថុសិល្បៈ | ៥៥ ៩៧៧ ០០០ |

## ២.២- ការងារអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានបេតិកភណ្ឌពិភពលោក

### ២.២.១- សមិទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា

#### ក- ការងារអភិរក្សនិងជួសជុលប្រាសាទ

**- ការជួសជុល** : ដើម្បីអភិរក្សនិងជួសជុលប្រាសាទនៅក្នុងតំបន់ឧទ្យានអង្គរនិងតំបន់ក្រៅឧទ្យានអង្គរ អាជ្ញាធរអប្សរាបានសហការជាមួយអង្គការនិងដៃគូនានា ដូចជាអង្គការមូលនិធិប្រាសាទពិភពលោក (WMF) គម្រោងអភិរក្សអាល្លឺម៉ង់-អប្សរា(GACP) វិទ្យាស្ថានស្រាវជ្រាវសម្បត្តិវប្បធម៌(NARA), Archaeogohy Survey of India(ASI), Japan APSARA Safegaurding Angkor(JASA), The Deutsche Gesellschaft fur Internationale Zusammenarbeit(GIZ), Sophia Mission(SOPHIA), TOBUNKEN, ITALIA និងស្ថានទូតបារាំង បានជួសជុលស្ថានីយមួយចំនួនដូចជា ជួសជុលស្ពានចំនួន២ គឺស្ពានហាលប្រាសាទអង្គរវត្តខាងលិចប្រវែង ៣០ម៉ែត្រនិងស្ពានហាលខាងជើងខ្លោងទ្វារដីឆ្នាំង។ ជួសជុលប្រាសាទចំនួន១៧ គឺកំពែងអង្គរធំប្រវែង២០ម៉ែត្រ

រុះរើខ្លោងទ្វារប្រាសាទតានៃខាងកើតដំណាក់កាលទី១ មឈូសបុរាណនៅប្រាសាទបន្ទាយសម្រែបានចំនួន១តួប៉ម លេខ៨និងបណ្ណាល័យជ្រុងអាគ្នេយ៍ប្រាសាទបាគង ប្រាង្គខាងជើងប្រាសាទបាតជុំ រុះរើប្រាសាទទន្លេស្ងួតដំណាក់កាលទី១ ប្រាសាទបាខែង ប្រាសាទព្រះខ័ន ប្រាសាទអង្គរវត្ត ប្រាសាទបាគង ប្រាសាទតាព្រហ្ម ប្រាសាទបាយ័ន ប្រាសាទតុបលិច ប្រាសាទប្រែរូប ប្រាសាទបន្ទាយសម្រែ ប្រាសាទមេបុណ្យខាងលិច និងប្រាសាទអកយំ(បានបញ្ចប់ដំណាក់កាលកសិន្ទុទី១)។ ជួសជុលច្រាំងខាងលិចប្រាសាទអង្គរវត្តប្រវែង៥០ម៉ែត្រនិងស្រះទឹកខាងមុខប្រាសាទអង្គរវត្តដំណាក់កាលទី១ ប្រវែង១៥ម៉ែត្រ។

- **ការអភិរក្សនិងទល់ទ្រ :** ក្រុមការងារបានបំពេញការងារនៅ Laboratory ក្នុងអភិរក្សដ្ឋានអង្គរ ប្រាសាទបាយ័ន ខ្លោងទ្វារដីឆ្នាំង សារមន្ទីរកុលាលភាជន៍ភូមិតានី និងបានទល់ទ្រនិងសង្គ្រោះបន្ទាន់បាន១៥ចំណុច នៅប្រាសាទឥដ្ឋនៅខាងមុខប្រាសាទបាគង ប្រាសាទបេងមាលា និងប្រាសាទចៅស្រីវិបុល។

- **កំណាយបុរាណវិទ្យា** បានកំណាយសង្គ្រោះចំនួន១៥កន្លែង រួមមានកំពែងអង្គរធំផ្នែកខាងត្បូង នៅខាងលិចប្រាសាទអង្គរវត្ត ខ្លោងទ្វារដីឆ្នាំង ត្រពាំងជើងគ្រុសនិងត្រពាំងតាជោ នៅតំបន់ភ្នំក្រោម ប្រាសាទអកយំ និងនៅតាមបណ្តោយផ្លូវសាងសង់ថ្មីឡើងខ្នងភ្នំគូលែនពីទីប្រជុំស្រុកស្វាយលើដល់ព្រះអង្គធំ។

-**ការបោះបង្គោលតំបន់ការពារ :** បានបោះបង្គោលការពារព្រំតំបន់ការពារចំនួន៥៤កន្លែងនិងដាក់ស្លាកសញ្ញាចំនួន៣ផ្លូវបុរាណពីបាគងទៅអង្គរនិងប្រាសាទក្បាលបី ព្រមទាំងដាក់បង្គោលរបារបេតុងចំនួន៧៥ដើម។

- **បានសហការជាមួយសាលាបារាំងចុងបូព៌ា**(EFEO) ដើម្បីស្រាវជ្រាវនៅក្នុងបរិវេណក្រុងអង្គរធំ ព្រមទាំងបានសហការជាមួយអង្គការស៊ីម៉ាក់ធ្វើការដោះមីនចំនួន១គ្រាប់ដែលភ្នាក់ងារបានប្រទះឃើញ ហើយបានយកចេញនិងបន្តរុករកគ្រាប់មីនមិនទាន់ផ្ទុះនៅក្នុងតំបន់ប្រាសាទចៅស្រីវិបុលជាបន្តទៀត។

- បានបញ្ចប់ការសាងសង់ជណ្តើរចំនួន១២កន្លែងនិងស្ពានឈើសម្រាប់ភ្ញៀវដើរទស្សនាប្រាសាទបេងមាលា ប្រវែង១៨៥ម៉ែត្រ និងទទឹង១,៥ម៉ែត្រ ព្រមទាំងបានសាងសង់ក្តារក្រាលទំហំ១,៥ម៉ែត្រx១,៨ម៉ែត្រចំនួន១កន្លែង ដើម្បីបញ្ចៀសគ្រោះថ្នាក់ជាយថាហេតុដល់ភ្ញៀវទេសចរដែលឆ្លងកាត់នៅប្រាសាទបេងមាលា

- ចុះហាមឃាត់ព្រះសង្ឃគង់នៅវត្តចាស់លើខ្នងភ្នំគូលែន ដែលសាងសង់កុដិនៅក្បែរសិលាចារឹក បានចុះហាមឃាត់សកម្មភាពទន្ទ្រានដីបុរាណដ្ឋានចំនួន២១ករណី និងចុះពិនិត្យសំណើសុំសាងសង់របស់ប្រជាពលរដ្ឋបានចំនួន៣២ករណី។ ជាមួយគ្នានេះដែរ បានចុះពិនិត្យក្បាលដីរបស់ប្រជាពលរដ្ឋ ដើម្បីសិក្សាពីផលប៉ះពាល់ដល់បុរាណដ្ឋានតាមសំណើរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងសុរិយោដីខេត្តបានចំនួន៦០ក្បាលដី ស្មើនឹង៣៨៦ ៧៧៣,១១ហិកតា

- ចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈនៅក្នុងបរិវេណប្រាសាទវត្តព្រះជាតុស្ថិតក្នុងឃុំខ្នារ និងវត្ថុសិល្បៈនៅក្នុងវត្តជីក្រែងស្ថិតក្នុងឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាបបានរួចរាល់។

## ខ- សំណង់អគារនៅរមណីយដ្ឋានអង្គរ-សៀមរាប

### ការរៀបចំសំណង់និងហេដ្ឋារចនាសម្ព័ន្ធ៖

- បានពិនិត្យការងារសាងសង់អគារភោជនីយដ្ឋាននិងសាលមហោស្រពនៃគម្រោងឧទ្យានវប្បធម៌កម្ពុជា-ចិន របស់ក្រុមហ៊ុនAngkor International Culture Investment & Development (CAMBODIA) Co.,LTD ក្នុងបរិវេណដីទំហំ២៣ហិកតាដែលជាការវិនិយោគរយៈពេលវែងរបស់ក្រុមហ៊ុនសុខាអូតែលស្ថិតក្នុងដីបុរីវប្បធម៌និងទេសចរណ៍ក្នុងក្រុងសៀមរាប ព្រមទាំងចុះពិនិត្យគម្រោងស្ពានស្ទឹងសៀមរាបជំហានទី២ ចាប់ពីស្ពានផ្លូវក្រវាត់ក្រុងចម្ងាយ៥គីឡូម៉ែត្រទៅផ្នែកខាងក្រោម ដើម្បីបញ្ចៀសការលិចលង់នៅប៉ែកខាងលើ ដោយសហការជាមួយសាលាខេត្ត ប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធ

- បន្តសិក្សាប្លង់មេនិងប្លង់ស្ថាបត្យកម្ម Welcome Center ដើម្បីសាងសង់អគារមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចភ្ញៀវទេសចរដែលស្ថិតនៅបុរីវប្បធម៌និងទេសចរណ៍ និងបានសិក្សាគម្រោងប្លង់កែលម្អផ្លូវនិងប្រឡាយទឹកនៅផ្លូវបុរីវប្បធម៌និងទេសចរណ៍អង្គរ(ផ្លូវសម្តេចវិបុលបញ្ញា**សុខ អាន**) ចាប់ពីមន្ទីរពេទ្យគន្ធបុប្ផាដល់រង្វង់មូលអប្សរា។

**គ- ការងារប្រព័ន្ធធារាសាស្ត្រ**(គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០១៩)

| ល.រ | បរិយាយ | ឯកតា | លទ្ធផល |
|---|---|---|---|
| ១ | សាងសង់សំណង់ទ្វារទឹក | កន្លែង | ៣ |
| ២ | ជួសជុលសំណង់ទ្វារទឹក | កន្លែង | ៨ |
| ៣ | សំណង់បង្ហៀរទឹក | កន្លែង | ១ |
| ៤ | សំណង់ស្ពានបេតុង | កន្លែង | ៣ |
| ៥ | សំណង់លូជ្រុងនិងលូមូល | កន្លែង | ២០ |
| ៦ | ផ្លូវក្រួសក្រហម | ម៉ែត្រ | ២ ៧៤០ |
| ៧ | ស្តារប្រឡាយនិងស្ទឹង | ម៉ែត្រ | ១១ ២៧២ |
| ៨ | ស្តារប្រព័ន្ធរំដោះទឹកតាមប្រាសាទ | ម៉ែត្រ | ៤៥ ២៦៣ |
| ៩ | សាងសង់និងជួសជុលទំនប់ | ម៉ែត្រ | ៨ ៣៣០ |
| ១០ | ដាំកូនឈើការពារជើងទេរតំបន់ប្រឡាយ | ដើម | ៣០ ៦៨២ |
| ១១ | ផ្គត់ផ្គង់ទឹកជូនកសិករប្រើប្រាស់សម្រាប់កសិកម្មនៅរដូវប្រាំង | ហិកតា | ៥ ០០០ |

**ឃ- ការងារអភិវឌ្ឍន៍សហគមន៍ក្នុងឧទ្យានអង្គរ**

- បន្តកម្មវិធីអប់រំបេតិកភណ្ឌសម្រាប់កុមារនៅសាលាបឋមសិក្សាលលៃនិងសិស្សវិទ្យាល័យហ៊ុន សែនប្រាសាទបាគង និងបានចុះអប់រំបេតិកភណ្ឌដោយសហការជាមួយអង្គការ Heritage Watch ដល់សិស្សានុសិស្សនៅតាមសាលានានានៅក្នុងតំបន់អង្គរ

- បានចុះពិនិត្យការស្នើសុំសាងសង់និងជួសជុលតូបចំនួន២ ៨៦៧ករណី ក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋនៅលើទីតាំងចំនួន១ ៧៩៩ករណី និងបន្តចុះពិនិត្យនិងតាមដាននូវសកម្មភាពនានាដែលបានអនុវត្តនៅតាមភូមិគោលដៅចាស់ទាំង១៨គម្រោងអភិវឌ្ឍន៍សហការជាមួយ New Zealand ហៅថា ACHA

- ការងារទេសចរណ៍ : សហគមន៍ទេសចរមកប្រើប្រាស់សេវាកម្មរទេះគោជឹក នៅសហគមន៍ទេសចរណ៍បឹងទទឹងថ្ងៃបាន៣៧លើក នៅសហគមន៍ទេសចរណ៍បន្ទាយស្រីបាន៨លើក និងនៅសហគមន៍កុដិសួរបាន៣៥លើក។

**ង- ការងារព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន**

**ការងារអភិរក្សនិងអភិវឌ្ឍន៍ព្រៃឈើ ៖**

- បានដាំកូនឈើចម្រុះសរុប៤០ ៥១១ដើម និងចែកចាយកូនឈើជូនដល់ស្ថាប័នពាក់ព័ន្ធសរុបចំនួន៧៥ ៨២២ដើម និងបានទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើនៅក្នុងតំបន់ឧទ្យានអង្គរចំនួន៣៦ករណីដោយបានសហការជាមួយមន្ត្រីឧទ្យានុរក្សនៃមន្ទីរបរិស្ថានខេត្តសៀមរាបនិងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។ ស្ថានីយបណ្តុះកូនឈើទាំងបីកន្លែងបានប្រមូលគ្រាប់ពូជឈើចំនួន៦៣គីឡូក្រាម និងបណ្តុះកូនឈើចំនួន៧៧ ៤៩១ដើម

- បានព្យាបាលជំងឺដើមឈើនៅក្នុងឧទ្យានអង្គរចំនួន៧ទីតាំង មានដើមឈើសរុបចំនួន២៨៣ដើម និងបញ្ចូលទិន្នន័យដើមឈើដែលបានព្យាបាលរួចចំនួន៣២៨ដើម ក៏ដូចជាបានវាស់ការលូតលាស់សាច់ឈើដែលបានព្យាបាលរួចចំនួន៤៤៣ដើម ព្រមទាំងបានអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃព្រៃឈើជូនដល់សហគមន៍រស់នៅក្នុងតំបន់ឧទ្យានអង្គរសរុប២៧លើក មានអ្នកចូលរួម១ ៧៣៩អង្គ/នាក់ ស្រី១ ១០៥នាក់។

**ការងារគ្រប់គ្រងហានិភ័យដើមឈើនិងរៀបចំទេសភាពវប្បធម៌** : បានចុះអង្កេតដើមឈើដែលមានហានិភ័យខ្ពស់សរុប១ ៧៤៦ដើម ដោយបានកាត់ក្រីមែកឈើនិងកាត់ដកហូតដើមឈើដែលមានហានិភ័យសរុបចំនួន៧៩៩ដើម ក៏ដូចជាបានធ្វើសារពើភណ្ឌដើមឈើសរុប៣៦៩ដើម ស្មើនឹង៨១ប្រភេទឈើ ព្រមទាំងបានរៀបចំសួនផ្កាក្រវាន់នៅមុខអង្គរខាងលិច(អតីតចំណតរថយន្តចាស់) ដោយបានដាំស្មៅ១១ ០០០ម៉ែត្រការ៉េ ដើមក្រវាន់៥០០ដើម ដើមធ្នង់១៧០ដើម រួមទាំងធ្វើការកែលម្អដាំស្មៅនៅខាងត្បូងប្រាសាទអង្គរវត្តចំនួន១ ០០០ម៉ែត្រការ៉េនិងដើមធ្នង់៣៦ដើម។

**ការងារបរិស្ថានៈ**

- បានកំណត់ទីតាំងសម្រាប់ចុះសិក្សាពីបញ្ហាបរិស្ថាន សិក្សាច្បាប់បរិស្ថានថ្មីទាក់ទងនឹងកិច្ចការការពារអភិរក្សបរិស្ថានក្នុងតំបន់ឧទ្យានអង្គរ និងផ្សព្វផ្សាយដល់សហគមន៍ឱ្យយល់ដឹងអំពីបេសកកម្មរបស់អាជ្ញាធរអប្សរា និងបានចុះត្រួតពិនិត្យការងារបរិស្ថាននៅតាមទីតាំងផ្ទាល់ក្នុងឧទ្យានអង្គរដើម្បីធ្វើឱ្យបរិស្ថានក្នុងតំបន់ឧទ្យានអង្គរមានលក្ខណៈល្អប្រសើរ ព្រមទាំងបន្តចុះអប់រំផ្សព្វផ្សាយនិងតាមដានវាយតម្លៃអំពីបរិស្ថានដល់កុមារនៅសាលាបឋមសិក្សាដូនឪ ត្រពាំងស្វាយ និងគោកគ្រើលសរុបចំនួន៣៥០នាក់ និងអប់រំផ្សព្វផ្សាយបរិស្ថានដល់អ្នកលក់ដូរនិងព្រះសង្ឃ

- បានជួបជាមួយស្ថាប័នជានាគុណភាពជប៉ុនJQA អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ និងអ្នកជំរុញការងារបរិស្ថានប្រចាំនាយកដ្ឋានទាំង១៥ ស្តីពីការគ្រប់គ្រងបរិស្ថានព្រមទាំងបានរៀបចំធ្វើសវនកម្មផ្ទៃក្រៅលើប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរអប្សរា ដោយស្ថាប័នជានាគុណភាពជប៉ុនJQA និងរៀបចំទទួលសវនករជប៉ុន។

## ច- ការងារស្រាវជ្រាវ តម្កល់ឯកសារ និងផ្សព្វផ្សាយ

**ការងារស្រាវជ្រាវៈ**

- ចុះអង្កេតស្រាវជ្រាវអំពីផ្លូវបុរាណ ពិនិត្យការប្រែប្រួលនៃការប្រើប្រាស់ដីស្រែ បោះបង្គោលព្រំផ្លូវតាមបណ្តោយផ្លូវបុរាណពីអង្គរទៅល្វេស ថតរូបទេសភាពវប្បធម៌នៅភ្នំបូក បន្ទាយស្រី បន្តសិក្សាពីភាពប្រែប្រួលទេសភាពវប្បធម៌ ព្រមទាំងចុះអង្កេតនិងថតរូបទេសភាពវប្បធម៌ សិក្សាអំពីមុខរបរអ្នកស្រុកដែលរស់នៅតាមបណ្តោយផ្លូវបុរាណពីអង្គរទៅបេងមាលា។ ជាមួយគ្នានេះដែរ ក៏បានចុះសិក្សាពីផលប៉ះពាល់នៃការធ្វើផ្លូវបុរាណពីសង្កាត់នគរភ្នំទៅឃុំអំពិល ស្រុកប្រាសាទបាគង

-ចូលរួមកំណាយជាមួយស្ថាប័នណារ៉ានៅស្ថានីយឡគោកទ្រាល និងចូលរួមកំណាយ ស្រាវជ្រាវនៅតំបន់អង្គរជាមួយសាកលវិទ្យាល័យតូរ៉ុនតូ ប្រទេសកាណាដា ព្រមទាំងចូលរួមសហការជាមួយស្ថាប័នJASA ដើម្បីចុះធ្វើការសិក្សាពីប្រភពអាចម៍រ៉ែដែកនិងវាស់ស្ទង់ថ្មភក់នៅរោងថែវខាងកើតនិងគួប៉មលេខ៤២ នៅប្រាសាទបាយ័ន

- សិក្សាពីភាជន៍និងគូររូបដែលបានមកពីប្រជាពលរដ្ឋប្រគល់ឱ្យពីភូមិរហាល សង្កាត់នគរធំ ក្រុងសៀមរាប ដោយសហការសិក្សាវត្ថុបុរាណជាមួយសាលាបារាំងចុងបូព៌ា

- បានគូសផែនទីគម្រោងផ្លូវនានារបស់អាជ្ញាធរជាតិអប្សរាចាប់ពីឆ្នាំ២០១៥-២០១៩ និងកែសម្រួលផែនទីព័ត៌មានភូមិសាស្ត្រទៅក្នុងឧទ្យានអង្គរដើម្បីផ្សព្វផ្សាយនិងប្រើប្រាស់ក្នុងអាជ្ញាធរអប្សរា កំពុងចុះបញ្ជីបំណែកកុលាលភាជន៍ពីតំបន់កោះកេរបានចំនួន៧០លេខរៀង ឡបង្កោងបានចំនួន១៦កេសនិងទទួលកុលាលភាជន៍ពីវិទ្យាស្ថាន NARA ចំនួន៨០កេសនិង៣០ការុង។ ចុះបញ្ជីវត្ថុសិល្បៈដែលបានមកពីកំណាយស្រាវជ្រាវនៅប្រាសាទទន្លេស្ងួតដល់លេខរៀង២៦៨ គូរបំណែកភាជន៍ដែលយកមកពីឡបង្កោងនិងឡខ្នារពោធិ៍បានចំនួន៣៣៩បំណែក

- បានទទួលវត្ថុសិល្បៈរបស់ស្ថានីយថ្មដល់ពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការបានចំនួន៣៥ការុង ១៣កេស បំណែកក្អម១ និងបំណែកក្រឡ១ ព្រមទាំងបានបញ្ចូលទិន្នន័យភាជន៍ដែលបានគូររួចទៅក្នុងកុំព្យូទ័រចំនួន២៥បំណែក រៀបចំកុលាលភាជន៍ឡើងវិញដែលបានមកពីឡថ្មដល់បានចំនួន១៨កេស និងផ្ទៀងផ្ទាត់កុលាភាជន៍ដែលបានចុះបញ្ជីរួចឡើងវិញ។

**ការងារតម្កល់ឯកសារៈ**

- បានរៀបចំបញ្ចូលរបាយការណ៍បង្ហាញពីសកម្មភាពស្តីពីការងារអភិរក្សរបស់អង្គការ GACP ចាប់ពីខែមករាដល់ខែធ្នូ ឆ្នាំ២០១៨ នឹងចាប់ពីខែមករាដល់ខែកក្កដា ឆ្នាំ២០១៩ និងបានរៀបចំស្រាវជ្រាវឯកសារស្តែនបានចំនួន១០ឯកសារនិងបានបញ្ចូលឯកសារMOU ឆ្នាំ២០០២ដល់ឆ្នាំ២០១៨ តាមរយៈកម្មវិធីATOM ចំនួន៣០ច្បាប់

- ផ្តល់យោបល់លើសំណើសុំនាំយកសំណាកទៅវិភាគនៅក្រៅប្រទេសដោយស្ថាប័នអន្តរជាតិចំនួន១១ និងផ្តល់យោបល់លើសំណើសុំសិក្សាស្រាវជ្រាវរបស់ស្ថាប័នអន្តរជាតិចំនួន១៦ និងបានពិនិត្យផ្តល់យោបល់ សុំគោលការណ៍ចុះហត្ថលេខាអនុស្សរណៈយោគយល់គ្នា កិច្ចព្រមព្រៀងគ្នារវាងអាជ្ញាធរជាតិអប្សរាស្ថាប័នពាក់ព័ន្ធ ស្ថាប័នអន្តរជាតិ ចំនួន៨ករណី។

**ការងារផ្សព្វផ្សាយៈ**

- ផលិតព័ត៌មានស្តីពីសកម្មភាពនិងសមិទ្ធផលរបស់អាជ្ញាធរជាតិអប្សរាបានចំនួន៣៨៩អត្ថបទ និងផលិតឯកសាររូបភាព ការងារតាមប្រាសាទ ការដ្ឋាននិងសកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាបានចំនួន៩៣កម្មវិធីថតវីដេអូបាន១១២កម្មវិធី និងបានផលិតអត្ថបទយកការណ៍ជាវីដេអូព្រមទាំងផ្សាយចេញបាន៥៥កម្មវិធី

- ផ្សព្វផ្សាយតាមវិទ្យុចំនួន៣ តាមគេហទំព័រអាជ្ញាធរជាតិអប្សរាបានចំនួន៣៧៥អត្ថបទ មានអ្នកបានឃើញចំនួន៩០២ ១២២ដង និងផ្សព្វផ្សាយតាមហ្វេសប៊ុក(facebook) គណនីផ្លូវការអាជ្ញាធរជាតិអប្សរាបានចំនួន៤១៦សកម្មភាព បានផ្សាយផ្ទាល់ចំនួន៥កម្មវិធី និងផ្សាយតាមទូរទស្សន៍អាជ្ញាធរជាតិអប្សរា តាមគេហទំព័រហ្វេសប៊ុក(facebook)ចំនួន២៦៦កម្មវិធី។

## ឆ- គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក

- ការងារដាំដុះសម្រាប់បង្ហាញនៅផ្ទះគំរូ ថែទាំដំណាំហូបផ្លែ១៤ប្រភេទ មានចំនួន១៣៧ដើម

- ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញាឆ្នាំ២០១៩ បានប្រមូលផលពីដំណាំម្រុំ បានថវិកា៣១ ៧៧៨ ៦០០រៀល និងចំណូលពីការលក់បន្លែ ផ្លែឈើ និងសត្វរបស់ប្រជាពលរដ្ឋ បានថវិកាចំនួន៨ ៥៦៧ ៤០០រៀល

-ការអប់រំ : អគារសិក្សា១ខ្នង មាន៥បន្ទប់ សិស្សានុសិស្ស៦០នាក់(សិស្សស្រី៣១នាក់) គ្រូបង្រៀន៥នាក់(ស្រី៤នាក់) និងថ្នាក់មត្តេយ្យ១ថ្នាក់ មានសិស្សចំនួន៣១នាក់ ព្រមទាំងបានសាងសង់សាលា១ខ្នងមាន៥ន្ទប់ សម្រេចបាន១០០% ដែលជាជំនួយសប្បុរសជនជប៉ុននិងបានដាក់សម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩។

### ង- ការងារគ្រប់គ្រងដីធ្លី សំណង់និងគ្រប់គ្រងទិន្នន័យ

- សហការជាមួយមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា(CMAC) ធ្វើការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតំបន់រមណីយដ្ឋានអង្គររយៈពេល៣ខែ(ឧសភា-កក្កដា)ឆ្នាំ២០១៩ បានផ្ទៃដីទំហំ៩៥៧ ៤៨៦ម៉ែត្រក្រឡា និងបានសហការជាមួយអាជ្ញាធរមូលដ្ឋាន អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីជំនាញចុះទប់ស្កាត់បទល្មើសផ្សេងៗចំនួន២៥ករណី ព្រមទាំងទប់ស្កាត់បទល្មើសព្រៃឈើនៅក្នុងតំបន់រមណីយដ្ឋានអង្គរសរុបចំនួន៣៧ករណី

- ចុះត្រួតពិនិត្យធ្វើកំណត់ហេតុកិច្ចសន្យាបញ្ឈប់មិនឱ្យសាងសង់សំណង់បន្តនិង ណែនាំឱ្យម្ចាស់រុះរើដោយខ្លួនឯងចំនួន៤៣ករណី និងចុះធ្វើកំណត់ហេតុកំណត់ក្បាលដី បោះបង្គោល ធ្វើការឈូសឆាយ ព្រមទាំងធ្វើរបងការពារក្បាលដីរដ្ឋប្រវែង២ ៩៧៥ម៉ែត្រ នៅភូមិព្រៃគុយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ជាមួយគ្នានេះដែរ បានដោះស្រាយបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋលើក្បាលដីចំនួន១៣ករណី ឆ្លើយតបទៅនឹងការទាមទាររបស់ប្រជាពលរដ្ឋ១៣ករណី។

## ២.២.២- សមិទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិព្រះវិហារ

### ក- ការងារអភិរក្ស

**ការលើកតម្លៃបេតិកភណ្ឌវប្បធម៌៖**

- រៀបចំ ចងក្រងឯកសារស្នើសុំចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរចូលជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។

**+ ការងារអភិរក្សនិងជួសជុល៖**

- ជួសជុលបំណែកខ្លងនាគផ្នែកខាងកើតនៃបង្កាន់ដៃនាគខាងជើងគោបុរៈទី៥ និងបានផ្គុំបំណែកខ្លងភ្ជាប់ជាមួយខ្លួននាគវិញនិងបិទបំពេញកន្លែងដែលបានបាត់បំណែក

- ជួលជុលបង្គោលផ្កាឈូកចំនួន១ដើម លាងសម្អាតស្លែបង្គោលផ្កាឈូកដែលត្រូវ ជួសជុលបង្គោលទី៣/៥/៦/១០/១១ បាញ់ថ្នាំពង្រឹងលើគល់បង្គោលទី១បែកជាពីរ និងបាញ់ថ្នាំពង្រឹងបង្គោលទី៥ជា៥បំណែក ដឹកយកក្បាលបង្គោលទី១១គាបជាប់គល់ដើមស្រទ្បៅ ជួសជុលតភ្ជាប់ ដាក់បញ្ឈរវិញចំនួន២បង្គោលគឺទី៨និងទី៩ និងសម្រង់ប្លង់បញ្ចូលបំពេញបន្ថែមថ្ម(នៅស្ពានហាលចន្លោះគោលបុរៈទី៤និងគោបុរៈទី៥) បានចងក្រងឯកសាររូបថត3D សិក្សាកំណត់ផែនទីហានិភ័យដោយលម្អិតលើប្លង់បាតរបស់ស្ពានហាល

- អភិរក្សនិងជួសជុលជណ្តើរបុរាណខាងជើងប្រាសាទព្រះវិហារតាមរយៈថវិកាមូលនិធិឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកសម្រាប់ការអភិរក្សសម្បត្តិបេតិកភណ្ឌពិភលោកឆ្នាំ២០១៨-២០១៩ ដោយបានធ្វើកំណាយសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា ធ្វើប្រព័ន្ធបង្ហូរទឹកភ្លៀងកាត់ទទឹងជណ្តើរ

- បានទល់ទ្រឈើនិងរឹងខ្សែកាបតាមវិធីសាស្ត្រផ្សេងៗនៅប្រាសាទថ្មបាយក្រៀម

- បានផ្លាស់ប្តូរស្បូវថ្មីប្រក់ដំបូលគ្របតួប្រាសាទឥដ្ឋនៅប្រាសាទរួមក្នុងបរិវេណប្រាសាទធំដើម្បីការពារជញ្ជាំងប្រាសាទដែលមានគំនូរបុរាណនៅតាមជញ្ជាំងនោះ តាមដានបម្រែបម្រួលថ្មនៅប្រាសាទធំដោយប្រើប្រាស់បន្ទះកញ្ចក់និងម៉ែត្រក្រិតបានចំនួន១៣បន្ទះ ដំឡើងរន្ទាកាត់ដើមស្នួលងាប់ចំនួន១ដើម

- ជួសជុលជណ្តើរឈើឡើងភ្នំប្រាសាទព្រះវិហារប្រវែង១ ៥០០ម៉ែត្រ ដោយបានជួសជុលសាលាដំណាក់ទី១ ជួសជុលកាំជណ្តើរ ជួសជុលថាសជណ្តើរ ប្តូរបង្គោលបង្កាន់ដៃ ប្តូររបារបង្កាន់ដៃ ដាក់ជើងជ្រែង និងប្តូរមេជណ្តើរ ចាក់ជើងតាងថ្មីនិងលាបថ្នាំការពារសត្វល្អិត ដែលត្រូវអនុវត្តបន្ទាប់ផុតរដូវវស្សា

- ជួសជុលដំបូលអគារពិព័រណ៍មិនអចិន្ត្រៃយ៍នៅសារមន្ទីរធម្មជាតិសកលសម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ រោងដាក់ទូកង និងជួសជុលខ្លងទំនប់បារាយណ៍ខាងលិចសម្រេចបាន១០០%។

+ កំណាយបុរាណវត្ថុវិទ្យាចំនួន១៥រណ្តៅ : កំណាយអន្តរាគមន៍សង្គ្រោះនិងអភិរក្សប្រាសាទក្នុងបរិវេណប្រាសាទធំ១រណ្តៅ កំណាយសង្គ្រោះនៅរហាលចំនួន៥រណ្តៅនិងរំកិលថ្មចំនួន៣ដុំចេញ កំណាយសង្គ្រោះនៅស្រះបុរាណត្រពាំងត្រាចចំនួន១រណ្តៅ កំណាយស្រាវជ្រាវឡបុរាណគោកដីផ្ទាំងចំនួន៣រណ្តៅនិងកំណាយសិក្សាស្វែងរកប្រព័ន្ធបង្ហូរទឹកបុរាណចំនួន៥រណ្តៅ

+ចុះបញ្ជីចម្លាក់តោថ្មបុរាណចំនួន១២តោ : ផ្គុំសាកល្បងបំណែកតោចំនួន៦តោ ប្រមូលចម្លាក់តោចំនួន២បំណែកនិងបំណែកតោបាត់ចំនួន១២បំណែក ជួសជុលសាកល្បងចម្លាក់តោដែលនៅសល់ចំនួន៣ ត្រូវប្រមូលជើងទម្រចំនួន៤ទៀតនិងស្វែករកបំណែកបន្តទៀត

+ បានធ្វើការបញ្ចូលទិន្នន័យប្រាសាទរួមក្នុងគម្រោងផែនទីហានិភ័យ និងចុះសិក្សាប្លង់ទល់ទ្រនៅប្រាសាទក្បាលខ្មោច និងរៀបចំចងក្រងឯកសារនៃរមណីយដ្ឋានប្រាសាទកោះកេរដើម្បីត្រៀមដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

- សិក្សារៀបចំឯកសារហានិភ័យប្រាសាទក្នុងរមណីយដ្ឋានប្រាសាទកោះកេរ និងរៀបចំឯកសារផែនការគ្រប់គ្រង និងរមណីយដ្ឋានប្រាសាទព្រះវិហារ

- ធនធានធម្មជាតិនិងទេសភាពវប្បធម៌ ដែលមានទីតាំងស្ថិតនៅតាមក្រវាត់ព្រំប្រទល់តំបន់២និងតំបន់៣ខ ជូនប្រជាពលរដ្ឋ១១២គ្រួសារ ដើម្បីបញ្ជាក់ពីការខណ្ឌព្រំតំបន់អភិវឌ្ឍន៍និងតំបន់ការពារ ដោយព្រះរាជក្រឹត្យមានស្លាកសរុបចំនួន១៦ស្លាក និងចុះបោះស្លាកសញ្ញាកំណត់ព្រំប្រទល់តំបន់អភិរក្សរបស់សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារចំនួន២៨ស្លាក ព្រមទាំងចូលរួមដោះស្រាយបញ្ហាដីធ្លីរវាងប្រជាជនក្នុងភូមិធម្មជាតិសម្តេចតេជោចំនួន៤គ្រួសារ។

**ខ- ការងារអភិវឌ្ឍន៍ទេសចរណ៍និងសហគមន៍**

**ការងារអភិវឌ្ឍន៍ទេសចរណ៍( គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០១៩ )**

- រមណីយដ្ឋានប្រាសាទព្រះវិហារបានទទួលភ្ញៀវទេសចរជាតិនិងអន្តរជាតិសរុបចំនួន១៦០ ៤២៨នាក់( ភ្ញៀវជាតិចំនួន១៣៥ ១០១នាក់ ភ្ញៀវអន្តរជាតិចំនួន២៥ ៣២៧នាក់ )

- រមណីយដ្ឋានប្រាសាទកោះកែរបានទទួលភ្ញៀវទេសចរជាតិនិងអន្តរជាតិសរុបចំនួន២៦៧ ៥១៣នាក់( ភ្ញៀវជាតិចំនួន២៣៦ ៣៦៧នាក់ ភ្ញៀវអន្តរជាតិចំនួន៣១ ១៤៦នាក់ )

- ចំនួនភ្ញៀវចូលទស្សនាសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារសរុបចំនួន១ ៥៧៦នាក់( ភ្ញៀវជាតិចំនួន១ ៨០៩នាក់ ភ្ញៀវអន្តរជាតិចំនួន៩៤នាក់ )

-បានចុះដាក់ស្លាកសញ្ញានៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារចំនួន៦ស្លាក និងរៀបចំស្លាកឈ្មោះប្រាសាទនៅក្នុងរមណីយដ្ឋានប្រាសាទកោះកែរចំនួន២៦ស្លាក ព្រមទាំងសិក្សារៀបចំឯកសារផែនការការគ្រប់គ្រងរមណីយដ្ឋានប្រាសាទកោះកែរ

- បានចាក់បេតុងផ្លូវចេញចូលចំណតភ្ញៀវទេសចរនៅចំណុចគ១ និងបានជួសជុលបញ្ជរត្រួតពិនិត្យសំបុត្រនៅចំណុចច១និងលើភ្នំប្រាសាទព្រះវិហារ

**ការងារអភិវឌ្ឍន៍សហគមន៍៖**

- បានសាងសង់រោងដាំបន្លែសរីរាង្គគំរូចំនួន២រោង ខ្ទងអណ្តូងស្នប់១អណ្តូង ដំឡើងជើងស៊ីទែនថ្មី១តប្រព័ន្ធ( Springkle ) តភ្ជាប់បណ្តាញអគ្គិសនី ដំឡើងប្រព័ន្ធភ្លើងសម្រាប់ប្រើប្រាស់ទូទៅនៅក្នុងសួនកសិកម្មគំរូរបស់សហគមន៍ភូមិធម្មជាតិសម្តេចតេជោ។ ស្រាវជ្រាវ អនុវត្តបច្ចេកទេសថ្មីៗនៅក្នុងការផលិតជីបំប៉នដំណាំ ថ្នាំដេញសត្វល្អិតតាមធម្មជាតិសម្រាប់ដំណាំបន្លែសរីរាង្គ បាចកំបោរសដើម្បីសម្លាប់មេរោគក្នុងស្រះមុននឹងបញ្ចូលទឹកឡើងវិញ ព្រមទាំងផ្តល់បច្ចេកទេសកសិកម្ម ចុះជួយរៀបចំសួនបន្លែលក្ខណៈគ្រួសារដល់កសិករ

- អប់រំបណ្តុះបណ្តាលសិស្សអនុវិទ្យាល័យ វិទ្យាល័យស្រអែម និងនៅតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារចំនួន១៦ប្រធានបទ ដឹកនាំសិស្សានុសិស្សទស្សនកិច្ចសិក្សាសរុប១២០នាក់ ចំនួន៣លើក សហគមន៍ចំនួន៧ ភូមិចំនួន៥ប្រធានបទ។

**២.២.៣- សមិទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិសំបូរព្រៃគុក( គិតពីខែកញ្ញា ឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០១៩ )**

ប្រាសាទសំបូរព្រៃគុក បានទទួលភ្ញៀវទេសចរជាតិនិងអន្តរជាតិសរុបចំនួន២២៧ ៤៦១នាក់ ក្នុងនោះភ្ញៀវអន្តរជាតិចំនួន២២ ៩៩៩នាក់ )។

**ក- ការងាររមណីយដ្ឋានបុរាណវិទ្យានិងអភិរក្ស**

- ជួសជុលប្រាសាទS11 ពង្រឹងខ្លោងទ្វារS5 សង្គ្រោះបន្ទាន់រចនាសម្ព័ន្ធដែលប្រេះរហែកនៃប្រាង្គS10 ជួសជុលចម្លាក់លម្អនៅលើជញ្ជាំងនិងចម្លាក់ប្រាសាទអណ្តែត នៃក្រុមប្រាសាទយាយព័ន្ធ

- គម្រោងសង្គ្រោះបន្ទាន់ចម្លាក់លម្អនៅលើជញ្ជាំងនិងចម្លាក់ប្រាសាទអណ្តែតដំណាក់កាលទី១និងដំណាក់កាលទី២ គម្រោងអភិរក្សគាំពារ តាមដានហានិភ័យតាមបណ្តាប្រាសាទប្រាង្គS7, S10 ប្រាសាទត្រពាំងរពាក់( Z1, Z2 ) និងប្រាសាទដូនមោង (D2) ប្រាសាទតាម៉ុម( T1 ) ព្រមទាំងគម្រោង ជួសជុលខ្លោងទ្វារខាងលិច( S5 ) និងខ្លោងទ្វារខាងកើតនៃក្រុមប្រាសាទយាយព័ន្ធ។

**ខ- ការងាររៀបចំដែនដី លំនៅឋាននិងប្រជាសាស្ត្រ**

- បានស្រង់ខ្នងផ្ទះក្នុងតំបន់ទី១ និងបានចុះទប់ស្កាត់ការសាងសង់សំណង់ដោយមិនសុំការអនុញ្ញាតចំនួន១៧ទីតាំង

- ចុះពិនិត្យ តាមដានការអនុវត្តសាងសង់ផ្ទះ ជួសជុលនិងចាក់ដីចំនួន៤០ទីតាំង ព្រមទាំងបានចុះពិនិត្យការស្នើសុំជួសជុលផ្លូវលំចាក់ដីក្រួសក្រហម៤ខ្សែ គឺផ្លូវលំនៅភូមិសំបូប្រវែង២៥៨ម៉ែត្រ ផ្លូវនៅភូមិកំពង់ឈើទាលប្រវែង៩៩២ម៉ែត្រ ផ្លូវចូលសហគមន៍បឹងដឹកកាយប្រវែង៣៧២ម៉ែត្រ និងនៅភូមិផាយសំពៅប្រវែង៨០២ម៉ែត្រ។

**២.៣- ការងារសាសនា**

ក- ស្ថិតិពុទ្ធសាសនា

| **វត្តអារាមនិងព្រះសង្ឃ** | | | |
|---|---|---|---|
| សូចនាករ | ២០១៨ | ២០១៩ | ប្រៀបធៀប |
| វត្តអារាមទាំង២គណៈ | ៤ ៩៨៥វត្ត | ៥ ០២៤វត្ត | កើន៣៩វត្ត |
| *គណៈមហានិកាយ* | ៤ ៧៤៤វត្ត | ៤ ៧៧២វត្ត | កើន២៨វត្ត |
| *គណៈធម្មយុត្តិកនិកាយ* | ២៤១វត្ត | ២៥២វត្ត | កើន១១វត្ត |
| ព្រះសង្ឃទាំង២គណៈ | ៧០ ៨៥៣អង្គ | ៧១ ៦១០អង្គ | កើន៧៥៧អង្គ |
| *គណៈមហានិកាយ* | ៦៦ ០៣៦អង្គ | ៦៦ ៦៥៨អង្គ | កើន៦២២អង្គ |
| *គណៈធម្មយុត្តិកនិកាយ* | ៤ ៨១៧អង្គ | ៤ ៩៥២អង្គ | កើន១៣៥អង្គ |
| អាចារ្យនិងអាចារិនី | ១៥ ៩៦៣នាក់ | ១៦ ៦៣០នាក់ | កើន៦៦៧នាក់ |

| | | | |
|---|---|---|---|
| គណៈកម្មការវត្ត | ៤០ ១៥២នាក់ | ៣៨ ៤០១នាក់ | ថយ១ ៧៥១នាក់ |
| តាជី | ៤ ៣៤៨នាក់ | ៣ ១៥០នាក់ | ថយ១ ១៩៨នាក់ |
| យាយជី | ១២ ០២២នាក់ | ១១ ៦៣០នាក់ | ថយ៣៩២នាក់ |
| **សាលាពុទ្ធិកសិក្សានិងសមណសិស្ស-និស្សិត** | | | |
| **ធម្មវិន័យ** | | | |
| ចំនួនសាលា | ៤៩១សាលា | ៤៥៦សាលា | ថយ៣៥សាលា |
| ចំនួនសមណសិស្ស | ៩ ៨៥០អង្គ/នាក់ | ៩ ២៣៥អង្គ/នាក់ | ថយ៦១៥អង្គ/នាក់ |
| **ពុទ្ធិកបឋមសិក្សា** | | | |
| ចំនួនសាលា | ៧៩៦សាលា | ៩១៥សាលា | កើន១១៩សាលា |
| ចំនួនសមណសិស្ស-សិស្ស | ២២ ៩៣០អង្គ/នាក់ | ២៤ ២០៩អង្គ/នាក់ | កើន១ ២៧៩អង្គ/នាក់ |
| គ្រូបង្រៀនក្របខ័ណ្ឌ | ១៨៦អង្គ/នាក់ | ១៧៧អង្គ/នាក់ | ថយ៩អង្គ/នាក់ |
| គ្រូជួល | ១ ៤៦២នាក់ | ១ ៤៦២អង្គ/នាក់ | |
| **ពុទ្ធិកមធ្យមសិក្សាបឋមភូមិ** | | | |
| ចំនួនសាលា | ៤០សាលា | ៤០សាលា | |
| ចំនួនសមណសិស្ស-សិស្ស | ៥ ៥៥១អង្គ/នាក់ | ៥ ៦៤២អង្គ/នាក់ | ថយ៩១ |
| គ្រូបង្រៀនក្របខ័ណ្ឌ | ១៤៧នាក់ | ១២៥អង្គ/នាក់ | ថយ២២អង្គ/នាក់ |
| គ្រូជួល | ៤២១នាក់ | ៣៨៨អង្គ/នាក់ | ថយ៣៣នាក់ |
| **ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ** | | | |
| ចំនួនសាលា | ១៤សាលា | ១៤សាលា | |
| ចំនួនសមណសិស្ស | ១ ៨៧២អង្គ/នាក់ | ១ ៧២៧អង្គ/នាក់ | ថយ១៤៥អង្គ/នាក់ |
| គ្រូបង្រៀនក្របខ័ណ្ឌ | ៣៥នាក់ | ៤០អង្គ/នាក់ | កើន៥នាក់ |
| គ្រូជួល | ២១០នាក់ | ២០២អង្គ/នាក់ | ថយ៨នាក់ |
| **ពុទ្ធិកឧត្តមសិក្សា** | | | |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជភ្នំពេញ** | ១ | ១ | |
| ចំនួនសមណនិស្សិត | ៤២០អង្គ/នាក់ | ៥១៧អង្គ/នាក់ | កើន៩៧អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ៣៧នាក់ | ៤៦នាក់ | ថយ៩នាក់ |
| គ្រូជួល | ៧៦នាក់ | ៤៨នាក់ | ថយ២៨នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ៩៤អង្គ/នាក់ | ៥៧អង្គ/នាក់ | ថយ៣៧អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តកំពង់ឆ្នាំង** | ១ | ១ | |

| | | | |
|---|---|---|---|
| ចំនួនសមណនិស្សិត | ៤០៣អង្គ/នាក់ | ៤៥៦អង្គ/នាក់ | កើន៥៣អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ១នាក់ | ១នាក់ | ០នាក់ |
| គ្រូជួល | ៦១នាក់ | ៥២នាក់ | ថយ៩នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ១៤១អង្គ/នាក់ | ៨៩អង្គ/នាក់ | ថយ៥២អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង** | ១ | ១ | |
| ចំនួនសមណនិស្សិត | ២៦២អង្គ/នាក់ | ៣៨២អង្គ/នាក់ | កើន១២០អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ៦នាក់ | ៨នាក់ | កើន ២នាក់ |
| គ្រូជួល | ៤២នាក់ | ៤៤នាក់ | កើន ២នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ៥៥អង្គ/នាក់ | ៤៤អង្គ/នាក់ | ថយ១១អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហមុនីរាជា ភ្នំពេញ** | ១ | ១ | |
| ចំនួនសមណនិស្សិត | ៨៣០អង្គ/នាក់ | ១ ៦២៤អង្គ/នាក់ | កើន៧៩៤អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ៦នាក់ | ៦នាក់ | ០នាក់ |
| គ្រូជួល | ៩១នាក់ | ៨៨នាក់ | ថយ៣នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ១៣៥អង្គ/នាក់ | ១៦៥អង្គ/នាក់ | កើន៣០អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ អគ្គមហាសេនាបតីតេជោ ហ៊ុនសែន ខេត្តកំពង់ចាម** | ១ | ១ | |
| ចំនួនសមណនិស្សិត | ៦១៧អង្គ/នាក់ | ៦៣៤អង្គ/នាក់ | កើន១៧អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ៥នាក់ | ៥នាក់ | ០នាក់ |
| គ្រូជួល | ៤៥នាក់ | ៤៥នាក់ | ០នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ៣៦អង្គ/នាក់ | ៧៤អង្គ/នាក់ | កើន៣៨អង្គ/នាក់ |
| ពុទ្ធិកក្រោយឧត្តមសិក្សា | | | |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ភ្នំពេញ** | ១ | ១ | |
| ចំនួនសមណនិស្សិត | ៦៣អង្គ/នាក់ | ៦៦អង្គ/នាក់ | កើន៣អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ១១នាក់ | ១១នាក់ | ០នាក់ |
| គ្រូជួល | | ៤៨នាក់ | ០នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ៣៨អង្គ/នាក់ | | ៣៨អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជា ភ្នំពេញ** | ១ | ១ | |

| | | | |
|---|---|---|---|
| ចំនួនសមណនិស្សិត | ១៤៦អង្គ/នាក់ | ៣៦២អង្គ/នាក់ | កើន២១៦អង្គ/នាក់ |
| គ្រូជួល | ១៦នាក់ | ២៥នាក់ | កើន៩នាក់ |
| សមណនិស្សិតបានបញ្ចប់ឆ្នាំ | ៥៦អង្គ/នាក់ | ១០៥អង្គ/នាក់ | កើន៤៩អង្គ/នាក់ |
| **ពុទ្ធិកសាកលវិទ្យាល័យ អគ្គមហាសេនាបតីតេជោ ហ៊ុនសែន ខេត្តកំពង់ចាម** | ០ | ១ | ១ |
| ចំនួនសមណនិស្សិត | ០អង្គ/នាក់ | ៧៤អង្គ/នាក់ | កើន៧៤អង្គ/នាក់ |
| គ្រូក្របខ័ណ្ឌ | ០នាក់ | ៣២នាក់ | កើន៣២នាក់ |

### ខ-ស្ថិតិពហិរសាសនា

| សូចនាករ | ២០១៨ | ២០១៩ | ប្រៀបធៀប |
|---|---|---|---|
| **អ៊ិស្លាមសាសនា** | | | |
| វិហារ | ៥១៦កន្លែង | ៥៦៨កន្លែង | កើន៥២កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ៦៧៥កន្លែង | ៧៦២កន្លែង | កើន៨៧កន្លែង |
| សាលាបង្រៀនសាសនា | ៥១៨កន្លែង | ៥២៩កន្លែង | កើន១១កន្លែង |
| អង្គការសមាគម | ១៥កន្លែង | ២១កន្លែង | កើន៦កន្លែង |
| បរិស័ទ | ៤៤៧ ៩៨៧នាក់ | ៤១៤ ៧៥៤នាក់ | ថយ៣៣ ២៣៣ |
| **គ្រិស្តសាសនា** | | | |
| វិហារ | ៦៥៣កន្លែង | ៦៩៤កន្លែង | កើន៤១កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ១ ៣៩១កន្លែង | ១ ៣៧៩កន្លែង | ថយ១២កន្លែង |
| សាលាបង្រៀនសាសនា | ៨២៧កន្លែង | ៨៩០កន្លែង | កើន៦៣កន្លែង |
| បរិស័ទ( កាតូលិក និងប្រូតេស្តង់ ) | ១០៩ ៧១៤នាក់ | ១០៩ ៩៩៩នាក់ | កើន២៨៥ |
| អង្គការសមាគម( កាតូលិក និងប្រូតេស្តង់ ) | ១១៧កន្លែង | ១១៥កន្លែង | ថយចុះ២ |
| **១- កាតូលិក** | | | |
| វិហារ | ៦៤កន្លែង | ៦៨កន្លែង | កើន៤កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ៤៤កន្លែង | ៣៩កន្លែង | ថយ៥កន្លែង |
| សាលាបង្រៀនសាសនា | ៦០កន្លែង | ៦១កន្លែង | កើន១កន្លែង |
| **២- ប្រូតេស្តង់** | | | |
| វិហារ | ៥៨៩កន្លែង | ៦២៦កន្លែង | កើន៣៧កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ១ ៣៤៧កន្លែង | ១ ៣៤០កន្លែង | ថយ៧កន្លែង |
| សាលាបង្រៀនសាសនា | ៧៦៧កន្លែង | ៨២៩កន្លែង | កើន៦២កន្លែង |
| បរិស័ទ | ៩៧ ៣៧៤នាក់ | ៩៦ ៥៩២នាក់ | ថយ៧៨២នាក់ |

| មហាយាន | | | |
|---|---|---|---|
| វិហារ | ១៤៨កន្លែង | ១៤៩កន្លែង | កើន១កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ៣៦កន្លែង | ២៩កន្លែង | ថយ៧កន្លែង |
| សាលាបង្រៀនសាសនា | ៣៦កន្លែង | ៤៥កន្លែង | កើន៩កន្លែង |
| បរិស័ទ | ១៦ ៩៦៩នាក់ | ១៧ ៩៨៦នាក់ | កើន១ ០១៧នាក់ |
| បាហៃ | | | |
| វិហារ | ៥កន្លែង | ៣កន្លែង | ថយ២កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ១៥កន្លែង | ១៥កន្លែង | |
| សាលាបង្រៀនសាសនា | ៤កន្លែង | ៣កន្លែង | ថយ១កន្លែង |
| អង្គការសមាគម | - | - | - |
| បរិស័ទ | ៤ ០០៣នាក់ | ២ ៥៣១នាក់ | ថយ១ ៤៧២នាក់ |
| កៅដាយ | | | |
| វិហារ | ៣កន្លែង | ២កន្លែង | ថយ១កន្លែង |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | - | ១កន្លែង | កើន១កន្លែង |
| សាលាបង្រៀនសាសនា | ១កន្លែង | - | ថយ១កន្លែង |
| បរិស័ទ | ១ ៨២៨នាក់ | ៤៨៩នាក់ | ថយ១ ៣៣៩នាក់ |

## ២.៤- ការងារព័ត៌មាន

| ប្រភេទអាជ្ញាបណ្ណដែលបានអនុញ្ញាតឱ្យផ្សព្វផ្សាយឬឃោសនា | ២០១៨ | | ២០១៩ | |
|---|---|---|---|---|
| | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត |
| ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ | | | | |
| ស្ថានីយទូរទស្សន៍រដ្ឋ(ទ.ទ.ក.) | | | | |
| *ផ្សព្វផ្សាយក្នុងប្រទេស(ភាសាខ្មែរ បារាំង អង់គ្លេស)*<br>*ផ្សព្វផ្សាយក្រៅបរទេស(ភាសាខ្មែរ បារាំង អង់គ្លេស)* | *៨ ៣៣៧ម៉ោង*<br>*១ ៦១៣ម៉ោង* | | *៨ ៧៤៤ម៉ោង*<br>*១ ៦៣០ម៉ោង* | |
| ស្ថានីយវិទ្យុរដ្ឋ | | | | |
| AM 918MHz *និង* FM 105.70MHz<br>*(ភាសាខ្មែរ បារាំង អង់គ្លេស)*<br>FM 96MHz<br>*(ភាសាខ្មែរ  អង់គ្លេស ចិន វៀតណាម ឥស្លាម)* | *៦ ២២៩ម៉ោង*<br>*៦ ៨៤០ម៉ោង* | | *៥ ១១៩ម៉ោង*<br>*៦ ៨៤០ម៉ោង* | |
| ទីភ្នាក់ងារ សារព័ត៌មានរដ្ឋ | | | | |
| *ទីភ្នាក់ងារសារព័ត៌មាន* AKP *បានចុះយកព័ត៌មាន*<br>*បោះពុម្ពព្រឹត្តិបត្រប្រចាំថ្ងៃ* | *៤ ៩៥៥លើក*<br>*១៤ ៥៥៩ច្បាប់* | | *៤ ៩៣៣លើក*<br>*១៣ ១៩១ច្បាប់* | |

## ២.៥- ការងារចុះបញ្ជីអង្គភាពសារព័ត៌មាននៅក្រសួងព័ត៌មាន

ការិយាល័យច្រកចេញចូលតែមួយនៅអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ នៃក្រសួងព័ត៌មាន បានចុះបញ្ជីអង្គភាពសារព័ត៌មាន ដូចខាងក្រោម:

១-គេហទំព័រនិងTV Online សរុបចំនួន៦៦៩អង្គភាព(គេហទំព័រចំនួន៥៨៨ និងTV Onlineចំនួន ៨១អង្គភាព)។

២ - ការសែតចំនួន៤៥០អង្គភាព ក្នុងនោះចាងហ្វាងជាជនបរទេស២៨អង្គភាព។

៣ -សមាគមសារព័ត៌មាន៥១អង្គភាព ក្នុងនោះចាងហ្វាងជាជនបរទេស១អង្គភាព។

៤ -ទស្សនាវដ្ដីចំនួន១៩៦អង្គភាព ក្នុងនោះចាងហ្វាងជាជនបរទេស៣១អង្គភាព។

៥ -ព្រឹត្តិបត្រចំនួន២២អង្គភាព ក្នុងនោះចាងហ្វាងជាជនបរទេស៧អង្គភាព។

៦ - រោងពុម្ពចំនួន១១៤អង្គភាព ក្នុងនោះចាងហ្វាងជាស្ត្រី៤នាក់(លុប១អង្គភាព)។

៧- សៀវភៅចំនួន២២អង្គភាព ក្នុងនោះចាងហ្វាងជាជនបរទេស៥អង្គភាព។

៨- ភ្នាក់ងារសារព័ត៌មានបរទេសចំនួន២៤អង្គភាព អ្នកឆ្លើយឆ្លងព័ត៌មាន១អង្គភាព។

៩- ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្មចំនួន១។

១០- ស្ថានីយវិទ្យុFM ចំនួន៨៣ស្ថានីយ នៅមានបណ្ដាញតាមខេត្តចំនួន១៣៧ស្ថានីយ និងវិទ្យុAM ចំនួន១ស្ថានីយនៅរាជធានីភ្នំពេញ។

១១- ទូរទស្សន៍អាណាឡូកចំនួន១៩ស្ថានីយ។

១២- ទូរទស្សន៍Digitalចំនួន៨ស្ថានីយ។

១៣- ទូរទស្សន៍ខ្សែកាបនៅរាជធានីភ្នំពេញ២ស្ថានីយនិងតាមខេត្តចំនួន២១០ស្ថានីយ។

១៤- ប្រព័ន្ធOTT ចំនួន៧។

១៥- ប្រព័ន្ធSatellite ចំនួន២(DTV,SKYOne)។

## មុំទី៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

### លទ្ធផលការងារសំខាន់ៗរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

### ១- ការចុះបញ្ជីដីធ្លី

| បរិយាយ | ការចុះបញ្ជីដី លក្ខណៈជា ប្រព័ន្ធ | ការចុះបញ្ជីដី លក្ខណៈដាច់ ដោយដុំ | ការចុះបញ្ជីដី សហគមន៍ជនជាតិ ដើមភាគតិច | សរុបតាមឆ្នាំ |
|---|---|---|---|---|
| ២០១៨(១ឆ្នាំ) | ២៣២ ១១៩ | ២ ២៨៤ | ១៦៥បណ្ណ ស្មើនឹង៥សហគមន៍ | ២៣៤ ៥៦៨បណ្ណ ស្មើនឹង ៥៨,៦៤% នៃផែនការ សរុបចំនួន៤០ម៉ឺនក្បាលដី |
| ២០១៩ (តុលា ២០១៨-កញ្ញា២០១៩) | ៣៤២ ១០៩ | ១ ៦៥១ | ៣០បណ្ណ ស្មើនឹង១សហគមន៍ | ៣៤៣ ៧៩០បណ្ណ ស្មើនឹង ៤៣% នៃផែនការសរុប ចំនួន៨០ម៉ឺនក្បាលដី |

លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ សម្រេចចេញបណ្ណបានចំនួន៥ ៤០០ ៣៧១ បណ្ណ(ស្មើនឹង៧៧,១៥%នៃក្បាលដីប៉ាន់ស្មាន៧លានក្បាលដី)។ ក្នុងនោះការចុះបញ្ជីដីជាលក្ខណៈប្រព័ន្ធសម្រេច បាន៤ ៧៨៣ ៣៨០បណ្ណ(តាមបទបញ្ជាលេខ០១បប បានចំនួន៦៤២ ៦០៣បណ្ណ)និងការចុះបញ្ជីដីមានលក្ខណៈ ដាច់ដោយដុំសម្រេចបាន៦១៦ ៩៩១បណ្ណ(ដីរដ្ឋបាន១ ៧៧៧បណ្ណ ទំហំ៧៣៦ ៥៦៥ហ.ត. ដីឯកជនបាន ៦១៤ ៥០០បណ្ណ និងដីសហគមន៍ជនជាតិដើមភាគតិចបាន២៥សហគមន៍ ស្មើនឹង៧១៤បណ្ណ ទំហំ២៣ ៣៣៨,២៥ ហ.ត. សម្រាប់២ ៦៨៣គ្រួសារ។

## ២- លទ្ធផលការងារ

### ២.១- សមត្ថកិច្ចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ)

| បរិយាយ | ទទួលពាក្យបណ្ដឹង | ចំណាត់ការ | | |
|---|---|---|---|---|
| | | បង្វែរ | ដោះស្រាយរួច | កំពុងដោះស្រាយ |
| ២០១៨(១ឆ្នាំ) | ១ ៨១៥ | ០ | ១ ៧៦៤ | ៥១ |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | ៧៩ | ១ | ១ | ៧៧ |

### ២.២- សមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ការដោះស្រាយចប់នីតិវិធីដោយយន្តការគណៈកម្មការសុរិយោដី និងក្រុមដោះស្រាយវិវាទរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

| បរិយាយ | ករណីទទួលបាន | ដោះស្រាយបញ្ចប់ | ច្រានចោល | ដកបណ្ដឹង | បង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធនិងឆ្លើយទៅសាមីសំណើ |
|---|---|---|---|---|---|
| ២០១៨(១ឆ្នាំ) | ១ ១១៥ | ៣៤៤ | ១៧៦ | ៤៧ | ៧៣ |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | ១ ៣៥០ | ៣០០ | ១៥០ | ៣៧ | ៤៨ |

លទ្ធផលសរុបនៃការដោះស្រាយទាំងបីយន្តការ ចាប់ពីដំណើរការរហូតដល់ខែកញ្ញាឆ្នាំ២០១៩ ទទួលពាក្យបណ្ដឹងបានចំនួន១២ ៤៤៣ករណី ក្នុងនោះដោះស្រាយរួចបាន៩ ៧៦១ករណី (ក្នុងនោះដោះស្រាយបញ្ចប់ចំនួន៦ ០៦៤ករណី ច្រានចោលចំនួន២ ៨០០ករណី ដកបណ្ដឹងចំនួន៨៩៧ករណី និងធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្ដឹងនិងបង្វែរសំណុំរឿងទៅសមត្ថកិច្ចពាក់ព័ន្ធចំនួន២៦៤ករណី។

## ៣- ការងាររៀបចំដែនដីនិងនគរូបនីយកម្ម

| ការងារសិក្សារៀបចំផែនការរូបវន្ត | | | |
|---|---|---|---|
| បរិយាយ | ថ្នាក់រាជធានី-ខេត្ត | ថ្នាក់ក្រុង-ទីប្រជុំជន | ថ្នាក់ឃុំ-សង្កាត់ |
| ២០១៨(១ឆ្នាំ) | -ប្លង់គោលប្រើប្រាស់ដី ខេត្តព្រះសីហនុ<br>-ប្លង់គោលប្រើប្រាស់ដី ខេត្តបាត់ដំបង | -ប្លង់គោលប្រើប្រាស់ដីក្រុងកែប<br>-ប្លង់គោលប្រើប្រាស់ដីក្រុងកំពត<br>-ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ<br>-ប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប<br>-ប្លង់គោលប្រើប្រាស់ដីស្រុកជ្រៃធំ | -ផែនការប្រើប្រាស់ដី ឃុំរាម ខេត្តព្រះសីហនុ<br>-ផែនការប្រើប្រាស់ដី ឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | | -ប្លង់គោលប្រើប្រាស់ដីក្រុងបូកគោ<br>-ប្លង់គោលប្រើប្រាស់ដីក្រុង ខេមរភូមិន្ទ | |

លទ្ធផលគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ បានសម្រេចដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីថ្នាក់រាជធានី ខេត្តចំនួន២ ថ្នាក់ក្រុង-ទីប្រជុំជនចំនួន៧ និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ-សង្កាត់ចំនួន២។

## ៤- ការអភិវឌ្ឍលំនៅឋាន

### ៤.១- លំនៅឋានតម្លៃសមរម្យ

| បរិយាយ | ចំនួនគម្រោង | ចំនួនលំនៅឋាន | | ចំនួនចំណែកឯកជន | |
|---|---|---|---|---|---|
| | | តម្លៃក្រោម ៣០ ០០០ ដុល្លារ | តម្លៃចាប់ពី ៣០ ០០០ ដុល្លារ | តម្លៃក្រោម ៣០ ០០០ ដុល្លារ | តម្លៃចាប់ពី ៣០ ០០០ ដុល្លារ |
| ២០១៨(១ឆ្នាំ) | ៤ | ៣ ៣៤១ | ៤ ៩៩០ | ១៥២០ | ១ ៤៤០ |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | ១ | ០ | ០ | ៤ ១៤០ | ១៥៦ |

លទ្ធផលសរុបគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ មានគម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យមានចំនួន៥គម្រោង សាងសង់លំនៅឋានចំនួន៨ ៣៣១ខ្នង និង៧ ២៥៦ ចំណែកឯកជន។

### ៤.២- លំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុ

| បរិយាយ | ចំនួនគម្រោង | ចំនួនលំនៅឋានសាងសង់ថ្មី | ចំនួនលំនៅឋានជួសជុលពង្រឹង |
|---|---|---|---|
| ២០១៨ (១ឆ្នាំ) | ១ | ១០ | ១២ |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | ១ | ១០៤ | ៩៨ |

លទ្ធផលសរុបគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ មានគម្រោងលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុមានចំនួន២គម្រោង សាងសង់លំនៅឋានថ្មីចំនួន១១៤ខ្នង និងជួសជុលពង្រឹងចំនួន ១១០ខ្នង។

### ៤.៣- ការអភិវឌ្ឍដោយចីរភាព

- បានរៀបចំការអនុវត្តឆ្លើយតបពេញលេញទៅនឹងសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងពិធីសារទាំងអស់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព ដែលកម្ពុជាជាហត្ថលេខី
- បានរៀបចំនិងប្រកាសដាក់ឱ្យប្រើប្រាស់ នូវផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពឆ្នាំ២០១៨-២០៣០ សម្រាប់រាជធានីភ្នំពេញ និងកំពុងជំរុញការរៀបចំផែនការនេះសម្រាប់បណ្ដាក្រុងសំខាន់ៗផ្សេងទៀត ដូចជាខេត្តកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងក្រុងបាវិត
- បានសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តកម្មវិធីនិងគម្រោងនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចបៃតង និងជីវៈចម្រុះ ដូចជាបានដាក់បញ្ចូលទស្សនាទានទាំងនេះ ទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០
- បានរៀបចំគោលការណ៍ណែនាំបច្ចេកទេស និងឯកសារសម្រាប់ផ្សព្វផ្សាយស្តីពីការជំរុញការប្រើប្រាស់អំពូលប្រសិទ្ធភាពថាមពល CFLs និង LEDs សម្រាប់ស្ថាប័នរដ្ឋ ដោយសហការជាមួយក្រសួងរ៉ែនិងថាមពលនិងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- បានសិក្សា និងបានលើកអនុសាសន៍គោលនយោបាយពាក់ព័ន្ធនឹងយានយន្តជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យលទ្ធភាពអនុវត្ត និងដាក់បញ្ចូលក្នុងគោលនយោបាយសារពើពន្ធឬយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៩-២០២៣
- បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសិក្សានិងចងក្រងរបាយការណ៍ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៦-២០៥០
- បានបង្កើតក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យ ដើម្បីពិនិត្យផ្តល់យោបល់ក្នុងការរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្តីពីថាមពលកកើតឡើងវិញ ដោយបានបោះពុម្ពផ្សាយរបាយការណ៍ស្តីពីការកាត់បន្ថយហានិភ័យ លើការវិនិយោគថាមពលកកើតឡើងវិញនៅកម្ពុជា ក្រោមកិច្ចសហការជាមួយUNDP ។

## ៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនៅតាមរាជធានី-ខេត្ត

### ១- រាជធានីភ្នំពេញ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលរាជធានីភ្នំពេញក្នុងឆ្នាំ២០១៩**

- រៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ២០២០-២០២៤ និងគម្រោងវិនិយោគបីឆ្នាំរំកិល២០២០-២០២២ ក្នុងនោះ គម្រោងសកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញចំនួន**២១៧** គម្រោងសកម្មភាពរបស់រដ្ឋបាលខណ្ឌសង្កាត់ចំនួន៤០៩ និងគម្រោងសកម្មភាពរបស់មន្ទីរ អង្គភាពចំនួន៨១ សរុបមានថវិកាគាំទ្រប្រមាណ **៩៨៥ ពាន់លានរៀល**

- អនុវត្តគម្រោងស្តារឡើងវិញប្រឡាយមេនាំទឹកស្ទឹងមានជ័យ និងគោលការណ៍ប្រទានកម្មរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** សម្រាប់ដោះស្រាយបញ្ហាសំណង់មិនរៀបរយលើផ្ទៃប្រឡាយ និងអភិវឌ្ឍលំនៅឋាននៅនឹងកន្លែងជូនប្រជាពលរដ្ឋក្រីក្រក្នុងសហគមន៍ស្ទឹងមានជ័យ។ ផ្អែកតាមគោលនយោបាយប្រទានកម្មរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ចំនួនសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញបានថយចុះពី**៣៣៥** សហគមន៍ក្នុងឆ្នាំ២០០៣ មកត្រឹមតែ**១៥១** សហគមន៍ក្នុងឆ្នាំ២០២០ ដែលមានមូលដ្ឋានក្នុងសង្កាត់ចំនួន**៤៥** នៃខណ្ឌ**១៣**(លើកលែងខណ្ឌ៧មករា ដែលសហគមន៍បុរីកីឡាត្រូវបានលុបចេញពីបញ្ជីសហគមន៍ក្រីក្រក្នុងឆ្នាំ២០១៤) សរុបមានខ្នងផ្ទះសរុប១២ ៨៧៦ខ្នង ស្មើនឹង១៣ ៩៦៣គ្រួសារ និងមានប្រជាពលរដ្ឋសរុប៦១ ៧១៥ នាក់។

ជារួមមកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈរដ្ឋបាលរាជធានីភ្នំពេញបានធ្វើប្រទានកម្មសរុបបានចំនួន២៩ទីតាំង លើផ្ទៃដីទំហំ៨២ហិកតា ដោយបានប្រគល់ដីធ្លីជូនប្រជាពលរដ្ឋប្រមាណ១៨.០០០គ្រួសារ។

- បិទបញ្ចប់ទាំងស្រុងសំណុំរឿងទំនាស់ដីធ្លីរ៉ាំរ៉ៃអូសបន្លាយរយៈពេលជាច្រើនឆ្នាំក្នុងតំបន់អភិវឌ្ឍន៍បឹងកក់និងសហគមន៍បុរីកីឡា ដោយបានប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ សិទ្ធិលំនៅឋាន និងគោលការណ៍មនុស្សធម៌ ព្រមទាំងកំពុងឈានទៅបន្តដោះស្រាយបញ្ចប់បញ្ហាតំបន់អភិវឌ្ឍន៍ឫស្សីកែវ តំបន់អភិវឌ្ឍន៍បឹងទំពន់ជើងឯក តំបន់អតីតផ្លូវដែក តំបន់ស្ថានីយ៍បូមទឹកទួលគោក តំបន់ស្ថានីយ៍ស្តុកទឹកបឹងត្របែក និងពិនិត្យរៀបចំតំបន់មិនរៀបរយមួយចំនួនទៀត

- បានផ្តល់សេវារបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ដោយបានរៀបចំកែសម្រួលខ្សែរត់ពី៣ខ្សែរហូតដល់១៣ខ្សែ ដោយប្រើប្រាស់រថយន្តក្រុងចំនួន២៣៥គ្រឿង ហើយជាបណ្តើរៗបងប្អូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានកាន់តែមានការគាំទ្រនិងនិយមប្រើប្រាស់សេវានេះ ជាមធ្យមមានប្រជាពលរដ្ឋ**៣ម៉ឺននាក់** បានប្រើប្រាស់សេវារថយន្តក្រុងជារៀងរាល់ថ្ងៃ

- បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលគម្រោងអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ក្នុងរាជធានីភ្នំពេញ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន ដែលការអនុវត្តគម្រោងនេះ គឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពចរាចរក្នុងរាជធានីភ្នំពេញ និងកំពុងបន្តយកចិត្តទុកដាក់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាគម្រោងរៀបចំប្រព័ន្ធផ្លូវឯកទិសក្នុងខណ្ឌកណ្តាលរាជធានីភ្នំពេញ គម្រោងស្ថាបនាស្ពានអាកាស និងផ្លូវក្រោមដីត្រង់ចំណុចរង្វង់មូលចោមចៅ គម្រោងកែលម្អប្រព័ន្ធចរាចរណ៍មុំសួនច្បារក្តាន់ពីរ និងតំបន់ខាងមុខសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គម្រោងស្ពានបេតុងឆ្លងកាត់ទន្លេសាប គម្រោងស្ពានបេតុងឆ្លងកាត់ទន្លេបាសាក់ គម្រោងសិក្សាផ្លូវក្រោមដីក្នុងខណ្ឌច្បារអំពៅ គម្រោងសិក្សាផ្លូវក្រោមដីក្នុងខណ្ឌឫស្សីកែវ គម្រោងស្ពានអាកាសថ្មើរជើងក្នុងតំបន់ប្រជុំជន គម្រោងផ្លូវថ្មើរជើងតាមបណ្តោយមាត់ទន្លេបាសាក់ និងគម្រោងផ្លូវអមសងខាងផ្លូវដែកឆ្ពោះទៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញជាដើម។

ជារួម ក្រោមដំបូលនៃសន្តិភាពរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរជាបណ្តើរៗ ហើយគម្រោងអភិវឌ្ឍន៍ជាច្រើនទាំងផ្នែករដ្ឋនិងផ្នែកឯកជន បាននឹងកំពុងដំណើរការយ៉ាងសស្រាក់សស្រាំនៅរាជធានីភ្នំពេញ ក្នុងនោះ សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសំណង់សិល្បៈការដែលយើងសម្រេចបាន រួមមាន៖

- មហាវិថី វិថី និងផ្លូវថ្នល់ដែលបានស្ថាបនាថ្មី និងពង្រីកបន្ថែមចំនួន៣៨ខ្សែ មានប្រវែងសរុបប្រមាណ៥៨០គីឡូម៉ែត្រ លើប្រវែងផ្លូវសរុប១ ៨៨៣គីឡូម៉ែត្រ

- ស្ពានអាកាសមានចំនួន៥កន្លែង ផ្លូវក្រោមដី៣កន្លែង ស្ពានបេតុងស្ថាបនាថ្មីចំនួន១៣កន្លែង និងផ្លូវអាកាសថ្មើរជើង៥កន្លែង និងកំពុងបន្តសិក្សាសាងសង់ស្ពានអាកាសថ្មើរជើងថ្មីចំនួន២៧កន្លែងបន្ថែមទៀតក្នុងគោលបំណងកាត់បន្ថយហានិភ័យនៃការដើរឆ្លងផ្លូវរបស់បងប្អូនប្រជាពលរដ្ឋ និងកាត់បន្ថយការកកស្ទះចរាចរណ៍ផងដែរ

- ស្ថានីយបូមទឹកស្ថាបនាមានចំនួន១៤កន្លែង ប្រឡាយជញ្ជាំងបេតុង៨ខ្សែ បណ្តាញលូប្រវែង ៩០១,២គីឡូម៉ែត្រ និងអណ្តូងលូគ្រប់ប្រភេទសរុបចំនួន៥៤.៧៥៦អណ្តូងលូ

- សួនច្បារសាងសង់ថ្មីនិងកែលម្អសោភណភាពឡើងវិញមានចំនួន១១៣កន្លែង

- សំណង់បុរីនិងបណ្តុំផ្ទះល្វែងមានចំនួន២៥៤កន្លែង

- អគារខ្ពស់ៗចាប់ពីប្រាំជាន់ឡើងទៅមានចំនួន១ ៤២៤អគារ

- ភោជនីយដ្ឋាន-អាហារដ្ឋាន៤៩៧ទីតាំង ផ្ទះសំណាក់៥២៨ទីតាំង និងសណ្ឋាគារប្រណីតដែលមានចំណាត់ថ្នាក់ពីផ្កាយ១ ដល់ផ្កាយ៥ ចំនួន១៨២ទីតាំង

- សេវាកម្មសុខភាពនិងកីឡាមាន១៣៤ទីតាំង សេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ១៣៥ទីតាំង សេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍៣៩៩ក្រុមហ៊ុន។

### ២-ខេត្តកណ្តាល

- ផ្លូវជាតិសំខាន់ៗឆ្លងកាត់ខេត្តកណ្តាល រួមមានផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ និងលេខ៨ ផ្លូវក្រវ៉ាត់ក្រុងទី២ ផ្លូវក្រវ៉ាត់ក្រុងទី៣ ផ្លូវល្បឿនលឿនភ្នំពេញ ព្រះសីហនុ និងផ្លូវខេត្តសំខាន់ៗមួយចំនួនទៀត

- ស្ពានធំៗក្នុងភូមិសាស្ត្រខេត្តកណ្ដាល រួមមានស្ពានត្បីបាហ្សា(ស្ពានអ្នកលឿងមិត្តភាពកម្ពុជា-ជប៉ុន) ស្ពានមិត្តភាពកម្ពុជា-ចិន ស្ពានព្រែកតាមាក់ ស្ពានមិត្តភាពកម្ពុជា-ចិនព្រែកក្ដាម ស្ពានមិត្តភាពកម្ពុជា-ចិនតាខ្មៅ(ស្ពានព្រែកសំរោង) ស្ពានមិត្តភាពកម្ពុជា-ចិន កោះធំ

- ជួសជុល ថែទាំផ្លូវជាតិ ផ្លូវខេត្ត ក្នុងភូមិសាស្ត្រខេត្តកណ្ដាល មានផ្លូវកៅស៊ូ៤៤៧គីឡូម៉ែត្រ ផ្លូវក្រួសក្រហម៤៣គីឡូម៉ែត និងស្ពារប្រឡាយរំដោះទឹកស្អុយ៦ ៦២៣ម៉ែត្រ សាងសង់ស្ថានីយបូមទឹកស្អុយចំនួន១កន្លែង

- សាងសង់ស្ពានចំនួន៤កន្លែង(ស្ពានលាក ស្ពានព្រែកស្បូវ ស្ពានព្រែករាំងទី១ និងស្ពានព្រែករាំង២)

- ការងារជួសជុលកែលម្អប្រឡាយ១ ៤០០ម៉ែត្រ ផ្លូវក្រាលកៅស៊ូ(DBST)១៥គីឡូម៉ែត្រ លូប្រវែងសរុប១២ ៧១៣ម៉ែត្រ រ៉ែហ្គា៤៤៤ម៉ែត្រ និងច្រាំងព្រែកជ្រៃធំ ការពារបង្គោលព្រំដែនលេខ២៤៦/២(១) ប្រវែង១០០ម៉ែត្រ

- ការងារវិនិយោគខេត្ត ចាប់ពីឆ្នាំ២០១៩ រហូតដល់បច្ចុប្បន្ន រដ្ឋបាលខេត្តបានសម្រេចនូវសមិទ្ធផលលើការងារវិនិយោគ លើការងារកែលម្អ និងជួសជុលផ្លូវ១៣៣ខ្សែសរុប១២៧,៦៨៨គ.ម. ព្រមទាំងការរៀបចំប្រឡាយ ប្រព័ន្ធលូ ស្ពាន ទ្វារទឹកនិងប្រព័ន្ធគមនាគមន៍ជាច្រើនទៀត

- ការដាក់ភ្លើងបំភ្លឺសាធារណៈក្នុងខេត្ត២០១៩-២០២០រួមមានបង្គោលដងគោម៣៥២ ដៃគោម៤៣០ដៃគោម អំពូល៨០៨អំពូល ប្រអប់បញ្ជា២៧ប្រអប់បញ្ជាប្រវែងសរុប២៧ ៧៩០ម៉ែត្រ

- បានសហការជាមួយអគ្គិសនីកម្ពុជា ក្នុងការសាងសង់រោងចក្រអគ្គិសនីកម្លាំង៤០០ មេហ្គាវ៉ាត់ លើផ្ទៃដី៤៣ហិកតា ស្ថិតនៅក្នុងភូមិកោះរះក្រោម ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល

- ក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គិសនី(រដ្ឋនិងឯកជន) ចំនួន៦២ក្រុមហ៊ុន មានអាជ្ញាប័ណ្ណអគ្គិសនី១ ០១០ ភូមិ ស្មើនឹង១០០%និងមានបណ្ដាញអគ្គិសនីគ្របដណ្ដប់លើភូមិ១០០៨ភូមិ ស្មើនឹង៩៩.៨០%

- បានសម្របសម្រួល ដោះស្រាយបញ្ចប់ និងរៀបចំចុះបញ្ជីសម្គាល់វិញ្ញាបនបត្រអចលនវត្ថុដីរដ្ឋទំហំ៥០ហិកតា ស្ថិតនៅភូមិព្រែកថ្មី សង្កាត់កោរខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល សម្រាប់សាងសង់អាងប្រព្រឹត្តិកម្មរំដោះទឹកកខ្វក់ចេញពីក្រុងតាខ្មៅ ដើម្បីចម្រោះទឹកកង្វក់បានទាន់ពេលវេលា ព្រមទាំងកុំឱ្យហូរចូលទៅក្នុងទន្លេដែលជាហេតុនាំឱ្យមានការបំពុលទឹក និងធានាបានសុខមាលភាពជូនប្រជាពលរដ្ឋ

- ឡដុតសំរាមចំនួន៤គ្រឿង(តម្លើងនៅទីលានចាក់សំរាមព្រែកហូរ១គ្រឿង តម្លើងនៅស្រុកអង្គស្នួល១គ្រឿង និងតម្លើងនៅស្រុកពញាឮចំនួន២គ្រឿង)

- ទីលាននិងរណ្ដៅចាក់សំរាមចំនួន៣ទីតាំង(១ទីតាំងនៅក្រុងតាខ្មៅ ១ទីតាំងនៅស្រុកស្អាង និង១ទីតាំងនៅស្រុកខ្សាច់កណ្ដាល)

- បានរៀបចំសហការនិងជំរុញឱ្យបង្កើតរមណីយដ្ឋានទេសចរណ៍ធម្មជាតិកែច្នៃ នៅរមណីយដ្ឋានចំការស្នេហ៍ ស្ពាយលែន(7NG) ព្រីនម៉ាន់និងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ភ្នំប្រសិទ្ធ វត្តកៀនស្វាយក្រៅ ស្អាងភ្នំ សម្រាប់ចូលទស្សនាកម្សាន្ត និងលម្ហែកាយ ព្រមទាំងបង្កើនចំនួនសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន នៅទូទាំងខេត្ត និងកាស៊ីណូនៅតាមតំបន់ព្រំដែន

- បានយកចិត្តទុកដាក់រៀបចំសោភណភាពក្រុង ស្រុកឱ្យកាន់តែទទួលបានភាពទាក់ទាញ ដែលទីក្រុងតាខ្មៅបានទទួលពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២។

### ៣- ខេត្តព្រះសីហនុ

- ផ្លូវដែកមានប្រវែង៦៩គ.ម.(ត្រពាំងរពៅ-ក្រុងព្រះសីហនុ)
- ផ្លូវជាតិលេខ៤មានប្រវែង១១៩,២០គ.ម.(ពេជ្រនិល-កំពង់ផែស្វយ័តក្រុងព្រះសីហនុ)
- ផ្លូវជាតិលេខ៣មានប្រវែង២១,៥០គ.ម.(ត្រពាំងរពៅ-វាលរេញ)
- ផ្លូវជាតិលេខ៤៥មានប្រវែង១១,៥គ.ម.(RN4ស្មាច់ដែង-ឃ្លាំងប្រេងPTTរាម)
- ផ្លូវខេត្តលេខ១៤៦ អា មានប្រវែង១៥,៦ គ.ម.(RN4តានៃ-ផែម៉ុងឬទ្ធី)
- ផ្លូវខេត្តលេខ១៤៦ បេ មានប្រវែ ២៤,៥គ.ម.(RN4ជើងគោ ស្រុកព្រៃនប់ ដល់ស្រុកស្ទឹងហាវ)
- ការស្ថាបនាផ្លូវក្រុងចំនួន៣៤ខ្សែ មានប្រវែងសរុប៨២.៥០៥ម៉ែត្រ ក្នុងខេត្តព្រះសីហនុ គិតចាប់ពីថ្ងៃបើកការដ្ឋានស្ថាបនាផ្លូវនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី រហូតមកដល់បច្ចុប្បន្នសម្រេចបានប្រមាណ៩៤% ដោយមិនគិតបញ្ចូលការងារអ៊ុតកៅស៊ូ គំនូសសញ្ញាចរាចរណ៍ ដាំដើមឈើ បំពាក់កាមេរ៉ាសុវត្ថិភាព បង្គោលភ្លើងបំភ្លឺផ្លូវនិងការរៀបកម្រាលថ្មក្រានីត ក្នុងនោះរួមមាន៖

+ មហាវិថីមាន៣ខ្សែ គឺមហាវិថីរាម មហាវិថីឆ្នេររាម និងមហាវិថីជំទាវម៉ៅប្រវែង២២.៧៣១ម៉ែត្រ ទទឹង៥០ម៉ែត្រ ទ្រូងផ្លូវ២៥.៧៥ម៉ែត្រ ផ្លូវរថយន្ត៦គន្លង ផ្លូវទោចក្រយានយន្ត២គន្លង ។

+ វិថីមាន១៤ខ្សែ ប្រវែង៤៩.៩៥៧ម៉ែត្រ ទទឹង២០ម៉ែត្រ ទៅ៤០ម៉ែត្រ ទ្រូងផ្លូវ១៧.២៥ម៉ែត្រ ផ្លូវរថយន្ត២ទៅ៤គន្លង ផ្លូវទោចក្រយានយន្ត២គន្លង ។

+ អនុវិថីមាន១៧ខ្សែ ប្រវែង១១.៨១៧ម៉ែត្រ ទទឹង៨ម៉ែត្រទៅ៤០ម៉ែត្រ ទ្រូងផ្លូវ៨.២៥ ម៉ែត្រទៅ១២ម៉ែត្រ មានផ្លូវរថយន្ត២គន្លង និងផ្លូវទោចក្រយានយន្ត២គន្លង។

- មានកំពង់ផែធំៗមានចំនួន៣ គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែឧកញ៉ាម៉ុង និងកំពង់ផែអន្តរជាតិស្ទឹងហាវ ស្ថិតនៅក្នុងស្រុកស្ទឹងហាវ និងមានអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

- រោងចក្រអគ្គិសនីដំណើរការដោយធ្យូងថ្មមានចំនួនពីរក្រុមហ៊ុន ស្មើនឹង៤រោងចក្រគឺ៖ក្រុមហ៊ុន CELI+II(ក្រុមហ៊ុនខេមបូឌាន អេនើជី លីមីតធីត)ស្ថិតនៅឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ផលិតបាន២៣៥មេហ្គាវ៉ាត់ និងក្រុមហ៊ុនCIIDG I+II(អេឡិចត្រូនិចផៅវើ ខូអីលធីឌី)ស្ថិតនៅឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុផលិតបាន៣៧៧មេហ្គាវ៉ាត់

- មានប្លុកប្រេងកាតចំនួនបួនប្លុក គឺប្លុក A, B, C, និងD។ ក្នុងនោះរោងចក្រចម្រាញ់ប្រេងកាតនៅខេត្តព្រះសីហនុមាន០១កន្លែង ស្ថិតនៅភូមិព្រៃកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ(កំពុងសាងសង់)។ កន្លែងសន្និធិប្រេងធំៗ(កន្លែងស្តុកប្រេងធំៗ) មានចំនួន៥កន្លែង រួមមាន (១)ក្រុមហ៊ុនសូគីម៉ិច ស្ថិតនៅឃុំអូត្រេះ ស្រុកស្ទឹងហាវ (២)ក្រុមហ៊ុនតេលា ស្ថិតនៅឃុំអូត្រេះ ស្រុកស្ទឹងហាវ (៣)ក្រុមហ៊ុនកាល់តិច ស្ថិតនៅឃុំអូត្រេះ ស្រុកស្ទឹងហាវ (៤)ក្រុមហ៊ុនអិល.អេច.អរ.ស្ថិតនៅឃុំកំពេញ ស្រុកស្ទឹងហាវ និង(៥)ក្រុមហ៊ុនភី.ធី.ធី.ស្ថិតនៅឃុំរាម ស្រុកព្រៃនប់។

- ស្ថិតិអាជីវកម្មក្នុងវិស័យទេសចរណ៍សរុបមានចំនួន៨៧៧ទីតាំង ក្នុងនោះ (១)សណ្ឋាគារ ១០៧ស្មើនឹង៧ ៥១៥បន្ទប់ (២)បឹងហ្គាឡូ៣៣ស្មើនឹង៤៦២ (៣)បន្ទប់ផ្ទះសំណាក់២៣០ស្មើនឹង២ ៧៧៥ បន្ទប់ (៤)ភោជនីយដ្ឋាន/អាហារដ្ឋាន៣១២ស្មើនឹង១៣ ៨៩២កៅអី (៥)ខារ៉ាអូខេ៣៨ស្មើនឹង៤៤៨បន្ទប់ (៦) ឱស្ថតែក ចំណុះ៨៩៨នាក់ (៧)បៀរហ្គាឌិន៣ស្មើនឹង៣៩០កៅអី (៨)ទូកដឹកភ្ញៀវទេសចរ៣០ម្ចាស់ស្មើនឹង ៥៤ទូក (៩)កីឡាទេសចរណ៍២០ និង (១០)ទីភ្នាក់ងារទេសចរណ៍២៣។ រមណីយដ្ឋានធម្មជាតិនិងកែច្នៃ៦ (មិនរាប់បញ្ចូលរមណីយដ្ឋានឆ្នេរ)។

**៤- ខេត្តកោះកុង**

- ផ្លូវជាតិលេខ៤៨និងស្ពានធំៗចំនួន៤ ជាសរសៃឈាមដ៏សំខាន់តភ្ជាប់ទៅតំបន់និងខេត្តនានា ទូទាំងប្រទេស

- ស្ពានកោះកុង តភ្ជាប់ពីក្រុងខេមរភូមិន្ទទៅកាន់ស្រុកមណ្ឌលសីមា មានប្រវែងសរុប១៩០០ ម៉ែត្រ

- ផ្លូវអ៊ិតកៅស៊ូ AC តាមផ្លូវក្រុងលេខ៩០០ ក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានប្រវែងសរុប ២,២២គីឡូម៉ែត្រ

- វារីអគ្គិសនីទាំង៣ទីតាំង មាន(១)វារីអគ្គិសនីគិរីរម្យ៣ អានុភាព១៨មេហ្គាវ៉ាត់ ស្ថិតនៅឃុំ ដងពែង ស្រុកស្រែអំបិល (២)វារីអគ្គិសនីឬស្សីជ្រុំក្រោមមានអានុភាព៣៣៨មេហ្គាវ៉ាត់ និង(៣)វារីអគ្គិសនី តាតៃមានអានុភាព២៤៦មេហ្គាវ៉ាត់

- មានតំបន់វិស្សមកាល តំបន់អេកូទេសចរណ៍ធម្មជាតិ ព្រៃកោងកាង ទឹកធ្លាក់ តំបន់ឆ្នេរ តំបន់ ផ្កាថ្ម និងតំបន់កោះមួយចំនួន និងមានសេវាកម្មទេសចរណ៍ ដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន មណ្ឌល កម្សាន្ត ក្នុងនោះ សណ្ឋាគារ១០មាន៣១៦បន្ទប់ ផ្ទះសំណាក់៩៦កន្លែងមាន១១៩៧បន្ទប់ ភោជនីយដ្ឋាន អាហារ ដ្ឋាន៩៩កន្លែង ។

**៥- ខេត្តកែប**

- បានរៀបចំកែលម្អសោភណភាពទីក្រុងកែបមានផ្លូវ សួនច្បារ និងការបំពាក់អំពូលភ្លើង

- មានផ្លូវជាតិឆ្លងកាត់២ខ្សែ គឺផ្លូវជាតិលេខ៣៣ និងផ្លូវជាតិលេខ៣៣អា មានប្រវែង៣៧,២៤គ.ម. និងផ្លូវខេត្ត៤ខ្សែមានប្រវែង៤៦,០៥គ.ម.

- មានស្ថានីយរថភ្លើង១កន្លែង និងផ្លូវដែកឆ្លងកាត់១៨គ.ម.មានផែទេសចរណ៍១កន្លែង

- មានសណ្ឋាគារ១៣(បន្ទប់៣២៧) ផ្ទះសំណាក់៥៧(បន្ទប់៥៧) បង់ហ្គាឡូ រីស៊ត២២(បន្ទប់ ២៧៨)

- រមណីយដ្ឋានទាក់ទាញទេសចរមាន៣៥កន្លែងនិងបានរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅតំបន់ ឆ្នេរលេងទឹក ផ្សារក្តាម ទីកន្លែងសម្រាប់ចាក់សំរាមដើម្បីដោះស្រាយបញ្ហាបរិស្ថាន។

**៦- ខេត្តកំពត**

- រោងចក្រផលិតស៊ីម៉ង់ត៍៤ កំពុងដំណើរការដែលអាចផលិតស៊ីម៉ង់ត៍បានចំនួន៦លានតោន ក្នុងមួយឆ្នាំ

- វារីអគ្គិសនីកំចាយអានុភាពតំឡើង១៩៤.១មេហ្គាវ៉ាត់ អាចផលិតអគ្គិសនីបានក្នុងមួយឆ្នាំ ជាង៤០០លានគីឡូវ៉ាត់

- កំពង់ផែសមុទ្រចំនួន៤កន្លែង មានកំពង់ផែទេសចរណ៍ចំនួន១កន្លែង ដែលសព្វថ្ងៃកំពុង សាងសង់បានប្រមាណ៣០% និងរំពឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២០

- មានតំបន់ទេសចរណ៍ពិសេសនៅរមណីយដ្ឋានឋានសួគ៌បូកគោ និងរមណីយដ្ឋានចំនួន១៦កន្លែងទៀត សហគមន៍ទេសចរណ៍ចំនួន៤កន្លែងនិងគោលដៅទាក់ទាញចំនួន៤កន្លែង(ចំការម្រេច ស្រែអំបិល សំណង់បេតិកភណ្ឌនិងសក្តានុពលទេសភាពដងព្រែក)

- មានកំពុងផែទេសចរណ៍ទឹកជ្រៅ ដែលអាចផ្តល់លទ្ធភាពដល់ការចូលចតរបស់នាវាទេស-ចរណ៍ធំៗ។

**៧- ខេត្តសៀមរាប**

- សាងសង់និងជួសជុលផ្លូវថ្នល់ក្នុងខេត្តសរុបចំនួន២៧ខ្សែ ដែលមានប្រវែងសរុប១៦,៤៥០គីឡូម៉ែត្របានដាក់លូនិងលូប្រអប់តាមបណ្តោយផ្លូវ។ ជួសជុលផ្លូវក្រឡុក(សំបុកមាន់ ប៉ះ) នៅលើកំណាត់ផ្លូវវេងការខូចខាតនានាក្នុងក្រុងបានទំហំ២ ៧៨៤,២ម៉ែត្រការ៉េនិងបានគូសគំនូសសញ្ញាចរាចរណ៍ចំនួន៤ ០៥៨ម៉ែត្រការ៉េ

- បានសាងសង់កម្រាល និងចិញ្ចើមផ្លូវបេតុងជ្រាបទឹក ដើម្បីការពារទឹកជំនន់ ទឹកដក់លើផ្លូវនិងចិញ្ចើមផ្លូវតាមបណ្តោយផ្លូវ២ធ្នូប្រវែង៩៣ម៉ែត្រពីចំណុចប្រសព្វPub Streetដល់មុខក្លោងទ្វារមន្ទីរពេទ្យបង្អែកខេត្តសៀមរាប រួមមានកម្រាលផ្លូវ ចំណតនិងចិញ្ចើមផ្លូវដែលជាជំនួយរបស់អង្គការJICA។ ខេត្តក៏បានរៀបចំកែលម្អសោភណភាពសួនច្បារមាត់ស្ទឹងខាងជើងស្ពានថ្មព្រះរាជដំណាក់ ដោយបំពាក់នូវឧបករណ៍ហាត់ប្រាណជាមួយគ្នានេះ ក្រសួងព្រះបរមរាជវាំងក៏បានកំពុងដំណើរការរៀបចំសោភណភាពសួនច្បារមុខព្រះរាជដំណាក់ផងដែរ

- បានដាក់បញ្ចូលនៃផែនការសកម្មភាពទីក្រុងឆ្លាតវៃអាស៊ាន ដោយផ្តោតលើវិស័យពីរជាចម្បង គឺសន្តិសុខនិងបរិស្ថាន។ នៅក្នុងវិស័យសន្តិសុខ រដ្ឋបាល ខេត្តផ្តោតទៅលើការបំពាក់កាមេរ៉ាសុវត្ថិភាពនិងភ្លើងសញ្ញាចរាចរណ៍ដោយឡែកក្នុងវិស័យបរិស្ថាន រដ្ឋបាល ខេត្តផ្តោតទៅលើការគ្រប់គ្រងសំណល់រឹងនិងសំណល់រាវនៅក្នុងក្រុងសៀមរាប

- ក្រុងសៀមរាប បានអនុវត្តនូវគម្រោងភ្លើងបំភ្លឺសាធារណៈឆ្លាតវៃដែលជាប្រភេទអំពូលLED គ្រប់គ្រងដោយប្រព័ន្ធឆ្លាតវៃ ដែលប្រតិបត្តិការដោយក្រុមហ៊ុនចំនួនពីរ គឺក្រុមហ៊ុនមីនីបៀរ(Minebea)របស់ប្រទេសជប៉ុន ដែលអំពូលសរុបចំនួន១ ៩៥០អំពូលនិងក្រុមហ៊ុនវីសាន់(Visun) ប្រទេសចិនដែលមានអំពូលសរុបចំនួន២ ៥៩៤អំពូល

- បានពង្រីកសមត្ថភាពរហូតដល់ផលិតទឹកស្អាតមានចំនួន៣០ ០០០ម$^{៣}$ក្នុងមួយថ្ងៃ ស្មើនឹង៥០% នៃតម្រូវការរបស់ប្រជាជនក្នុងទីប្រជុំជនក្រុងសៀមរាប ដែលមានរហូតដល់ប្រមាណ៦០ ០០០ម$^{៣}$ ក្នុងមួយថ្ងៃ និងមានអតិថិជនប្រើប្រាស់ទឹកស្អាតក្នុងក្រុងសរុប១១ ០២៨គ្រួសារ។ សហការជាមួយទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍(AFD) ក្នុងការកសាងរួចរាល់នូវរោងចក្រផលិតទឹកស្អាតបន្ថែម១៥ ០០០ម$^{៣}$ ក្នុងមួយថ្ងៃនិងពង្រីកបណ្តាញមេចំនួន៦ ០៨៧ម៉ែត្រ។ អនុវត្តគម្រោងបណ្តាញទឹកស្អាតរួចរាល់ ដែលជាថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មានប្រវែងសរុប១០០គីឡូម៉ែត្រនិងបានភ្ជាប់បណ្តាញចូលផ្ទះចំនួន៥ ០០០តំណ

- អគ្គិសនីក្នុងខេត្តឆ្នាំ២០១៩ បានចែកចាយទូទាំងឃុំ សង្កាត់១០០ឃុំ-សង្កាត់របស់ខេត្ត ដែលអាចផ្គត់ផ្គង់បានអតិថិជនសរុប១៥៩ ៣៤៤ កើនឡើង១៣ ៥៩៦ស្មើនឹងភូមិចំនួន៨៦៦ភូមិកើនឡើង៥៥ភូមិនៃភូមិទូទាំងខេត្តសរុប៩២៧ភូមិ។

**៨- ខេត្តកំពង់ធំ**

- ប្រព័ន្ធធារាសាស្ត្រចំនួន២៦១(បានស្តារ ជួសជុល កែលម្អ និងសាងសង់ថ្មីចំនួន៦៧កន្លែង) ប្រភពទឹកសំខាន់ៗ មានស្ទឹងសែនហូរកាត់ខេត្តកំពង់ធំ២៦៥គ.ម. ស្ទឹងស្ទោង១៥៣គ.ម. ស្ទឹងតាំងក្រសាំង១០៣គ.ម.និងស្ទឹងជីនិត២៩៣គ.ម.

- មានអនុស្ថានីយអគ្គិសនីចំនួន១ ដែលអគ្គិសនីកម្ពុជាបានដាក់ឱ្យដំណើរការ ដោយភ្ជាប់ក្នុងដំហានដំបូងផ្នែកខ្សែបញ្ជូនតង់ស្យុង១១៥KV ពីខេត្តព្រះវិហារមានអានុភាព២២MW និងមកពីខេត្តកំពង់ចាមមាន៤MW។ ចំនួនស្ថានីយផលិតនិងចែកចាយថាមពលអគ្គិសនីទូទាំងខេត្តមាន២១ស្ថានីយ ក្នុងនោះបានភ្ជាប់ជាមួយបណ្តាញជាតិរួចហើយចំនួន១៩ស្ថានីយ និងថាមពលអគ្គិសនីដើរដោយប្រើឌីជ្សែលចំនួន២ស្ថានីយ

គិតត្រឹមខែឧសភា ឆ្នាំ២០២០ ឃុំ/សង្កាត់ ដែលមានដែនអាជ្ញាបណ្ណអគ្គិសនីគ្របដណ្តប់ចំនួន៧៩ ឃុំ/សង្កាត់ ស្មើ៩៧,៥៣%នៃ( ឃុំ/សង្កាត់ទូទាំងខេត្តចំនួន៨១ ) ភូមិដែលមានបណ្តាញអគ្គិសនីប្រើប្រាស់រួចហើយចំនួន៧៣១ភូមិ ស្មើ៩៥,៣០%នៃភូមិទាំងអស់ទូទាំងខេត្ត

- មានរមណីយដ្ឋានទេសចរណ៍សំខាន់ៗចំនួន៦កន្លែងគឺ រមណីយដ្ឋានប្រវត្តិសាស្ត្រ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រប្រាសាទសំបូរព្រៃគុក រមណីយដ្ឋានវប្បធម៌ធម្មជាតិភ្នំសន្ទុក រមណីយដ្ឋានធម្មជាតិស្ទឹងព្រៃប្រស់ រមណីយដ្ឋានកែច្នៃបឹងសំរិទ្ធិ និងរមណីយដ្ឋានកែច្នៃស្ទឹងជីនិត។

## ៩- ខេត្តបាត់ដំបង

- ក្នុងឆ្នាំ២០១៩ រដ្ឋបាលខេត្តបាត់ដំបង បានសាងសង់ផ្លូវថ្មីសរុប៣ខ្សែប្រវែង១៧គីឡូម៉ែត្រ សាងសង់ស្ពានបាឡេ១ប្រវែង១៥ម៉ែត្រ និងបានជួសជុលថែទាំផ្លូវជាតិផ្លូវខេត្តបានប្រវែង៩៦៣គីឡូម៉ែត្រ។ ទន្ទឹមនេះ ខេត្តក៏បានសាងសង់លូរំដោះទឹកភ្លៀងប្រវែង៩,១៤គីឡូម៉ែត្រ និងបានជួសជុលថែទាំស្តារប្រព័ន្ធលូបង្ហូរទឹកតាមចិញ្ចើមផ្លូវ ស្រះរងទឹកកខ្វក់ ប្រឡាយមេនិងថែទាំស្តារវីហ្គា។ ជាមួយគ្នានេះ ស្ថានីយប្រព្រឹត្តិកម្មទឹកស្អុយមួយនៅប៉ែកខាងកើតស្ទឹងសង្កែកំពុងសាងសង់ រីឯស្ថានីយប្រព្រឹត្តិកម្មទឹកស្អុយមួយទៀតនៅប៉ែកខាងលិចស្ទឹងកំពុងសិក្សាគម្រោងហើយទីលានចាក់សំរាមថ្មីក៏កំពុងសិក្សាគម្រោងដែរ។

- អង្គភាពរដ្ឋាករទឹកបាត់ដំបងផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងបាត់ដំបងនិងពីរស្រុកទៀតដែលមានគ្រួសារប្រជាពលរដ្ឋចំនួន៥៦.៨% ភ្ជាប់ទៅនឹងបណ្តាញទឹកស្អាត

- ខេត្តបាត់ដំបង បានទទួលការផ្គត់ផ្គង់ថាមពលពីប្រព័ន្ធខ្សែបញ្ជូនជាតិ ១១៥ គីឡូវ៉ុល តាមរយៈអនុស្ថានីយ៍ CPTL(ដែលភ្ជាប់ពីប្រទេសថៃ)និង២៣០គីឡូវ៉ុល តាមរយៈអនុស្ថានីយ៍ CPG (ដែលភ្ជាប់ពីភ្នំពេញ)និងម៉ាស៊ីនភ្លើងបម្រុងសរុបចំនួន៣គ្រឿង កម្លាំងសរុប៣មេហ្គាវ៉ាត់។ ក្រៅពីអង្គភាពអគ្គិសនីបាត់ដំបង ខេត្តមានសេវាករអគ្គិសនីចំនួន២៩ ទៀត

- បានរៀបចំនិងផ្លាស់ប្តូរអំពូលភ្លើងបំភ្លឺតាមដងផ្លូវសាធារណៈទាំងអស់ក្នុងក្រុងបាត់ដំបង ឱ្យទៅជាអំពូលLED។ ខេត្តក៏បានកែលម្អសួនច្បារតាមដងស្ទឹងសង្កែ ដោយរៀបចំឱ្យមានទីធ្លាបន្ថែម បំពាក់ឧបករណ៍សម្រាប់ហាត់ប្រាណបន្ថែម និងរៀបចំកន្លែងអ្នកលក់ដូរចំណីអាហារតាមចិញ្ចើមផ្លូវឱ្យកាន់តែមានការទាក់ទាញនិងអនាម័យ

- មានសណ្ឋាគារនិងផ្ទះសំណាក់មានការកើនឡើងពី៧០ទីតាំង( សរុប២ ២៧៥បន្ទប់ )ក្នុងឆ្នាំ២០១៤ដល់១៥១ទីតាំង( សរុប៣ ៥៣៩បន្ទប់ ) ។

## ១០-ខេត្តប៉ៃលិន

- បច្ចុប្បន្នផ្លូវជាតិលេខ៥៧ ជាផ្លូវកៅស៊ូល្អស្អាតហើយមិនត្រឹមតែប៉ុណ្ណោះ ផ្លូវគមនាគមន៍នៅក្នុងខេត្តត្រូវបានកសាងជាផ្លូវខ្វាត់ខ្វែង ក្នុងនោះផ្លូវកៅស៊ូDBSTមានប្រវែង១១០.១៥៤គីឡូម៉ែត្រ ផ្លូវអ៊ុតកៅស៊ូAC ប្រវែង២ ៤៥០គីឡូម៉ែត្រ ផ្លូវបេតុង១២ ២៤៥គីឡូម៉ែត្រ ផ្លូវក្រួសសល្បាយថ្មភ្នំប្រវែង៣៤១ ១៦១គីឡូម៉ែត្រ អមទៅដោយសំណង់សិល្បៈការ។ ក្នុងនោះឆ្នាំ២០១៩និងដើមឆ្នាំ២០២០ យើងបានពង្រីកផ្លូវឲ្យកាន់តែធំក្រាលកៅស៊ូDBST និងផ្លូវអ៊ុតកៅស៊ូAC៣ខ្សែ ព្រមទាំងបានកសាងឡើងវិញនូវសួនច្បារមុខសាលាខេត្តរៀបចំដាក់បង្គោលភ្លើងបំភ្លឺផ្លូវឲ្យកាន់តែទំនើបស៊ីវិល័យនិងមានសោភណភាព ស្របតាមផែនការអភិវឌ្ឍ៥ឆ្នាំនិងផែនការវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្តដែលបានអនុម័តដោយក្រុមប្រឹក្សា។

**១១- ខេត្តកំពង់ស្ពឺ**

-ការងារថែទាំជាប្រចាំផ្លូវជាតិ ផ្លូវខេត្ត សរុបចំនួន២៤ខ្សែ មានប្រវែងសរុប៥៤៥,០៥គ.ម.

-ការងារជួសជុលខួប សរុបចំនួន៣ខ្សែ មានប្រវែងសរុប៧,១០០គ.ម.

-ការងារថែទាំផ្លូវជាលក្ខណៈខួបឆ្នាំ២០១៩ មានចំនួន៤ខ្សែ ប្រវែង២០,៥០គ.ម.អនុវត្តបាន ១០០%

-ការងារថែទាំផ្លូវជាលក្ខណៈប្រចាំឆ្នាំ២០១៩ មានចំនួន៩ខ្សែ ប្រវែង១០០,៦០គ.ម.អនុវត្តបាន១០០%

-ការងារជួសជុលបន្ទាន់ជំហានទី១និងទី២ ឆ្នាំ២០១៩ មាន៤ខ្សែ ប្រវែង១២,៧៥ គ.ម.អនុវត្តបាន ១០០%

- មានរមណីយដ្ឋានប្រវត្តិសាស្ត្រ៤កន្លែង(រួមមានល្អាងបុរាណវិទ្យាភ្នំចាស់ បុរាណវិទ្យាភ្នំព្រះ រមណីយដ្ឋានប្រវត្តិសាស្ត្រតេទឹកពុះនិងរមណីយដ្ឋានប្រាសាទភ្នំក្អែកពង)។ រមណីយដ្ឋានធម្មជាតិមាន៨កន្លែង រួមមានឧទ្យានជាតិព្រះសុរាម្រិតកុសមៈគីរីរម្យ មណ្ឌលកំសាន្តគីរីរម្យ សហគមន៍ទេសចរណ៍ធម្មជាតិចំបក់ សហគមន៍ទេសចរណ៍ធម្មជាតិជ្រាវ រមណីយដ្ឋានអំពែភ្នំគីរីរម្យផាញរីសត កីឡាដ្ឋានវាយកូនហ្គោល រមណីយដ្ឋានឫទ្ធីគីរីសែនមនោរម្យនិងសារមន្ទីរនេះបុរី១កន្លែង។ តំបន់ទេសចរណ៍ផ្សងព្រេងមាន២ទីតាំងគឺភ្នំឱរ៉ាល់និងភ្នំខ្នងផ្សារ។

**១២- ខេត្តពោធិ៍សាត់**

-ស្ថាបនាផ្លូវជាតិនិងផ្លូវខេត្ត៣ខ្សែ ជួសជុលផ្លូវក្រាលគ្រួសក្រហម១ខ្សែ ជួសជុលជើងទេរក្បាលស្ពាន និងជើងទេរផ្លូវប្រវែងសរុប៣៦គីឡូម៉ែត្រ ដាក់លូបេតុងតាមបណ្តោយផ្លូវជាតិលេខ៥ និងការជួសជុល ថែទាំផ្លូវ ដើម្បីធ្វើឱ្យប្រសើរឡើងវិញ។

-ស្ថាបនាទំនប់បង្រៀរក្បាលហុងស្ទឹងពោធិ៍សាត់ប្រវែង៩៤ម ទទឹង៤៦,៣៥ម កម្ពស់១,៣ម ជំហានទី២(អនុវត្តបាន១០០%)។

-ដាំបង្គោលភ្លើងសាធារណៈចំនួន១៥១ដើម និងតបណ្តាញប្រវែង៥ ៨៨០ម៉ែត្រ សងខាងផ្លូវក្នុងក្រុងពោធិ៍សាត់(កំពុងអនុវត្ត)។

-ស្ថាបនាទំនប់បង្រៀរក្បាលហុងស្ទឹងពោធិ៍សាត់ប្រវែង៩៤ម ទទឹង៤៦,៣៥ម កម្ពស់១,៣ម ជំហានបញ្ចប់(កំពុងអនុវត្ត)។

- ក្នុងខេត្តមានប្រព័ន្ធជារាសាស្ត្រតូចធំចំនួន២៩ប្រព័ន្ធ សំណង់បង្ហៀរចំនួន៥កន្លែង ប្រឡាយមេ និងប្រឡាយរងចំនួន១២៦កន្លែង ដែលអាចផ្គត់ផ្គង់សម្រាប់ស្រោចស្រពដំណាំទាំងរដូវប្រាំង និងរដូវវស្សាលើផ្ទៃដីចំនួន៨០ ០៦០ហ.ត។

-បណ្តាញផ្លូវដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់ មានចំនួន៣៨ខ្សែប្រវែងសរុប៨៩៣,១៦គ.ម. រួមមានផ្លូវជាតិ១លេខចំនួន១ខ្សែប្រវែង៨៦,៣០គ.ម. ផ្លូវជាតិ២លេខចំនួន៥ខ្សែប្រវែង៣៣០,៧៨គ.ម. ផ្លូវខេត្តចំនួន៣២ប្រវែង៤៧៦,០៨គ.ម. និងស្ពានសរុបចំនួន១៩០ប្រវែង ៤ ៧៤៦ម លូគ្រប់ប្រភេទប្រវែង៩ ២៧៨ម។ ផ្លូវក្នុងក្រុងពោធិ៍សាត់មានចំនួន៧៦ខ្សែប្រវែង៥៧,៥៤គ.ម.(ក្រាលកៅស៊ូប្រវែង៣៥,៣៧គ.ម.)និងលូគ្រប់ប្រភេទចំនួន២ ៣៩៥ម។

- នៅមានតំបន់ទេសចរណ៍ សណ្ឋាគារ៦កន្លែង ផ្ទះសំណាក់៣៨កន្លែង ផ្ទះមានបន្ទប់ជួល៨កន្លែង ភោជនីយដ្ឋាន២៣កន្លែង អាហារដ្ឋាន/ហាងលក់គុយទាវកាហ្វេ៦៥កន្លែង ការ៉ាអូខេ២១កន្លែង ក្លឹបកម្សាន្ត១កន្លែង បៀកាជិន១កន្លែង ម៉ាស្សា២០កន្លែង ទូកដឹកភ្ញៀវទេសចរ២៥គ្រឿង រមណីយដ្ឋាននិងតំបន់ទេសចរណ៍៣៤កន្លែង

ក្នុងនោះមានរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន២កន្លែង រមណីយដ្ឋានធម្មជាតិកែច្នៃ១កន្លែង រមណីយដ្ឋានកសិទេសចរណ៍២កន្លែង និងរមណីយដ្ឋានធម្មជាតិ២៩កន្លែង។ មូលដ្ឋានអាជីវកម្មមកបន្តអាជ្ញាបណ្ណ៩៤កន្លែង និងបើកថ្មី២៩កន្លែង។ ចំពោះរមណីយដ្ឋាននិងតំបន់ទេសចរណ៍ទាំង៣៤កន្លែង យើងមានរមណីយដ្ឋានមួយចំនួនដែលបានរៀបចំរួចនិងមានដំណើរការ(រមណីយដ្ឋានទឹកធ្លាក់ច្រកល្មៀង សហគមន៍ភូមិអណ្តែតទឹកកំពង់លួង បូជនីយដ្ឋានប្រវត្តិសាស្ត្រលោកឧកញ៉ាឃ្លាំងមឿង រមណីយដ្ឋានល្បាក់កំពេញ សហគមន៍ទេសចរណ៍រាំងទិលគ្រួសារខ្ញុំ)។ ដោយឡែករមណីយដ្ឋាននិងតំបន់ទេសចរណ៍មួយចំនួនទៀត បាននិងកំពុងរៀបចំឱ្យមានដំណើរការដូចជាសហគមន៍រាំងខ្ទាវ សហគមន៍ទំព័រ អេកូទេសចរណ៍តំបន់អូសោម និងរមណីយដ្ឋានអូរដា។

**១៣-ខេត្តតាកែវ**

- ផ្លូវជាតិមាន៦ខ្សែ(ផ្លូវជាតិលេខ២លេខ៣ លេខ២២ លេខ២៣ លេខ៣១ និងផ្លូវជាតិលេខ៤១) ដែលមានប្រវែងសរុប១៦៥,៩២០ គ.ម.

- ផ្លូវខេត្តមានចំនួន២៥ខ្សែដែលមានប្រវែងសរុប៣៩៦,៩៩០គ.ម. ក្នុងនោះប្រភេទកម្រាលកៅស៊ូ២៤៣,៨៩១គ.ម. ប្រភេទកម្រាលផ្លូវបេតុង១៧,៨០០គ.ម. និងប្រភេទកម្រាលដីលាយថ្ម៣៥,២៩៩ គ.ម.

- ផ្លូវក្នុងក្រុងមានចំនួន៤៧ខ្សែ(ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង) ដែលមានប្រវែងសរុប៦១,៦៣៨គ.ម.

- មានរមណីយដ្ឋានទេសចរណ៍៩កន្លែង ក្នុងនោះ រមណីយដ្ឋានទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រនិងធម្មជាតិមាន៥កន្លែង រួមមានភ្នំដា ភ្នំបាយ៉ង់កោរ ភ្នំជីសូរ្យ ភ្នំតាម៉ៅ និងទន្លេបាទី។ រមណីយដ្ឋានទេសចរណ៍វប្បធម៌និងធម្មជាតិមាន២កន្លែង រួមមានភ្នំខ្លែងនិងភ្នំជីតាពេជ្រ។ រមណីយដ្ឋានទេសចរណ៍ធម្មជាតិមាន១កន្លែង គឺជ្រោះផ្អោកនិងរមណីយដ្ឋានទេសចរណ៍ធម្មជាតិកែច្នៃមាន១កន្លែង គឺកំពូលពេជ្រ។ ប្រាសាទបុរាណ២កន្លែង ដែលមិនទាន់ធ្វើការស្តារ និងអភិវឌ្ឍន៍ឲ្យក្លាយជារមណីយដ្ឋានទេសចរណ៍នៅឡើយ គឺប្រាសាទនាងខ្មៅ និងប្រាសាទជប់ពល។ សារមន្ទីរ២កន្លែង គឺសារមន្ទីរខេត្ត និងសារមន្ទីរអង្គរបុរីនិងមណ្ឌលឧក្រិដ្ឋកម្ម១កន្លែង (ក្រាំងតាចាន់) ជាមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ជាមួយនោះដែលរមណីយដ្ឋានដែលល្បីនិងមានភាពទាក់ទាញភ្ញៀវទេសចរ មានចំនួន៦កន្លែង រួមមានរមណីយដ្ឋានទេសចរណ៍ភ្នំជីសូរ្យ ភ្នំតាម៉ៅ ទន្លេបាទី កំពូលពេជ្រ ភ្នំដា និងជ្រោះផ្អោក។

**១៤- ខេត្តមណ្ឌលគិរី**

- ប្រវែងផ្លូវក្នុងខេត្តសរុប៨៥១,៣៧គ.ម.ក្នុងនោះផ្លូវក្នុងខេត្តមានចំនួន៨ខ្សែប្រវែង៥៣០,៥ គ.ម. ផ្លូវក្នុងក្រុងសែនមនោរម្យមានចំនួន៥៩ខ្សែ ប្រវែង ៦៥,៨៧ គ.ម. និងផ្លូវលំសរុប៣២ខ្សែ ប្រវែង២៥៥ គ.ម.

- មានស្ថានីយ៍វារីអគ្គិសនីខ្នាតតូចចំនួន២កន្លែង គឺស្ថានីយ៍ អូររមីស និងស្ថានីយ៍អូរម្លែង សម្រាប់ផ្គត់ផ្គង់ថាមពលដល់ប្រជាពលរដ្ឋក្នុងក្រុងសែនមនោរម្យមានថាមពលផ្គត់ផ្គង់ចំនួន៣៧0KWH និងបានតភ្ជាប់បណ្តាញពីរខ្សែពីប្រទេសវៀតណាម

- មានគោលដៅទេសចរណ៍ចំនួន៣៦កន្លែង ក្នុងនោះមានតំបន់រមណីយដ្ឋានទឹកធ្លាក់ តំបន់រមណីយដ្ឋានវប្បធម៌ជនជាតិដើមភាគតិច តំបន់ភ្នំ តំបន់ទេសភាព ភូមិជនជាតិ សមុទ្រឈើ សហគមន៍ទេសចរណ៍ដែនជម្រកសត្វព្រៃ និងមានអាកាសធាតុត្រជាក់។ ខេត្តមានក្រុមហ៊ុនវិនិយោគលើវិស័យទេសចរណ៍ដោយឯកជនសរុបមានចំនួន១១ទីតាំង ក្នុងនោះមាន ទឹកជ្រោះប៊ូស្រា អូរផ្លាយ រមនា១ រមនា២ ជ្រៃយស់ ចម្ការកាហ្វេ អូររមីស ជ្រៃធំ ដំណាក់ស្តេច និងក្បាលព្រះ។

**១៥- ខេត្តរតនគិរី**

- ជួសជុល ស្ថាបនា និងពង្រីកផ្លូវប្រភេទDBST ចំនួន១៥ខ្សែ ប្រវែង៧ ០៣៧ម៉ែត្រ ជួសជុលនិងស្ថាបនាផ្លូវក្រាលក្រួសក្រហម៤ខ្សែប្រវែង២០ ៣៣៩ម៉ែត្រ សាងសង់ស្ពាន រៀបការ៉ូឡាចិញ្ចើមផ្លូវ កប់លូរំដោះទឹកភ្លៀង សួនច្បារសាធារណៈ

- សម្រាប់អគ្គិសនីខេត្តមាន៣ប្រភព ក្នុងនោះរួមមានផលិតដោយវារីអគ្គិសនីផ្ទាល់ខ្លួនមានអានុភាព១.២៦Mw (វារីអគ្គិសនីអូរជុំ)ទិញថាមពលពីប្រទេសវៀតណាមមានអានុភាព១២Mw និងប្រភពវារីអគ្គិសនីសេសានក្រោម២មានអានុភាព១២Mw។ ប្រជាពលរដ្ឋដែលទទួលបានអគ្គិសនីប្រើប្រាស់សរុប១៩ ៥៩២ខ្នងផ្ទះ។ សម្រាប់ការងារទឹកស្អាតនៅក្នុងខេត្តមានក្រុមហ៊ុនវិនិយោគនិងសេវាករឯកជនចំនួន៤ទីតាំងក្នុងក្រុង ស្រុកចំនួន៣ដែលមានអានុភាពផលិតទឹកស្អាត១ ២៩២ ១៩០ម៣ ក្នុងមួយឆ្នាំ សមត្ថភាពផលិតជាមធ្យម៣ ៥៤០ម៣/ថ្ងៃ ហើយបានភ្ជាប់បណ្តាញទឹកស្អាតសរុបចំនួន៦ ២០៥ខ្នងផ្ទះ។ បច្ចុប្បន្នខេត្តបានកសាងប្លង់គោលប្រើប្រាស់ដីបាន១ក្រុង

- មានរមណីយដ្ឋានទេសចរណ៍ក្នុងខេត្តសរុបមានចំនួន ១៤កន្លែង ក្នុងនោះរមណីយដ្ឋានធម្មជាតិចំនួន១២កន្លែង និងរមណីយដ្ឋានវប្បធម៌ធម្មជាតិចំនួន២កន្លែង រមណីយដ្ឋានទេសចរណ៍ធម្មជាតិចំនួន៨កន្លែងគ្រប់គ្រងដោយសហគមន៍ជនជាតិដើមភាគតិច។

**១៦- ខេត្តស្ទឹងត្រែង**

- ពង្រីកការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ក្នុងទីប្រជុំជនក្រុង និងមូលដ្ឋានស្រុកដែលបច្ចុប្បន្នមានអង្គភាពរដ្ឋាករទឹកក្នុងក្រុងស្ទឹងត្រែង និងនៅតាមបណ្តាឃុំ សង្កាត់មួយចំនួនមានបណ្តាញទឹកសហគមន៍បច្ចុប្បន្នមាន៩បណ្តាញទឹកសហគមន៍

- រៀបចំការងារថែទាំបរិស្ថានអនាម័យក្នុងក្រុង ដោយបានបង្កើតទីលានចាក់សំរាម១កន្លែង និងរៀបចំឱ្យមានយន្តការសេវាប្រមូលសំរាមជាប្រចាំ

- ទំនប់វារីអគ្គិសនីសេសានក្រោម២ មានអនុភាព៤០០មេហ្គាវ៉ាត់ បច្ចុប្បន្នកំពុងប្រតិបត្តិការ

- ស្ពានឆ្លងកាត់ទន្លេធំៗ៤កន្លែង មានស្ពានឆ្លងទន្លេសេកុងប្រវែង១ ០៥៧ម៉ែត្រ ស្ពានឆ្លងទន្លេមេគង្គប្រវែង១ ៧៣១ម៉ែត្រ ស្ពានឆ្លងទន្លេកុងសែនជ័យប្រវែង២៦០ម៉ែត្រ និងស្ពានកោះទន្សាយសែនជ័យឆ្លងកាត់ទន្លេកុងផ្នែកខាងលើប្រវែង២៤០ម៉ែត្រ

-រៀបចំការចាក់ជម្រាលច្រាំងទន្លេ ដើម្បីការពារច្រាំងនិងលើកកម្ពស់សោភណភាពក្នុងទីប្រជុំជនក្រុងសម្រេចបាន២៧០ម៉ែត្រ

- រៀបចំស្ថាបនារង្វង់មូលក្នុងទីប្រជុំជនក្រុងស្ទឹងត្រែង២កន្លែងនិងសួនច្បារ៧កន្លែង

- រៀបចំបង្កើតរមណីយដ្ឋានអេកូទេសចរណ៍ចំនួន២០កន្លែង តាមតំបន់មូលដ្ឋានដងទន្លេមេគង្គ សេកុង សេសាន ស្រែពក និងនៅតាមសហគមន៍ជនជាតិដើមភាគតិច។

**១៧- ខេត្តក្រចេះ**

- មានហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តសរុបប្រវែង៩៨៨,១០គីឡូម៉ែត្រ ក្នុងនោះផ្លូវក្រាលកៅស៊ូប្រវែង៣៨៣,៧៦គីឡូម៉ែត្រ ក្រួសក្រហមប្រវែង៥៩១,១០គីឡូម៉ែត្រ ផ្លូវក្នុងក្រុងក្រចេះ(កៅស៊ូបេតុង)ប្រវែង៨,៥២គីឡូម៉ែត្រ ស្ពានចំនួន១០៩កន្លែងស្មើនឹង៤ ២៥១ម៉ែត្រ លូ៣៧៤កន្លែងស្មើនឹង១៧ ២៦៨ម៉ែត្រនិងដាឡូ៧៨កន្លែងស្មើនឹង១ ០៩៩ម៉ែត្រ

- កំពុងសាងសង់ផ្លូវក្រាលកៅស៊ូប្រវែង២២,៨៧គីឡូម៉ែត្រ ផ្លូវក្រាលបេតុងប្រវែង៣១៧ម៉ែត្រ។ ស្ពាបនាស្ពានបេតុង៦កន្លែង ស្ពាន៥កន្លែងលើកំណាត់ផ្លូវជាតិលេខ៧៣ប្រវែង៤៦០ម៉ែត្រជាជំនួយឥតសំណង របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងស្ពានអណ្តែងដូនលើកំណាត់ផ្លូវខេត្តលេខ៣៧៧ ជាអំណោយ របស់សាធារណរដ្ឋសង្គមនិយមវៀតណាមដែលសម្រេចបាន៩០%

- មានបណ្តាញអគ្គិសនីគ្របដណ្តប់លើភូមិ២១៤ភូមិ ស្មើនឹង៨២,៩៥% នៃភូមិសរុប២៥៨ភូមិ ទូទាំងខេត្ត

- មានអាជីវកម្មទឹកស្អាតឯកជន១៦មូលដ្ឋាន ដែលគ្របដណ្តប់លើក្រុង១ ស្រុក៥ បណ្តាញចែក ចាយប្រវែង៤៤១គីឡូម៉ែត្រ

- មានតំបន់រមណីយដ្ឋានទេសចរណ៍ទាំង១៩កន្លែង ក្នុងនោះរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ៥ កន្លែង រមណីយដ្ឋានធម្មជាតិ១៣កន្លែង និងរមណីយដ្ឋានវប្បធម៌ធម្មជាតិ១កន្លែង។

### ១៨- ខេត្តព្រះវិហារ

- ផ្លូវថ្នល់មានប្រវែងសរុប៧៦៤.៥៥គីឡូម៉ែត្រ ដែលស្ថិតនៅក្នុងភូមិសាស្ត្រខេត្ត មានដូចជាផ្លូវ ក្រាលកៅស៊ូDBSTប្រវែង៤៨៥.៩១គីឡូម៉ែត្រ ក្នុងនោះ ផ្លូវជាតិក្រាលកៅស៊ូDBSTប្រវែងសរុប២៣២,៥៣គីឡូ ម៉ែត្រ។ ផ្លូវខេត្តក្រាលកៅស៊ូDBSTប្រវែងសរុប១៦២,៣៨គីឡូម៉ែត្រ

- សាងសង់ស្ពានបេតុងសរសៃដែកចំនួន២កន្លែង ស្ថិតក្នុងស្រុកឆែបដែលមានប្រវែង៦៣ម៉ែត្រ

- ជួសជុលពង្រីកផ្លូវចំនួន៣ខ្សែ ដោយក្រាលកៅស៊ូDBST ប្រវែង៥,៩៩៦ម៉ែត្រ ការងារជួសជុល ផ្លូវចាក់បេតុងចំនួន២ខ្សែ ប្រវែង៧៦០ម៉ែត្រ ស្ថិតក្នុងក្រុងព្រះវិហារ

- ជួសជុលសួនច្បារកណ្តាលទ្រូងផ្លូវកោះកែរប្រវែង១ ៥៦៤ម៉ែត្រនិងរបាំងទ្រូងផ្លូវប្រវែងសរុប ៣ ៩២២ម៉ែត្រ និងដាំបង្គោលភ្លើងបំភ្លឺផ្លូវចំនួន២៤០ដើម តាមបណ្តោយផ្លូវកោះកែរ ស្ថិតនៅក្នុងក្រុងព្រះវិហារ។

- ចែកចាយអគ្គិសនីសរុប១៥មូលដ្ឋាន សេវាករលក់ចែកចាយប្រភពអគ្គិសនីពីប្រទេសឡាវ មានចំនួន៧.៥មេហ្គាវ៉ាត់

- មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍សរុបក្នុងខេត្តព្រះវិហារសម្រាប់ឆ្នាំ២០១៩ រួមមាន សណ្ឋាគារចំនួន៤ទីតាំង ម៉ូតែល២ទីតាំង ផ្ទះសំណាក់៣៩ទីតាំងស្មើនឹង៦៩៦បន្ទប់ ភោជនីយដ្ឋាន អាហារដ្ឋាន សរុបចំនួន៥០ទីតាំង។

### ១៩- ខេត្តឧត្តរមានជ័យ

- រៀបចំកែលម្អសោភ័ណភាពក្នុងទីប្រជុំជនខេត្ត ក្រុង(កែសម្រួលនិងស្ថានាបន្ថែមសួនច្បារ ដាក់ បង្គោលភ្លើងបំភ្លឺផ្លូវ និងតុតែមលម្អពេលរាត្រី។ល។) ស្តារប្រព័ន្ធលូ និងស្តារបណ្តាញស្ពាន ផ្លូវនានា ដោយប្រែក្លាយ ពីផ្លូវក្រួសក្រហមទៅជាផ្លូវបេតុង និងផ្លូវក្រាលកៅស៊ូជាបន្តបន្ទាប់

- មានទេសចរណ៍ធម្មជាតិ៧កន្លែង ទេសចរណ៍វប្បធម៌មាន១៤៤កន្លែង ក្នុងនោះប្រាសាទតាមាន់ ប្រាសាទតាក្របី ស្ពានបុរាណ ទួលបុរាណជាដើម និងតំបន់ប្រវត្តិសាស្ត្រចំនួន១៤កន្លែង។

## ២០- ខេត្តត្បូងឃ្មុំ

- ដាក់ភ្លើងបំភ្លឺសាធារណៈក្នុងខេត្ត២០១៩ ក្នុងតំបន់រដ្ឋបាលខេត្ត១ ៥១០ បង្គោលនិងតាមបណ្តាក្រុងស្រុកចំនួន៣៣៩បង្គោល

- មានអគ្គិសនីចំនួន៨៤២/៨៧៣ភូមិ ស្មើនឹង៩៦%, និងមានបណ្តាញអគ្គិសនីគ្របដណ្តប់លើភូមិ៨៤២ភូមិ ស្មើនឹង៩៦%

- មានផ្លូវជាតិធំៗចំនួន៥ខ្សែ គឺផ្លូវជាតិលេខ៧ លេខ៨ លេខ១១ លេខ៧២ លេខ៧៣ និងផ្លូវសំខាន់ៗដែលតភ្ជាប់ពីទីរួមខេត្តទៅក្រុង ស្រុក ឃុំសង្កាត់ និងភូមិសរុបប្រវែងប្រមាណ៧៥១គ.ម. ក្នុងនោះផ្លូវចាក់កៅស៊ូមានប្រវែងប្រមាណ៥២៦គ.ម. ផ្លូវបេតុងមានប្រវែង៥០គ.ម. ផ្លូវក្រាលគ្រួសក្រហមមានប្រវែងប្រមាណ១៧៥គ.ម. មានស្ពានឆ្លងកាត់ទន្លេមេគង្គចំនួន២ខ្សែ គឺស្ពានមិត្តភាពកម្ពុជាជប៉ុន( គីហ្សូណា )និងស្ពានស្ទឹងត្រង់-ក្រូចឆ្មារ( ដែលនឹងសង់រួចនៅឆ្នាំ២០២១ )

- មានរមណីយដ្ឋានព្រះធាតុបាស្រី រមណីយដ្ឋានហ្លួងព្រះស្តេចកន ចម្ការកៅស៊ូ រមណីយដ្ឋានទឹកធ្លាក់ហោង រមណីយដ្ឋានភូមិអភិវឌ្ឍអន្លង់ជ្រៃ រមណីយដ្ឋានអូរក្តុង រមណីយដ្ឋានតាសែដូងក្រអូប រមណីយដ្ឋានចំការឈូករ័ត្ន និងសារមន្ទីរមេមត់

- មានសណ្ឋាគារចំនួន៦កន្លែង ស្មើនឹង២៤១បន្ទប់ ផ្ទះសំណាក់ចំនួន៥៤កន្លែង ស្មើនឹង៧៩២បន្ទប់ ភោជនីយដ្ឋាន និងអាហារដ្ឋាន៣៣កន្លែង។

## ២១- ខេត្តបន្ទាយមានជ័យ

- បានបំពាក់បង្គោលភ្លើងសាធារណៈចំនួន៤០០ដើម និងជួសជុលបណ្តាញបង្គោលភ្លើង២ ៤០០ម. ផ្លូវបេតុងមានប្រវែង១៩ ០៨០ម. ផ្លូវកៅស៊ូបេទីមប្រវែង១ ២៣៨ម. ផ្លូវកៅស៊ូDBSTប្រវែង៧ ៣០៦ម. លូរំដោះទឹកប្រវែង៣ ៨៨៨ម. ស្លាបនាភ្លើងបញ្ជាចរាចរចំនួន៥កន្លែង ស្ថាបនាសួនសាធារណៈទំហំ៧៩ ៤១០ម$^២$ និងសួនមុខសាលាខេត្ត ៣៣.៦២៧ម$^២$

- មានបណ្តាញផ្លូវថ្នល់ ផ្លូវជាតិ ផ្លូវខេត្តសរុប២១ខ្សែ ដែលមានប្រវែងសរុប៧០០,២៩០គ.ម. ប្រភេទក្រាលកៅស៊ូA/Cប្រវែង១០១,០៨០ ក្រាលកៅស៊ូប្រភេទDBSTប្រវែង៣៨០,១១គ.ម.ក្រាលបេតុងប្រវែង១,៨៨០គ.ម.

- ផ្គត់ផ្គង់អគ្គិសនីបានប្រើប្រាស់ថាមពលពី២ប្រភព គឺប្រភពក្នុងស្រុក( បណ្តាញជាតិ )និងពីប្រទេសថៃ ដែលមានអាជ្ញាបណ្ណអគ្គិសនីមាន២៣អាជ្ញាបណ្ណក្នុង៦៥៨ភូមិមាន៦៤៥ភូមិស្មើនឹង៩៨%មានអគ្គិ-សនីប្រើប្រាស់និង១៣ភូមិទៀតបាននិងកំពុងដាំបង្គោលនិងបំពាក់បណ្តាញភ្លើង

- រៀបចំផែនទីហេដ្ឋារចនាសម្ព័ន្ធ ផែនទីរដ្ឋបាល និងផែនទីប្រើប្រាស់ដីធ្លី៨ក្រុង ស្រុក បាន១០០% ដោយឡែកក្រុងប៉ោយប៉ែតបានរៀបចំប្លង់គោលបាន១០០%

- តំបន់សេដ្ឋកិច្ចពិសេសអូរនាង មានរោងចក្រ៥ កាត់ដេរ ផលិតប្រអប់ផ្លាស្ទិក និងបង្គុំសម្ភារៈបរិក្ខាអេឡិចត្រូនិក ប្រអប់គ្រឿងអលង្ការ

- តំបន់សេដ្ឋកិច្ចពិសេសសានកូ មានរោងចក្រ១២ ផលិតហាតឌីស គ្រឿងបំពាក់រថយន្ត ផលិតក្បាលចង្កឹះលេខរថយន្ត ស្បែកអំប្រីយ៉ាម៉ូតូ បង្គុំខ្សែភ្លើង បំពង់ដែក គ្រឿងបន្លាស់អគ្គិសនី

- តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភីមានរោងចក្រ២ ផលិតបង្គុំខ្សែភ្លើង សេវាដួលឃ្លាំង និងរោងចក្រ

- សួនឧស្សាហកម្មសិរីសោភ័ណមានរោងចក្រ៣រោងចក្រកាត់ដេរសម្លៀកបំពាក់

-រោងចក្រដែលស្ថិតនៅក្រៅពីតំបន់សេដ្ឋកិច្ចពិសេសនិងសួនឧស្សាហកម្មមានរោងចក្រ៥

- ឧស្សាហកម្មទេសចរណ៍មាន២៦៩កន្លែង សណ្ឋាគារ២៥កន្លែង ផ្ទះសំណាក់៨៣កន្លែង ផ្ទះស្នាក់៧កន្លែង ភោជនីយដ្ឋាន៣៤កន្លែង អាហារដ្ឋាន៦៥កន្លែង ខារ៉ាអូខេ២៤កន្លែង ក្លិបកម្សាន្ត៣កន្លែង ម៉ាស្សានិងស្ប៉ា២៨កន្លែង។ មានរមណីយដ្ឋានប្រវត្តិសាស្ត្រ២កន្លែង រមណីយដ្ឋានធម្មជាតិ៥កន្លែង និងរមណីយដ្ឋានកែច្នៃ៤កន្លែង។ រដ្ឋបាលខេត្តបានធ្វើការប្រឡងប្រណាំងទីក្រុងស្អាត បរិស្ថានស្អាត បដិសណ្ឋារកិច្ចល្អ និងធ្វើការកែលម្អសេវាផ្នែកសណ្ឋាគារ ផ្នែកបដិសណ្ឋារកិច្ច ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព បារាយណ៍មេបុណ្យក្រុងប៉ោយប៉ែត និងទីរួមខេត្តបន្ទាយមានជ័យឱ្យមានសោភណភាពសម្រាប់ភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់។

**២២- ខេត្តកំពង់ចាម**

- មានផ្លូវជាតិឆ្លងកាត់ចំនួន៣ខ្សែ សរុបប្រវែង១១៦,៩៧គ.ម. ក្នុងនោះ ផ្លូវជាតិលេខ៦ ចាប់ពីចំណុចព្រំប្រទល់ស្រុកមុខកំពូល ខេត្តកណ្តាល ដល់ព្រំប្រទល់ស្រុកតាំងគោក ខេត្តកំពង់ធំប្រវែង៥៦,០៨គ.ម. ផ្លូវជាតិលេខ៧ ចាប់ពីរង្វង់មូលស្ពន់ស្រុកជើងព្រៃដល់គល់ស្ពានគីហ្សូណាប្រវែង៤៩,០០គ.ម. និងផ្លូវជាតិលេខ៦១ ចាប់ពីព្រំប្រទល់ស្រុកពញាឮ ខេត្តកណ្តាលដល់ថ្នល់កែងស្រុកបាធាយប្រវែង១១,៨៩គ.ម.

- មានអនុស្ថានីយអគ្គិសនី១កន្លែងនៅឃុំក្រឡា ស្រុកកំពង់សៀម១០០MWដែលមានក្រុមហ៊ុនផ្គត់ផ្គង់និងសេវាករចែកចាយអគ្គិសនីមានចំនួន៣៧ក្រុមហ៊ុន ដែលមានដែនអាជ្ញាបណ្ណអគ្គិសនីគ្របដណ្តប់លើភូមិចំនួន៩១៦ភូមិលើ៩១៦ភូមិស្មើនឹង១០០%។ ក្នុងឆ្នាំ២០១៩ បានភ្ជាប់ចរន្តអគ្គិសនីចំនួន១៧២ ៣០៣ខ្នងផ្ទះ ដែលគ្របដណ្តប់ទូទាំង១០ក្រុង ស្រុក នៃភូមិចំនួន៨៨៥ភូមិលើ៩១៦ភូមិស្មើនឹង៩៦,៦២%

- រមណីយដ្ឋាននៅក្នុងខេត្តកំពង់ចាម មានចំនួន១២កន្លែង។ ដោយឡែក រមណីយដ្ឋានមានសក្តានុពលទាក់ទាញទេសចរសំខាន់ៗមានចំនួន៦កន្លែង រួមមានភ្នំប្រុសភ្នំស្រី នគរបាជ័យ ភ្នំហាន់ជ័យ ភ្នំជើងព្រៃ ទឹកធា និងរមណីយដ្ឋានឆ្នេរខ្សាច់កោះប៉ែន។ ជាមួយនេះ អាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងខេត្តកំពង់ចាម សរុប៧៥៩កន្លែង។ រីឯសណ្ឋាគារ ផ្ទះសំណាក់ បង់ហ្គាឡូបែមប៊ូវីសត មានចំនួន១២២កន្លែង ស្មើនឹង២ ១៨៧បន្ទប់ ក្នុងនោះ សណ្ឋាគារ១៨កន្លែង មាន៩២២បន្ទប់ ផ្ទះសំណាក់១០៤កន្លែងមាន១ ១៨២បន្ទប់ បង់ហ្គាឡូបែមប៊ូវីសត ១កន្លែងស្មើ១៣បន្ទប់ ភោជនីយដ្ឋានចំនួន១២កន្លែងនិងអាហារដ្ឋានចំនួន១០៥កន្លែង។

**២៣- ខេត្តព្រៃវែង**

- មានផ្លូវជាតិ៥ខ្សែ ប្រវែង១៩៧,៥៥គ.ម. ផ្លូវខេត្តចំនួន៣០ខ្សែ ប្រវែង៥៧៣,៩២៥គ.ម. និងផ្លូវជនបទសរុបចំនួន១ ០៩៧ខ្សែមានប្រវែង៣ ៥៧០គ.ម.។ ឆ្នាំ២០១៩ បានស្ថាបនាផ្លូវកៅស៊ូDBST ចំនួន២ខ្សែ ប្រវែង៧,៤០គ.ម.។ ជួសជុលផ្លូវក្រាលកៅស៊ូ(DBST)ចំនួន៥ ខ្សែប្រវែង១២,០៣គ.ម.។ ជួលជុលផ្លូវក្រាលក្រួសក្រហមចំនួន១៣ខ្សែ ប្រវែង៧៣,០៦គ.ម.។ ជួសជុលផ្លូវបន្ទាន់ចំនួន៦ខ្សែ ប្រវែង២២,៩៨០គ.ម.

- ផ្លូវគមនាគមន៍ពីទីរួមខេត្តទៅបណ្តាក្រុង/ស្រុក ជាផ្លូវក្រាលកៅស៊ូ និងផ្លូវពីក្រុង/ស្រុកទៅបណ្តាឃុំ/សង្កាត់ ជាទូទៅជាផ្លូវក្រាលកៅស៊ូ ផ្លូវបេតុង ផ្លូវក្រាលក្រួសក្រហម និងផ្លូវក្រាលខ្សាច់ភ្នំ។ ដោយឡែកការសាងសង់អណ្តូងទឹក និងអនាម័យជនបទមានអណ្តូង១៩៥ ៩៣០អណ្តូងស្មើនឹង៨៧% និងបានសាងសង់បង្គន់អនាម័យចំនួន២១២ ១៨៩បង្គន់ស្មើនឹង៩៣,០២% ដែលជាការសម្រេចគោលដៅខ្ពស់ក្នុងការអនុវត្តកម្មវិធីជាតិ

- មានថាមពលអគ្គិសនីប្រើប្រាស់២៤ម៉ោងលើ២៤ម៉ោង គ្របដណ្តប់គ្រប់ក្រុង/ស្រុកនិងប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ចំនួន១៨១ ២០១ខ្នងផ្ទះ ស្មើនឹង៧៥%នៃខ្នងផ្ទះសរុប

- មានបណ្តាញទឹកស្អាតគ្របដណ្តប់តំបន់ទីប្រជុំជនទាំង១៣ក្រុង/ស្រុក ស្មើនឹង៥៤ឃុំ/សង្កាត់(៤៣៤ភូមិ) ដែលមានប្រជាពលរដ្ឋប្រើប្រាស់សរុប២៨ ៧៦៦គ្រួសារ

- មានទីតាំងទេសចរណ៍ដូចជា រមណីយដ្ឋានប្រវត្តិសាស្ត្រនគរភ្នំ ស្ថិតក្នុងស្រុកបាភ្នំរមណីយដ្ឋានធម្មជាតិចំនួន៣កន្លែង គឺរមណីយដ្ឋានទួលព័ន្ធតាឡីបឹងស្នេហ៍"សត្វស្លាប"(ស្រុកបាភ្នំ) រមណីយដ្ឋានស្ទឹងចារ(ស្រុកកំចាយមារ) និងរមណីយដ្ឋានដីដុះ(ស្រុកពាមជរ) រមណីយដ្ឋានវប្បធម៌ចំនួន៣កន្លែង គឺរមណីយដ្ឋានទួលបារាយអណ្តែត រមណីយដ្ឋានទួលអស់លោកប្រជាតុ ក្រុងព្រៃវែង និងរមណីយដ្ឋានប្រាសាទព្រៃដើមស្រុក(ស្រុកស៊ីធរកណ្តាល)

-សណ្ឋាគារ ផ្ទះសំណាក់ទូទាំងខេត្តសរុប៨៥កន្លែង ស្មើនឹង៨៥៧បន្ទប់ ភោជនីយដ្ឋាន និងអាហារដ្ឋានមានចំនួន៥៥កន្លែង។

## ២៤- ខេត្តស្វាយរៀង

- មានតំបន់សេដ្ឋកិច្ចពិសេសចំនួន១១កន្លែង កំពុងដំណើរការ៨កន្លែងសរុបទូទាំងខេត្តមានក្រុមហ៊ុន រោងចក្រ សហគ្រាស ក្រុមហ៊ុនឯកជន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបចំនួន២១៦កន្លែង ក្នុងនោះរោងចក្រសហគ្រាសចំនួន១១៣កន្លែង ក្រុមហ៊ុនកាស៊ីណូនិងសណ្ឋាគារ២៣កន្លែង ព្រមទាំងក្រុមហ៊ុនឯកជនធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨០កន្លែង

- មានផ្លូវថ្នល់សរុប៥០ខ្សែ ប្រវែងសរុប៧៧១គ.ម. ក្នុងនោះផ្លូវអ៊ុតកៅស៊ូ AC/DBST ប្រវែង៣០៣គ.ម. ផ្លូវម៉ាកាដាមប្រវែង៣ ៥០០ម៉ែត្រ ផ្លូវបេតុងប្រវែង៥ ១៥០ម៉ែត្រ និងផ្លូវក្រាលក្រួសក្រហមប្រវែង៤៦០គ.ម.។ ផ្លូវជាតិមាន៣ខ្សែ គឺផ្លូវជាតិលេខ១ ប្រវែង៦៥គ.ម. ផ្លូវជាតិលេខ១៣ និងលេខ១៨ ប្រវែង៨៤គ.ម.។ ផ្លូវខេត្តមាន៤៧ខ្សែ ប្រវែងសរុប៦៤៤គ.ម.។ ស្ពានមាន៤១កន្លែង ប្រវែងសរុប១ ៣០៨ម៉ែត្រ

-មានប្រភពអគ្គិសនីសំខាន់ៗ៣ គឺពីរាជធានីភ្នំពេញ ផលិតផ្ទាល់ខ្លួននិងពីប្រទេសវៀតណាមដែលមានប្រជាពលរដ្ឋប្រើប្រាស់ប្រមាណ៨០ ៩៩៥គ្រួសារ ស្មើនឹង៥៤%

- មានតំបន់ទេសចរណ៍មណ្ឌលកម្សាន្ត៣៥កន្លែង ផ្ទះសំណាក់៧១កន្លែង សណ្ឋាគារ២៦កន្លែង ភោជនីយដ្ឋាន៧៨កន្លែង ផ្សាររាត្រី១កន្លែង និងមជ្ឈមណ្ឌលកម្សាន្តមនុស្សពេញវ័យ៣៥កន្លែង។

## ២៥- ខេត្តកំពង់ឆ្នាំង

- មានផ្លូវសរុបប្រវែង៣ ៤៦៩,៥៧គ.ម. ក្នុងនោះផ្លូវក្រាលកៅស៊ូប្រវែង៥០០,៤២គ.ម. ផ្លូវក្រាលគ្រួសក្រហមប្រវែង២ ០៣៩,១៣គ.ម. ផ្លូវដីសប្រវែង៩១៨,២៤គ.ម. ផ្លូវបេតុង១១,៧៩គ.ម. ស្ពាន៧៥កន្លែងប្រវែង១ ៩៧១ម និងដាឡូ១០០កន្លែង ប្រវែង៦៧៦ម លូគ្រប់ប្រភេទប្រវែង៣៣ ១៨៩ម

- មានតំបន់សក្តានុពលទេសចរណ៍ចំនួន២៣កន្លែង ក្នុងនោះតំបន់ទេសចរណ៍១៣កន្លែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ១០កន្លែង និងសួនច្បារកំសាន្ត៥

- សម្បត្តិវប្បធម៌ជាច្រើនដូចជា ប្រាង្គប្រាសាទបុរាណ អាគារប្រវត្តិសាស្ត្រ ស្ថានីយបុរេប្រវត្តិរមណីយដ្ឋានប្រវត្តិសាស្ត្រ ផ្ទះបុរាណ ទីទួលបុរាណ ដែលទាំងអស់នេះគឺជាផ្នែកមួយ នៃបេតិកភណ្ឌរូបីរបស់ជាតិនិងរបស់ខេត្ត។ ប្រាសាទបុរាណនៅមានរូបរាង និងគុណភាពពី៤០ ទៅ៥០% មានចំនួន៦កន្លែងស្មើនឹង៩ប្រាង្គប្រាសាទ ស្ថានីយបុរេប្រវត្តិសាស្ត្រមាន៣កន្លែង ប្រាសាទដែលបែកបាក់នៅសល់តែគ្រឹះមាន៧កន្លែង រមណីយដ្ឋានប្រវត្តិសាស្ត្រមាន៥កន្លែង ផ្ទះបុរាណ១០កន្លែង ព្រះវិហារបុរាណ៤កន្លែង ស្រះទឹកបុរាណ៥កន្លែង ទីទួលបុរាណ

៤៤កន្លែង វត្ថុបុរាណរក្សាទុកក្នុងសារមន្ទីរមាន៨៥មុខ ស្មើនឹង១០២ដុំ-ផ្ទាំង។ សិប្បកម្មចម្លាក់១៩កន្លែង (ចម្លាក់ស៊ីម៉ង់ត៍៥ ថ្ម២ និងឈើ១២កន្លែង) ឡដុតកុលាភាជន៍១២កន្លែង ស្មូនក្អម ផ្ទាំង និងធ្វើកុលាភាជន៍ជាលក្ខណៈគ្រួសារ១ ៩២៥គ្រួសារ តម្បាញកន្ទេល៣១៥គ្រួសារ ផលិតវត្ថុពីផ្តៅ ល្ពាក់ ឬស្សី ស្លឹកត្នោត១ ៧១៦គ្រួសារ និងតម្បាញក្រម៉ាមាន២កន្លែង។

## ៦- ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ចនិងប្រទានកម្ម

### ក្រសួងរៀបចំដែនដី គូបនីយកម្ម និងសំណង់

| បរិយាយ | ទំហំផ្ទៃដី បានបែងចែក | ចំនួនគ្រួសារ ទទួលដី | ចំនួនផ្ទះ បានសាងសង់ | ចំនួនបណ្ណ កម្មសិទ្ធិ |
|---|---|---|---|---|
| ២០១៨(១ឆ្នាំ) | ២ ២០១ហិកតា | ៨២៤ | ៥៣៧ | ២ ៤០២ |
| ២០១៩ (តុលា ២០១៨-កញ្ញា២០១៩) | ៦ ១១៦,៤២ហិកតា | ២ ៦៥៤ | ៥៣៧ | ២ ៤១២ |

លទ្ធផលសរុបនៃការបែងចែកដីគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ បានបែងចែកដីជូនគ្រួសារសរុបចំនួន៣ ៤៧៨គ្រួសារ មានផ្ទៃដីសរុបទំហំ ៨ ៣១៧,៤២ហ.ត. (ក្នុងនោះជូនអតីតកងកម្លាំងប្រដាប់អាវុធ គ្រួសារកងទ័ពនិងនគរបាលជាតិតាមបណ្តោយព្រំដែន គ្រួសារពលរដ្ឋក្រីក្រស៊ីវិលទូទៅនិងគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច) បានសាងសង់ផ្ទះសរុបចំនួន១ ០៧៤ខ្នង និងបានផ្តល់វិញ្ញាបនបត្រសម្គាល់អចលនវត្ថុចំនួន៤ ៨១៤បណ្ណ។

## ៧- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់

| បរិយាយ | ចំនួន គម្រោង | ផ្ទៃក្រឡា សំណង់(ម$^2$) | តម្លៃប៉ាន់ស្មាន (ដុល្លារអាម៉េរិក | ប្រៀបធៀបទុន វិនិយោគ(%) |
|---|---|---|---|---|
| ២០១៨(១ឆ្នាំ) | ៣ ២៩០ | ១២ ៣៧៨ ១១៩ | ៥ ៧៥៥ ០៧០ ១២០ | |
| ២០១៩ (តុលា ២០១៨-កញ្ញា ២០១៩) | ៤ ១៨២ | ១៤ ៥៨៧ ៣២៥ | ៧ ៤២៩ ០៤១ ៦៤៥ | កើនឡើង ២៩,០៩% |

លទ្ធផលសរុបគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ មានគម្រោងចំនួន៧ ៤៧២ ផ្ទៃក្រឡាសំណង់ចំនួន២៦ ៩៦៥ ៤៤៤ម$^2$ ដែលមានតម្លៃប៉ាន់ស្មានចំនួន១៣ ១៨៤ ១១១ ៧៦៥ដុល្លារអាម៉េរិក។

| បរិយាយ | សហគ្រាសក្រុមហ៊ុន | ចំនួន ក្រុមហ៊ុន | ប្រភេទ៣ | ប្រភេទ២ | ប្រភេទ១ | សរុបរួម |
|---|---|---|---|---|---|---|
| ២០១៨ (១ឆ្នាំ) | ក្រុមហ៊ុនសាងសង់ | ៣២១ | ២១៥ | ៤៦ | ៦០ | ៣៣៤ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៣ | ៩ | ៣ | ១ | |
| ២០១៩ (តុលា ២០១៨-កញ្ញា២០១៩) | ក្រុមហ៊ុនសាងសង់ | ៤៣២ | ២៨៦ | ៦៣ | ៨៣ | ៤៥៤ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ២២ | ១៤ | ៣ | ៥ | |

លទ្ធផលសរុបគិតចាប់ពីឆ្នាំ២០១៨ មកដល់ត្រឹមខែកញ្ញា ឆ្នាំ២០១៩ មានក្រុមហ៊ុនសាងសង់ចំនួន៣៣៤ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ចំនួន៤៥៤។

**៨- ទិន្នន័យអគារស្នាក់នៅរួមនិងបុរី**

| បរិយាយ | អគារស្នាក់នៅរួម | បុរីលំនៅឋាននិងលំនៅឋានមានលក្ខណៈបុរី |
|---|---|---|
| ២០១៨ (១ឆ្នាំ) | | |
| ២០១៩<br>(តុលា ២០១៨-កញ្ញា២០១៩) | ១៥២គម្រោង | ៤០គម្រោង(ស្មើនឹង១៦ ៥៨៩ខ្នង) |

**មុំទី៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**

**១- ក្រសួងបរិស្ថាន សម្រេចការងារដូចខាងក្រោម ៖**

- បានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង ប្រព័ន្ធលូ និងប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងក្របខ័ណ្ឌនៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ដល់រដ្ឋបាលក្រុង ស្រុកមួយចំនួន និងបានជួយអន្តរាគមន៍ដល់ក្រុងស្រុកមួយចំនួន ដែលប្រឈមនឹងកំណើនសំរាមសំណល់រឹងច្រើន តាមរយៈការផ្តល់ឡដុតសំរាមនៅតាមទីតាំងគោលដៅសំខាន់ៗ

- បានពង្រឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់តាមរយៈការអនុវត្តវិធានការច្បាប់ ចំពោះទីតាំងបង្កការបំពុលការគ្រប់គ្រង និងការសម្អាតសំណល់គ្រោះថ្នាក់ដែលបង្កដោយសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះ

- បានដំណើរការស្ថានីយតាមដានគុណភាពខ្យល់និងទឹក ព្រមទាំងធ្វើការតាមដានគុណភាពប្រភពទឹកសាធារណៈនៅរាជធានីភ្នំពេញនិងខេត្តគោលដៅហើយកំពុងជំរុញការបំពាក់ឧបករណ៍ស្វ័យត្រួតពិនិត្យនិងរាយការណ៍អំពីការបញ្ចេញនិងការបំភាយសារធាតុពុលទៅក្នុងបរិស្ថាន ទឹក ដី ខ្យល់ ចំពោះទីតាំងគម្រោងដែលអាចបង្កហានិភ័យបរិស្ថានខ្ពស់។

**២- ក្រសួងសាធារណការនិងដឹកជញ្ជូនសម្រេចការងារបានដូចខាងក្រោម៖**

**២.១- សហការជាមួយសាធារណរដ្ឋកូរ៉េអនុវត្ត៖**

- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់នៅក្រុងតាខ្មៅ ខេត្តកណ្តាល បច្ចុប្បន្នកំពុងសិក្សាគម្រោងលម្អិត សម្រេចបាន**៥៥%**

- គម្រោងកែលម្អស្ទឹងសៀមរាប ដំហានទី២(ការស្តារស្ទឹងសៀមរាបផ្នែកខាងក្រោមការទប់ច្រាំងនិងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ)បច្ចុប្បន្នកំពុងសិក្សាគម្រោងលម្អិត សម្រេចបាន៨០%។

**២.២- សហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អនុវត្ត៖**

- គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង(កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុង រួមមានក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងទីប្រជុំជនអ្នកលឿង)សម្រេចបាន**៧៤%**

- គម្រោងអភិវឌ្ឍន៍ក្រុងរបៀង២ ផ្តោតលើការអភិវឌ្ឍក្រុងតាមតំបន់ឆ្នេរ គឺក្រុងកំពត(សាងសង់ប្រព័ន្ធលូចម្រោះទឹក សំណល់ និងទីលានកប់សំរាម) និងក្រុងព្រះសីហនុ(សាងសង់ប្រព័ន្ធលូរំដោះទឹកភ្លៀងនិងទីលានកប់សំរាម)សម្រេចបាន**៤៥,៦០%**

- គម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាប រួមមានក្រុងកំពង់ឆ្នាំង(សាងសង់ទំនប់ការពារទឹកជំនន់និងទីលានកប់សំរាម) ក្រុងពោធិ៍សាត់(សាងសង់បណ្តាញលូនិងទីលានកប់សំរាម) សម្រេចបាន**២៥%**

- គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យតាមបណ្តាខេត្ត រួមមានសាងសង់បណ្តាញលូប្រមូលទឹកកខ្វក់ និងស្ថានីយប្រព្រឹត្តិកម្មនៅក្រុងបាត់ដំបង សាងសង់បណ្តាញលូប្រមូលទឹកកខ្វក់នៅក្រុងសៀមរាប ប្រព័ន្ធគ្រប់គ្រងអាងស្តុកទឹកកខ្វក់នៅក្រុងកំពង់ចាម ក្រុងព្រះសីហនុ និងសាងសង់កែលម្អស្ថានីយប្រព្រឹត្តិកម្មនៅក្រុងព្រះសីហនុ សម្រេចបាន**៣៥%**។

## សកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងកម្មវិធីសំខាន់ៗ ដូចតទៅ៖

១- ពិធីបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកដំបូង នីតិកាលទី៦ នៃរដ្ឋសភា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨។

២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២៧ ៤៤៤នាក់ នៅឃុំពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។

៣- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **នៃ ប៉េណា** អនុប្រធានទី១ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នៅភូមិគ្រឹះបុរីប៉េងហួត សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨។

៤- ពិធីអបអរសាទរទិវាគ្រូបង្រៀន ៥តុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨។

៦- ពិធីចូលជួបសម្តែងការគួរសមនិងផ្តល់អនុសាសន៍ដល់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា ២៩នាក់ មុននឹងទៅចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍និងជប៉ុន លើកទី៤៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨។

៧-ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ៦ ៧៨៥នាក់ នៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

៨- ពិធីបើកសន្និសីទអន្តរជាតិថ្នាក់តំបន់ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយនិងអន់គុណភាព នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២៣ ០០០នាក់ នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១០- ពិធីសំណេះសំណាលនិងផ្តល់ប្រាក់រង្វាន់ លើកទឹកចិត្តដល់សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៨ ទទួលបាននិទ្ទេសA មាន៤០៨នាក់(ស្រី ១៩៤នាក់) នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១- ពិធីចុះសួរសុខទុក្ខនិងសំណេះសំណាលជាមួយកុមារពិការភ្នែក គ ថ្លង់ នៅអង្គការគ្រួសារថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១២- ពិធីបិទមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ១៧ ៩១២នាក់ នៅឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១៤- ពិធីអបអរសាទរខួបលើកទី២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC) នៅសណ្ឋាគារសុខាអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨។

១៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ១៧ ៦២១នាក់ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

១៦- ពិធីបើកបុណ្យសមុទ្រឆ្នាំ២០១៨ លើកទី៧ ក្រោមប្រធានបទ "**ឆ្នេរស្អាត ពលរដ្ឋ រមណីយ**" នៅខេត្តកោះកុង កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨។

១៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីសេសានក្រោម២ មានអានុភាព៤០០មេហ្គាវ៉ាត់ នៅឃុំស្រែគ និងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។

១៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ៦០៦នាក់ នៅឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។

១៩- ពិធីសម្ពោធវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ និងខួបលើកទី២០ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨។

២០- ពិធីប្រគល់ពានរង្វាន់ដល់ជ័យលាភីកីឡាវាយកូនហ្គោល នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

២១- ពិធីអបអរសាទរបុណ្យចូលឆ្នាំសកលឆ្នាំ២០១៩ នៅវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

២២- ពិធីចូលជួបសម្តែងការគួរសមនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា**១០៥នាក់** នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៩។

២៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី**១៨ ២៧៣នាក់** នៅឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩។

២៤- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីលើកទី៣ ជាមួយអ្នកសារព័ត៌មានប្រមាណ**៤ ៥០០នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។

២៥- ពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣(ផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ១) ប្រវែង **៥០,៩៧ គ.ម.** ចំណាយថវិកាប្រមាណ**២៧៣លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅផ្លូវជាតិលេខ២ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

២៦- ពិធីប្រកាសជាផ្លូវការក្រុមប្រឹក្សាវប្បធម៌អាស៊ី នៅទីលានជល់ដំរី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីរាត្រីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។

២៧- ពិធីប្រារព្ធខួប២០ឆ្នាំ នៃថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ នៅបញ្ជាការដ្ឋានកងទ័ពជើងគោក សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

២៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី**១១ ៧៣៨នាក់** នៅឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

២៩- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៣០- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩។

៣១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី**១១ ២២៧នាក់** នៅឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

៣២- ពិធីអបអរសាទរទិវាទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ «**ទីក្រុងស្អាត ទីក្រុងផ្តល់ភាពកក់ក្តៅ**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

៣៣- ពិធីបើកកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់លើកទី១ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

៣៤- ពិធីបញ្ចុះបឋមសិលាសាងសង់មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ត្បូងឃ្មុំ ចំណាយថវិកាប្រមាណ**៥០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩។

៣៥- ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩។

៣៦- ពិធីបើកការដ្ឋានសាងសង់សំណង់ផ្សេងៗក្នុងគម្រោងការពារទឹកជំនន់និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញជំហានទី៤ ចំណាយថវិកាប្រមាណ**៣០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩។

៣៧- ពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៨ ក្រោមប្រធានបទ «**លើកកម្ពស់យេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩។

៣៨- ពិធីអបអរសាទរទិវាវប្បធម៌ជាតិ៣មីនា លើកទី២១ ក្រោមប្រធានបទ «**យុវជនដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩។

៣៩- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារការបរទេសឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩។

៤០- ពិធីសំណេះសំណាលនិងពិសាអាហារជាមួយអ្នកប្រកបមុខរបរជាក់ស៊ីក្លូ**៣២០នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩។

៤១-ពិធីសំណេះសំណាលសួរសុខទុក្ខជាមួយគ្រូ យុវនារី និងកុមារីរងគ្រោះនៅ«**មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទុំទាវ**» នៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩។

៤២- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**៣ ០៤៣នាក់** (ស្រី១ ៤១២នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

៤៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសុខាភិបាលឆ្នាំ២០១៨និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩។

៤៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី**១៣ ៨៦៦នាក់** នៅតំបន់សេដ្ឋកិច្ចពិសេស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩។

៤៥- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។

៤៦- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៥ ក្រោមប្រធានបទ «**ទន្លេផ្សារភ្ជាប់សន្តិភាព ប្រជាជន និងទេសចរណ៍**» នៅខេត្តកំពង់ឆ្នាំង កាលពីល្ងាចថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩។

៤៧- ពិធីប្រគល់វិញ្ញាបនបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ៧០៩អង្គ/នាក់**(ស្រី៦៧៦នាក់)នៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

៤៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី**១០ ៦៨៩នាក់** នៅឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

៤៩- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតដល់និស្សិត**១ ៥៧៨នាក់**(ស្រី៦៤០នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

៥០- ពិធីបើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ មានប្រវែង**១៩០.០១គ.ម.** តភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាប្រមាណ**២ ០០០លានដុល្លារអាម៉េរិក** ក្រោមរូបភាពសាងសង់ ធ្វើអាជីវកម្មផ្ទេរ (BOT) ដែលជាទុនវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មស្ពាននិងថ្នល់ចិន នៅឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

៥១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ២៤៥នាក់**(ស្រី៥៧២នាក់)នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

៥២- ពិធីបើកសន្និសីទចក្ខុវិស័យកម្ពុជាលើកទី១៣ ឆ្នាំ២០១៩ ក្រោមប្រធានបទ «**ការប្រែក្លាយផ្នែកឌីជីថល ឆ្ពោះទៅកាន់ឧស្សាហកម្មទី៤.០**» នៅសណ្ឋាគារហ្រ្គេត ឌូករាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

៥៣- ពិធីប្រគល់សញ្ញាបត្រដល់គរុនិស្សិតនិងគរុសិស្ស**១ ៩១៨នាក់**(ស្រី៧១៣នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៥៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៥៥- ពិធីអបអរសាទរខួប១០០ឆ្នាំ(១៩១៩-២០១៩) របស់អង្គការអន្តរជាតិខាងការងារ (ILO) និងខួប៥០ឆ្នាំ(១៩៦៩-២០១៩)នៃសមាជិកភាពរបស់កម្ពុជា នៅអង្គការអន្តរជាតិខាងការងារ ក្រោមប្រធានបទ «**បង្កើន យុត្តិធម៌សង្គម លើកកម្ពស់ការងារសមរម្យ**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

៥៦- វេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជន លើកទី១៨ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

៥៧- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **៣ ២១៣នាក់**(ស្រី២ ៧០៤នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។

៥៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពត ចំណាយថវិកាប្រមាណ **២៧លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅសង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩។

៥៩- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឡើងវិញស្ពានមិត្តភាពកម្ពុជា-ជប៉ុន (ស្ពានជ្រោយចង្វាទី១) ចំណាយថវិកាប្រមាណជាង**៣០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន កាលពីព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

៦០- ពិធីពិសាបាយសាមគ្គីឆ្នាំ២០១៩ ជាមួយកីឡាករ កីឡាការិនី គ្រូបង្វឹក**៤ ០៩៦នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩។

៦១- ពិធីសម្ពោធជាផ្លូវការសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ **«ព្រះស្រីញ្ញាសានវឌ្ឍនៃ»** នៅសង្កាត់វត្តភ្នំខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៦២- ពិធីពិសាបាយសាមគ្គីជាមួយសមាគមសម្ព័ន្ធខ្មែរ-ចិន**៥ ៥០០នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩។

៦៣- ពិធីចាក់បេតុងតភ្ជាប់ស្ពានមិត្តភាពកម្ពុជា-ថៃ(ស្ទឹងបត់-បានណងអៀង) ចំណាយថវិកាជាង**១៩លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា និងពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥ ចំណាយថវិកា **២៦,៤២លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីរាជរដ្ឋាភិបាលថៃ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

៦៤- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**២ ២៨៧នាក់** (ស្រី១ ១៩៤នាក់)នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

៦៥- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីជាមួយនិយោជិត កម្មករ កម្មការិនី**៣ ៧០០នាក់** ដើម្បីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ នៅឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៦៦- កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូ នៃក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិនៅកម្ពុជា**២០នាក់** នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩។

៦៧- ពិធីពិសាអាហារស្រាយបួសខែរ៉ៅម៉ាឌននៃសាសនាអ៊ិស្លាមកម្ពុជា**៤ ៧៥០នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩។

៦៨- ពិធីប្រារព្ធទិវាកាកបាទក្រហមពិភពលោក អឌ្ឍចន្ទក្រហម៨ឧសភា ឆ្នាំ២០១៩ លើកទី១៥៦ ក្រោមប្រធានបទ «**ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា**» នៅទីស្នាក់ការកណ្ដាលកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៩។

៦៩- វេទិកាធុរកិច្ចកម្ពុជា-នេប៉ាល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩។

៧០-ពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនាអ៊ិស្លាមកម្ពុជា**៧២៥នាក់** នៅវិហារបឹងកក់ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៩។

៧១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**៣ ១៦១នាក់**(ស្រី ១ ៤៨៥នាក់)នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩។

៧២- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**១ ៣៥៦នាក់**(ស្រី៨៧១នាក់)នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩។

៧៣- សន្និសីទកំពូលសារព័ត៌មានអាស៊ីឆ្នាំ២០១៩ លើកទី១៦ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩។

៧៤- ការចុះពិនិត្យការដ្ឋានផ្ទាល់ និងជួបសំណេះសំណាលសួរសុខទុក្ខជាមួយជនរងគ្រោះក្នុងឧបទ្ទវហេតុបាក់រលំអគារកម្ពស់៧ជាន់ នៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីរាត្រីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។

៧៥- ពិធីផ្ទេរការគ្រប់គ្រងសាលាកុមារពិការភ្នែកនិងកុមារគថ្លង់ នៃអង្គការគ្រួសារថ្មីឱ្យស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា និងការដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិអប់រំពិសេស នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៧៦- ពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី កីឡាករ កីឡាការិនី ក្នុងឱកាសចុះពិនិត្យការដ្ឋានសាងសង់**ពហុកីឡដ្ឋានជាតិមរតកតេជោ** ដែលបាននិងកំពុងសាងសង់ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩។

៧៧- ពិធីប្រគល់សញ្ញាបត្រវិទ្យាសាស្ត្រនគរបាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រដល់និស្សិតនាយនគរបាលបន្តវេននិងសិក្ខាកាមថ្នាក់វិញ្ញាបនបត្រសរុប**១ ៤៦៥នាក់**(ស្រី១០២នាក់) នៃបណ្ឌិត្យសភានគរបាលកម្ពុជា នៅបណ្ឌិត្យសភានគរបាលកម្ពុជា ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩។

៧៨- វេទិកាធុរកិច្ចកម្ពុជា ស្រីលង្កា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩។

៧៩- ពិធីបើកកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្ដល់យោបល់ប្រចាំឆមាសលើកទី២ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

៨០- ពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម(CLMTV) នៅសណ្ឋាគារអប្សរាផាលេសក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

៨១- ពិធីអបអរសាទរខួប៧០ឆ្នាំ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

៨២- ពិធីប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រដល់សិស្សថ្នាក់វិជ្ជាជីវៈគរុកោសល្យ និងនិស្សិតថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**១ ១៨៣នាក់**(ស្រី៦៣៥នាក់)នៃសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ និងប្រកាសផ្សព្វផ្សាយជាផ្លូវការសៀវភៅ **«ហ៊ុន សែន កម្ពុជា»** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩។

៨៣- ពិធីសំណេះសំណាលជាមួយបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **«និទ្ទេសA» ៤៤៣នាក់**(ស្រី២២៣នាក់) សម័យប្រឡងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។

៨៤- ពិធីចូលជួបសម្តែងការគួរសមនិងពិភាក្សាការងាររបស់គណៈប្រតិភូសហគ្រិនចិនដែលដឹកនាំដោយលោក **ហ៊ុន ខឺជូ** ប្រធានសហគ្រិនចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៨៥- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ(១០តុលា ១៩៧៩-១០ តុលា ២០១៩) នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៨៦- ពិធីចូលជួបសម្តែងការគួរសមរបស់ប្រតិភូយុវជនកម្ពុជា**២៩នាក់** នៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍និងជប៉ុនលើកទី៤៦ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៨៧- ពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរជាគ្រិស្តបរិស័ទ ដើម្បីសុខដុមនីយកម្មវិស័យគ្រិស្តសាសនានិងពិសាភោជនាហារ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩។

៨៨- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**៤ ០៣៨នាក់**(ស្រី១ ៣៤៤នាក់)នៃសាកលវិទ្យាល័យបៀលប្រាយ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

៨៩- ពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ក្រោមប្រធានបទ **«តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់»** នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩០- ពិធីផ្សព្វផ្សាយនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣»** នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស៊ីម៉ងត៍ របស់ក្រុមហ៊ុនថៃប៊ុនរ៉ុង ចំណាយថវិកាប្រមាណ**១១០លានដុល្លារអាម៉េរិក** នៅឃុំល្អាង ស្រុកដងទង់ ខេត្តកំពត កាលពីព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩២- ពិធីបើកការដ្ឋានស្ថាបនាផ្លូវចំនួន**៣៤ខ្សែ** ប្រវែង**៨៤,៥០គ.ម.**. នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាជាតិប្រមាណជិត**៣០០លានដុល្លារអាម៉េរិក** កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញារង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**១ ៩៥៨នាក់**(ស្រី៤៤៧នាក់) នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៤- ពិធីសំណេះសំណាលជាមួយអត្តពលិកនិងប្រតិភូកីឡាកម្ពុជា ដែលត្រូវទៅចូលរួមប្រកួតកីឡាស៊ីហ្គេម លើកទី៣០ នៅប្រទេសហ្វីលីពីន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៥- ពិធីបើកកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកលើកទី២ ក្រោមប្រធានបទ «**ការឆ្លើយតបចំពោះបញ្ហាប្រឈមគន្លឹះនាពេលបច្ចុប្បន្ន: សន្តិភាព ការបង្រួបបង្រួមជាតិ ការពឹងពាក់គ្នាទៅវិញទៅមក វិបុលភាពទៅវិញទៅមក និងគុណតម្លៃសកល**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៦- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេចរាជបុត្រីព្រះរាម**នរោត្តម បុប្ផាទេវី** ទេពនាជវឌ្ឍី ឯកឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នៅវត្តបទុមវតីរាជវរារាម សង្កាត់ចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៧- ពិធីសម្ពោធ «**អគារឥន្ទ្រទេវី**» របស់រាជបណ្ឌិត្យសភាកម្ពុជា និងអបអរសាទរខួប២០ឆ្នាំ នៃការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា នៅរាជបណ្ឌិត្យសភាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩៨- ពិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ានលើកទី១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩។

៩៩- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត**៦ ៧៦២នាក់**(ស្រី២ ៧៦១នាក់) នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩។

១០០- ពិធីសម្ពោធពិព័រណ៍ផលិតផលខ្មែរនិងទំនិញនាំចេញ នាំចូលកម្ពុជាលើកទី១៤ កម្រិតអន្តរជាតិ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩។

១០១- ពិធីប្រគល់សញ្ញាបត្រដល់និស្សិត២ ៥៨៨នាក់(ស្រី១ ៥២២នាក់)នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

១០៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត**២ ៨៣១នាក់**(ស្រី១ ៦១៤នាក់)នៃសាកលវិទ្យាល័យវេស្ទើន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

១០៤- ពិធីជួបសំណេះសំណាលជាមួយប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

១០៥- ពិធីបើកបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត កាលពីល្ងាចថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៩។

១០៦- ពិធីសម្ពោធផ្សារគំរូព្រំដែន ចំណាយថវិកាប្រមាណ**២លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលវៀតណាម នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩។

១០៧- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**២ ៧៩០នាក់**(ស្រី១ ៣៨០នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

១០៨- ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

១០៩- ពិធីបើកការប្រកួតវាយកូនគោល «**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវឌ្ឍនហ្គោលរីសត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

១១០- ពិធីបិទការប្រកួតវាយកូនគោល «**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវឌ្ឍនហ្គោលរីសត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីល្ងាចថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានទទួល៖**

១- សញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកទំនាក់ទំនងនយោបាយពីសាកលវិទ្យាល័យគ្រើកនៃព្រះរាជាណាចក្រថៃ ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។

២- គោរមងារជាសាស្ត្រាចារ្យកិត្តិយសផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យប៉េកាំង នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៣- ពានរង្វាន់ «**ភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចល្អ**» ពីសហព័ន្ធសន្តិភាពសកល (UPF) នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

ក្រៅពីនេះ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៖

**ក**- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តអង្គរជ័យ នៅឃុំអង្គររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩។

២- ពិធីប្រកួតកីឡាវាយកូនគោល «**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅទីលានហ្គ្រេនភ្នំពេញ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីជប់លៀងប្រកាសជ័យលាភីការប្រកួតកីឡាវាយកូនគោល «**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៤- ពិធីបញ្ចុះខណ្ឌសីមានិងសម្ពោធសមិទ្ធផលនានា ក្នុងវត្តនទីជោត្តនារាម (ហៅវត្តខ្សោកជើង) នៅឃុំពពឹស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩។

៥- ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩។

៦-ពិធីអបអរសាទរទិវាគ្រូបង្រៀន ក្រោមប្រធានបទ «**គុណភាពគ្រូជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល**» នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩។

៧- ពិធីបើកវេទិកាជាតិអេកូទេសចរណ៍លើកទី១ នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- ពិធីបើកសន្និបាតបូកសរុបការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ព្រមទាំងទិវាជនមានពិការភាពកម្ពុជាលើកទី២១ និងអន្តរជាតិលើកទី៣៧ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩។

៩- ពិធីប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩។

**ខ**- សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៩៥៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

២- ពិធីហោះហើរបង្ហាញឧទ្ធម្ភាគចក្រ នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

៣- ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានគម្រោងឈូងសមុទ្រតារា នៅតំបន់អភិវឌ្ឍន៍តារាសាគរ ស្រុកគិរីសាគរ ខេត្តកោះកុង កាលពីល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មលេខ៩៦៣ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់ ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

៥- ពិធីខួប៤២ឆ្នាំ **«ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០-៦-១៩៧៧/២០-៦-២០១៩»** នៅសាលាបឋមសិក្សា **ម៉ុន រ៉ានី ហ៊ុន សែន** កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។

៦- ពិធីបើកជាផ្លូវការកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៤ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសណ្ឋាគារសុខាសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

៧- ពិធីអបអរសាទរខួបអនុស្សាវរីយ៍២៥ឆ្នាំ ថ្ងៃបង្កើតកងពលតូចលេខ៧០(១៥ តុលា ១៩៩៤-១៥ តុលា ២០១៩) នៅបញ្ជាការដ្ឋានកងពលតូចលេខ៧០ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

៨- ពិធីសម្ពោធអគារបឋមសិក្សា១ខ្នង អគារអនុវិទ្យាល័យ១ខ្នង និងទីចាត់ការ១ខ្នង ក្នុងអនុវិទ្យាល័យស្ពានត្នោត នៅឃុំត្នោត ស្រុកជីក្រែង ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

៩- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៥៩៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ប្រារព្ធនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

**គ**- ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកមហាសន្និបាតលើកទី៣៩ របស់សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩។

**ឃ**- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងជនមានពិការភាពអន្តរជាតិលើកទី៣៦ ឆ្នាំ២០១៨ ក្រោមប្រធានបទ **"លើកកម្ពស់សិទ្ធិជនមានពិការភាពធានាដល់ការធ្វើបរិយាបន្ន និងសមភាព"** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨។

២-ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៧ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨។

៣- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

៤- ពិធីសម្ពោធសមិទ្ធផលនានានិងកាត់ឫសសីមាព្រះវិហារវត្តអង្គនិស្សយ័ នៅសង្កាត់ឪឡោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៥- ពិធីវប្បធម៌និងទេសចរណ៍កម្ពុជា-ចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩។

៦- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

**ខ**- លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានទូទាំងប្រទេសលើកទី២៨ ឆ្នាំ២០១៩ នៅវិហារជំគីឡូម៉ែត្រលេខ៩ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ទិវាជាតិអំណានឆ្នាំ២០១៩ ក្រោមប្រធានបទ «**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

៣- ពិធីបិទមហោស្រពសិល្បៈចម្រៀងខ្មែរជាសកលលើកទី៥ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីចូលជួបសម្តែងការគួរសមរបស់លោក **រ៉ូសែល អឹម ណិលសុន** (Russel M. Nelson) ប្រធានសាសនាចក្រនៃព្រះយេស៊ូគ្រិស្តនៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កាលពីល្ងាចថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីសំណេះសំណាលជាមួយតំណាងអាចារ្យ អាចារិនី មកពីទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីប្រគេននិងប្រគល់សញ្ញាបត្រដល់សមណនិស្សិតនិងនិស្សិត**១ ១០៦អង្គ/នាក់** នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩។

**ច**- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះបឋមសិលាសាងសង់អគារមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ ចំណាយថវិកា **៥៥០លានយ័ន** ស្មើនឹងប្រមាណ **៨០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅក្នុងបរិវេណមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

២- ទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨ ក្រោមប្រធានបទ "**យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥**" នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨។

៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍន៍ជនបទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

៤- ប្រារព្ធទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៩ នៅអាងទឹកបឹងស្នោ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៥- ពិធីបិទបញ្ចប់គម្រោងការលុបបំបាត់ភាពពិការភ្នែកដោយសារជំងឺភ្នែកឡើងបាយ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

**ឆ**- ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីប្រារព្ធខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩។

២- ពិធីប្រារព្ធខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩។

៣- ប្រារព្ធទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៩ លើកទី២៦ ក្រោមប្រធានបទ **«ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍»** នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩។

**ជ**- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសាធារណការនិងដឹកជញ្ជូន ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

២- ពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ ជាមួយនិយោជិត កម្មករ កម្មការិនីនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីបើកកិច្ចប្រជុំលើកទី១៥ រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធឆ្នាំ២០១៩ នៅសណ្ឋាគារសូហ្វីតែល អង្គរភូគីត្រា ហ្គោហ្វ និងស្ប៉ារីហ្សត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីសម្ពោធរោងចក្រផលិតផល មីជាតិ នៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីចូលជួបសម្តែងការគួរសមរបស់គណៈប្រតិភូនៃសហព័ន្ធពាណិជ្ជករចិនទាជីវសកល និងថ្នាក់ដឹកនាំសមាគមសម្ព័ន្ធខ្មែរ ចិន នៅកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងពាណិជ្ជកម្ម នៅទីស្តីការក្រសួងពាណិជ្ជកម្ម កាលពីល្ងាចថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

**ឈ**- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តរតនមុនីតាប៉ាវ(ហៅវត្តពងទឹក) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩។

២- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តគិរីគង្គា(ហៅវត្តប្រផាត់) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩។

៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តបន្ទាយជ័យមង្គល នៅឃុំកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសារពេជ្រពណ្ណរាយ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៥- ពិធីស្រោចសុគន្ធវារីព្រះចៅអធិការវត្តនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពាមមង្គល នៅឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៦- ពិធីសម្ពោធអគារសិក្សា១ខ្នង មាន៣ជាន់ ១៥បន្ទប់ និងឆ្លងសមិទ្ធផលនានាក្នុងសាលាបឋមសិក្សាភាសាខ្មែរ ចិន សេង ម៉េង នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៧- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តច័ន្ទរង្សី(ហៅវត្តព្រះអង្គ) នៅឃុំរកាពប្រាំស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៨- ពិធីសម្ពោធឆ្លងកុដិថ្មនិងសមិទ្ធផលនានាក្នុងវត្តព្រះពុទ្ធមហាសាស្ត្រារាម នៅឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីល្ងាចថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៩- ពិធីសម្ពោធឆ្លងឧបដ្ឋានសាលានិងសមិទ្ធផលនានាក្នុងវត្តពោធិសាល(ហៅវត្តអំពិល) នៅឃុំប៉ឺស២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

១០- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តគិរីវណ្ណារាម នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

១១- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តជ័យមុនី នៅឃុំទួលសូ្ល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

១២- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តបទុមរង្សី នៅឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

១៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពោធិគយា(ហៅវត្តវិហារខ្ពស់) នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩។